គ្រួមជំនួនទៀមទាងម្លាប់
COMMISSION DES MŒURS & COUTUMES

# ពាក្យសុទិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៦ ខែកក្កដា លេខ ៧
ព.ស. ២៤៨៧ – គ.ស. ១៩៤៤

LIBRARY
BUDDHIST INSTITUTE



# កាកល្យសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បណ្ឌិតរឿង | ទំព័រ |
|---|---|---|
| — មត្តញ្ញុតាកថា .... ..... | ព្រះមហា ដា- ឆាយ ..... | ៤៨៣ |
| — បញ្ញាសជាតកភាគទី ២ (តមក) . ... | បណ្ឌិតមហា ឈឹម- ស៊ុម .... | ៤៩៧ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — រឿងសៅរ៍សោយ (តមក) ..... .. | ព្រះមហាឧត្តមវិជ្ជា ប៊ុង- ប៉ម .. | ៥១២ |
| — រឿងសាមកុក (តមក) ..... | ឧកញ៉ា នូ- កន ..... | ៥១៨ |
| — ទាលៈនឹងទមយន្តី (តមក) ..... | អ្នកស្រី ស្រ៊ុន - សារិយ៉ាន់ .... | ៥២៤ |
| — ដំណើរអស្ចារ្យនៃលោក ភ័ស្ចូប៊ីយូយេ (ត- ចប់) ..... | លោកវ៉ាយ - ប៊ុក ក្រុមការ .... | ៥៣១ |
| — ដំណឹងតាមខ្សែក្នុងកន្ត្រាះ (តមក) .... | លោកផេង - ជ្រើរ ..... | ៥៤៤ |
| **កំណត់ទីផ្សេងៗ** | | |
| — ពិធីបុណ្យព្រហ្មទាន ..... | ពុទ្ធសាសនបណ្ឌិត្យ ..... | ៥៤៨ |


មួយឆ្នាំមាន ៤២ សៀវភៅ — ដំឡៃដាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*


PARTIE RELIGIEUSE: Page

— Mattannutakatha . . . . . *Brah maha CHEA-CHHAY* . . . 483

— Pannasajataka vol-II (suite) . *M. CHHIM-SOUM* . . . . . 497

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne (suite) . . . . . *Brah Maha PEUNG-PAM* . . . 512

— Histoire de Samkok (suite) . . *Oknha NOU-KAN* . . . . . 518

— Nala et Damayanti (suite) . . *Mme SRIN-SARIS-YANN* . . . 524

— Le voyage extraordinaire de Vasio bioyé (suite et fin) . . *M. RAY-BUC* . . . . . 531

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . . . 544

NOTES ET CHRONIQUES:

— Distribution des prix à l'Ecole Supérieure de Pali . . . . . *INSTITUT-BOUDDHIQUE* . . . 548


Prix d'abonnement annuel (comprenant 12 numéros) 200$00

# មង្គលត្ថកថា

## ព្រះមហា ជា-ធាយ វត្តខ្ចាស់ណ្ហាលោម

រៀបរៀង

---

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្សការ ចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធ ព្រះអង្គនោះ (ត្រមាំង ព្រះធម៌នឹង ព្រះអរិយសង្ឃ ដោយសេចក្តីគោរព) ។*

*ថ្ងៃនេះជាថ្ងៃឧបោសថកាល, ពួកពុទ្ធបរិស័ទខ្លះបានសមាទានឧបោសថសីលតាំងពីបុព្វណ្ហសម័យ ។ ពេលនេះជាធម្មស្សវនកាលត្រូវតាមសណ្តាប់ប្រពៃណីពីបុពណ្ណសម័យ នៃពុទ្ធមាមកជនរៀងពីមុនមក ។ អាត្មាភាពបានទទួលការៈមកសំដែងព្រះធម៌តាមសមគួរដល់កាលវេលា ។ សូមសំដែងអំពីមង្គលត្ថកថា តាមន័យពុទ្ធភាសិតមួយបាទថា :*

### មង្គលា សទា សាធុ

*" ការៈនៃបុគ្គលអ្នកស្គាល់ប្រមាណ រមែងញ៉ាំងប្រយោជន៍ឲ្យសម្រេចសព្វៗ កាល " ។*

*ពុទ្ធភាសិតនេះ ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សរសើរបុគ្គលអ្នកស្គាល់ប្រមាណ ថាជាអ្នកអាចធ្វើប្រយោជន៍ឲ្យសម្រេចបានគ្រប់កាល ។*

សូមអធិប្បាយសេចក្តីនៃពុទ្ធភាសិតនេះដូចសេចក្តីតទៅនេះ :

មគ្គញ្ញូតា ប្រែថា "ភាពនៃបុគ្គលអ្នកស្គាល់នូវប្រមាណ" គឺស្គាល់ថា ធ្វើយ៉ាងនេះសម, យ៉ាងនេះល្អ, យ៉ាងនេះចុះរុបៀប, ត្រូវទំនងសមតាមកាលៈទេសៈ, កាលបើធ្វើយ៉ាងនេះទៅ រមែងបានសម្រេចប្រយោជន៍យ៉ាងនោះ ជាដើម ។ ការស្គាល់ប្រមាណនេះ មានទំនងគួរនឹងពណ៌នាបានច្រើនន័យ តែបើនឹងរួបរួមជាគោលនៃសេចក្តីអធិប្បាយ មានតែ ៥ ប្រការ ដូច្នេះ គឺ :

១ - ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

២ - ការដឹងប្រមាណក្នុងការងើយកិច្ច

៣ - ការដឹងប្រមាណក្នុងការប្រែតាំងខ្លួន

៤ - ការដឹងប្រមាណក្នុងបុគ្គល

៥ - ការដឹងប្រមាណក្នុងធម៌ ។

## ទី ១ - ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ

ការដឹងប្រមាណក្នុងទ្រព្យសម្បត្តិនេះ ចែកចេញជា ៣ ប្រការតទៅទៀត គឺស្គាល់ប្រមាណក្នុងការស្វែងរក ១ ស្គាល់ប្រមាណក្នុងការថែរក្សា ១ ស្គាល់ប្រមាណក្នុងការបរិភោគប្រើប្រាស់ ១ ។

ការចេះលៃលកវកវាយស្វែងរកទ្រព្យសម្បត្តិ ឲ្យត្រឹមត្រូវតាមគន្ធង់ធម៌ គឺវៀរចាកដំនួញ ៥ ប្រការ, មិនស្វែងរកដោយអាការកុហក

ការគួតធ្វោកបំបាត់ប្រវ័ញ្ចន៍ទ្រព្យរបស់អ្នកដទៃ មិនរំពៃគុយគន់សំឡឹង
សំឡក់លួចឆ្កត់បែជាន់ដណ្តើមយកគោគ្រឿងអ្នកដទៃ ដោយកិច្ចកល
ចោរកម្ម, មិនបន្ទំដោយកែកជញ្ជីង តែកៀសដោយរង្វាល់ នាឡិ
តៅ កន្ទាំង បំបិទបំបាំងតែលៃលកឲ្យតែវាងចំណេញ ដោយទុច្ចរិត
កលទុច្ចរិត ។ ទាំងត្រូវរៀបចាកស្ថាន ៤ យ៉ាងទៀត គឺរៀបមិនលំអៀង
ព្រោះសេចក្តីគាប់ចិត្ត សេចក្តីស្រឡាញ់ ១ មិនលំអៀងព្រោះសេចក្តី
ខ្លាចឆ្ងំ ឬសេចក្តីស្អប់ ១ មិនលំអៀងព្រោះសេចក្តីល្ងង់ខ្លៅ មិនដឹង
ទុសត្រូវ ១ មិនលំអៀងព្រោះទ្វាចអំណាច ១ ហើយមិនប្រព្រឹត្តស៊ី
សំណូកសូកអង្វរសង្កត់សង្កិនយកផលប្រយោជន៍ឡើយ ព្រោះសុទ្ធ
តែជាការស្វែងរកមិនសម មិនល្អ មិនត្រូវទំនងទេ ជាការស្វែងរក
ទុសចាកគន្ធងធម៌ដោយពិតប្រាកដ ។ ការស្វែងរកដោយទុច្ចរិត
ព្រះពុទ្ធជាម្ចាស់ទ្រង់ហាម ព្រោះជាហេតុនាំឲ្យមានសេចក្តីក្តៅក្រហាយ
ទាំងនាំឲ្យជួបប្រទះនឹងទុក្ខទោសគ្រោះថ្នាក់ច្រើនប្រការផង ឈ្មោះថា
ស្វែងរកសេចក្តីទុក្ខមកឲ្យខ្លួននឹងអ្នកដទៃ នាំឲ្យមានសេចក្តីវិនាសក្ខីន
លោកទាំងពីរ ។ ហេតុនេះ សាធុជនគួរតែគេចវៀរចៀសវាងឲ្យផុត
អំពីការស្វែងរកមិនប្រកបដោយធម៌ ហើយស្វែងរកដោយទុច្ចរិតប្រកប
ដោយធម៌វិញ ទើបជាហេតុនាំឲ្យត្រជាក់ចិត្តខ្លួននឹងអ្នកដទៃ, ទ្រព្យ
សម្បត្តិដែលរកបានមកដោយសុចរិត ជាសម្បត្តិនិត្យនៅចំរុងចំរើនឡើង

តាមលំដាប់ ។ កាលបើស្វែងរកទ្រព្យសម្បត្តិ បានមកដោយយុត្តិធម៌ត្រឹមត្រូវហើយ គួរស្គាល់ប្រមាណក្នុងការថែរក្សាទ្រព្យនោះថែមទៀត គឺត្រូវចេះរក្សាកុំឲ្យខូចអន្តរាយ ដោយភ័យផ្សេងៗ គឺភជភ័យ, ចោរភ័យ, អគ្គិភ័យ, ទុកភ័យ, ឧដ្ឋានភ័យ, ទឹងអកប្អមមិត្តភក្តិជាមួយគ្នា ដោយបានគិតប្រុងជានិច្ចថា "អាត្មាអញគិតធ្វើដូចម្តេចហ្ន៎ ដើម្បីកុំឲ្យពួកការរបស់ជាន់យកទ្រព្យសម្បត្តិ កុំឲ្យពួកការលក់ពិន័យទោសបាន, កុំឲ្យចោរលួចប្លន់ កុំឲ្យមានអាសន្នដោយភ្លើងឆេះ, កុំឲ្យទឹកលិច, កុំឲ្យមនុស្សអកប្អមមិត្តភក្តិជាមួយដែលមិនគាប់ចិត្តនឹងគ្នាដណ្តើមយកទៅបាន" ។ ព្រោះថាទ្រព្យសម្បត្តិដែលរកបានមកហើយ បើបណ្តែតបណ្តោយធ្វេសប្រហែសនឹងវិនាសបាត់ទៅវិញ ដោយភ័យផ្សេងៗ មានពួកភ័យជាដើមនោះនាំឲ្យបង់កំឡាំងខូចខាតពេលវេលាដែលចំរកចំធ្វើមក ប្លុនកាលនាំឲ្យបង់ខាតទ្រព្យធនជាខ្លួនដើម ដោយតាមរកបរបស់ដែលបាត់ទៅនោះ ខ្វេកាគខ្លើនទៀតក៏សឹងមាន ។ ហេតុនេះ បុគ្គលជាម្ចាស់ទ្រព្យគួរតែប្រយ័ត្នក្នុងការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិឲ្យម៉ឺងម៉ាត់ ទើបចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការថែរក្សា ។ ដើម្បីនឹងថែរក្សាទ្រព្យសម្បត្តិឲ្យបានបីតថេរចិរកាលទៅនោះ ត្រូវដឹងវិធីរក្សាដូចតទៅនេះ :

១ - ចេះស្វែងរករបស់ដែលបាត់

២ - . ចេះដួសជុលរបស់ដែលចាស់គ្រាំគ្រា

៣ - ចេះប្រើប្រាស់ឲ្យល្អមដល់ប្រមាណ

៤ - មិនតាំងបុរស ឬស្ត្រីខ្ទុស្តសីលជាធំ ។

មែនពិត, ធម្មតាទ្រព្យសម្បត្តិដែលគង់នៅ ឬនឹងចំរើនតទៅទៀតបាននោះ ក៏ពីព្រោះតែអ្នកម្ចាស់ទ្រព្យចេះថែរក្សា ចេះចាយចេះប្រើប្រាស់ ។

បុគ្គលដែលស្គាល់ប្រមាណក្នុងការប្រើប្រាស់ ចាយវាយទ្រព្យសម្បត្តិតាមកម្លាំងធនធានរបស់ខ្លួន ដឹងអស់ដឹងគង់ដឹងបង់ដឹងបាត់, មិនចាយខ្ជះខ្ជាយគោរគាវឥតសណ្តាប់ធ្នាប់ មិនបណ្តោយឲ្យសម្បត្តិទ្រព្យវិនាសអន្តរាយដោយល្បែងពាលា ល្បែងស្រី ល្បែងស្រា កញ្ឆា អាកេរ្ត ឬញៀនញ៉ាំមជ្ឈប់ចិត្តនឹងល្បែងក្តាល់ផ្សេងៗ មានបៀ ប៉ោកឆ្នូ អាប៉ោងជាដើម ទើបចាត់ថាជាអ្នកស្គាល់ប្រមាណក្នុងការប្រើប្រាស់ចាយវាយ ។ ម្យ៉ាងទៀត ត្រូវចេះទុកជាក់ទ្រព្យរបស់ឲ្យមានរបៀបរៀបរយល្អ កុំចោលរាត់រាយ ដូចអ្នកខ្វះមានផ្ទះធំទូលាយល្អពេក តែមិនចេះរៀបចំទុកជាក់ឲ្យល្អស្អាតបាត ចេះតែគ្រាត់គ្រែវែកាយប៉ាយពេញតែផ្ទះសម្បែងម្ល៉ោះហើយទៅជាចង្អៀតចង្អល់ស្អុកស្កះ មិនល្អមើលទៅវិញ ។ ត្រូវចេះថ្នមរបស់ឲ្យល្អ គឺត្រូវដឹងថា របស់នេះតូច, ធំ, ក្រាស់, ស្តើង, ជាប់, ផុយ, តិច, ច្រើនជាដើម ហើយប្រើយ៉ាងណាឲ្យតែខាងបានល្អសមរម មិនធ្ងន់ធ្ងឹងកែកអកផង ត្រូវចេះលៃលកកេរចាយជួសជុល

កែកុនប៉ះប៉ុន ទ្រព្យរបស់ដែលបាក់បែក ឬច្រឡាក់ច្រឡូស ចេះជួសជុល ជុសខាត់សំអាតឲ្យល្អជាច្រើនគឺ, យ៉ាងនេះទើបចាត់ថាជាអ្នកស្គាល់ ប្រមាណក្នុងការប្រើប្រាស់ ។

ន័យមួយទៀត បុគ្គលអ្នកដឹងប្រមាណក្នុងទ្រព្យសម្បត្តិគឺដែលស្វែងរក ថែរក្សា ប្រើប្រាស់ទ្រព្យសម្បត្តិឲ្យត្រឹមត្រូវតាមធម្មដូចពាណិនាមកនេះ ឈ្មោះថាជាអ្នកញ៉ាំងប្រយោជន៍ឲ្យសម្រេចបានគ្រប់កាល ឈ្មោះថាជាអ្នកមានសេចក្តីសុខច្រើនប្រការណាស់ ព្រោះទ្រព្យសម្បត្តិនោះអាចញ៉ាំងបុគ្គលជាម្ចាស់ទ្រព្យឲ្យសម្រេចប្រយោជន៍ដូចតទៅនេះ

១ - អ្នកមានទ្រព្យសម្បត្តិ តែងបិញ្ចឹមខ្លួន និងក្រុមគ្រួសារគឺ មាតាបិតា បុត្រធីតា ទាសកម្មករ ឲ្យជាសុខទៅបាន ។

២ - អ្នកមានទ្រព្យសម្បត្តិ អាចចងមិត្រមេត្រីនឹងអ្នកក្បែរខាងបានតាមត្រូវការ ។

៣ - អ្នកមានទ្រព្យសម្បត្តិ អាចបំបាត់ភ័យអន្តរាយនៃទ្រព្យដែលកើតអំពីហេតុផ្សេងៗបាន ។

៤ - អ្នកមានទ្រព្យសម្បត្តិ អាចធ្វើនូវពលិកម្ម ៥ ប្រការគឺ:

ក) ញាតិពលិ ការសង្គ្រោះញាតិ

ខ) អតិថិពលិ ការទទួលភ្ញៀវ

គ) បុព្វបេតពលិ ការធ្វើបុណ្យទុទ្ទិសផលដូនដល់ប្រពៃបុរសដែលចែកឋានចាត់ទៅហើយ

ឃ) រាជពលិ ការបង់ពន្ធដារសួយសារអាករជាប្រយោជន៍ផែនដី

ង) ទេវពលិ ការធ្វើបុណ្យទុទ្ទិសផលថ្វាយទេវតា ។

๙ - អ្នកមានទ្រព្យសម្បត្តិ អាចបរិច្ចាគទ្រព្យរបស់ខ្លួន ឲ្យជាទានដល់សមណព្រាហ្មណ៍អ្នកប្រតិបត្តត្រឹមត្រូវបានតាមប្រាថ្នា ឬក៏អាចកសាងសាលាទានជាសាធារណៈ ឬកុដិ វិហារ សាលា ជាសង្ឃទានប្រគេនសង្ឃ អ្នកប្រកបកិច្ចក្នុងព្រះពុទ្ធសាសនា ឬសាងសាលារៀនមន្ទីរពេទ្យ ទំនុកបំរុងការរៀនសូត្រ, ទំនុកបំរុងខាងការព្យាបាលរោគបានដោយសេរីនឹងសេចក្តីត្រូវការ ។

រួមការដឹងប្រមាណដូចបានអធិប្បាយមកនេះ ឈ្មោះថាការដឹងប្រមាណក្នុងទ្រព្យសម្បត្តិ ។

## ទី ๒ - ការដឹងប្រមាណក្នុងការណីយកិច្ច

កិច្ចការដែលយើងត្រូវធ្វើ ហៅថា ករណីយកិច្ច, ធម្មតាកិច្ចការក្នុងលោកមានអស់ សុទ្ធសឹងតែមានសភាពប្លែកៗពីគ្នា គឺកិច្ចការខ្លះត្រូវធ្វើ, កិច្ចការខ្លះដាយស្រួល ស្រណុកធ្វើ, កិច្ចការខ្លះត្រូវ

ខ្លះតិច, ខ្លះធ្ងើយូរ ខ្លះធ្ងើធាប់; តែបើរួមឲ្យខ្លឹមក្នុងមានតែត្រឹម ២ យ៉ាងគឺ កិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា ១ កិច្ចការដែលត្រូវធ្វើដោយកម្លាំង ១ ។ ការសិក្សារៀនសូត្រនូវចំណេះវិជ្ជា អក្សរសាស្ត្រ ចតុព្ពិធលេខ ១ បរមត្ថ-វិជ្ជា ធម៌វិន័យតែសិក្ខា ជាដើម ហៅថាកិច្ចការដែលត្រូវធ្វើដោយប្រាជ្ញា ព្រោះជាកិច្ចដែលយើងត្រូវប្រើគំនិតរិះពិចារណា ឲ្យយល់ច្បាស់ចិត្តពិតប្រាកដទើបធ្វើទៅបាន ។ កិច្ចការហត្ថកម្មសម្រាប់អ្នកស្រែចំការ ជាងឈើ ជាងកំបោរ ឬការដែលត្រូវលើកលីពុនជញ្ជូនវែកសែងជាដើម ឈ្មោះថាកិច្ចការត្រូវធ្វើដោយកម្លាំង ។

ការដឹងប្រមាណ គឺស្គាល់ថា កិច្ចការនេះត្រូវធ្វើយ៉ាងនោះ, កិច្ចការនោះ ត្រូវធ្វើយ៉ាងនេះ, កិច្ចនេះគួរធ្វើ កិច្ចនោះមិនគួរធ្វើ, អំពើនេះធ្វើទៅនាំឲ្យចំរើន, អំពើនោះធ្វើទៅនាំឲ្យវិនាសហិនហោច ប្រយោជន៍ខ្លួននឹងអ្នកដទៃ; យ៉ាងនេះជាដើម ហៅថាស្គាល់ប្រមាណក្នុងកិច្ចការ ។ មែនពិត, កិច្ចការណាក៏ដោយ ដែលជាកិច្ចត្រូវធ្វើនោះ បុគ្គលត្រូវតែពិចារណាឲ្យជាក់ច្បាស់ចូលចិត្តសិប់សិន សឹមធ្វើទើបប្រសើរ ព្រោះថាកិច្ចការដែលបុគ្គលធ្វើដ្បិតដ្បួសហួសទៅហើយ ហើយកាយក៏ចាចិត្ត រមែងជិតជាប់ស្ងួតនោះប្រាកដ មិនងាយនឹងកែប្រែបានឡើយ ប្រៀបដូចជាធ្នាំងដីដែលបែកហើយមិនដែលផ្សារភ្ជាប់វិញបានទេ បើទុកជាផ្សារបាន ក៏មិនជាប់មាំល្អដូចដើម ។ កិច្ចការណាដែល

បុគ្គលធ្វើទៅហើយ ត្មៅក្រហាយតាមក្រោយ នាំឲ្យខូចខាតប្រយោជន៍ខ្លួននឹងអ្នកឯទៀត នាំឲ្យចង្អៀតចង្អល់ដល់ចិត្តគំនិតអធ្យាស្រ័យអ្នកដទៃ បុគ្គលមិនគប្បីធ្វើកិច្ចការនោះឡើយ, សមដូចជាពុទ្ធភាសិតថា អ្នកពិទ្ធក្តៅ សេយ្យោ "អំពើអាក្រក់ បុគ្គលកុំធ្វើ ល្អជាង" ។ បុគ្គលអ្នកធ្វើអំពើអាក្រក់មិនងាយបានសេចក្តីសុខកាយសប្បាយចិត្តទេ ។ បុគ្គលអ្នកស្គាល់ប្រមាណក្នុងកិច្ចការ ដែលខ្លួនត្រូវធ្វើដូចពណ៌នាមកនេះ ហៅថា ជាន់ប្រមាណក្នុងតណ្ហាយកិច្ច ។

## ទី ៣.— ការជាំងប្រមាណក្នុងការបែរក្បាខ្លួន

ខ្លួនជាទីស្រឡាញ់ពេញចិត្តរបស់ជនគ្រប់គ្នាតាំងអស់ បានជាជនតាំងនោះខំថ្នាក់ថ្នមថែទាំរក្សាខ្លួន ឲ្យបានសេចក្តីសុខដោយទៅបាយផ្សេងៗគ្នា, អ្នកខ្លះកំចេះរក្សាខ្លួនឲ្យបានសុខកាពគ្រាន់បើ, អ្នកខ្លះក៏តឡប់ជាផ្ទុយនឹងបំណងដើមទៅវិញ ។ ព្រះពុទ្ធជាបរមគ្រូដ៏ឆ្លាស់ប្រដៅឲ្យថែរក្សាខ្លួនដោយវិធីសំអាតកូមិភាគ គេហដ្ឋាន សំអាតគ្រឿងប្រើប្រាស់ សំអាតគ្រឿងស្លៀកពាក់ សំអាតគ្រឿងធឹកនឹងកោជន៍ភ័ស្តុចំណីអាហារ សំអាតសរីរាវយវៈរាងកាយឲ្យស្អាតល្អ ព្រោះថាកាលបើទីលំនៅជាដើមមិនស្អាតល្អហើយ ជាហេតុនាំឲ្យរូបកាយរបស់យើងដែលអាស្រ័យនូវគ្រឿងមិនស្អាតមានពេគផ្សេងៗ, កាលបើរូប

ពាធកាយមានរោគហើយ ចំត្តដែលអាស្រ័យនៅក្នុងរូបកាយ ធ្វើម្តេចនឹងប្រព្រឹត្តទៅដោយស្រួលបាន? កាលបើចិត្តមិនស្រួលហើយ គំនិតជ្រាជ្ញាធ្វើម្តេចនឹងដុះដាលចំរើនឡើងបាន? កាលបើគំនិតជ្រាជ្ញាមិនចំរើនលូតលាស់ភ្លឺស្វាងហើយ ប្រយោជន៍ដែលយើងត្រូវការចង់បានក្នុងបច្ចុប្បន្ននេះ នឹងលោកខាងមុខ ធ្វើម្តេចនឹងសម្រេចតាមជ្រាជ្ញាទៅបាន? ហេតុនេះគួរយល់ថា បណ្តារោគទាំងអស់សុទ្ធតែជាសត្រូវជាបច្ចាមិត្តជាអ្នកបំផ្លាញនូវប្រយោជន៍នៃអស់យើងពាល់គ្នា ព្រោះសេចក្តីពិតថា អ្នកណាមួយ ទោះជាអ្នកមានទ្រព្យសម្បត្តិសក្តិសព្តិក្តី ជាអ្នកជ្រាជ្ញក្តី ជានាម៉ឺន ឫពស្តុប្រជាក្តី កាលបើត្រូវរោគចូលមកលុកលុយដុះដាន់ក្នុងរូបកាយហើយក៏ត្រឡប់ជាមានអានុភាពតិច ប្រើការមិនកើតទាំងអស់ ព្រោះចាញ់អំណាចរោគ ។ ហេតុដូច្នេះ គួរយើងខំឧស្សាហ៍សំអាតលំនៅជាដើម ដើម្បីការពារកុំឲ្យរោគកើតឡើងបាន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សរសើរណាស់ នូវបុគ្គលដែលចេះថែរក្សាពាធកាយ ថានាំឲ្យបានសេចក្តីសុខសប្បាយ មានអាយុយឺនយូរ, ទ្រង់ត្រាស់សំដែងថា សណិកំ ជីវតិ អាយុំ បាលយំ "អាយុដែលបុគ្គលរក្សា រមែងបានស្ថិតគង់ទៅ ៗសន្សឹមៗ បន្តិចម្តងៗ" ។

រួមសេចក្តីដែលអធិប្បាយមកនេះហៅថា ជំនឹងប្រមាណក្នុងការថែរក្សាខ្លួន ។

## ទី ៤ - ការដឹងប្រមាណក្នុងបុគ្គល

ការដឹងប្រមាណក្នុងបុគ្គល សំដៅយកការចេះលៃលកតម្រូវអធ្យាស្រ័យនៃគ្នានឹងគ្នា ដែលនៅក្នុងសង្គមជាមួយដើម្បីនឹងរក្សាសេចក្តីសុខឲ្យកើតមានសព្វខ្លួន ព្រោះមនុស្សយើងដែលកើតឡើងក្នុងលោក មានសន្ដានមិនដូចគ្នាពាំងអស់ទេ មានមុះគ្រស់ឆ្ងល់បុណ្យសក្តិខ្ពស់ទាប មានទ្រព្យសម្បត្តិតិចច្រើន មានការគាន់ទំនៀមទំលាប់ផ្សេងៗ ដោយឡែកៗពីគ្នា ទើបព្រះសាស្ដាទ្រង់ត្រាស់ប្រដៅឲ្យដឹងប្រមាណក្នុងបុគ្គល ដូចសេចក្តីពន្យល់តទៅនេះ ៖

១ - ត្រូវឲ្យមានសេចក្តីស្មោះត្រង់រកគ្នា ចេះសង្គ្រោះគ្នាទៅវិញទៅមកតាមថ្នាក់តាមជាន់ គឺមាតាបិតានឹងបុត្រធីតា, គ្រូអាចារ្យនឹងសិស្ស, ស្វាមីនឹងភរិយា, មិត្រសម្លាញ់នឹងមិត្រសម្លាញ់ផងគ្នា, ចៅហ្វាយនាយនឹងជនអ្នកនៅក្រោមបង្គាប់, បព្វជិតនឹងគហស្ថ ត្រូវសំដែងសេចក្តីស្មោះត្រង់ទៅវិញទៅមក កុំកាន់កំរិយាខ្នាំងសត្រូវគ្នា ។

២ - ត្រូវចេះទប់ចិត្ត ទប់សំដី ចេះបន្ធូរកាយវិនលំនោរគ្នា ចេះខ្ចីខ្ចាខ្លួនខ្លួវវែលដែលគួបសម្គគណាមួយចូលមកញ៉ាំញ៉ី មិនឲ្យកើតសេចក្តីក្រោធឹងឹង នាំឲ្យឈ្លោះទាស់ទែងខ្វែងគំនិតគ្នា ។

៣ - បើមានសេចក្តីក្រោធកើតឡើង ត្រូវចេះបន្ទោមបន្ថយកំហឹងនោះឲ្យលេស់ស្រាកស្រុតទៅវិញ, ត្រូវចេះលៃលកកែតុបាយដើម្បី

រំលត់កំហឹង គួរកុំព្យាបាទ ចង់អាឃាតគំនុំគុំគួនគ្នា ព្រោះនឹងនាំឲ្យមានពៀរនឹងគ្នាតទៅថ្ងៃមុខ ។

៤ - ត្រូវចេះរំលែកចែកចាយ ចំណាយធនធានទិញអាហារចំណីគ្រឿងបរិភោគ ឧបភោគ ឲ្យដល់គ្នីគ្នា ។ -

ការដឹងប្រមាណដូចបានពោលមកនេះ ហៅថា ដឹងប្រមាណក្នុងបុគ្គល ។

## ទី ៥ - ការដឹងប្រមាណក្នុងធម៌

ការចេះលៃលកទន្ទេញស្វាធ្យាយ សង្កេតពិនិត្យពិនិស្ច័យនូវសេចក្តីធម៌អាថ៌ណាមួយ ឲ្យយល់ច្បូលចិត្តជាក់ច្បាស់ ចេះចាំច្បាកដស្ទាត់ដំនាញប្តូរសេចក្តីឈ្លាសវៃក្នុងការបង្ហាត់បង្រៀនប្រៀនប្រដៅណែនាំពន្យល់ធម៌តាមកាលគួរ តាមដំណើរបរិស័ទតិចច្រើន ព្រមទាំងការយល់ខ្ចប់នូវកម្រងធម៌ថា ធម៌នេះត្រូវលះបង់ ធម៌នេះត្រូវចំរើន ឬយល់ខ្ចប់នូវនៃសេចក្តីប្រតិបត្តិ ដូចដឹងថា ទានត្រូវបរិច្ចាគយ៉ាងនេះទើបមានផលច្រើន, សីលត្រូវរក្សាយ៉ាងដូច្នេះ ទើបបរិសុទ្ធ, ភាវនាត្រូវចំរើនតាមរបៀបនេះទើបសម្រេចគុណវិសេស; ដូច្នេះជាដើម ហៅថា ស្គាល់ប្រមាណក្នុងធម៌។ បុគ្គលអ្នកស្គាល់ប្រមាណក្នុងធម៌ហើយប្រតិបត្តិតាមធម៌ រមែងបានទទួលកម្រៃផលពីព្រះធម៌វិញ, ដូចព្រះសាស្តាថា ធម្មោ ហវេ រក្ខតិ

ធម្មបារី ធត្តុំ មហន្តំ វិយ វិស្សកាលេ "ធម៌តែងអភិបាលរក្សាបុគ្គលអ្នកប្រតិបត្តិប្រតិបត្តិតាមធម៌ ដូចធ្នូធំសម្រាប់ចាំងការពារមិនឲ្យភ្លៀងទឹក" ។ ឯ ទុគ្គតិ គច្ឆតិ ធម្មបារី "បុគ្គលអ្នកប្រតិបត្តិធម៌ រមែងមិនទៅកាន់ទុគ្គតិ" ។ ធម្មបារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច "បុគ្គលអ្នកប្រតិបត្តិធម៌ រមែងសម្រេចឥរិយាបថទាំង ៤ គឺដេក ដើរ ឈរ អង្គុយ ជាសុខក្នុងលោកនេះ និងលោកខាងមុខ" ។

រួបរួមការដឹងប្រមាណទាំង ៥ ប្រការ ដូចបានពណ៌នាមកនេះ ហៅថា មត្តញ្ញតា "ភាពនៃបុគ្គលអ្នកស្គាល់ប្រមាណ" ។ បុគ្គលអ្នកដឹងប្រមាណ ដូចបានពណ៌នាមកដោយសង្ខេបៗនេះ រមែងញុំាងប្រយោជន៍គ្រប់យ៉ាង ឲ្យសម្រេចបានគ្រប់កាល ដូចពុទ្ធភាសិតដែលបានពោលខាងដើមហើយ ថា មត្តញ្ញតា សាធុ ។

អត្ថាភាពសំដែងធម៌ទេសនាមកនេះ សមគួរដល់កាលវេលាតែប៉ុណ្ណេះ ។ សូមឲ្យពុទ្ធបរិស័ទសប្បុរសទាំងឡាយបានសម្រេចឥដ្ឋមន្ថាផលវិបុលសុខគ្រប់ប្រការ! ។

ធម្មទេសនាគុភាវេន សុខិតា ហោន្តុ បាណិនោ
ទ្វីសុ អត្តេសុ តិដ្ឋន្តុ សហ សព្វេហិ ញាតិភិ

ដោយអានុភាពនៃព្រះធម៌ទេសនានេះ សូមឲ្យសត្វទាំងឡាយបានសេចក្តីសុខគ្រប់ប្រការ! សូមឲ្យតាំងនៅក្នុងប្រយោជន៍ទាំងពីរប្រការ គឺប្រយោជន៍ក្នុងលោកនេះ ទទឹងបរលោក ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា!

រតនត្តយតេជេន សកលលោកវាសិនោ
ភិន្តឹ រ៉ុំឡុំ បប្បោន្តុ សន្តិភាវញ្ច នាញ្ញថា

ដោយតេជានុភាពនៃព្រះរតនត្រៃ គឺព្រះពុទ្ធ ព្រះធម៌ ទំនឹង ព្រះសង្ឃ សូមឲ្យប្រជាជនទាំងឡាយដែលអាស្រ័យនៅក្នុងសកលលោក បានដល់នូវការលុតលាស់ដុះចំរើន នឹងសន្តិភាព កុំបីឃ្លាតក្បាយជាបការៈដទៃឡើយ! ។

---

## ធម៌នៃអ្នកម្ចាស់ផ្ទះដែលត្រូវប្រតិបត្តិទៅរកភ្ញៀវ

ចូរមក! មកណេះ! អញ្ជើញអង្គុយលើអាសនៈនេះ! ហេតុអ្វីក៏ខានអញ្ជើញមកលេងយូរម្ល៉េះ? អ្នកសុខសប្បាយជានាទេឬ? ល្អាអ្នកពុំលណាស់តើ! សូមដូនពរអ្នកឲ្យសុខសប្បាយ! ខ្ញុំមានចិត្តរីករាយសប្បាយណាស់ បានឃើញអ្នកមកលេង! ។ នេះជាសិរីនៃលោកសម្បូរសទាំងឡាយ ដែលលោកឃើញនរជនណាមួយមកជិតផ្ទះ បើពុកជាជនសោះជាជនថោកទាបក៏ដោយ លោកតែងតែនិយាយដូច្នេះជានិច្ច ។ នេះជាធម៌នៃអ្នកម្ចាស់ផ្ទះទាំងឡាយជាធម៌ងាយសោះ ហើយអាចប្រគល់ស្ថានសួគ៌ឲ្យទៀតផង ។

ភាគទី ២

បណ្ឌិតមហា ឈឺម - ស៊ុម សាស្ត្រាចារ្យ
នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាបព្វជិត ពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

---

## សុភមិត្តជាតក ទី ៩

(និយាយអំពីដំណើរច្រោត់ច្រាស ព្រោះមានតៀរដោយយកក្លួនសត្វ)

ណោកអាចារ្យ ឈឺម - ស៊ុម ក្រមដំនុំព្រះត្រៃបិដក

ប្រែពីបាលី

អាកាសិ តុវំ ទេវាតិ ឥទំ ធម្មទេសនំ សត្ថា ជេតវនេ
វិហរន្តោ ទេវទត្តស្ស អកតញ្ញុតំ អារព្ភ កថេសិ ។ កាល
សម្តេចព្រះបរមសពិជ្ញសាស្តាចារ្យ ទ្រង់គង់នៅវត្តជេតពនសុគន្ធកុដិសិរី-
មហាវិហារ ទ្រង់ប្រារព្ធសេចក្តីអកតញ្ញូរបស់ទេវទត្ត ហើយសំដែង
ព្រះធម្មទេសនា មានបទព្រះបាលីថា អាកាសិ តុវំ មេវ ដូច្នេះជាដើម ។
សេចក្តីដំណាលថា សម័យថ្ងៃមួយនោះ ភិក្ខុទាំងឡាយកំពុងប្រជុំ
និយាយគ្នាអំពីសេចក្តីអកតញ្ញូរបស់ទេវទត្ត ឮតែសូរសំឡេងមាត់ទ្រហឹងកង

សាលាធម្មសភា; ដួនជាសម្តេចព្រះបរមសាស្តា ទ្រង់ពុទ្ធដំណើរចូលមក គ្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ, អម្បាញ់មិញនេះ អ្នកទាំងឡាយ ប្រជុំនិយាយគ្នាពីរឿងអ្វី?" ។ ភិក្ខុទាំងនោះក្រាបបង្គំទូលថា "សូមទ្រង់ ព្រះមេត្តាប្រោស, ខ្ញុំព្រះអង្គទាំងឡាយប្រជុំនិយាយពីរឿងទេវទត្តដែលមានសេចក្តីអកតញ្ញូ" ។ សម្តេចព្រះបរមគ្រូទើបទ្រង់គ្រាស់ថា "ម្នាលភិក្ខុទាំងឡាយ, ទេវទត្តជាមនុស្សអកតញ្ញូមិនត្រឹមតែឥឡូវនេះទេ, ពីដើមមកក៏ជាបុគ្គលអកតញ្ញូចំពោះតថាគតដែរ"; ទ្រង់គ្រាស់តែប៉ុណ្ណោះហើយក៏ទ្រង់គង់ស្ងៀម ពុំមានព្រះពុទ្ធដីកាថាដូចម្តេចទៀតសោះ, គ្រាតែភិក្ខុទាំងនោះអាចធនា ទើបទ្រង់នាំអតីតនិទានមកសំដែងប្រាប់ថា ៖

អតីតេ កិរ ភិក្ខវេ បញ្ចាលគរាជ សុភមិត្តោ នាម រាជា រជ្ជំ ការេសិ ម្នាលភិក្ខុទាំងឡាយ, កាលពីព្រេងនាយ មានព្រះបរមក្សត្រមួយព្រះអង្គទ្រង់ព្រះនាម ព្រះបាទសុភមិត្ត សោយរាជសម្បត្តិក្នុងនគរចម្បាក, ទ្រង់មានព្រះអនុជមួយព្រះអង្គទ្រង់ព្រះនាម អសុភមិត្ត ជាឧបរាជ ។ ព្រះអង្គមានព្រះរាជទេវីព្រះនាម នាងកេសិនី, មានព្រះរាជបុត្រាពីរព្រះអង្គគឺព្រះរាជបុត្រច្បងព្រះនាម ជេយ្យសេនកុមារ ព្រះរាជបុត្រប្អូនព្រះនាម ជេយ្យទត្តកុមារ ។

ចំណែកតមកខាងក្រោយ អសុភមិត្តជាឧបរាជ មានគំនិតគិតក្បត់ថា "កាលបើព្រះរៀមរបស់អញនៅកាន់រាជសម្បត្តិនេះជាអង្វែងទៅ, អាត្ម

អញ មុខជាមិនបានសោយរាជ្យទេ, បើដូច្នោះ មានតែអាត្មាអញដណ្តើមយកពលសម្បត្តិទើបគួរ", លុះគិតដូច្នេះហើយ ក៏ទ្រង់ប្រទានគ្រឿងស្លាកវណៈ មាសប្លាក់វត្ថុនិងគ្រឿងអម្ពរស្លាតាំងឡាយជាច្រើនដល់ពួកសេវាមាត្យរាជមន្ត្រីដើម្បីឲ្យគេចុះចូលនឹងទ្រង់ បម្រុងនឹងដណ្តើមយកពលសម្បត្តិ ។ គ្រាដែលអស្កុកមិត្តនរបាលកំពុងតែប្រជុំពួកសេនា, ជួនជាមានអាមាត្យម្នាក់ជាអ្នកតតញ្ញូ ចូលទៅរកព្រះបរមពោធិសត្វ ហើយក្រាបបង្គំទូលរឿងនោះតាមការណ៍ពិតថា ៖

អរិកាសិ គុរុ ទេវ តេ បិ យាបិតុមាគតោ
ឧជ្ជេហិ ទេវ សីឃម្ហិ អហំ វក្ខាមិ ការណំ
អជ្ជមេវ តិមំ រត្តិំ កឯជ្ជោ តំ ឃាដេស្សតិ
អប្បមាទេន វក្ខាហិ អត្តានញ្ច អជ្ជមេវាតិ ។

•បពិត្រព្រះសម្មតិទេព, ព្រះអង្គធ្លុសប្រហែសហើយ; សូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានអភ័យទោស, ទូលព្រះបង្គំជាខ្ញុំមកដើម្បីរំលឹកព្រះសតិព្រះអង្គ, សូមទ្រង់គ្រោកឡើងឆាប់ៗ, ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបបង្គំទូលឲ្យសព្វគ្រប់តាមហេតុការណ៍; កន្លងវេលាពាក្រឹថ្ងៃនេះ ព្រះអនុជព្រះអង្គប្រទំនឹងពិឃាតព្រះអង្គហើយ, សូមព្រះអង្គកុំប្រហែសឡើយ, ថ្ងៃនេះសូមទ្រង់ប្រយ័ត្នព្រះអង្គឲ្យមែនទែន ! ។

ព្រះបរមពោធិសត្វទ្រង់ព្រះសវនាការស្តាប់ពាក្យអាមាត្យនោះហើយ
ក៏ទ្រង់ត្រិះរិះក្នុងព្រះចិត្តថា "បើសិនជាអាត្មាអញតតាំងប្លាំងគ្នា, មុខ
ជាប្អូនអញព្រមទាំងពួកពលសេកលយោធា នឹងវិនាសខូចខាតអស់ច្រើន
ពុំខាន, បើដូច្នោះ មានតែអាត្មាអញគេចដោះថ្កាណរត់ចេញចាកពាជដ្ឋាន
ក្នុងវេលាពេលយប់នេះទើបគួរ" លុះទ្រង់ដញ្ជឹងរំពឹងគិតដូច្នេះស្រេច
ទើបស្តេចទ្រង់ព្រះពាជទានវង្វាន់ ដោយសេចក្តីមេត្តាករុណាចំពោះ
អាមាត្យនោះ ហើយទ្រង់បញ្ជូនឲ្យត្រឡប់ទៅវិញ, ទើបទ្រង់ស្តេចចូល
ទៅក្នុងសំណាក់ ព្រះនាងទេវីតែងកអគ្គ ទ្រង់ទតព្រះពាជបុត្រាទាំងពីរ
ថើបជញ្ជក់ព្រះសិរសា ទ្រង់មានព្រះពាជឫទ្ធារត្រាស់ផ្តាំព្រះនាងទេវីថា:
"ម្លៃប្អូនភ្ងាប្រិយ, ចូរស្តីនាងប្រុងប្រយ័ត្ន កុំប្រហែសកូនទាំងពីរណាស្ងួន!
ចូរពុំងាយចំណែកឲ្យកូនកុំឲ្យអស់កមិត្តសម្លាប់បានឡើយ!" ហើយ
ទ្រង់ត្រាស់ប្រាប់សព្វជំណើរស្រេចក្តីថា

(១) ម្នាលប្អូនស្រី, បងលាប្រិមប្រិយទៅព្រៃហើយ, ព្រៃនោះ
មានសុទ្ធតែម្រឹគពាឡបេនប្ងន, ដីរឹតបងគួរឲ្យសង្ស័យណាស់
ប្រហែលជានឹងស្ងាប់ក្នុងព្រៃធំនោះ តែម្នាក់ឯងទៅទេ
ក៏ពុំដឹង ។ បងនឹងកៀសខ្លួនចេញទៅនៅក្នុងព្រៃហេមពាន្ត
ដែលមានតែពួកសត្វម្រឹគជារបិន, បងនឹងសាងសន្សំបុណ្យ

---

១ ពាក្យត្រង់នេះ ខាងបាលី លោកស្រង់យកពីវេស្សន្តរជាតក ត្រង់ហិមវន្តវណ្ណនា ។

ចារមីក្នងវៃ្រដែលដេរជាសដោយម្រែតសាហាវ ជាទីនៅ
អាស្រ័យនៃសត្វរមាសខ្វា, ចូរពុំឆ្ងាយនាងនៅសប្បាយរីករាយ
តាមគុណចុះ ។

ព្រះនាងទេវីបានឮព្រះពជនុង្ការដូច្នោះក៏ទ្រង់ត្រាស់ព្រះពជសារនីយ
ថា "បពិត្រព្រះបរមកញ្ញាស្វាមីម្ចាស់ថ្លៃបួនអើយ, ព្រះអង្គទ្រង់មាន
ព្រះពជនុង្ការថាម្តេចដូច្នោះ?" ហើយ

ព្រះនាងកេសិនីទេវីដ៏ល្អល្អះសព្វអង្គឥន្ទ្រិយ មានព្រះពជ-
សារនីយ៍ក្រាបបង្គំទូលព្រះពជស្វាមីថា ព្រះអង្គទ្រង់មានព្រះ
ពជនុង្ការដូច្នេះ ខ្ញុំម្ចាស់ពុំដែលឮទេ! ព្រះពជនុង្ការដែល
ព្រះអង្គទ្រង់ត្រាស់មកនេះ អាក្រក់ណាស់ពុំប្រសើរសោះ,
បពិត្រព្រះពជសម្ភារ ព្រះអង្គទ្រង់ស្តេចនៅតែមួយព្រះអង្គ
ឯងពុំសមគួរទេ, បពិត្រព្រះបរមក្សត្រ, កេសិនីខ្ញុំម្ចាស់
ធ្វាប់គោរពប្រតិបត្តិ ពុំដែលលោះមួយវេលា; បើព្រះអង្គ
ទ្រង់ស្តេចទៅទីណា, ខ្ញុំម្ចាស់ស៊ូតែតាមទៅក្នងទីនោះផង,
ខ្ញុំម្ចាស់ស៊ូតែស្លាប់ជាមួយព្រះអង្គ ពុំព្រមនៅរស់តែម្នាក់ឯង
ឲ្យចំបែងចិត្តព្រោះឥតស្វាមីទេ, តាមទៅស្លាប់ជាមួយនឹង
ព្រះអង្គ ប្រសើរជាងការរស់នៅដោយសេចក្តីព្រាត់ច្បាស
ចាកព្រះអង្គ; បើខ្ញុំម្ចាស់ព្រាត់ច្បាសចាកព្រះអង្គហើយរស់

នៅ, ខ្ញុំម្ចាស់ទឹងបង្គំរកើងឲ្យឆេះឡើងសន្ធោសន្ធៅ មាន
អណ្តាតប្រសព្វគ្នាតែ ๑ កក់ ហើយលោតចុះសម្រុកសម្ងាប់
ខ្លួនកងកើងនោះប្រសើរជាង; បពិត្រព្រះនរបតី, ដូចជា
មេដំរីតែងប្រកៀកប្រកិតជាប់ស្លឹត តាមដំរីឈ្មោលមានក្លុក
ដើរតត្រុកទៅក្នុងព្រៃត្រែចទៅក្នុងពនាល័យ ជ្រោះច្រក
ញាកកុំគិរី សព្វទីថាបទីខ្ពស់ទំនួលខ្ពស់ ពុំឲ្យឃ្លាតឃ្លាសោះ
យ៉ាងណាមិញ; ខ្ញុំម្ចាស់ក៏ស៊ូតែពកូនសម្លាញ់ចាំងពីរ ទៅ
តាមព្រះកូមី ពុំឲ្យឃ្លាតដូច្នោះដែរ; ខ្ញុំម្ចាស់ ជាស្រីងាយ
បិញ្ចឹមណាស់, ពុំព្រមលាកលះព្រះអង្គឡើយ, បពិត្រព្រះ
ម្ចាស់ថ្លៃបូនអើយ, ខ្ញុំម្ចាស់ពុំព្រមនៅជាសុខ ក្នុងព្រៃនេត
នេះទេ ។

លំដាប់នោះព្រះបាទក្រុងសុកមិត្ត ទ្រង់អង្វរកព្រះនាងកេសិនីជា
អគ្គមហេសីថា ៖

ម្នាលបូនមាសពុំងា, នាងធ្លាប់តែលាយលាបស្រឡាបកាយ
ដោយក្រចេះបួងបន្ទន់ មានសុគន្ធពិដោរ ក្រអូបក្រអែបជា
ប្រក្រតី, ឥឡូវនាងចង់តាមបង់ទៅនៅព្រៃ កេសិនីនាង
បានអ្វីលាភ? នាងអើយ, ធម្មតាអ្នកនៅព្រៃ រមែង
ប្រឡាក់ដោយកកស្អុយជាទីគួរខ្ពើមរអើមមមាំមា, បើម្ល៉ះ

តើ ពុំជានាងចង់តាមទៅធ្វើអ្វី? ម្យ៉ាងទៀត កេសិនីនាងជាប់ស្នៀកដណ្តប់សុទ្ធសឹងតែសំពត់កាសិកព័ស្ត ខោមកព័ស្ត ឱមកព័ស្ត ទឹងទុម្មព័ស្ត មានតណ្ហាស្អែសស់ មានសាច់ទន់ល្មន់ល្វៃ, កាលបើនាងទៅនៅព្រៃ តើទេវីនាងស្នៀកកម្រងស្បៃភ្ញាំងមានសម្ផស្សរឹងគ្រាំង ដូចម្តេចកើត? លក្ខណៈ ម្នាលកេសិនីជាស្ត្រីគ្រប់លក្ខណ៍, ការនៅក្នុងព្រៃមិនស្រួលទេ, តែងតែមានសេចក្តីទុក្ខព្រួយជាប់ជាប្រក្រតី; បើដូច្នេះ ចូរប្រមប្រិយនាងកុំទៅរងទុក្ខលំបាកឡើយ ។

ទើបនាងកេសិនីទេវី ដ៏ល្អឆ្អះសព្វអង្គឥន្ទ្រិយ ទ្រង់ធ្វើយតបព្រះពុទ្ធង្កាព្រះពុទ្ធភត្តាមីថា ខ្ញុំម្ចាស់ពុំចង់បានសេចក្តីសុខដូច្នោះឡើយ; បើព្រាត់ប្រាសចាកព្រះអង្គហើយ ធ្វើម្តេចឡើយ ខ្ញុំម្ចាស់នឹងរស់នៅបាន ។

កាលព្រះបាទសុកមិត្តបវរេក្សត្រ ទ្រង់ឃាត់ដាច់អហង្ការកំព្រះអគ្គជាយាពុំព្រមសោះ, ទើបព្រះអង្គទ្រង់អនុញ្ញាតព្រមទាំងបំភ័យថា ម្នាលទេវី, ចូរប្អូនស្រីនាងប្រុងប្រៀបរៀបចំឲ្យឆាប់ៗចុះ, ការនៅក្នុងព្រៃនោះ វរមែងមានសេចក្តីលំបាកកម្រអត់ទ្រាំបានណាស់ មុខតែទឹងប្រទះពួកកណ្តុបរបោមមូសស្រាំងស្រួយ ទឹងឃ្មុំជាច្រើន, សត្វទាំងនោះ

ទឹងបៀតបៀនខាងក្នុងព្រៃនោះមិនលែង; មិនតែប៉ុណ្ណោះ ក្នុងព្រៃនោះ មានសត្វពស់ផ្សេងៗជាច្រើន គឺពស់វែក រនាម ពស់វែកដំបូក ពស់វែកស្រែង ពស់វែកក្រមើ ពស់ព្រៃ ពស់ថ្លាន់ធំៗ នៅអាស្រ័យក្នុងស្ទឹង; ពស់ទាំងនោះ បើបានប្រទះមនុស្សឬសត្វម្រឹគកាលណា ក៏តែងរួបរឹតបរិភោគជាអាហារ; មានតាំងខ្លាឃ្មុំធំៗ សំបើមគួរខ្លាច, ខ្លានោះ បើបានឃើញមនុស្សហើយ, ទុកជាមនុស្សនោះរត់ឡើងដើមឈើ ក៏វាពុំលែងដែរ តែងតែតាមទាំឲ្យខាងតែបាន; មានតាំងក្រមើព្រៃស្នងវែងៗ វាតែងសម្ងៀងសម្លុចសម្លាប់តែវ័ធមានរូបកាងធំៗ ជាត់ច មុខគួរឲ្យខ្លាច វាតែងចុះដេកគ្រាន់នៅក្នុងខ្ចាចប្របស្ទឹងសោតុម្ពក; បើសិនជាខាងឃើញហ្វូងសត្វម្រឹគសាហាវយង់ឃ្នងគឺទន្សាងគោព្រៃ គ្រែចឡើងចុះចម្រុះគ្នាក្នុងពនាល័យ តាមជ្រោះជ្រងជ្រលងច្រកចង្អៀត ហើយខាងឯងមានកូនផងទៀត ដូចជាមេគោបណ្តើរកូនខ្ទីយ៉ាងនេះតើ ស្រីនាងធ្វើដូចម្តេច? ម្នាលទេវី ក្នុងទីផ្លូវច្រកចង្អៀតទាំងនោះ នាងឯងឃើញតែមតែពួកស្វាដែលកាចៗប៉ុណ្ណោះ ក៏ប្លែកជាងនឹងមានភ័យខ្លាំង, អម្បាលនៅក្នុងប៉ុរីរាជវាំង គ្រាន់តែឮសំឡេងមាត់ឆ្កែលូ ម្តេចនាងតក់ស្លុត

ញ៉ាំរន្ធត់ទន់ខ្លួនដូចគេថ្លោច, ចំណង់ម៉ើចរត្រែចទៅកាន់ព្រៃ តើកេសិនីនាងធ្វើយ៉ាងណា ? ព្រហ្មបួនមាសពុំដា, កុងព្រៃព្រឹក្ស តែដល់ថ្ងៃត្រង់ឡើងកាលណា ពួកសូរសព្ទមិនាត់ សត្វបក្សីទីពុយមៀមខ្វែងស្រាក់ដែលគួរខ្លាច មកប្រជុំគ្នាយំបន្ទាច គួរឲ្យព្រឺក្បាលព្រឺពេម, ចូរព្រលឹងដោមនាងកុំបង់តាមទៅឡើយ ។

កាលដែលព្រះបាទក្រុងសុកមិត្តបរមកជា ទ្រង់ត្រាស់ដូច្នេះហើយ, ទើបព្រះនាងកេសិនីទេវី ដ៏ល្អល្អះសព្វឥន្ទ្រិយ ទ្រង់មានព្រះពាសនិយថា បពិត្រព្រះបរមពន្ធុអគ្គក្សត្រា, ទុកជាព្រះអង្គត្រាស់ប្រាប់ថា កុងព្រៃប្រកបដោយភ័យដ៏ពន្ធឹកយ៉ាងណា ក៏ភ័យទាំងអស់នោះ ខ្ញុំម្ចាស់ស៊ូតែទទួលយ៉ាប់ងើតាមកម្មពីព្រៃង តែដែលឲ្យខ្ញុំម្ចាស់នៅសង្រែងតែម្នាក់ឯង នោះនៅពុំបានទេ ស៊ូតែតាមទៅបំរើព្រះបាទាពុំព្រមឲ្យឃ្លាតឃ្លាឡើយ ; បើខ្ញុំម្ចាស់ដើរពុំរួច, ក៏ស៊ូតែលូនដោយទ្រូងកាត់ព្រៃញាតស្បាត ជ្រៀតជ្រែកញែកគុម្ពត្រែងសសិត បបុះ រណ្តាស ស្បូវ ស្មៅដំណេកទន្យាយ ខំតកាយការលូនទៅពីខាងមុខព្រះអង្គ ពុំសុខចិត្តឲ្យស្តេចលះបង់ ឲ្យនៅត្រមោចត្រមង់ជាស្រីមេម៉ាយទេ, ស៊ូតែទៅនៅរងទុក្ខ

កន្ធវៃ ជាមួយនឹងព្រះស្វាមី ប្រសើរជាងនៅមេម៉ាយ! ធម្មតាកូមារីតាំងឡាយ តែងតែបានស្វាមីមួយ។ នោះដោយសេចក្តីប្រព្រឹត្តវិត្តប្រតិបត្តិច្រើនប្រការណាស់ គឺដោយខ្លាចពោះធំប្រលើសឡើង ពុំចេញរាងស្ដើតឆើតឆ្ងង់ ក៏រមែងរុំពោះរុំដោះ ដោយសំពត់នឹងខ្នើតរួចធ្វើរុំដោយឈើឈ្មោះគោហនុ(១) ហើយទំបើរក្ងើតគឺទំយកចិត្តទុកដាក់នឹងត្រកួលរៀមច្បង ពោះបើនិយាយស្តីនឹងអ្នកផង ក៏ដោយសេចក្តីប្រុងប្រយ័ត្ន ក្រែងគេថាស្រីផ្តេសផ្តង់ស, ខ្លាចក្រែងសៅសម្បុរ ក៏ទំងូតទឹកត្រីកត្រហាមទំដុសដំឡើងឈាមឲ្យស្រស់ជាប្រក្រតី, ដល់វេលាបានស្វាមីហើយ ត្រឡប់ជាត្រាប់ប្រាសនិកសចោរត្មាជាស្រីមេម៉ាយទៅ កន្ធទ្រូងសែនក្តៅឆេះឆួលឈឺផ្សា ជាទុក្ខវេទនាណាស់ព្រះអង្គ បពិត្រព្រះចមពង្សអង្គនរបតី, សូមទ្រង់មេត្តា៧ប្រាសដល់កេសិនី, ខ្ញុំម្ចាស់សូមតាមព្រះចក្រីទៅទៅកន្ធវៃ ជាមួយផង ។ បពិត្រព្រះចមជន, ទុក្ខខ្ញុំម្ចាស់គ្រានេះពេញជាធ្ងន់ ព្រោះ

---

១ គោហនុស័ព្ទនេះ ប្រែថាឈើមានសណ្ឋានដូចដ្ឋាមដោ, ប៉ុន្តែដោយអ្នកកម្ពុជរដ្ឋ ពុំដែលប្រើ បានជាពុំដឹងហៅដោយភាសាខ្មែរថាខ្លួចឆ្កែច ។ ប្រហែលជាស្រី អ្នកមជ្ឈិមប្រទេសសម័យបុរាណ មានឈើនេះប្រើជាច្រើនគ្នា, បានជាក្នុងរឿងជាភាសាបាលី មាននិយាយពីកិច្ចវិត្តរបស់ស្ត្រី ដែលដំសាច់ខ្លួនដោយឈើនេះជាច្រើនអន្លើ ដូចរឿងនាងចិញ្ចាជាដើម ។

ជានយល់ពិតថា ធម្មតាស្រីមេម៉ាយជាទីមើលងាយនៃបុរស, សូម្បីស្រីនោះឥតសេចក្តីប្រាថ្នាផ្តេសផ្តាសសោះ ក៏បុរសហ៊ានចាប់បង្ខំចាំធ្វើអំណាចឥតកោតក្រែង; ប៉ុន្តែបើគេដឹងថាស្រីប្តីលែង, គេនឹងគ្រែងចោល ពុំបរិភោគរបស់សំណល់នោះឡើយ ដោយខ្លាចជាប់ចង្កៀ! បើយ៉ាងនេះ, ទ្រង់ខ្ញុំម្ចាស់ប្រាកដជាប្រែធាក្តៅផ្សាដូចគេចាក់ក្អូរភ្លឺ ដោយគ្រឿងសស្ត្រា; បពិត្រព្រះកស្តា, សូមទ្រង់មេត្តា ឲ្យខ្ញុំម្ចាស់តាមទៅចំរើព្រះបាទព្រះអគ្គផង ។ បពិត្រព្រះចម-ភាព, ធម្មតាស្រីមេម៉ាយ ជាទីមើលងាយនៃជនទាំងពួកមនុស្សប្រុសតែលជាច្រើនគ្នា តែងផ្តល់សេចក្តីទុក្ខវេទនាធ្វើឲ្យកើតអំពល់កង្វល់ព្រួយជាច្រើនប្រការ គឺអ្នកខ្លះហ៊ានចាប់សក់កញ្ចក់ទាញទៅ ឲ្យដួលដេកនៅលើផែនពសុធា, អ្នកខ្លះហ៊ានសំឡក់សំឡឹងចំនេត្រាពុំព្រមគេចចៀសដោយឥតរវៀសសោះ; កាលបើដូច្នោះ ក្នុងទ្រង់ខ្ញុំម្ចាស់នោះ ទំងឈឺឆៀបក្តៅផ្សាឧបមាដូចជាគេចាក់គេកូរដោយគ្រឿងអាវុធ; បពិត្រព្រះចមម្ចុដ, ខ្ញុំម្ចាស់ស៊ូតែបីបុត្រតាមព្រះអគ្គទៅ ពុំព្រមនៅទេ ។

ម្យ៉ាងទៀត មនុស្សប្រុសទាំងឡាយតែងមើលងាយស្រីមេម៉ាយ ថាជាស្រីមានសម្បុរកាយសោះកក្រោះអស់រសជាតិអស់ដម្ងៃ ចុះថ្ងៃដល់កំណត់ ជាស្រីងាយនឹងបំបត់ពត់ឲ្យងាកបែរវេតាមក្បាច្បាបស់ប្រុស, កាលបើដូច្នោះ ពួកប្រុសទាំងនោះនឹងហ៊ានធ្វើកិរិយាជន្ទេញជន្ទរ ឲ្យកើតសេចក្តីវិវាទដូចជាក្អែកនឹងមៀម; បើតែយ៉ាងនេះ ទ្រង់ខ្ញុំម្ចាស់នឹងកំណែ្រមឈឺធៀបក្តៅផ្សាននឹងប្រេះឆា ដូចគេចាក់ទុកពុះទម្លាយពុំខាន; បពិត្រព្រះនរបតី, ខ្ញុំម្ចាស់កេសិនី ស៊ូតែតាមព្រះបក្តីទៅ ពុំព្រមនៅជាស្រីមេម៉ាយទេ ។

ម្យ៉ាងទៀត ធម្មតាស្រីមេម៉ាយ ទោះបីនៅក្នុងក្រុមញាតិទាំងឡាយ ដែលជាត្រកូលខ្ពស់ខ្ពស់ល្អាឃ រុងរឿងដោយគ្រឿងមាសនឹងប្រាក់ពស្ត្រាភរណៈឥតមានខ្វះអ្វី ក៏កុំគប្បីសង្ឃឹមថា អញមុខជាលែងត្រូវពាក្យគេរិះគន់ហើយដូច្នេះឡើយ, មិនមែនដូច្នោះទេ, ទៀងតែត្រូវមាត់គេជាប្រាកដ; បើរួចពីពាក្យបងប្អូន, គង់ត្រូវពាក្យកូនរបស់គេ ឬត្រូវពាក្យនរណាមួយដែលខុកជាប់ស្រឡាញ់ជិតជិតស្និទ្ធស្នាលយ៉ាងណាក៏ដោយ គេនឹងថាឲ្យដោយសេចក្តីមើលងាយថា "ស្រីនេះមេម៉ាយឥតប្តី គ្មានការងារអ្វីគាន់ចិញ្ចឹមខ្លួនទេ, មុខតែវាងនឹងនៅនាំឲ្យវេលាអំពល់ទុក្ខដល់យើង អស់

មួយដងតែវា ជាប្រាកដ"; កាលបើយ៉ាងនេះ ខ្ញុំនឹងខ្ចីម្ចាស់ទឹកក្តីលំដួលក្តៅផ្សា ប្រែធម្មជាតិពីបើចំណែកតុំលែងឡើយ; បពិត្រព្រះកស្សាសូមីខ្ញុំអើយ, ទុក្ខបួនគ្រានេះ ពេញជាមហាធន់ផុតវិស័យនឹងថ្លែង, ហេតុដូច្នេះ កេសិនីខ្ញុំម្ចាស់សូមតែសូរពន្ធនចោលកន្ទែង ស្មើនឹងតាមព្រះកស្សាទៅតុំព្រមនៅទេ ។

ម្យ៉ាងទៀត ដូចជាស្តេចព្រៃកន្ទែកន្ទេរដែលជាមេទឹកដល់ជារ បើឥតទឹកហូរជាជម្ងឺតា ក៏ឥតបានការអ្វីឡើយ លោកចាត់ជាស្តេចអាក្រាត; តុំនោះសោតទេ, ដូចជាដែនទៀតខ័ណ្ឌសីមា ដែលឥតស្តេច ឥតអ្នកសម្រេចការ ក៏លោកចាត់ថាជាដែនអាក្រាតដែរ, យ៉ាងណាមិញ; ចំណែកខាងស្រីមេម៉ាយទុកជាមានបងប្អូនតាំងឡាយដប់ម្ភៃនាក់ ក៏ហាក់ដូចជាស្រីអាក្រាត ដូច្នោះដែរ; កាលបើទៅជាស្រីមេម៉ាយដូចជាអាក្រាតកាយនៅឯនទេដូច្នេះ. ខ្ញុំម្ចាស់នឹងប្រែបែរបែកវិលចេញពីគ្នាជាប្រាកដតុំលែង; បពិត្រព្រះគម្ពែង, ខ្ញុំម្ចាស់សូមតែសូរពន្ធនតាមព្រះអង្គទៅ តុំព្រមនៅទេ ។ ម្យ៉ាងទៀត ដូចជាពពួកជវៈ រមែងមានទង់ជាគ្រឿងកំណត់ឲ្យគេស្គាល់ប្រាកដបាន, ឬដូចជាក្អែង រមែងមានផ្សែងជា

គ្រឿងប្រាកដ, ឬដូចជាដែន រមែងមានស្តេចជាគ្រឿង
ប្រាកដ, ដូចម្តេចមិញ; ជាតិស្ត្រី ក៏រមែងមានស្វាមីជា
គ្រឿងប្រាកដដូច្នោះដែរ; បើឥតស្វាមី, ពុំពេញជាស្ត្រីទេ;
ជាតិនេះ ខ្ញុំម្ចាស់កើតមកជាមនុស្សនឹងគេ គួរពាប់ថាជាស្ត្រី
ពេញទីបាន ព្រោះមានស្វាមីពេញមុខ; ឥឡូវបើព្រះអង្គ
បោះបង់ឲ្យទៅមេម៉ាយ, ខ្ញុំម្ចាស់សែនក្តៅក្រហាយក្នុងចិត្តឥត
ឧបមា, ទ្រង់ខ្ញុំម្ចាស់វែងខ្លោចផ្សាប្រាកដជាប្រែធាបែកធ្លាយ
ពុំខាន; សូមព្រះអង្គទ្រង់ប្រោសប្រាណ អនុញ្ញាត ឲ្យ
កេសិនីខ្ញុំម្ចាស់តាមទៅផង ។ សេចក្តីពិតដែលបណ្ឌិតបាន
ប្រកាសទុកមកថា ស្រីឯណា ទោះបីជាធីតារបស់ត្រកូល
អ្នកមានក្តីរឿងខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ កាលបើស្វាមី
មានសេចក្តីថ្នោះថ្នាយធ្ងាក់ខ្វះជាអ្នកកំសត់ទុគ៌ត ក៏ស៊ូតែ
លំអុត រង់សេចក្តីកំសត់ជាមួយផង, កាលបើស្វាមីចំរើនសិរី
ឡើងថ្នាក់ជាអ្នកសុខសប្បុរ ក៏ជាស្រីសុខសប្បុរជាមួយផង;
ទេព្តាទាំងឡាយ តែងសរសើរស្រីបែបនេះ ថាជាស្រីមាន
កិត្យកិរិយាគម្រមាននរណាធ្វើដូច, ស្រីបែបនេះ អ្នកផងគួរ
យកជាគ្នា; ហេតុដូច្នេះ សូមព្រះកស្តាកុំទ្រង់ជំនាយទឹង
ខ្ញុំម្ចាស់; ដើម្បីឲ្យខ្ញុំម្ចាស់បានឈ្មោះថាស្រីមានសំពត់ស្វែក

ជាទិច្ចតទៅ គួរតែព្រះបរមរាជទ្រង់អនុញ្ញាតឲ្យតាមទៅផង កុំឲ្យវេទនាខ្លាំងពេក; កាលបើផែនដីពុំបានបែករលាកហាលេបខ្ញុំម្ចាស់ឲ្យស្លាប់ទៅជាបណា សេចក្តីខ្វាចផ្សាក្នុងទ្រូងខ្ញុំម្ចាស់ជាស្រីមេម៉ាយ ក៏រឹតតែក្លាយខ្លាំងឡើងពុំស្លាប់ទៅជាបាននោះ; កុំថាតែឲ្យខ្ញុំម្ចាស់នៅពេលដូច្នោះសូម្បីមាននរណាមួយ អាចឲ្យផែនដីទាំងមូល ដែលមានព្រំប្រទល់ដល់មហាសមុទ្រ ផុកសុទ្ធតែគ្រឿងរតនវត្ថុផ្សេងៗមកខ្ញុំម្ចាស់ ឲ្យតែជាប់ចិត្តស្រឡះពីព្រះស្វាមី ក៏កេសិនីខ្ញុំម្ចាស់ពុំព្រមដែរ ។

ស្រីណាអេះ? កាលបើស្វាមីមានទុក្ខ ហើយបែរជាចង់បានសុខចំពោះខ្លួនម្នាក់ឯង! តើបេះដូងស្រីនោះដូចម្តេចទៅបានជាចិត្តភ្លៅអាក្រក់ម្ល៉េះ? ខ្ញុំម្ចាស់ពុំមែនជាស្រីចិត្តអាក្រក់ដូច្នោះឡើយ កាលៈបើព្រះមហាពជ ជាអ្នកចំអើនកងដែនរបស់ជន ទ្រង់ចេញចាកព្រះពជបុរី ទៅគង់នៅកងព្រៃ កេសិនីសុំតែតាមព្រះអង្គ ដែលធ្លាប់ទ្រង់ព្រះពជទានសេចក្តីសុខគ្រប់ប្រការ ពុំព្រមនៅជាស្រីមេម៉ាយអនាថា កំព្រាឥតស្វាមីទេ(๑) ។

(មានត)

---

๑ សេចក្តីភិលាបរបស់នាងកេសិនី តាំងពីខាងដើមម្ចាស់ដល់ត្រឹមនេះ ចំណែកខាងបាលីខ្ញុំបានពិនិត្យឃើញថា លោកអ្នកតែងរឿងនេះ បានដកស្រង់មកពីវេស្សន្តរជាតក ត្រង់ខាងកណ្តាល។

(សិសោរដាតក)

# ព្រះមហាឧត្តមរិដ្ឋ ធម្មញ្ញាណោ ប៊ិង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុរតី ក្រុងភ្នំពេញ
រៀបរៀងតាមគម្រោយសាស្ត្រាស្ទឹករិត

(តមក)

---

កុំណែនោះព្រះជាទ ។ សំសៅវ៍នរនាថ ឃើញហោរហើយអ-
ម្ចាស់មានដំរាស់ ត្រាស់ប្រាប់ដោយដំ- ណើរសព្វឥតបំ -
ផ្លើសក្លាត់ឡើយណា ។ "ហោរអើយ! គួរស្តែង យប់មិញនេះឯង
អញផ្ទំនិត្រា យល់សប្តិហាក់ដូច កំពូលភ្នំណ៌ភ្នា -
សាទអញនេះណា បាក់ធ្មាក់ទីថៃ ។ ចូរហោរពាំនឡាយ
គន់គូរឲ្យឆាយ ដោយក្បួនសាស្ត្រសៃយ ឲ្យដឹងដំណឹង
នេះតើម្តេចនៃ ភល់ខ្លួនទីថៃ ដៃ។ រួសា" ។
ដោយអញយល់សប្តិ ហោរមើលឲ្យគ្រប់ យល់កាចប្តូរ
ល្អប្តូរអាក្រក់ ប្តូរដូចម្តេចម្តា តើជាយ៉ាងណា
ឲ្យដឹងសេចក្តី" ។ កុំណែហោរស្តែងស្តាប់ បន្ទូលសាស័ព្ទ
ពីព្រះចក្រី ហោរបើកដំរាក ភល់គ្នាឃ្លាតខ្លី
គន់គូរាសី ច្រកតីតាមក្បួន ។ ហោរាគួរាស
ដោយប្រាជ្ញាឈ្វាស ចំពោះភល់ខ្លួន សឹងតែត្រូវគ្នា

ប្រកបបច្ចុបដ្ឋន តាមដោយទូរក្សន ឥតខុសពីគ្នា ។
អស់ហោរទាំងឡាយ ក្រញ្ជក្រាបថ្វាត់ថ្វាយ បង្គំវន្ទា
ទូលតាមសំនួន នៃក្សួនសាស្ត្រា "បពិត្រកុណា
មេត្តានេះម្តង ។ យើងខ្ញុំគ្រប់គ្នា មើលគ្រោះកាចជា
សត្វគ្រប់ហើយហោង ពុំចេះនឹងច្រោស អស់ទោសនេះម្តង
ខុកជាខ្ញុំល្អង់ ព្រះចុះអម្ចាស់ ។ បពិត្រពជា
យើងខ្ញុំគ្រប់គ្នា ឃើញអាក្រក់ណាស់ នឹងកើតវិបរិត
ត្រូវពិតត្រង់ម្ចាស់ កំណត់នៅខ្លះ តែ ៧ ថ្ងៃ ។
ព្រះសៅរ៍ទេព្តា នឹងចេញយាត្រា ចាកសួគាល័យ
មកក្សួមរាសី នឹងអម្ចាស់ថ្ងៃ កុំម្ចាស់សង្ស័យ
កុងព្រះទ័យា ។ ទៅ ៧ ថ្ងៃ ព្រះសៅរ៍នោះនៃ
នឹងសោយរាជ្យ ឲ្យម្ចាស់ចេញចាក ពីនគរា
ព្រាត់ច្រាសជាយ៉ា មុខមន្ត្រីផង ។ បើដូច្នេះណា
កុំព្រះរាជា ប្រហែសឡើយហោង សូមរៀបផ្តាក្តី
ជាភ្លើការផង កុំឲ្យមានហ្មង កើតទុក្ខអំពល់ ។
លុះដល់វេលា ដែលសៅរ៍ទេវ នឹងចូលមកដល់
ព្រះអង្គបូជា ក្តីផ្តាឲ្យឈប់ ជាការមង្គល
ទទួលព្រះសៅរ៍ ។ អង្វរសូមទោស ឲ្យលោកសន្តោស

ឲ្យបានបិតនៅ សម្បូរសម្រុង អង្វរលោកទៅ
សូមឲ្យព្រះសៅរ៍ ទទួលបូជា ។ ម្ចាស់ធ្វើដូច្នោះ
ព្រះសៅរ៍នឹងលោះ ឲ្យសុខវិញណា សេពសោយសម្បត្តិ
ពស្ត្រវដ្ឋសីមា នូវនាងជាយា អគ្គមហេសី ។
យើងខ្ញុំគ្រប់គ្នា ទូលព្រះរាជា ឲ្យជ្រាបសេចក្តី
មេត្តាអត់ទោស ច្បាណាច្បាសច្រើណី យើងខ្ញុំនេះខ្លី
ជាខ្ញុំបាទ” ។

បទតំណោល

កាលនោះឯអគ្គព្រះបាទ សិសៅរ៍នរនាថ ស្តេចស្តាប់នូវពាក្យហោរា ។
ថាឲ្យសំពះច្នោះណា ស្តេចក្រែវក្រែងា ពន្ធឹកអធិកខ្លាំងវិក្រែ ។
ហាក់ដូចអគ្គីវិស័យ នេះក្តីឫប្លែយ រន្ធត់អស់ទាំងអគ្គច្បាណ ។
ឬមួយនឹងប្រែប្រៅទៅឋាន ដូចនាគហារហាន ត្រូវនឹងដំបងដែកណា ។
ត្រង់ចុងកន្ទុយអាត្មា ក្រែវក្រែងមហិមា ឧបមាបីដូចម្តេចមិញ ។
រីស្តេចទ្រង់ព្រះក្រែងវិញ ដូចនាគនោះមិញ ឈឺផ្សាក្នុងព្រះទ័យណាស់ ។
ទើបស្តេចមានព្រះតម្រាស់ ហោរអើយម្តេចអះ ឲ្យអញសំពះចុះចាញ់ ។
ព្រះសៅរ៍ទេវបុត្តនោះអញ តុំព្រមចុះចាញ់ តុំព្រមសំពះឡើយណា ។
ព្រះសៅរ៍នោះជាទេវតា ឯអញនេះណា តើជាទេវតាណាចៅ ។
ម្តេចឯងឲ្យអញនេះទៅ ឬជាព្រះសៅរ៍ អញតុំព្រមតាមឡើយណា ។

អញមានវិទ្ធិបេស្កា តតអ្នកឯណា ឧបមានឹងអញនេះបាន ។
ពលរេហ៍សេនាភាហាន ហ្នឹងសែនកោដិលាន សឹងជាសម្រាប់អញឯង ។
មានតាំងជាវ៉ូដ្ឋីជាវ៉ែង ឆ្កួលាំពែង អញឯងមិនខ្លាចសៅរ៍ឡើយ ។
កើតមកជាស្តេចចក្រហើយ ពុំត្រូវកន្តើយ ត្រូវច្បាំងពុំត្រូវសំពះ ។
តតាំងឲ្យដឹងតេជះ ខោះចាញ់ខោះឈ្នះ នោះទើបហៅប្រុសគ្រាន់បើ ។
សៅរ៍នោះតែមួយទេតើ ម្តេចហ៊ានសើរ៉ើ មោះមកបំផ្លាញអញបាន" ។
ក្រុំណាខោះហោរគ្រប់ច្បាណ៌ស្តេងស្តាប់ស្តេចមាន មានរឹងរូសច្នោះណា ។
ទើបហោរក្រុញក្រាបវន្ទា ទូលព្រះរាជា តាមដោយដំណើរព្រះសៅរ៍ ។
"បពិត្រព្រះជាទេចមចៅ រ័ឯព្រះសៅរ៍ ពុំបានឲ្យឃើញឡើយណា ។
ខោះតាំងស្រមោលធាយា រូបរាងអង្គា នោះជាកំចាំងសូន្យសោះ ។
សូមទ្រង់មេត្តាសង្គ្រោះ កុំក្រោធដូច្នោះ តបន្ទោះព្រះសៅរ៍ឡើយណា ។
សូមស្តេចរៀបអស់ក៏ផ្កា រណ្តាប់រណ្តា ឬជាព្រះសៅរ៍ទើបបាន ។
ព្រះអង្គឧឡឹងសុខក្សេមក្សាន្តបរិបូណ៌ធនធានសូមមានស្តេចតាមយើងណា" ។
ក្រុំណានោះព្រះជាទេក្សត្រា ស្តាប់ពាក្យហោរា ពណិនាសេចក្តីសព្វកាយ ។
ស្តេចរឹងជាក្រោធមាល្យាយ ដៃញ៉ាហោរខ្លាត់ខ្លាយហើយមានព្រះរាជបញ្ជា ។
ឲ្យមន្ត្រីខាងយុទ្ធនា អគ្គបញ្ជា ចូលគាល់ព្រះអង្គធាប់ឮ ។

លុះដល់សេនាបតី ចូលគាល់ចក្រី នរបតីទ្រង់ត្រាស់ប្រាប់ថា ។
" តាំងពីថ្ងៃនេះឯងណា ទៅដល់ទីវ៉ា គ្រប់ជា ៧ ពុំឃ្លាត ។
ចូរលោកប្រឹងប្រែងសង្កាត ឲ្យពលនុហាត យាមល្បាតក្នុងនគរ ។
ទ្វារទាំង ៤ ទិសនោះណា ចូរដាក់យោធា រក្សា ១ ទ្វារ ១ ពាន់ ។
ទាំងប្រាសាទ ៧ ជាន់ ត្រូវដាក់ ១ ពាន់ ១ ជាន់ ៗ ដូចគ្នា ។
បើឃើញព្រះសៅវ៍ទេវ៉ា ចូរឲ្យសេនា នាំគ្នាចូលកាប់សំឡាប់ ។
ពុំនោះឲ្យចូលចោមចាប់ ចងជាប្រញាប់ នាំមកឲ្យយើងឆាប់ខ្លឹ " ។
កន្លែណានោះសេនាបតី លុតលាចក្រី ឃ្លាតខ្លីចេញមកចាត់ការ ។
រៀបចំអស់ពលបរិវារ តាមព្រះទុង្ការ ដោយមុខដោយងារឫសពាន់ ។
១ ទ្វារសឹងជា ១ ពាន់ ប្រាសាទសោភ័ណ ១ ជាន់ ១ ពាន់ស្រេចណា ។
សឹងតែប្រដាប់ប្រដា កាំបិតធ្នូស្មា គ្រប់គ្នាដោយដៃទីថៃ ។
ខ្លះកាន់ខែលខាន់ប្រពៃ ចិត្តចង់យកជ័យ រំពៃនេត្រាឆ្វេងស្តាំ ។
ខ្លះកាន់លំពែងលលាំ ប្រយ័ត្នប្រចងចាំ ចាំចាប់នូវសៅវ៍ទេវ៉ាបុត្រ ។
ឥតខ្លាចឥតមានតក់ស្លុត ចិត្តចង់ប្រយុទ្ធ ចិត្តមុតមិនខ្លាចឡើយណា ។
ពួកពលសកលយោធា ច្រើនពៃរៃមហិមា រក្សាគ្រប់ទ្វារដុំជិត ។
សេនាសុទ្ធសឹងរឹងប៉ឹង រឹបឹងប្រឹងប្រិត ពាក់ព័ន្ធសព្វគ្រប់ប្រាណ ។
ខ្លាចតែត្រង់ព្រះសៅវ៍ចូលបាន ប្រយ័ត្នមិនហានប្រហែសដល់តិចឡើយនែ ។

ប្រយ័ត្នតាំងយប់តាំងថ្ងៃ គ្រឿងគ្រប់ដោយដៃ រាំពៃគយគន់ពុំឆ្ងេស ។
ឯព្រះសិសៅវ៍ធិបេស ស្តេចក៏ពុំឆ្ងេស ឫហៃសព្រះអង្គអាត្មា ។
ស្តេចទ្រង់មកុដសុវណ្ណា ដាំត្បូងសោភា សឹងពេជ្រំលេចយល់យង់ ។
មរកតមណីរ័តន៍បញ្ចង់ ហើយទើបស្តេចទ្រង់ ព្រះពស្ត្រប្រពៃចាន់ចាក់ ។
ចេសលួសខៀវសេយទ្វាយទ្វាក់ បក្សីចឹកចាក់ បទុមក្រពុំមាល័យ ។
ស្តេចទ្រង់សង្វារ័តន៍ថ្ងៃ កងកណ្តាមាសម័យ ងាំខ្លួរពាយទឹកវិល ។
ព្រះហស្តស្តេចទ្រង់ធ្នូសិល្ប៍ កៅដ៏ណ្តាមាសស្រិលព្រះខ័នខ្លួរមូលសក្តិជ័យ ។
ឥតថុចបីកកុចឡើយនៃ រុងរឿងពេកក្រៃ ឧបមេយ្យដូចសីហៈណា ។
សម្តេចសិសៅវ៍រាជា ប្រុងប្រៀបអាត្មា ប្រយោជន៍ប្រយ័ត្នការអង្គ ។
ស្រាប់ស្រេចស្តេចស្តេចចាំរង់ តតាំងនឹងអង្គ ព្រះសៅវ៍ទេវបុត្រជាម្ពង ។
លុះដល់ពាក្រឹកទ្វង ចាន ៧ ហោង ព្រះសៅវ៍ទេវបុត្រនោះណា ។
ចុះមកសង្កត់លក្ខណា ធ្វើឲ្យក្សត្រា ពុំដឹងអាត្មាឡើយនៃ ។
ក្សណៈនោះសិសៅវ៍ជៀសជ័យ កើតក្តៅព្រះទ័យ វិស័យដូចឆ្អួតលេលា ។
ស្តេចទតឃើញពលយោធា ដែលចាំរក្សា នៅនាក្រាំងគ្គ័ណ៌ក្រាសាទថ្ងៃ ។
ក៏កើតក្តួលក្តៅហ្អឹងឆ្ងល់ ស្តេចហួតខ័នជ័យ ដាលដៃញាអស់ពលសេនា ។
អស់ពលសកលយោធា កិតក័យតក្កម្មា រួតរត់ប្រពួនទីនៃ ។

(មានត)

កណ្ឌទី ១៩

# ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាំងវៃឆ្លាសបើបានអាន
ធំងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

លុះកន្ធង់មកយូរថ្ងៃ ចូរឆ្លូវឲ្យអញ្ជើញឡៅពីស៊ីសៀង ទទួលមាន់ថង់ដែលចូរឆ្លូវប្រើទៅស្តាប់ការពាជការខាង ស្រុកអ្នកសៀវនោះត្រឡប់វិលមក យកសេចក្តីជំរាបចូរឆ្លូវថា ឥឡូវកង់ស៊ុនចានចាញ់ដៃអ៊ិនសៀវទៅហើយ ។ ឡៅពីបានស្តាប់ក៏ភ័យស្ងុតរន្ធត់ចិត្ត ទើបសួរមាន់ថង់ថា ដែលអ៊ិនសៀវឈ្នះកង់ស៊ុនចាននោះដោយហេតុអ្វី? ។ មាន់ថង់ឆ្លើយថា អ៊ិនសៀវលើកទ័ពទៅវាយកង់ស៊ុនចាន ។ លើកទ័ពមកតទល់គ្នាក៏ច្បាំងការចាញ់ដៃអ៊ិនសៀវជាច្រើនគ្រា កង់ស៊ុនចានក៏ឲ្យទៅសង់សែនប្រចាំតយកំពស់ ២០ ព្យាម ហើយដញ្ជូនស្រូវនឹងចំណីអាហារទៅទុកក្នុងស្រុកជាច្រើន

កេណ្ឌសេនាតាហានឡើងរក្សានាទីសែនបន្ទាយមាំមួន ឯស្រុកចំណុះកង
ស៊ុនចាន តាំងប៉ុន្មាន ក៏បកសំបុត្រថ្វីងចូលទៅកង ស៊ុនចានថា អ៊ីនសៀវ
លើកទ័ពមកវាយស្រុកតូចស្រុកធំបែកភ្នាត់ភ្នាយជារច្រែនតំបន់ សុំឲ្យលើក
កងទ័ពទៅជួយ កងស៊ុនចានឆ្លើយតបទៅវិញថា សេនាតាហានគ្រប់
ស្រុកប្រែចិត្តមិនគិតជួយច្បាំងទេ មិនដឹងកាលណាទឹងបានលើកទៅជួយ
ឡើយ នោះស្រុកចំណុះតាំងអស់ឮឃើញសំបុត្រឆ្លើយតបដូច្នោះ តាំង
អស់គ្នាក៏តូចចិត្ត គិតស្រុះគ្នាចូលទៅចំណុះចុះចូលខាងអ៊ីនសៀវតាំងអស់,
កងស៊ុនចានដឹងដូច្នោះ ក៏ធ្វើសំបុត្រចូលមកក្រាបទូលព្រះថៅហៀនតេ
សុំកងទ័ពលើកទៅជួយ តាហានអ៊ីនសៀវចាប់ចំរើដែលកាន់សំបុត្រនោះ
បាន កងស៊ុនចានក៏ប្រើចំរើឲ្យនាំសំបុត្រទៅដល់តៀវអៀនខៀត ឲ្យ
លើកកងទ័ពទៅជួយ បើមកដល់កាលណាឲ្យអុដក្លើងជាសំគាល់ កង
ស៊ុនចានទឹងលើកតាហានវាយខ្ជប់ពីក្នុងមក តាហានអ៊ីនសៀវក៏ចាប់ចំរើ
នាំសំបុត្រនោះបានទៀត ហើយអ៊ីនសៀវបំបែកតាហានឲ្យទៅពួនបង្កប់
ជា ២ កង តាហានកងកណ្តាលឆ្លើជាឆ្ងាយកំពែងចូលទៅ អ៊ីនសៀវឲ្យ
អុដក្លើងឆ្ងាយពីបន្ទាយប្រហែល ៣០ សិន (១២០០ម.), កងស៊ុនចាន
ឃើញពន្លឺក្លើងដូច្នោះក៏សំគាល់ថា តៀវអៀនលើកទ័ពមកជួយ ក៏បើក
ទ្វារស្រុកចំហហើយលើកទ័ពចេញទៅ, តាហានអ៊ីនសៀវកណ្តាល
ក៏ធ្វើជាថយរត់ទៅ ហើយអុដផាវជាសញ្ញាឡើង កងទ័ពដែលពួនបង្កប់

តាំងសង្ឃភាគ កំលើកស្រែចេញមកវាយប្លន់តាំងសង្ឃភាគ កាប់សម្លាប់ តាហានកងស៊ុនចានស្លាប់ជាច្រើនណាស់, កងស៊ុនចានរត់ចាក់ទ័ពត្រឡប់ ចូលស្រុកវិញបាន, អ្នកនេសាទឲ្យតាហានដឹកអុងម៉ុងចូលទៅចំលុះឡើង កណ្តាលស្រុក ហើយយកក្លើងដុតអស់ផ្ទះសម្បែងក្នុងស្រុក, កងស៊ុន ចានឃើញគាល់ច្រកកេផ្លូវវេះរត់ពុំរួច ក៏សម្លាប់កូយាបុត្រាបស់ខ្លួនស្លាប់ អស់រលីង ហើយអាកខ្លួនឯងស្លាប់ទៅទៀត, អ្នកនេសាទគ្រានេះចាន តាហានកងស៊ុនចានខ្ទុកជាច្រើនណាស់ ។

ឡៅពីចានឮដូច្នោះ ក៏មានសេចក្តីអាណិតកងស៊ុនចានដោយកង ស៊ុនចានមានឧបការគុណ ចានទូលស្នើសុរសើរគុណបំណាច់ថ្វាយព្រះ ចៅហៀនតេ ។ ទ្រង់ច្រាសឲ្យឡៅពីចានជាចៅហ្វាយស្រុកផេងង្ហួនគួន ហើយគិតដល់ដូឡង ដោយមិនដឹងថាជារស់ឬស្លាប់ ។ ចូឆ្លក់សួរ មាន់ថងថា អ្នកនេសាទចានស្រុកប៉ាក់បុងហើយ តើត្រូវធ្វើដូចម្តេច ខ្លះ? ។ មាន់ថងឆ្លើយថា ខ្ញុំចាធ្លាប់ណឹងថា អ្នកសុតនៅស្រុកហួយណាំ តាំងខ្លួនជាស្តេច ប្រព្រឹត្តទុច្ចរិតកំហែងកំចាកពេកក ស្តេចជាតាំងពួង បែកខ្ញែកខ្ញាយទៅជាច្រើន អ្នកសុតឲ្យបំរើទៅចាប់ដល់អ្នកនេសាទជាបង ថានឹងបញ្ជូនគ្រាសម្រាប់ពជ្យទៅឲ្យអ្នកនេសាទនោះ អ្នកនេសាទមិនចាន់ជឿ ចានតបថា ឲ្យអ្នកសុតជាប្អូនបញ្ជូនគ្រាទៅឲ្យមុន ឥឡូវអ្នកសុតនាំគ្រប់ គ្រួនឹងសារពើទ្រព្យសម្បត្តិចេញពីស្រុកហួយណាំ នឹងនាំគ្រាសម្រាប់

ពាក្យ ទៅឲ្យអ្នឥនសៀវនៅឯស្រុកគីដីវ៉ បើអ្នឥនសៀវនឹងអ្នឥនសុតដួបជុំគ្នា
ក៏នឹងមានកំឡាំងច្រើនឡើង សូមឲ្យនឹងទៅកំចាត់ចេញក៏កម្រែកម្រៃ
ហើយណាស់ ការណ៍នេះសូមឲ្យលោកវិនិតកុំឲ្យមនុស្ស ២ នាក់នេះ
ចូលជិតគ្នាបាន ។ ចូឆូបានស្តាប់ក៏ទៅសៀម ។

ឡៅតីមកគិតតែក្នុងចិត្តថា "គ្រានេះបានការស្រួលហើយ ចាំវិនិ
គិតប្រែប្រួលឲ្យផុតពីកណ្តាប់ដៃចូឆូទៅជាមុន ដើម្បីនឹងគិតការតទៅ"
គិតហើយ ក៏ក្រោកឡើងគំនាប់ចូឆូហើយថា ឥឡូវអ្នឥនសុតនាំគ្រប់គ្រួ
នឹងសារពើទ្រព្យរបស់ទៅរកអ្នឥនសៀវហើយ ឃើញថាអ្នឥនសុតគង់នឹង
លើកជម្រើមមកលើស្រុកឈីដីវ៉ ខ្ញុំបាទនឹងសុំនាហានយកអាសាលើកទៅ
វាយស្កាត់កណ្តាលផ្លូវឃើញនឹងបានដោយងាយ ។ ចូឆូឮឡៅតីថាដូច្នេះ
ក៏ត្រេកអរណាស់ហើយថា វេលានេះស្មើរពេលហើយ៎ ចាំព្រឹកស្អែកខ្ញុ
នឹងចូលទៅក្រាបបង្គំទូលព្រះចៅហៀនតេទ្រង់ជ្រាបជាមុន ។ ឡៅតីក៏
លាចូឆូចេញទៅផ្ទះវិញ ។ លុះព្រឹកឡើង ចូឆូនឹងឡៅតីក៏ចូលទៅក្រាប
បង្គំគាល់ ចូឆូយកសេចក្តីក្រាបទូលស្តេចព្រះចៅហៀនតេថា ឥឡូវអ្នឥនសុត
នឹងលើកទ័ពទៅសន្ធប់គ្នាជាមួយនឹងអ្នឥនសៀវ បើឈ្នះទាំង ២ នេះចូល
ជល់គ្នានឹងគ្នាហើយ គង់នឹងគិតការជាធំមាំមួនណាស់ ទូលព្រះបង្គំជា
ខ្ញុំសូមព្រះពជ្ឈានឲ្យឡៅតីលើកទ័ពចំនួន ៥ ម៉ឺន ចេញទៅចាំស្កាត់
វាយកណ្តាលផ្លូវដែលអ្នឥនសុត នឹងលើកធ្វើទៅត្រង់ស្រុកឈីដីវ៉នោះ ។

ព្រះចៅហៀនតេក៏យល់ព្រម ។ ហើយចូឆូទឹងឡៅពីក៏ក្រាបបង្គំលាចេញមក ចាត់ចែងរៀបសេនាទាហានប្រគល់ឲ្យឡៅពីចំនួន ៥ ម៉ឺន ។

ព្រះចៅហៀនតេ ឃើញចូឆូទឹងមន្ត្រីខ្វាក់ដការឯទៀតលាចេញទៅអស់ហើយ នៅសល់តែឡៅពីក៏ទ្រង់ព្រះកន្សែងសោកាហើយត្រាស់ទឹងឡៅពីថា ខ្ញុំមិនឃើញអ្នកឯណាក្រៅ ទឹងនៅឈឺឆ្អាលសម្រាលទុក្ខរបស់ខ្ញុំ ឃើញតែមាម្នាក់ទឹងពីងពាក់ដម្រែះប្រាជ្ញាជួយគិតការតទៅឥឡូវមាចេញទ័ពទៅក្រៅហើយ កាលណាឡើយទឹងបានត្រឡប់វិលមកវិញ ។ ឡៅពីក៏ក្រាបថ្វាយបង្គំលាចាំនក្រៀមក្រំពុំសប្បាយចិត្តទឹកអាណិតព្រះចៅហៀនតេពន់ប្រមាណ លុះបានទៅដល់ជួបទឹងចូឆូ ក៏ប្រគល់ទាហានចាំន ៥ ម៉ឺនឲ្យឡៅពី ហើយឲ្យដូឡៃទឹងឡដៀវ ២ នាក់អមឡៅពីទៅជាមួយ ។ ឡៅពីក៏រកឫក្សពោរជាមង្គល ដល់ពេលហើយក៏លះចូឆូលើកទ័ពចេញទៅជាមួយទឹងគួនអ៊ូតៀវហ៊ុយ ចាកដែនត្រែងហ៊ីគោ ។ ឯតាំងស៊ុនដឹងថា ឡៅពីលើកកងទ័ពចេញទៅ ក៏ស្រែកទៅជួបទឹងឡៅពីធ្វើបីដូចជួនដំណើរកងទ័ព ហើយតាំងស៊ុនក៏ចូលទៅនិយាយទូរឹបទឹងឡៅពីថា ការណ៍ដែលព្រះចៅហៀនតេទ្រង់មានព្រះតម្រាស់ឲ្យយើងរួមគិតគ្នា នោះកុំបីឲ្យអ្នកបំភ្លេចគេចមិនគិតឡើយ ។ ឡៅពីតបថា "ការជាអាថ៌កំបាំងនោះខ្ញុំមិនភ្លេចទេ ខ្លួនអ្នកជាធំនៅកងទ័ពនេះជាក្រាយខ្ញុំ ចូលទំតែរ៉ះហើយទឹងបិទបាំងកុំឲ្យខ្វះខ្វាយ បើខ្ញុំចេញ

ទៅបានតស៊ូការស្លាប់ណា នឹងធ្វើដំណឹងមកឲ្យអ្នកជ្រាប។ ហើយ
កំលាំងស៊ុនចេញទៅ ខ្ញុំស្រួតលើកទ័ពទាំងថ្ងៃទាំងយប់មិនឈរឈប់
សោះ ។

គួនអ៊ូ, តៀវហ៊ុយនិយាយនឹងឡៅតីថា លោកលើកទ័ពគ្រប់
គ្រងមិនដែលស្រួតរួតប្រញាប់ដូចលើកទ័ពម្តងនេះ ដែលលោកខ្ញុំស្រួត
ប្រញាប់ដូច្នេះតើដោយហេតុអ្វី? ។ ឡៅតីតបវិញថា "ខ្ញុំនៅមក
ទៅកងកណ្តាប់ដៃចូឆូចមាដូចជាសត្វបក្សាជាប់ក្នុងទ្រុង ពុំនោះសោត
ដូចជាមច្ឆាជាប់ក្នុងសប ឥឡូវគេបើកលែងឲ្យយើងរួចចេញពីទ្រុងនឹងសប
ហើយ កំរមែងត្រែកអរសប្បាយ ត្រូវខ្ញុំខ្ជាន់កាយ ស្រួតប្រញាប់ឲ្យ
ដល់ទៅទីលំនៅ" ថាហើយក៏ឲ្យគួនអ៊ូ, តៀវហ៊ុយបង្គាបានឲ្យស្រួត
រួតដំណើរទៅ ។

ខណៈនោះ ធៀយ៉ុកនឹងគុយកែដែលចូឆូប្រើទៅនាំស្បៀងអាហារ
ឯស្រុកក្រៅ លុះឮដំណឹងថា ចូឆូប្រើឡៅតីជាមេទ័ពចេញទៅដូច្នោះ
ក៏ភ័យណាស់ ខ្ញុំស្រួតរួតត្រឡប់ចូលទៅក្នុងហ៊ូតោ ចូលទៅដំកំបចូឆូថា
ហេតុម្តេចបានជាលោកបើកឲ្យឡៅតីចេញទៅធ្វើមេទ័ពដូច្នោះ ។ ចូឆូថា
បានជាឲ្យឡៅតីចេញទៅនោះ ព្រោះឥឡូវនេះអ្នួនសុតនឹងលើកកងទ័ព
ទៅសន្ធប់រួមដៃគ្នានឹងអ្នួនសៀវ ដែលឲ្យឡៅតីលើកទ័ពទៅប្រយោជន៍
ចាំស្កាត់ផ្លូវអ្នួនសុត កុំឲ្យឆ្ងងទៅបានត្រង់ស្រុកឈីដីវ ។ (មានត)

រឿងព្រេងប្រទេសឥណ្ឌៀ

អ្នកស្រីស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តមក)

---

ព្រះនាងមានបន្ទូលទៀតថា: "ឧត្តមភរិយាដ៏មានវិជ្ជា, បើសិនជាខ្ញុំម្ចាស់ បានប្រព្រឹត្តអ្វីខុសនឹងសេចក្តីស្នេហាព្រះអង្គ បើសិនជាស្តេចក្តៅចិត្តដល់សេចក្តីសប្បាយរបស់ព្រះពជបុត្រាហើយ សូមតែទ្រង់គិតដល់ករណីយកិច្ចដែលជាធំរបស់ទ្រង់តែប៉ុណ្ណោះទៅចុះ, ពួករដ្ឋមន្ត្រីដែលគិតដល់វាសនាប្រទេសជាតិ គេនៅទីនេះគាំងអស់ ហើយគេមានសេចក្តីបារម្ភជាខ្លាំងណាស់ ដោយគេមិនដឹងជាហេតុអ្វី បានជាទ្រង់ប្រព្រឹត្តព្រះពជចរិយាបែបនេះ, ចុះព្រះអង្គមិនឮសំឡេងរស្តែស្រែកគឹកកងលាន់ឮក្រៃវ៉ៃដូចជាខ្ញុំម្ចាស់ទេឬ? បណ្តារស្តែបៃជ្រៃតគ្នានៅក្រោងទ្វារព្រះបរមរាជវាំង ស្រែកឲ្យគេបើកទ្វារឲ្យ ដើម្បីនឹងមកបញ្ចេញនូវសេចក្តីទោមនស្សរបស់គេនៅចំពោះព្រះភ័ក្ត្រព្រះអង្គ, ទាល់តែដល់ម្ល៉ោះឬទើបស្តេចលះបង់ស្បែងចង្រៃនេះចេញ?" ។ វេលានោះ ព្រះបាទនាលៈមិនឆ្លើយតបព្រះនាងទមយន្តីទេ ទ្រង់ព្រះតម្រិះតែចុះឡុកឡាក់ ។

ព្រះនាងទេមយន្តីទ្រង់យល់ថាព្រះអង្គកំលោះតែហើយ កំទ្រង់យាងត្រឡប់ចូលទៅក្នុងព្រះដំណាក់វិញដោយអៀនអន់ ហើយដាក់ព្រះភក្ត្រជ្រប់ ។

ព្រះនាងទ្រង់បីបមថ្មមព្រះពាជបុត្រទាំងពីរ ហើយមានព្រះបន្ទូលហៅ វរស្ន័យ (Varshneya) ដែលជានាយអស្វបាល ហើយមានព្រះបន្ទូលថា: "វរស្ន័យ! ក្នុងចំណោមអាមាត្យស្តេចទាំងអស់ ឯងជាមនុស្សត្រង់ទង្ហិ ដឹងថា ឯងអាចទុកចិត្តនៃខ្ញុំបាន, ឯងដឹងស្រាប់ហើយ ថាព្រះករុណាជាម្ចាស់មានជោគវាសនាអាក្រក់មកគ្រប់សង្កត់, ទ្រង់ក្រសាលល្បែងក្តាល់ជាមួយនឹងព្រះអង្គម្ចាស់ប៉ុស្ការៈ ដែលជាព្រះអនុជព្រះអង្គ ហើយទ្រង់ចេះតែបាជ័យ, យើងមិនដឹងជាស្តេចអស់ព្រះពាជទ្រព្យប៉ុន្មានទៅសល់ប៉ុន្មានទេ. ទ្រង់មានព្រះទ័យធ្ងន់ធ្ងឹលែងទាល់តែលែងឮពាក្យអង្វរមិត្តសំឡាញ់ទ្រង់អស់, ឯងមិនលែងឮគេនិយាយថា ទ្រង់មិនត្រូវស្តាប់ពាក្យខ្ញុំផងទេ, ចូរឯងកុំស្មានថាខ្ញុំបន្ទោសស្តេច, វរស្ន័យ! ខ្ញុំគ្មានតែជាស្រីបំរើស្តេចប៉ុណ្ណោះទេ ប៉ុន្តែខ្ញុំនៅតែព្រួយបារម្ភ ហើយខ្ញុំមិនចង់ឲ្យព្រះពាជបុត្រព្រះអង្គដឹងរឿងនេះឡើយ, ការវេទនាត្រូវធ្លាក់លើឥតុនឹងម្តាយប៉ុណ្ណោះ, ចូរឯងមើលការខុសត្រូវថ្វាយទ្រង់ផងណា, វរស្ន័យ! ចូរឯងយកព្រះពាជវរណាយ៉ាងមាំ យកសេះណាយ៉ាងលឿន ហើយចូរឯងដឹកនាំព្រះពាជបុត្រា-បុត្រីខ្ញុំទៅឯប្រទេសវិទេកិៈ, ដល់ហើយចូរឯងប្រគល់ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គ ថ្វាយទៅព្រះបិតាខ្ញុំ រួចចូរឯង

ទៅនៅបំរើស្តេចណាដែលមិនដឹងគុណវិល្បង្វក់ឲ្យសុខសប្បាយទៅចុះ" ។

វិរស្ម័យតេទៅរកសេះមកទឹមព្រះពជវជ, ឯព្រះនាងក៏នាំព្រះពជបុត្រទាំងពីរមកជាក់រទេះ ។ ដោយព្រះនាងទ្រង់ព្រះកន្សែងផ្តឹតផ្តក់ខ្លាំងពេក ព្រះនាងអួលណែនព្រះឧរកនឹងមានព្រះទុក្ខារផងពុំបាន ។ វិរស្ម័យធ្វើតាមព្រះសវនីយ៍ បាននាំព្រះពជបុត្រទាំងពីរទៅថ្វាយព្រះបាទកិមៈ ។ ថ្ងៃមួយ នាយសេះក៏បានដំណឹងថា ព្រះចៅក្រុងអយុធ្យាព្រះនាមព្រះបាទ រីតូបនិ: (Rituparna) ទ្រង់សព្វព្រះរាជហឬទ័យត្រូវការរកនាយសារថីដ៏មានថ្លៃដែរ វិរស្ម័យក៏ចូលថ្វាយខ្លួនជានាយសារថីស្តេចនោះទៅ ។

* * *

វគ្គទី ១៩

ព្រះបាទនាល:នៅតែជាប់ព្រះទ័យនឹងវិល្បង លុះកន្លងអំណាចនៃអាទិទេពកាលី ហើយទ្រង់ស្គាល់តែពីចាញ់ដរាប ។ លុះដល់គ្រឿងមាស, ប្រាក់, ត្បូងមុក្តា, ទន្សាន, នឹងព្រះតស្ត្រទ្រង់ បានទៅព្រះអគ្គមាស់ប៉ុស្ការ:អស់ហើយ ព្រះអង្គទ្រង់រង្វេងដល់ទៅហ៊ានលេងជាក់ប្រទេស ហើយទ្រង់ចាញ់ទៀត ។ ក្នុងខណៈនោះ ព្រះអគ្គមាស់ប៉ុស្ការ:មានបន្ទូលទៅកាន់ទ្រង់ ទាំងព្រះសម្រួលផងថា "លុមសូវិល្បង

ប៉ុណ្ណឹងចុះ តើខ្ញុំនៅមានរបស់អ្វីទៀតជាក់ជាបំផុត ខ្ញុំនៅសល់តែព្រះនាងទមយន្តីទៀតទេ" ។ ព្រះបាទនាលៈលុះខ្ញុំព្រះសណ្តាប់ព្រះអនុជមានបន្ទូលដូច្នោះហើយ ព្រះអង្គខ្ញុំក្អាក់ស្មារតីក្រញាងហើយ ស្រាប់តែខ្ញុំវិតក្កមួយរំពេច ។ ព្រះអង្គក៏ខ្ញុំគ្រោកឈរមួយរំពេច ដោយគ្មានព្រះតុង្ការតបទៅវិញសោះ ខ្ញុំដោះព្រះពស្ត្រគ្រវត់ចោលនៅទីនោះ ហើយខ្ញុំមានព្រះអង្គទទេវត់ចូលទៅរកព្រះនាងទមយន្តី ដែលគង់ចាំព្រះអង្គក្នុងបន្ទប់ ។

លុះព្រះនាងយល់ស្តេចយាងចូលទៅដល់ ព្រះនាងក៏មានបន្ទូលដោយព្រះសូរសៀងស្រទន់ថា: "ស្តេចយាងមកដល់ហើយ! ឧព្រះអង្គជាទីស្រឡាញ់ខ្ញុំម្ចាស់ គ្រាន់តែបានឃើញព្រះភ័ក្ត្រខ្ញុំក៏កើតសេចក្តីសប្បាយ, កាលពេលដែលមានជោគជ័យ ខ្ញុំម្ចាស់ស្រឡាញ់ខ្ញុំ, នៅពេលដែលខ្ញុំមានទុក្ខ ខ្ញុំម្ចាស់តែតែស្រឡាញ់ខ្ញុំថែមទៀត" ។ ព្រះបាទនាលៈខ្ញុំព្រះកន្យាឯ, ព្រះនាងជូតទឹកព្រះនេត្រលួងលោមព្រះអង្គ ហើយមានព្រះបន្ទូលថា: "ដោយព្រះអង្គស្តេចយាងមករកខ្ញុំម្ចាស់វិញ គ្មានសំលៀកបំពាក់នៅជាប់នឹងព្រះអង្គដូចជាខ្ញុំកើបនឹងសម្ងោល ខ្ញុំម្ចាស់ត្រូវបីបាច់ថែរក្សាព្រះអង្គឲ្យដូចជាគេថែរក្សាកូនខ្ចី ខ្ញុំម្ចាស់នឹងជួយគាំពារសេចក្តីខ្សោយរបស់ព្រះអង្គ, តពីថ្ងៃនេះទៅ ខ្ញុំម្ចាស់នៅសល់តែកំណាត់សំពត់គំពាំងនេះ ១ ទេ ដែលយើងត្រូវស្ងៀកដណ្តប់

ជាមួយគ្នា ដូច្នេះយើងរីតែរួមគ្នាជិតទៅទៀត" ។ ព្រះចុន្ទនាល: ទ្រង់រំដួលព្រះទ័យពេក ហើយស្រវាឧបព្រះនាងទមយន្តី ។ ទ្រង់យកសំពត់គំរាងមកដណ្តប់ ហើយនាំគ្នាចេញចោលព្រះរាជវាំងដ៏យ ។ ទ្រង់យាងដើរកាត់ទីក្រុង ពួកបណ្តាភស្តុនាំគ្នាមើលលាន់ដោយឋភញ្ជេញសេចក្តីមេត្តា ប៉ុន្តែគ្មានអ្នកណាម្នាក់ថ្វាយដំបូលជូតដល់ទ្រង់សោះ ។ ទ្រង់ចេះតែយាងរហូតដល់ស្រុកវៃស ហើយក៏ទ្រង់យាងតាមផ្លូវមួយលុះដល់ឃប់ទ្រង់ប្រទះឃើញខ្ទមមួយតូច ក៏នាំព្រះនាងចូលឈប់សម្រាកផ្ទំផ្ទាល់ផែនដី ។

* * *

វគ្គទី ២០.

លុះព្រឹកឡើង ព្រះចុន្ទនាល:ទ្រង់តើនមុនព្រះនាង ទ្រង់ទតឃើញព្រះនាងផ្ទំមានព្រះកក្តួញញឹមស្រស់ ព្រះអង្គក៏ទ្រង់ព្រះកន្សែងយ៉ាងខ្ចាំង ។ ដល់ព្រះនាងតើនឡើង ឃើញទឹកព្រះនេត្រព្រះកស្តាព្រះនាងក៏មានបន្ទូលសួរថា: "ហេតុអ្វីបានជាព្រះអង្គទ្រង់ព្រះកន្សែងបើខ្ញុំម្ចាស់សប្បាយចិត្តយ៉ាងនេះទៅហើយ ដោយគ្រាន់តែបាននៅជិតព្រះអង្គប៉ុណ្ណោះ" ។ ព្រះចុន្ទនាល:ទ្រង់មានបន្ទូលតបថា: "ឧព្រះនាងដ៏វិសុទ្ធ ! ព្រះនាងគ្មានកំហុសអ្វីទេ បងបានបំផ្លាញប្រទេស គេមិនព្រមឲ្យយើងជ្រកកោននឹងគេផង បន្តិចទៅទៀតប្រហែលជាយើង

កើតវេទនាដោយឥតអាហារបរិភោគមិនដឹង ចូរប្អូនស្តាប់បង់ឲ្យជាក់ ដ្បិតបង់ជាធំលើប្អូន ហើយជាប្រយោជន៍ដល់ប្អូនទេបានជាបង់និយាយ: ផ្លូវនេះជាផ្លូវទៅប្រទេសវិទេគិ: ចូរប្អូនដើរតាមផ្លូវនេះទៅ ឲ្យសុខសប្បាយចុះ" ។

ព្រះនាង់ធ្វើយថា: " ទេ! ព្រះអង្គមិនឃើញខ្ញុំម្ចាស់ញ័រពន្លត់ ដោយគាន់តែគិតឃើញថា មានមនុស្សកំណាចអាចមកតង្រាត់បង្ក្រាស់យើង ទេឬ? គួរអ្វីឲ្យខ្ញុំម្ចាស់បោះបង់ព្រះអង្គចោលនៅពេលដែលព្រះអង្គកំពុងតែមានទុក្ខ! ខ្ញុំម្ចាស់ត្រូវជាអ្នកលួងលោមព្រះអង្គ នៅពេលណាដែលព្រះអង្គអស់កម្លាំង ដូចជាបណ្តិតតែង់ពោលជារឿយ ៗ ថា: ស្រីជាគ្រួដ៏វិសេសសម្រាប់អ្នកដែលមានទុក្ខធ្ងន់: ខ្ញុំម្ចាស់មិនដឹងជានិយាយអ្វីទូលព្រះអង្គទៀតទេ" ។

ព្រះបាទនាល: ក៏មានបន្ទូលតបថា: " ពិតមែនហើយ សម្រាប់ទុគ្គបុរស គ្មានមិត្តភក្តិ គ្មានគ្រូពេទ្យណាអាចផ្ទឹមនឹងស្រីបានឡើយ! ចូរព្រះនាង់កុំស្មានថាបង់បោះបង់សេចក្តីស្នេហារបស់ប្អូនបាន" ។

ព្រះនាង់ធ្វើយថា: "ម្តេចក៏ព្រះអង្គទ្រង់ចង្អុលបង្ហាញផ្លូវទៅប្រទេសវិទេគិ: ហើយទ្រង់មានព្រះបន្ទូលឲ្យខ្ញុំម្ចាស់ដើរតាមផ្លូវនេះទៅ ហើយថាសូមឲ្យខ្ញុំម្ចាស់បានសេចក្តីសុខ! ខ្ញុំម្ចាស់ដឹងថាព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ហើយ ប៉ុន្តែទ្រង់ខ្វាចខ្ញុំម្ចាស់វង់វេទនា ខ្ញុំម្ចាស់ចង់ទៅឯប្រទេសព្រះវរបិតាខ្ញុំម្ចាស់ដែរ ប៉ុន្តែលុះត្រាតែស្តេចនាំខ្ញុំម្ចាស់ទៅ យើងនឹងនៅជាសុខសាន្ត

ទាំងពីរនាក់ ព្រះវរបិតាខ្ញុំម្ចាស់នឹងទទួលព្រះអង្គដោយមេត្រីភាព ហើយ ព្រះអង្គនឹងគង់នៅជាធំនៅទីនោះផង" ។

- "បងដឹងហើយ ថាព្រះវរបិតាបួននឹងឲ្យបងនៅដោយសុខស្រួល ហើយទុកពាជសម្បត្តិទៃជំដូចជាពាជសម្បត្តិបង ទុកព្រះបរមពាជកាំងទៃជំដូចជា ព្រះបរមពាជកាំងបង ប៉ុន្តែនៅកន្លែងណាដែលកាលពីមុន បងបានបញ្ចេញ មុខដោយពេញកិត្តិយស ទាំងដោយយកសេចក្តីសប្បាយទៅផ្សាយផង នោះ បងមិនយកសេចក្តីទុក្ខ នឹងសេចក្តីខ្មាសទៅបង្ហាញផងទេ" ។

- "បើដូច្នោះ ព្រះអង្គកុំបង្ហាញផ្លូវនេះខ្ញុំម្ចាស់ទៀត ចូរយើងនាំគ្នាដើរទាំងពីរនាក់ទៅ កុំតូញតែអ្នកណាទៀតឲ្យសោះ" ។

ទៃកំយាងកាត់ព្រលឹងចូលព្រៃជាមួយព្រះនាងទមយន្តី ដោយអត់ព្រះស្មូយ ឥតទឹកសោយ ទៃដំណើរដោយដីយកមេយជាដំបូល ។ ចួនកាលព្រះបាទនាលៈទៃព្រះកន្លែង ប៉ុន្តែព្រះនាងទមយន្តីបេះតែញញឹមដរាប។

* * *

(មានត)

ដំណើរអស្ចារ្យនៃលោកកាស្យប៊ីយូយេ

លោកយូកូគុស៊ី រៀបរៀង

# លោកវ៉ាយ-ប៊ុក ក្រមការ

ប្រែពីភាសាចាក់ងមកជាភាសាខ្មែរ

(ត-ចប់ តពីខ្សែលេខ ៥)

---

## កតិអ្នកធំពេ

នៅប្រទេសជប៉ុន, តែងមានបុត្រដែលមានមាតាបិតា ដកហូតយក
ក្តៅមិត្តអស់ ព្រោះកូននោះទៅរៀបវិវាហមង្គលការនឹងស្ត្រី ដែលមាតា
បិតាមិនព្រមព្រៀងសោះ, គេនៅតែរាតបុកណានិយមប្រទេស, ការណ៍
ដែលដកហូតនេះ មកពីបុត្របង្ខិតតាមពួកបណ្ឌិតក្លែងក្លាយ ។
នេះជាផលនៃចំណងធ្វើមិនត្រូវទៅតាមកាលៈទេសៈ ដើម្បីនឹងឲ្យទៅ
កាន់ឋានៈឧត្តមកងដ៏វិសាល ។

មានមនុស្សខ្លះគិតថា ប្រទេសឥណ្ឌាហើយនឹងស្ថានសួគ៌ គឺជា
ប្រទេសតែមួយ ហើយថា ពួកបណ្ឌិតនឹងសត្វទ្វារស់នៅក្នុងព្រៃ ។
កាលណាបើមនុស្សល្ងង់មិនចេះគិតអានសៀវភៅ ដែលគេធ្វាប់និយមយក
ទៅឲ្យរៀនសូត្រនៅសាលាចិន, មនុស្សនោះតែងមានចិត្តចង់ធ្វើត្រាប់តូវ
សាតបុកណា ហើយទុកតូវតែអ្វីទំនើប ឬវត្តដែលកើតនៅប្រទេសជប៉ុន
ថាជាវត្តថោកទាប ដូចអ្នកចែវទូកមិនប្រសប់ឡើងទៅខាងលើស្ទឹង ចែវ
ម្តងទៅមាត់ច្រាំងខាងធ្វេង ម្តងទៅមាត់ច្រាំងខាងស្តាំ ។ ពិតមែនតែបាន

អប់រំជាមុន, មនុស្សបែបនេះបញ្ចេញឱ្យឃើញថាយកវត្ថុពិតថាមិនពិត, សុចរិតទៅជាទុច្ចរិត, ហើយបើបិតាជាអ្នកល្ងង់ខ្លៅផង បិតានោះតែងតែពោលចំពោះបុត្រនូវពាក្យបុរាណ ឬសុភាសិតនៃបណ្ឌិតផ្សេងៗ បន្ទុំដើម្បីទឹងប្រព្រឹត្តទៅតាមទំនើងចិត្តខ្លួន ។ មនុស្សនេះតែងធ្វើគ្រាប់ពួកពាលដែលប្រព្រឹត្តសុទ្ធតែលាមកអប្រិយ, មិនបានប្រព្រឹត្តតាមពួកបណ្ឌិតដែលបំពេញកិច្ចប្រកបដោយអកិដនភាពនឹងសុចរិត ។ គេអាចឃើញញយនូវបិតាមាតា ដែលមិនចូលចិត្តនឹងការសិក្សា ដោយយល់ថាការសិក្សានាំឱ្យកូនក្មេងកាចហើយទុច្ចរិត, តែមានបិតាមាតាខ្លះអាចពិនិត្យនូវការសិក្សា ដោយពិចារណានូវផលល្អ ឬអាក្រក់ជាអវសាន ។

ដូចគ្នានឹងមនុស្សដែលកាន់ច្រឡំ ចំពោះការស្មានទូវសុខភាពរបស់ខ្លួន ដោយហេតុថា មិត្តសំឡាញ់នៃមនុស្សនោះ បានជាសះស្បើយនូវរោគរបស់ខ្លួន ដោយគ្រូពេទ្យបានជាក់ឧសថ, ចំណែករោគខ្លួនឯងក៏ត្រូវប្រើឧសថបែបគ្នា ។ បើបានដំណឹងថា អ្នកជិតខាងឆ្លងទឹកសុខស្រួលសប្បាយ អ្នកខាំងនោះក៏ទៅឆ្លងទឹកដូចគ្នា ។ អ្នកខាំងនោះបរិភោគឧសថដោយស្មាន, មិនបានពិនិត្យឱ្យច្បាស់លាស់, មិនភ្លាយល់ថាសមាសភាពនៃបុគ្គលនីមួយៗផ្សេងគ្នា ដូចជាទ្រង់ទ្រាយមុខខុសគ្នា ។ ការសិក្សាដែលដូចជាឧសថដដែល, មិនអាចយកទៅអប់រំឬបរិភោគបានគ្រប់ៗគ្នាទេ ។

* * *

## ៥.— ដំណើរទៅកាន់សុញ្ញប្រទេស

**Pays de desolation)**

លោក ក៏សូប៊ីយូយេ មិនទាន់ឆ្ងាយពីចាន់ដើរនូវផ្លូវដែលជាប់ពី "ឫកណានិយមប្រទេស" ដោយហោះហើរលើអាកាសមានផ្លូវឆ្ងាយជាច់ស្រយាល ។ ហោះចម្ងាយប្រាំបីពាន់យោជន៍, លោកបានឃើញភូមិភាគមួយដ៏ធំទូលាយ ហើយដល់លោកចុះមកដល់ដី, ទើបមានគេប្រាប់ថា ភូមិភាគនេះ គេហៅថា សុញ្ញប្រទេស ។ លោកបានអញ្ជើញទៅពំនាក់អាស្រ័យ នៅគេហដ្ឋានលោកមូកុសង៉ីយ: (mokuzenya), ទីប៊ីកាម៉ាចិ (Chikamachi) ។ វត្ថុជាបឋមដែលប្លែកជាងគេគឺមនុស្សតាំងអស់មានប្រហោងនៅកន្ទងដើមទ្រូង ជាហេតុឲ្យពួកមន្ត្រីធំៗអាចយកមនុស្សតាំងនោះ ទៅប្រើជាយានដំនិះបាន ។ មនុស្សតាំងអស់នោះ មានប្រាថ្នាចង់ចេញឬ? អ្នកតាំងនោះ ហៅថាសាពីរនាក់មកយកជង្កែកស៊ីកន្ទឹងប្រហោងដើមទ្រូង ហើយអ្នកតាំងអស់ក៏ឡើងទៅណាតាមប្រាថ្នា ។ ចំណែកខាងបិតាមាតាក៏បាននាំកូនទៅយកឲ្យលាអាកាស ដោតន្ទឹងជង្កែកដូចគ្រឿងក្នុងប្រអប់ ។ បើគេត្រូវការលោកគ្រូពេទ្យមកមើលពេត មានមនុស្សដែលមានកម្ទាំងមាំមួនទៅយកលោកមកដោយដោតជង្កែកទៅក្នុងប្រហោងដើមទ្រូង ហើយក៏យកជង្កែកនោះដាក់លើស្មានាំមក ។ បើតាមពិត ប្រហោងដើមទ្រូងនោះជាការធ្វើឲ្យស្រួលកន្លែងកិច្ចគ្រប់យ៉ាង, តែវត្ថុអ្វីដែលវិសេស គង់មានគុណវិបត្តិ ។

អ្នកប្រទេសនោះ មិនស្គាល់ច្បាប់ទឹងសាសនាតាំងពីបូពណាសម័យ
មកឡើយ, វៀរលែងតែព្រះពុទ្ធប្រកាសមួយដែលហាមប្រជាជន មិន
ឲ្យអានសៀវភៅទឹងសិក្សាខាងទំនៀមទម្លាប់បុពណា ។ មនុស្សម្នាក់ៗ ធ្វើ
ការតាមទំនើងចិត្តហើយមិនមានអ្នកណាស្គាល់ការខុសត្រូវសោះឡើយ ។
ក្បាច់សិល្ប.នៃគេហដ្ឋាន, របៀបកាត់ត្រឹងសំលៀកបំពាក់ហើយទឹង
អាកប្បកិរិយាប្រែប្រួលជានិរន្តរ៍ ហើយប្រជាជនសាកសួរតែរឿងការដែល
យើញទឹងក្បែកប៉ុណ្ណោះ ៖ ពួកនេះគ្មានគោរពគ្នាទៅវិញទៅមកទេ ។
ទាសាម្នាក់អាចពោលបានថា ‘ម្ចាស់ខ្ញុំគឺជាមនុស្សដូចខ្ញុំដែរ ហើយ
ដែលខ្ញុំបំរើគាត់ក៏ព្រោះគាត់ចិញ្ចឹមខ្ញុំ” ។ កូនប្រុសអាចពោលបានថា
“ខ្ញុំមិនបានសុំបិតាមាតាមកកើតទឹងគាត់ទេ, គឺបុព្វហេតុមកពីគាត់ចាំង
អស់ ព្រោះហេតុដូចនេះ បានជាគាត់មិនមានសិទ្ធិដេរស្តីបន្ទោសខ្ញុំទេ” ។
កិរិយាមិនស្តាប់បង្គាប់ស្វាមីទេ ហើយបុរសដ៏ទឹងដែលមានកម្លាំងមាំមួន
មិនមានចិត្តរួញរាត្រង់ការឈ្លោះទាស់គ្នាទឹងបងប្អូនរបស់ខ្លួន ។ អ្នក
កម្លាំងជាងគេទឹងមានវ័យក្មេងជាងគេ អាចបានបរិភោគអាហារដ៏ប្រសើរ
ទឹងស្ងៀកពាក់ខោអាវល្អអស្ចារ្យ ។ សុញ្ញប្រទេស ជាប្រទេសវិសេស
វិសាលជាបំផុតរបស់អ្នកចាំងនោះ ។ តែជនណាដែលចាស់ជរាត្រូវតែគេ
ដេញចេញពីគេហដ្ឋាន ។ ជនចាស់ៗស្ងៀកពាក់ខោអាវចាស់ៗ ហើយ
បរិភោគនូវអាហារជាមធ្យមតែងយល់ថា ប្រទេសនេះជាភូមិភាគកងទ័ពក

លោកមួយដែលមានសកាពលាមកជាងគេ, ហើយគួញក្បែរចំពោះការគ្មានកតញ្ញូនៃបុត្រ ។

លោក ហ៊ាសូប៊ីយូយេ បានស្តាប់ពួកគេនិយាយទៅទីក្រុង នាគសគី (Nagasaki) អំពីប្រទេសមួយដែលស្វាមីកើតទុក្ខព្រោះប្រពន្ធមានគភ៌ ។ ដូចជាមានការណីយ៍នៅសុញ្ញប្រទេស, នាយកោជនាគារម្នាក់គួញក្បែរថាការិយារបស់ខ្លួនមានគភ៌ជិតគ្រប់ខែហើយ ជិតប្រសូតបុត្រ ។ ឯនាង៏ជាការិយាដើរទៅមកជូចសត្វមួយដង៏ផង់ខ្យៅ. ស្តីឲ្យស្វាមី ហើយបន្ទោសស្វាមីថា "មិនមែនជាអង្គប្រុស" ហើយមិនចេះចប់ចេះសោះ, នាង៏ពោលថា "បើខ្ញុំមានគំនិតខ្លី ដូចជាស្វាមីខ្ញុំ។ មុខជារង៏ចាប់គ្រោះវហួតដល់មរណភាព" ។

ស្វាមីនោះបានឆ្លើយតបចោទប្រកាន់ប្រពន្ធវិញថា "ហ៊ាមិនអាណិតអាសូរចំពោះការព្រួយលំបាកអញសោះ" ហើយកំញើញគំរាមប្រពន្ធចង់លែងលះចោល ។ នាង៏ជាការិយាក៏យល់ព្រមលែងលះ តែដល់ប្រសូតបុត្រហួចក៏ត្រឡប់ជាសុខស្រួលនឹងគ្នាទៅវិញ ។

លោក ហ៊ាសូប៊ីយូយេ ក៏ចេញចាកប្រទេសនេះ ដោយចិត្តកែកយ ហើយដឹកក្រសាហោះទៅកាន់ទីឯទៀត ។

## កតិអ្នកឯពទ្ធ

គឺជាការខុសស្រឡះ ត្រង់ដែលមានមនុស្សខ្លះយល់ថា មនុស្សនឹង៏សត្វតិរច្ឆានមានសកាពផ្សេងគ្នា, បុគ្គលដែលមានគំនិតខ្លី ប្រព្រឹត្តតាម

សេចក្តីថ្នាក់ថ្នមរបស់ខ្លួន ហើយក្មេងសាសនាដែលប្រៀបមនុស្សដូចគ្នានឹងសត្វតិរច្ឆាន ។ គោគ្រាន់ធ្វើឲ្យមនុស្សពោរពេញលន់ពន់ប្រមាណ ហើយមនុស្សនោះសប្បាយចិត្តពន់ពេក បើគ្មានអ្នកណាបានរកឃើញ នូវការប្រព្រឹត្តិលាមករបស់ខ្លួន, ដូចជាចចកដែលមិនមែនពុំស្គាល់អន្ទាក់ឬអន្លង់ប៉ុន្តែ, តែយល់ថាអញនឹងពិសោធន៍មើល ត្រង់ការអាស្រ័យចំណីនៅក្នុងអន្លង់កុំឲ្យមានគ្រោះថ្នាក់ ។ ជីវភាពរបស់មនុស្សត្រចត្តួចស្តួចស្តើងណាស់ ហើយមិនច្បាស់ប្រាកដ តែកម្មកាពចំពោះមនុស្សតែងបានផលអាក្រក់ល្អ ចួនកាលមកដល់ពេលក្រោយក៏មាន ។ បើតាមការសង្កេតភ្លាម, ដូចជាមិនសមរម្យសោះចំពោះមនុស្សដែលមានជីវភាពប្រកបដោយជោគវាសនាល្អ ត្រឡប់ទៅជាគិតអនាគតខ្លុកជាមុនទៅវិញ ។ តែមនុស្សដែលនៅសុញ្ញប្រទេសសប្បាយចិត្តតែនឹងពេលវេលាមិនខ្វែង, តែលែងគិតចំពោះអនាគតរបស់ខ្លួន ។ មិនមែនគ្រាន់តែកេគទេដែលនាំមកនូវទុក្ខគ្រប់យ៉ាងនឹងសេចក្តីលំបាកគ្រប់បែបគឺចិត្តជាម្ចាស់ទៀតក៏នាំមកនូវទុក្ខដែរ ។ គេត្រូវតែមានចិត្តស្មោះស្ម័គ្រមិនត្រឹមតែនាយចៅហ្វាយ, បិតាឬបង្កើតរបស់ខ្លួនទេ ថែមរហូតទៅដល់មនុស្សក្នុងពិភពលោកទាំងមូល ។

*
* *

## ៦.— ដំណើរទៅកាន់ប្រទេសយក្ខ

(Pays des Géants)

ពិតមែនតែលោក ភ័ស្ចប៊ីយូយេ បានធ្វើដំណើរទៅកាន់ប្រទេសជាច្រើន លោកនៅតែមានថាមកាពមិនចេះអន់ថយសោះឡើយ, លោកនៅតែមានបំណងខ្លាំងក្លាចង់ធ្វើដំណើរតទៅទៀត ។ លោកតាំងចិត្តថានឹងតម្រង់ទៅកាន់ស្ថានសួគ៌ នៅខាងបស្ចឹមប្រទេស ដែលព្រះពុទ្ធគង់នៅ ។ លោកបានឆ្លងកាត់សមុទ្រខាងត្បូង ។ ក្រសានោះហើរយ៉ាងលឿនចម្ងាយប្រាំមួយរយពាន់យោជន៍ក្នុងមួយថ្ងៃ ហើយហើរក្នុងរយៈវេលាបីខែ ។ រស្មីព្រះអាទិត្យអន់ថយចុះតាមលំដាប់, ហើយដល់ខែដប្រាំទៅជួបប្រទះនឹងឆាងឆឹតអន្ធការពេញលក្ខណៈ តែលោកជ្រាបថាលំដាប់តពីប្រទេសដែលគ្មានពន្លឺព្រះអាទិត្យព្រះចន្ទ មានប្រទេសមួយទៀតថ្មី ហើយលោកក៏បង្ខំក្រសានោះឲ្យហោះកាន់តែលឿនឡើង ។ តើលោកនឹងក្រសាដែលឆ្លងកាត់ប្រទេសងងឹតនោះ អស់រយៈវេលាប៉ុន្មាន គ្មានអ្នកណាអាចដឹងបាន ដោយថ្ងៃនឹងយប់លាយលំគ្នានៅប្រទេសនោះតែចន្ទិចខែតមានពន្លឺចេញពីខែមួយថ្ងៃក ហើយដល់ខែដប្រាំបួន លោកអញ្ជើញទៅដល់ប្រទេសមួយទៀតថ្ងៃកអស្ចារ្យ ។ លោកក៏លោតចុះពីក្រសាអញ្ជើញទៅសម្រាកកម្លាំងនៅកន្លែងព្រៃឫស្សី តែព្រៃឫស្សីនោះដល់ពិនិត្យឲ្យច្បាស់ទៅជាមានសភាពជាដើមស្រូវសាលីទៅវិញ ។ រីឯតាំងអស់នៅក្នុងប្រទេសនោះ មានសភាពធំអស្ចារ្យ ដើមពិស្សធ៌លិស

(Pissenlis) មានទ្រង់ទ្រាយកំពស់ទទឹងជនជាតិជប៉ុនដ៏ធំ ។ កាលណា លោកបានឃើញគេហដ្ឋានធំសម្បើមអស្ចារ្យ, ត្រពាំងទៅជាបឹងធំ គំនរ សម្រាមដូចជាភ្នំហ្វូជី (Fuji), លោកគិតស្មានថា លោករចនារូបលោកឲ្យ តូចទាប ដោយវិចារណញ្ញាណកំចាំងដែលគ្មានអ្នកណាអាចមើលយល់ បាន ។ តែមិនជាអ្វីទេ ។ មានមនុស្សប្រុសស្រីធំសម្បើមអស្ចារ្យជា ច្រើនពួកបានឃើញគាត់នៅទីនោះ ។ មានយក្ខមួយបានចាប់លោកយក ទៅហើយយកលោកទៅដាក់ក្នុងបាតដៃវ៉ា រួចសួរលោកថា អញ្ជើញមក ពីណា? ហេតុម្តេចក៏បានជាទាបតូចត្រឹមម្ល៉េះ? ។ លោកឆ្លើយតបទៅយក្ខ វិញថា លោកមកពីប្រទេសជប៉ុន ហើយបើទុកជាយក្ខនោះប្រមាថលោក ដោយលោកមានទ្រង់ទ្រាយទាបតូច, តែយក្ខកោតខ្លាចលោក ដោយ ឃ្លោកមានប្រាជ្ញាឈ្លាសវាងវៃ ។ ពួកយក្ខក៏នាំគ្នាសើចខ្លាំង តែ លោកឥតភ័យតក់ស្លុតទេ ។ មានយក្ខមួយនាម "សាស្ត្រាចារ្យ វិទ្យាសាស្ត្រសុខុម (le Professeur Science Profonde)" បានយកលោក មកកាន់ទីឯបាតដៃ ដូចជាគេរកចាប់អំពិលអំពែកមួយហើយក៏នាំលោក យកទៅឯគេហដ្ឋានរបស់គេ បានជូនលោកតាំងទូរ្គាប់ចាយមួយធំ ប្រហែលទឹងថ្មែកឥឡូវ ។ លោក ប៉ាស្ចូប៉ីយូយេ ឃើញខ្លួនលោក ប៉ុនកូនចាប ។

ដំណឹងនេះ ក៏ផ្សាយខ្ចរខ្ចាយទៅគ្រប់ទិសទាំងមជ្ឈបទថា មានសត្វមួយ ថ្មែកមកដល់ទីនេះ, មានយក្ខជាច្រើនមកមើល លោកប៉ាស្ចូប៉ីយូយេ,

លោកបានធ្វើឲ្យយក្ខទាំងនោះពេញចិត្ត ដោយលោកប៉ុនប្រសប់ខាងពាក្យពាក់ព័ន្ធពេក ។ លោកបានព្យាយាមធ្វើអាកប្បកិរិយាលោកដូចជាអ្នកសប្បាយចិត្ត ហើយត្រមៃឆ្ងល់, បើលោកប្រកែកនឹងមានគ្រោះថ្នាក់ធំតទៅអនាគត ។ លោកបានយល់ឃើញថា ការប្រតស្រូវសម្បូណ៌ពន់ពេក ហើយមានសព្វឆ្នាំឥតមានខានឡើយ តែលោកចំស្រាវជ្រាវចំពោះយក្ខទាំងនោះ នូវស្មាមគំនូសនៃការសិក្សាផ្សេងៗ អំពីច្បាប់, សាសនា, សច្ចធម៌, មនុស្សជាតិនោះគ្មានសោះឡើយ ។ សូម្បីតែនាមឈ្មោះដោយបោរីកាព ត្រមទាំងមនុស្សធម៌, គុណាការក៏គ្មានដែរ ។ យក្ខប្រុសឆ្លើតឧកាសទៅក្លែងស្រែ យក្ខស្រីនៅគេហដ្ឋានរវល់ដេរនឹងត្បាញវែ ។ ប្អូនកាលយក្ខទាំងនោះនាំគ្នាមកជួបជុំហើយជជែកគ្នា តែមិនបានទាស់ខែងនឹងគ្នាទេ ហើយរឿងរ៉ាវដែលពោលទាំងប៉ុន្មានគ្មានខ្លឹមសារ ។ លោក រ៉ាសូប៊ីយូយ យល់ថាយក្ខទាំងនេះមានប្រាជ្ញាតិច ហើយពិតមែនតែលោកទាបតូចជាង លោកអាចបង្ហាញនូវផ្លូវពិតនៃជីវភាព ត្រមទាំងបំភ្លឺនូវច្បាប់ផ្សេងៗ ឲ្យយក្ខទាំងនោះស្តាប់បាន ។ មានកាលមួយថ្ងៃ, ពួកយក្ខទាំងអស់នោះ បានមកសួរលោក។ មានប្រសាសន៍ថា· ពិតមែនតែលោកកើតនៅប្រទេសជប៉ុន, តែលោកបានធ្វើដំណើរទៅគ្រប់ប្រទេសក្នុងពិភពលោក ហើយលោកបានស្គាល់ទំនៀមទម្លាប់ នឹងករណីយកិច្ចនៃយក្ខប្រុសទាំងនោះ ។ "អ្នកឯងនៅ

ប្រទេសដ៏ធំទូលាយមែនពិត, តែអ្នកឯងមិនស្គាល់នូវមនុស្សធម៌សោះឡើយ ។ នៅប្រទេសចិន បណ្ឌិតកុង-ហ្វូ ស៊ី, ឧទ្ធមឆង-ស៊ី លោកបានបង្រៀននូវមនុស្សធម៌, នៅប្រទេសឥណ្ឌា ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ព្រះអង្គបានបង្ហាញនូវមនុស្សគ្រប់គ្នា នូវលទ្ធិផ្លូវសួគ៌និងនរក, នៅប្រទេសជប៉ុន យើងបានឃើញនូវទេវតានិងនាគទេពធីតាជាច្រើន ។ អ្នកណាដែលមិនស្គាល់មនុស្សធម៌ អ្នកនោះជាមនុស្សហីន-ជាតិពាលទុច្ចរិត" ។ លោកបានថ្លែងពីពេះជាឯគេដូចពួកវ៉ាគិន, បើខ្លួនជាព្រះពុទ្ធរូបក៏គង់នៅស្ងៀមមិនបាន មុខជាឆ្លើយតបមិនខាន; តែពួកយក្សដែលស្តាប់ទាំងប៉ុន្មានគ្មានរំកើបអ្វីឡើយ ។ មានយក្សម្នាក់នោះបានឲ្យពរសព្វសាធុការ នូវម្ចាស់គេហដ្ឋានដែលបុិនប្រសប់កេឃើញនូវវត្ថុអ្វីប្លែកជាងសុទ្ធ ដែលមានប្រាជ្ញាព្រមទាំងវត្ថុសើចលេងកំសាន្តសប្បាយជាងបក្សាសេកទៅទៀត ។ ការដែលបពជ័យចំពោះសុន្ទរកថាដែលសូត្រនេះបញ្ជាក់ឲ្យឃើញថា អ្នកស្តាប់ទាំងប៉ុន្មានជាពួកលង់ខ្លៅដោយពិត, ប្រៀបដូចជាយកម្ទេលទៅចាក់ចាវ ដែលពេញទៅដោយកន្ទក់ ឬស្វែងកេដែកដែលក្តៅយកទៅជុតដី ។

ដល់អវសាន, លោកបានដំរាបទៅម្ចាស់គេហដ្ឋានថា "នៅប្រទេសគេឯទៀត ពិតមែនតែតូចជាងប្រទេសនេះ តែគង់តែបង្ហាញចំពោះប្រជាជនទូវផ្លូវត្រឹមមួយ (មគ្គសច្ចឬ វិសុទ្ធិមគ្គ) សម្រាប់ឲ្យប្រតិបត្តិតាម,


គេបានពាល់អំពីនាក់ទៅញ្ញាជន ឬជាគុណសម្បត្តិប្រាំយ៉ាងសំខាន់ៗ (យុត្តិធម៌, អប្បមាទធម៌, មត្តញ្ញុតា គឺការដឹងប្រមាណ នឹងពលភាព), គេមានច្បាប់ដែលទុបត្តម្ភអ្នកទុពលភាព; នៅប្រទេសដែលល្ងង់ខ្លៅដូចប្រទេសនេះ គុណសម្បត្តិទាំងលើនេះគ្មាន, ដោយហេតុថា ខ្ញុំបានមកដល់ទីនេះ, ខ្ញុំពិសោធន៍ចង់បង្ហាត់បង្រៀនពួកនេះឲ្យចេះដឹងខ្លះ, តែមិនបានសម្រេចដូចបំណងឯ'' ។

អ្នកម្ចាស់គេហដ្ឋានញញឹម តែឥតមានឆ្លើយតបអ្វីសោះឡើយ ។ តែមានគេមកសួរបញ្ហាចំពោះអ្នកម្ចាស់គេហដ្ឋាន ។ ក៏ពោលថា - 'អ្នកប្រហែលជាមានប្រាជ្ញាគាន់បើ ហើយប្រហែលជាលោកអាចយល់នូវសេចក្តីដែលខ្ញុំនឹងអធិប្បាយដំណាមជូនដូចតទៅនេះ ។. មនុស្សឆ្លាយពិចារណាយល់នូវមនុស្សគួច ។ ល្ងាកនឹងយល់មនុស្សឆ្លាយ ។ សូម្បីតែក្មេងនៃប្រទេសនេះ ស្គាល់ដោយសុក្រិតនូវចិត្តគំនិតអធ្យាស្រ័យរបស់អ្នក ។ មនុស្សណាដែលជាអ្នកប្រាជ្ញថ្នាក់ខាងច្រើនយល់ថា អ្នកប្រាជ្ញថ្នាក់ខ្ពស់ល្ងង់ជាងខ្លួន ។ នៅមជ្ឈដ្ឋានចំពោះខ្លួនអ្នក។ យល់ថាមជ្ឈដ្ឋាននោះមានប្រាជ្ញាជាងគេ ។ ហេតុម្តេចក៏មនុស្សមានប្រាជ្ញាតិចតួចស្តួចស្តើងបែបនេះ យល់នូវប្រាជ្ញាដ៏ធំទូលាយនៃអគ្គបណ្ឌិត ដែលស្គាល់ពីដើមហួតដល់ចុងនោះកើត ។ អ្នកដែលមានចំណេះជាន់ខាងស្គាល់ចំពោះតែបុព្វហេតុនៃវត្តុតាងឯណាយ ។ ព្រោះហេតុដូចនោះបានជា

ធម្មជាតិវេទនាឲ្យមានកើតបណ្ឌិតជាច្រើន ដើម្បីនឹងណែនាំអ្នកដែលគ្រាប់ទៅកាន់ផ្លូវរបស់ខ្លួនឲ្យមកកាន់ផ្លូវត្រង់វិញ ប្រៀបដូចជាបិតាមាតាដែរបន្ទោសបុត្រធិតា ។ ទុក្ខនៃបណ្ឌិតទាំងនោះមានប្រយោជន៍ចំពោះមនុស្សតូចតែម្យ៉ាង ទុក្ខគឺជាប្រអប់មួយដែលគេប្រមូលមនុស្សតូច ។ ជាក់ក្នុងប្រអប់នោះ ។ មនុស្សតូចទាំងនោះ ទំអំពាវនាវនូវទុក្ខផ្សេង ។ តែមិនអាចឃើញអ្វីពីក្រៅសោះឡើយ, តែមនុស្សធំអាចមើលឃើញស្គាល់ខាងក្នុងប្រអប់ ហើយពិចារណាពីខាងក្រៅថែមទៀត ។ អ្នកឯងគេឃុំឃាំងនៅក្នុងប្រអប់ពិភពលោក ហើយអ្នកឯងមិនអាចដឹងនូវបរលោកទៀត ។ អ្នកឯងអានសៀវភៅដូចជាក្មេងនិយាយមិនច្បាស់ ។ ព្រោះតែកង់ពិភពលោក, មនុស្សសុទ្ធតែតូច ។ ហើយច្បាប់ក៏តិច, មានច្បាប់បទបញ្ញត្តិសុភាសិតដែលយើងមិនត្រូវការ ។ នៅក្នុងប្រទេសយើង, មនុស្សនៅទីនេះបានទទួលព័ត៌មានូវច្បាប់ដ៏ធំធេងយ, មនុស្សទាំងនេះមិនដែលប្រព្រឹត្តនូវបាបអកុសលអ្វីឡើយ, តើយើងត្រូវការមនុស្សធម៌, យុត្តិធម៌, ចោរភាពនឹងក្បួនច្បាប់សុភាសិត ហើយនឹងសាសនាមកធ្វើអី អ្នកឯងយល់ទេដែលយើងពណ៌នាជំរាបនេះ រ៉ាស្ទូប៉ីយូយេ !" ។ អ្នកម្ចាស់គេហដ្ឋានពោលជាអរសានតែប៉ុណ្ណោះ ហើយខ្លួនលោករ៉ាស្ទូប៉ីយូយេ កុំឲ្យអួតអំពីច្បាប់ជារបស់លោក ហើយចូរលោករស់នៅដោយសេចក្តីសុខស្ងៀមចុះ ។

លោក ក៏សូបីយូរយ ដល់ចានឮសព្ទក៏ចានៃអ្នកម្ចាស់គេហដ្ឋានដូច នេះ, ក៏មានចិត្តអៀនអន់ពេកហើយកោតខ្លាចលោក "វិទ្យាសាស្ត្រសុខុម" ជាអនេក ។ លោកយល់ថា ចំពោះយោបល់ល្ងង់ខ្លៅមនុស្សតូច, នឹង សេចក្តីយល់ឃើញដ៏ធំទូលាយនៃមនុស្សធំ គ្មានត្រូវដែនទេ ។ រួចលោក ក៏ឡើងដំរែកសារលែតឡប់មកកាន់ប្រទេសជប៉ុនវិញ ។

ចប់



ដំណឹងតាមខ្សែក្នុងកន្លែង:

# លោក ផេង-ជ្រឿ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

## ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តមក)

---

សម័យនោះ វាលខ្នង់ភ្នំឡើងពណ៌ខៀវត្រមៃ ថ្កុំថ្កាំងឡាយ ត្រឡប់មានពណ៌ពព្រក់, ឯណោះ ខាងនាយឆ្ងាយបន្តិច ពន្លឺព្រះអាទិត្យ ចាំងត្រូវសំពត់ដំរីដែលក្លាយពណ៌ទៅជាត្រហមដូចមាស ។

ធីតាចាំងពីរនៅឈប់ស្ងៀមមួយស្របក់ ។ ការណ៍ដែលបានប្រទះ ហេតុមិនបានជាគិតនេះ នាំចាននារីបងប្អូនទៅកងអន្ទង់ គឺសេចក្តីវិតក្ក មិនចេះក្ងេច តែដែលនឹកជាងគេគឺនាងឡីឡា ។

កាលណានាងនឹកដល់រឿងត្រែង ដែលភ្ជាប់បានស្គាប់ពីក្មេងអំពី ព្រះអគ្គមាសដែលនាងជាប់ចិត្ត នាងមិននឹកអ្នកណាដទៃក្រៅពី អ៊ីស្មាអ៊ីល ឡើយ ។ នាងស្រមៃឃើញមុខ ឃើញភ្នែកភ្លៅល្អក់ ព្ភសំដីតឹងបែប ពីរោះនឹងសុះសុ ស្ថិតនៅក្នុងចិត្តជាធម្មតា ។ រូបអ៊ីស្មាអ៊ីលដែលបាន ពោលពាក្យជំពីរោះទៅរកនាង ដែលបានសំដែងសេចក្តីគោរពដល់ នាងជាស្ត្រីកំសត់ក្រៃតែពពែ នាងគ្មានក្ងេចទេ នាងរក្សាសេចក្តីលឹក ទុកនៅខាងក្នុងដួងព្រលឹងរបស់នាង ។

នាងហួចស្រែកហៅពពែ ហើយពីរនាក់បងប្អូនដើរប្រកិតគ្នា នាង ឡើងកាន់ផ្លូវឆ្ពោះតម្រង់ទីសំណាក់អាស្រ័យ ។ មានអ្នកជិះសេះពីរនាក់

ពួនទៅនឹងដើងកំមួយ លបមើលនាង ។ មិនបានជាឃើញ ។ គេស្រែក ពាក់ជាអាក៉ាប់ សំលៀកបំពាក់ព្រមទាំងគ្រឿងប្រដាប់សេះសឹងតែវត្ថុមានតម្លៃ អាចប្រាប់ឲ្យដឹងថាជាពួកអ្នកត្រកូលខ្ពង់ខ្ពស់ ។ លុះយល់ថានាងដើរកាន់តែជិតទីសំណាក់ហើយ ។ អាចស្តាប់ឮសូរសំដីអ្នកដំរែមកដល់ អ្នកជិះសេះក៏ព្រមគ្នាបង្ខូវកាត់ប្រញាប់ដើម្បីឲ្យជួបនឹងនាង ។

ប្រហែលជានាងឮសូរដើងសេះផាយមកពីក្រោយ ឬមួយជាដោយសារពេលដឹតយប់បានជានាងក្រមុំតែប្រញាប់ ។ គ្រាន់តែអ្នកជិះសេះមកដល់ផ្លូវបំបែកនាងទាំងពីរនាក់ចូលក្នុងជំរុំផុត គេក្រឡេកឃើញតែស្រមោលមួយភ្លែត ។ អ្នកជិះសេះមុន ស្រែកដេរសេះ ហើយរាយសេះគាល់ហោះដើងពីរដើងបី ចំណែកអ្នកម្នាក់ទៀតគិតតែពីសើច ។

អ្នកជិះសេះមុនស្រែកថា: "អញស្មានក្តៅចិត្តអស់យ៉ាង" ។

គេតាំងរាយសេះបរបំផាយតាមផ្លូវកាត់ បត់ចូលដល់ជ្រុងទីសំណាក់របស់ជំនាងដែលទើបនឹងចូល ។

គេលោតចុះពីលើសេះភ្លាម ។ គូកនគេក៏ចុះដែរ ប៉ុន្តែក្នុងឧកាសដែលអ្នកទីមួយស្ទុតកាំបិតស្ទៀតចេញពីស្រាម ហើយបើកសំពត់ជំរំនឹងចូលតាម, អ្នកទី ២ ស្ទុះមកឱបទាំងត្រចៀកថាគ្មានជនណាមានសិទ្ធិត្រូវប្រើបទកំហែងក្នុងទីលំនៅអ្នកដទៃទេ ! ។

អ្នកទី ១ លោបែបទ្រឹង ហើយបញ្ចេញអាការមិនសប្បាយចិត្ត ក៏
ត្រឡប់សិតកាំបិតទៅក្នុងស្រោមស្បែកមានដាំសុទ្ធតែត្បូងវិញ ។
ខណៈនោះ ជនពាំងពីរបានឮកូនពពែយំនឹងសំណើចនៃនារីពីក្នុងដំរំ
មកហើយ គេហាក់ដូចជាឆ្កាប់បានឮសំឡេងបែបហ្នឹងដែរ ។

បុរសទី ១ ទះទ្រូងហើយថា: អញសំណាងអាក្រក់ណាស់, សំណើច
នេះនាំឲ្យអញចង់ឆ្កួត, ពីព្រឹកមិញ អញបានច្រៀងសំណើចបែបហ្នឹង
កាលដែលនាងទៅងូតស្រាតនៅក្នុងជ្រោះ, រៀបសើចបែបហ្នឹង, អញ
ស្គាល់ច្បាស់ណាស់ ខឿនជានាងហ្នឹងហើយ រួមហ្អណាស៎! ។

គេឈរដាក់មុខដ្រាប់ចុះដូចតាំងសមាធិ ខាងស្រូបយករូបសម្បត្តិ
នាងឡីឡាដែលបានឃើញពីថ្ងៃមុន ។ លុះឈរពីរ៉ឹងយូរទៅ គេនឹក
ឃើញសព្វ គឺស្មាសាច់ពេញហើយមាំ កមូលស្អាត ស្ពានឡើងក្បាំ
មូលដូចបទុមបុប្ផាមិនខានរីក ទឹកដៃជាំៗយ៉ាងថ្លាហូរស្រោចពាសពេញខ្លួន
នាកណ្តាលថ្ងៃ នាងមិនដឹងជាគេលបមើលហើយបញ្ចេញអាការៈដ៏ទន់
ល្អន់ល្អាស ដូចកូនឈ្លូស ពត់ចុះពត់ឡើង ចំពោះធម្មជាតិ ។ ហើយ
គេនឹកដល់រូបនាងខាងក្នុង នៅព្រហ្មចារីយ៍ មិនដឹងជាស្អាតយ៉ាងណា
ម្ល៉ោះហើយសេចក្តីតម្រេកវិតតែកើតឡើងជាខ្លាំងក្លា រួចគេប្តេជ្ញាក្នុងចិត្ត
ថានឹងយកនាងហ្នឹងឲ្យបាន ។ ហើយគេដកដង្ហើមធំ ។

ឃើញដូច្នោះ គូកនគេយកដៃទៅគោះឲ្យដឹងខ្លួន ហើយស្តីឲ្យថា: កុំឆ្គត! ហេតុអ្វីក៏ធ្វើឲ្យខាតពេលវេលាព្រោះតែតាមនាងនេះ? ចូរសំឡាញ់ថាឲ្យត្រង់មកមើល បើប្រសិនជានាងហ្នឹងមក តើជាគាប់ប្រសើរយ៉ាងណា? នាងនេះជាស្ត្រីកំសត់ដើរទេសទេតើ! បើសំឡាញ់ចង់បាន មិនចេះខ្វះទេ គគោកបែបហ្នឹង! ។

គេបើកក្បាលៈឡើង អ្វីក៏មិនថា ។

សំឡាញ់បេះគេមិនយល់ថា សេចក្តីតម្រែកវុកពនន្ទ្រានក្នុងសន្តានគេ ហើយថែមទាំងធ្វើគេឲ្យកើតមានតាមរាគកូនក្តីទុកឈាម ដោយត្រូវការចង់បាននាងព្រហ្មចារីយ៍កូនកន្លាៈនោះឡើយ ។

សំឡាញ់និយាយទៀតថា: ត្រូវយើងទៅវិញ! ។

ជនទាំងពីរនាក់ផែលឡើងលើសេះដោយស្ងៀមស្ងាត់: រស្មីមបេនអាប់ជាឡស់ទឹមហាម៉ែតតេលុប ជាមិត្តភ័ក្តិអាក្រក់ នាំគ្នាវិលទៅទីក្រុងវិញ កូនពេលព្រលប់យប់ស្ងាត់ ទាំងស្ពាយស្រណោះ ។

(មានត)

## តំណឹងបុណ្យព្រហ្មទានក្នុងឆ្នាំ ១៩៥៤

# ពុទ្ធសាសនបណ្ឌិត្យ

---

កាលពីថ្ងៃទី ២១ ខែមីនាឆ្នាំ ១៩៥៤ នៅយ៉ាសាលាចាលីជាន់ខ្ពស់ មានពិធីបុណ្យប្រគេនព្រហ្មទាន ដល់និស្សិតសមណៈ ១២៦ អង្គ គឺនិស្សិតទើបប្រឡងចេញបានសញ្ញាបត្រសាលាចាលីជាន់ខ្ពស់ ចំនួន ៦៦ រូប និងនិស្សិតប្រឡងឡើងថ្នាក់នៅឆ្នាំទី ៤ ចំនួន ៦០ រូប ។

បុណ្យព្រហ្មទាននេះ កើតមានឡើងដោយសមាគមមិត្តសាលាចាលីជាអ្នកផ្តើមធ្វើរៀងពីឆ្នាំ ក្រោមអធិបតីភាពព្រះគុណៈជាអម្ចាស់ជីវិតលើត្បូង នៅយ៉ាសាលាចាលីជាន់ខ្ពស់ ។ ពិធីបុណ្យលើកនេះជាលើកទី ៥ ។

ពិធីបុណ្យប្រគេនវង្វាន់ដ៏ប្រសើរ ចំពោះសមណសិស្សនេះ បានផ្តើមឡើង តាំងពីយប់ថ្ងៃសៅរ៍ទី ២១ មីនា ពេលម៉ោង ៨ យប់ ដែលមានការដួបជុំបព្វជិតគ្រហស្ថ ពុទ្ធបរិស័ទជាច្រើនរយនាក់ ដើម្បីស្តាប់ព្រះបរិត្តទន្ទឹងធម្មទេសនា ។ នៅយ៉ាសាលាចាលីជាន់ខ្ពស់ មានការតាក់តែងលំអដោយទង់ជាតិទង់សាសនា រចនាដោយភ្លើងតាមក្បោងព្រួយ ជាពិធីបុណ្យមួយដ៏រុងរឿង ។

នៅថ្ងៃអាទិត្យទី ២៦ ខែមីនា ម៉ោង ៣ រសៀល មានការជួបជុំពុទ្ធ-បរិស័ទ មានសម្តេចព្រះសង្ឃនាយក ទទឹងឯកទត្តមហាន់ - ណាកជាដើម ចូនទទឹមន្ត - អញ្ជើញទៅកាន់ពិធីបុណ្យនេះ ។ ដល់ម៉ោង ៥ រសៀល ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងមកជាអធិបតី ហើយ លោក ប៉ាយ - ប៊ុក អធិរតីសមាគមមិត្តសាលាចាលី ចូនថ្លែងសុន្ទរកថា កាន់នាមនៃសមាគម ថ្វាយស្វាគមន៍ចំពោះព្រះបិយមហាវីរក្សត្រិយ៍ ទទឹងឥស្សរជនទាំងបពូជិត ទាំងស៊ីវិល ដូចតទៅនេះ ។

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្សជាអកិលក្ខិតសម័យនៃព្រះតេជព្រះគុណពាល់ ព្រះអង្គ ទុកដូចជាបុជ្ជាមួយដើមផ្សាយក្នុងគ្រអូបឈ្ងុយឈ្ងប់ទាំងនាមសព្ទ ទទឹងគុណសព្ទល្បីខ្ចរទៅកាន់ព្រះពជអាណាចក្រ ហើយទុកជាអនុស្សាវរីយ៍ ដ៏អស្ចារ្យមួយក្នុងព្រះពុទ្ធសាសនា; ព្រះករុណាជាស្តេចទាំងឡាយ ! ទេយ្យវត្តទាំងនេះ សម្រាប់បូជាចំពោះព្រះករុណាគ្រប់អង្គ ដែលចូនព្យាយាមសិក្សាគ្នានវេលាចំនេរអស់រយៈ ៤ ឆ្នាំ ទើបចូនសម្រេចនូវចំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធសាសនា ជាវិជ្ជាអាចផ្តល់នូវសាធារណ-ប្រយោជន៍ដល់ប្រជាជនរួមជាតិ កាន់តែពុំខ្វះ ។

សមាគមមិត្តសាលាចាលី មានសេចក្តីសង្ឃឹមខ្ពស់ជាមុនថា ព្រះតេជព្រះគុណគ្រប់អង្គនេះហើយ នឹងចូនជាគ្រូអាចារ្យនៃពួកឧបាសក ឧបាសិកា ហើយជាអ្នករក្សាក្តីដំណែលនៃព្រះពុទ្ធសាសនា ឲ្យចូន

បិតថែរចិរកាលទៅអនាគត ។ សាលាចាស់ជាន់ខ្ពស់ទុកដូចជាបិតាឬ
ជាបុព្វាចារ្យ ដែលបានចិញ្ចឹមបីបាច់ថែរក្សាព្រះតេជព្រះគុណឲ្យបាន
ចំរើនវ័យវឌ្ឍនាការ ឲ្យមានវិជ្ជាដែលជាហេតុរចនានូវជោគវាសនាព្រះ
តេជព្រះគុណឲ្យបានប្រកបដោយសុវត្ថិភាពគប់យ៉ាង ។ សូមព្រះ
តេជព្រះគុណកុំភ្លេចសាលាចាស់ជាន់ខ្ពស់នេះ បើព្រះតេជព្រះគុណគង់
នៅជាកេទបព្វជិតក្តី សឹកទៅជាគហស្ថក្តី ក៏ត្រូវជួយទុបត្ថម្ភសាលានេះ
ត្រមាំងសមាគមមិត្តសាលាចាស់ដែលជាសរសេរកន្លងសាលានេះ ឲ្យ
បានរស់ពនមានជីវតរឹងប៉ឹងដោយសាមគ្គីគ្នា ដើម្បីនឹងជួយយឺតយោង
ជាតិ សាសនា មហាក្សត្រិយ៍ ទាំងផ្លូវអាណាចក្រនឹងពុទ្ធចក្រ ឲ្យភ្ជឹ
ស្វាងបែរមុខទៅរកវឌ្ឍនភាពនឹងសន្តិភាព ។ ដ្បិតប្រទេសកម្ពុជាដែល
បានឯកភាជ្ជនេះ កំពុងត្រូវការវីរបុរសណាស់ ដើម្បីខ្ជាន់ជ្រៀនប្រដៅ
ប្រជាជនខ្មែរ ឲ្យប្រតិបត្តិទាន - សីល - ភាវនាតាមពុទ្ធាវាទ, ត្រមាំង
ឲ្យរៀនវិជ្ជាផ្លូវលោកផ្លូវធម៌នឹងធ្វើឲ្យចាប់អានភាសាអក្សរជាតិ ឲ្យចេះរក្សា
នូវអារ្យធម៌ខ្មែរ នូវកិត្តិយសខ្មែរ ឲ្យផ្សាយទៅពេញកន្លែងសកលលោក ។

កន្លែងអវសានេះ សហគមមិត្តសាលាចាស់ សូមអុណ្ណព្រះរតន-
ត្រ័យជួយទុបត្ថម្ភព្រះករុណាជាអម្ចាស់ជីវតលើត្បូង សូមព្រះគង់នៅជា
សុខក្នុងសិរីភាជសម្បត្តិ ត្រមាំងព្រះពជវង្សានុវង្ស ! ។ សូមអសន្តិសុខ
វិនាសពីប្រទេសកម្ពុជាដោយឆាប់រហ័ស ! ហើយនឹងឲ្យឯកទុត្តម-អស់

លោកអ្នក ជានច្រកបដោយសិរីសួស្តីជយមង្គលគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ! ។

បន្ទាប់មក ព្រះតេជព្រះគុណព្រះពោធិវ័ង្ស ហួត - តាត ចាងហាងសាលាបាលីជាន់ខ្ពស់ ជានថ្លែងសុន្ទរកថាមួយបន្តមកទៀត រៀបរាប់អំពីការចែករង្វាន់នេះថាជាកិច្ចអាចរាប់បញ្ចូលក្នុងការកុសល ដែលមានលទ្ធផលក្នុងបច្ចុប្បន្នទីដ៏បរិសុទ្ធ, និង សូមទទួលអំណរដ៏ក្រៃលែង ចំពោះសមាគមមិត្តសាលាបាលី ដែលធ្វើការកុសលដូច្នេះជាច្រើនឆ្នាំមកហើយដោយឥតរួញរា ហើយនឹង សូមសំដែងនូវសេចក្តីគោរព ជាដំណាងបុគ្គលិកទាំងអស់ក្នុងសាលានេះ ចំពោះព្រះករុណា, សម្តេច, ឯកឧត្តម នឹងអស់លោកទាំងឡាយ ដែលទ្រង់ស្តេចមកជាព្រះរាជាអធិបតីក្នុងទុកាសបុណ្យព្រហ្មចាននេះ ទុកដូចជានាំនូវសិរីសួស្តីដ៏ប្រសើរ មកព្រះរាជទានដល់សាលាបាលីជាន់ខ្ពស់, កិត្តិយសនេះនាំឲ្យសាលានេះមានដំណើរទៅកាន់សេចក្តីចំរើន ។

ហើយថ្លែងសេចក្តីគ្រើនរុងរឹតប្រស្រ័យនឹងសិស្សនៃសាលានេះ ដើម្បីអប់រំសតិបញ្ញាវបស់សិស្សត្រៅក្នុងអនាគតថា

ការរៀនសូត្រចំណេះវិជ្ជាគ្រប់ប្រភេទក្តីលោកនេះ រមែងដឹកនាំមនុស្សជាតិនឹងពិភពលោកឲ្យមានការប្រែប្រួលឆ្ពោះទៅមុខ,ពីហានៈថយថោកទៅកាន់ហានៈដ៏ខ្ពង់ខ្ពស់, ពីការលង្ខិលទៅកាន់ការចេះដឹង ដូច

យើងបានឃើញនឹងភ្នែកស្រាប់ហើយ សេចក្តីថ្លៃថ្លៃនិងសេចក្តីចំរើនរុងរឿង ជាផលបានមកអំពីចំណេះវិជ្ជា។ បានមកអំពីការរៀនសូត្រវប្បធម៌របស់មនុស្សក្នុងលោក។ បណ្តាចំណេះវិជ្ជាទាំងនោះ, ការសិក្សាព្រះបរិយត្តិធម៌នឹងវិជ្ជាដទៃ។ ក្នុងសាលាជាន់ខ្ពស់នេះ អាចពាប់បញ្ចូលទៅក្នុងចំណេះវិជ្ជាផ្នែក ១ ក្នុងលោកបានដែរ បើចំពោះប្រទេសកម្ពុជាយើងនេះ ជនជាតិខ្មែរយើងក្នុងអតីតកាល បានធ្លាប់និយមពាប់អានថាជាចំណេះវិជ្ជាជាន់ខ្ពស់បំផុតរបស់ជាតិ ព្រោះគោលចរិកសំខាន់ៗ នៃវប្បធម៌ខ្មែរមានអក្សរសាស្ត្រជាដើម តាំងពីសម័យបុរាណរហូតមកដល់សម័យបច្ចុប្បន្ននេះរមែងពឹងផ្អែកទៅលើព្រះពុទ្ធសាសនាស្ទើរតែទាំងអស់។

ហេតុនេះសុំឲ្យអស់លោកជានិស្សិតទាំងឡាយ ចំគិតរំពឹងពិចារណាឲ្យវែងឆ្ងាយ ធ្វើចិត្តឲ្យធ្ងន់ឲ្យនឹងធឹង ហើយខំសិក្សាចំណេះវិជ្ជាទាំងផ្លូវធម៌នឹងផ្លូវលោក ចំពោះតែវិជ្ជាណាដែលបពូជតអាចរៀនបាន ពុំទាស់ខ្ពង់នឹងផ្លូវសាសនា ឲ្យបានចេះដឹងឲ្យបានសមល្មមជាទីពឹងបង្អែកនៃពុទ្ធសាសនិកជនតទៅ ដូចជាព្រះនាគសេនមហាថេរក្នុងសម័យអតីតកាល ដែលអាចតទប់នឹងចំណេះរបស់ព្រះបាទមិលិន្ទធ្លាជាដបាន។

កាលបើព្រះតេជព្រះគុណព្រះពោធិវង្ស ចាងហ្វាងសាលាជាន់ខ្ពស់ ថ្លែងសុន្ទរកថាដូចខាងលើនេះចប់ហើយ ព្រះកុណាជា

អម្ចាស់ដ៏វិសេសលើសលុង ទ្រង់ថ្វាយព្រះពរដល់សាសន៍ទៅកាន់ព្រះសង្ឃ, នាម៉ឺន សព្វមុខមន្ត្រីនឹងប្រជាពលស្តួចដូចតទៅនេះ ។

ខ្ញុំព្រះករុណាខ្ញុំសូមប្រគេន- ជូនទូវសេចក្តីសោមនស្សរីករាយ សរសើរដល់ពួកសមណនិស្សិត ដែលមានកត្តញ្ញូឡើងបានសញ្ជាប់ត្រូវ, និងដល់អស់លោកទាំងអស់គ្នា ដែលបានរៀបចំពិធីបុណ្យនេះ ជាកិច្ចខំនុកបំរុងការរៀនសូត្រក្នុងសាលាបាលីជាន់ខ្ពស់ ហើយបានបរិយាយសេចក្តីដែលបានត្រិះរិះគិតមក ។ ឥឡូវនេះខ្ញុំព្រះករុណាខ្ញុំនឹងពណ៌នាជាសណ្តាប់ នៃព្រះសង្ឃនឹងអស់លោក ដូចមានតទៅនេះ ៖

ដោយឃើញថា ប្រទេសនីមួយៗ បើចង់ឲ្យថ្កុំថ្កើងរុងរឿងលូតលាស់ទៅមុខទៀត លុះតែបណ្តុះបណ្តាលឲ្យបាននូវចំណេះវិជ្ជារបស់ពលរដ្ឋប្រទេសនោះ បានលូតលាស់ខ្ពស់ឡើង ។

ចំណែកព្រះពុទ្ធសាសនាយើង ក៏មានស្ថានភាពដូច្នោះដែរ គឺថាសាសនាយើងដែលបានថ្កុំថ្កើងក៏ដោយសារវឌ្ឍនភាព ដែលមានក្នុងការអប់រម្យចេញពីខ្លួនឯង. ឲ្យបានចេះដឹងច្រើនឥតខ្ចោះឡើង ។

មួយយ៉ាងទៀត ក្នុងប្រទេសនីមួយៗ បើចំនួនវត្តដែលចេះដឹងកាន់តែកើនច្រើនឡើង រស្មីនៃអារ្យធម៌របស់ប្រទេសនោះក៏រីកឡើងដែរ ។

ចំណែកខាងពុទ្ធបរិក្ខារ បើវត្តសមណៈមានចំនួនកាន់តែរីកខ្ពស់ឡើង រស្មីនៃព្រះពុទ្ធសាសនាយើង ក៏កាន់តែរុងរឿងថ្វាចិញ្ចាចឡើងដែរ ។

ហេតុដូចម្តេចក៏ថាចំណេះវិជ្ជានាំឲ្យកិត្តិយសដល់ប្រទេស, ដល់សង្គម, ដល់បុគ្គលឯកជន? ។

គេនិយាយថា វិជ្ជាអាចលើកឋានៈរបស់បុគ្គល ។ ហេតុអ្វីក៏ថាយ៉ាងដូច្នេះ? ។

ការនេះមិនមែនដោយសារតែបុគ្គលនោះមានសញ្ញាប័ត្រគាន់នៅដៃទេ. គឺមកពីអាចឲ្យសំគាល់ថាបានថា បុគ្គលណាដែលស្វែងរកវិជ្ជានេះមកបាន បុគ្គលនោះឯងរមែងមានសមត្ថភាពធ្វើខ្លួនឲ្យរួចពីសេចក្តីងងឹត គឺអវិជ្ជា ។ អវិជ្ជានេះហើយដែលជាហេតុដើម ជាមូលដ្ឋាននៃទុក្ខទោសរបស់មនុស្ស ព្រោះមនុស្សគ្មានវិជ្ជាពុំមានមូលដ្ឋាននៃការត្រិះរិះសំកប់ពិចារណារកខុសត្រូវល្អអាក្រក់ទេ ។ អវិជ្ជានេះ ជាហេតុដើមនៃអំពើទុច្ចរិតទាប់ថោក ព្រោះមនុស្សគ្មានវិជ្ជា ពុំអាចមានឧត្តមគតិខ្ពង់ខ្ពស់នៅក្នុងខ្លួន ។ អវិជ្ជានេះជាមូលដ្ឋាននៃអវិឌ្ឍន: ពីព្រោះមនុស្សគ្មានវិជ្ជា ពុំមានសមត្ថភាពក្នុងវឌ្ឍនាការ ។

ចំណេះវិជ្ជារបស់ពលរដ្ឋ អាចនាំឲ្យពលរដ្ឋយល់ក្តីច្បាស់មែនទែនឡើង នូវសិទ្ធិនឹងករណីយកិច្ចរបស់ខ្លួន, ឲ្យចេះបំរើប្រទេសជាតិឲ្យបានប្រសើរឡើង ធ្វើប្រទេសជាតិឲ្យមានអារ្យធម៌ បានចំរើនលឿនជាមុខ ។

ចំណេះវិជ្ជា ចំណែកឯព្រះតថាគតប្រគេនលោកនូវមគ្គាបាយដែលនាំលោកឲ្យជ្រាបច្បាស់នូវខ្លឹមសារនៃព្រះពុទ្ធសាសនា នូវព្រះធម៌នឹងព្រះវិន័យ ។

ចំណេះវិជ្ជានេះប្រគេនសមត្ថភាពដល់ព្រះសង្ឃ ដែលអាចនឹងចំរើនព្រះពុទ្ធសាសនា តំណាងព្រះពុទ្ធសាសនា នឹងផ្សាយព្រះពុទ្ធសាសនាឲ្យបានច្បាស់បរិសុទ្ធតាមគន្ថធម៌ធម៌និងវិន័យ កុំឲ្យមានការកំពូនច្រឡំក្នុងការបកប្រែ ក្នុងការប្រតិបត្តិ នឹងកុំឲ្យមានការរវែងធោតជឿតាមតំណាប់ខុស ។ ដូច្នេះយើញថា ចំណេះវិជ្ជាជាការចាំបាច់ ។

ប៉ុន្តែខ្ញុំសូមអរគុណ ខ្ញុំចង់ពិតព្រះគេជគុណ, បងដំរាបអស់លោក-អ្នកថាចំណេះវិជ្ជាមានការចាក់ទងជាប់នឹងសុភនិច្ឆ័យ ព្រមទាំងលំអានរបស់វិន័យ នឹងសុចរិតយុត្តិធម៌ យើងនឹងញែកឲ្យបែកចេញពីគ្នាពុំបានឡើយ ។

ដូច្នេះឧបមាថា បុគ្គលមួយមានសញ្ញាច័ត្រនីតិបណ្ឌិត, ឬមហាបរិញ្ញាអក្សរសាស្ត្រឬបរិញ្ញាច័ត្រសាស្ត្រ តែបុគ្គលនោះចំណានតែខាងមើលងាយដល់អ្នកឯទៀត សូម្បីតែគេមានវ័យចាស់ជាងក្តីក៏ប្រមាទមើលងាយគេ ដោយគិតថាខ្លួនចេះជាង, ខ្លួនមិនត្រូវការស្តាប់សេចក្តីអ្វីឬរឿការអ្វីអំពីមនុស្សណាទេ ។

ម្យ៉ាងទៀតឧបមាថា បុគ្គលនោះចេះស្គាល់តែសិទ្ធិរបស់ខ្លួន, ហើយពុំព្រមស្គាល់នូវកាណីយកិច្ចខ្លួនផង ចេះស្គាល់ ចេះសែ្វងរក ចេះមើលឃើញតែប្រយោជន៍របស់ខ្លួន របស់បក្សពួកខ្លួន, ពុំស្គាល់ប្រយោជន៍ប្រទេស ឬប្រយោជន៍សាធារណជនទេ, ចេះស្គាល់គុណទុក្ខធួរៈតែរបស់ខ្លួននឹងពួកខ្លួន ហើយពុំព្រមស្គាល់នូវគុណចំណាប់ទុក្ខធួរៈរបស់

អ្នកឯទៀតទេ តើត្រូវនុកថាបុគ្គលនោះជាអ្នកចេះដឹងពេញលក្ខណៈជាអ្នកមានចំណេះវិជ្ជាបានឬទេ? ។

អ្នកពជការណាមួយ ដែលថាមានចំណេះ បើអ្នកនោះឯងជាមនុស្សពុទ្ធិតែ បើអ្នកនោះឯងជាអ្នកឥតសណ្តាប់ធ្នាប់, ចំពោះវិន័យ ចេះតែមិនសុខចិត្តពីនេះពីនោះធ្វើបាបអ្នកគួច ហើយប្រទូសរ៉ាយនឹងអ្នកជំដោយខ្លួនមិនផ្សាយចែករំលែកសេចក្តីយុត្តិធម៌ឲ្យទៅអ្នកគួច បើមិនចេះទទួលបញ្ជាដែលអ្នកធំគេជាក់ឲ្យប្រតិបត្តិដោយត្រឹមត្រូវតាមច្បាប់ ចេះទទួលមួយតែបញ្ជាណាដែលឲ្យប្រយោជន៍ដល់ខ្លួនផ្ទាល់ មន្ត្រីនោះឯងពុំឲ្យប្រយោជន៍ដល់ប្រទេសខ្លួនបានទេ ហើយសំគាល់ថាជាអ្នកមានវិជ្ជា ពុំបានឡើយ ។

ហេតុនេះហើយបានជាខ្ញុំកុណាខ្ញុំ បរិយាយអម្បាញ់មិញនេះថាចំណេះវិជ្ជាពុំអាចនឹងចែកញែកអំពីសុកនិច្ឆ័យ នឹងលំអានយុត្តិធម៌នឹងលំអានរបស់វិន័យបានទេ ។

សុកនិច្ឆ័យ ពាក្យចាក់ឋាថា (le bansens) នោះគឺថាស្តាំពុំឆ្វេងពុំមែនឈ្មីយ ព្រោះមនុស្សខ្លះពិតមែនតែចេះច្រើន ប៉ុន្តែនៅឆ្វេង រមែងគិត ឬធ្វើអ្វីទៅច្រើនផ្ទុយនឹងការត្រូវ ។

គិតឆ្វេង ប្រព្រឹត្តឆ្វេង អាចនាំកឲ្យកើតគ្រោះថ្នាក់ ។

បើដូច្នេះ ព្រះតេជព្រះគុណនឹងអស់លោក អ្នកគង់ជាបគង់ឈ្វេងយល់បានទូរតំរិះរបស់ខ្ញុំកុណា - ខ្ញុំ ។ ការរៀនសូត្រមែងនាំខ្លួនយើងឲ្យចៀសរួចផុតពីអវិជ្ជា ។

អំពើធ្វេងក្តី អំពើអយុត្តិធម៌ក្តី អំពើដែលមិនប្រកបដោយសណ្ដាប់ធ្នាប់នឹងគន្ធធម៌ច្បាប់គន្ធធម៌វិន័យក្តី ចូលក្នុងគន្ធធម៌អវិជ្ជា ។

មនុស្សម្នានចំណេះ ខុកជាចេះដឹងលើសលុបគ្មានកំចាំងអ្វីសោះ ហើយស្គាល់គ្មានខ្លះខ្លូវអាថ៌កំបាំងនៃវិទ្យាសាស្ត្រ, បើមនុស្សនោះក្លែចខ្លួរលំអានតាមវិន័យ ភរណីយកិច្ច-យុត្តិធម៌ សុកនិច្ចយហើយ អាចក្លាយទៅជាគ្រឿងចំក្រមួយ ដែលគ្មានតែវិលបង្កបង្កើតផលបាន ប៉ុន្តែពុំអាចចេះពិចារណាអំពីផលល្អ នឹងអាក្រក់ អន្តរាយនោះបានទេ ។

សេចក្តីដែលខ្ញុំកុណាខ្ញុំ ថ្លែងមកនេះ ប្រហែលជាមិនឃ្លៀងឃ្លាតអំពីដំបូន្មានព្រះសម្មាសម្ពុទ្ធបរមគ្រូដែលទ្រង់ត្រាស់ថា:

ពហុម្បិបេ សហិតំ ភាសមានោ ន តក្ករោ ហោតិ យថា បរម្មុខោ ជាដើម ប្រែថា "ខុកជាចេះដឹងច្រើនយ៉ាងណា តែមិនប្រតិបត្តិឲ្យបានល្មមតាមចំណេះ ជាការមិនមានផលប្រយោជន៍ប្រសើរប៉ុន្មានដែរ" ។

ដោយយើងស្រឡាញ់ប្រទេសយើងនេះហើយ ដោយយើងចង់ឲ្យប្រទេសយើងនេះ ស្គាល់ខ្លួរសេចក្តីវឌ្ឍនឹងខ្ពង់ខ្ពស់ខ្លួរឯកពាជ្យធំទុលាយបានជាយើងខំស្វែងរកវិជ្ជានឹងវឌ្ឍនធម៌ ។ ឯខាងព្រះពុទ្ធសាសនាវិញក៏ដូច្នោះដែរ ។

ប្រទេសយើងនៅថ្ងៃនេះ ដែលខ្ញុំគុណា ខ្ញុំ មានកិត្តិយសមកជាអធិបតីកិត្តិពិធីចែកវង្វាន់នេះ ទើបនឹងអង្គុលចូលទៅកាន់ឯកភាពព្រះគ្រោយដែលបានទទួលផ្នែរសមត្ថកម្មគុណការ បញ្ជាការសឹកនឹងប៉ូលិសដែលជាកេតនកណ្ដាធំបង្អស់សម្រាប់ជាតិពាំង ៗ មក យើងទើបនឹងបានទទួលសមត្ថកម្មសេសសល់ឯទៀតពាំង ៗ ឡាយ ព្រមទាំងអធិបតេយ្យភាពពេញទីខាងការទូតដែលយើងបានសម្រេចជាឯកច្ឆន្ទដោយភាវជាតិចុលមានខ្ញុំគុណា ខ្ញុំ ជាអធិបតីកិត្តិការនេះ ទើបនឹងផ្ដាច់ចោលជាអសារបង់នូវកិច្ចសញ្ញាពីមុនចំពោះរបៀបតាំងទូត គឺថាមិនចាំបាច់មានសេចក្ដីយល់ព្រមពីប្រធានាធិបតី ប្រទេសចាក់ពាំងដូចមុនទេ ចាប់តាំងអំពីនេះតទៅយើងមានអំណាចប្ដូរទូតនៃប្រទេសយើងនឹងប្រទេសដទៃផ្ទាល់តែម្ដង ។ នៅសល់តែបញ្ហាហិរញ្ញវត្ថុ ទឹងពាណិជ្ជកម្មក្រៅប្រទេសតែពីរមុខនេះទេ ដែលយើងនៅត្រូវយកទៅជជែកគ្នាទៀត នាក្រុងហ្វាំសៃ ព្រោះនៅមានពាក់ទងគ្នានឹងប្រទេសយៀកណាម ហើយនឹងប្រទេសលាវផង ។

ប៉ុន្តែបើតុណាជាយើងស្រាយបញ្ហាទាំងនេះចានស្រេច ក៏ប្រយើងកុំស្មានថាយើងអស់កិច្ចអ្វីដែលត្រូវបំពេញទៀតហើយនោះ កុំស្មានថាឯកភាពរបស់ប្រទេសយើងអាចរស់នៅ អាចមានរស្មីភ្លឺចែងដរាបដល់អវសានតទៅទៀតបាន ដោយយើង តុំចាំបាច់ទ្រទ្រង់នោះ ។

បើអ្នកបំរើរាជការស៊ីសំណូក ហើយតុំរកប្រយោជន៍ឲ្យប្រទេសឲ្យសង្គមជាតិទេ បើសេនាធិបាននិងមិនបំពេញបេសកកម្មរបស់ខ្លួនឲ្យពេញ

លក្ខណៈទេ ឬមិនគោរពវិន័យគាហាន់ទេ បើសិស្សសាលានឹងនិស្សិត
មិនព្រមបំពេញកិច្ចត្រឹមត្រូវសូត្រតែងជាអ្នករៀនសូត្រទេ បើមនុស្សនៅ
តែគ្មានសណ្តាប់ធ្នាប់ នៅតែមានការប្រទូសរ៉ាយនឹងគ្នា បែកបាក់គ្នា
នឹងបះបោរនៅតែកាន់តែតិចុះតិត អយុត្តិធម៌មុសាវាទ នឹងបេសុញ្ញវាទ
ឯកពាជ្យដែលយើងខ្ញុំបាននឹងបានមកនេះ មុខជាដល់នូវមរណៈ ហើយ
ប្រទេសយើងក៏ទៅជាមួយដែរ ។

ចំណែកខាងបព្វជិត ក៏មានការណីយត្រូវបំពេញដែរ ។

សេចក្តីត្តន់ត្តស់របស់ប្រទេសនឹងសេចក្តីរុងរឿងរបស់ព្រះពុទ្ធសាសនា
ញុំាងឲ្យព្រះសង្ឃនៅកៀកជាប់នឹងការណីយកិច្ចរៀងពាល់អង្គ កុំឲ្យឃ្លាត
ពីវិន័យពុទ្ធបញ្ញត្តិ កុំឲ្យឃ្លាតពីចរិយាវត្តជាព្រះសង្ឃ ជាអ្នកបំភ្លឺផ្លូវ ជាគ្រូ
នៃយុត្តិធម៌ នៃវិចារណាញ្ញាណនៃសុភនិច្ឆ័យ នៃរបៀបរៀបរយ នៃធម្ម-
ចរិយា នៃការទៀងត្រង់សុចរិតចាគនឹងខន្តី ដើម្បីឲ្យយើងទាំងអស់គ្នាជា
គ្រហស្ថបានជែកនៅក្រោមម្លប់ដ៏ត្រជាក់នៃព្រះពុទ្ធសាសនាផង ឲ្យយើង
បានស្រាកស្រាន្តពីសេចក្តីលំបាកកង្វល់ចិត្តគំនិតនឹងកាយ ហើយឲ្យយើង
មានសេចក្តីសង្ឃឹមលើអនាគតដើម្បីមានសទ្ធាជ្រះថ្លាធ្លុងលុមក្នុងកិច្ចដ៏លំ-
បាក ដែលត្រូវបំពេញឲ្យប្រទេសជាតិមានដ៏រីតបិតថេរចិរកាលតទៅមុខ ។

ជាតិយើង ក្នុងជីវភាពខ្លួននេះ និយមតែនូវវត្ថុពីរយ៉ាងគឺ: ឯក-
ពាជ្យប្រទេសនេះ ១, សេចក្តីរុងរឿងព្រះពុទ្ធសាសនានេះ ២, ដែល
យើងគ្រប់ប្តូចនឹងឲ្យបាននៅគង់វង្សជានិច្ចកាល ។

ឯការជ្យយើង ទឹងបានចំរើនលូតលាស់ហើយទឹងបាននៅគង់វង្សតទៅ បើពលរដ្ឋ ទោះបីមានរបរអាជីវៈដូចម្តេចក៏ដោយ ចេះប្រកាន់ដោយខ្ជាប់ខ្ជួនថាទឹងធ្វើការរបរខ្លួននោះ មិនត្រឹមតែដោយកម្លាំងកាយទឹងសតិបញ្ញាប៉ុណ្ណោះទេ គឺថែមទាំងត្រូវយកទៅបូជាកងការនេះខ្លួរសេចក្តីស្នេហាការទឹងជាតិ សទ្ធាចំពោះការណីយកិច្ចខ្លួន ប្រតិបត្តិវិន័យចំពោះច្បាប់ សុចរិតយុត្តិធម៌ចំពោះសង្គមទឹងបុគ្គល ។

ព្រះពុទ្ធសាសនាយើងទឹង រុងរឿងភ្លឺចិចែងបាន លុះណាតែព្រះសង្ឃបន្ថែមលើសេចក្តីចំរើនដ៏អនេក ដែលលោកចេះធ្វើឲ្យបានមកហើយក្នុងផ្នែកការសិក្សានោះ គឺបន្ថែមខ្លួរសេចក្តីចំរើន ដែលលោកប្រាថ្នាឲ្យបានសម្រេចក្នុងផ្នែកប្រតិបត្តិវិន័យ ដោយហ្មត់ចត់បរិសុទ្ធគ្មានខ្ចោះ ព្រមទាំងក្នុងផ្នែកសង្គមកិច្ចដែលជំបូន្មានព្រះពុទ្ធអង្គ អាចញ៉ាំងឲ្យលោកទាំងនោះ ជួនជាប្រយោជន៍ដល់ប្រទេសជាតិយ៉ាងស្អាតស្អម្លៅបាន ដោយព្រះសង្ឃនោះហើយដែលជាធម្មជាតិដឹកនាំទៅកាន់ការសង្គ្រោះគ្នា ទៅដល់មិត្តភាព ទៅដល់ការចងចាប់គ្នា រួបរួមស្រុះស្រួលគ្នាហើយទឹងសន្តិភាព ។

ព្រះករុណា សូមថ្លែងខ្លួរសេចក្តីខំនុកឧកចិត្តដោយគោរព ទឹងសេចក្តីស្នេហាចំពោះទៅមន្ត្រីសង្ឃធំៗ ទឹងវិសមណៈនោះនៃព្រះពុទ្ធសាសនាដ៏ថ្លៃថ្លាវិសេស រហស់យើងគ្រប់ព្រះអង្គ ។ ចប់

# ភាគ្គិយសុត្តន្ត

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ២៦ ខែសីហា លេខ ៨

ព.ស. ២៤៩៨ – គ.ស. ១៩៥៤



# ភ្នំពេលសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — មាតាបិតុគុណកថា | ព្រះញាណកោសល ញាណ-ឈីន | ៥៦៣ |
| — សមភាពក្នុងព្រះពុទ្ធសាសនា | ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ | ៥៧៨ |
| — បញ្ញាសជាតកភាគទី ២ (តមក) | បណ្ឌិតមហា ឈឹម-ស៊ុម | ៥៨៦ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — រឿងសៅរ៍សោយ (តមក) | ព្រះមហាឧត្តមវិជ្ជា ប៊ឹង-ប៊ម | ៦០៦ |
| — រឿងសាមកុក (តមក) | ឧកញ៉ា នូ-ហន | ៦១១ |
| — ឥសិនទិងទមយន្តី (តមក) | អ្នកស្រី ស្រ៊ុន-សារិយ៉ាន់ | ៦១៥ |
| — ដំណឹងតាមឡរ៉ល់ក្នុងឧត្តរៈ (តមក) | លោក ផេង-ជ្រើរ | ៦១៩ |
| — សកម្មភាព នៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីការសាងវិលុកចេតិយ | លោក ជាប-ពិន | ៦២៣ |
| **កំណត់ទឹងប្រវត្តិការណ៍** | | |
| — ពិធីបុណ្យបញ្ចុះបឋមសិលា នៅទីស្ថាបនា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ | ពុទ្ធសាសនបណ្ឌិត្យ | ៦៣៤ |



មួយឆ្នាំមាន ៤២ លេខ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Matapitugunakatha . . . . . | *Vén. NHEAN-CHHOEUN* . . . | 563 |
| — L'égalité d'après la religion Bouddhique . . . . . | *M. BOU-PO* . . . . . | 578 |
| — Pannasajataka vol-II (suite) . | *M. CHHIM-SOUM* . . . . . | 596 |


PARTIE LITTERAIRE:


| | | |
|---|---|---|
| — Le « SAU-SOY » ou l'influence saturnienne (suite) . . . . . | *Vén. PEUNG-PAM* . . . . . | 606 |
| — Histoire de Samkok (suite) . . | *Oknha NOU-KAN* . . . . . | 611 |
| — Nala et Damayanti (suite) . . | *Mme SRIN-SARIS-YANN* . . . | 615 |
| — Le souffle du désert (suite) . | *M. PHENG-CHRIV* . . . . . | 619 |
| — L'activité de la Commission des Mœurs et Coutumes . . . . | *M. CHAP-PIN* . . . . . | 623 |


NOTES ET CHRONIQUES:


| | | |
|---|---|---|
| — La pose de la 1e pierre à l'Université Bouddhique «PREAH SIHANOUK » . . . . . | *INSTITUT BOUDDHIQUE* . . . | 634 |


Prix d'abonnement annuel (comprenant 12 numéros) 200$00

# ព្រះញាណកោសល ញាណ-ឈឺន

ទេសនាក្នុងពិធីបុណ្យ ដឹកភត្តទាន របស់លោកឧកញ៉ាឧកញ៉ាយកមន្ត្រី ឃឺន-ចឹម
អ្នកគ្រប់គ្រងពុទ្ធសាសនបណ្ឌិត្យ ដែលធ្វើជូនមាតាបិតាក្នុងគេហស្ថាន កាលពីថ្ងៃសៅរ៍ ៧ រោច
ខែចេត្រ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ (២៤ - ៤ - ៥៤)

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*អត្ថាកាតសូមចំរើនពរ ៤ ប្រការគឺ អាយុ, វណ្ណ:, សុខ:, ពល: ចំពោះពួកពុទ្ធបរិស័ទទាំងឡាយ, ក្រែងអត្ថាកាតសំដែងទៅហើយមានភ្លាំងភ្លាត់ ឬ ឆ្គាំឆ្គងពាក្យពេចន៍កន្លងពេលសំដែងសូមខន្តីអភ័យទោស,អត្ថាកាតសូមស្រង់យកពាក្យប្រកាសរបស់លោក ចាប-ពិន អម្ចាញ់មិញ ត្រង់ដែលថា មតកកត្តុទាន នឹង ជីវិតកត្តុទាននោះ មកសំដែងជាធម្មទេសនាតទៅ ដើម្បីឲ្យសមរម្យដល់ពិធីបុណ្យ ដែលលោកទាយិកាព្រមទាំងក្រុមញាតិកំពុងចាត់ចែងនេះ ដ្បិតបុណ្យបែបនេះ លុះតែសប្បុរសអ្នកមានសទ្ធាជ្រះថ្លាមោះមុត ចំពោះគុណលោកអ្នកមានគុណ ទើបអាចបរិច្ចាគធនធានធ្លើទៅកើត បើមានសទ្ធាចិត្តស្តាក់ស្តើរមិនជឿស៊ប់ទេ ក៏មិនអាចនឹងបរិច្ចាគបានឡើយ ។*

*ពាក្យថា "មតកកត្តុទាន" គឺធ្វើទានចុងក្រោយផលជូនចំពោះបុព្វការីជនដែលចែកស្ថានទៅកាន់បរលោកនាយ, ពាក្យថា "ជីវិតកត្តុទាន"*

គឺធ្វើទានទុទ្ទិសផលជូនចំពោះបុព្វការីជន ដែលកំពុងមានជីវិតារសន់នៅ
សព្វថ្ងៃ ។

បណ្តាបុណ្យទាំងពីរប្រការនេះ មតកភត្តទាន ធ្លាប់ឃើញគេ
ធ្វើរឿយ ។ ចំពោះវេលាដែលមានញាតិទទួលមរណៈថ្មីៗ ឬយូរហើយ,
ឯដីវិតកភត្តទាន យូរៗទើបមានម្តង ព្រោះអ្នកដែលមានជីវិតរស់នៅគេ
ពុំសូវនឹកនាដល់ ទោះបីមានទឹកដល់ខ្លះហើយធ្លី ក៏ប្រែជានគេហៅ
ថាធ្វើបុណ្យឆាក ឬបុណ្យវេរបច្ច័យ ៤ ទៅវិញ គេមិនហៅថាបុណ្យ
ជីវិតកភត្តទានទេ ព្រោះពាក្យនេះគេមិនធ្លាប់ហៅ; តែតាមការពិត បុណ្យ
ឆាកឬបុណ្យវេរបច្ច័យ ៤ ក៏គឺបុណ្យជីវិតកភត្តទាននោះឯង ។

វេលានេះ អាត្មាភាពសូមសំដែងអំពីបុគ្គលវេគ្រែកង់លោកជាមុនសិន
រួចហើយសឹមត្រឡប់មកសំដែងបញ្ចប់ពាក្យថាជីវិតកភត្តទាននេះ ជាខាង
ក្រោយ ។

ព្រះពុទ្ធដីកាក្នុងព្រះសុត្តន្តបិដក អដ្ឋកថានិកាយខុទ្ទកនិកាយថា ទ្វេមេ
ភិក្ខវេ បុគ្គលា សង្ឃេ សវិដ្ឋមានា ទុល្លភា លោកស្មិំ ប៉ុណ្ណោះ
ជាដើម ប្រែថា "ម្នាលភិក្ខុទាំងឡាយ! បុគ្គលពីរចំពូកនេះ រកបាន
ដោយក្រៃលែងលោក" ។ ពាក្យមេ ទ្វេ "បុគ្គលពីរចំពូក តើអ្វីខ្លះ?
បុគ្គលពីរចំពូកនោះគឺ បុព្វការីបុគ្គល (បុគ្គលអ្នកធ្វើឧបការមុន) ១ កតញ្ញូ

កតវេទីបុគ្គល (បុគ្គលអ្នកដឹងគុណនៃការគុណដែលគេធ្វើចំពោះខ្លួនហើយធ្វើតបគុណវិញ) ១ ទាំងពីរចំពូកនេះ រមែងរកបានដោយក្រកុងលោក" ។

ហេតុម្តេចបានជាបុគ្គលពីរពួកនេះ គេរកបានដោយក្រកុងលោក? បានជាគេរកបានដោយក្រកុងលោក ព្រោះបុព្វការីបុគ្គល ដូចមាតាបិតា កម្រមានធម៌មានព្រហ្មវិហារធម៌ទាំង ៤ និងសង្គហធម៌ទាំង ៤ ពេញលេញទៅលើបុត្តធីតា ច្រើនតែបាននេះខ្លះនោះ ។ ចំណែកកតញ្ញូកតវេទីបុគ្គល ដូចបុត្តធីតា ក៏កម្រមានធ្វើកិច្ចតបគុណលោកវិញ ឲ្យបានពេញបរិបូណ៌តាមស្ថាន ៥ យ៉ាង ។

មួយទៀត បុព្វការីបុគ្គល និងកតញ្ញូកតវេទីបុគ្គល ជាអ្នកប្រតិបត្តិការតាមធម៌ស្មើគ្នាទៅវិញទៅមកនោះ កម្រមានច្រើនតែបានម្ខាងខ្លះម្ខាង គឺបើមាតាបិតាមានព្រហ្មវិហារធម៌និងសង្គហធម៌ទៅលើបុត្តធីតាៗ តែវាជាមិនមានធ្វើកិច្ចតបគុណលោក ឬមាតាបិតាមិនមានធម៌គ្រប់គ្រាន់ទៅលើបុត្តធីតា ។ ត្រឡប់ជាមានធម៌គ្រប់គ្រាន់ទៅវិញមាតាបិតា; អាស្រ័យហេតុនេះ បុព្វការីបុគ្គល និងកតញ្ញូកតវេទីបុគ្គល ទើបចាត់ជាបុគ្គលរកក្រកុងលោក ។ សូមសាធុជនប្បុរសទាំងឡាយ ចាំស្តាប់អាត្មាភាពនឹងអធិប្បាយតទៅនេះ ។

ធម្មតា បុព្វការីបុគ្គល គួរឬមាតាបិតាលោកមេធាវីតាំងអត់ស្រេកអត់ឃ្លាន អត់ក្តៅត្រជាក់ អត់ការធ្ងន់ធ្ងរបស់បុត្តធីតា

ពុំប្រកាន់ទោស ថែមទាំងពុំជួញគ្រាន់តែក្នុងការព្យាបាលបុត្តធីតាឡើយ ហើយគ្រាលព្រហ្មវិហារធម៌ទៅលើបុត្តធីតាសត្វទាំងពួង តាំងពីពេលដែលបានជ្រាបថាពារកមកចាប់ផ្ទៃដរាបដល់តើតឡើង នេះហើយជាឧបការគុណយ៉ាងធ្ងន់ធ្ងរសឹតគួនឹងប្រៀបផ្ទឹមបាន មានតែកម្រាស់ថ្កើងពីដម្រៅមហាសមុទ្រ កំពស់ភ្នំព្រះសុមេរុ ជាគ្រឿងឧបមានុបមេយ្យប៉ុណ្ណោះ ។ ចំពោះសង្គហធម៌វិញ មាតាបិតាតែងបំពេញធម៌ ៤ ប្រការគឺ

១ – ហាមប្រាមបុត្តធីតា មិនឲ្យប្រព្រឹត្តអំពើអាក្រក់សព្វយ៉ាង មានហាមមិនឲ្យធ្វើវេរ ៤ ជាដើម,

២ – ដឹកនាំពន្យល់បុត្តធីតាឲ្យដ្រះថា ឲ្យតាំងនៅក្នុងគុណដ៏ល្អគ្រប់ពួក ដូចការសែ្វងរកប្រយោជន៍បច្ចុប្បន្ន ទំាងប្រយោជន៍បរលោក ដោយមានពុំបាន មានបំពេញកុសលជាដើម,

៣ – ដឹកនាំពន្យល់បុត្តធីតាឲ្យសិក្សាវិទ្យាសាស្ត្រទាំងផ្លូវលោក ផ្លូវធម៌ ឧបត្ថម្ភប្រដាប់សម្រាប់រៀន សំលៀកបំពាក់ ទំាងអាហារូបករណ៍តាមហានៈរបស់ខ្លួន,

៤ – លុះបុត្តធីតាចំរើនវ័យវឌ្ឍនាហើយ ក៏ចែកសម្បត្តិណាគ្រប់ខ្នះ អសម្បត្តិណាគ្រប់ខ្នះ តាមមានតាមបាន ដើម្បីទុកជាកត្តិយសជាទីរលឹក,

៥ – រៀបចំអាពាហ៍ពិពាហមង្គលឲ្យបុត្តធីតាមានគ្រួសារ តាមត្រកូលដែលសមគួរ ។

សង្គហធម៌ចំនួន ៤ ប្រការនេះសុទ្ធតែជាឧបការគុណដ៏ជ្រាលជ្រៅចូលចូលយូរយូរផុតវិស័យនៃជនដទៃនឹងអាចធ្វើត្រាប់បាន ។

មិនត្រឹមតែប៉ុណ្ណោះ ពោះចំនួនដ៏ជ្រាលជ្រៅគម្លីរគោពន្ធនឹងអាចកំចាំងចាំងប៉ុន្មាន ដែលជាប់ពាក់ពន្ធនៈដោយផ្លូវចំរើន កន្លងផុតលោកបរលោក សឹងនាំយកមកលាតត្រដាងចង្អុលប្រាប់បុគ្គលិកា ដូចពាក្យថា កូនអើយ! ការចាយវាយទ្រព្យខ្ទះខ្ទាយពុំសមហេតុផល យូរៗទៅក៏គង់នឹងវិនាសហិនហោចពុំខាន ដូចថ្នាំសម្រាប់បន្ទាត់ក្អែក, ទឹកត្រែកត្រូវនាច, ដុំសាច់កន្លងអំបែងក្តៅ, អម្បាលត្រូវទឹកជាដើម ហេតុនោះ កូនកុំប្រមាទឲ្យសោះ, ឯការសន្សំទ្រព្យត្រូវទំនងសមតាមហេតុផលវិញតែងបានលូតលាស់ចំរើនកកូនឡើងរៀងរាល់ថ្ងៃ ដូចមេឃ្មុំ, មេកន្ធិ៍ពាំតែសរផ្គាមកធ្វើសំបុកធ្វើទឹកផ្អែម, ចាប់ធ្វើសំបុក, កណ្តៀវកូនត្រៀក, ទឹកគ្មោតកន្លងបំពង់, ទឹកត្រែកជន់ជោរជ្រលោះដែរ ហេតុនោះ កូនត្រូវសំចៃទ្រព្យ ។

ជម្បូនន្ទានដ៏ថ្លៃថ្លូរពោះប្រាប្តប្រយោជន៍ចំពោះបុគ្គលិកានេះ សឹងជាស្មើនៃព្រហ្មវិហារធម៌របស់បុព្វការីបុគ្គល ផ្សាយទៅលើបុគ្គលិកាទាំងឡាយ ។ តែមានជនជាមាតាបិតាខ្លះ កាលខាងកមកចាប់ផ្តើម បែរជាកេងប្តាំមកផឹកលុតចោលចេញ, ខ្លះដល់ខាងក្រៃសូតមក យកទៅកប់ចោលទាំងរស់, ខ្លះគ្រាន់តែចិញ្ចឹមឲ្យរស់ គ្មានទំនុកបំរុងតាមសង្គហធម៌

ទាំង ៥ ម្ចាស់ហើយបុត្តធីតានោះទៅជាល្ងីល្ងើ ស្មើគ្មានឥសត្វ ជាមនុស្ស
ឥតវិជ្ជា ឥតទ្រព្យសម្បត្តិ ឥតធម៌ក្នុងខ្លួន ។ ហេតុនោះ បុព្វការីបុគ្គល
ទើបលោកចាត់ថា ជាបុគ្គលរកបានដោយក្រកន់លោក ។

ឯកតញ្ញូកតវេទីបុគ្គលវិញ គួយ៉ាងដូចបុត្តធីតាត្រូវជាអ្នកឧបត្ថម្ភ
ស្គាល់ទម្ងន់ឧបការនោះ។ ហើយតាំងចិត្តដូច្នេះថា អាត្មាត្រូវតែធ្វើតប
ឧបការនឹងអាក់ខានមិនបាន ហើយស៊ូតែធ្វើការតបស្នងពេញកម្លាំង
មិនបណ្តែតបណ្តោយឲ្យចិត្តលង់ទៅក្នុងអំណាចអវិជ្ជា គឺការមិនដឹងគុណ
នោះឡើយត្រូវតែប្រតិបត្តិតបឧបការធម៌របស់លោក ឲ្យពេញលេញវិញ
ដោយស្ថាន ៥ យ៉ាង ដូច្នេះ

១ - អាត្មាត្រូវតែចិញ្ចឹមលោកវិញ,

២ - អាត្មាត្រូវតែធ្វើកិច្ចដំនួសលោកវិញ,

៣ - អាត្មាត្រូវតែរក្សាវង្សត្រកូលលោកឲ្យល្អ,

៤ - អាត្មាត្រូវតាំងខ្លួនក្នុងគុណធម៌ សមគួរជាអ្នកឧបត្ថម្ភទ្រព្យ
មតិកបាន,

៥ អាត្មាត្រូវតែធ្វើទក្ខិណាទានជូនចំពោះលោកទាំងកំពុងមានជីវ-
កាតនឹងមរណកាតទៅហើយ ។

បុត្តធីតា មិនត្រឹមតែត្រូវធ្វើតបដោយបច្ចុប្បន្នធម៌ទាំង ៥ ប្រការ
ប៉ុណ្ណោះឡើយ ត្រូវធ្វើតបដោយឧបការធម៌ជាន់ខ្ពស់ ៤ យ៉ាងដទៃទៀតគឺ

ត្រូវញុំាងមាតាបិតាឲ្យមានសទ្ធា ឲ្យមានសីល ឲ្យមានចាគៈ ឲ្យមានបញ្ញា ឲ្យសមដល់ទម្ងន់ព្រហ្មវិហារធម៌របស់បុព្វការីជនទាំងនោះ ។

មានបុត្តធីតា២នាក់ ក្នុងលោកប្រកបដោយអវិជ្ជា ជាអ្នកវង្វេងមិនដឹងគុណ មិនធ្វើតបគុណ គឺធ្វើសន្ដានព្រងើយៗ មិននឹកនា មិនគោរពគុណលោក បែរជាប្រវត្ដិចិត្ដទៅជាខៃ ។ មិនសមដល់តម្លៃទឹកចិត្ដរបស់លោកដែលអន្ទោលទៅរកបុត្ដធីតា សមដូចបុរាណកាសិតថា "ម្ដាយវង្វេកកូនដូចចង្រ្កាបដេញ កូនវង្វេកម្ដាយវិញដូចព្រះបែរក្រោយ" ប៉ុណ្ណេះជាដើម ។ ព្រោះហេតុនោះ ទើបកតញ្ញូកតវេទីបុគ្គល គេរកបានដោយក្រកក្នុងលោក ។

មួយទៀត កតញ្ញូកតវេទិតាធម៌មិនមែនជាធម៌ដទៃទេ ពិតជាធម៌របស់អ្នកប្រាជ្ញ ដ្បិតអ្នកប្រាជ្ញត្រូវមានអង្គធម៌ ๔ យ៉ាងជាគ្រឿងទ្រទ្រង់សម្រាប់ចង្អុលបង្ហាញឲ្យឃើញជាក់ស្ដែងក្នុងទីប្រជុំជន; មិនចាំបាច់តែបុគ្គលអ្នកចេះដឹងសព្វវិទ្យា ជាលោកិយនិងលោកុត្ដរៈ ទើបហៅថាអ្នកប្រាជ្ញទេ សូម្បីបុត្ដធីតា ដែលមានអង្គធម៌ដូចខាងលើនេះ លោកក៏ហៅថាអ្នកប្រាជ្ញបានដោយពិត ។ ឯអង្គអ្នកប្រាជ្ញ ๔ យ៉ាងនោះគឺ: កតញ្ញូ-កតវេទិតា๑, អត្ថសុទ្ធិ๑, ធម្មសុទ្ធិ๑, សង្គហៈ๑, រួមជា ๔ យ៉ាង ។

ត្រង់ កតញ្ញូកតវេទិតា ជាអង្គទី ๑ បានដល់ភាពនៃបុត្ដធីតាជាអ្នកដឹងឧបការគុណលោក ហើយធ្វើការដឹងនោះឲ្យជាក់ស្ដែងតបស្នង

ឧបការគុណវិញ ដូចអស់លោកជាទានិស្សរាធិបតីកំពុងចាត់ចែងធ្វើ នេះឯង ។

ត្រង់ អត្តសុទ្ធិ ជាអង្គទី ២ បានដល់ការធ្វើខ្លួនឲ្យបរិសុទ្ធគឺតាំងខ្លួនទុកក្នុងគុណធម៌ថ្លៃថ្នូរ មានមិនសម្លាប់សត្វលួចប្រពៃគេជាដើមដែលជាអំពើថោកទាបដោយផ្ទាល់ខ្លួន ដូចអស់លោកអ្នកជ្រាបកប់ប្រសប់កាន់តាប់មកហើយ ។

ត្រង់ បរសុទ្ធិ ជាអង្គទី ៣ បានដល់ការធ្វើឲ្យបុគ្គលដទៃបរិសុទ្ធគឺមិនត្រាន់តែតាំងខ្លួនទុកក្នុងគុណធម៌ថ្លៃថ្នូរផ្ទាល់ខ្លួនប៉ុណ្ណោះទេ ត្រូវដឹកនាំពន្យល់អ្នកដទៃឲ្យតាំងនៅក្នុងគុណធម៌ដូចខ្លួនផងដែរ ។

ត្រង់ សង្គហៈ ជាអង្គទី ៤ បានដល់ការសង្គ្រោះដួយយឺតយោងសណ្តោងឲ្យរួចពីគ្រោះថ្នាក់ ដោយសង្គហធម៌ ៤ យ៉ាង គឺការបរិច្ចាគទាន ១, និយាយពាក្យពីរោះ ១, ធ្វើការងារជាប្រយោជន៍ជាគំរាតុក្ខមិទុកជាស្មាដៃ ១, មិនប្រកាន់ឫកពាឆ្មើងឆ្មៃ ១ ។ ឯសង្គហធម៌សម្រាប់គ្រួសារដែលជាប់ពាក់ព័ន្ធមកក្នុងសិង្គាលោវាទសូត្រនោះ ក៏សឹងសង្គ្រោះចូលក្នុងអង្គទី ៤ នេះដែរ ។

អង្គអ្នកប្រាជ្ញទាំង ៤ យ៉ាង ដូចរៀបរាប់មកដោយខ្លួសៗនេះ សុទ្ធតែជាអំពើអ្នកប្រាជ្ញ ។ ព្រះគតិវន្តមុនីសម្មាសម្ពុទ្ធទ្រង់សរសើរអំពើអ្នកប្រាជ្ញនេះណាស់ ទ្រង់សំដែងបន្ទាបអំពើពាល តួនតិះដៀលជនពាល

ហើយទ្រង់លើកដំកើងអំពើបណ្ឌិត សរសើរជនបណ្ឌិត ដូចមានក្នុងមង្គលសូត្រថា "ការមិនគប់រកបុគ្គលពាល គប់រកតែបណ្ឌិតជាមង្គល" ដូច្នេះជាដើម ។

សប្បុរសទាំងឡាយ! អាត្មាភាពសំដែងអំពីបុគ្គលរកបានដោយក្រពីរចំពូកដោយសេចក្តីបំប្រួញនេះ ដើម្បីជាផ្លូវគំនិតនៃសាធុសប្បុរស ។ បន្ទាប់ពីនេះ នឹងសូមសំដែងសាថយក្រោយវិញ ដើម្បីសំដែងបញ្ជាក់ត្រង់ពាក្យ "ជីវិកកត្តគាន" តទៅទៀត ។ ជីវិកកត្តគាន គឺធ្វើគាន ទៅសផលជូនបុព្វការីជន គឺមាតាបិតាដែលមានជន្មាយុរស់នៅនាបច្ចុប្បន្ននេះផង ទាំងជូនស្បៀងអាហារ គ្រឿងសំលៀកបំពាក់ ទីដេក ទីនៅសមគួរតាមហានៈរបស់លោក ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានក្នុងកាលសព្វថ្ងៃនេះផង ភ័ព្វបច្ចូលក្នុងជីវិកកត្តគានដែរ ។ សេចក្តីនេះសឹងមានរឿងគោយាតកបុត្តកងក្នុងគម្ពីរធម្មបទជាគោលអាង ៖

សេចក្តីថា មានបុរសម្នាក់នៅជិតក្រុងសាវត្ថីធ្វើបរចិញ្ចឹមជីវិតខ្លួនទំនឹងគ្រួសារ ដោយការពិឃាតគោ ដើម្បីលក់សាច់តែមួយមុខប៉ុណ្ណោះ តាំងពីក្មេងដរាបដល់អាយុ ៥៥ ឆ្នាំ, ម្ល៉ោះហើយការទទួលទានសាច់គោរាងប៉ុណ្ណោះឆ្នាំនោះ ជ្រាក់ទៅជាសម្ផស្សញ៉ាំមជាប់ចិត្តនៃគោយាតកបុរសនោះ ។ ថ្ងៃមួយកងកាលជាខាងក្រោយ គោយាតកបុរសត្រឡប់មកពីលក់សាច់វិញ បានប្រគល់សាច់ ១ ដុំឲ្យភរិយាធ្វើម្ហូបទទួលទាន ហើយ

កំដើរទៅកាន់កំពង់ទឹក, លុះឆ្លងទឹករួចរំលងមក ក៏យោលើកស្លាកជ្រាយមក
ជូនពិសា, ស្រាប់តែពុំឃើញសាច់ គោយាតកបុរសក៏សួរទៅកវិយា ។
ដំរាបថា "ជនជាសំឡាញ់របស់អ្នកឯង គេថាមានក្តៀវទើបនឹងមកដល់ថ្មី
គេរកម្ហូបទទួលក្តៀវនោះពុំបាន គេមកសួរតែសាច់, ខ្ញុំជ្រាប់តែថាសាច់
ក្រៅពីនេះទៀតពុំមានទេ, សូម្បីខ្ញុំឃាត់ហាម គេក៏ពុំស្តាប់, សំឡាញ់អ្នក-
ឯងនោះ នៅចចេសតែកាន់យកសាច់នោះទៅ" ។ គោយាតកបុរសេ
និយាយថា "ឯងលើកស្លាកយកទៅវិញចុះ យើងមិនអាចនឹងបរិភោគ
ជ្រាយដោយឥតមានសាច់គោបានទេ" លុះថាហើយក៏កាន់កាំបិតដើរ
តម្រង់ទៅកាន់ក្រោលគោខាងក្រោយផ្ទះ ចាប់យកគោមួយមកហើយ.
លូកដៃទៅក្នុងមាត់គោកាត់យកអណ្តាតគោត្រឹមគល់មកឲ្យកវិយាចំអិន ។
លុះកវិយាចំអិនឆ្អិនស្រេចលើកមកជូនជាថ្នូ, គាត់ក៏បរិភោគជ្រាយមួយមាត់
អណ្តាតគោមួយមាត់, វេលានោះ គាត់ទំពាសាច់គោក៏ខាំអណ្តាត
របស់ខ្លួនជាប់ធ្លាក់ចុះមកក្នុងចានជ្រាយមួយរំពេច ដោយអំណាចនៃកម្ម
ជាមហស្ចារ្យនោះ, មានឈាមស្រក់ហូរស្រាក់ច្រឡាក់សំពត់អាវ ។
គោយាតកបុរសស្រែកកេងំរដោយជង្គង់ ៤ ដូចគោ មិនយូរថ្លៃក៏ធ្លើកាល
កវិយាទៅរងទុក្ខក្នុងអវីចិនរក ។ ចំណែកគោ ក្រោយពីគោយាតក
បុរសនោះកាត់អណ្តាតយកទៅ ក៏រងទុក្ខវេទនាមានឈាមហូរហាម
ស្រែកកេងំពាំងយប់ពាំងថ្ងៃ មិនយូរប៉ុន្មានក៏ស្លាប់ដីរិតទៅដែរ ។

កាលគោយាតកបុរសជិតនឹងស្លាប់នោះ នាងព្រាហ្មណីជាភរិយានិយាយនឹងបុត្រប្រុសរបស់ខ្លួនម្នាក់ថា "នែកូន! មើលចុះបិតារបស់អ្នកវារដោយជង្គង់ ៤ ដូចគោ ស្រែកពេទំាងយប់ទាំងថ្ងៃ, សេចក្តីទុក្ខនេះក្រែងធ្លងមកដល់អ្នកផងដឹង? ដូច្នេះអ្នកកុំគិតម្តាយឡើយ ត្រូវអ្នកវត់ទៅរកទីណាដែលមានសួស្តីហើយនៅជាសុខចុះ[1] ។ ឯបុត្តហេតុតែខ្លាចសេចក្តីមរណៈ ក៏សំពះលាមាតាវត់ទៅកាន់ដែនតក្កសិលា បានចូលទៅរៀនធ្វើការក្នុងផ្ទះនាយជាងមាសម្នាក់ នាយជាងក៏ស្រឡាញ់រាប់អានខ្លាំងចិត្តស្មោះអស់ពីដួងហឫទ័យ ដកបដល់លើកធីតារបស់ខ្លួនដែលមានវ័យគ្រប់ការ ឲ្យជាភរិយារបស់គោយាតកបុត្តនោះ ។

តពីនោះមក ជាងមាសដែលជាបុត្តរបស់គោយាតកក៏បានលួតលាស់ចំរើនដោយកោគុណនឹងបុត្តធីតា ។ លុះគាត់ចាស់ជរា ពួកបុត្តធីតានៃជាងមាសនេះ បានរៀនចំណេះវិជ្ជាសិល្បសាស្ត្រពេជាងមាសស្ទាត់ជំនាញ ហើយក៏ត្រឡប់មកកាន់ក្រុងសាវត្ថីដែលជាមាតុប្រទេសរបស់ដីតាវិញ តាំងគេហដ្ឋាននៅក្នុងក្រុងសាវត្ថីនោះ ។ អាស្រ័យការសេពគប់នឹងសប្បុរស កូនជាងមាសក៏កើតសទ្ធាជ្រះថ្លាមុតមាំក្នុងសន្តាន

---

១ សេចក្តីនេះ គួរនឹងចាប់ថ្នាក់ថា បិតាកំពុងវេទនាជិតនឹងស្លាប់បែរជាវត់ចោល ប៉ុន្តែត្រង់នេះប្រហែលព្រះគន្ថរចនាចារ្យលោកស្រួតរួចទៅសំដែងខាងមុខ។ ត្រង់ដ៏វិកភត្តខាន ឲ្យជាសេចក្តីពិស្តារវិញ ។

ទើបប្រឹក្សាគ្នាថា "បិតារបស់យើង កាលនៅឯដែនតក្កសិលា លោកមិនដែលបានធ្វើការកុសលអ្វីមួយដែលជាអំពើគាប់ប្រសើរសោះ ឥឡូវលោកមានវ័យចាស់ជរាហើយ" ទើបបុត្តធីតាទាំងនោះដំរាបបិតាថា "បពិត្របិតា! ពួកយើងខ្ញុំជាកូនទើបថ្វាយទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ដើម្បីឧទ្ទិសផលជូនដល់បិតា ក្នុងថ្ងៃស្អែកនេះ" ។ លុះព្រឹកឡើង បុត្តធីតាទាំងនោះក៏បានអង្គាសចង្ហាន់ថ្វាយព្រះសម្ពុទ្ធព្រមទាំងព្រះសង្ឃ កាលបើស្រេចកត្តកិច្ចហើយ ទើបគ្រាបបង្គំទូលព្រះមានព្រះភាគថា "បពិត្រព្រះសុគត! ខ្ញុំព្រះអង្គទាំងឡាយថ្វាយដីវកកត្តនេះដល់ព្រះអង្គ ដើម្បីសម្រេចផលដល់បិតា; សូមព្រះអង្គធ្វើអនុមោទនាចំពោះបិតារបស់ខ្ញុំព្រះអង្គឲ្យបាន" ។

ព្រះសម្ពុទ្ធក៏ទ្រង់ជាស់តឿនគោឃាតកបុត្ត (ជាឯមាស) ដោយព្រះពុទ្ធដីកាថា "នែឧបាសក! រូបអ្នកចាស់ហើយ មានសរីរៈខ្ទេចខ្ទាំហើយ ប្រហែលជួចស្លឹកឈើខ្ទេចខ្ទាំ, ចំណែកកុសល់ជាស្បៀងក្នុងដំណើរតាមផ្លូវនឹងទៅកាន់បរលោករបស់អ្នកៗ ពុំមានមានសោះ ដូច្នេះអ្នកត្រូវប្រញាប់ធ្វើទូវកុសលជាទីពឹងរបស់ខ្លួន, អ្នកត្រូវតាំងខ្លួនជាឫស្សិតកុំតាំងខ្លួនជាដនពាលឡើយ" ព្រះអង្គទេសនាខំនេះអស់រយៈពីរថ្ងៃ ។ លុះចប់ទេសនា ក្នុងថ្ងៃជាគំរប់ពីរ គោឃាតកបុត្តនោះក៏បានតាំងនៅក្នុងអនាគាមិផល ។

បពិត្រសប្បុរសចាំងឡាយ ! រឿងគាយាតកបុត្តដែលអាត្មាភាពបាននាំមកដោយសេចក្តីសង្ខេបនេះ ជាគាលសម្រាប់កាត់បង់នូវការងឿងឆ្ងល់ក្នុងដំរិះកត្តិជានផង ហើយជាលំអានដ៏ថ្លៃថ្លាសម្រាប់ពុទ្ធបរិស័ទផង ។

ធម្មតាបុគ្គលកុងលោក រមែងបានកប់ប្រសប់ទទួលដំណើរចាំងពីរគឺ ដំណើរបុព្វការីបុគ្គលនឹងកតញ្ញូកតវេទីបុគ្គលពាល់ព្រមតែគ្នាជាងបានឡើយ ។ បុព្វការីបុគ្គលជាអ្នកធ្វើឧបការមុន ។ ឯកតញ្ញូកតវេទីបុគ្គលត្រូវជាអ្នកធ្វើតបស្នងវិញ ។ តែការណ៍នេះ មិនមែនចេះតែបានសម្រេចលទ្ធផលតាមសមប្រកបទេ ព្រោះថាលុះតែបុគ្គលចាំងពីរក្រុមនេះ មានបញ្ញាការណៈឫងយល់ស្របគ្នា ឬមានបុណ្យកំពូរស្មើគ្នា ទើបសម្រេចលទ្ធផលចាំងសងខាងទៅបាន, បើមិនស្របគ្នាហើយ ក៏មិនអាចនឹងសម្រេចផលទៅបានទេ សមដូចសុភាសិតរបស់ដីកាចារ្យថា កិប្បត្តា អប្បញ្ញា ជឹងា ជនអ្នកឥតបុណ្យ តែងបានបុត្តធីតាមិនល្អ កុទ្ទាសា អប្បញ្ញា ជឹងា ជនអ្នកឥតបុណ្យ តែងបានខ្ញុំប្រុសស្រីមិនល្អ ប៉ុណ្ណោះជាដើម ជានិយសម្រាប់និច្ឆ័យក្នុងរឿងនេះ ។

ក្នុងសម័យនេះ អស់លោកអ្នកជាបុត្តធីតានៃឧបាសិកានាម ប្រុងប្រៀងចូលក្នុងបុត្តធីតាល្អគួរជាទីសរសើរ ព្រោះមានកតញ្ញូកតវេទិតា-

ធម៌ចំពោះមាតា ត្រូវតាមគន្ថធម៌អ្នកប្រាជ្ញតែងមានឃ្យាងឃ្យាត, គួរតែមានសេចក្តីរីករាយជាកំយ្យាភាព ចំពោះការបរិច្ចាគទេយ្យវត្ថុតបស្នងដ៏ថ្លៃថ្លាក្នុងបច្ចុប្បន្ននេះថា អាត្មាមានលាភបានធ្វើបុណ្យចំលើអគ្គអរហន្ត គឺមាតាដែលកុំពុងមានជន្មាយុរស់នៅ ។ ពាំងនាសិកានាម ប្រធុមជាមាតាសោត ក៏សង្រ្គោះបួលក្នុងពួកជនអ្នកមានបុណ្យមានជោគវាសនាមួយដែរ ព្រោះបានទទួលបតិការៈ ការតបស្នងដ៏ខ្ពង់ខ្ពស់អំពីបុត្តធីតាពាំងនេះឃើញជាន់ក្បែក ហើយគួរតែអង្អែលផ្ទៃពោះខ្លួនដោយមនោសញ្ចេតនាប្រមោជរីករាយចំពោះការកើតផ្ទៃ ថាផ្ទៃពោះអញ ពេញជាមានតំព្ងណាស់ ព្រោះបានកូនមកសុទ្ធតែប្រកបដោយធម៌, ដូចគាលព្រះសិរីមហាមាយាពុទ្ធមាតា ដែលបានស្តាប់ពាក្យសរសើរពុទ្ធគុណនឹងពាក្យអញ្ជើញព្រះនាងមកស្តាប់ព្រះអភិធម្ម ឯស្ថានតាវត្តឹង្សអំពីសំណាក់សក្កទេវរាជហើយ នាងក៏ស្ទើចស្ទប់ស្រែងនឹកសរសើរផ្ទៃព្រះនាងថា “ឧហ្ន៎! ផ្ទៃរបស់អាត្មាហៅពេញជាមានលាភមានសំណាងបំផុតបានពព្រះពុទ្ធមួយព្រះអង្គជាអ្នកប្រាជ្ញឆ្នើមក្នុងលោក” ។ ព្រះនាងក៏ត្រេកអរឥតឧបមា ហើយគមនាការមកកន់ស្ថានតាវត្តឹង្សជាមួយនឹងព្រះឥន្ទ្រាធិរាជ នាគ្រានោះឯង ។

មួយទៀត ពុទ្ធទិបណ្ឌិតតែងសរសើរអ្នកដឹងគុណហើយធ្វើតបគុណនេះជាអនេកបរិយាយ ព្រោះការនេះជាប្រធាននៃកុសលពាំងពួង ដោយមានបទថ្លៃថា កតញ្ញូតា ធម្មមូលា សេចក្តីដឹងគុណ ធ្វើតប-

គុណ ជាឫសគល់នៃធម៌ទាំងឡាយ កតញ្ញូតា បជានតា លោកសេចក្តីដឹងគុណ ធ្វើតបគុណជាអំពើប្សង់កន្លងលោក ។ បុពណ្ហបណ្ឌិតទាំងឡាយលោកតែងបំពេញធម៌នេះរៀងរាល់រូប ព្រោះជាបវេណីធម៌សម្រាប់កាលទាំងពួង ពោះកន្លងពុទ្ធកាលក្តី ក្រៅពុទ្ធកាលក្តី ធម៌នេះគង់នៅថ្កើរស្រស់បំព្រងឥតមានចាស់ស្រិតស្រពោនសាបសូន្យទៅទេ ។ ជនដែលបានបំពេញធម៌នេះនឹងត្រូវទទួលលទ្ធផលគឺមានអាយុវែង រមែងជាអ្នកគេចផុតអំពីទុបសគ្គតូចធំផ្សេងៗបាន ទាំងបច្ចុប្បន្នទាំងបរលោក, ទាំងនាយបំផុតនឹងបានសម្រេចពុទ្ធញ្ញាណ បច្ចេកពោធិញ្ញាណ សាវកពោធិញ្ញាណ ចូលកាន់សីវិស្ថានគឺព្រះនិព្វាន សមគួរតាមវាសនាបារមីរៀងខ្លួនពុំសោះសូន្យឡើយ ។

អាត្មាភាពពណ៌នាមកក្នុងមគ្គកត្តជាន នឹងដំកកត្តជាន សូមបញ្ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។ តែមុននឹងបញ្ចប់នេះ អាត្មាភាពសូមឲ្យតេជានុភាពបុណ្យនៃដំកកត្តជាននេះ ជួយទុបត្តម្ភគាំពារទុជាសាសនាប្រធុម ឲ្យបានជាសះស្បើយចាកភោគាពាធ ឲ្យមានកម្លាំងមាំមួនចាប់តាំងពីថ្ងៃនេះរៀងទៅ !

ចំណែកអស់លោកអ្នកជាបុត្តធីតាមានលោកទុកញ្ញា" យឺន - ប៊ីម ជាដើម ដែលជាអ្នកមានកតញ្ញូបានធ្វើកុសលនេះជូនមាតា សូមឲ្យកុសលនេះជួយឲ្យបានសម្រេចតាមន្ទាញផលតាមក្តីប្រាថ្នាកុំបីឃ្លៀងឃ្លាត !

# ឃុនបណ្ណាគុរក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែចាកភ្ជាប់ធម្មចក្ស អក្សរថៃ

---

សមភាព គឺភាពជាអ្នកស្មើគ្នាក្នុងពួកមនុស្ស ជារឿងដែលគេច្រើនតែនិយាយគ្នាក្នុងលោក ហេតុនេះ គួរនិយាយសមភាពក្នុងផ្លូវធម៌ខាងសាសនាផង ឲ្យយើញជាគូគ្នា ដើម្បីប្រៀបធៀបមើលដោយហេតុផលថា សមភាពនោះ យើងគួរព្រមទទួលត្រឹមណា ទើបនឹងបានជាការសមរំលឹ ។

## សភាពក្នុងលក្ខណៈធម្មតា

មនុស្សយើងដែលកើតមកហើយតែងតែប្រែប្រួលទៅដោយលំដាប់ មិនតាំងនៅដូចដើមទេ គឺតាមដែលមើលយើញ តាំងពីសម្រាលចាកគភ៌មាតាមកជាកូនខ្ចី ចេះតែចំរើនវ័យឡើងជាក្មេងធំ ជាក្មេងដំទង់ ជាកំឡោះក្រមុំ ជាកណ្តាលមនុស្ស ហើយក៏ចាស់ជាតូច្នេះតាម ថយចុះដោយលំដាប់ទៅវិញ រហូតដល់ទីបំផុតក៏ស្លាប់ ដូចគ្នាគ្រប់មនុស្សទាំងអស់ ឥតរើសមុខថាអ្នកណាឡើយ ។ នេះជាលក្ខណៈមួយដែលមានស្មើគ្នាទៅក្នុងពួកមនុស្សគ្រប់រូប. ក្នុងព្រះពុទ្ធសាសនា ហៅថា អនិច្ចលក្ខណៈ ប្រែថា "លក្ខណៈមិនទៀងទាត" ។

មួយទៀត គ្រប់មនុស្សដែលកើតមកមានសង្ខារកាយហើយរមែងមានទុក្ខប្រចាំជាប់មកតែម្តង ព្រោះសង្ខារកាយនេះទន់ខ្សោយ

រស់នៅបាន តែត្រូវតែអាស្រ័យបច្ច័យជាគ្រឿងបន្ត មានអាហារទឹក អាកាសជាដើមចាំជួយឧបត្ថម្ភជានិច្ច ទើបមានអាការស្រែកឃ្លានក្នុង វេលាត្រូវការអាហារជាដើម មនុស្សទើបត្រូវតែថែរក្សាទំនុកបម្រុងឲ្យ សមគួរតាមសេចក្តីត្រូវការ ជាការដែលត្រូវចាត់ការមិនចេះៗសល់ហើយ ។ ប៉ុន្តែកាលបើមនុស្សមិនបានគិតពិចារណាមើល ច្រើនតែមិនសូវដឹងរឿង នេះ ហើយនៅមានទុក្ខដទៃៗមានសេចក្តីឈឺចាប់ជាដើមចូលមកចៀត ចៀនទៀត យ៉ាងនេះស្មើគ្នាតាំងអស់តតាំសម្បុរ ។ នេះជាលក្ខណៈមួយ យ៉ាង ដែលមានស្មើគ្នាខ្ជាក់ក្នុងពួកមនុស្ស, ក្នុងព្រះពុទ្ធសាសនា ហៅថា ទុក្ខលក្ខណៈ ប្រែថា "លក្ខណៈជាទុក្ខ" ។

មួយទៀត សេចក្តីប្រែប្រួលនៃសង្ខារពាងកាយ នឹងសេចក្តីទុក្ខ ផ្សេងៗដែលមានប្រចាំសង្ខារ សូម្បីជារបស់ដែលមនុស្សមិនត្រូវការ មិនចង់ថា ប៉ុន្តែមិនអាចនឹងតែងប្តូរគេចចៀសវាងឲ្យផុតទៅបាន តែងតែ ត្រូវកើតមានដូច្នោះតាមសភាពរបស់សង្ខារពាងកាយ ព្រោះមិននៅក្នុង អំណាចរបស់អ្នកណា ។ ភាពជារបស់មិននៅក្នុងអំណាច បង្គាប់បញ្ជា របស់អ្នកណានេះឯង ជាលក្ខណៈមួយយ៉ាងដែលមានស្មើគ្នាខ្ជាក់ក្នុងពួក មនុស្ស, ក្នុងព្រះពុទ្ធសាសនា ហៅថា អនត្តលក្ខណៈ ប្រែថា "លក្ខណៈមិនមែនជារបស់នៃខ្លួន" ។

លក្ខណៈទាំង ៣ ប្រការនេះ មានស្មើគ្នាខ្ជាក់ក្នុងពួកមនុស្សទាំង ពួងដែលចាត់ថាជាសង្ខារប្រភេទមួយ ហៅថា ខន្ធបញ្ចកសង្ខារ ប្រែថា

"សង្ឃារមានចិត្តត្រង់ត្រង" លោកនើបហៅថា សាមញ្ញលក្ខណៈ ជាន សេចក្តីថា មនុស្សត្រង់រូប មានកេត, ចាស់, ឈឺនឹងស្លាប់ដូចគ្នាទាំង អស់ នើបឈ្មោះថាជាអ្នកស្មើគ្នា ដោយលក្ខណៈធម្មតា ៣ ប្រការនេះ មិនទៀង, ជាទុក្ខ, ជាអនត្តា មិនប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នា ។ រឿង នេះជាសេចក្តីពិត ដែលសម្តេចព្រះបរមសាស្តាទ្រង់សំដែងដោយហេតុ ផល; កាលបុគ្គលពិចារណា ដោយហេតុផលហើយ រមែងយល់ឃើញ តាមការណ៍ពិត គ្មានចន្លោះដែលនឹងទង់ទាញហាមឃាត់ជាន ។ នេះឯង ជាសមភាព គឺភាពជាអ្នកស្មើគ្នាក្នុងពួកមនុស្សដោយលក្ខណៈធម្មតា ។

## សមភាពក្នុងសេចក្តីប្រព្រឹត្តិ

ប្រការមួយទៀត សេចក្តីប្រាថ្នាសុខនឹងមិនប្រាថ្នាទុក្ខ រមែងជា សេចក្តីចេះដឹងស្មើគ្នាក្នុងពួកមនុស្សទាំងពួង ។ រឿងនេះជាសេចក្តីពិត អ្នកដែលត្រូវការប្រាថ្នាសេចក្តីទុក្ខលំបាក សូម្បីតែមានតែម្នាក់ក៏គ្មានក្នុង លោក, គ្រប់មនុស្សសុទ្ធតែប្រាថ្នាសុខទាំងអស់គ្នា ប៉ុន្តែមនុស្សទាំងអស់ នឹងមានសុខស្មើគ្នាក៏ទេ ព្រោះសុខមិនមែនសម្រេចដល់បុគ្គលដោយ គ្រាន់តែមានចិត្តប្រាថ្នាប៉ុណ្ណោះឡើយ ត្រូវតែអាស្រ័យហេតុ គឺការស្វែង រកនឹងការប្រកបធ្វើ ។ អ្នកឈ្លាសវៃដឹងស្គាល់ហេតុនៃសុខហើយធ្វើត្រូវ តាមហេតុ រមែងបានសុខដូចប្រាថ្នា ។ ចំណែកអ្នកល្ងង់ខ្លៅ ធ្វើដោយ ស្មានដោយមិនទាន់បានដឹងហេតុនៃសុខជាមុន តែងប្រទះសុខដោយគាប់

ជួនខ្លះ ឃ្លាងទេទៀតខ្លះ ។ ព្រោះហេតុនោះមនុស្សក្នុងលោកសូម្បី
ស្រឡាញ់សុខស្មើគ្នា ប៉ុន្តែបានសុខមិនស្មើគ្នាទេ សូម្បីដូច្នោះ ក៏នៅ
តែឈ្មោះថា ជាអ្នកស្មើគ្នាដោយសេចក្តីជ្រាបថាសុខនឹងជ្រាបថាឲ្យផុត
ទុក្ខ ។ ដោយហេតុនេះ មនុស្សគ្រប់រូបអ្នកត្រូវការសុខ ត្រូវតែ
បណ្តុះបណ្តាលសេចក្តីចេះដឹងហេតុនៃសុខនឹងទុក្ខឲ្យកើតមានឡើងក្នុងខ្លួន
ដើម្បីចៀសវាងហេតុនៃទុក្ខចេញ ប្រកបហេតុនៃសុខតែម្យ៉ាង ទើប
នឹងបានសុខដូចសេចក្តីជ្រាបថា ។

កាលបើសុខជាទីជ្រាបរបស់មនុស្សទូទៅ ឥតសល់ម្នាក់យ៉ាងនេះ
ហើយ វត្ថុណានាំសុខមកឲ្យ វត្ថុណាជាកន្លែងកើតនៃសុខ វត្ថុនោះតែង
ជាទីជ្រាបរបស់មនុស្សទូទៅឥតសល់ម្នាក់ដូចគ្នាដែរ ។ កាលបើមនុស្ស
គ្រប់រូបនាំគ្នាជ្រាបតែវត្ថុមួយដូចគ្នាយ៉ាងនេះហើយ ក៏ត្រូវតែប្រណាំង
ប្រជែងដណ្តើមគ្នាជាធម្មតា ដូចជាការប្រឡងចំណេះវិជ្ជា ដើម្បីដណ្តើម
យកនាទីឋានន្តរសក្តិ ។ កាលបើការដណ្តើមគ្នាកើតមានឡើងហើយ
សេចក្តីខ្ពើសខាក់ខ្ពាំងខ្ពប់ថ្ងាំងថ្ងាក់អាក់អន់ចិត្តក្តៅក្រហាយចិត្តនឹងគ្នាក៏កើត
មានឡើង ។ កាលបើការទាំងនេះកើតមានឡើងហើយ សេចក្តីវាទំ
ឈ្លោះប្រកែកគ្នា សេចក្តីអាឃាតព្យាបាទបំផ្ងិចបំផ្លាញគ្នា ក៏រមែងមាន
ឡើង នឹងសេចក្តីបៀតបៀនផ្តន្ទាឈ្លានីះគ្នាក៏ត្រូវមានតាមគ្នាមកដែរ
ព្រមជាមួយនឹងសេចក្តីទុក្ខលំបាក ក្តៅក្រហាយដោយប្រការផ្សេងៗ ។

កាលបើដូច្នេះ ផ្លែលោកនឹងជាសុខដូចសេចក្តីជ្រុះថ្នា កំប្រែក្លាយទៅជាបានខុសលំបាកក្តៅក្រហាយ ដែលមិនមានអ្នកណាជ្រុះថ្នាឡើយ ។ រឿងនេះចង្អុលឲ្យឃើញថា មនុស្សជាច្រើនរូបធ្វើខុសច្បាប់នៃសមភាពនឹងខុសសេចក្តីជ្រុះថ្នារបស់ខ្លួនឯង ពាំងនេះ កំព្រោះតែសេចក្តីជ្រុះថ្នារបស់ខ្លួនឯងនោះហើយជាដើមហេតុ ។

ដើម្បីនឹងការពារផលដែលមិនគួរជ្រុះថ្នា មិនឲ្យកើតឡើងបាន ដើម្បីនឹងឲ្យមនុស្សផុតចាកសេចក្តីបៀតបៀនបំផ្លាញគ្នា មនុស្សគ្រប់រូបទើបត្រូវតែមានសមភាពក្នុងសេចក្តីប្រព្រឹត្តចំពោះគ្នា· គឺថាពាំងអស់គ្នាត្រូវតែប្រព្រឹត្តកន្លងផ្លូវដែលនឹងមិនប្រទូសរ៉ាយ ចំពោះសមភាពក្នុងសេចក្តីជ្រុះថ្នារបស់គ្នានឹងគ្នាមួយជាន់ទៀត ។ សមភាពក្នុងសេចក្តីប្រព្រឹត្តនេះ ក្នុងព្រះពុទ្ធសាសនាព្រះបរមសាស្តាទ្រង់បញ្ញត្តហៅថា ៖

សីលសាមញ្ញតា "ភាពជាអ្នកស្មើគ្នាដោយសីល" ។ សីលប្រែថា ប្រក្រតី សំគាល់សេចក្តីថា មិនកំរើក. ភាពជាអ្នកស្មើគ្នាដោយសីល សំគាល់សេចក្តីថា ភាពជាអ្នកមានសេចក្តីប្រព្រឹត្តផ្លូវកាយវាចារៀបរយស្មើគ្នា ជាដល់រឿងចាកការសម្លាប់រហូតដល់ការប្រទូសរ៉ាយកាយ ១ រឿងចាកការលួចទ្រព្យសម្បត្តិរហូតដល់ការលំអៀងទ្រព្យរបស់អ្នកដទៃ ១ រឿងចាកការតន្ធល់ស្មើសក្នុងកិរិយានឹងប្តីប្រពន្ធរបស់អ្នកដទៃ ១ រឿងចាកការនិយាយកុហកបំផ្លាញប្រយោជន៍របស់អ្នកដទៃ ១

វៀរចាកការសេពរបស់ស្រវឹងមានសុភជាៈដ៏មវែលធ្វើឲ្យខូចស្មារតីមិនដឹងខុសនឹងត្រូវ ១ រួមជា ៥ ប្រការ ហៅថា បញ្ចវេរវិរតិ ប្រែថា "វៀរចាកពៀរច្បាំ" ព្រោះការប្រព្រឹត្តកម្ម ៥ ប្រការនេះ ជាការកេងឲ្យកើតពៀរ គឺសេចក្តីអាឃាតព្យាបាទបំផ្ទិចបំផ្ទាញគ្នាឲ្យកើតមានឡើង ។

មែនពិត ជីវិតនឹងកាយវែងជាទីស្រឡាញ់របស់មនុស្សទូទៅ រហូតដល់សត្វមានជីវិតតាំងពួង កាលបើមានគេប្រទូសរ៉ាយ ក៏វែងឈឺចាប់រាំបាក ហើយចងអាឃាតព្យាបាទតបទៅវិញខ្លះ ទាំងអ្នកធ្វើទាំងអ្នកវង់អំពើក៏គ្មានប្រក្រតីសុខទាំងអស់គ្នា ចេះតែមានពៀរមានភ័យជានិច្ច ព្រោះគំនិតក្រុងប្រទូសរ៉ាយបំផ្ទិចបំផ្ទាញគ្នា ។ ទ្រព្យសម្បត្តិរបស់អ្នកណា អ្នកនោះតែងតែស្រឡាញ់ប្រកាន់ស្តាយ កាលបើមានចោរលួចឆក់ជណ្តើមប្លុកចាត់បង់ទូចខាតទៅ ក៏តែងតូចចិត្តកើតទុក្ខសោកស្តាយកើតគំនិតគុំគួនចងអាឃាតដល់អ្នកធ្វើ ។ បុត្រកិរិយាវែងជាទីស្រឡាញ់ជាទីជាប់ចិត្តអាឡោះអាល័យ កាលបើមានការកន្ធរលើសកើតឡើងធ្វើសែស្រឡាយ នៃវង្សត្រកូលឲ្យច្របូកច្របល់សៅហ្មងមិនស្អាតបរិសុទ្ធជាទីមើលងាយ ។ មនុស្សយើងគ្រៃពីការស្រឡាញ់បុត្រកិរិយាហើយវែងមានសេចក្តីស្រឡាញ់វង្សត្រកូលយ៉ាងវៃលែង ព្យាយាមនឹងគ្រប់គ្រងថែរក្សាឲ្យបរិសុទ្ធផូរផង់តាមសេចក្តីនិយមរបស់លោក កាលបើមានគេហ៊ានប្រមាថមើលងាយប្រព្រឹត្តកន្ធរប្រពៃណីហើយ ក៏កើតសេចក្តី

ក្តៅគ្រហាយឈឺចាប់ចង់តំនុំគាយាតព្យាបាទ ។ មនុស្សក្នុងលោក
កាលបើថាដោយគោលធម៌ហើយ សុទ្ធតែត្រូវការសេចក្តីស្នេហ៍ត្រង់ដល់
គ្នាទាំងអស់ សូម្បីពាក្យសំដីដែលនិយាយគ្នា ក៏ប្រាថ្នាឲ្យបានពុំបាន
ស្តាប់តែពាក្យដែលពិតប្រាកដ មិនកុហកបញ្ឆោត ព្រោះពាក្យពិត
មិនធ្វើឲ្យខូចប្រយោជន៍ មានតែឲ្យសម្រេចប្រយោជន៍ ទើបធ្វើឲ្យជាទី
ជឿទុកចិត្តដល់គ្នាទៅវិញទៅមក សឹងជាផ្លូវផុតភ័យយ៉ាងឯក ។ លោក
នេះ បើមានតែសេចក្តីពិតដល់គ្នាទើបគ្នាហើយ ទើបសូម្បីជាប្រកតី សុខ
គ្មានអ្វីប្រៀបផ្ទឹមបាន ប៉ុន្តែប្រពឹត្តទៅមិនកើត ព្រោះមនុស្សក្នុងលោក
មានកិលេសហើយឃើញតែខ្លួនឯងមួយ ។ សូម្បីអ្នកណាក៏ដោយ
កាលបើមានគេនិយាយកុហកបញ្ឆោតហើយ ក៏រមែងចូលចិត្តឮសហើយ
ជំណើរការឮសទៅតាម ខូចខាតប្រយោជន៍ដែលខ្លួនទើបត្រូវបានត្រូវ
សម្រេច ។ ព្រោះហេតុនោះ បានជាគ្មានអ្នកណាចូលចិត្តស្តាប់ពាក្យ
កុហកសោះ សូម្បីខ្លួនអ្នកដែលច្រើនតែនិយាយកុហកគេ ក៏មិនចូល
ចិត្តឲ្យអ្នកណាមកនិយាយកុហកខ្លួនវិញដែរ ចូលចិត្តឲ្យគេនិយាយតែ
ពាក្យពិត កាលបើមានគេនិយាយកុហកក៏កើតគ្រោធឡើងស្អប់ខ្ពើមលែង
ជឿទុកចិត្តគេតទៅមុខទៀត ខ្លួនអ្នកដែលមិនចូលចិត្តពាក្យកុហកសោះ
ក៏ចេះតែនៅនិយាយកុហកគេជាដរាប ជាអ្នកប្រទូសព្រៃយដល់គោលធម៌
ក្នុងខ្លួនឯង ទើបជាអ្នកប្រទូសព្រៃយដល់គោលធម៌របស់លោក ឈ្មោះថា

ចំណាយប្រយោជន៍ខ្លួនឯងនឹងអ្នកដទៃ តាំងពីវាចា ព្រោះសេចក្តីឃ្លៀងឃ្លាតលែងទុកចិត្តគ្នាកើតមកតែអំពីមនុស្សពៀប ច្រើនតែនិយាយកុហកជាគ្រឿង ។ ការធ្វើ ការនិយាយ, ការគិត ដែលនឹងប្រព្រឹត្តទៅក្នុងផ្លូវត្រូវ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងនឹងអ្នកដទៃនោះ រមែងកើតមានដល់អ្នកមានសតិជុំវិញ ។ ធម្មតាសាមញ្ញជន សូម្បីកាលនៅមិនទាន់ស្រវឹងក៏គង់តែមានវេលាក្ងេចក្ងាំង ធ្វើខុស និយាយខុស គិតខុសបង្កសេចក្តីវិនាសដល់ខ្លួននឹងអ្នកដទៃ កាលបើចេះតែសេពរបស់ស្រវឹងធ្វើឲ្យខូចសតិថែមលើសដើមឡើងទៀត សេចក្តីខុសខូចកោងកាចអាក្រក់រឹងតែតែមានកម្លាំងខ្លាំងឡើងពាល់តែផុតថា នឹងនិយាយក៏មិនអស់មិនចប់ មានគំរូនៅគរគោក និយាយយ៉ាងដាយៗ ត្រង់ក.របង្កសេចក្តីរំខានចិត្តដល់អ្នកនៅជិតខាងជូចជាក្នុងក្រុមគ្រួសាររបស់ខ្លួន លោកថាអ្នកស្រវឹងស្រាហើយ តែងបង្កពៀរ ៥ ប្រការខាងដើមបានដោយងាយណាស់ ព្រោះហេតុនោះការផឹកទឹកស្រវឹង ទើបចាត់ថាជាហេតុកពៀរភ័យ ។ ចំណែកបញ្ចុះវេរវិរតិ គឺការលះវៀរចាកពៀរ ៥ ជាគុណធម៌ពាក់ព័ន្ធពៀរក្នុងលោក នឹងចាត់ថាជាសីល ព្រោះធ្វើលោកឲ្យជាប្រក្រតីសុខ ប្រាសចាកការបៀតបៀនបំផ្លាញគ្នានឹងគ្នា ។ កាលមនុស្សតាំងពួនតាំងចិត្តរក្សាសីល ៥ ប្រការនេះជានិច្ច មិនហ៊ានឈានតន្ទឹងព្រោះហេតុអ្វីៗហើយ មនុស្សគ្រប់រូបក៏ឈ្មោះថាមានសមភាពក្នុងសេចក្តីប្រព្រឹត្តិ

សមជាមនុស្សដែលគប់ថាមានអាវុធមិ ។ ការដែលមនុស្សគ្រែប់រូបជា
អ្នកមានសីលស្មើគ្នានេះឯង ហៅថា សីលសាមញ្ញតា ភាពជាអ្នក
ស្មើគ្នាដោយសីល ។

អ្នកណាប្រព្រឹត្តបែកផ្សេងខុសនឹងបក្សពួករបស់ខ្លួន ដោយគ្រឡប់
យល់ឃើញរបស់ដែលគេនិយមថាអាក្រក់ថានាស ក៏ឃើញរបស់ស្អ អ្នក
នោះរមែងជាទីស្អប់ខ្ពើមជាច័រឆ្កៀស របស់ពួកដែលបែកចាកពួកទៅ
ដែលហៅថា បែកសាមគ្គី រមែងឲ្យផលអាក្រក់ដល់ខ្លួនឯង នឹងប្រ
ពាញកំឡាំងរបស់ពួកឲ្យថយចុះ ព្រោះហេតុនោះ សីលសាមញ្ញតា
ទើបចាត់ថាធម៌ជាទីតាំងនៃសាមគ្គីផង ។

## សមភាពក្នុងសេចក្តីយល់ឃើញ

មនុស្សគ្រែវតែនៅរួបរួមគ្នាជាពួកទើបបាន គ្រែពឹងពាក់អាស្រ័យគ្នា
គ្រែរួមកម្លាំងជួយគ្នារក្សាពួករបស់ខ្លួនឯង សូម្បីមានសេចក្តីស្មើគ្នាដោយ
ការប្រព្រឹត្តល្អ ជាគ្រឿងការពារសេចក្តីបៀតបៀនបំផ្លាញគ្នាហើយក្តី
ប៉ុន្តែបើមានសេចក្តីយល់ឃើញមិនស្មើគ្នាទេ រមែងជាហេតុឲ្យបែកសាមគ្គី
រវាងទាស់ខែងគ្នា ចង្អុលកម្លាំងគ្នាឯង នាំសេចក្តីវិនាសមកឲ្យដល់ពួក
គណៈរបស់ខ្លួនឯង ។ ព្រោះហេតុនោះ មនុស្សអ្នករួមគ្នាជាពួកគណៈ
គ្រែវតែមានសមភាពក្នុងសេចក្តីយល់ឃើញខ្លះមិនបានទេ ដើម្បីជាគ្រឿង
ការពារសេចក្តីបែកសាមគ្គី ។ សមភាពក្នុងសេចក្តីយល់ឃើញនេះ
ជាពាក្យក្នុងព្រះពុទ្ធសាសនា ព្រះបរមសាស្តាទ្រង់បញ្ញត្តហៅថា ៖

ទិដ្ឋិសាមញ្ញតា "ភាពជាអ្នកសើគ្នាដោយសេចក្តីយល់ឃើញ" ។

សេចក្តីយល់ឃើញនោះ ភោលនេះ ឧបាសនវោហារថា ទិដ្ឋិ ជាពាក្យកណ្តាល ។ បើសំគាល់សេចក្តីខាងល្អ ថែម សម្មា នៅខាងដើមជា សម្មាទិដ្ឋិ (សេចក្តីយល់ឃើញត្រូវ) បើសំគាល់សេចក្តីខាងអាក្រក់ ថែម មិច្ឆា ភ្ជាប់ខាងដើមជា មិច្ឆាទិដ្ឋិ (សេចក្តីយល់ឃើញខុស) បើចំពោះតែកម្លាំងសព្វថា ទិដ្ឋិ គ្មានសព្វដងនៅខាងដើមឬខាងចុងទេ សំគាល់សេចក្តីខាងល្អខាងអាក្រក់ តែក្នុងទីនេះសំគាល់សេចក្តីតែខាងល្អ ។ ទិដ្ឋិ (សេចក្តីយល់ឃើញ) នេះជារបស់សំខាន់ណាស់ បើមានសេចក្តីយល់ឃើញខុស ក៏ជាហេតុឲ្យធ្វើខុស និយាយខុស គិតខុស នាំទៅសុទ្ធតែភ័យអន្តរាយនឹងសេចក្តីនោសមកឲ្យខ្លួនឯងនឹងពួកគណៈរបស់ខ្លួន, បើមានសេចក្តីយល់ឃើញត្រូវ ក៏ជាហេតុឲ្យធ្វើត្រូវ និយាយត្រូវ គិតត្រូវ នាំគុណប្រយោជន៍ សុខសួស្តីមកឲ្យខ្លួននឹងពួកគណៈរបស់ខ្លួន ។ ព្រោះហេតុនោះសេចក្តីយល់ឃើញទើបជារបស់ដែលគួរតែប្រឹងប្រយ័ត្ន ឲ្យប្រព្រឹត្តទៅតែកងផ្លូវដែលត្រូវ ។ សេចក្តីយល់ឃើញឯណា មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងនឹងអ្នកដទៃ សេចក្តីយល់ឃើញនោះជាសេចក្តីយល់ឃើញត្រូវ ដូចសេចក្តីដែលយល់ឃើញថា របស់ទាំងពួងរមែងជាប់ដោយហេតុផល ហើយ

ផលមែនប្រព្រឹត្តទៅតាមអំណាចនៃហេតុ មានដើមថា មនុស្សដែលកើតមកក្នុងពួកគណៈគ្នានេះ សូម្បីជាអ្នកមានសេចក្តីកើត ចាស់ ឈឺ ស្លាប់ជាធម្មតាស្មើគ្នា ឥឡូវ សូម្បីជាអ្នកស្រឡាញ់សុខស្អប់ខ្ពើមទុក្ខស្មើគ្នាក៏ពិតមែនហើយ ប៉ុន្តែសូម្បីដូច្នោះ ក៏នៅតែជាអ្នកមិនស្មើគ្នាដោយហេតុគឺកម្មរបស់ខ្លួនឯងដែលបានធ្វើទុកមក អំណាយចំណែកឲ្យជាអ្នកល្អខ្លះ អាក្រក់ខ្លះ ផ្សេងៗ គ្នា គឺមនុស្សខ្លះមានអាយុវែង មនុស្សខ្លះមានអាយុខ្លី មនុស្សខ្លះមានរោគភ័យបៀតបៀនមិនសមប្រកប មនុស្សខ្លះសមប្រកបគ្មានរោគភ័យបៀតបៀន មនុស្សខ្លះទាល់ក្រអនាថា មនុស្សខ្លះមានធនធានយ៉ាងសម្បូណ៌ មនុស្សខ្លះជាទីស្អប់ខ្ពើម មានសឹកសត្រូវច្រើន មនុស្សខ្លះជាទីស្រឡាញ់ពេញចិត្តអាណិតអាសូរបស់ជនទាំងឡាយ គ្មានសឹកសត្រូវ មនុស្សខ្លះជាទីជឿស្តាប់របស់ជនទាំងឡាយ មនុស្សខ្លះជាទីប្រមាថមើលងាយ មិនជាទីជឿស្តាប់របស់អ្នកណា មនុស្សខ្លះរដេរដើរវិកលចរិត មនុស្សខ្លះសម្បូណ៌ដោយសេចក្តីគិតសេចក្តីចេះដឹង មនុស្សខ្លះល្ងង់ខ្លៅ មនុស្សខ្លះមានប្រាជ្ញាឈ្លាសវៃ មនុស្សខ្លះមានតេជានុភាពជាទីពាប់អានកោតក្រែង មនុស្សខ្លះគ្មានតេជានុភាព មិនជាទីគោរពកោតក្រែងប៉ុណ្ណោះជាដើមជាគ្រឿងចង្អុលឲ្យឃើញថា ជាផលដែលជាប់មកអំពីហេតុ ប្រព្រឹត្តទៅតាមហេតុ ។ ម៉ោយ៉ាងនេះដូចហេតុផល ឥឡូវ មានសេចក្តីយល់ឃើញក្នុងន័យនៃហេតុផលហើយ ក៏ឥឡូវសន្និដ្ឋានថាន

ថា ចំណែកដែលល្អដូចគាត់ជាអ្នកមានអាយុវែងជាដើម រមែងជាផលនៃ
ហេតុគឺកម្មខាងល្អពិតប្រាកដ, ចំណែកដែលអាក្រក់ ដូចគាត់ជាអ្នកមាន
អាយុខ្លីជាដើម រមែងជាផលនៃហេតុគឺកម្មខាងអាក្រក់ពិតប្រាកដ, កាល
ខ្ញុំធ្លាក់នៅកងឋាន:ដូចម្តេច ក៏ទឹងធ្វើខ្ញុំឲ្យជាអ្នកសមគួរដល់ឋាន:ដូច្នោះ
គឺថាកាលធ្លាក់នៅកងចំណែកអាក្រក់ថោកទាបជាងគេ ក៏មិនតូចចិត្ត
ឥច្ឆាឈ្នានីះអកដទៃដែលមានឋាន:ល្អជាងខ្លួន . រមែងជាអ្នកដឹងខ្លួនបានថា
ព្រោះយើងធ្វើកម្មមិនល្អ ដែលទឹងអំណោយផលដូច្នេះតុកមក បានជាត្រូវ
យ៉ាងនេះ ហើយព្យាយាមប្រឹងប្រែងតួខ្លួនមិនធ្វើកម្មអាក្រក់ ធ្វើតែកម្ម
ដែលល្អជាគ្រឿងកែទៃ ក៏ទឹងបានជាអ្នកមានឋាន:ល្អឡើងដោយលំដាប់,
បើជាអ្នកធ្លាក់នៅកងចំណែកល្អធំខ្ពស់ជាងគេ ក៏មិនគប្បីប្រកាន់ខ្លួន
ថាណាមាថមើលងាយអ្នកដទៃ ដែលមានឋាន:ថយថោកជាងខ្លួន
ទឹងមិនគប្បីចំណាន់ឫស្យាអ្នកដទៃ ដែលមានឋាន:ស្មើទឹងខ្លួន ព្រោះ
បានពិចារណាឃើញថា ដែលយើងជាអ្នកមានឋាន:ល្អប្រសើរជាងគេ
ឬស្មើមុខទឹងគេដូច្នេះ ក៏ព្រោះតែយើងបានធ្វើកម្មល្អ ដែលទឹងឲ្យផល
ល្អតុកមក កម្មល្អទើបអំណោយឲ្យយើងបានត្រឹមនេះ ទឹងខំព្យា-
យាមធ្វើកម្មល្អឲ្យកាន់តែច្រើនៗឡើងទៀត ក៏ទឹងបានជាអ្នកល្អកាន់តែ
ច្រើនឡើងជាបទៅ មិនធ្លាក់ថោកទាប ។ សេចក្តីយល់ឃើញដែល
នៅកងតន្ទឹងហេតុផលដូច្នេះ រមែងជាហេតុការពារមិនឲ្យបុគ្គលធ្លាក់ទៅ

កងជ្រុវថោកទាប មានតែត្រឡប់ផ្ទុយផ្តើមឲ្យជាអ្នកល្អច្រើនឡើង ពាំងជាត្រឿងហាមឃាត់សេចក្តីឫស្យាគ្នា សេចក្តីប្រកាន់ខ្លួនជ្រុលមើលងាយអ្នកដទៃ នឹងសេចក្តីសង្គត់សង្កិនគ្នាមិនឲ្យកើតឡើងបាន ។ កាលមនុស្សអ្នករាប់ជាប់កងពួកជាមួយគ្នា ជាអ្នកមានសេចក្តីយល់ឃើញត្រូវស្មើគ្នា ពួកគណៈក៏រមែងមានសេចក្តីចំរើនដោយបុគ្គលអ្នកល្អ នៅរួមគ្នាជាពួកដោយសេចក្តីស្រុះស្រួល មានសេចក្តីសុខទូទៅគ្រប់គ្នា ។

ប្រការមួយទៀត ជនទាំងឡាយនៅជាពួក នឹងរួបរួមគ្នាជាពួកបាន ត្រូវតែអាស្រ័យសេចក្តីព្រមព្រៀងជួយគ្នាធ្វើមុខការ គឺត្រូវគោរពដល់មុខការរបស់ខ្លួន ដោយឃើញយកចិត្តទុកដាក់ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់នឹងត្រូវគោរពដល់មុខការរបស់អ្នកដទៃ ដោយមិនប្រតិបត្តិការឲ្យជាទីខ្មើសខាស់ដល់មុខការរបស់អ្នកដទៃ ដោយមិនមើលងាយ ហើយត្រូវព្រមទទួលសម្តីដែលជាប់ដោយខ្លួន ។ បុគ្គលអ្នកធ្វើមុខការ ដូចព្រមទទួលថាអ្នកនោះអ្នកនេះជាធំ ជាប្រធានអ្នកដឹកនាំឬជាអ្នកគ្រប់គ្រងរបស់ពួក បុគ្គលនោះតែងនៅក្រោមបង្គាប់បញ្ជា ហើយប្រតិបត្តិតាមមុខការរបស់ខ្លួនតាមដែលគេតែងបង្គាប ចំនប្រកាន់ថាស្មើគ្នាដូចគ្នាទាំងអស់ជាការបង្អាក់សេចសម្តីដែលមិនមានអ្នកណាអាចបង្អាក់សេចបាន ។ ព្រោះលោកគឺប្រជុំជនទៅរួមគ្នាបាន ក៏ដោយអាស្រ័យសម្តីហើយប្រតិបត្តិដំណើរការជាប់ទាក់ទងគ្នាក្នុងរបៀបនៃសម្តី មិនឲ្យខុសចាកសម្តីទៅបាន

ដូចសម្តែងថាមាតាបិតា បុត្រធីតា ស្វាមីភរិយា ញាតិមិត្រជាដើម ពាក្យនេះជាប់ដោយមុខការប្រចាំខ្លួនដែលនឹងត្រូវប្រតិបត្តិដល់គ្នាជាសំខាន់ បើនឹងលះរៀមុខការប្រចាំខ្លួនរបស់ជនពាក្យនេះចេញ លោកក៏តាំងនៅមិនបាន សម្តែងក៏អស់នាទី ។ មួយទៀត បើលោកនេះនឹងមិនមានសម្តែងហើយ មនុស្សនឹងធ្វើសេចក្តីចូលចិត្តពាក់ព័ន្ធគ្នាមិនបានឡើយ ព្រោះហេតុនោះ សម្តែងទើបជារបស់ដែលលើកចោលមិនបាន សូម្បីពួកជននឹងប្រែការគ្រប់គ្រងគ្នាដោយវិធីណាក៏ដោយ ។ ដោយហេតុនេះ អ្នកមានសេចក្តីយល់ឃើញត្រូវ រមែងយល់ឃើញថា ការដែលសម្តែងថាអ្នកនោះជាធំជាប្រធានជាអ្នកដឹកនាំឬជាអ្នកគ្រប់គ្រង . ឬថាអ្នកនោះជាអ្នកបង្គាប់បញ្ជា អ្នកនោះជាវរៈបន្ទាប់ជាអ្នកនៅក្រោមបង្គាប់បញ្ជាជាដើមនេះមិនមែនជាការចំណាយរំលាងសមភាពក្នុងពួកជនទេ គ្រាន់ជាការរក្សាសមភាពក្នុងពួកជនឲ្យមាំមួនទៅវិញ ។ ព្រោះពួកនឹងតាំងនៅបានក៏ដោយអ្នកមានមុខការស្មុគស្មាញជួយគ្នាធ្វើការតាមនាទី ដោយអើពើស្មើគ្នា ។ កាលអ្នកណាបានទទួលសម្តែងឲ្យធ្វើនាទីរបស់អ្នកដឹកនាំពួក . បើជនអ្នកនៅរួមពួកជ័ពាក់ព័ន្ធជាវរៈបន្ទាប់ មានសេចក្តីគោរពចំពោះនាទីរបស់អ្នកនោះ ប្រតិបត្តិការតាមនាទីរបស់អ្នកវរៈបន្ទាប់ដោយត្រឹមត្រូវ នាទីអ្នកដឹកនាំដែលសម្តែងតែងតាំងគ្នាឡើងនោះ ក៏រមែងសម្រេចប្រយោជន៍ កិច្ចការរបស់ពួករមែងដំណើរទៅដោយរលូយ ។

បើជនអ្នកនៅរួមពួកជាមួយគ្នា មិនគោរពចំពោះនាទី របស់អ្នកដឹកនាំ ហើយ ចេះតែបែកខ្ញែកពីគ្នាធ្វើតែតាមអំពើចិត្តរៀងខ្លួនទៅហើយ កិច្ច ការតាំងឡាយក៏ខ្ចាត់ខ្ចាយផ្តេសផ្តាស ល្អខ្វះអាក្រក់ខ្វះ ច្បាស់ច្បាំ គ្នាអស់ឥតរបៀប ជាការបន្ថយសមភាព ទីឯបន្ថយកម្លាំងសេចក្តីចំរើន របស់ពួកឲ្យអូនថយចុះទៅ រហូតដល់តាំងនៅមិនបាន ។ ព្រោះហេតុ នោះ គ្រប់ពួកមិនរើសថាតូចឬធំទេ ដូចគ្រួសារមួយ . ឬក៏មិនប្រទេស មួយ ទើបត្រូវតែមានប្រធានអ្នកដឹកនាំខ្លះមិនបាន ។ សូមឲ្យកងខ្លួនឯង អាយុវែងតាំងឡាយរមែងធ្វើមុខការតាំងអស់គ្នា ក្នែកជាអ្នកដឹកនាំ ទើប បាននាមថានេត្រ ខួរក្បាលមានទាំងគិតអានត្រែងរួមនៅត្រង់ក្បាល យើងទើបលើកក្បាលថាខ្ពស់ តែការសំខាន់របស់អាយុវែងនោះ ក៏គឺ ដួយគ្នា ធ្វើនាទីឲ្យរាងកាយនេះប្រព្រឹត្តទៅដោយល្អ ដោយមិនចេះ រង្គើសប្រណែនប្រចាំគ្នាឡើយ រាងកាយនេះទើបគង់នៅបាន ។ រាង កាយរបៀបដូចពួក ក្នែកឬខួរក្បាលប្រៀបដូចប្រធានអ្នកដឹកនាំរបស់ ពួក ពួកជនរមែងខ្ពស់ទាបជាងគ្នាដោយដំណែងនាទី រហូតដល់ គុណធម៌សេចក្តីឈ្លាសវៃទីឯអាច តែរមែងស្មើគ្នាដោយសេចក្តីត្រូវធម៌ ដែលគ្រប់មនុស្សមាន ទីឯប្រយោជន៍ដែលទីឯគប្បីបានរួមគ្នាក្នុងការ ងារបស់ពួក ។ កាលសេចក្តីស្មើគ្នាមានឡើងដោយហេតុផល សូម្បី សេចក្តីខ្ពស់ទាបជាងគ្នា ក៏រមែងមានឡើងដោយហេតុផលដូចគ្នា, ការ

ដែលរឹងមាំកំតែឲ្យស្មើគ្នាទៅតាំងអស់ត្រៃបាបម៉្លេះយ៉ាងនោះ រមែងប្រព្រឹត្តទៅមិនបានរួយ ព្រោះទើសខាត់ដល់គោលធម៌តីហេតុផលសូម្បីព្រះអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា គង់តែនៅមានខ្វះសំខាប់ជាង ។ គ្នាដោយជាន់នៃមគ្គផល តែស្មើគ្នាតាមគោលនៃសមភាពដូចពោលមកហើយ ។ សេចក្តីយល់ឃើញត្រូវតាមគោលនៃសមភាព ដ៏ប្រពៃដោយហេតុផលនេះ រមែងជាគុណគួរក្រែងថាកងពួកជនអ្នកនៅជាពួកគណៈ ដើម្បីកំឆ្លងការបែកសាមគ្គី ទំនាក់ប្រណាំងប្រជែងសង្កត់សង្កិនគ្នាឯង ព្រោះហេតុនោះ ទិដ្ឋិសាមញ្ញតា "ភាពជាអ្នកស្មើគ្នាដោយសេចក្តីយល់ឃើញ" ទើបជាធម៌ដែលគួរក្រែងថាយ៉ាងក្រៃលែង ។

ភាពជាអ្នកស្មើគ្នាដោយសេចក្តីយល់ឃើញក្នុងទីនេះ ដោយន័យដ៏ទៀងទាត់ សំដៅយកសេចក្តីយល់ឃើញរួមគ្នា ក្នុងផ្លូវដែលត្រូវតាមគន្ធនធម៌ ។ ធម្មតាបុគ្គលរមែងមានសេចក្តីយល់ឃើញបែកផ្សេងគ្នាទៅបាន តាមសេចក្តីគិតឃើញរបស់ខ្លួន ប៉ុន្តែបើកងរបស់ជួចគ្នា តើតមានសេចក្តីយល់ឃើញបែកផ្សេងគ្នាឡើង រមែងប្រព្រឹត្តទៅដើម្បីវិវាទឈ្លោះប្រកែកគ្នា ។ កាលចំណែកម្ខាងប្រកាន់ថារបស់ខ្លួនត្រូវ ក៏គ្មានផ្លូវដែលនឹងស្រុះស្រួលគ្នាបាន ។ ព្រោះហេតុនោះ សេចក្តីយល់ឃើញត្រូវតែមានគន្ធនធម៌ជាគោល, សេចក្តីយល់ឃើញរបស់ចំណែកខាងណាមិនប្រកបដោយគន្ធនធម៌ ចំណែកខាងនោះរមែងប្រឹកាមិនបាន

មិនគួរប្រកាន់អាងសេចក្តីយល់ឃើញរបស់ខ្លួនទុកទេ គួរតែត្រមតាមចំណែកដែលប្រកបដោយគន្ធធម៌ ។ គន្ធធម៌ក្នុងនេះ បានដល់ផ្លូវដែលមិនខូចធ្លុះ ទាំងរបស់ខ្លួន ទាំងរបស់ជនខ្លះទៀត ។ មួយទៀត សូម្បីនឹងមានសេចក្តីយល់ឃើញរួមគ្នាទាំងអស់ក្នុងពួកជាមួយគ្នា ប៉ុន្តែបើមិនប្រព្រឹត្តទៅតាមគន្ធធម៌ទេ ក៏មិនបានជាការ ព្រោះប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសដល់មនុស្សទាំងពួង ទាំងធំនាស់នឹងសេចក្តីយល់ឃើញរបស់ជនពួកដទៃដែលប្រកបដោយគន្ធធម៌ ជាផ្លូវឲ្យបែកសាមគ្គីនឹងពួកដទៃតទៅទៀត ។ ព្រោះហេតុនោះ គួរតែមានសេចក្តីយល់ឃើញរួមគ្នាចំពោះតែក្នុងគន្ធធម៌ប៉ុណ្ណោះ ទើបនឹងអាចរក្សាសាមគ្គីទុកបានដោយខ្លួនឯង ។

ព្រះបរមសាស្តាទ្រង់សំដែងសមភាព គឺភាពជាអ្នកស្មើគាក្នុងពួកមនុស្ស ដោយគោលធម៌ ៣ ប្រការ គឺទ្រង់សំដែងសមភាព ដោយន័យនៃសាមញ្ញលក្ខណៈថា គ្រប់មនុស្សធ្លាក់នៅក្នុងលក្ខណៈដែលមិនទៀង ជាទុក្ខ ជាអនត្តា តាមដែលបានឃើញ គឺកើតមកហើយក៏ចាស់ឈឺ ស្លាប់ដូចគ្នាទាំងអស់ ដូច្នេះ ដើម្បីឲ្យឃើញសេចក្តីវិនាសសាបសូន្យ សេចក្តីមិនស្ថិតស្ថេរ នឹងបានជាអ្នកមិនប្រមាទស្រាំង ក្នុងវ័យក្នុងសេចក្តីមិនមានរោគ ក្នុងជីវិត ក្នុងរបស់សំឡាញ់ ។ ទ្រង់សំដែងភាពជាអ្នកស្មើគា ដោយសេចក្តីប្រព្រឹត្តិល្អ ដែលហៅថា

សីលសាមញ្ញតា ដើម្បីហាមឃាត់សេចក្តីបៀតបៀនបំផ្លាញគ្នា ។ ទង់សំដែងភាពជាអ្នកស្មើគ្នា ដោយសេចក្តីយល់ឃើញត្រូវតាមគន្ថធម៌ដែលហៅថា ទិដ្ឋិសាមញ្ញតា ដើម្បីហាមឃាត់សេចក្តីយល់ឃើញខុសផ្សេងនឹងសេចក្តីវិវាទទាស់ទែងបែកសាមគ្គី ។ សមភាព ៣ ប្រការនេះជាគោលធម៌សំខាន់នៃក្រឡែងរបស់លោក ជារបស់ទៀងទាត់មិនប្រែប្រួលព្រោះហេតុណា ។ បើជនក្នុងលោកទាំងមូលព្រមគ្នាប្រតិបត្តិតាមគោលសមភាព ៣ ប្រការនេះគ្រប់គ្នាហើយ លោកនឹងដល់សន្តិសុខ ជ្រកសួរចាកភ័យពៀរនឹងសេចក្តីចង្អៀតចង្អល់ ទើសទាក់ដោយប្រការទាំងពួង ព្រោះមនុស្សនឹងធ្វើសេចក្តីល្អដល់គ្នា គឺជួយទំនុកបំរុងគ្នា នាំគ្នាឆ្ពោះទៅរកសេចក្តីសួស្តីគឺសេចក្តីផុតភ័យ មិនមានទីបំផុត ព្រោះហេតុនោះអ្នកជ្រកថ្ងាសន្តិសុខដល់ខ្លួន នឹងដល់ពួកគណៈរបស់ខ្លួន ទើបគួរតែយកចិត្តទុកជាក់ក្នុងសមភាព ៣ ប្រការនេះ ហើយប្រតិបត្តិដំណើរការកុំឲ្យខុសវិធីនៃសមភាពនោះ ។

សូមសេចក្តីសុខសួស្តីបូរមានដល់អស់លោកអ្នក

ដោយតេជានុភាពព្រះរតនត្រៃ !

---

ភាគទី ២

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## សុភមិត្តជាតក ទី ៩

(តមក)

(និយាយអំពីដំណើរព្រាត់ប្រាស ព្រោះមានពៀរដោយយកកូនសត្វ)

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមដំនុំព្រៃត្រៃបិឆក

ប្រែពីបាលី

*គ្រានោះ ព្រះបាទព្រហ្មទត្តសុភមិត្តមហារាជ ជាស្តេចចំរើនក្នុងដែនរបស់ឯង ទ្រង់មានព្រះរាជឫទ្ធារថា: កូនតូចៗ របស់យើង ធ្លាប់តែបរិភោគបាយស្រូវសាលី នឹងមួយចំណីមានឧជារសធ្លាញ់ពិសា ចុះដល់ចេញទៅនៅក្នុងព្រៃព្រឹក្សា ត្រូវបរិភោគតែផ្លែឈើ តើនឹងធ្វើយ៉ាងម៉េច? ម្យ៉ាងទៀត ធ្លាប់បរិភោគភោជនាហារលើតុកមាសដ៏ថ្លៃថ្លា មានខមូន ១ រយបាល: ជាព្រះរាជទ្រព្យមានជាប់មក ១ រយរាជ្យហើយ, ដល់គ្រាដែលចេញទៅនៅព្រៃ បរិភោគអាហារចំណីលើ*

ស្លឹកឈើ តើត្រែងធ្វើដូច្នេះ មិនកើតទេដឹង? មួយទៀត កុមារតាំងឡាយ កាលនៅទីអាយ ធ្លាប់ស្លៀកដណ្តប់សុទ្ធសឹងសំពត់កាសិកព័ស្ត្រ ទោមកព័ស្ត្រ ខុមទុព្វព័ស្ត្រ មានសាច់ល្អិតម៉ដ្ឋទន់ល្អន់ល្វៃ ដល់ទៅនៅក្នុងព្រៃ ត្រូវស្លៀកដណ្តប់កម្រងស្បូវ តើត្រែងស្លៀកដណ្តប់មិនកើតទេដឹង? មួយទៀត ធ្លាប់ទៅណាមកពីណា សុទ្ធតែទៅមកដោយព្រៃសលៀងសុពណ៌សិវិកា ឬកជវថដ៏ថ្លៃថ្លា មានស្មុំស្រឡាំហែហមត្រៀបត្រា, ដល់វេលាចេញទៅនៅព្រៃព្រឹកល្ងាត្រូវតែដើរផ្លាល់ជាតា តើពុំជានាងឲ្យក្មេងតាំងនេះធ្វើដូច្នេះដូចម្តេចកើត? មួយទៀត កាលដែលនៅទីឋានអាយ កុមារតាំងឡាយ ធ្លាប់តែផ្ទុំលើទីសយនាគ្រឡាបទុំ ដែលក្រាលដោយចៀមចំពែព្រឹម ពូកះខ្នើយរងព្រះសីរ រងព្រះជាតាបិទជុំងដោយព្រះសន្ទិយា នៅនាប្រាង្គប្រាសាទ ដ៏ល្អស្អាតមានទ្វារបង្អួចតន្ទឹះ ចង់បើកឬបិទក៏បានតាមប្រាថ្នា ជាទីដ៏ថ្លៃថ្លាក្លិនផ្កែកចិញ្ចាចចិញ្ចែង, ដល់វេលាដែលនិទាឃសាតកន្ទែងស្ទែងទៅនៅព្រៃ ត្រែងបុត្រពីសីធ្លុំលើកម្រាលស្បូវក្រាលផ្ទាប់នឹងតល់ឈើមិនកើតទេដឹង? មួយទៀត; កុមារតាំងឡាយ ធ្លាប់តែលាបស្រឡាបកាយដោយគ្រឿង

សុគន្ធជាត គឺក្រចេះបួនចន្លុះ មានក្លិនក្រអូបជាប្រក្រតី, ដល់ចេញទៅនៅព្រៃ សឹងប្រឡាក់ដោយកក់ផងធូលី តើនាងឲ្យកូនចាំងពីរទៅប្រឡាក់ប្រឡូសដូច្នេះ ដូចម្តេចកើត? មួយទៀត ពាក្យចាំងពីរធ្លាប់នៅជាសុខស្រួលមានមនុស្សប៉ក់ផាត់ដោយសៀភេមច្រៀមចាមរី ទឹងភេមកន្ទុយក្លែក ដោយដៃស្រាលៗជាធម្មតា. ដល់ចេញទៅនៅព្រៃព្រឹក្សា មានតែមូសរះចុមភេមចាំចាំងទិវាតែ, តើកេសិនីនាងបណ្តោយឲ្យកុមារទៅរងលំបាកដូច្នេះ ម្តេចកើត? ៦

ព្រះនាងកេសិនីទេវី ដ៏ឈ្លាសវៃសព្វអង្គឥន្ទ្រិយ ទ្រង់ត្រាស់ព្រះពាក្យនេះ ឆ្លើយតបព្រះពាក្យស្វាមីវិញថា: បពិត្រព្រះកស្តា, សូមទ្រង់ព្រះមេត្តា កុំមានព្រះពាក្យយ៉ាងនេះឡើយ នាំឲ្យធុកធួលក្តួលក្តៅកាយហ្ន៎ទ័យ នៃខ្ញុំម្ចាស់ខ្លាំងណាស់! ទោះបីបើខ្ញុំម្ចាស់ស្លាប់ ក៏ស៊ូតែស្លាប់ជាមួយព្រះអង្គ, តែងរស់នៅត្រមោចត្រមង់ ព្រាត់ប្រាសបាត់ព្រះអង្គទៅនោះពុំបានទេ! ព្រះអង្គទ្រង់តែងទុក្ខលំបាក់បានយ៉ាងណា, ខ្ញុំម្ចាស់ក៏តែបានយ៉ាងនោះដែរ; ពេលនេះខ្ញុំម្ចាស់ស៊ូតែខំពាក្លូនចាំងពីរទៅតាមក្រោយព្រះពាស្វាមី ពុំខាន ។

គ្រានោះ ព្រះមហាសត្វមិនអាចឃាត់ព្រះនាងទេវីបាន់សោះ ទើបទ្រង់ត្រាស់បណ្តោយ អនុញ្ញាតឲ្យថា "ម្នាលមាសពុំងា, បើដូច្នោះបងនាងទៅទៅជាមួយនឹងបងចុះ" ។ លំដាប់នោះ ព្រះនាងទេវីក៏រៀបចំស្បៀងសម្រាប់លៀងដំរីតស្រេចហើយ ព្រះនាងទ្រង់ពាជេយ្យទត្តកុមារ, ព្រះពាជ្រទ្រង់ពាជេយ្យសេនកុមារ ស្ពាយស្បៀងអាហារដោយព្រះអង្សា បណ្តើរគ្នាចេញចាកព្រៃនគរទៅទាំងពួក ។

អង្គុសម្តេចព្រះបរមសពិជ្ឈសាស្តា កាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ជាបទព្រះគាថាថា:

យទា ប កេសិនី ទេវី អាហរិត្វា សកំ បុត្តំ
ជេយ្យទត្តំ គហេត្វាន ឧគរា និក្ខមិ តទា
តតោ សុភមិត្តោ រាជា អំសេ អាទាយ បសិព្វកេ
ជេយ្យសេនញ្ច អាទាយ សកំ បុត្តំ និក្ខមិ

កិក្ខវេ ម្នាលភិក្ខុទាំងឡាយអើយ, មុខគួរឲ្យអាស្រូវដល់ក្រត្រទាំងបួនព្រះអង្គ ដែលភ្ញាប់តែទ្រង់ចំរើនដោយសេចក្តីសុខក្នុងព្រះសិរីរាជសម្បត្តិ គ្រានោះព្រះអង្គទ្រង់ខ្ចាត់ចាកពាជបុរីដ៏ប្រសើរ ដោយដំណើរពុំសមសោះគឺព្រះនាងកេសិនីពាជទេវី នាំព្រះពាជបុត្រាទាំងពីរ មកប្រដុំគ្នារញ្ជាំ នាង

ទ្រង់ពរួចត្រឹមតែដេយ្យទត្តកុមារ យាត្រាចេញទៅ, សម្តេច
ព្រះបរមចៅសុភមិត្តពាដា ស្តាយនៃដោយព្រះអង្គា ព្រះហត្ថា
ដឹកព្រះហ័ស្តដេយ្យសេនជាពជបុត្រចូន បណ្តើរគ្នាត្រសង
ចេញទៅទាំងកណ្តាលភត្រី ដោយសេចក្តីផ្អកផ្អំនឹងគ្នីនឹងកូន
ព្រះពជនក ។

គ្រានោះ មហាសត្តទ្រង់ចេញចាកព្រះនគរ ទ្រង់ស្តេចត្រចរ
ទៅតាមលំជាប់ ស្រាប់តែជល់ស្ទឹងមួយ; ព្រះអង្គមានសេចក្តីនឿយ
ព្រួយពេក ទើបនាំព្រះពជទេពិនីព្រះពជបុត្រាទាំងពីរចូលទៅឈប់
សម្រាកព្រះកាយពលក្រោមដើមទន្ទាប់មួយដើមក្បែរស្ទឹងនោះ, ទ្រង់
បញ្ជូកអាហារចំណីព្រះពជបុត្រទាំងពីរ ហើយទើបទ្រង់ត្រាស់ព្រះពជ-
ឧដ្ឋារថា "ម្នាលនាង, ស្ទឹងនេះជ្រៅណាស់ យើងមិនអាចឆ្លងទៅ
ត្រើយនាយទាំង ៤ នាក់ឯានឡើយ, កុមារទាំងពីរតូចៗ ណាស់ យើង
ទុកឲ្យនៅខាងអាយសិន, បងចម្ងឹងនាងទៅមុន សឹមត្រឡប់មកចម្ងឹង
កុមារទាំងនេះជាខាងក្រោយ" ។ ទើបព្រះនាងទៅទ្រង់បំពៅដេយ្យទត្ត-
កុមារ យកសំពត់សាជកក្រាលឲ្យផ្ទំ, លុះដេយ្យទត្តកុមារផ្ទំស្កប់ហើយ
ព្រះនាងទ្រង់ក្រោកឡើងសន្សឹមៗ បញ្ជូកអាហារចំណីដេយ្យសេនកុមារ,
ព្រះហត្ថាទ្រង់បបោសអង្អែលបៅមព្រះសិរសាព្រះពជបុត្រា ទ្រង់ផ្តាំថា
"កែកូនពុំងា, ចូរអ្នកកុំប្រែកែស, ចូរអ្នករក្សាប្អូន ហ្នឹកូនស្ងួន!

ទំព័ចិតាអ្នកត្រឡប់មកយកវិញ" ។ លំដាប់នោះ ដេយ្យសេនកុមារ ក្រាបបង្គំទូលព្រះវរបិតាថា "បពិត្រព្រះវរបិតា, បើទ្រង់ស្តេចទៅបាត់យូរ, ទូលព្រះបង្គំជាខ្ញុំទាំងគួ ជាកេងំកំព្រាអនាថា នៅនាទ្បេរស្ងប់ ស្ងាត់ឈឹងទាំងកណ្តាលអង្ករ; ដូច្នេះសូមព្រះករុណានាថស្តេចកុំយូរពេក, សូមត្រឡប់មកយកទូលព្រះបង្គំជាខ្ញុំទៅធាប់ៗ" ។ ក្សត្រទាំងពីរព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យព្រះរាជបុត្រកំសួតហាក់ដូចជាឱដ៏ធ្លាយព្រះឧរ, ទើបព្រះរាជាទ្រង់លួងលោមព្រះរាជបុត្រឲ្យក្សាន្តព្រះទ័យស្រួលហើយ. ទ្រង់នាំព្រះមាងទៅចុះធ្វូនទីទំហំ ៣ គាវុត; លុះធ្វូនផុតដល់ត្រើយនាយទ្រង់ឲ្យព្រះនាងទៅគង់ចាំ ទៀបគល់ឈើមួយដើម ហើយទ្រង់ប្រុងប្រៀបនឹងហែលធ្វូនត្រឡប់មកវិញ ។

គ្រាដែលព្រះអង្គនាំព្រះរាជទេពីធ្វូនស្ងឹងទៅ ក្នុងរាត្រីនោះ ដួនជាមានព្រានសំណាញ់ពីរនាក់ អុំទូកទៅចតនៅផ្លូវខ្សាច់ ត្រាច់ទៅកែ្សរច្រាំងម្ខាង, ព្រះរាជកុមារទាំងពីរព្រះអង្គ ទ្រង់ព្រះសណ្តាប់ឮសំដីព្រានសំណាញ់ទាំងនោះគិតស្មានជាបិតារបស់ខ្លួនក៏ស្រែកហៅ ។ ព្រានសំណាញ់ទាំងពីរនាក់ឮហើយ ចូលទៅឃើញកុមារទាំងនោះ ក៏មានសេចក្តីករុណា, ពយុកម្ខួយអង្គម្នាក់ៗ ដាក់លើទូកអុំនាំយកទៅផ្ទះរៀងខ្លួន ។

ព្រះរាជាទ្រង់ត្រឡប់មកដល់, ទ្បើងផុតពីទឹកមកវក់ព្រះរាជបុត្រទាំងពីរពុំឃើញ ក៏ទ្រង់ព្រះដង្ហើយហៅថា "កូនអើយ, អ្នកនៅឯណា?

បិតាមកយកអ្នកហើយ, កូនអើយអ្នកកុំតូចចិត្ត" ហើយស្តេចទ្រង់សុះទៅ
សុះមកវត់រកទាំងភក្តី; លុះក្ងីបាស់ឡើងព្រះចក្ខីពុំបានឃើញព្រះរាជ-
បុត្រត្រង់កន្លែងដែលគង់នៅ ក៏ព្រះចមចៅទ្រង់គង់ដាច់សម្រក់ព្រះអស្សុ-
ធារ ដោរដលនេត្រាហូរសស្រាក់ញាក់ញាប់ក្រហល់ក្រហាយ ក្តៅសព្វ
ព្រះអង្គកាយ ហើយទ្រង់ព្រះកន្សែងសោកដង្ហោយហៅរកព្រះរាជបុត្រ
ទាំងពីរដរាបដល់ស្មុតជាត់ព្រះស្មារតី ។

តមត្តំ បកាសេន្តោ សត្ថា អាហ សម្តេចព្រះសម្ពុទ្ធបរម-
សាស្តាចារ្យជាម្ចាស់ទ្រង់ជានត្រាស់ឡើង ទ្រង់ប្រកាសសេចក្តីនោះថា

សោ តត្ថ បរិទេវិត្វា ពហុការុញ្ញសញ្ជិតំ
ឧទកតីរំ បុន គន្ត្វា តត្ថេវ បតិតោ ឆមា
សោ រាជា បរិទេវិត្វា ពហុការុញ្ញសញ្ជិតំ
ឧទកតីរំ បុន គន្ត្វា បន្នោ វិបតិតោ ឆមា
សោ រាជា បរិទេវិត្វា ពហុការុញ្ញសញ្ជិតំ
ឧទកតីរំ បុន គន្ត្វា សុរិយោ វិបតិតោ ឆមា[1] ។

ព្រះជាម្ចាស់ត្រង់សុកមិត្តបរមរាជា ទ្រង់ព្រះកន្សែងសោក
អួលអន់ព្រះទ័យ ជោកប្រៃព្រះកាយាក្នុងទីនោះ ហើយទ្រង់

---

๑ គាថានេះ លោកស្រែង់យកពីវេស្សន្តរជាតកត្រង់មទ្រីបាត ។

ស្តុះរត់ទៅរកព្រះពាដបុត្រឯកំពង់ទឹកទៀត ដោយព្រះទ័យ
ប្រកបដោយសេចក្តីករុណាច្រើនប្រការ ទ្រង់នឹកស្មានថា
តែងព្រះពាដបុត្រតាំងពីរនោះលោតចុះទៅក្នុងទឹក; កាល
បើរកពុំឃើញ ក៏ទ្រង់ដួលចុះទៅលើផែនដី សន្ធប់ផាត់
ព្រះស្មារតីទៅនាទីនោះឯង; លុះក្សារឡើងទ្រង់ព្រះកន្សែង
សោកក្នុងទីនោះ ហើយស្តុះរត់ទៅរកឯកំពង់ទឹកទៀត ដោយ
សេចក្តីករុណាចំពោះព្រះពាដបុត្រា ទ្រង់ដួលសន្ធប់នៅទី
នោះទៀត ដូចជាព្រះចន្ទ្រជ្រុះធ្លាក់ចុះមកលើផែនដី; អគ្គ
សម្តេចព្រះនរបតីក្រុងសុកមិត្ត ទ្រង់រឹតតែថ្ងូរព្រះកន្សែង
សោកក្នុងទីនោះ ហើយទ្រង់ស្តុះរត់ទៅរកឯកំពង់ទឹកទៀត
ដោយព្រះទ័យប្រកបដោយមហាករុណា ក្សត្រាទ្រង់ដួល
សន្ធប់ដូចជាព្រះអាទិត្យជ្រុះចុះមកលើផែនដី ។

សម្តេចព្រះចក្រីទ្រង់ក្សារឡើង ទ្រង់ព្រះកន្សែងថ្ងូរវៀបរាប់ថា
"ឱកូនកំសត់មាសខ្ចីពុកអើយ ! កាលនៅស្រុកនាយនៅឡើយ បើបិតា
ទៅទីណាបាត់មុខមួយដងមួយកាល អ្នកតែងយំស្រែក មើលផ្លូវផ្សា
ក្អែក; កាលបើបានឃើញបិតាមកដល់ អ្នកតាំងពីរតែងរត់ត្រសងមក
ទទួល ដូចជាកូនម្រឹគឃើញមេ ក្នុងវេលាកំពុងស្រេកទឹកក្សែរ ក៏ដក
ហែរត់ដម្រង់មកក្បឹងជុំវិញ ដោយសេចក្តីត្រេកអរសេចក្តីស្រឡាញ់

ស្ដេច ធ្វើចិត្តបិតាឱ្យក្រៃក្រាប់ញ័រ, កូនអើយ, ឥឡូវនេះម្ដេចឡើយ ចានជាចាត់មុខអ្នក! អ្នកប្រឹងពួនសំងំអ្វីយូរដល់ម្ល៉ះ? ឥដំណើរអញនេះ ពេញជាឆ្ងោយភ្នំឯណាស់! ហ៊ានលាកលះចោលកូនតូច តំណូចប៉ុន នេះឱ្យនៅឯកឯង ដូចជាមេម៉ឹតលៀងកា ឬមេម៉ឹតអ៊ីនានា ពុំនោះសោតទេ ដូចជាបក្សីព្រាប ឬមេសីហៈ ដែលជាប់ដំណាក់ដោយអាមិស គិតតែត្រង់ការប្រឹងប្រែងស្វែងរកអាមិសដោយគិតស្មានថាបានសុខ ហើយផុតពីសំបុក ឬចេញហួសពីលំនៅទៅ ស្រាប់តែកូនតូចៗដែលនៅត្រូវមានអន្តរាយដោយឥតដឹងខ្លួនសោះ ។ ឱ! មុខគួរឱ្យស្រណោះដល់កូនទំង៏ពីរជាទីបំផុត អ្នកធ្លាប់តែរត់មកចាំមើលផ្លូវឪពុកពីចម្ងាយដូចកូនខ្ចីនៃមេម៉ឹតលៀងកា ធ្លាប់តែរត់ទទួលមកដូច្នោះ, ឥឡូវអញឥតឃើញកូនតូចទាំងពីរនោះសោះ! កូនអើយ អ្នកនៅឯណា? ហៃកូនពុំងាមាសឪពុកអើយ ទោះបីអ្នកប្រឡាក់ប្រឡូសដោយកក់ផង៏ធូលី ឬអាចម៍ដីយ៉ាង៏ណាក៏ដោយ ឱ្យតែអ្នករត់មករកឪពុកចុះ ក៏ឪពុកនៅតែត្រេកអរ, ឥឡូវនេះ ឪពុកឥតឃើញអ្នកសោះ ឱ្យឪពុករស់នៅដូចម្ដេចកើត? ហៃកូនពុំងា, អ្នកឯង៏ដូចជាក្អែកស្គាំរបស់បិតា; នែចា, អ្នកឯង៏ដូចជាប្អូនទ័យនៃឪពុក; ឥឡូវនេះ ម្ដាយអ្នកឯង៏ជាស្រីអនាថាមុខជាកំព្រាដេកតែម្នាក់ឯង៏ហើយ" ។ ព្រះបាទក្រុង៏សុកមិត្តបរមភជាទ្រង់រកព្រះរាជបុត្រាពុំឃើញ ក៏ទ្រង់ស្ដេចចុះទៅឯកំពង់ទឹករិញ - ទ្រង់ព្រះកន្សែង៏ថ្ងែង៏សោកាថា

ឥមេ តេ ជម្ពុការុក្ខា នវទិសា សិន្ធុវារិតា
វិរិជាតិ រុក្ខជាតាតិ តេ កុមារា ឥ ទិស្សរេ ។
អស្សដ្ឋា បឥសា ចេមេ តិគ្គោធា ច កបិដ្ឋនា
វិរិជាតិ រុក្ខជាតាតិ តេ កុមារា ឥ ទិស្សរេ[1] ។

ខ: ខ, ដើមត្រែងដម្ពុត្រែកទាំងនេះអើយ មានសំណុំស្លឹកលាស់ដង្កុំដង្គោលចោលមែកបែកទៅសព្វទិសា សឹងដណ្តើបស្រងយកជាតិដលធាតុជាវត្ថុអំពីសមុទ្រ ទាំងរុក្ខជាតិផ្សេងៗមានច្រើនជាទីបំផុតគួរតែបុត្រអ្នកចូលដែក. ម្តេចទើយបានជាយើងរកកុមារទាំងនោះពុំឃើញ ។ ខ! ដើមត្រែកញ្ជាទាំងឡាយនេះអើយ គឺដើមពោធិ៍ចាយ ខ្នុរណាំង វែង ខ្ញែង សឹងដុះប្រកិតជាប់គ្នា ជាមួយនឹងរុក្ខជាតិនានាច្រើនប្រការពុំឃ្លាតគ្នា ម្ល៉ៃអ្វីតែកុមារក៏បែកបាត់ពីយើងទៅ យើងស្តាត់រកគ្រប់ផ្លូវពុំឃើញសោះដូច្នេះ ។ (មានត)

---

๑ គាថានេះ លោកស្រែង់ពីវេស្សន្តរជាតកត្រង់មទ្រីបាព ជាគាថាដែលគេធ្លាប់សូត្រជាបទស្មូត។

(សិសោរដាតក)

# ព្រះមហាឧត្តមរិដ្ឋា ផលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមគម្ពីរសាស្ត្រាស្ងឹករិត

(តមក)

---

ស្ងាំងកាំងភ័ន្តកាំងខ្ញាំងកៃ ញ៉ែរដើងញ៉ែរដៃ ទីដៃ ។ គ្រប់គ្នា ។
ខ្លះរស់ខ្លះក្ស័យជន្មា ខ្លះខ្ទាចចេស្តា ប្រពួនប្រពាន់កែវរ ។
ស្តេចដេញអស់ពលនិករ រួតរត់ខ្ចាយខ្លួរ ពន្ធូកពន្ធឹកតោកកៃ ។
ស្តេចចុះចាកច្រាសាទជ័យ ស្ទុះរត់ដៃ ។ ដល់ដីក្សត្រៃម្ដងម្នា ។
ផែលមហាលទ:អស្សពាហន៍ បើកបរលើលា ក្សត្រាដូចជាឆ្កួតស្មោះ ។
បរសេះទំលាយចំពោះ បន្ទាយរាំងនោះ កំផ្ទុះទាំង ៧ ជាន់ ។
ទីនាំងកម្ចាំងរួសពាន់ ក្សត្រៃថ្លៃសោភ័ណ កំញាក់កន្ត្រាក់បរបោះ ។
រឹងមនោមយនោះ ធ្លាប់តែហៀរហោះ ចំពោះអាកាសវេហាស៍ ។
តែកាលគ្រោះដល់ហើយណា កំផ្លើឲ្យវា ហៀរហោះដូច្នោះពុំបាន ។
ទើបនាំព្រះអង្គទៅថ្ពាន ចាកបុរីហាន ដោយន្ទូវកម្ចាំងឥតបី ។
អស់ពលរថល់ឃ្លាតខ្វី ដេញតាមនរបតី ឥតបីខាន់មួយខ្សែយណា ។
ព្រះបាទសិសៅរ៍រាជា ចាកនគរា តែមួយព្រះអង្គឯងឆៅ ។
ចូលដល់មណ្ឌលត្រៃត្រៀម ពុំដឹងសៅដៅ លំនៅទីហានខ្សែយណា ។

ទៅឆ្ងាយចម្ងាយមាគ៌ា ៣០យោជន៍ណា សុរិយាទន់ៗបណ្ដូចដៃថ្ងូ ។
ស្ដេចឃ្លាទៅដល់ដើមដៃ មួយដុំនៀបដៃត្រៃ តែដៃតែឈឺឆ្អឹងសាខា ។
សេះថយកំឡាំងហើយណា ឯមហាក្សត្រា តាយាក៏ទ្រមល្លិតដៃល្អ ។
រំងើយអស់ទាំងសរសៃ ចុះចាកអាជានេយ្យ អស្ស័យគ្រាមដៃសាខា ។
ស្ដេចអត់ទាំងកោជនា ឆេឆាងកាយា សន្ធៃសន្ធឹកនឹត្យទៅ ។

ដំណើរព្រៃបាទសិរីសៅវ័ ទុកស្ទេរឈប់ទៅថ្ងៃរៀងនាងជាយា ។
ដែលគន់ក្នុងនគរ នាងនាថដឹងជា ក្សត្រាចាកចេញទៅបាត់ ។
ទើបអង្គក្សត្រីវរតន៍ ប្រៃពណ៌រត់ស្ពាត់ ច្រវាត់រត់រកជា ។
អស់ពលសកលយោធា ស្ពាត់រកក្សត្រា រវាត់រវាមដោយដៃ ។
រកទៅដោយខ្ជួនទីដៃ សព្វជនពីរកដៃ ទីដៃ ។ គ្រប់គ្នា ។
រត់រកដោយជង់អាជ្ញា ជ្រងជ្រោះបព្វតា នានាពុយល់ស្ដេចសោះ ។
អស់ពលយោធាទាំងនោះ រកដោយចន្ទោះ កៀនកោះគុម្ពោតគួចធំ ។
តត្រែករកក្សត្រទ្រង់តម សព្វដៃពុះគម ទិសទាំង ៨ សព្វសាយ ។
ខ្លះរកដំបត ។ រៀងអាយ ខ្លះរកទៅឆ្ងាយ សឹងតែអស់ចិត្តគ្រប់គ្នា ។
ពុយល់ហើយវិលលីលា ជួបជុំអស់គ្នា ម្ដីម្នាក្រាបទូលនាងនាថ ។
“បពិត្រយើងខ្ញុំព្រះបាទ រត់រកសង្ឃាត ដោយជ្រោះដន្ទដងដៃ ។
ពុំឃើញអម្ចាស់ឡើយនៃ យើងខ្ញុំរំពៃ តត្រែករុករកពុយល់ ។
រកសព្វទូទីថ្នាក់ថ្កល់ អស់ចិត្តពុយល់ យើងខ្ញុំរសាយដៃស្មោះ ។

រកសព្វពុំមានចន្លោះ ព្រៃព្រឹកសានះគ្រោះ ឥតខ្វះចន្លោះតែឯណា ។
ពុំចេះតាមតែមេត្តា យើងខ្ញុំគ្រប់គ្នា សូវស្វែងស្តាត់រកពុំឃើញ" ។

## បទព្រហ្មគីត

ឯនាងនាថជាយា ស្តាប់ពាក្យអស់រោភ័ណ
ខ្លួលថារកពុំឃើញ នាងសែនខ្លាំងក្នុង ។
កូនច្រែងដូចគេបុក កើតជាទុក្ខឈឺខ្លោចផ្សា
ញាប់ញ័រអស់អង្គា ព្រះជាយាច្រែងកន្សែង ។
ឯអស់ទាំងស្រីសុំ សឹងខ្លួញយំពុំក្តែង ។
ផ្តេកផ្តួលនៅលើលែង ច្បាសាខឯងឥតមានស្បើយ ។
ខ្លះសោយសោកដោយដឹ ខ្លួញចក្រីសូវលេងលើយ
នៀលជាក់ដីហើយ កន្ត្រែងហឹងហាក់ហឹងយំ ។
ឯនាងនាថអានន្ទ - ទើតនន់មហេសីធំ
សោយសោកក្សត្រទុគ្គម ទុកក្រែងខ្លាចផ្សាក្រៃ ។
ទាងសោកៗសង្រែង ឈឺកន្ទេងក្នុងហ្លួតយ
សង្រែងរែងសង្រៃ ម្ល៉េះសមក្សត្រីយដន្ទុំលែង ។
ព្រះឧស្ហនាដ៏ខ្លួញទៅ "ទុ! ព្រះចៅជាតម្ដែង
"ទុ! សមស្តេចវង្វេង ចាកកន្ទែងទៅឋានណា ។
ខ្ញុំឲ្យគេតាមរក ដោយភូមិឆកព្រៃព្រឹក្សា

ពុំយល់ព្រះពជា　　ស្តេចលីលាទៅណាបាត់ ។
ខ ! ព្រះរៀមក្សត្រថ្ងៃ　　ធ្លាប់គង់ឰ្យច្រាសាទតែន
មន្ត្រីគាល់ហ្មបថ្ងាត់　　ឥឡូវស្ងាត់សូន្យជ្រងំ ។
ឃើញតែមុខមន្ត្រី　　បាត់នរបតីថ្ងៃទត្តម
ព្រះអើយ ! ខ្ញុំប្អូនក្រំ　　ក្រែចង្រៃតណែនស្ទើរភ្លាយ ។
ខ ! ពីថ្ងៃនេះទៅ　　សមប្អូនទៅជាមេម៉ាយ
ទុក្ខអើយឥតរសាយ　　សព្វរាត្រីឥតបីល្ហែ ។
ពីដើមឃ្លានព្រះអង្គ　　ស្តេចតែងគង់ ។ លើតែគ
ឥឡូវនេះឯងឯង　　ឃើញតែតែគបាត់ព្រះអង្គ ! ។
ប្អូនឃើញតែកន្ទែង　　ដែលស្តេចស្តែងតែងធ្លាប់គង់
ឥឡូវពុំយល់យង់　　តើស្តេចគង់កងឋានណា ។
ប្អូនឃើញតែដំណាក់　　បាត់រៀមរែកវែងស្មៅហា
ពុំដែលអាក់ចិន្តា　　ឰ្យប្អូនជាទុក្ខដល់ម្តង ។
ព្រះអង្គសោយសម្បត្តិ　　សម្បូណ៌ក្តាត់សុខកន្ទ
អស់ស្តេចជាទៃផង　　នាំសួយវៃថ្វាយបង្គំ ។
ឥឡូវនេះឯងណា　　បាត់ពាជាសូន្យជ្រងំ
ខ្ញុំប្អូនកើតទុក្ខធំ　　ហាក់ដូចកំរាលលើ ។
ខ ! ព្រះរៀមតែន់ថ្ងៃ　　រស់ឬក្សយប្អូនសើរើ

ឥឡូវព្រៃអគ្គតើ ជាដូចម្តេចប្អូនពុំដឹង ។
ប្អូនឲ្យគេរត់រក ស្ពាត់ទៅមកឥតដំណឹង
ចាត់ឈ្មោះសោះសូន្យឈឹង ប្រុសព្រលឹងទៅឋានណា ។
ព្រះអគ្គស្តេចប្រាសទៅ ឲ្យប្អូននៅអនាថា
ស្តេចគ្រាប់ដោយមាគ៌ា តែពីរគ្នាទឹងអាជានេយ្យ ។
ស្តេចព្រាត់ពីទ្រូងប្អូន មសារសូន្យទៅទីណៃ
ប្អូនមើលផ្លូវរាំងៃ រំពឹងគិតត្រែងស្តេចដល់ ។
ឧ ! ពេលថ្មើរនេះហើយ កាលណាឡើយទឹងបានយល់
ប្អូនឃើញតែឡើយឡល់ ប្អូនពុំយល់ព្រះពេជ ។
ឧ ! ហេតុតែកម្មកាយ ពីព្រៃឯនាយតាមឋានណា
ធ្វើឲ្យព្រះកស្តា កន្ត្តិបិន្ធាគតផ្សេងទៅ ។
បណ្តាលឲ្យព្រះទ័យ ជាទុក្ខកៃកើតមួយម៉ៅ
បណ្តាលឲ្យក្តួលក្តៅ កូនព្រះទ័យថ្លើមប្រមាត់ ។
ឧ ! កម្មៗ ពីព្រៃឯ ពុំរវើរវៃទៅណាចាត់
ធ្វើឲ្យមហាក្សត្រ ចាកចេញចាត់ដូច្នេះណា ” ។
នាងសោកៗ សង្រែង ឈឹកខ្លួនវែងខ្លោចផ្សា
យូរបន្តិចជាយា នាងបន្ទោទុក្ខស្រាកស្រាន្ត ។
ដំណើរនេះស្ទុះនៅ ទឹងថ្លែងទៅតាមដោយជាន
អំពីមហាក្សត្រក្សាន្ត ដែលស្តេចឈប់ម្ខាងព្រៃផ្ទៃ ។ (មានត)

កណ្ឌទី ១៩

# ឧកញ៉ាវិបុលរាជសេនា ង្ហួ-កន ប្រៃរៀបរៀង

( តមក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ធឹងចេះឧបាយកល់បំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ធៀយ៉ុកថាគ្រាដែលឡៅពីគេចរត់ពីលីចោ៉ាមកជ្រកនៅនឹងលោក ខ្ញុំបាទ យល់ឃើញថាឡៅពីជាទីចំរូងចំរះទៅខាងមុខ ខ្ញុំបាទក៏បានជំរាបលោក ជារឿយៗថា ឲ្យសម្លាប់ឡៅពីចេញ លោកមិនធ្វើតាមខ្ញុំបាទ ក្រោយ នោះលោកឲ្យឡៅពីធ្វើជារៀមហ្វាយស្រុកអ៊ូដីវ រួចត្រឡប់ទៅនៅស្រុក សៀវដាយ ហើយឡៅពីបែកពីលីចោ៉ាមកទីពឹងលោកវិញ ដែលលោក ដឿខុកចិត្តឲ្យឡៅពីធ្វើជាមេទ័ពលើកចេញទៅគ្រានេះ ឧបមាដូចលែង ខ្លាឲ្យទៅក្នុងព្រៃឬលែងក្រពើឲ្យចុះទៅក្នុងទឹកទន្លេ តំណាទៅឯមុខឡៅពី ក៏គង់នឹងមានកំឡាំងច្រើនឡើង លោកទឹងបង្អាបឲ្យរាបទ័ពទៅវិញក៏ កម្រណាស់ ។

គុយតែជំពាបចូលធ្លូថា ដែលលោកមិនបានសម្លាប់ខ្លៅពីចេញ ហើយយកទុកប្រើប្រាស់នោះគួរហើយ តែឥឡូវលោកប្រើឲ្យខ្លៅពីចេញទៅធ្វើជាមេទ័ពនោះមិនត្រូវសោះ ព្រោះបុពណមានពោលទុកថា បើអ្នកឯណាជាមេទ័ពគាន់អាជ្ញាសិទ្ធិតែម្ដង ក៏មានចិត្តកំរើកយ៉ាងធំធូលាយដូចបានធ្វើដល់ ១ ពាន់ដង ខ្ញុំបាទយល់ឃើញថា ខ្លៅពីមានកុំភ្លាំងឡើងនឹងប្រែចិត្តចេញពីលោក តទៅមុខលោកទំនងបានសេចក្ដីព្រួយលំបាកព្រោះខ្លៅពីជាប្រាកដ ឲ្យលោកត្រិះរិះគិតឲ្យមាំមួនចុះ ។

ចូលធ្លូបានស្ដាប់ធ្វើយ៉ាកនឹងគុយតែ និយាយរាប់រៀបដូច្នោះក៏ឲ្យភ័យស្ទុកស្ទឹងចិត្ត ទើបចាត់ប្រៃទៅធ្លូឲ្យលើកទាហានសេះ ៥០០ ទៅតាមខ្លៅពី បើទាន់ហើយឲ្យប្រាប់ឲ្យត្រឡប់មកវិញ ។ ទៅធ្លូក៏លើកទាហានសេះ ៥០០ បរយ៉ាងប្រញាប់តាំងយប់តាំងថ្ងៃ លុះទៅដល់ជិតកងទ័ពខ្លៅពីហើយ ខ្លៅពីក៏គ្រវែកមើលគ្រាយឃើញផង់ធូលីដីហុយខ្ទេចខ្ទាំងឡើង ឮសន្ធឹកដើរសេះចាលប៉ះពាល់គ្នាគឹកកង ក៏និយាយនឹងគួនអ៊ូ, គ្រៀវហ៊ុយថា "ដែលឮសន្ធឹកមកពីគ្រាយនោះ មុខជាចូលប្រៃឲ្យលើកទ័ពមកតាមយើងឲ្យត្រឡប់ទៅវិញជាប្រាកដហើយ" ថាហើយក៏បញ្ជាប់កងទ័ព ហើយចាត់គួនអ៊ូ, គ្រៀវហ៊ុយឲ្យពកងទ័ពឈរគាន់អាវុធសង្កាត់ផ្លូវចាំការពារអន្តរាយ ។

លុះទៅដូចរសេះមកដល់ឃើញទាហានខ្លៅពីត្រៀមប្រុងខ្លួនដូច្នោះក៏លោតចុះពីលើសេះដើរទៅកណ្ដាលកងទ័ពតែម្នាក់ឯង ហើយនិយាយ

ទីឆ៍ឡៅពីថា ឥឡូវមហាឧបាជ្ឈាយ៍ខ្ញុំបានមកតាមអញ្ជើញលោកឲ្យលើកកឋិនទៅតឡប់ទៅស្រុកហ្លួគោរវិញ ទីឆ៍បានបញ្ជាក់សេចក្តីដល់លោកទៀត ។ ឡៅពីក៏ឆ្លើយតបទៅទៀងវិញថា ម៉ាលមហាឧបាជនាំយើងទៅគ្រាបបង្គំគាល់ព្រះចៅហៀនតេ សុំព្រះរាជទានឲ្យយើងធ្វើជាមេទ័ពលើកពលទៅស្វាក់ប៉ាយកឋិនទៅអ៊ូនស៊ុត ព្រះចៅហៀនតេក៏ទ្រង់ព្រះរាជានុញ្ញាត យើងក៏បានគ្រាបថ្វាយបង្គំលា ម៉ាឆ៍មហាឧបាជឯងក៏បានចាត់ចែងបែគល់ពលទាហានឲ្យយើង ហើយបង្គាប់ថ្កាប់ថ្កាទរាជការដល់យើងគ្រប់ប្រការ បានជាយើងលើកទ័ពចេញមកតាមព្រះរាជតម្រាស់ព្រះចៅហៀនតេ ឥឡូវមហាឧបាជត្រឡប់ឲ្យមកតាមយើងឲ្យរំលៅវិញ បើប្រសិនយើងនឹងរំលៅវិញវេលានេះ ក៏នឹងមានសេចក្តីខុសពីព្រះរាជតម្រាស់ព្រះចៅហៀនតេ បើដូច្នេះចូរអ្នករំលៅយកសេចក្តីសមគួរប្តឹងមហាឧបាជមុនចុះថា បើកាលណាយើងធ្វើសង្គ្រាមសម្រេចហើយគង់នឹងលើកកឋិនទៅតឡប់ចូលទៅគ្រាបទូលព្រះចៅហៀនតេ ហើយនឹងនាំសេចក្តីពីកិច្ចរាជការប្តឹងមហាឧបាជឲ្យជាបតាមការ ។

ទៅធូបានស្តាប់ពាក្យឡៅពីនិយាយដូច្នោះក៏គិតថា "កាលចូរូប្រើអញមកនោះនឹងបានដាក់កំហិតថា បើឡៅពីមិនត្រមត្រឡប់រំលៅវិញឲ្យអញកំហែងបង្ខិចបង្ខំចាប់នាំខ្លួនឡៅពីឲ្យបានយកទៅក៏ឥតអង្គើមាន ដែលឡៅពីនិយាយមកដូច្នេះ ក៏ត្រឹមត្រូវតាមព្រះរាជតម្រាស់ណាស់ បើដូច្នេះ

ត្រូវតែអញត្រឡប់វិលទៅដំរាបចូរធូរវិញសិនចុះ បើចូរធូនឹងឲ្យធ្វើប្រការម្តេច សុំអញវិលត្រឡប់មកវិញធ្វើតាមបង្គាប់នោះជាគ្រោយ” លុះគិតដូច្នោះហើយក៏ណាឡៅពីនាំចាហានទាំងអស់ ស្រូតត្រឡប់ចូលទៅក្រុងហ៊ូតៅវិញ ចូលទៅដំរាបចូរធូតាមពាក្យឡៅពីនិយាយនោះគ្រប់ប្រការ ។ ចូរធូបានស្តាប់ក៏ទាល់គំនិតចេះតែគិតរវិតក្តួ ធ្វើយ៉ាងនឹងគុយតែក៏និយាយដំរាបចូរធូថា ដែលលោកប្រើឲ្យទៅតាមឡៅពីហើយឡៅពីមិនត្រមមកនោះ លោកយើញឬសដូចពាក្យខ្ញុំបាទដំរាបមែនឬទេ? ។ ចូរធូតបថា យើងបានចេញវាចាប្រើឡៅពីទៅហើយ បើនឹងបង្ខំឲ្យត្រឡប់វិលមកវិញក៏បានតែនឹងយើញថា យើងចរចាមិនជាសត្យវិបត្តិពាក្យសំដីហៅថាពាក្យ ២ សូម្បីឡៅពីមានចិត្តកំរើតគិតប្រទូសព៉ាយនឹងយើងវិញ យើងក៏មិនត្រូវខ្លាចអ្វីនឹងថ្លូដៃឡៅពីប៉ុណ្ណោះ ប្រការ ១ ទៀត យើងក៏បានប្រើដូច្នេះនឹងឲ្យដៀវឲ្យកាន់កាប់ទៅជាមួយផង បើឡៅពីប្រែចិត្តចេញពីយើងយ៉ាងណា គង់តែដូច្នេះនឹងឲ្យដៀវមានសំបុត្រមកដល់យើងជាមិនខាន ។

(មានត)

រឿងព្រេងប្រទេសឥណ្ឌា

# អ្នកស្រី ស្រីធ - សារីយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យភ្នំពេញ

## បែរតីកាសាបាលីមកជាភាសាខ្មែរ

(តមក)

---

### វគ្គទី ២១

យប់មួយ ព្រះបាទនាលៈនាំព្រះនាងគ្រែចចូលក្នុងដំរៃញឹក ហើយទ្រង់ទ្រឿយព្រះអង្គនឹងដើរឆ្ងាយ ។ ព្រះនាងទមយន្តី ទ្រង់ទ្រឿយហាត់ខ្ជាំងដោយយាងដើរផ្លូវឆ្ងាយពេក ក៏ទ្រង់ប្រៃព្រះអង្គផ្ទួលក់នៅនាគល់ឈើ ។ ព្រះបាទនាលៈទ្រង់ព្រួយព្រះហឫទ័យខ្លាំងពេកក៏ផ្ទុំពុលក់ ទោះបីទ្រង់អស់ព្រះកាយពលយ៉ាងនេះ ក៏ទ្រង់ចេះតែព្រះតម្រិះវែងទៅៗ ថា "តើអញដើរលុកលុយក្នុងដំរៃនេះធ្វើអ្វី ចុះបើសិនជាស្ងាប់ទៅ មិនប្រសើរជាងនៅរស់ដោយវេទនាយ៉ាងនេះឬ? តើការដែលធ្វើកុំឲ្យព្រះនាងទមយន្តីស្គាល់ទ្វារសេចក្តីវេទនាយ៉ាងក្រៃលែងនោះ មិនមែនជាករណីយកិច្ចរបស់អញទេឬ? ឯព្រះនាងវង់សេចក្តីវេទនាដោយសារតែអញប៉ុណ្ណោះ, តើព្រះនាងដែលប្រកបដោយសេចក្តីស្មោះត្រង់យ៉ាងនេះត្រូវទទួលសេចក្តីទុក្ខ សេចក្តីទ្រឿយព្រួយជារង្វាន់ទៅវិញឬ? បើសិនជាទុកព្រះនាងឲ្យនៅតែឯង ប្រហែលជាព្រះនាងមានកត្តូនឹងទៅរកប្រទេសព្រះវរបិតា

ឃើញ, បើសិនជាអញចេះតែនៅជាមួយនឹងព្រះនាង។ ចប្ញស់ជាវង
វែទនាលើសអ្នកកំសត់ទុគ៌តផងទាំងពួង បើអញដើរចេញចោលព្រះនាង
នៅទីនេះទៅ មានថ្ងៃណាមួយព្រះនាងនឹងបានសប្បាយ ។! តែវាមិនយូរ
ក៏ប្លែបបង់ត្រូវតែលានាងក្នុងពេលនេះ" ត្រាស់ហើយព្រះអង្គក្រោក
ឡើង ហើយទ្រង់ហែកសំពត់គំនរ ដែលទ្រង់ដណ្តប់ទាំងពីរព្រះអង្គនោះ
ជាពីរ ដោយមិនធ្វើឲ្យព្រះនាងភ្ញាក់ទេ ទ្រង់យកសំពត់នោះ ១ កំណាត់
ហើយយាងចេញយ៉ាងរហ័ស ។ ប៉ុន្តែបន្តិចក្រោយមក ព្រះអង្គទ្រង់ញ័រ
ចំប្រប់ដោយនឹកអាល័យព្រះនាង ហើយក៏ត្រឡប់យាងចូលទៅជិតព្រះ
នាងវិញ ។ លុះព្រះអង្គឃើញព្រះនាងនៅផ្ទំលក់ដោយស្រួល ព្រះ
អង្គក៏ទ្រង់ព្រះកន្សែងសោកា ហើយទ្រង់នឹកក្នុងព្រះហឫទ័យថា:

ឱ! តែវាវរមិត្តល្អឥតខ្ចោះ គួរឲ្យសោមនស្សអស់ពិចិត្រ
សូម្បីព្រះពាយព្រះអាទិត្យ មិនដែលទាស់ចិត្តនឹងកញ្ញា ។
មានកក្រើញញឹមចេញវស្នី គួរឲ្យមេត្រីអូម្ល៉ះណា
កាលតើនក្នុងវៃតែឯកា ម្ល៉ះសមជីតាញ៉ាំរចំប្រប់ ។
នាងត្រែចក្នុងវៃសម្បូរសុខ សាហាវខ្លាំងក្លាត់វេលាយប់
មានទាំងពស់ពិសមកប្រសប់ សូមព្រះម្ចាស់កម្ពុជួយនាងណា ។
ព្រះនាងប្រកបល័ក្ខណ៍ខត្តម ទេវតាតួចធំក្នុងលោកា
សូមជួយទ្រទ្រង់តែវាកន្ទិដ្ឋា រៀមលាដីព័ត្រឹមហ្នឹងអើយ! ។

រៀមមិនក្ងេចគុណីយកិច្ចរៀមឡើយ ប៉ុន្តែដោយព្រះនាងច្រកបដោយគុណធម៌ដ៏ខ្ពង់ខ្ពស់ ព្រះនាងនឹងបានសម្រេចនូវសេចក្តីសុខ រៀមលាហើយទេមយន្តីស្រីមាសបង!" ត្រាស់ហើយព្រះអង្គក៏យាងចេញទៅឆ្ងាយម្តងទៀត ប៉ុន្តែព្រះអង្គនៅតែវិលត្រឡប់មកកេព្រះនាងវិញ ទោះបីទ្រង់ខំកាត់ព្រះទ័យយ៉ាងណា ក៏ទ្រង់នៅតែរកកម្លាំងនឹងលះបង់ព្រះនាងពុំបាន, ទ្រង់យាងទៅហើយត្រឡប់ចូលមកវិញជាបួនដង ។ ក្រោយបង្អស់ព្រះបាទនាល: ទ្រង់បង្ហូរទឹកព្រះនេត្រសស្រាក់ ហើយយាងចូលដៃព្រៃជ្រៅចោលព្រះនាងទេមយន្តី ដែលនៅផ្ទុលក់តែម្នាក់ឯងក្នុងកណ្តាលដៃព្រៃ ។

វគ្គទី ២២

ព្រះនាងផ្ទុស្តប់ស្តល់ ក៏តើនឡើងដោយរីករាយ ហើយក្រឡេកមើលព្រះបាទនាល: ដោយឆ្កល់នឹងមិនឃើញព្រះអង្គ ។ ព្រះនាងទំរៃសែកហៅព្រះអង្គ តែពុំឮសូរឆ្លើយ ។ នៅពេលនោះ ព្រះនាងទតយល់សំពត់ជាប់ជាប់ជាប់មួយកំណាត់ ព្រះនាងទ្រង់សោយសោកជាខ្លាំងថា: "ឧ! ព្រះនាល ម្ចាស់ប្អូន! ស្តេចហ៊ានយាងទៅចោលប្អូន ឲ្យប្អូននៅកន្លែព្រៃស្ងាត់ជ្រងំតែម្នាក់ឯង, ខ្ញុំម្ចាស់បានដឹងច្បាស់ហើយថាព្រះអង្គស្រឡាញ់ខ្ញុំម្ចាស់ណាស់ ហើយព្រះអង្គបានសច្ចាថានឹងមានព្រះទ័យស្មោះត្រង់នឹងខ្ញុំម្ចាស់ជាដរាប ចុះហេតុម្តេចបានជាព្រះអង្គជាប់ព្រះទ័យយាងទៅចោលខ្ញុំម្ចាស់ដូច្នេះ? ខ្ញុំម្ចាស់ផ្ទុលក់ដោយគ្មានបាវម្តងអ្វីបន្តិចសោះ

ហើយព្រះអង្គយាងចោលខ្ញុំម្ចាស់ មិនដឹងជាស្តេចយាងទៅទីណា, តើព្រះអង្គមិនចាំពាក្យដែលទ្រង់បានសច្ចាចំពោះមុខស្តេចចតុលោកថាលទេឬ? តើឲ្យខ្ញុំម្ចាស់រស់នៅម្តេចបាន បើព្រះអង្គបែកឆ្ងាយពីខ្ញុំម្ចាស់ដូច្នេះ?" ។

រួចស្រាប់តែព្រះនាងឈប់ទ្រង់ព្រះកន្សែងទៅវិញ ហើយទ្រង់ព្រះសំរួលចាំងព្រះហស្តផង ព្រះនាងទ្រង់ស្រែកថា: "ខ្ញុំម្ចាស់ដឹងហើយ ព្រះអង្គលែងវិតក្កទៀតហើយ ដើម្បីនឹងធ្វើកុំឲ្យខ្ញុំម្ចាស់សង្ស័យ ព្រះអង្គទ្រង់ក្រសាលបិទបញ្ជូននឹងខ្ញុំម្ចាស់ ព្រះអង្គមុខតែទៅបញ្ជូនក្រោយដើមឈើនោះហើយ, ខ្ញុំម្ចាស់ឃើញហើយ ព្រះនាល:! ដូច្នេះ បើកាលណាខ្ញុំម្ចាស់ហៅ ព្រះអង្គត្រូវឆ្លើយកុំខាន សូមទ្រង់ព្រះសណ្តាប់ខ្ញុំម្ចាស់" ហើយព្រះនាងទ្រង់ស្រែកហៅ ហៅស្តេចដោយបង្អួសព្រះសូរសៀងថា: "នាល:! នាល:!" សំឡេងព្រះនាងកាន់តែឮរំពងខ្លាំងឡើង ។ ប៉ុន្តែគ្មានឮសូរឆ្លើយមកវិញសោះ ព្រះនាងក៏ពោលបន្ទោសថា: "នាល: កំណាច! កុំទ្រង់ក្រសាលដូច្នេះទៀត ព្រះអង្គមិនជាបជាខ្ញុំម្ចាស់ត័យទេឬ? ព្រះអង្គមិនទ្រង់យល់ជាខ្ញុំម្ចាស់សោកទេឬ? ស្តេចយាងមកជិតខ្ញុំម្ចាស់ឲ្យឆាប់ឡើង ខ្ញុំម្ចាស់មិនមែនយំដោយអាណិតខ្លួនខ្ញុំម្ចាស់ទេ គឺខ្ញុំម្ចាស់អាណិតដល់ព្រះអង្គដែលសេចក្តីស្រែកឃ្លានទ្រាំទ្រៀយណាយក្នុងព្រះអង្គ តើព្រះអង្គទ្រង់ទៅជាយ៉ាងណាទៅ! បើគ្មានខ្ញុំម្ចាស់នៅលួងលោមជិតព្រះអង្គនៅពេលដែលទ្រង់រងទុក្ខវេទនា" ។

(មានត)

ដំណើរតាមឡរ៉ូតក្នុងកម្ពុជា:

# លោក ធើង-ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុជ្ជាភ្នំពេញ

## ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(ត្រមក)

---

## ៣— អំពីបម្បាំង

ពេលវេលាចេះតែកន្ទរ៉ាទៅ ។ ។ នារីទាំងពីរមិនបានចេញទៅណាឆ្ងាយឡើយ តិចរវល់ជាច្រើនទាំងឲ្យនាងនៅតែជិតម្តាយក្នុងទីសំណាក់គ្មានការណ៍អ្វីធំដុំល្មមយកជាកស្តានបានទេ ក្រៅពីកំដៅព្រះអាទិត្យ ។

ព្រឹកមួយ នាងឡីឡាទៅងូតទឹកជ្រោះដែលឆ្ងាយបន្តិច ហើយក្រឡេកទៅក្រៅឃើលដូចជាឃើញរាងមនុស្សម្នាក់ ស្ងៀកពាក់ស៊ុគន្ធួនទៅជាចន្ទោះដើមគ្រៃតពីរដើម នាងលួចសំឡឹងសង្កេតឲ្យច្បាស់មួយស្របក់ឃើញក្បាលដួតធ្លុត ទឹងសំពត់មានតម្លៃលេចប្រាកដឡើងតាមចន្ទោះដើមគ្រៃត ហើយឈរសំឡឹងទៅដើងមេឃ ។ មុខហ្នឹង ពងហ្នឹងនាងដូចបានឃើញម្តង កាលដែលអ្នកដំរះសេះពីរនាក់ ដេញតាមនាងនឹងបងនាងរហូតមកដល់ទីសំណាក់ ហើយរកធ្វើអ្វីមិនកើតដោយខុសច្បាប់ ។ លុះដឹងជាក់ដូច្នោះ ឡីឡាស្ទុះរត់ចេញពីទឹកមករកទីអាស្រ័យដោយស្ងៀមស្ងាត់អាក់ខានមិនបានងូតទឹកលេងកំសាន្តក្នុងពេលព្រហាមដែលជាពេល

ត្រជាក់ សម្រាប់ធ្វើសាច់ឈាមឲ្យខ្សែងពណ៌ស្អាត ។ ចំណែកខាងជីវភាពវិញតែប្រពឹត្តទៅ មានអាការខាងក្រៅជាសុខសាន្តត្រាណ ។

ពួកប្រុសៗ ថ្ងៃល្ងាចត្រឡប់ចូលមកវិញ នាំគ្នាទៅជំរាបលោកតាម៉ាត្រុក អំពីកិច្ចការដែលអាត្មាបានធ្វើអ្វីៗខ្លះពីថ្ងៃ ។

ក្នុងក្រុមអ្នកដើរទេសចាំងឡាយ មានមនុស្សធ្វើការច្រើនបែប គឺមានតាំងពីមនុស្សអ្នកមុជទឹកវាយកផ្លាំងផ្កាថ្ម នៅស្រុកឌ្រីប៉ូលីជាដើមឡើងទៅ កាលណាការបានផ្លាំងផ្កាថ្មច្រើនហើយ ក៏យកមកវាចនាជាគ្រឿងប្រើប្រាស់ផ្សេងៗ យ៉ាងទន់ស្ងួតល្អ . មានគ្រូពេទ្យចេះយកខ្លឹមក្រិស្នានឹងផ្កាកូឡាបមកសូចំពញ់យកជាតិធ្វើជាម្សៅ ដើម្បីទុកសម្រាប់តែងកាយនឹងរក្សាឆវីវណ្ណស្រីៗឲ្យនៅគង់វង្សបានល្អ ហើយចេះធ្វើម្សៅក្រអូបខ្លះទៀតសម្រាប់ឲ្យស្រីចាស់ៗលាបទៅ ត្រឡប់មានសម្បុរដូចនារីអាយុ ២០ ឆ្នាំ អ្នកធ្វើជំនួញសំពត់ស៊ីក្លាតស្បែកសម្លាប់ហើយសំពត់សូត្រ មកចាំទទួលនៅស្រុកឌ្រីប៉ូលីអំពីអ្នកជំនួញមកពីប្រទេសអឺរុប ។

មនុស្សទាំងនេះ សុទ្ធតែជាអ្នកធ្លាប់ប្រពឹត្តការចិញ្ចឹមជីវិតដោយខ្នងសត្វអូដ្ឋកន្លងវាលកន្លារៈ កណ្តាលថ្ងៃក្តៅ ចាន់ប្រទះនឹក្រែងតែមួយភ្លែតៗ ។ ម្ល៉ោះហើយគេច្រើននិយាយបំផ្ងើសបញ្ឆោតបញ្ឆិលខ្លះ អំពីកោតសម្បត្តិដែលគេបានឃើញ អំពីនាម៉ឺនតួចធំដែលមានសេចក្តីពាប់អាណដល់គេអំពី

អាំងធ្វើបាសាដែលគេបានយល់ ។ តាមការណ៍ពិត គឺគេច្រើនតែបង្កើត
ដោយខ្លួនឯង ដើម្បីនិយាយឲ្យពីរោះដល់ត្រចៀកលោកតាម៉ាត្រូក
ចូលចិត្តស្តាប់ដោយសេចក្តីគោរព ។ រៀលាស្ងាចកាលណា គេដែល
បរិភោគស្តាប់ស្តាល់ខ្លួវបាយរោតនឹងសាច់ចៀមអាំងហើយ គេនាំគ្នាអង្គុយ
ដំកង់ចាំស្តាប់គេនិយាយរឿងដ៏ប្លែក ។ ។ កាលណាគេនឹកពាំងដោយ
ស្រមាក់ស្រម័យខ្លួវអាំងបាសាខ្លួវទឹត្រូងប្រកបដោយសម្បត្តិផ្សេង ៗ ខ្លួវរូប
ស្រីស្អ ។ ខ្លួវមេខ្លួសប្រកបដោយចំកមុខរីករាយ ខ្លួវបាវព្រាវចិត្តស្លូតត្រង់
គឺថាបើពោលដោយសង្ខេប គឺជារឿងដែលធ្វើឲ្យអ្នកចាចរក៍ទាំងប៉ុន្មាន
ដែលធ្លាប់តែដេកលើកន្ទេល ឬដេកតែនឹងដីត្រេកអរជំរំសំពត់ប្រកបដោយ
ភ័យអំពីពស់ ក្អែប ខ្លួយជានិច្ច ហើយមិនស្គាល់អ្វីត្រៃពីរាល់កន្លាង
ស្តាប់ពុកាលណា មានក្អែកក្រឡង់ ទឹកកោត ទឹកចន់ ទឹកសប្បាយដោយ
សារផង រួចទើបពួកអ្នកចាចរក៍សុំឲ្យនាងឡឺឡាច្រៀងបង្ហើយកិច្ចពុង
ក្រោយ ដែលមានសំឡេងដ៏បរិសុទ្ធ អាចញាំងចិត្តបុរសទាំងឡាយ
ឲ្យតេញចរិបូណ៌ ។

នាងច្រៀងរំលឹកអំពីរឿងតាមពាត ទឹងមរណកម្មដែលជាអនិច្ចតាធម៌
ជារឿងដែលតាំងពីយូរណាស់មកហើយ គេតែងទុកជាទំនុកមួយរបស់
អ្នកស្រុក ជាទំនុករបស់សាមញ្ញជន ។

សំឡេងនាង តែស្រែកជ្រែងឡើងកាលណា អាចធ្វើឲ្យពួកគ្រប់-
គបដោយសេចក្តីរំភើប ស្រណោះស្រណោកលន្ទង់លន្ទោច ។ សំឡេង
នាងជាអាហារមានឧជារសដល់ប្តាជ្ញាមឹងចិត្តនៃបុរសស្លឹក ដែលចាស់មុន
អាយុព្រោះការងារជ័យ៉ាប់លំបាកក្នុងវាលតន្ត្រារៈ ។ សំឡេងនាងមាន
អានុភាពអាចកំចាត់បង់នូវទុក្ខមុខអាត្រក់ តើតមកអំពីការខឿយហត់ក្នុង
វេលាថ្ងៃចោលបាន ។

ចំណែកពួកអ្នកដើរទេស តំបណ្តោយចិត្តឲ្យអណ្តែតតាមសូរនៃចំ-
រៀងនាង គេបណ្តែតដួងវិញ្ញាណឲ្យស្ទុង ទឹកទៅស្ថានណាមួយជាវិជ្ជមាន-
ភាព ទឹកដល់អ្នកត្រឡត់គ្មានគណៈ ដើរជួញដោយវាលតន្ត្រារៈគ្មានទាយ
គ្មានបារម្ភរៀ គឺថាស្ថានដែលមានតែសុភ្លានរូបដូចព្រះបន្ទូ ទឹងស្តេចចិត្ត
សប្បុរស ចូលចិត្តធ្វើការកុសល ។

ព្រះអង្គសំកំដួយគេទាំងនោះឲ្យបានសុខស្រួល ។

គឺថាក្នុងត្រីស្ងាត់ មានតែវាយោបក់មកពីវាលតន្ត្រារៈ មានតែពន្លឺ
ផ្កាយលើមេឃ ទឹងសូរចំរៀងដែលធ្វើឲ្យគណៈនេះបានអស្ចារ្យដំណេក
ជាសុខឥតមានចលាចលអ្វីឡើយ ។

ចំណែកទំនុកបន្ទរដ៏ស្រទន់ស្រទោច ចេញបន្តគ្នារជឹកពីមាត់នាង
ត្រមុំ ដែលមានរូបយ៉ាងស្អាតដូចជាផ្កា ។

(មានត)

# សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# បរិយាយពីការសាងវិលុកចេតិយ (ភ្នំពេញ)

របស់លោក ចាប - ពិន

---

តាមនាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ខ្ញុំសូមបរិយាយពីការកសាងវិលុកចេតិយ (ភ្នំក្នុងភ្នាប់) ដើម្បីរំលឹកដល់ទំនៀមនេះដូនជាសណ្តាប់ធ្នាប់អ្នកប្រមជាតិ ដូចតទៅខាងមុខ ៖

ចេតិយដែលគេសាងដោយដីឥដ្ឋសុទ្ធ គឺគេយកដីឥដ្ឋមកចាក់គរហើយពូនឲ្យមានរូបជាចេតិយឡើង ហៅតាមភាសាបាលីថា "វិលុក-ចេតិយ" តែអ្នកផងតែងហៅជាភាសាខ្មែរថា "ពូនភ្នំក្នុងភ្នាប់" ព្រោះគំនរឥដ្ឋដែលពូនឡើងនោះមានស្ថានភាពប្រហែលភ្នំ ។

វិលុកចេតិយនេះ មានគតិនិយមថា ធ្វើឡើងដើម្បីទុកិ្ខសថ្វាយជាសក្ការបូជាដំណាងព្រះចូឡាមណីចេតិយ នៅស្ថានតៃត្តឹង្សសួគ៌ដែលពួកទេវតាសាងបញ្ចុះព្រះកេសធាតុ (ព្រះកេសា) និងព្រះទាឋាធាតុ (ព្រះចង្កឹមកែវ) នៃព្រះសម្មាសម្ពុទ្ធ ដោយសំគាល់ថាបានផលានិសង្សណាស់ ។

ការកសាងវិលុកចេតិយ នៅប្រទេសកម្ពុជាយើង មានធ្វើតាំងព្រះពុជាតាំងប្រជាពលរដ្ឋ, តាំងពីរបៀបនេះ មានទំនៀមទំលាប់ច្បាប់ត្រម

តាំងពីដើមប្រវត្តិសាស្ត្រ គ្រាន់តែទំនៀមទាំងព្រះពុទ្ធរូបជាផ្លូវការ ហៅថា "ព្រះពុទ្ធពិធី" ។ ឬក៏អធិកអធំជាងពិធីក្តី ។ រហូតធ្វើជាផ្លូវការតែងធ្វើនៅវត្តកុំជួនពេញ ទើងព្រះវិហារព្រះកែវមរកត ដូចក្នុង គ. ស. ១៩៥៤ នេះ ធ្វើនៅវត្តកុំជួនពេញនៅថ្ងៃទី ៥ ទើង ៦ មេសា, ធ្វើនៅព្រះវិហារព្រះកែវមរកត នៅថ្ងៃទី ៨ ទើង ៩ មេសា ។ ព្រះពុទ្ធពិធីនេះមានពិស្តារក្នុងសៀវភៅព្រះពុទ្ធពិធីទ្វាទសមាសភាគ ១ ដែលក្រុមដំនុំទំនៀមទម្លាប់រៀបរៀងចោះពុម្ពហើយ មានផ្សាយនៅតុន្តសាសនបណ្ឌិត្យ ។

ក្នុងទីនេះ សូមពណ៌នាដោយសង្ខេបនូវពិធីក្តី ដូចតទៅនេះ:

ក) លុកចេតិយ តើតែងសាងនៅទីណា ? មានទ្រាតប៉ុណ្ណា ? មានទ្រនំព្រាយដូចម្តេច? សាងម្តង ។ មានប៉ុន្មានគួរចេតិយ? មានគ្រឿងប្រកបដូចម្តេច ?

តាមប្រែបដើម ឃើញថា ឥតមានកំណត់ឲ្យសាងនៅទីណាទេ, តែបើតាមទម្លាប់ដែលបុព្វាចារ្យធ្លាប់ធ្វើមក គឺធ្វើនៅទីណាដែលមានដីខ្ពាច់ល្អ ហើយបើតាមទំនៀមទម្លាប់របស់ប្រទេសកម្ពុជាយើង គេច្រើនធ្វើនៅទីវត្ត ដោយទីនេះជាទីប្រជុំជនផង ដើម្បីនឹងឲ្យបានដីបូលវត្តផង, ឯទីដទៃក្រៅពីទីនេះ ដូចនៅដើមពោធិ៍ជាទីសក្ការបូជារបស់ប្រជាជនជាដើមក៏មានធ្លើខ្លះដែរ តែធ្វើដោយតិច ។

ខ) សាងក្នុងវេលាណា ?

តាមរឿងប្រាប្តដើម មានរឿងខ្លះកំណត់ថាត្រូវសាងគឺធ្វើនៅវេលាចូលឆ្នាំ" រឿងខ្លះគ្មានតែណែនាំឲ្យធ្វើ ឥតមានកំណត់កាលវេលា, តែតាមទំនៀមរបស់ខ្មែរយើងតែងធ្វើទូទៅតាំងស្រុកក្នុងវេលាចូលឆ្នាំ គឺចំថ្ងៃចូលឆ្នាំ ៣ ថ្ងៃក៏មាន មុនឬក្រោយថ្ងៃចូលឆ្នាំបន្តិចបន្តួចដែលរួមហៅថា "ផ្លូវចូលឆ្នាំ" ក៏មាន, ក្រៅពីផ្លូវនេះគេធ្វើចំពោះពេលបុណ្យចម្រើនអាយុដើម្បីឲ្យបានអាយុយឺនយូរ ទឹងចំពោះពេលដែលមាតាឬបិតាឈឺធ្ងន់ ដើម្បីរំដោះគ្រោះ, ពីរពេលខាងក្រោយនេះមានធ្វើតែចំពោះឯកជនតាមពេលដែលមានការជាការចាំបាច់ មិនមែនមហាជនធ្វើតាំងស្រុកទេ, បើផ្លូវចូលឆ្នាំនោះ គេធ្វើទូទៅតាំងប្រទេស ។

គេសាងមានខ្នាត ទំហំ ឬកំពស់ប៉ុណ្ណា?

វាលុកចេតិយគ្មានតម្រាណាមួយកំណត់ខ្នាតជាកម្រិតថា ទំហំឬកំពស់ជូចម្តេចទេ ស្រេចទាំលើអធ្យាស្រ័យរបស់អ្នកសាងចង់ធ្វើប៉ុណ្ណាក៏បាន; ហេតុនេះ បានជាឃើញគេធ្វើខ្នាតតូចៗ ប៉ុនពាន់គោមប្រតិស្ឋានលើតុឬថាសចំពោះពេលរំដោះគ្រោះក៏មាន; ខ្នាតកណ្តាលទំហំមូលចំនួន ២ - ៣ ហត្ថ កំពស់ត្រឹមបង្កេះក៏មាន; ខ្នាតធំៗប៉ុនធ្មឹមស្រូវមានភាពប្រហែលដំបូកធំឬកូនកុំក៏មាន ។

តាមដែលបានសង្កេតមក ខ្នាតតូចៗ ជំគល់លើតុឬថាសគេធ្វើចំពោះឯកជនដែលធ្វើរំដោះគ្រោះនៅពេលដែលគេមានជម្ងឺធ្ងន់; ខ្នាតកណ្តាលនឹងខ្នាតធំៗ គេធ្វើទូទៅតាំងប្រទេសនៅវេលាចូលឆ្នាំ ។

*គេសាងឆ្កឹងៗ ចំនួនប៉ុន្មានគួរចេតិយ?*

*វាលុកចេតិយ* គ្មានតម្រាណាមួយកំណត់បរិមាណថាចំនួនប៉ុន្មាន ទេ, តែតាមទំនៀមនៅប្រទេសកម្ពុជាយើង បើដើម្បីរំដោះគ្រោះចំពោះ ឯកជនដែលធ្វើតាមគ្រឹះស្ថានរបស់ខ្លួន ឃើញគេធ្វើតែមួយក៏មាន ដល់ ៣ ឬ ៥ ក៏មាន ហើយគេធ្វើតូចៗ ដាក់លើតុឬថាសដូចបរិយាយពីខាង ដើម ការដែលធ្វើតែមួយ ឬធ្វើដល់ ៣ ឬ ៥ នោះសោត ក៏ឥតមាន តម្រាណាមួយនិយាយដល់ គឺស្រេចនៅលើអធ្យាស្រ័យអ្នកធ្វើ បើធ្វើ នៅទីវត្ត ឃើញគេធ្វើព័ទ្ធជុំវិញព្រះវិហារតាមទិសទាំង ៨, តែចួនកាល ឃើញគេធ្វើនៅទីសមគួរណាមួយ ក្នុងវត្តតែចំនួន ៥ ចេតិយក៏មាន គឺធ្វើ មួយធំខ្ពស់ចំកណ្តាល (ដែលតាមចាស់ៗ និយមថាធ្វើដំណាងក្តីសង្ឃ ដែលជាទីតាំងឋានត្រៃត្រឹង្ស), តូចៗបួន នៅទិសទាំង ៤ គឺទិសបូព៌ ទក្សិណ បស្ចឹម ឧត្តរ (ដំណាងក្តីយុគន្ធរដែលជាទីតាំងឋានចាតុម្មហា-រាជិកា) ។

*ត្រឿងប្រកបវាលុកចេតិយដូចម្តេចខ្លះ?*

តាមទំនៀមទ្វេរយើង កាលបើគេជញ្ជួនដីខ្សាច់មកចាក់គរឲ្យ មានទ្រង់ទ្រាយប្រហែលភ្នំ មានកំពស់ទំហំធំតូចល្មមតាមដែលគេត្រូវ ការឡើងហើយ គេប្រើនយកកញ្ចឹមមួយកំណាត់ ឬយកកញ្ចឹមទាំងមូលមកកប់ ឲ្យនៅត្រឹមកជាក់ត្រង់កំពូល ត្រង់ចេតិយ ឲ្យមានសណ្ឋានដូចក្បាច់ក

ចេតិយមែនទែន. វត្តខ្លះដែលគេរកដីខ្សាច់ពុំបានហើយគេចង់ឲ្យចម្រើនដី វត្តគេយកដីកណ្តើរធ្វើជំនួសក៏មាន ធ្វើហើយគេធ្វើកដាំតិចខ្នុរជុំវិញពីក្រៅចេតិយចាំងនោះ ទុកតែមាត់ទ្វារចេញចូល ៤ ទិស គេធ្វើពន្លឺ ៨ ជាក់គ្រប់ ៨ ទិស មានពន្លឺមួយទៀតគេសន្មតជាពន្លឺព្រះកាល ឬព្រះយមកជជាក់នៅទិសបូព៌ា មានចាំងតែត្រួត ទឹងទង់រលកដោតគ្រប់ពន្លឺចាំងនោះផង ព្រមចាំងបូជាដោយផ្កាក្រឹ ទឹងស្អាតមិនកំអប់ជាដើម ។

កាលគេធ្វើគ្រឹងប្រជាប់ដូចរៀបរាប់ខាងលើនេះរួចហើយ វេលាថ្ងៃរសៀលចាបគេយកទៀនធូបទៅអុជ យកផ្កាឈើមានពណ៌ផ្សេងៗទៅដោតជាក់បូជានឹងយកទង់ធ្វើពីក្រដាសពណ៌ផ្សេងៗ ទៅដោតបូជានៅកំពូលវាលុកចេតិយចាំងនោះ ហើយមានអាចារ្យម្នាក់នាំទុបាសក ទុបាសិកាដើរប្រទក្សិណ ៣ ជុំរួចនមស្ការព្រះរតនត្រ័យ សមាទានសីល ហើយយកសំពត់សទៅព័ទ្ធឈើង ដូចអង្រឹកពីលើវាលុកចេតិយចាំងនោះ រួចនាំសូត្រអធិដ្ឋានវាលុកចេតិយចាំងអស់ ដែលគេហៅតាមសំដីអ្នកស្រុកថា "បំបួសក្នុំ" ឲ្យជាដំណាងព្រះបូព្វាមណីចេតិយឯឋានតែត្រឹងឬសូត្រដោយបាលីថា ឥមំ វាលុកចេតិយំ បុព្វាមណិចេតិយំ អធិដ្ឋាមិ (ប្រែថា) "ខ្ញុំសូមតាំងចិត្តអធិដ្ឋានព្រះចេតិយខ្សាច់នេះ ឲ្យជារបស់ដំណាងព្រះបូព្វាមណីចេតិយ" ។

ក្រោយពេលបំបួសកុំ, រៀលយប់គេនាំគ្នាបូលវិហារឬសាលាបុណ្យ
និមន្តព្រះសង្ឃសូត្រព្រះបរិត្ត រួចទេសនាសាស្ត្រាអានិសង្សខ្លាច ចើ
បុណ្យនោះគេធ្វើត្រង់លើថ្ងៃបូលឆ្នាំ លុះចប់ទេសនា គេលេងល្បែង
ផ្សេង ។ តាមទម្លាប់ស្រុករបស់គេ មានលេងឈូង អង្គញ់ ពាញ
ព័ត្រ ច្រៀងកញ្ជាជាដើម, រៀលព្រឹកគេអង្គាសយាគូ ថ្ងៃត្រង់
អង្គាសភត្តប្រគេនព្រះសង្ឃទ្វេទៅតាំងវត្តគ្រប់ចីថ្ងៃចីយប់, នៅថ្ងៃគម្រប់
៤គេនិមន្តព្រះធម្មកថិកទេសនាសង្គាយនាធ្វើបុណ្យ ហើយនិមន្តលោក
បង្សុកូល រួចប្រគេនរណ្តាប់ទេយ្យទានមានសំពត់សាដកឈើគូសបាវស្ករ
តែជាដើមចំពោះព្រះសង្ឃតាមសមគួរដល់សទ្ធា ជាការសម្រេចពិធី
បុណ្យសាង៧លុកចេតិយ ត្រឹមប៉ុណ្ណេះ ។

តាមទំនៀមរ៉ាលុកចេតិយដែលគេបានអធិដ្ឋាន (បំបួស) ហើយគេ
កាន់ថាបានឡើងពេញជាពុទ្ធចេតិយមែន។ នរណាមួយទៅរំលាយព្រះ
ចេតិយនោះមុនគេផ្សឹកចេញ គេទុកថាជាមានទោសធ្ងន់ណាស់, ដោយ
ហេតុនេះ កាលគេធ្វើបុណ្យធ្វើហើយ អាចារ្យក៏ផ្សឹកចេញភ្លាមដោយ
ភាសាថាលីថា គិមំ រាលុកចេតិយំ បច្ចុទ្ធាមិ (ប្រែថា) "ខ្ញុំផ្សឹក
ឥឡូវនេះនូវរ៉ាលុកចេតិយនេះ គឺដកចិត្តចេញលែងកាន់ថាជារ៉ាលុកចេតិយ
ហើយ" ។ ក្រោយពីនោះទោះនរណារំលាយក៏គ្មានទោសពៃរ៍អ្វីទេ
ហើយគេយកដីខ្លាច់កុំនោះទៅស្ថាបនាជាវត្តអ្វី ។ កុងវត្តតាមត្រូវការ ។

មានសូត្រមួយឈ្មោះមហាសំការសូត្រ សំដែងពីដើមកំណើតរឿងបុណ្យសាងរូបព្រះចេតិយថាបានផលានិសង្សណាស់ មានសេចក្តីដូចស្រែងមកដោយសង្ខេបតៈទៅនេះថា:

សម័យមួយ ព្រះបរមសាស្តាទ្រង់ប្រថាប់ក្នុងវត្តជេតពន ទ្រង់សំដែងធ្វើយប្រស្នាព្រះបាទបសេនទិកោសលថា: មហាបពិត្រ! អ្នកដែលបានសាងរូបព្រះចេតិយបានបូជារូបព្រះចេតិយ ដោយវត្ថុផ្សេងៗ មានផ្កាក្រឡឹងក្រអូបនឹងទៀនធូបជាដើមបានផលច្រើន តែងបានទៅកើតក្នុងត្រកូលក្សត្រត្រកូលព្រាហ្មណ ។ល។

អ្នកដែលបានដោះលែងសត្វក្នុងទុកាសសង្ឃានចូលឆ្នាំថ្មី រមែងមានអាយុយឺនយូរមានសេចក្តីសុខច្រើន អ្នកណាបានផ្គត់ទំកមាតាបិតាគ្រូបជ្ឈាយ៍អាចារ្យក្តី បានរក្សាសីលក្តី ឲ្យទានក្តី បានអុជប្រទីបជូលាក្តី បានដោតទង់ជូបូជាក្តី បានដឹកស្រះក្តី បានសង់ស្ពានក្តី បានធ្វើផ្លូវថ្នល់ក្តី ។ល។ ព្រះចតុលោកបាលតែងកត់ឈ្មោះអ្នកនោះទុកលើផែនមាស, បើអ្នកណាមិនស្គាល់គុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ មិនធ្វើបុណ្យ ធ្វើតែបាប ព្រះចតុលោកបាល តែងតែកត់ឈ្មោះអ្នកនោះទុកលើស្បែកឆ្កែ ។ល។

ក្រៅពីមហាសំការសូត្រដែលថ្វែងមកខាងលើនេះ មានរឿងនិទាន ២ ទៀតសុទ្ធតែនិយាយពីដើមកំណើត នៃការកសាងរូបព្រះចេតិយទាំងអស់គឺ

ន័ទានទី ๑ ដំណាលពីព្រះពោធិសត្វនាមចុរិកៈ ជាឈ្មួញសំពៅ
ចេីកសំពៅទៅដួញបានឃេីញផ្កាឧប្បាច់ល្អនៅឆ្នេរសមុទ្រ កំបបួលពា-
ណិជឯទៀត កសាងជាវាលុកចេតិយ១ទុំសជាដំណាងព្រះបូព្វាមណី
ចេតិយនៅឋានតៃត្រឹង្សស្ថគិ ដែលបញ្ចុះព្រះកេសាធំងព្រះចង្កឹមតែវ៉ៃន
ព្រះសម្មាសម្ពុទ្ធ បានបេះផ្កាឈេីបូជា បានដេីរប្រទក្សិណ ៣ ដុំ ហេីយ
ចេីកសំពៅចេញទៅ ។ លុះចុរិកពោធិសត្វទំងឈ្មួញទាំងនោះរំលាង
បញ្ចូកុន្ទទៅបានទៅកេីតជាទេវបុត្រនៅឋានសួគ៌ច្រេីនជាតិ ច្យុតពីឋាន
សួគ៌មកកេីតជាស្តេចចក្រពត្តិ ជាស្តេចឯកពាជ្យច្រេីនជាតិ, ទីបំផុតចុរិក-
ពោធិសត្វបានត្រាស់ជាព្រះពុទ្ធ, ឈ្មួញឯទៀតបានជាពុទ្ធសាវ័កដោយ
អំណាចផលដែលបានសាងវាលុកចេតិយនោះឯង ។

និទានទី ២ ដំណាលថានេសាទម្នាក់ សម្រាប់សត្វចិញ្ចឹមជីវិត
តាំងពីក្មេងរហូតដល់ចាស់មិនដែលធ្វេីបុណ្យម្តងសោះ, ថ្ងៃមួយកំពុងតែលី
លំពែង ស្តាយថាយកញ្ចប់ចេញទៅព្រៃស្វែងរកសត្វ មានភិក្ខុ ១ រូប
សុំចង្ហាន់, ដោយលោភខ្លួចសុំមិនលែងសោះ នេសាទក៏ពូតថាយ
១ ពំនួតប្រគេនទៅ ។ លុះនេសាទស្លាប់ទៅត្រូវពួកយមបាលចាប់ខ្លួន
ទៅសួរពីរឿងធ្វេីបុណ្យថាបកាលនៅជាមនុស្ស, នេសាទតបថាមិនបាន
ធ្វេីបុណ្យសោះ ធ្វេីតែបាប យមបាលក៏ចាប់នេសាទចុះទៅកន់ក្តៅន
រក, នេសាទក្រឡេកឃេីញក្តៅសម្បារដូចព្រៃចេីវ ក៏ខឹកដល់ចាន

របស់ខ្លួនទើបធ្វើយ៉ាងដូច្នោះថា កាលខ្លួននៅជាមនុស្សបានធ្វើទានបាយ ១ ពាន្ធូតដល់កិក្ខុ ១ រូបដែរ ។ យមបាលប្រាប់ថា បើដូច្នោះអ្នកឯងត្រូវបានឡើងទៅកើតឯឋានសួគ៌ ៧ ថ្ងៃ, ដល់ថ្ងៃទី ៨ យើងនឹងយកអ្នកឯងមកទម្លាក់នរកវិញ ។ នេសាទក៏បានទៅកើតឯឋានសួគ៌ ឈ្មោះ អន្ទំលោកកង្ស៊ីនីទេវបុត្រ មានវិមាន មានបរិវារ មាននាងសុវណ្ណនារីជាទេពី ។ អន្ទំលោកកង្ស៊ីនីទេវបុត្រសោយសុខបាន ៦ ថ្ងៃ ទឹកដល់ពាក្យយមបាលក៏ចោមនស្ស ចូលទៅដេកយំ, នាងសុវណ្ណនារីសួរក៏ប្រាប់តាមដំណើរ, នាងថា បើដូច្នេះយើងត្រូវសាងវាលុកចេតិយ ហើយធ្វើបុណ្យឆ្លងទើបរួចចាកកម្មពៀរនោះ ។ អន្ទំលោកកង្ស៊ីនីទេវបុត្រក៏ចាត់ការកសាងវាលុកចេតិយស្រេចក្នុងថ្ងៃទី ៧ ។

ដល់ថ្ងៃទី ៨ ពួកយមបាលទៅកេ, នាងសុវណ្ណនារីប្រាប់ថា ស្វាមីយើងបានសាងវាលុកចេតិយបានធ្វើបុណ្យឆ្លង បានរួចស្រឡះចាកកម្មពៀរហើយ, បើអ្នកនៅតែត្រូវការយកខ្លួនទៅធ្វើគោសខ្មៅតបូរអ្នកពប់គ្រាប់ខ្សាច់ ១ ពែងនេះសិនបើពប់អស់ទើបយកទៅបាន ។ ពួកយមបាលក៏ពប់តាំងពីព្រឹកដល់ថ្ងៃត្រង់ គ្រាប់ខ្សាច់ដែលពប់ហើយជាក់ស្តែងពែងកំពស់ចុងត្នោត តែពែងនៅតែពេញជាដែល ពួកយមបាលចាញ់ចំណោះក៏ត្រឡប់ទៅយមលោកវិញ ។ អន្ទំលោកកង្ស៊ីនីទេវបុត្របាននៅក្នុងឋានសួគ៌ដរាបមក ដោយអំណាចអានិសង្សកសាងវាលុកចេតិយនោះឯង ។

និទានទី ៣ ដំណាលថា មានក្មេងម្នាក់ចេះតែទៅពូនកំទ្បាច់លេង នៅផ្នែកខាងក្បែរផ្ទះដោយគាំងចិត្តជាបុណ្យតាមនិស្ស័យក្មេង ពូនហើយដេកនៅលើលំដាប់ក្បែរកំទ្បាច់នោះរាល់ថ្ងៃ ទាល់តែអ្នកស្រុកគេហៅក្មេងនោះថា "ចៅកំដៅលទ្បាច់" ។

ថ្ងៃមួយ ព្រះឥន្ទ្រាបើកទិព្វចក្ខុមកឃើញចៅកំដៅលទ្បាច់ពូនកំទ្បាច់ក៏ចាត់ឲ្យនាងទេពធីតា ១ រូបមកធ្វើជាកវិយា, គាំងពីបានកវិយាហើយចៅកំដៅលទ្បាច់មានខ្លួនថ្លាណាស្អាតជាត មានកិត្តិសព្ទល្បីល្បាញថាចៅកំដៅលទ្បាច់ជាន ប្រពន្ធល្អណាស់ ។ ខណ្ឌលវេលានោះព្រះរាជាម្ចាស់ផែនដី ទ្រង់ព្រះនាមវិគ្គត គ្មានព្រះរាជបុត្រតរាជសម្បត្តិ ពួកសេនាបតីគិតឃើញថា ចៅកំដៅលទ្បាច់គួរធ្វើព្រះរាជា ក៏ចាត់ការផ្សឹងបុស្សរថ (រថផ្កា) រកអ្នកមានបុណ្យ បុស្សរថរត់ទៅត្រូវលើចៅកំដៅលទ្បាច់ ទើបគេនាំគ្នាអញ្ជើញទៅសោយរាជ្យ អភិសេកនាងទេពធីតាជាអគ្គមហេសី ។

សូត្រនិទានខាងលើនេះ សុទ្ធតែជាសាស្ត្រាស្នឹកវិតជាគម្ពីរតែងឡើងខាងក្រោយ, មហាសំការសូត្រកាសាបាលី និទានតាំង ៣ សម្រាយកាសាខ្មែរ អ្នកផងតែងហៅនិទានតាំងនោះថា "សាស្ត្រាអានិសង្សទ្បាច់", សាស្ត្រាតាំងនោះបើមិនមួយក៏មួយជម្កុំថាកច្រើនយកមកទេសនានៅពេលធ្វើបុណ្យកសាងវិលុកចេតិយ ព្រោះហេតុនេះទើប

ខ្មែរយើងទើបមានសទ្ធាជ្រះថ្លានាំគ្នាធ្វើបុណ្យនេះជាប់ជាប្រពៃណីរៀងមក ដរាបដល់សព្វថ្ងៃនេះ ។

បណ្តាសូត្រនឹងនិទាន ដែលមាននិយាយពីការកសាងវលុកចេតិយ តាំងប៉ុន្មាន ដូចបានស្រង់មកថ្លែងដោយសង្ខេបខាងលើនេះ មហាសំការសូត្រ និទានបាកពោធិសត្វ នឹងនិទានចេតកំដលខ្លាច់គ្រាន់តែសំដែងថា ពួនក្តុំខ្លាច់បានផលានិសង្សច្រើន, ចំណែកនិទាននេសាទថា ពួនក្តុំខ្លាច់ផ្តាច់កម្មពៀរ, ព្រោះហេតុនេះបានជាជនសាម័ញ្ញនិយមដឿតាមនិទាននេសាទថា ពួនក្តុំខ្លាច់ផ្តាច់បាប; តែសម្រាប់ជនជាបណ្ឌិតដែលយល់ការណ៍ពិតតាមគោលពុទ្ធវចន: មិននិយមដូច្នោះទេ បើពួនក្តុំខ្លាច់ក៏ពួនទុំសថ្វាយជាតំណាងព្រះចូឡាមណីចេតិយត្រង់ៗ យកផលានិសង្សដើម្បីបានសេចក្តីសុខ សេចក្តីចម្រើនក្នុងលោកនេះ នឹងលោកខាងមុខ ។

បរិយាយពីទំនៀមសាងវលុកចេតិយ (ពួនក្តុំខ្លាច់) ចប់ដោយសង្ខេបត្រឹមប៉ុណ្ណេះ ។

---

# តំណឹងបុណ្យបញ្ចុះបឋមសិលា

## នៅទីស្ថាបនាពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ពុទ្ធសាសនបណ្ឌិត្យ

---

កាលពីថ្ងៃទី ២៤ ខែមីនាឆ្នាំ ១៩៥៤ មានធ្វើពិធីបុណ្យបញ្ចុះបឋមសិលាចារឹក នៅកន្លែងស្ថាបនា "ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ" ជាមហាវិទ្យាល័យខាងពុទ្ធសាសនា សម្រាប់ព្រះសង្ឃឫគ្រហស្ថសិក្សាវិជ្ជាជាន់ខ្ពស់ថ្នាក់បណ្ឌិត នៅក្រោមអធិបតីភាពនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្រសួងធម្មការជាអ្នកចាត់ចែង ។ ចាប់ផ្តើមតាំងពីយប់ថ្ងៃអង្គារ ទី ២៣ រហូតដល់ពេលព្រឹកថ្ងៃទី ២៤ មីនា ទើបបានបញ្ចប់ ។

នៅពេលថ្ងៃទី ២៣ មីនានោះ មានការជួបជុំព្រះសង្ឃចំនួន ៥០០អង្គ និងពុទ្ធបរិស័ទជាង ២០០០ នាក់ ចូលរួមអញ្ជើញទៅសំដែងសេចក្តីគោរពអបអរចំពោះសំណាក់នៃគ្រឹះស្ថាននេះ ។ ម៉ោង ៨ យប់ ព្រះសង្ឃបានចំរើនព្រះបរិត្តកងចុងក្រោយនៅកន្លែងដែលកសាង រួចនិមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ សំដែងធម៌ ដែលជាហេតុញ៉ាំងចិត្តពុទ្ធបរិស័ទទាំងឡាយ ឲ្យរីករាយមានសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង ។ បន្ទាប់មក មានភាពយន្ត (កុន) បញ្ចាំងជូនប្រជាជនមើលជាទីគាប់ចិត្ត ។

ព្រឹកឡើងថ្ងៃទី ២៤ ចាប់តាំងពីម៉ោង ៨,៣០ នាទីទៅដល់ម៉ោង ៨, ៥៨ នាទី ឥស្សរជនទាំងឡាយទាំងបព្វជិតទាំងគ្រហស្ថ មានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈ, សម្តេចព្រះធម្មលិខិតទត្តមប្រឹក្សាវត្តលង្កា, ព្រះពោធិវង្សហួត-តាតហាងហ្វាងសាលាបាលីជាន់ខ្ពស់ នឹងកជាគណៈ ហានានុក្រម, ចំណែកគ្រហស្ថមានឯកទត្តមចាន-ណាក នាយករដ្ឋមន្ត្រី, ឯកទត្តមប៉ែន-នុត អតីតរដ្ឋមន្ត្រីទី ១, សមាជិករដ្ឋាភិបាល, ឯកទត្តមយិត-ស៊ុនប្រធានក្រុមប្រឹក្សាជាតិ, លោកគ្តាវ្រដាហ្គត់កុម័ស្សីរស្តីទី, អគ្គទូត, ឯកទត្តមហ៊ុយ-កន្ទុល អតីតនាយករដ្ឋមន្ត្រី នឹងអតីតរដ្ឋមន្ត្រីជាច្រើនរូប ព្រមទាំងនាយកមន្ទីរ នាយក្រុមការជាច្រើនតំណែង ចូលរួមជាមួយនឹងអញ្ជើញទៅជាទត្តមមង្គលកិច្ចពិធីបុណ្យនេះ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលមានក្រុមប្រឹក្សាឯកជនអមព្រះអង្គទាំងពីរបូ, រាជអង្គរក្ស, លេខាធិការផ្ទាល់ព្រះអង្គហែហមផង ចូលស្តេចយាងទៅដល់កន្លែងសង់គ្រឹះស្ថានមហាវិទ្យាល័យ នៅម៉ោង ៨, ៥៩ នាទី ។ កំឡុងពេលដែលស្តេចយាងចុះពីព្រះទីនាំងរថយន្ត គណៈរដ្ឋមន្ត្រីបានរង់ចាំក្រាបថ្វាយបង្គំទទួល ត្រង់ចំពោះមុខតារាវិថីស៊ីសុវត្ថិ ។ នៅទីនោះមានក្រុមការពារព្រះអង្គ នឹងក្រុមភ្លេងព្រះរាជទ្រព្យឈរជាពីរជួរចាំធ្វើគារវកិច្ច នឹងប្រគំភ្លេងបទនគររាជជាទីកិត្តិយសចំពោះព្រះរាជដំណើរ ដែលស្តេចយាងមកដល់ ហើយបន្ទាប់តមកទើបព្រះមហាវីរៈ

ក្សត្រិយ៍យាងចូលទៅប្រថាប់នៅក្នុងបាតុកម្មួយ ដែលវិចិត្រដោយទង់ជាតិ ទង់សាសនានឹងស្លឹកក្រុងជាតិជាគ្រឿងលំអ ។

ក្នុងពេលនោះ ឯកឧត្តម សម-ញាណ រដ្ឋមន្ត្រីក្រសួងធម្មការ សិល្បការ នឹងសង្ឃសិក្សាធិការ បានសំដែងនូវមនោភាពដ៏សម្បយុត្តដោយសោមនស្សចេតនា នឹងបីតិប្រាមោជដ៏ក្រៃលែង ចំពោះព្រះករុណាជាអម្ចាស់ដ៏វិតលើត្បូង, ចំពោះសម្តេច, លោកហ្គត់កុម្មីស្សែរ, ឯកឧត្តមនាយករដ្ឋមន្ត្រីនឹងរដ្ឋមន្ត្រីទាំងឡាយ ព្រមទាំងទង់ នឹងឯកឧត្តមជាអង្គទូត ដែលបានស្តេចយាង-និមន្ត-អញ្ជើញមកជួបជុំជាមហាសន្និបាតកងពិធីបុណ្យនេះ ដែលទុកជាកិត្តិយសមួយដ៏ប្រសើរ នឹងជាមង្គលសួស្តីមួយដ៏ឧត្តម សមដល់កិច្ចការដែលទាក់ទងនឹងព្រះពុទ្ធសាសនាជាទីគោរពរបស់ប្រជាជនក្នុងប្រទេស ។ ហើយឯកឧត្តមសូមព្រះពរជាន់ខ្ពស់បន្តិច ដើម្បីថ្លែងសុន្ទរកថា រៀបរាប់នូវមូលហេតុនៃការកសាងមហាវិទ្យាល័យនេះដោយសង្ខេប ដូចតទៅនេះ ៖

ការសិក្សាខាងព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជានេះ បានកើតឡើងតាំងពីឆ្នាំ ១៩១៤ ចំនួន ៤០ ឆ្នាំមកហើយ គឺសាលាបាលីជាន់ខ្ពស់នេះឯង ជាសាលាតែមួយ បីតនៅក្នុងសេចក្តីឧបត្ថម្ភរបស់ព្រះពរជ្រាតិចាល ។ ឯសាលាចាស់វិញបានកើតមានឡើងតាំងពីឆ្នាំ ១៩៣៣ បីតនៅក្នុងសេចក្តីឧបត្ថម្ភរបស់លោកចៅអធិការវត្ត ព្រមទាំងពុទ្ធបរិស័ទ

ដើងវត្ត ពាជការគ្រាន់តែទទួលស្គាល់ហើយនឹងជួយចាត់ការឲ្យមានរបៀប
រៀនសូត្រ នឹងការប្រឡងចេញពីសាលាប៉ុណ្ណោះ ។ សាលាចាលីវង
នោះ កើតឡើង ២១ ឆ្នាំហើយមានចំនួន ៣៩១ ពាងក្នុងក្រុងនឹងខេត្ត
ក្រៅ បពូជិតដែលសិក្សាក្នុងសាលាចាលីវង ចានគ្រប់ ៣ ឆ្នាំ ត្រូវ
ប្រឡងចេញចានទទួលវិញ្ញាបនប័ត្រ ១ ជាសំគាល់ ហើយមានអំណាច
ប្រឡងចូលរៀន ក្នុងសាលាចាលីជាន់ខ្ពស់ចាន សព្វថ្ងៃនេះមានកាន់តែ
ច្រើនឡើង។ ដូចក្នុងឆ្នាំ ១៩៥៣ នឹង ១៩៥៤ នេះ ឃើញមានបពូជិត
ដល់ទៅ ២.០០០ រូប មកប្រឡងដណ្តើមយកកន្លែងរៀនក្នុងសាលាចាលី
ជាន់ខ្ពស់ ដែលមានតែ ១០០ កន្លែង ឃើញត្រូវនៅសល់ ១ ៩០០ រូប ។

សាលាចាលីជាន់ខ្ពស់សព្វថ្ងៃនេះ ពុំអាចនឹងចាត់ការឲ្យចំរើនជាង
នេះទៅទៀតចានទេ ព្រោះខ្វះទីកន្លែងរៀន ខ្វះគ្រូបង្រៀន ។ ម្យ៉ាង
ទៀត សិស្សដែលចានទទួលសញ្ញាប័ត្រពីសាលានេះហើយ ឥតមាន
មហាវិទ្យាល័យបន្តចំណេះវិជ្ជាជាន់ខ្ពស់ទៅទៀត ម្ល៉ោះហើយឃើញថា
ពួកបពូជិតក្នុងប្រទេសក៏បិតនៅក្នុងហាន: ជាអ្នកមានចំណេះពុំចាន់គ្រប់
គ្រាន់ គឺថាពួកបពូជិតជានិស្សិតចាំងនេះ មានចំណេះវិជ្ជា គ្រាន់តែអាច
បំពេញកិច្ចការខាងព្រះពុទ្ធសាសនា សម្រាប់ប្រទេសរបស់ខ្លួនប៉ុណ្ណោះ
មិនអាចនឹងផ្សាយព្រះពុទ្ធសាសនា ពីប្រទេសរបស់ខ្លួនទៅនានាប្រទេស
ចានឡើយ ចាំងពុំអាចនឹងទៅបំពេញមុខការ ប្រសើយខាងផ្លូវសាសនា

ជាមួយនឹងពុទ្ធសាសនិកជន ក្នុងនានាប្រទេសបានទៀត ដោយហេតុមកពីពុំបានចេះភាសាបរទេសឲ្យល្មមគ្រប់គ្រាន់ ។ ការខ្វះខាតយ៉ាងនេះនាំឲ្យពួកបព្វជិតជានិស្សិត ខ្វះសេចក្តីអង់អាចខ្វះគំនិតដែលត្រូវគិតធ្វើឲ្យព្រះពុទ្ធសាសនាបានចំរើនប្លែកពីធម្មតា ហើយថែមទាំងខ្វះយោបល់ដ៏ថ្លៃថ្លាផងទៀត ។

អាស្រ័យហេតុដូចខាងលើនេះហើយ ទើបព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាអគ្គសាសនូបត្ថម្ភក៍ ទ្រង់សព្វព្រះពជ្ឈទ័យនឹងពង្រីកការសិក្សាខាងព្រះពុទ្ធសាសនា ឲ្យបានធំទូលាយឡើង ឲ្យសមតាមកាលៈទេសៈ នៃប្រទេសឯកពជ្ឈ ទើបទ្រង់មានព្រះពជបញ្ជាមកក្រសួងធម្មការ ឲ្យពិនិត្យមើលហើយចាត់ការរៀបចំពង្រីកការសិក្សាឲ្យបានចំរើនឡើង ។

ក្រសួងធម្មការ បានទទួលព្រះបរមពជនុដ្ឋារ ហើយចាត់ការតាំងគណៈកម្មការមួយក្រុមនឹងអនុគណៈកម្មការ ១ ក្រុម ដើម្បីរៀបចំរបៀបបង្រៀនក្នុងសាលាបាលីជាន់ខ្ពស់ ព្រមទាំងរៀបចំបង្កើតឲ្យមានការសិក្សាថ្នាក់ខ្ពស់ឡើងទៀត គឺបង្កើតឲ្យមានមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ហៅថា "ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុពជ" ។

ក្នុងកិច្ចពង្រីកការសិក្សានេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងទ្រង់បានសម្រេចឲ្យយកទីដីនេះ គឺដីដែលមានគោលសុីមាត់ព័ទ្ធជុំវិញ

នេះហើយ ដែលទុកជាមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ។ ហើយ ទ្រង់បានបរិច្ចាគព្រះពរជទ្រព្យផ្ទាល់ព្រះអង្គ ១ សែនរៀលសម្រាប់កសាង ព្រមទាំងស្តេចយាងមកជាព្រះរាជាធិបតីភាព ក្នុងពិធីបុណ្យបញ្ចុះបឋម-សិលា នាថ្ងៃសុក្រមង្គលនេះ ទុកជាព្រះមហាករុណាគុណយ៉ាងប្រសើរបំផុត ។

ការរៀបចំបង្កើតមហាវិទ្យាល័យនេះ មានគហបតី ១ នាក់ឈ្មោះ បេ-យាន ជាអ្នកជំនួញ កើតសេចក្តីជ្រះថ្លាមុនគេ បានទទួលកសាង គ្រឹះស្ថានមួយខ្នងពីឥដ្ឋស៊ីម៉ងត៍ មានបណ្តោយ ២៤ ម៉ែត្រ ទទឹង ១២ ម៉ែត្រ, ត្រង់កន្ទែងជាផ្ទះស្នងចាស់ នៅជ្រុងវិថីកញ្ញាឈុនទឹងតារវិថី-ស៊ីសុវត្ថិ ជាខាងជើងសាលាចាលីជាន់ខ្ពស់ ទីដីនេះមានបណ្តោយ ៨០ ម៉ែត្រទឹងទទឹង ៦០ ម៉ែត្រ ជាព្រះពរជអំណោយនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។

លុះចប់សុន្ទរកថានេះ ព្រះកូមិន្ទទ្រង់ស្តេចយាងទៅប្រតិស្ឋានស៊ី-ម៉ងត៍លាយដោយដីឥដ្ឋចំដណ្តប់លើតានថ្មាក់ ដែលមានគហបតីបេ យាន ព្រមទាំងបុត្រាបុត្រីនិងក្រុមញាតិទទួលគោរពថ្វាយ ។ ព្រះមហាក្សត្រីយ៍ ទ្រង់យកព្រះហស្តចាប់ស្ទាបព្រាបូកវត្ថុធាតុនេះដាក់ទៅក្នុងរណ្តៅ ស្រេច ហើយទើបរំកិលបឋមសិលាបញ្ចុះពីលើ ព្រមទាំងទ្រង់ច្រាសព្រះពរជ ពានសុគន្ធរាលើបឋមសិលានេះផង ។

ក្នុងពេលដែលព្រះមហាក្សត្រិយ៍ កំពុងប្រគំស្នានបឋមសិលាជា
និមិត្តរូបនេះ ព្រះសង្ឃបានស្វាធ្យាយគឺសូត្រជយន្តោប្រសិទ្ធិជោគជ័យជា
មួយនឹងព្រះពរជាច្រើនយ៉ាងកិច្ចផង, បន្ទាប់ពីព្រះមហាក្សត្រិយ៍មក សម្តេច
ព្រះសង្ឃនាយកចាំងពីរគណៈ នឹងសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សា
សមាជិករដ្ឋាភិបាលព្រះពរជប្រគំកូរ៉ាល់ព្រះអង្គ, ប្រធានក្រុមប្រឹក្សាជាតិ,
លោកហ្គក់កុមីស្សារីនឹងអគ្គទូត បានគ្រោះទឹកលើបឋមសិលានេះ តមក
ទៀត ជាកិច្ចឧប្បត្តិកបង្កបង្កើតមហាវិទ្យាល័យនេះឡើងជាក់នាមថា
ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហគ្គរាជ ដើម្បីពង្រីកកិច្ចសិក្សា ខាង
ព្រះពុទ្ធសាសនា ឲ្យបានវិតែត្តង់ត្តស់ សំរាប់សិក្ខាកាមកុលបុត្រ ។

ខាងពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីសង្ឃឹមរួកជាមុនថា. គង់នៅ
មានពុទ្ធបរិស័ទ ដែលមានសទ្ធាជ្រះថ្លា ដូចគហបតិបៈ យាននេះ
ច្រើនទៀត អាចយល់ប្រយោជន៍ដល់ជាតិ, សាសនា, មហាក្សត្រិយ៍
ដួយស្រោចស្រង់មាតុភូមិឲ្យបានថ្កុំថ្កើង ក្នុងពេលដែលទើបនឹងបាន
ឯករាជ្យថ្មីៗនេះ ។

ពិធីបុណ្យបញ្ចុះបឋមសិលានេះ បានបញ្ចប់នៅម៉ោង ៩ នឹង ៣០
នាទី ក្រោយពេលដែលព្រះមហាក្សត្រិយ៍ ស្តេចយាងត្រឡប់ទៅគាន់
ព្រះបរមរាជវាំងវិញ ។

ពុទ្ធសាសនបណ្ឌិត្យ ។

# តម្លៃសទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណាំងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ២៦ ខែកញ្ញា លេខ ៩

ព.ស. ២៤៩៧ – គ.ស. ១៩៥៤



# អត្ថសន្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — វិធីអប់រំចិត្ត ..... | លោក ស៊ុន- ហ៊ាន ..... | ៦៤៣ |
| — ពុទ្ធបរិស័ទគឺអ្នកណា ..... | ឃុនបណ្ឌានុរ័ក្ស ប៊ូ- ប៊ូ .... | ៦៥៦ |
| — បញ្ញាសជាតក ភាគទី ២ (តមក) . ... | បណ្ឌិតមហា ឈឹម- ស៊ុម .... | ៦៦៥ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — រឿងសៅរ៍សោយ (តមក) ..... | ព្រះមហាឧត្តមវិជ្ជា ប៉ឹង- ប៊ម .. | ៦៧៧ |
| — រឿងសាមកុក (តមក) ..... | ឧកញ៉ា ន្ហូ- ពន ..... | ៦៨៤ |
| — ឥសិនទឹងទមយន្តី (តមក) ..... | អ្នកស្រី ស្រ៊ុន - សារីយ៉ាន់ .... | ៦៩៦ |
| — ដំណឹងតាមខ្សល់ក្នុងពន្ធារៈ (តមក) .... | លោក ផេង - ជ្រឿ ..... | ៧០៤ |
| **កំណាត់ទឹងប្រវត្តិការណ៍** | | |
| — ពិធីឈាបនកិច្ចសព អ៊ុយ- ម៉ាង ..... | ឧកញ៉ា មួង- ឃួន ..... | ៧១២ |



មួយឆ្នាំមាន ៤២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Le perfectionnement moral. . | M. SIN-HEAN . . . . . | 643 |
| — Les Bouddhistes . . . . . | M. BOU-PO . . . . . | 656 |
| — Pannasajataka vol-II (suite) . | M. CHHIM-SOUM . . . . . | 665 |


PARTIE LITTERAIRE:


| | | |
|---|---|---|
| — Le « SAU-SOY » ou l'influence saturnienne (suite) . . . . . | Vén. PEUNG-PAM . . . . . | 677 |
| — Histoire de Samkok (suite) . . | Oknha NOU-KAN . . . . . | 684 |
| — Nala et Damayanti (suite) . . . | Mme SRIN-SARIS-YANN . . . | 696 |
| — Le souffle du désert (suite) . | M. PHENG-CHRIV . . . . . | 704 |


NOTES ET CHRONIQUES:


| | | |
|---|---|---|
| — L'incinération du Vén. Brah Amarabhirakkhita UY-PANG . | M. MUONG-KHUON . . . . . | 712 |


Prix d'abonnement annuel (comprenant 12 numéros) 200$00

# សុីន-ហាវ សៀនដៅពុទ្ធសាសនបណ្ឌិត្យ

## រៀបរៀង

---

### ១ — ចិត្តគឺអ្វី?

ចិត្តគឺជាធម្មជាតគ្មានរូបដែលជាស្តេចគ្រប់គ្រងនគរកាយ ។ ចិត្តនេះគេមិនអាចមើលឃើញដោយមំសចក្ខុបានទេ ព្រោះជាទាមធម៌, តាមពិត អ្នកដែលមិនដឹងចិត្តថាគឺអ្វី តែងមិនឃើញចិត្តទេ, តែកាលបើដឹងថាចិត្តគឺអ្វី តែងឃើញចិត្តបានតាមកម្លាំងនៃសេចក្តីដឹងនោះ ។

គេច្រើនចូលចិត្តថា វិញ្ញាណ, មនោ, ចិត្ត ទាំង ៣ នេះដូចគ្នា, ព្រោះហេតុនោះ គេទើបកំណត់វិញ្ញាណជាចិត្ត ចិត្តជាវិញ្ញាណខ្លះ, មនោជាចិត្ត ចិត្តជាមនោខ្លះ, ច្រឡូកច្រឡំគ្នាអស់ទៅ ទាំងនេះឯងព្រោះតែមិនស្គាល់ចិត្តថាជាអ្វី ។ ដែលពិតនោះ វិញ្ញាណ, មនោ, ចិត្តនេះមានមុខការផ្សេងៗ គ្នា តែជាប់ទាក់ទងគ្នា ។

វិញ្ញាណគឺការដឹងច្បាស់ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ហើយវិញ្ញាណនេះជាផ្លូវដែលជាប់តដល់ចិត្ត ហេតុនោះ វិញ្ញាណខុកដូចជាអ្នកបញ្ជូន, មនោខុកដូចជាអ្នកទទួល, ចិត្តខុកដូចជាអ្នកដឹង ។ ចិត្តដែលមានស្រឡាញ់មានស្អប់ជាដើម ព្រោះមានគ្រឿងផ្សំគឺអារម្មណ៍

ហើយនឹងគ្រឿងទទួលគឺកិលេស ។ អារម្មណ៍នឹងកិលេសផ្សំគ្នាកាលណា កំធ្វើចិត្តឲ្យវិបរិត ដូចវិឡុកចាយសម្ងួត ត្រូវមានគ្រឿងបញ្ចូនទឹងគ្រឿងទទួលសម្ងួតទើបច្រាកជាបាន ពុំនោះទេដូចអគ្គិសនីដែលឲ្យកើតប្រយោជន៍ជាច្រើន មានឲ្យកើតពន្លឺជាដើម កំព្រោះមានគ្រឿងផ្សំព្រមតាំងខ្សែ ប្រជាប់បើកបិទ នឹងអំពូលដូចម្តេចមិញ, វិញ្ញាណ, មនោ ចិត្ត ក៏មានមុខការជាប់ទាក់ទងគ្នាដូច្នោះដែរ ។ ចិត្តដែលមានអារម្មណ៍ចូលមកផ្សំព្រោះអំណាចកិលេស ដែលមានឫសគល់មកអំពី ភគៈ ឬ លោភៈ ទោសៈ មោហៈ ទើបមានសេចក្តីស្រឡាញ់សេចក្តីស្អប់; ចិត្តដូច្នេះ នៅក្រោមអំណាចកិលេស ។ សេចក្តីជាប់ចំពាក់តាំងឡាយក្នុងលោក ដែលកើតឡើងហើយកងអតីតក្តី ក្នុងបច្ចុប្បន្នក្តី កងអនាគតក្តី តែងកើតមានឡើង ព្រោះចិត្តនៅក្រោមអំណាចកិលេសជាមូលហេតុ ។ កាលណាចិត្តមិនមានគ្រឿងផ្សំគឺអារម្មណ៍ នឹងគ្រឿងទទួលគឺកិលេសទេ កាលនោះចិត្តក៏មានអំណាចលើកិលេស គឺនៅកងលោក សូម្បីលោកនឹងជាប់ចំពាក់ដូចម្តេច ក៏មិនអាចធ្វើឲ្យចិត្តញាប់ញ័របាន ។ ព្រោះហេតុនោះ កងផ្លូវព្រះពុទ្ធសាសនាទើបលើកការអប់រំចិត្តថាជាកិច្ចសំខាន់បំផុត ។ រឿង"វត្ថុនឹង វត្ថុស្ថានតាំងឡាយដែលច្រាកដនៅកងលោក សុទ្ធតែជាអាការសំដែងចេញរបស់ចិត្តតាំងអស់ ។ វត្ថុគ្រប់យ៉ាងទើបធ្លាក់កងអំណាចរបស់ចិត្ត មានតែចិត្តប៉ុណ្ណោះទេដែល

អាចធ្វើលោកឲ្យញាប់ញ័រ ឬធ្វើលោកឲ្យស្ងប់បាន ព្រោះហេតុដូច្នោះ ទើបគួរអប់រំចិត្ត ។

## ២— លក្ខណៈរបស់ចិត្ត

ចិត្តជាធម្មជាតវិចិត្រវិក្រែពេក ដោយសារអារម្មណ៍ចូលមកផ្សំដូចព័ណ៌ផ្សែងសំពត់ កាលបើព័ណ៌ផ្សែងណាផ្សែងសំពត់ សម្បីសំពត់នោះមានព័ណ៌ស ក៏ត្រូវផ្លាស់ទៅតាមព័ណ៌ផ្សែងសំពត់នោះ សំពត់ទើបមានព័ណ៌ផ្សេងៗ ដូចម្តេចមិញ ចិត្តក៏ដូច្នោះដែរ ។ មនុស្សម្នាក់ៗមានចិត្តតែ ១ ដួងទេ តែដែលមានច្រើនដួង ព្រោះអារម្មណ៍នោះឯងចូលមកលាយ, គឺកាលចិត្តប្រកាន់អារម្មណ៍ណាក៏ប្រែទៅតាមអារម្មណ៍នោះ, អាការដែលសំដែងចេញក៏រមែងប្រព្រឹត្តទៅតាមអារម្មណ៍នោះ ។

លោកពោលថា ចិត្តនេះជាធម្មជាតបម្រែបម្រួលខ្លឹល អន្ទះអន្ទែងរក្សាបានដោយកម្រ ហាមឃាត់បានដោយកម្រ ត្រាច់ទៅក្នុងមួយត្រាច់ទៅតែ ១ ដួង មានកាយជាទីអាស្រ័យ ហេតុនេះ ការកំណត់ដឹងលក្ខណៈរបស់ចិត្ត ក៏គួរនឹងកំណត់ដឹងដោយទំយន់នេះ ។

តាមប្រក្រតី ចិត្តនេះកាលបើត្រូវព្រាត់ប្រាសចាកអារម្មណ៍ដែលធ្លាប់សេពគប់មកហើយ ក៏សំដែងអាការបម្រែបម្រួលខ្លឹល ដូចត្រីដែលគេលើកចេញពីទឹកចោះទៅលើគោក, ជាធម្មជាតអន្ទះអន្ទែង ដោយសំដែងអាការឲ្យប្រាកដដូចពាន្យក្នុងព្រៃ ឬដូចធន់ដែលនៅលើសសរ

កាលខ្យល់បក់ក៏ត្រឡប់ទៅត្រឡប់មក, ជាធម្មជាតរក្សាបានដោយកម្រ គេក៏ដឹងបានដោយអាការដែលសំដែងចេញ ដូចគោដែលនៅជិតស្រែមានសំពួង គេកម្រនឹងរក្សាកុំឲ្យស៊ីសំពួងក្នុងស្រែនោះបាន, ជាធម្មជាតហាមឃាត់បានដោយកម្រ ដោយមានអាការដូចក្មេងដែលកំពុងរពឹសកម្រនឹងហាមឃាត់មិនឲ្យរពឹសបាន, ត្រាច់ទៅក្នុងទីធ្លាយចំពោះតែ ๑ ដួងគឺត្រាច់ស្វែងរកអារម្មណ៍ ឬរឿងរ៉ាវដែលធ្លាប់ដឹងធ្លាប់ឃើញមិនឈប់ឈរ ស្គាលទីណាដែលធ្លាប់ទៅហើយ សូម្បីត្រឡប់មកឃ្យូរ ក៏ត្រាច់ទៅក្នុងស្ថានទីនោះបាន កាយនៅទីនេះទេតែចិត្តអាចត្រាច់ទៅពេញលោក បើនឹកបន្តិចផ្លូវដែលចិត្តត្រាច់ទៅមួយថ្ងៃ។ ក៏ហួសប្រមាណដែលនឹកឮបាន ចំពោះកាយត្រាច់ទៅមិនបានត្រឹមណា ព្រោះត្រូវហត់នឿយ តែចិត្តមិនមែនដូចកាយទេ ទីណាកាយត្រាច់ទៅមិនបាន ចិត្តត្រាច់ទៅបាន សូម្បីមានគ្រឿងកំចាំងក៏លេចរួចទៅបាន ទីដែលគេហាមក៏បំពានចូលទៅ ព្រោះហេតុអ្វី? ព្រោះអារម្មណ៍ដែលចូលមកផ្សំចិត្តមានច្រើនយ៉ាង ចិត្តប្រកាន់អារម្មណ៍នេះហើយ បណ្តាយទៅប្រកាន់អារម្មណ៍ឯណោះទៀត រំលងរំលើមករកទីបំផុតគ្មាន ទើបឈ្មោះថាត្រាច់ទៅក្នុងទីធ្លាយ ហើយត្រាច់ទៅតែ ๑ ដួង ។

កាយយើងនេះ បើមិនមានចិត្ត ក៏មានអាការដូចគាយយន្តដែលខ្វះមនុស្សគ្រាញ កាលបើមានចិត្តចូលមែបអាស្រ័យ ក៏មានអាការដូច

កាយន្តដែលមានមនុស្សភ្ញាក់, កាយន្តនឹងសំដែងអាការលោតកំ
ផ្លាស់ប្តូរទៅយ៉ាងណា គឺភ្ញាក់មនុស្សដែរ, កាយសំដែងអាការឲ្យ
ក្រោធយ៉ាងណាបានក៏ព្រោះចិត្តជាអ្នកបង្គាប់ការ ឬនឹងប្រៀបកាយដូច
ផ្ទះ ចិត្តដូចអ្នកនៅអាស្រ័យ ផ្ទះនោះបើម្ចាស់អ្នកនៅអាស្រ័យជាមនុស្ស
មានកិរិយាមារយាទល្អ ក៏ជាផ្ទះល្អ មានគ្រឿងប្រដាប់វិចិត្រល្អ តាម
កម្ចាត់របស់ម្ចាស់ផ្ទះ ជាទីគួរមើលគួរសើរជាបសាទនីយស្ថាន ឲ្យ
កើតសេចក្តីជ្រះថ្លាដល់អ្នកបានឃើញ ដូចព្រះសុគន្ធកុដី ទីគង់នៅរបស់
ព្រះពុទ្ធ ឬក្រាសាទពាជរាំងរបស់ព្រះមហាក្សត្រជាដើម តែបើម្ចាស់ផ្ទះ
នោះជាមនុស្សមិនល្អ គឺជាពាលជន ដូចចោរជាដើម ផ្ទះនោះក៏
ត្រូវប៉ះពាល់ទៅជាទីគួរខ្ពាច មិនគួរឲ្យចូលជិតបាន ។នេះមានឧបមា
ដូចម្តេច កាយនឹងចិត្តក៏ដូច្នោះដែរ ។ កាលចិត្តបានទទួលការអប់រំកន្លង
ផ្លូវល្អដែលជាប្រយោជន៍ហើយ អាការដែលសំដែងចេញមកតាមផ្លូវ
កាយផ្លូវវាចាក៏ល្អ តែបើចិត្តខ្វះការអប់រំ ឬ បានអប់រំកន្លងផ្លូវមិនជាល្អ
ដែលគ្រាសចាកប្រយោជន៍ គ្រាសចាកធម៌ អាការដែលសំដែងចេញ
មកតាមផ្លូវកាយផ្លូវវាចាក៏មិនល្អ ដោយន័យនេះទើបអាចឃើញបានថា
ចិត្តសំខាន់ជាងកាយ ព្រោះហេតុនោះយើងគួរអប់រំចិត្តតាមសមត្ថភាព
នឹងឧកាស មិនគួរបណ្តោយចិត្តឲ្យធ្លាក់ទៅក្នុងអំណាចកិលេស គួរតាម
រក្សាហាមគ្រាមការពារកុំឲ្យប្រព្រឹត្តទៅដូច្នោះ, ពេលគួរអត់សង្កត់

កំបូរអត់សង្កត់ ពេលគួរបង្ក្រាប់កំបូរបង្ក្រាប់កុំបណ្តោយឲ្យចិត្តទៅតាមអំណាចតិលេស ដែលជាហេតុនាំទុក្ខទោសមកឲ្យ, ពេលគួរសួយលើកដំកើង កំបូរសួយលើកដំកើងឲ្យក្លាហានឲ្យត្រេកអរវីកពាយ កុំធ្វើចិត្តឲ្យរួញរាដៅកង់ក់, ពេលគួរសម្ងឹងពិនិត្យ កំបូរសម្ងឹងពិនិត្យចុះ ។

សាធុជនទាំងឡាយ ដែលប្រាកដថាជាអ្នកមានកិត្តិស័ព្ទល្អ មានសុខចំរើនរុងរឿងមិនសាបសូន្យ គឺព្រោះបានអប់រំចិត្តរបស់ខ្លួនតាមសមគួរ, ផ្សេងគ្នាខ្លះ តែការអប់រំតិច អប់រំច្រើន អប់រំក្នុងផ្លូវលោក ឬអប់រំក្នុងផ្លូវធម៌ប៉ុណ្ណោះ ។ ចំណែកផលដែលកើតមកអំពីការអប់រំនោះ ក៏ប្រាកដជាអំណាយផលឲ្យតាមកម្ទាំងនៃការអប់រំ. កាលអប់រំកង់ផ្លូវណាត្រឹមណា ក៏រំមែងបានផលកង់ផ្លូវនោះត្រឹមនោះ មិនប្រាសចាកផលឡើយ ។

## ๓ — វិធីអប់រំបិត្ត

កង់ខាងដើមនៃការអប់រំចិត្តនេះ ត្រូវស្គាល់ចិត្តត្រឹមទាំងស្គាល់លក្ខណៈ នឹងអាការរបស់ចិត្ត សម្រាប់ត្រួតត្រាពិចារណា ដូចមានកញ្ចក់សម្រាប់ទុះមើលស្រមោលមុខ ព្រោះធម្មតាការអប់រំត្រូវយ៉ាងត្រូវមានគ្រឿងសម្រាប់ប្រើកង់ការនោះ ត្រឹមទាំងសេចក្តីសំគាល់នៃការអប់រំ, សូម្បីការអប់រំចិត្តក៏ដូច្នោះដែរ គឺត្រូវរៀនឲ្យដឹងរឿងចិត្តល្មមជាគោលការនឹងសេចក្តីសំគាល់នៃការអប់រំចិត្តជាមុន ដើម្បីធ្វើចិត្តឲ្យជាធម្មជាតគួរ

ដល់ការងារដ៏ប្រពៃ ទាំងផ្លូវលោក ទាំងផ្លូវធម៌ ឲ្យទាល់តែចិត្តស្ងប់ចាក
អកុសលធម៌ទាំងឡាយ មានការដឹងហេតុផលជាក់ច្បាស់តាមសេចក្តីពិត,
ចំណែកផលដែលយើងធ្វើថ្នាយ៉ាងក្រៃលែង ក៏គឺឲ្យជាចិត្តពេញបរិបូណ៌
ដោយសេចក្តីសុខមែនៗ មិនមានអ្វីលាយឡំ ។ ការអប់រំចិត្តនេះមិន
មែនគ្រាន់តែទំនុកបំរុងដល់ការងារផ្លូវធម៌ប៉ុណ្ណោះទេ ដែលពិតនោះគឺទំនុក
បំរុងដល់ការងារចំណែកគតិលោកផង ព្រោះការងារដ៏ប្រពៃទាំងឡាយ
ដែលឲ្យសម្រេចប្រយោជន៍ទាំងខ្លួនឯង ទាំងពួកគណៈប្រទេសជាតិ សុទ្ធ
តែមានធម៌ដ៏ប្រពៃលាយឡំទាំងអស់ សូម្បីការអប់រំចិត្តកង់ទីនេះ ក៏គឺ
អប់រំចិត្តឲ្យមានធម៌ដ៏ប្រពៃ ដោយលះបង់ធម៌ចំណែកអកុសលដែលមាន
ទុក្ខជាផលនោះចេញ ហើយអប់រំបំពេញធម៌ចំណែកកុសលដែលមាន
ផលជាសុខឲ្យកើតមានឡើង ក្នុងចិត្តរបស់ខ្លួន ។

គ្រឿងឧបករណ៍ក្នុងការនេះ ក៏មិនត្រូវមានដើមទុនអ្វីប៉ុន្មានទេ
គ្រាន់តែព្យាយាមឲ្យមានសតិគ្រប់គ្រងចិត្តកំណត់ពិចារ-
ណាត្រួតត្រាសង្កេតមើលក្នុងការដែលធ្វើ ពាក្យដែលនិយាយ រឿង
ដែលគិតឲ្យដឹងថាជាសុចរិត ឬទុច្ចរិត; កាលនឹងធ្វើអ្វី និយាយអ្វី គិតអ្វី
គួរពិចារណាមើលថា បើយើងនឹងធ្វើយ៉ាងនេះ គិតយ៉ាងនេះទៅ តើជា
សុចរិត ឬទុច្ចរិត, កាលដឹងថាជាសុចរិត គប្បីធ្វើ, គប្បីនិយាយ, គប្បីគិត,
កាលដឹងថាជាទុច្ចរិត ក៏កុំធ្វើ កុំនិយាយ កុំគិត; សូម្បីធ្វើហ៊ាយ

និយាយហើយគិតហើយ កំតប្បីពិចារណាដូច្នោះទៀត កាលដឹងថាជាសុចរិត កំតប្បីនៅដោយចិត្តជ្រះថ្លាមោទនាត្រេកអរ សិក្សាប្រតិបត្តិកុសលធម៌ទាំងយប់ទាំងថ្ងៃចុះ កាលដឹងថាជាទុច្ចរិត កំតប្បីសំដែងទោសដែលធ្វើល្មើសនោះចេញ ហើយតាំងចិត្តសង្រួមប្រយ័ត្នតទៅ កុំធ្វើថែមទៀត នេះឯងជាកិច្ចខាងដើមនៃការអប់រំចិត្ត ។

កាលបើការធ្វើ ការនិយាយ នឹងការគិតជាសុចរិតហើយ បើមានបំណងនឹងព្យាយាមបំពេញតទៅ កំគួរអប់រំចិត្តរបស់ខ្លួនឲ្យតាំងនៅក្នុងសេចក្តីសប្បុរស, អ្វីជាសត្រូវចំពោះសេចក្តីសប្បុរចិត្ត គួរព្យាយាមបង្ក្រាបលះវៀរចេញ ហើយអប់រំបំពេញធម៌ដែលកឲ្យកើតសេចក្តីសប្បុរចិត្តនោះឲ្យមានឡើង ត្រាអត់ធន់ធ្វើចិត្តរបស់ខ្លួនឲ្យធូរធ្ងន់ធ្ងរ នឹងនូនតែកងធម៌ជាចំណែកកុសល ។ នីវរណៈធម៌ គ្រឿងកំងរមិនឲ្យចិត្តបានដល់សេចក្តីសប្បុរ គឺកាមច្ឆន្ទៈ ព្យាបាទៈ ថីនមិទ្ធៈ ឧទ្ធច្ចកុក្កុច្ច វិចិកិច្ឆា ទាំង ៥ នេះជាសត្រូវដោយត្រង់ចំពោះសេចក្តីសប្បុរចិត្ត គួរពិចារណាមើលថា នីវរណៈនោះមានទោសយ៉ាងណា, កាលបើពិចារណាឃើញទោសហើយកំគួរលះចេញ សូម្បីលះមិនជាប់ស្រឡះទេ ក៏ឈ្មោះថាល្អជាងការបណ្តោយទៅតាមអំណាចនីវរណៈដែរ, កាលបើនីវរណៈកើតឡើងគ្របសង្កត់ចិត្ត កំគួរពិចារណាមើលឲ្យដឹងថានេះជានីវរណៈ ដែលកឲ្យកើតសេចក្តីពេញចិត្តស្រឡាញ់ជ្រះថ្លាជាប់ជំពាក់ទៅក្នុងរូប សំឡេង ក្លិន រស សម្ផស្ស

ដែលគួរជ្រាបថ្នាំខ្លះ, កឲ្យកើតអាយាត បំផ្លាញប្រទូសរ៉ាយគេខ្លះ, កឲ្យកើតសេចក្តីរួញរយ នឹងឆន្ទៈដោកឆ៍ក់ខ្លះ, កឲ្យកើតសេចក្តីរាយមាយនឹងរសាប់រសល់ខ្លះ, កឲ្យកើតសេចក្តីសង្ស័យមិនជាប់ស្រេចខ្លះ ទាំងនេះឯងសុទ្ធតែជាសត្រូវចំពោះសេចក្តីស្ងប់ចិត្តទាំងអស់ ។ កាលបើដូច្នេះហើយ គួរធ្វើទុកក្នុងចិត្តដោយៗថាយដែលត្រូវ គឺឲ្យឃើញថាអារម្មណ៍ទាំងឡាយមានរូបសម្ងើជាដើមនោះ ដែលគួរស្រឡាញ់ គួរជ្រាបថ្នាជទ្វេញជន្ទូចិត្ត ក៏ព្រោះចូលចិត្តថាស្រស់បស់ល្អ ដែលជាសេចក្តីចូលចិត្តខុស គួរគិតឲ្យឃើញថាមិនស្រស់បស់មិនល្អទេ តែដែលឃើញថាស្រស់បស់ថាល្អទៅវិញ ក៏ព្រោះការគាក់តែងបរិហារកាយដែលជាចំណែករូបប៉ុណ្ណោះ. បើខ្លះការគាក់តែងជាដើមហើយ ការមិនស្រស់បស់ល្អអាចកើតជ្រាកជង្រឹង ។ កាលៗស្បាហ៍ពិចារណាកំណត់យ៉ាងនេះហើយ ចិត្តក៏នឹងឃ្លាតចាកកាមច្ឆន្ទៈនោះបានតាមសមគួរព្រោះហេតុនោះ កាលបើនឹងមើលនឹងស្តាប់ជាដើម ទើបគួរជាអ្នកចេះមើលចេះស្តាប់ តទៅនឹងបានប្រយោជន៍មកពីការមើលការស្តាប់នោះពុំខាន ។ សូម្បីនីវរណៈដទៃ ។ កើតឡើងក៏គួរពិចារណាដោយៗថាយនេះដែរ កាលតែចិត្តជល់ខ្ជាប់នូវសេចក្តីស្ងប់ពិតជ្រាកជង្រឹង មានអាការស្រដៀងនឹងវង់ភ្លើងដែលនៅកងអំពូល, កាលបើអប់រំចិត្តបានយ៉ាងនេះហើយ ឈ្មោះថាជាអ្នកមានចិត្តនៅលើអំណាចនីវរណៈជាថ្នាក់ទី ២ នៃការអប់

រំចិត្ត, តពីនេះទៅត្រូវពិចារណាជ្រាវជ្រាវសេចក្តីកើតរលត់នៃសង្ខារ ព្រោះចេញឲ្យឃើញជាភាគជាចំណែកដោយគួរដល់ពាក្យថា ទុក្ខ ជាតុ អាយតនៈ ព្រមទាំងហេតុបច្ច័យ ដរាបដល់លះសេចក្តីប្រកាន់ដោយអំណាចតណ្ហាមានៈទិដ្ឋិថា "នុ៎ះរបស់អាត្មាអញ នុ៎ះជារូបរបស់អាត្មាអញ," ដែលជាមគ្គឲ្យដល់នូវសេចក្តីបរិសុទ្ធហ្មត់ចត់ផុតចាកទុក្ខទាំងពួង; នេះឯងជាកំពូលនៃការអប់រំចិត្ត ។

## ៤ — ផលនៃការអប់រំចិត្ត

ចិត្តនេះ កាលបើគេបានអប់រំល្អហើយ ធ្វើឲ្យស្ងប់បរិសុទ្ធហ្មត់ចត់ហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ធំសេចក្តីចំរើនយ៉ាងក្រៃលែង អាចនាំសេចក្តីសុខមកឲ្យជានិច្ច ។ សេចក្តីសុខដែលកើតមកអំពីការអប់រំចិត្តឲ្យស្ងប់ធំបរិសុទ្ធនេះ ជាសេចក្តីសុខយ៉ាងត្រជាក់ត្រជុំ មិនមានសេចក្តីសុខណាៗក្នុងលោកស្មើបាន, លោកអ្នកមានប្រាជ្ញាតែងនិយមក្នុងការអប់រំចិត្តជានិច្ចកាល ។

ប្រយោជន៍ដែលកើតអំពីការអប់រំចិត្តនោះ ចែកចេញជា ៣ ជាន់ គឺ ទិដ្ឋធម្មិកត្ថៈ (ប្រយោជន៍ក្នុងបច្ចុប្បន្ន), សម្បរាយិកត្ថៈ (ប្រយោជន៍ក្នុងបរលោក), បរមត្ថៈ (ប្រយោជន៍ខ្ពស់គឺព្រះនិព្វាន) ។

ទិដ្ឋធម្មិកត្ថៈ អំណាចផលឲ្យតាំងខ្លួនបានជាគោលចរិកត្រឹមត្រូវក្នុងបច្ចុប្បន្ន ។ ព្រោះហេតុនោះ អ្នកប្រាថ្នាផលជាន់នេះ គួរអប់រំចិត្ត

ឲ្យមានសេចក្តីទុស្សាហ៍ឱ្យឃ្លាតកង់ការណីយកិច្ចដែលជាទាទីរបស់ខ្លួន គឺថាបើនៅកង់វ័យដែលត្រូវសិក្សា កំគួរត្រិះរិះរើសការសិក្សាដែលជាប្រយោជន៍ លះវៀរការសិក្សាដែលជាទោសចេញ, កាលបើឃើញការសិក្សាដែលជាប្រយោជន៍ហើយ កំចូរព្យាយាមចំពោះការសិក្សានោះតាល់តែសម្រេចផលតាមបំណង កុំខ្ជឿយណាយរួញរាឡើយ, កាលបើបានទទួលការងារណា ។ ដែលគេប្រគល់ឲ្យ កំចូរតាំងចិត្តព្យាយាមធ្វើការងារនោះ ។ ឲ្យបានសម្រេចផលតាមដែលគេប្រគល់ឲ្យប្តូរគេទុកចិត្ត គួរអប់រំចិត្តឲ្យស្មោះត្រង់ចំពោះខ្លួនឯង ចំពោះអ្នកដទៃ ចំពោះការងារដែលជាទាទីរបស់ខ្លួន ចំពោះកាលវេលា ចំពោះសមាគម ឲ្យចិត្តមានសតិសម្បជញ្ញៈ អត់ធន់ ត្រៀវក្លា អាចហាន រឹកពាយ ខន់ក្លាន់, មានសច្ចកតញ្ញុតវេទិ បដិភាណឈ្លាសវៃដ៏ងហេតុការណ៍មិនភ្លាត់ផ្តើលអាចប្រកបកម្មណីយនោះ ។ ឲ្យសមគួរដល់កាលៈទេស ចេះរក្សាកម្មណីយនោះ ។ មិនឲ្យសាបសូន្យ ឲ្យមានតែសេចក្តីចំរើនដោយលំដាប់ រហូតដល់ទ្រព្យសម្បត្តិដែលរកបានមកដោយធម៌ដ៏ប្រពៃ កំចេះរក្សានឹងថយក់យកកង់ផ្លូវដែលជាប្រយោជន៍ ចេះកាន់ប្រយោជន៍របស់ទ្រព្យសម្បត្តិទុកឲ្យបាន មិនបណ្តោយឲ្យប្រាសចាកប្រយោជន៍ ដែលនឹងត្រូវប់ជាទោសដល់ខ្លួន ពាំងត្រូវជាមនុស្សមានកល្យាណមិត្តរួមកិច្ចការ ឬប្រឹក្សាប្រឹងប្តេការងារគ្រឿងចិញ្ចឹមដ៏វិតជាដើម, កាលបើអប់រំចិត្តបានយ៉ាងនេះហើយ គង់នឹងបានទទួលផលដូចពោលមកពុំខាន ។

សម្បកយ៉ិតត្ថ: អំណោយផលឲ្យចេះធ្វើប្រយោជន៍ដល់ពួកគណៈប្រទេសជាតិ ហើយជាគុណសម្បត្តិជាប់នឹងខ្លួន ដូចស្រមោលជាប់តាមក្បាណ សូម្បីនឹងទៅកាន់ទិសណា ។ ក៏រមែងអំណោយផលតាមដូនទៅខុបត្តម្ភកនឹងទិសនោះៗ មិនឲ្យមានទុក្ខលំបាក ។ ព្រោះហេតុនោះ អ្នកប្រាថ្នាផលជាន់នេះ គួរអប់រំចិត្តឲ្យមានសទ្ធា គឺជឿកម្មវបស់ដែលគួរជឿ, ឲ្យមានសីល គឺតាំងចិត្តប្រតិបត្តិតាយ៉ាងរៀបរយប្រាសចាកទោសទាល់តែចិត្តជាប្រក្រតីមិនកំរើកញាប់ញ័រ, ឲ្យមានចាគៈ គឺចេះបែងចែកលះបង់ខាងក្នុងនឹងខាងក្រៅ ធ្វើចិត្តឲ្យខ្ជូលាយមិនចង្អៀត, អ្វីជាសត្រូវរបស់សទ្ធានឹងសីលជាចំណែកខាងក្នុងក៏រមែងលះបាន, អ្វីជាសត្រូវរបស់ការខាងក្រៅក៏រមែងលះបាន, ឲ្យមានបញ្ញាដឹងហេតុផលតាមពិត កម្មវបស់ដែលខ្លួនដឿនឹងលះបង់ ។ ការអប់រំចិត្តបានយ៉ាងនេះ រមែងជាហេតុធ្វើចិត្តឲ្យស្គាល់ជាក់លាក់កម្មការបំពេញ ប្រយោជន៍រួមគឺពួកគណៈដែលខ្លួនទៅអាស្រ័យ ជាគុណសម្បត្តិឲ្យជាអ្នកលឿនជាប់គេកម្មពួកនោះៗ ។

បរមត្ថ: អំណោយផលឲ្យជាអ្នកមានចិត្តបរិសុទ្ធផុតចាកកិលេសាសវៈផុតចាកកម្មទុក្ខទាំងពួង; ព្រោះហេតុនោះ អ្នកប្រាថ្នាផលជាន់នេះ គួរអប់រំចិត្តឲ្យមានបញ្ញាជាហេតុដែកទុក្ខ ដែលមានតណ្ហាជាដែនកើត, កាលបើអាចលះតណ្ហាបានដាច់ស្រឡះហើយ កម្មទុក្ខទាំងពួងក៏រលត់អស់ដូចភ្លើងដែលអស់ប្រេង រមែងរលត់ទៅដូច្នោះ ។

វិធីអប់រំចិត្តតាមដែលភណិនាមកនេះ សូមលោកអ្នកមានប្រាជ្ញាពិចារណាមើលចុះ បើលោកអ្នកនិយមក្នុងការអប់រំចិត្តហើយ តែមិនបានសម្រេចលទ្ធផលដល់ជាន់ខ្ពស់បំផុត បានត្រឹមតែការធ្វើ ការនិយាយ ការគិត ជាសុចរិតប៉ុណ្ណោះ ក៏គប្បីនឹកសង្ឃឹមក្នុងចិត្តចុះថា ខ្លួនតិះដៀលខ្លួនឯងមិនបាន, អ្នកដឹងពិចារណាហើយក៏សរសើរ, កិត្តិស័ព្ទខ្ចរខ្ចាយមិនត្រអូបខ្ចរខ្ចាយទៅគ្រប់ទិសានុទិស, មិនជាអ្នកវង្វេងវង្វើកាលកិរិយា, សូម្បីនឹងត្រូវចំណាយទន្ទេញក៏មានសុគតិជាទីបញ្ចប់ត្រឡប់ទៅកន្លងមុខ, សុទ្ធតែជាផលដែលគួរប្រាថ្នាពិតៗ ទើបជាការសមគួរណាស់តែចំពោះការអប់រំចិត្តនេះ ដើម្បីសម្រេចផលជាសុខក្នុងទីគ្រប់ស្ថាន គ្រប់កាលសម័យ ។ វិធីអប់រំចិត្តមានន័យដូចពោលមកដូច្នេះឯង ។ ចប់

ចិត្តសៅហ្មងមកពីមិនប្រឹងអប់រំ
ប្រឹងសន្សំធ្វើទានសីលនឹងការនា,
ចិត្តសៅហ្មងនាំឲ្យរងទុក្ខខ្លោចផ្សា
ក្នុងអនាគតកាលនឹងបច្ចុប្បន្ន ។
ចិត្តបរិសុទ្ធផុតមន្ទិលស្រឡះស្អាតក្ខឹង
មកអំពីប្រឹងចំពាក់មិនស្រាកស្រន់,
ចិត្តបរិសុទ្ធនាំឲ្យសុខអនេកលន់;
សាធុជនគួរអប់រំចិត្តទៅអើយ!

ពុទ្ធបរិស័ទកឹម្អកណា

# ឃុនបណ្ណាផ្ទុក្ស ប៊ុ-ប៊ុ នៅពុទ្ធសាសនបណ្ឌិត្យ

*រៀបរៀង*

---

## ពាក្យប្រារព្ធ

មនុស្សយើងកើតមកហើយ មិនថាអ្នកមានឬអ្នកក្រ អ្នកឆ្លាត់ឆ្លៀសអ្នកៈថាកខាបទេ សុទ្ធតែស្អប់ខ្ពើមទុក្ខ ចង់ឲ្យានសុខដូចគ្នាទាំងអស់ គ្មានអ្នកណាចង់ឲ្យានទុក្ខស្រឡាញ់ទុក្ខសោះ កុំថាដល់ទៅខ្លួនវាឯងទុក្ខ សូម្បីតែគ្នាន់តែពាក្យថា ទុក្ខ ក៏មិនចង់ឲ្យឮផង ។ ហេតុនេះ ឲ្យានជាមនុស្សគ្រប់រូបខំគិតរកឧបាយដើម្បីធ្វើឲ្យខ្លួនផុតពីទុក្ខទោស ឲ្យខ្លួនឲ្យានសុខដោយវិធីផ្សេងៗគ្នា អ្នកខ្លះខំធ្វើការងារចិញ្ចឹមជីវិតត្រឹមត្រូវតាមផ្លូវលោកផ្លូវធម៌ក៏មាន អ្នកខ្លះធ្វើការងារខុសច្បាប់ខុសផ្លូវលោកផ្លូវធម៌ក៏មាន សូម្បីខ្មៀយហាត់យ៉ាងណាក៏មិនរួញរា ចាំងនេះ ក៏ព្រោះតែគេចង់ឲ្យខ្លួនឲ្យានសុខតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកស្វែងរកសុខនោះ មិនមែនចេះតែឲ្យានសុខត្រូវបទេ បើអ្នកណាធ្វើត្រូវតាមផ្លូវឲ្យកើតសុខ អ្នកនោះទើបឲ្យានសុខដូចបំណងចិត្តចាំថ្ងៃ បើអ្នកណាធ្វើខុសផ្លូវឲ្យកើតសុខ អ្នកនោះមិនឲ្យានសុខ ត្រូវប់ជាឲ្យានទុក្ខផ្ទុយនឹងបំណងខ្លួនទៅវិញ ព្រោះខ្លួនមិនដឹងដើមហេតុដែលឲ្យកើតសុខទុក្ខសោះ ។

តាមពិត សុខទុក្ខជាផលរបស់កម្មៗជាហេតុ ។ បើកម្មល្អជាហេតុ តែងបានសុខជាផល, បើកម្មអាក្រក់ជាហេតុ តែងបានទុក្ខជាផល ។ សុខទុក្ខនឹងកើតមានឡើងដោយសារតែខ្លួនឯងជាអ្នកធ្វើ អ្នកណាធ្វើល្អ អ្នកនោះបានសុខ អ្នកណាធ្វើអាក្រក់ អ្នកនោះបានទុក្ខ ។ សុខទុក្ខនេះចែករំលែកឲ្យគ្នាមិនបានទេ បើគ្រាន់តែពន្យល់ប្រាប់ដើមហេតុឲ្យកើតសុខទុក្ខដល់គ្នាបាន ដូចជាប្រាប់គ្នាថា បើអ្នកចង់ដឹងត្រជាក់ ត្រូវអ្នកងូតទឹក បើអ្នកចង់ដឹងក្តៅ ត្រូវអុកហាលថ្ងៃឬអាំងភ្លើងជាដើម ។ ត្រជាក់នឹងក្តៅមានចំពោះតែខ្លួនអ្នកងូតទឹកឬហាលថ្ងៃប៉ុណ្ណោះ ចំណែកអ្នកប្រាប់មិនត្រជាក់ឬក្តៅទេ សុខទុក្ខក៏ដូចជាត្រជាក់នឹងក្តៅនេះដែរ ។

លទ្ធិសាសនាពាំងពួនដែលកើតមានឡើងក្នុងលោក ក៏កើតមកតែអំពីគំនិតរបស់លោកជាសាស្ត្រានោះ។ គិតចៀសវាងទុក្ខទោសហើយស្វែងរកសុខតែមួយ"ឯ"ប៉ុណ្ណោះ ប៉ុន្តែសាសនាពាំងនោះមានពាក្យប្រៀនប្រដៅផ្ទុយគ្នា ទៅតាមគំនិតយោបល់សាស្ត្រានោះ។ ។

ចំពោះព្រះពុទ្ធសាសនា មានពាក្យប្រៀនប្រដៅអំពីផ្លូវចៀសវាងទុក្ខទោស ទឹងផ្លូវធ្វើឲ្យកើតសុខក្នុងលោកនេះទឹងលោកខាងមុខ ដោយបរិយាយដំណាលផ្តៀងផ្តិតសុទ្ធមណាស់ ដូចការព្រះសម្មាសម្ពុទ្ធ ជាន តែងដឹងច្បាស់ ។ ដំបូងបំផុត ទ្រង់ប្រដៅសាវ័កឲ្យស្គាល់ទុក្ខ, ឲ្យស្គាល់ហេតុកើតទុក្ខ, ឲ្យស្គាល់ទីរលត់ទុក្ខ ទឹងឲ្យស្គាល់ផ្លូវប្រតិបត្តិឲ្យដល់ទីរលត់ទុក្ខ, រួមខ្លីថា ព្រះពុទ្ធអង្គទ្រង់ប្រាប់ហេតុឲ្យកើតសុខទុក្ខមុនរឿងផ្សេង ។ ។

ហេតុនេះ មនុស្សគ្រប់រូបទើបត្រូវតាន់សាសនាពុកជាគោលសម្រាប់គ្រប់គ្រងជីវិតរបស់ខ្លួនឲ្យបានសុខស្រួលរាល់ថ្ងៃ ដូចជាតាន់ប្បាប់សម្រាប់ស្រុកទេសដែរ ។ ប៉ុន្តែ អ្នកណាតាន់សាសនាអ្វី . អ្នកនោះត្រូវតែខំគិតដេញដោលរកហេតុផលក្នុងសាសនានោះ ឲ្យឃើញពិតប្រាកដដោយប្រាជ្ញារបស់ខ្លួន កុំបេះតែតាន់សាសនាដោយសារគេបង្ខំ ដោយខ្លាចគេ ឬក៏ដោយអៀនខ្មាសគេ ។

ក្នុងសៀវភៅនេះ ខ្ញុំអធិប្បាយចំពោះតែវិធីប្រតិបត្តិក្នុងព្រះពុទ្ធសាសនាមួយប៉ុណ្ណោះ សាសនាឯទៀតលើកទុក ។

សូមលោកអ្នកតាន់ព្រះពុទ្ធសាសនាជួយវិនិច្ឆ័យប្រស្នាទៅនេះផង៖

១ - ព្រះពុទ្ធអង្គជាអ្នកបង្កើតលោកឬ ?

២ - ព្រះពុទ្ធអង្គជាអ្នកដាក់ទោសទណ្ឌកម្ម ដល់ពួកសាវ័កដែលល្មើសពុទ្ធប្បញ្ញត្តិឬ ?

៣ - ព្រះពុទ្ធអង្គជាអ្នកទទួលទុក្ខទោសជួសពួកសាវ័កឬ ?

៤ - ព្រះពុទ្ធអង្គជាអ្នកទទួលពាក្យអង្វរករបន់ស្រន់ របស់ពួកសាវ័កឬ ?

៥ - ព្រះពុទ្ធអង្គជាម្ចាស់កម្មផលមែនឬទេ ?

ប្រស្នាទាំង ៥ ប្រការនេះ សូមអស់លោកអ្នកមើលសេចក្តីក្នុងរឿងនេះ កាលបើមើលហើយនឹងបានយល់ច្បាស់ណាស់មិនខាន ។

## អត្ថបទដែលត្រូវពោលក្នុងទីនេះគឺ


១.— ពុទ្ធបរិស័ទ
២.— ការណីយកិច្ចរបស់ពុទ្ធបរិស័ទ
៣.— ដើមកំណើតរបស់ព្រះពុទ្ធជាអ្នកបង្កើតសាសនា
៤.— រូបរាងរបស់ពុទ្ធសាសនា
៥.— វិត្ថុបំណងរបស់ពុទ្ធសាសនា
៦.— គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនា
៧.— គោលនៃការប្រតិបត្តិធម៌យ៉ាងត្រឹមត្រូវបំផុតក្នុងពុទ្ធសាសនា
៨.— ផលដ៏ប្រសើរបំផុតនៃការប្រតិបត្តិធម៌ក្នុងពុទ្ធសាសនា ។


## ពុទ្ធបរិស័ទ

ពាក្យថា "ពុទ្ធបរិស័ទ" បែកជា ២ បទ គឺ ពុទ្ធ ១ បរិស័ទ ១ ។ ពុទ្ធ ជាព្រះនាមនៃព្រះសមណគោតម ដែលជាសាស្តាអ្នកបង្កើតសាសនា(១) ។ បរិស័ទ ជាឈ្មោះពួកជនដែលកាន់សាសនាត្រូវគ្នាជួបជា ពួកពុទ្ធបរិស័ទ, ពួកគ្រិស្តបរិស័ទ, ពួកអិស្លាមបរិស័ទ ជាដើម ។ រួម ពុទ្ធ នឹង បរិស័ទ ភ្ជាប់គ្នាជា ពុទ្ធបរិស័ទ ប្រែថា "បរិស័ទរបស់ព្រះពុទ្ធ" ឬថា "ពួកជនអ្នកកាន់ពុទ្ធសាសនា គឺជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ" ។ ពួកពុទ្ធបរិស័ទទាំងអស់នឹងផ្ទាស់ឈ្មោះហៅថា "ពុទ្ធសាសនិកជន" ឬ "ពុទ្ធមាមកៈ" ឬ "ពុទ្ធសាវ័ក" យ៉ាងនេះវិញក៏បាន សំដៅយកពួកជនអ្នកកាន់ពុទ្ធសាសនាដូចគ្នា ។

---

១ មានសេចក្តីពិស្តារក្នុងច្បាប់ពុទ្ធប្រវត្តិឬគម្ពីរបឋមសម្ពោធិ ។

មនុស្សដែលបាននាមថា "ពុទ្ធបរិស័ទ" នោះ គេមិនបានតំណាត់ថា ជាជាតិអ្វីទេ ។ មិនតំណាត់ថាប្រុសឬស្ត្រី ក្មេងឬចាស់ទេ ឲ្យតែអ្នកណាប្រព្រឹត្តត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធហើយ អ្នកនោះក៏បាននាមថា "ពុទ្ធបរិស័ទ" ដូចគ្នាទាំងអស់ ។ ពុទ្ធបរិស័ទ មាន ២ ពួក គឺគ្រហស្ថ ១ ពួក បព្វជិត ១ ពួក ។

អ្នកដែលមានចិត្តចង់តាំងខ្លួនជាពុទ្ធបរិស័ទ - ត្រូវតែសិក្សាឲ្យចេះដឹងខ្លួនទៅ ។

## ការណីយកិច្ចរបស់ពុទ្ធបរិស័ទ

ខាងពួកគ្រហស្ថ[1] មុនដំបូង ត្រូវតាំងចិត្តដឿតម្នាក់ នឹងដឿគុណព្រះរតនត្រ័យ ហើយបន្ទាប់ចាសូមស្មាណៈទាសរួចប្រកាសប្តេជ្ញាខ្លួនថាជាអ្នកគោរពកាន់អាទិកាន់ពុទ្ធសាសនា នៅទីចំពោះព្រះភក្ត្រព្រះពុទ្ធរូប ឬចំពោះព្រះភក្ត្រភិក្ខុ ១ រូប ២ រូបឡើងទៅ នៅទីកន្លែងណាក៏បាន ។ លុះធ្វើកិច្ចទាំង ២ យ៉ាងខាងដើមនេះស្រេចហើយ ត្រូវសមាទានសីល ៥ ឬសីល ៨ នឹង ប្រព្រឹត្តតាមធម៌វិន័យសម្រាប់គ្រហស្ថជារៀងច្រើនប្រការតទៅទៀត ។ ពុទ្ធបរិស័ទខាងពួកគ្រហស្ថ បើប្រុសហៅ "ឧបាសក," បើស្ត្រីហៅ "ឧបាសិកា" គឺអ្នកតាំងចិត្តយកព្រះរតនត្រ័យជាទីពឹងជាទីរលឹក ។

ការណីយកិច្ចខាងពួកបព្វជិត[2] មុនដំបូង អ្នកដែលចង់បួស ត្រូវ

---

๑ ការណីយកិច្ចខាងគ្រហស្ថមានពិស្តារក្នុងច្បាប់តិហិបដិបត្តិ ។ ๒ ការណីយកិច្ចខាងអ្នកបួសមានពិស្តារក្នុងបព្វជ្ជាខន្ធក៍ ។

ចូលទៅរកលោកគ្រូអាចារ្យឬព្រះឧបជ្ឈាយ៍ សូមរៀនសូត្រធម៌វិន័យ
សម្រាប់អ្នកបួសឲ្យបានចេះដឹងល្មមសមគួរហើយ ក៏រកត្រៃចីវរបរិក្ខារ
សម្រាប់អ្នកបួស, លុះរកបានសព្វគ្រប់ហើយ ចូលទៅសូមបួសក្នុង
សំណាក់លោកគ្រូអាចារ្យ. កាលបួសរួចហើយ បើប្រុសហៅថា
"សាមណេរ" ឬ "កិក្ខុ" បើស្រីហៅ "សាមណេរី" ឬ "កិក្ខុនី" ។

អ្នកដែលបាននាមប្បញ្ញត្តិថាជា "ពុទ្ធបរិស័ទ" ហើយ គួរណាស់
តែចំសិក្សារឿងរ៉ាវនៃព្រះពុទ្ធជាម្ចាស់យ៉ាងល្អិតតទៅទៀត ដើម្បីឲ្យបាន
យល់ច្បាស់លាស់អំពី ៖

## ដើមកំណើតនៃព្រះពុទ្ធជាអ្នកបង្កើតសាសនា

ព្រះពុទ្ធជាបរមគ្រូនៃយើង ជាមនុស្សអស្ចារ្យ ទ្រង់សម្ភពក្នុង
សក្យត្រកូល ព្រះជាតិជាក្សត្រ បានទ្រង់សោយរាជសម្បត្តិក្នុងព្រះ
ជន្ម ១៦ វស្សា ទ្រង់ពិចារណាឃើញនូវសេចក្តីទុក្ខព្រួយរបស់ព្រះអង្គ
និងមនុស្សសត្វជាច្រើន ទើបលះបង់ចោលរាជសម្បត្តិចេញទ្រង់ព្រះផ្នួសក្នុង
ព្រះជន្ម ២៩ គង់ក្នុងវិធីតិះដៀលធម៌ជាគ្រឿងរំលត់ទុក្ខព្រួយអស់រយៈ
៦ ឆ្នាំ ទើបទ្រង់បានជ្រាបធម៌ជាគ្រឿងរំលត់ទុក្ខព្រួយនោះ ក្នុងព្រះជន្ម
៣៥ មានព្រះនាមថ្មីថា "ពុទ្ធ" មានព្រះនាមតាមព្រះគោត្រថា "ព្រះ
ពុទ្ធសមណគោតម" ឬ "ព្រះពុទ្ធសក្យមុនីគោតម". ព្រះអង្គបរិនិព្វាន
ក្នុងព្រះជន្ម ៨០ គត់(១) ។

---

១ រឿងរ៉ាវនៃព្រះពុទ្ធមានសេចក្តីពិស្តារក្នុងប្បាប់ពុទ្ធប្រវត្តិ ឬ ក្នុងគម្ពីរបឋមសម្ពោធិ ។

ពួកពុទ្ធបរិស័ទ កាលបើបានចេះដឹងរឿងរ៉ាវនៃព្រះពុទ្ធហើយត្រូវតែសិក្សាឲ្យយល់ច្បាស់លាស់អំពី ៖

## រូបរាងរបស់ពុទ្ធសាសនា

ពាក្យថា "ពុទ្ធសាសនា" ចែកជា ២ បទ គឺពុទ្ធ ១ សាសនា ១ ។ ពុទ្ធ ជាព្រះនាមនៃព្រះបរមសាស្តាអ្នកឆ្លើមបង្កើតសាសនា ដូចថាមកហើយ ។ សាសនា ប្រែថា "ពាក្យប្រៀនប្រដៅ" រួមចូលគ្នាជា ពុទ្ធសាសនា ប្រែថា "ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ" ។

ពាក្យប្រៀនប្រដៅទាំងអស់ ដែលព្រះបរមសាស្តាត្រាស់ទេសនាដូន្មានពួកពុទ្ធបរិស័ទ តាំងពីបានត្រាស់ដឹងជាព្រះពុទ្ធរហូតដល់បរិនិព្វានក្នុងកំឡុង ៤៥ ឆ្នាំ សូម្បីព្រះអង្គសំដែងបែកខ្ញែកៗជាប៉ុន្មានផ្នែកក៏ដោយ ក៏គង់តែហៅដោយសរុបថា "ពុទ្ធសាសនា" តែម្យ៉ាងប៉ុណ្ណោះ សឹងមានជាប់រហូតមកដល់សព្វថ្ងៃនេះ រាប់ថារូបកាន់របស់ពុទ្ធសាសនា កើតមកបានអាយុ ២៤៩៧ ឆ្នាំហើយ ។

ពួកពុទ្ធបរិស័ទ កាលបើបានស្គាល់រូបកាន់របស់ពុទ្ធសាសនាហើយ ត្រូវតែគិតរិះរៃជ្រាបដោយលំអិតទៀត ៖

## វត្ថុបំណងរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល គោះបីព្រះបរមសាស្តាត្រាស់ទេសនាដូន្មានពួកពុទ្ធបរិស័ទដោយព្រះវិនយបិដកក្តី, ព្រះសុត្តន្តបិដកក្តី, ព្រះ

អភិធម្មបិដកក្តី ក៏មានវត្ថុបំណងតែមួយ គឺទ្រង់ដឹកនាំពួកពុទ្ធបរិស័ទឲ្យ ប្រតិបត្តិឈមមុខទៅរកព្រះនិព្វាន ដែលជាទីរលត់ទុក្ខតែម្យ៉ាងប៉ុណ្ណោះ ។

ប៉ុន្តែ មានន័យជាអនេកប្រការ(๑) ដែលព្រះអង្គដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិយកផលប្រយោជន៍នានាលោកិយ ដែលជាអ្នកមិនទាន់បានដល់ព្រះនិព្វាន ដូចជាព្រះអង្គត្រាស់ប្រាប់ប្រយោជន៍ ๓ យ៉ាង គឺប្រយោជន៍ក្នុងជាតិនេះ ๑ ក្នុងជាតិខាងមុខ ๑ ប្រយោជន៍ប្រសើរបំផុត គឺព្រះនិព្វាន ๑ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់នូវវត្ថុបំណងរបស់ពុទ្ធសាសនាហើយ ត្រូវតែខំពិចារណាឲ្យល្អិតជ្រាលជ្រៅស្រាវជ្រាវរកនូវ

## គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាខាងមូល មានចតុរារិយសច្ច (របស់ពិត ๔ យ៉ាង) ជាកំពូល, ធម៌គ្រប់យ៉ាងសុទ្ធតែសង្គ្រោះរួមចុះក្នុងវង់ចតុរារិយសច្ចទាំងអស់ ។ សេចក្តីប្រតិបត្តិគ្រប់បែបដែលមានប្រាកដក្នុងគម្ពីរទាំងឡាយ ក៏តែងកើតមានឡើងដើម្បីសេចក្តីចេះដឹង នូវចតុរារិយសច្ចដោយប្រាជ្ញា, ចតុរារិយសច្ចជាកំពូលធម៌, ការចេះដឹងចតុរារិយសច្ច ជាកំពូលនៃព្រហ្មចរិយ,(๒) ការប្រតិបត្តិដើម្បីឲ្យត្រាស់ដឹងចតុរារិយសច្ចដោយប្រាជ្ញា ជាកំពូលនៃការប្រតិបត្តិទាំងមូល ។

---

๑ មានសេចក្តីពិស្តារក្នុងច្បាប់សិង្គាលោវាទសូត្រលេខ ម. ๒๑ ។ ๒ ការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុត ។

## បគុណារិយសច្ច

ពាក្យថា "បគុណារិយសច្ច" ប្រែថា "របស់ពិតដ៏ប្រសើរមាន ៤ យ៉ាង" គឺ


๑ - ទុក្ខអរិយសច្ច របស់ពិតដ៏ប្រសើរ គឺទុក្ខ

๒ - សមុទយអរិយសច្ច របស់ពិតដ៏ប្រសើរ គឺហេតុប្រជុំកើតទ្បើងនៃទុក្ខ

๓ - និរោធអរិយសច្ច របស់ពិតដ៏ប្រសើរ គឺធម៌រលត់ទុក្ខ

๔ - មគ្គអរិយសច្ច របស់ពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

(មានត)



# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បានឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង
កាលដែលនៅជាបព្វជិត ពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

(តមក)

---

## សុភមិត្តជាតក ទី ៩

(តមក)

(និយាយអំពីដំណើរក្រោតក្រាស ព្រោះមានឧពៀរដោយយកកូនសត្វ)

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមដំនុំព្រះត្រៃបិដក

ប្រែពីបាលី

ព្រះបាទក្រែងសុភមិត្តនោះ លុះទ្រង់ព្រះកន្សែងសោកបាក់ប្រះ
ព្រះអង្គយ៉ាងនេះហើយ ក៏មិនអាចទប់ព្រះស្មារតីបានឡើយ ទ្រង់ដួល
សន្ធប់ក្នុងទីនោះ លុះភ្ញាក់ព្រះស្មារតីឡើងហើយ ទើបទ្រង់អារកាត់
សេចក្តីសោកដោយព្រះអង្គឯងថា ៖

ការជួបជុំគ្នានឹងការព្រាត់ប្រាសគ្នានេះ ជាធម្មតារបស់សត្វ-
លោកទេតើ! បណ្ឌិតរមែងដឹងខ្លួនតាមសភាពពិតយ៉ាង
នេះ បានជាមានសេចក្តីសង្វេគក្រៃពេក ។

លំដាប់ពីនោះមក ព្រះអង្គទ្រង់មានព្រះអស្សាសៈធូរស្រួលហើយ
ទ្រង់ក៏ចុះទៅកាន់ស្ទឹងវិញ ។

ពីទា កាលេ កាលនោះមានឪពុកសំពៅម្នាក់ បើកសំពៅ
ទៅប្របន្ទេរស្ករជាមួយនឹងពួកចំណុះសំពៅច្រើនណាស់ បាន
ឃើញនាងទេវីបរិបូណ៌ដោយលក្ខណៈ មានរូបល្អចំណាប់អង្គុយនៅ
ក្រោមម្លប់ឈើ ក៏ឡើងទៅចាប់យកនាងមកជាភរិយាក្នុងសំពៅហើយបើក
ទៅ ។ គ្រានោះ ព្រះនាងទេវី ហាក់ដូចជាមានព្រះទ័យប្រែធាតុ
សញ្ជែកចេញជា ៧ ភាគ ព្រោះព្រះនាងខ្ចីរឭកព្រះរាជបុត្រទាំងពីរ
ព្រមទាំងព្រះស្វាមី ទើបក្សត្រីខ្ចីព្រះកន្សែងសោកថា:

វិយោគោ មេ កតោ បុព្វេ តវយិ មិគបក្ខិនោ
តេន កម្មវិបាកេន វិយោគោ បតិនា សហ

ខ្ញុំ! អាត្មាអញអើយ! ឫកជាធ្លាប់ពង្រាត់ពួកសត្វម្ចឹគ
បក្សីពីជាតិមុនមក បានជាត្រូវព្រាត់ឫសាកកូនពន្លក
ព្រមទាំងស្វាមី, ដំណើរនេះ ឫកជាផលកម្មនោះឯង
សូងតាមមកទាន់ផ្តន្ទាយើង ឲ្យព្រាត់ឫសគ្នាយ៉ាងនេះ ។
នាយសំពៅក៏ប្រឹងតែបើកសំពៅ នាំព្រះនាងទៅកាន់ទីតាម
សេចក្តីប្រាថ្នារបស់ខ្លួន ។

ចំណែកខាងព្រះពោធិសត្វ ខ្ចីធ្លឹងឹកស្ទឹងឡើងមកគេព្រះនាងទេវីនៅ
ទៀបដើមឈើនោះមិនឃើញ ទើបខ្ចីស្ទុះទៅមកៗស្វែងរកក្នុងទីជិតៗ
សព្វកន្លែង ក៏នៅតែមិនឃើញទៀត ទើបព្រះមន្ត្រីខ្ចីព្រះកន្សែងថា:

ទ្រ! អាត្មាអញអើយ! ជាមនុស្សអនាថា កំព្រាកណ្តាច
កណ្តែងតែម្នាក់ឯងស្ងាត់ឈឹង នៅប្រាបមាត់ស្ទឹងនេះតើហ្ន៎!
ចាបតែពុត្រាកំសត់កម្រ ព្រាត់ប្រាសឃ្លាតបាត់ពីខ្លួនទៅ
ឥឡូវអញរកកន្លែងមិនឃើញទៀត! នុះ ទ កម្មអើយ!
ម្តេចឡើយបានជាយើងវង់ទុក្ខ ខ្ជាត់ក្ងាត់ប្រាសព្រាត់ទៅតែ
ឯង។ ដូច្នេះ? បើតែម៉្លេះៗអញស្ងាប់កុងទីនេះទើបប្រសើរ,
រស់នៅតែម្នាក់ឯងដូចម្តេចកើត! ម្ចាលនាងទេវីជាទីពេញ
ហ្ឫទ័យ, បងមកនៅកុងព្រៃស្ងាត់សូន្យឈឹង តើបងនឹងធ្វើដូចម្តេច? បងរឹងរឹតតែសន្ធើងសង្កើងភ្ញាំងឡើង។ យ៉ាង
នេះដូចម្តេចឡើយនឹងរួចពាក់សេចក្តីទុក្ខនេះបាន? នុះ ទ
ទេវតាអើយ, អ្នកគាំងឡាយឋិតនៅលើកុំ លើទីភូមិភាគ
ពសុធា លើអាកាសវេហាស៍ឬលើទីណាៗក្តី ឥឡូវនេះ
មានតែអ្នកគាំងឡាយហ្នឹងហើយជាទីពឹងរបស់ខ្ញុំ, ធ្វើម្តេចឲ្យ
ខ្ញុំបានឃើញនាងកេសនី? នរណាអើយជាទេព្តា ឬ មនុស្ស
ឬយក្សដែលមានឫទ្ធិច្រើន អាចដោះខ្ញុំឲ្យបានរួចពាក់សេចក្តី
ទុក្ខ, អ្នកនោះនឹងជាទីពឹងរបស់ខ្ញុំតទៅ ។

ព្រះបរមពោធិសត្វទ្រង់ព្រះកន្សែងរៀបរាប់ដូច្នេះហើយ ក៏ទ្រង់
ដួលសន្ធប់ផ្តាត់ព្រះស្មារតីកុងទីនោះ; លុះទ្រង់មានព្រះអស្សាសៈធូរ

ស្រួលបន្តិចទៀងហើយ ក៏ហាក់ជានឹងឆ្គួតព្រះហ្ឫទ័យ ។ តមត្តំ បកា-
សេឡ្ហោ សត្តា អាហ កាលអគ្គសម្តេចព្រះបរមសពិជ្ញសាស្តាចារ្យ
ទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ដូច្នេះថា ៖

កទ្ធលិវ រាគប្បប្បិតា ជាតា បិត្តលតាវនេ
បរិទេវិឡ្ហោ សោ រាជា តត្តេវ បតិតោ ឆមា

ព្រះរាជាអគ្គនោះ ទ្រង់ព្រះកន្សែងសោយសោកបោកខ្លួន
ដួលទៅលើដែនដីកន្លងទីនោះ ដូចជាដើមចេកដែលដុះក្នុង
ព្រៃចិត្តលតាវន៍ ត្រូវខ្យល់ព្យុះបោកកំទេចដួលខ្ទេចដូច្នោះ ។
លុះព្រះមហាសត្វទ្រង់មានព្រះអស្សាស: ដកដង្ហើមធូរស្រួល
ហើយ ទើបទ្រង់ក្រោកឡើងចាកទីនោះ ស្តុះទៅរកខាងនេះខាងនោះ
មិនឃើញព្រះនាងទេវីតែមាំងព្រះរាជបុត្រតាំងពីរសោះ ទើបទ្រង់ព្រះ
កន្សែងសោករៀបរាប់ទៀតថា:

ទេឡ្ហាអើយ! ខ្ញុំមិនឃើញកូនតាំងពីត្រែម តាំងកិរិយារបស់
ខ្ញុំឡើយ ប្រហែលជាសត្វស្វាបអ្នីធាបធត់យកទៅធ្វើជាចំណី
អាហារទេដឹង? ឬមួយការកបរបស់ខ្ញុំស្វាប់ចាត់ដោយខ្លួនឯង
ទេ? ទេឡ្ហា! ប្រាកដជាសត្វក្អែកមៀមចឹកសម្លាប់ជន
តាំងនោះកុំឲ្យខ្ញុំរកឃើញមែនហើយ ការកបរបស់ខ្ញុំស្វាប់មែន
ហើយ! ទ! អាត្មាអញ យំសោកយ៉ាងនេះពីរបីលើក

ហើយ, ប្អូនប្រុសរបស់អាត្មាអញសោត កំញ៉ាំរចំប្រុងទាំងម្ទេះ កំនៅតែមិនឃើញព្រះរាជបុត្រទាំងពីរ ព្រមទាំងនាងទេវីដែលមានតន្ត្រីយ៍ស្អាតខ្លោះ ។ ពេលនេះប្អូនប្រុសរបស់អញ កំពុងញាប់ញ័រដូចជាអន្លោកក្រឡឹងតែរបក់ល ព្រោះតែមិនឃើញជនទាំងបីនាក់នោះ ។ បើអាត្មាអញមិនបានឃើញជនទាំងបីនេះទេ តែព្រះអាទិត្យអស្តង្គតទៅក្នុងយប់នោះ ហើយក្តីស្វាន់ឡើងវិញពេលណា អាត្មាអញមុខជាស្លាប់ក្នុងពេលព្រឹកនោះមិនខាន ។

ព្រះមហាសត្វទ្រង់ព្រះកន្សែងសោក រំរើរពេយដូច្នោះហើយ កំស្តេចទ្រង់ត្រេចពីទីនោះ ទៅតែមួយព្រះអង្គ ។

ត្រង់ចន្លោះនេះ មានពាក្យចោទច្រៀតជណ្តឹងសួរមកថា ក្សត្រទាំងបួនព្រះអង្គ ដែលព្រាត់ប្រាសគ្នាយ៉ាងនេះ ព្រោះបាបកម្មដូចម្តេច? ពាក្យដោះស្រាយថា កាលពីព្រេងនាយ ក្សត្រទាំងបួនព្រះអង្គនោះ ប៉ាន់ទៅអង្គុយទៅទៀបគល់ឈើមួយដើម ត្រង់ចន្លោះផ្លូវដែលខ្លួនដើរទៅ ។ កុមារជាបុត្រទាំងពីរនាក់ បានឮសំឡេងកូនសេក[1]យំលើបុងឈើ ក៏ចង់បានកូនសេកនោះមកលេង, ទើបយំលំអុកឲ្យមាតា ត្រាតែមាតាអត់

---

๑ ប្លែងនេះ អ្នកប្រាជ្ញពីបុរាណបានប្រែទៅជាភាសា, ក្នុងប្លែងកំណាព្យនោះ លោកប្រែថា "កូនចៅលភោក., ប្រហែលជាគម្ពីរដែលលោកយកមកធ្វើប្បាប់ប្រែនោះ - មានបាលីថា "នដ្ឋូហរោតកានំ" ដូច្នេះទេដឹង? ៖

ត្រាំមិនបាន ក៏អង្វរស្វាមីឲ្យទៅដើរយកកូនសេកនោះមកឲ្យកូនលេង. កាលកុមារចាំងពីរលេងកូនសេកនោះ បានជកពេមស្វាបក់ រចោចអស់បីខន, កម្មនោះឯងឲ្យផលផ្តល់ឲ្យក្សត្រចាំង ៤ ព្រះអង្គបានដល់នូវសេចក្តីព្រាត់ប្រាសចាកគ្នាយ៉ាងនេះ អស់កំណត់ ៥០០ ជាតិ ។ តំមត្តំ បកាសេត្តោ សត្តា អាហ អង្គសម្តេចព្រះបរមសាស្តាកាលទ្រង់ប្រកាសសេចក្តីនោះទ្រង់ត្រាស់ថា ៖

តតោ មគ្គន្តរេ រុក្ខេ សុវិបោតកំ គហេត្វា
បោតំ បិ ច កុមារ តីណិ (តេសំ) លោមានិ រុឍ្ឍិ

កុមារចាំងពីរលេងកូនសេក ឲ្យដកតែពេមបីគត់ ក្បែរផ្លូវនោះ ក៏កម្មនោះតាមមកឲ្យផលដល់ម្ល៉េះ ។

បិតានោះ ក៏យកកូនសេកទៅទុកលើដើមឈើវិញ; ដោយផលកម្មនោះ បានជាត្រូវព្រាត់ប្រាសចាកគ្នាដូច្នេះ ។

ឯអង្គព្រះបរមពង្សក្រែងសុកមិត្ត ទ្រង់ចេញចាកពីនោះទៅចាំងទុក្ខក្រៀមក្រំ ដោយសេចក្តីរលឹកនឹកដល់ព្រះភរតបុត្រ ទើងអគ្គមហេសីណាស់ ទើបត្រាស់ថា ៖

អប្បិយេហិ សម្បយោគោ វិប្បយោគោ បិយេហិ ច
ទុក្ខោ បិយវិយោគញ្ច បរិប្ផន្ទិតំ វិដ្ឋតិ ។

បេមតោ ជាយតេ សោកោ បេមតា ជាយតេ ភយំ
បេមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។
កាមតោ ជាយតេ សោកោ កាមតោ ជាយតេ ភយំ
កាមតោ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។
តណ្ហាយ ជាយតេ សោកោ តណ្ហាយ ជាយតេ ភយំ
តណ្ហាយ វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។
រតិយា ជាយតេ សោកោ រតិយា ជាយតេ ភយំ
រតិយា វិប្បមុត្តស្ស នត្ថិ សោកោ កុតោ ភយំ
ឯវំ វិសេសតោ ញត្វា ន ករេ បិយពន្ធនន្តិ ។

*ដំណើរសេមច្រកបដោយអារម្មណ៍មិនជាទីស្រឡាញ់ក្តី ដំ-ណើរព្រាត់ច្បាសចាកអារម្មណ៍ជាទីស្រឡាញ់ក្តី កំសុទ្ធតែនាំមកនូវសេចក្តីទុក្ខ; បើអាត្មាអញ ផ្តាច់បង់នូវសេចក្តីស្រឡាញ់ចំពោះអារម្មណ៍ ដែលព្រាត់ច្បាសទៅនោះបាន ទើបគួរនឹងបាននូវសេចក្តីសុខ ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីសេចក្តីស្រឡាញ់ទាំងអស់; បើផុតសេចក្តីស្រឡាញ់ហើយ, សោកក៏គ្មាន ភ័យក៏គ្មាន ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីសេចក្តីច្បាស; បើផុត*

សេចក្តីក្រោធហើយ, សេចក្តីសោកក្តី ភ័យក្តីក៏មិនមាន ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីតណ្ហា; បើរួចផុតចាកតណ្ហាហើយ, សេចក្តីសោកក្តី ភ័យក្តី នឹងមានមកពីណា ។ សេចក្តីសោកក្តី ភ័យក្តី កើតមកអំពីសេចក្តីត្រេកអរ; បើអស់សេចក្តីត្រេកអរហើយ, សេចក្តីសោកនឹងភ័យ នឹងមានពីណា? បើបុគ្គលដ៏ចម្រើនយ៉ាងនេះហើយ មិនគួរធ្វើចំណងគឺសេចក្តីស្រឡាញ់ ឲ្យជាប់ជាមួយនឹងគេឯទៀតឡើយ ។

ព្រះមហាក្សត្រទ្រង់ព្រះតម្រិះ សោយសោកដូច្នេះហើយស្តេចក៏ត្រេចចរកេ ។ កាលព្រះពោធិសត្វ ទ្រង់ត្រេចទៅតាមលំដាប់ក៏ស្រាប់តែបានដល់នគរតក្កសិលា ហើយទ្រង់ចូលទៅក្នុងឧទ្យានដ៏សម្រាកព្រះកាយ លើថ្មមង្គលសិលាឯកគល់ពោធិព្រឹក្សមួយដើម ។

គ្រានោះ ដួងជាព្រះពាជាព្រះបាទនគរតក្កសិលាទ្រង់ស្តេចព្រះវិង្គតទៅ ។ ពួកពាជសេវកាមាត្យ ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីធ្វើព្រះសរីរកិច្ចរួចស្រេច, ដល់ថ្ងៃទី ៧ ក៏ប្រជុំប្រឹក្សាគ្នាក្នុងទីព្រះលានថា "ព្រះពាជាម្ចាស់យើងគ្មានព្រះពាជបុត្រសោះ. តើបាននរណាសោយពាជ្យ? ដែនសីមា បើឥតស្តេចគ្រប់គ្រងថែរក្សាទេ មិនងាយនឹងតាំងនៅបានទេ, ឥឡូវនេះ អ្នកក្តី ខ្ញុំក្តី តើនរណាគាចសោយពាជ្យកើត" ។ ទើបបុរោហិតម្នាក់ធ្វើឡើងថា "ត្រូវតែយើងនាំគ្នាផ្សងបុស្សរថ ឲ្យ

ទៅកសើសស្តេចដ៏ប្រសើរ ទើបគួរ, បើអ្នកណាមានលក្ខណៈមានបុណ្យ-
គ្រប់គ្រាន់ គង់តែបុស្សវេទនឹងនាំអ្នកនោះមកពុំខាន អ្នកនោះឯងទើប
សោយភោជ្យបាន" ។ អាមាត្យទាំងនោះ ក៏ទទួលព្រមថា សាធុ
ហើយលើកគ្រឿងបញ្ជាកកុធភណ្ឌជាក់លើបុស្សវេទនោះ ។ បុរោហិត
លែងបុស្សវេទតាំងផ្សងថា

ឆត្តំ ចាមរិ ឧណ្ហីសំ ខគ្គំ សុវុណ្ណបាទុកំ
ឥមានិ បញ្ចភណ្ឌានិ រាជូនំ អភិសេកតទ្ធិ

"គ្រឿងបញ្ជាកកុធភណ្ឌ ៥ យ៉ាងគឺ ឆត្រ ១ ផ្ចិត ១ មកុដ ១
ព្រះខាន់ ១ សុពណ្ណិបាទុក៍ ១ នេះជារបស់សម្រាប់អភិសេក
ព្រះរាជាទាំងឡាយ (បើអ្នកឯណាមានបុណ្យវាសនា គួរបាន
ជាស្តេចសោយភោជ្យក្នុងនគរយើងនេះ, សូមឲ្យបុស្សវេទទៅ
ឈប់ត្រង់កន្លែងអ្នកនោះ") ។

លំដាប់នោះ បុស្សវេទទៅប្រទក្សិណព្រះរាជមន្ទីរហើយចេញទៅ
តាមទ្វារខាងកើត ។ ពួកមហាជនក៏រៀបចំតូរ្យតន្ត្រីជាច្រើនតាមក្រោយទៅ ។
ឯបុស្សវេទ ក៏ចូលទៅធ្វើប្រទក្សិណមង្គលសិលា ក្នុង ៣ ខ្សាន់ហើយក៏ឈប់
ទៅ ។ ខណៈនោះ បុរោហិតក៏ចូលទៅឃើញព្រះមហាសត្វកំពុងផ្ទំលក់
លើផែនមង្គលសិលាតែមួយព្រះអង្គឯង ទើបឲ្យប្រគំភ្លេងតូរ្យតន្ត្រីឡើង
ដើម្បីលួងព្រះបរមពោធិសត្វមើល ។ សំពួតូរ្យតន្ត្រីក៏លាន់ឮឡើងហាក់

ដូចកត្រែកដែនត្រឡាមហាប្រឹបពី ។ ទើបព្រះបរមពោធិសត្វក្សារឡើង បើកសំពត់ទូរព្រះសិរសាទ្រង់ទតឃើញពពួកសេនាយោធា ហើយក៏ទ្រង់ប្រែព្រះកាយផ្លុំធ្វើជាលក់វិញ ។ ព្រាហ្មណ៍បុរោហិត បើកសំពត់សាជកដែលព្រះអង្គទ្រង់ទូរ មើលលក្ខណៈត្រង់ព្រះបាទាសព្វគ្រប់ប្រការហើយលាន់មាត់ថា "ម្នាលគ្នាយើងដ៏ចំរើន, ចូរអ្នកទាំងអស់គ្នាពិនិត្យលក្ខណៈបុរសនេះមើល, បុរសនេះ ទើបអាចសោយរាជ្យជាស្តេចធំក្នុងទ្វីបទាំងបួនបាន" ។ ពួកមហាជនឮហើយ ក៏នាំគ្នាលើកដៃប្រណម្យជាក់លើសិរសាបង្គំទូលថា "បពិត្រព្រះនរបតីក្សត្រៃលោកប្រសើរអើយ, សូមព្រះអង្គទ្រង់ទទួលយករាជសម្បត្តិ, សូមព្រះអង្គជាម្ចាស់នៃរាជសម្បត្តិរបស់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមព្រះអង្គគ្រប់គ្រងប្រជារាស្ត្រទាំងឡាយចុះ" ហើយនាំគ្នាក្រាបបង្គំទូលថា ៖

នគរនេះជាទីក្សេមមនោរម្យ សមជាទីសប្បាយ ប្រដាប់ដោយកំពែងនឹងក្លោងទ្វារល្អឆើតឆាយ ដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានគ្រប់គ្រងរក្សាទុកដើម្បីថ្វាយដល់ព្រះអង្គ, ទាំងក្លាសាទដ៏ប្រសើរស្អាងស្អាត រុងរឿងដោយកំពូលគាងឃ្វាយ ដែលពេញដោយពួកកញ្ញាទាំងឡាយនេះ ក៏ទូលព្រះបង្គំជាខ្ញុំសូមថ្វាយចំពោះព្រះអង្គដែរ ។

ព្រះមហាសត្វទ្រង់ព្រះសណ្តាប់ពាក្យមហាជននោះហើយ ក៏ទ្រង់ក្រោកឡើងសន្សឹមៗ ទ្រង់មានព្រះពាក្យតម្រាស់ត្រាស់សួរថា "ម្នាលអ្នក

តាំងឡាយដ៏ចំរើន, ចុះស្តេចរបស់អ្នកតាំងឡាយទៅណា?" ។ ពួកមហាជន
ក្រាបបង្គំទូលស្នងព្រះពុទ្ធដ្ឋានវាថា "បពិត្រព្រះសម្ពារ, ព្រះពុទ្ធារបស់ទូល
ព្រះបង្គំជាខ្ញុំទ្រង់ព្រះទិវង្គតហើយ" ។ - ចុះព្រះពុទ្ធបុត្រ ព្រះពុទ្ធធីតានឹង
ព្រះពុទ្ធវង្សានុវង្សរបស់ព្រះអង្គទៅណា? ។ - សូមទ្រង់ព្រះមេត្តាប្រោស,
គ្មានទេ ។ - អើ! បើដូច្នោះ ខ្ញុំនឹងទទួលតាមពាក្យអ្នកតាំងឡាយបាន ។
ពួកមហាជនឮព្រះពុទ្ធដ្ឋានត្រាស់ទទួលហើយ តំរៀបអភិសេកក្នុងទី
នោះ ។ ព្រះអង្គទ្រង់ថ្កើងដោយព្រះយសជាអស្ចារ្យ ទ្រង់ស្តេចទៅកាន់
ទីណាក៏ទីនោះតក្រើកអំពើតញាប់ញ័រ ។ ពពួកមហាជនប្រគំភ្លេងតូរ្យ-
តន្ត្រីឡើង ឮសូរសំឡេងហឹងអឹងអាប់ហាក់ដូចជាសូរសំឡេងលាតក្នុងផ្ទៃ
មហាសមុទ្រ ។ ពួកអាមាត្យក៏នាំព្រះអង្គមកគាន់ព្រះនគរ ចោមរោម
ឈូឆរហែឡើងទៅលើប្រាសាទស្ទាតសោភា ។ ទើបព្រាហ្មណ៍
បុរោហិតនាំគ្នាចូលទៅក្រាបបង្គំទូលអំពីចំនួនព្រះពុទ្ធទ្រព្យ ដែលមាន
នៅគ្រប់ក្រមថា ៖

នេះពលដំរី នេះពលសេះ នេះពលរថ នេះពលថ្មើរជើង
ព្រមទាំងព្រះពុទ្ធនិវេសន៍នេះផង ទាំងស្រីព្រះស្នំដែលស្អិត
ស្អាងតែងអង្គចាំគាល់បំរើនេះផង ទូលព្រះបង្គំទាំងឡាយ
សូមថ្វាយចំពោះព្រះអង្គ, សូមទ្រង់ទទួលប្រើប្រាស់តាម
សព្វព្រះពុទ្ធហ្ឫទ័យ ។

តាំងពីពេលនោះរៀងមក ព្រះអង្គទ្រង់ធ្វើការកុសលមានទានជាដើម ព្រះអង្គទ្រង់សោយរាជ្យប្រកបដោយទសពិធរាជធម៌ ឥតមានមោះមន្ទិលឡើយ ។

ចំណែកខាង ព្រានសំណាញ់តាំងពីនាក់ ប៏ចាប់ថែរក្សាព្រះរាជបុត្រតាំងពីព្រះអង្គ ដូចកូនដែលលេចចេញពីសាច់របស់ខ្លួន ។ លុះកុមារតាំងនោះចំរើនធំឡើង ព្រានសំណាញ់ក៏នាំគ័ស្តុការបណ្ណាការទៅក្រងតកសិលាថ្វាយកុមារតាំងពីរនោះឲ្យជាឰរាជការ ។ គ្រានោះ ព្រះរាជាទ្រង់ឃើញកុមារតាំងពីរនោះហើយ ទ្រង់ត្រាស់សួរថា "កុមារតាំងពីរនេះកូននរណា?" ។ ព្រានសំណាញ់ក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាជ្រាស កូនរបស់ទូលព្រះបង្គំជាខ្ញុំ" ។ ព្រះរាជាទ្រង់ត្រាស់សួរទៀតថា "ម្តេចក៏កុមារតាំងនេះមានរូបល្អល្អះ គួរជ្រះថ្លាគួរពេចពិលរមិលមើលដល់ម្ល៉េះ មិនស្រដៀងនឹងអ្នកតាំងឡាយសោះដូច្នេះ?" ។ - សូមទ្រង់ព្រះមេត្តាជ្រាស, កុមារតាំងនេះកាត់ចាន់ទៅខាងម្តាយ ។ លំដាប់នោះព្រះរាជាទ្រង់ព្រះចិន្តាថា "ត! កុមារតាំងនេះដូចកូនអញណាស់តើហ្ន៎! បើសិនជាកូនអញនៅ ល្មមលើកមកធៀបនឹងគ្នាបាន" ក៏ព្រះអង្គមានព្រះរាជហឫទ័យស្រឡាញ់កុមារតាំងនោះដូចជាព្រះរាជបុត្រ ។ ឯកុមារតាំងនោះក៏មានប្រាជ្ញាស្មារតីធ្វើឆ្ងាតសមគួរជាព្រះអង្គម្ចាស់ ។ ព្រះរាជាទ្រង់ឃើញឫកមារយាទកុមារនោះល្អ ក៏មានព្រះរាជហឫទ័យជ្រះថ្លារីករាយ ទ្រង់ប្រទានយសសក្តិឲ្យឡើងជានាយត្រកាល ។ (មានត)

(សិសោរដាតក)

# ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ឹង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមគម្រោយសាស្ត្រាស្នឹកវិត

(តមក)

---

ស្តេចអត់ក្រយាស្ងោយ ពុំបានសោយតិចខ្លីយនៃ
សន្ធឹកវ័ណសន្ធៃ កៀកមនោម៉យហើយសោកា ។
ស្តេចទ្រង់ព្រះកន្សែង ព្រះនុស្ងថ្ងែងទៀងទួញថា
"នុះនុ ! គួរអនិច្ចា ខ្ញុំនាគ្នាមកវិបត្តិ ។
ប្រាសព្រាត់នគរ មកវេទនាពន់ពេកក្តាត់
វង់ទោសវង់វិបត្តិ ប្លែកត្រកាលកណ្តាលព្រៃ ។
វីទុក្ខទាំងនេះណា ជាផលកម្មចង្រៃ
ពុំគឺអ្នកដទៃ គឺអញឯងធ្វើមកណា ។
ព្រោះអញគ្មានជំនឿ ពុំព្រមជឿពាក្យហោរា
ទើបវង់វេទនា កុងវេលាគ្រានេះឯង ។
នុះនុ ! ខ្ញុំនអញអើយ ពុំគួរខ្លីយមកចំបែង
ធ្វាប់នៅទីកន្លែង ប៉ុរីរម្យសមសំពន្ធ ។

កាលដល់យាមព្រឹកស្អែក តែងធ្លាប់សោយដោយសុខសាន្ត
កន្លែកាជន៍មាសថ្កើងថ្កាន ពុំដែលមានក្តីសៅហ្មង ។
យាមផ្ទាំងសុខសែន លើព្រះខែនល្អកន្ទុង
សឹងក្រាលកម្រាលផង មានសម្ផស្សខ្ទង់ត្រជាក់ ។
យាមគង់ៗបល្ង័ង្ក មានគ្រឿងតាំងសឹងចំឡាក់
មន្ត្រីនូវសេវ័ក ស្មុគគាល់គាល់ត្រៀបត្រា ។
ឥឡូវព្រាត់ប្តី តើបានអ្វីគាន់កោក្តា
មានតែទុក្ខវេទនា ជាតំណាងតាងចំណី ។
ពេលដេកត្រូវដេកលើ ពូកស្លឹកឈើក្រាលផ្កាល់ដី
ពេលគង់ៗទុក្ខី ក្រោមដើមដៃជែតែឯកា ។
ពុំមានស្មុគគាល់ សម្រាប់គាល់ដូចជម្មតា
មានតែសេះនេះណា ជាសំឡាញ់រួមសុខទុក្ខ ។
ទឹងមានតែចន្ទ្រា ជាជ្រាលាជួយឲ្យសុខ
ជំនួសភ្លើងត្រជាក់ ដែលធ្លាប់មានកន្លែងបុរី ។
ឮតែសូរសត្វយំ កន្លែងូរគមដួសតន្ត្រី
យកតែសត្វបក្សី ជាវចាំប្រចាំថ្ងៃណា ។
ឧ! ខ្លួនអញឯងនេះ ទុក្ខខ្លាំងម្ល៉េះពេញហៅហាន
តើខ្លួនអញនឹងបាន រឿងអ្វីគាន់កោក្តា ។

អញនឹងអង្គុយលើ　　ស្មៅស្វឹកឈើម្តេចទៅរ៉ា
លុះត្រឹកព្រាងសុរិយា　　បាននរណាបង្ហាញផ្លូវ ។
បើអញពុំដឹងថា　　ទៅខាងណាទើបបានត្រូវ
បើបោះអញនេះកូវ　　គង់តែត្រូវស្លាប់ជាម្ពង ។
គិតហើយរងឹតែគិត　　អញអាណិតតែនួនល្អង
អានន្តទើបង　　នាងនឹងបានតែក្តីទុក្ខ ។
នាងមិនឃើញអាត្មា　　ជាកស្តាប់ដួមសុខ
ពីថ្ងៃនេះទៅមុខ　　មានតែទុក្ខជាអំណោយ ។
នាងនឹងក្មេចស្អាងអង្គ　　ក្មេចស្រែស្រងំក្មេចព្រៃស្វាយ
ហើយនាងនឹងត្រូវសោយ　　តែទឹកនេត្រជួសកោដន ។
ទុះទ្រុស់ប្រមប្រិយ　　ម្ទេះសមស្រីនាងទុក្ខធ្ងន់
ឥតល្អែឥតស្រាកស្រន់　　ទំពំចួបនឹងរៀមរ៉ក" ។
ស្តេចសោក ។ រៀបពាប់　　តាមតែគាប់ចិត្តទុក្ខជាក់
ស្រែចហើយព្រះចមចក្រ　　ផ្ទៀងព្រះកាយផ្ងំនិទ្រា ។
លុះត្រឹកព្រាងស្រែចហើយ　　ពុំលង់ឡើយព្រះពាជា
ស្តេចតើនចាកនិទ្រា　　ទើបក្សត្រានឹកវិពៃ ។
មិនដឹងនឹងដើរទៅ　　ស្ថានលំនៅឯណានៃ
ស្តេចគិតយកមនោម័យ　　ដឹកកាត់ព្រៃដងអាជ្ញា ។

สีងមានស្បៃ ๆ ស្បាត ដុះញឹកញាតច្រៃនមហិមា
ឈើផងសីងបន្ទា មុតបាទាលំអាកវិក្រ ។
ស្តេចយាងទៅពុំបាន ទើបក្សត្រក្សាខ្ពង់ឡើងអាជានេយ្យ
បរកាត់ទំលាយព្រៃ រង្គងពុំដឹងមាគ៌ា ។
ស្តេចបរព្រៃទីនាំង អស់កំឡាំងទន់កាយា
ស្តេចឈប់បេះផលា សោយហើយណាបរទៀតទៅ ។
ស្តេចទតព្រៃព្រឹក្សា ច្រៃនត្រៀបត្រានាព្រៃជ្រៅ
ដើមដុះច្រែងច្រាងទៅ ស្តេចគិតទៅដល់ដំណោក់ ។
នឹកនាងនាថអានុភ្ន- ទើតន់ធោមរលំក្តណ៌
ទឹកនេត្រហូរសស្រោក់ ស្រោចព្រះកន្ត្រកដោយព្រៃទៅ ។
មើលមានហ្វូងសត្វម្រឹគ ដើរគគឹកវកស៊ីស្មៅ
ស្តេចឆ្ពៀងព្រះនេត្រទៅ ទតអស់ម្រឹគផងពាំងព្រៃយ ។
រមាំង, រមាស, ខ្លា, គោ, មហិង្សា, ពាំងច្រៃស, ត្រយ
ទន្សាង, ខ្លូវទន្សាយ ស្វាន, ចចក ពាំងធ្នាប់ ។
ខ្លះបោលកៀងកាល់ញី ខ្លះវកស៊ីក្រោមព្រឹក្សា
សត្វផងច្រៃនណាស់ណា ក្រៃនឹងរាប់នឹងគណនា ។
ស្តេចទតអស់ពាំងម្រឹគ ហើយស្តេចនឹកនគរា
ព្រះឧស្តង្គថ្លែងពួញថា "ម្ន៎! អាត្មាអញានេះនៃ ។

ភ្ញាប់ទៅសោយសម្បត្តិ ឥឡូវភ្លាត់មកដោយព្រៃ
ឃើញតែសត្វទីថៃ ទឹងដើមលេបីដូច្នេះណា ។
ន! សត្វផងតាំងឡាយ ឯងសប្បាយដោយត្រីកូ
ប្រដេញប្រដោលគ្នា កៀងគូរចោលប្រឡែង ។
ខ្លះដេកខ្លះដើរទៅ រកស៊ីស្មៅដោយឥតក្រែង
ខ្លះឈរនៅកន្លែង កូនប្រឡែងនឹងមេវា ។
ក្រមើឡើងកកល់ អួតគ្នាដល់ដើរវេរ
ងើយងឹមមកកេគ្នា ចោលកន្លែងលេងសប្បាយ ។
គោស្ទៀងស៊ុះស៊ុះចោលលេង លោតកញ្ឆេងជើង៤ច្រាយ
ដីជាប់ដូចគេកាយ ចោលទៅឆ្ងាយហើយវិលវែង ។
ន!សត្វផងតាំងឡាយ ឯងសប្បាយអីម្ចឹង ។
អនិច្ចាខ្លួនអញហ្ន៎ឹង កើតទុក្ខតឹងម្នាក់ឯងណា ។
ន!កម្ម ។ តីព្រៃឯង ឲ្យអញឯងកើតទុក្ខា
ម្នាក់ឯងតែឯងា ឥតអ្នកណាជាតីវែង ។
មានតែសេះនេះណា ចូនជាគ្នានឹងអញហោង
ដឹកហើយដុះលើខ្នង ឥតមនុស្សផងជា ២ នាក់" ។
ស្តេចសោកហើយអនិច្ចា ទឹកនេត្រាហូរសស្រាក់
ដល់នេត្រស្រោចព្រះកន្ត្រក ហូរហៀរភ្នាក់សត្វដោយព្រៃ ។
.....

ស្តេចយាងសោកបណ្តើរ  ក្សត្រៃបសើរទេល់ទុក្ខក្រៃ
ព្រះនេត្រាវៃ  ឃើញសត្វក្រៃពេចន៍ត្រៀបត្រា ។
គោក្រៃពន្ធូវញី  ប្តូរអូសដ៏សម្បុរច្បា
ស្នែងស្រួចដូចបន្ទា  ពេចន៍ត្រៀបត្រាញីឈ្មោលផង ។
ឯឈ្លូសនុនស៊ីស្មៅ  ខ្លាលបង៉ៅពីក្រោយខ្នង
លោតទះឈ្លូសជាម្តង  ខុសឯឈ្លូសត្រែវតែដី ។
ឯឈ្លូសស៊ុះចោលង៉ៅ  ចូលក្រៃជ្រៅនៅវាហ៍
ខ្លាសោតលោលោតប៉ុ  លឡកស្នៀតរីតែឯង ។
ជ្រកក្រៃពេចន៍ឥតបី  នុនឈ្លូសដ៏ខ្លះទន្ទឹង
កញ្ជេងលោតប្រទ្បែង  ដេញគ្នាឯងលេងសប្បាយ ។
កីលែនទូវកីកា  ទាំងអូដ្ឋលាផងទាំងឡាយ
ដោយបនដោយហូងហ្វាយ  ដើរវៀងពយក្រៃលែង ។
ស្តេចទតអស់សត្វផង  ពេចន៍កន្ធងគួរស្រប់ស្រែង
កន្ធង់ទ្រែងរឹងចំបែង  ខ្លាចដំរីរមាសខ្លា ។
ស្តេចហួសពីនោះង៉ៅ  ចូលក្រៃជ្រៅដងអាត្មា
មើលមានក្រៃត្រីក្បា  ដើមក្រស្នាក្តាំតាកុផង ។
ចំប៉ីទូវចម្ប៉ា  ទាំងក្តាំងងាពុំសែនហោង
ផ្តឹក, កាំង, ត្រាំង, ភ្លូកូង,  ស្តីស្តៅផងអង្គាញ់ណា ។

ត្រីង, ត្រួស, ស្វាតស្វាយចន្ទ  ក្រូចក្រពន់ចន្ទន៍ក្រស្នា
ទន្ទាប់ខ្នូវទន្ទា  ត្រែស, អង្គារ, អង្កោល, ត្នោត ។
ត្រាក្តៅខ្នូវសណ្តាន់  រៃដែលំពាន់លំពស់ពោត
ក្រកោះក្រឡាញលោទ  ត្រាចត្បែងខ្នុងពង្រៃឃ្មុំ ។
ស្តេចយាងធ្វើងនេត្រា  យល់ព្រឹក្សាស្រោងត្រឈៃ
ត្រឈឹងលូតលាស  សត្វផងទំយំទ្រហឹង ។
ស្តេចស្តាប់សព្ទមាត់រៃ  យំក្នងរៃរៃកណ្តឹង
ព្រះនេត្រស្តេចសំឡឹង  ឃើញកូរំងទំខ្នូ ។
ត្រសេកត្រសេះទំ  សត្វសេកយំទំដើមត្រា
ពក្សាក់ទំពក្សា  សត្វទាទំដើមស្តៅ ។
សារិកាហើរទៅទំ  ចាប់ខ្ទេទំដើមតាត្រៅ
លលកហើរសំដៅ  ចុះទំនៅដើមពង្រំកុ ។
សត្វសេកសោមបណ្ឌិត  ទំនៃបនិត្យដើមសូកំ
ពពួលហើរទៅទំ  នាដើមកូម្ពវិក្សារដើមក្រ ។
ទ្រមែងខ្មែងទំមែក  ត្រលែងវែកទំដើមញ
ពពេចទំពាក់ស  រន្ធពង្រិតង្រួលនៅ ។
ការិកយំពីពោះ  ហើរផ្លេកផ្លោះទំដើមញៅ
រន្ធបង្កៀងធាបទៅ  ចុះទំនៅដើមត្រសាំង ។

(មានត)

កណ្ឌទី ១៩

# ឧកញ៉ាវិបុលរាជសេនា ន្ង-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាជវង្សឆ្លាសបើបានអាន
ធឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯម៉ាថេងចៅហ្វាយស្រុកសៃលៀងដែលចូលទៅខៅក្នុងក្រុងហ៊ូគោ នោះ ចានរួមគំនិតនឹងឡាពី, តាំងសុិន ដើម្បីនឹងរំលាងកំចាត់ចូរួចញ តាមឡាយព្រះហស្តព្រះចៅហៀនតេ ។ លុះឡាពីលើកទ័ពចេញទៅ ហើយ ទ្វួលមានបំរើចូលទៅប្តឹងម៉ាថេងថា ឥឡូវមានកើតសឹកក្នុង ស្រុកសៃលៀង ។ ម៉ាថេងក៏ចូលទៅគ្រាបបង្គំលាព្រះចៅហៀនតេ ហើយប្រមូលកងយោធារបស់ខ្លួនលើកចេញទៅស្រុកសៃលៀង ។ ឯ ឡាពីកាលលើកទ័ពទៅដល់ស្រុកឈីជីវ គឺមៅដែលចូរួចឲ្យទៅកំងរក្សា

ស្រុកនោះដឹងថា ខ្លៅពីលើកទ័ពមកកំចេញទៅឧលនាំចូលទៅក្នុងទីគេហស្ថាន ហើយឲ្យរៀបតុៈលៀងកោជនាហារ ។

ឯស៊ុនខៀនទឹងប៊ីតុកដែលនៅវក្សាគ្រប់គ្រងរាយបុត្រខ្លៅពី លុះដឹងថា ខ្លៅពីត្រឡប់មកកំមានសេចក្តីត្រេកអរណាស់, នាំគ្នាទៅជួបទទឹងខ្លៅពី ហើយពណ៌នាពាយរឿងពីសេចក្តីសុខទុក្ខគ្រប់គ្រងរបស់ខ្លៅពីជាប្រក្រតី ។ ខ្លៅពីក៏មានសេចក្តីសោមនស្សសោទរណាស់ លាតីមៅទៅកាន់ទីគ្រប់គ្រងរបស់ខ្លួន ។

ខណៈនោះ មានបំរើសេះចូលមកប្តឹងពីកិច្ចការ ដល់ខ្លៅពីថាអ៊ួនសុតធ្វើការទុច្ចរិតអាក្រក់ លុយប៊ុតទឹងតាន់ឡាន់ដែលជាសេនាអ្នកសុតបានសេចក្តីក្តៅក្រហាយ ក៏នាំកូនតាហានរត់ទៅនៅធ្លើចោរក្នុងព្រៃឥឡូវអ៊ួនសុតលើកគ្រប់គ្រងទឹងសារពើទ្រព្យសម្បត្តិ នាំយកគ្រាសម្រាប់ការទទឹងទៅប្រគល់ឲ្យអ្នកសៀវជាបង បានមកដល់ព្រំដែនស្រុកឈីជីវហើយ ។ ខ្លៅពីបានឮដូច្នោះ ក៏នាំពលទាហានលើកចេញពីស្រុកឈីជីវទៅ បានប្រទះទឹងកងទ័ពតីឡែងជាទ័ពស្រួចនៃអ៊ួនសុត ។ តឿវហ៊ុយកំបរសេះចូលទៅច្បាំងទឹងតីឡែងបាន ១០ ភ្លេង តឿវហ៊ុយវៃស្រកគំហកដោយសំឡែងខ្លាំង សេះតីឡែងក៏ភ្ញាក់ស្ទុះថយក្រោយ តឿវហ៊ុយបានកល់ការ ក៏ដេញចូលទៅយកជាវកាប់តីឡែងធ្លាក់ពីលើសេះស្លាប់ ។ ទាំហានតីឡែងក៏បែកខ្ចាត់ខ្ចាយរត់ទៅដល់អ៊ួនសុតៗ ដឹងថាតីឡែងស្លាប់ក៏ទឹកចិត្តណាស់ បង្ខំលើកទ័ពធំចូលមកតទឹងទ័ពខ្លៅពី ។

ឡៅពីក៏ប្រើគួនអ៊ូ, តៀវហ៊ុយជាទ័ពបែកស្តាំ ឲ្យជូឡេងទឹងឡៅវ ជាទ័ពបែកឆ្វេង ឡៅពីជាកងកណ្តាល ហើយបង្គាប់ឲ្យទំពប៉ែកស្តាំទឹងឆ្វេងថា បើឃើញអ៊ួនសុតចូរាំងដេញយើងមក អ្នកទាំង ២ កងចូរលើកកងទ័ពខ្ញុំរាយទាំងសងខាងឲ្យមាំមួន ។ លុះអ៊ួនសុតលើកទ័ពមកដល់ ឡៅពីក៏បរសេះចេញទៅមុខទាហាន ហើយរៃសែកដេរអ៊ួនសុតថា អាក្សត់ មឹងមិនដឹងថ្ងៃនេះទឹងស្លាប់ទេឬ? មឹងបានគ្រាសម្លាប់ពស់រហើយ តាំងខ្លួនជាស្តេច ឥឡូវព្រះថៅហៀនតេឲ្យអញលើកកងទ័ពមកបង្ក្រាប បើអាឯងស្រឡាញ់ជីវិតចូរប្រញាប់ចុះមកពីលើសេះមកគំនាប់អញ បើអាឯងនៅរឹងទទឹងមិនព្រមចំណុះអញទេ អាឯងព្រមទាំងញាតិសាលោហិតទឹងស្លាប់តាំងអស់គ្នា ។

អ៊ួនសុតបានឮដូច្នោះខឹងណាស់ "ក៏រៃសែកដេរឡៅពីថា ខ្លួនអាឯងអួតថាកាន់ព្រះតម្រាស់ ទឹងឲ្យអញចំណុះចុះចាញ់នោះ អញមិនត្រូវការទេ ថ្ងៃដែអាឯងយ៉ាងណាអញក៏ដឹងហើយ អាឯងធ្លាប់សម្លាប់នរណាស្លាប់ខ្លះ?" ថារហើយអ៊ួនសុតក៏បង្ខំបរពលចូលតយុទ្ធនឹងទ័ពឡៅពីជាគោឡាហល ។

ឡៅពីក៏បរពលចូលហើយធ្វើជាចយត្រឡប់ទៅក្រោយ អ៊ួនសុតឃើញបានការ ក៏ដេញតាហានតាមគ្នាចូលទៅ ឡៅពីក៏បរពលទល់គ្នាប្រចាក់ប្រកាប់ជាច់ដៃទៅវិញទៅមក ។ គួនអ៊ូ, តៀវហ៊ុយនឹងជូឡេង,

ឡដៀវដែលជាបែកធ្លែងស្តាំ ឃើញថាគ្មានការហើយក៏បរទេលចូលវាយរួបតាំងសង្គាមជុំវិញកងទ័ពអ្នឧសុត ។ ខាហានឡៅពីដេញតាមសម្លាប់ខាហានអ្នឧសុតស្ងាប់ពិការជាច្រើន សាកសពដែលស្ងាប់នោះគរលើគ្នាដូចជាគំនរអុសឈើពាសពេញប្រហពី ឈាមហូរដេរជាស្រះធរណីជាទីពន្ធឹកមហិមា ។ កងទ័ពអ្នឧសុតក៏បែកខ្ចាត់ខ្ចាយរត់ព្រាត់ព្រាយពីគ្នាអស់ទៅ ។

ឯលុយប៉ុកនឹងតាន់ឡាន់ដែលជាសេនាអ្នឧសុត រត់ទៅធ្លើចោរព្រៃនោះលុះភ្លឺថា អ្នឧសុតបង្ក៏ងគ្នានឹងឡាពី លុយប៉ុកនឹងតាន់ឡាន់ក៏លើកពួកចោរទៅវាយយកទ្រព្យរបស់ នឹងស្បៀងអាហាររបស់អ្នឧសុតបានជាច្រើន ។ ពេលនោះ អ្នឧសុតដែលបែកទ័ពខ្ចប់ខ្ចាតគ្រឿងសស្ត្រាវុធនឹងស្បៀងអាហារដឹងថា ពួកចោរចាំងឡុយលើកគ្នាទៅស្លាក់វាយដណ្តើមយកទ្រព្យរបស់ទឹងស្រែអង្គរស្បៀងអាហារអស់ទៅទៀត អ្នឧសុតក៏នាំគ្នាត្រឡប់ទៅឈប់នៅតំបន់កាំងតេង សល់តាហានសុទ្ធតែមនុស្សចាស់ជាប្រហែល ១ ពាន់ប្លាយ សល់ស្រែវគោជន៍សល់ប្រហែល ៣០ រនេះ មនុស្សចាស់ជាចាំងៗក៏អត់ឃ្លាន ដោយជាប់ស្បៀងអាហារស្ងាប់ទៅខ្លះ ដើរសុំបានអ្នកស្រែកបានមកបរិភោគក៏មិនឆ្អែតខ្លះ ។

កាលអ្នឧសុតទៅនៅកងតំបន់កាំងតេងនោះ ជារដូវគិម្ហន្តក្តៅណាស់ ភរិយាឬត្រចាំងឡាយក៏មានចិត្តក្តៅក្តួលខឹងនឹងអ្នឧសុត ដែលធ្វាប់ធ្វើទុក

ទោសបុកម្នញមកពីដើម ក៏យកស្រូវគោជន៍សាលីតាំងសំបកដាំបាយឲ្យ
អ្ន៊ួនសុតបរិភោគ ។ អ្ន៊ួសុតក៏ថា យើងលេបមិនចុះទៅកន្លងបំពង់គេ ឲ្យ
រកទឹកឃ្មុំមកឲ្យយើងលាយថ្នាយស៊ុ ។ អ្នកផ្ងើថ្នាយឮក៏ខឹងឆ្ងើយថា ឧន
រកទឹកឃ្មុំឯណាថ្នានកន្លងនេះ មានតែឈាមមនុស្ស ។ អ្ន៊ួនសុតឮដូច្នោះក៏
មានសេចក្តីតូចចិត្ត ស្រែកគំហកគំរាមដោយសំឡេងខ្លាំង ក៏ក្អួតឈាម
ចេញមកប្រហែល ១ នាឡិ ដួលផ្ងាក់ពីលើគ្រែក៏ដាច់ខ្យល់ស្លាប់កន្លងនោះ
កាលអ្ន៊ួនសុតស្លាប់នោះ ព្រះថោរហ្នេតយាងទៅតង់ទៅក្រុងហ្ស៊ូគោ
ថ្នាន ៤ ឆ្នាំ ៨ ខែ ។

ឯអ្ន៊ួនអ៊ុនជាកូយឃើញអ្ន៊ួនសុតជាមស្លាប់ ក៏លើកសពដាក់លើក្តារ
ឈូសហើយនាំគ្រប់គ្រួនឆ្ងៃគ្រាសម្រាប់ពជ្យ គ្រឡប់ទៅស្រុកឡាំយ៉ុង
លុះទៅដល់ស្រុកលោកាំង ឈ្មោះឈើដីរ៉ប៉ង់ពួកអ្នកស្រុកលោកាំងដឹង
សេចក្តី ក៏លើកប័ក្សពួកទៅស្ថាត់ពួយអ្ន៊ួនអ៊ុន ឈើដីរ៉ប៉ង់ក៏សម្លាប់អ្ន៊ួនអ៊ុន
ឆ្ងៃគ្រប់គ្រួអ្ន៊ួនសុតស្លាប់តាំងអស់ ហើយយកគ្រាសម្រាប់ពជ្យនោះទៅឲ្យ
ចួបក្រុងក្រុងហ្ស៊ូគោ ។ ចួបចួបានគ្រាសម្រាប់ពជ្យនោះក៏មានសេចក្តីសោ
មនស្សគ្រែកអរណាស់ ហើយតាំងឈើដីរ៉ប៉ង់ជាថៅហ្វាយស្រុកគោ-
ឡេង ឧនឲ្យបំណាច់រង្វាន់ ។

ឯឡៅពីលុះដឹងថាអ្ន៊ួនសុតស្លាប់ហើយ ក៏ធ្ងើសំបុត្របកឲ្យជូឡេង
ឆ្ងៃឡរជៀវគាន់ចូលទៅគ្រាបបង្គំចូលថ្វាយព្រះថោរហ្នេតគ ឧនជូន

ដំណឹងពីការឲ្យចូឆូជ្រាបតាមដំណើរ ដែលបានប្រាំងនឹងអ្នកសុតនោះ រហូតអ្នកសុតបែកចិត្តទៅនៅតំបន់កាំងតេង, ឯការហាន ៥ ម៉ឺននោះឡើយ សុំទុកនៅក្សត្រស្រុកឈីជីវ ។

ដូឡេងនឹងឡៅកើតខ្លួលយកសំបុត្រនោះ ស្រួតត្រួតចូលទៅជូនចូឆូឯក្រុងហ៊ូគោ ចូឆូឃើញសំបុត្រដូច្នោះក៏ខឹងណាស់ថា យើងប្រើអ្នកទាំង ២ នាក់ឲ្យការនាក់ការបក់កងចិត្តទៅជាមួយនឹងឡើយ ហេតុម្តេចបើអ្នកត្រឡប់មកមិននាំយកការហាន ៥ ម៉ឺនមកផង ក៏ឲ្យនៅនឹងឡើយពីរទាំងអស់" ថាហើយក៏បង្គាប់ពេជ្ឈឃាដឲ្យចាប់ខ្លួនដូឡេងនឹងឡៅទៅនឹងប្រហារជីវិត ។

ស៊ុនហុកក៏ដំរាបចូឆូថា លោកចាត់ប្រើឡើយពីធ្វើជាមេទ័ពការនាំអាជ្ញាសិទ្ធិទៅធ្វើការក្នុងវឿនវង្គសង្គ្រាម; ឯដូឡេងនឹងឡៅឲ្យធ្វើជាកូនកងទ័ពនៅក្រោមបង្គាប់ឡើយពីរ យកការហាន ៥ ម៉ឺនទុក ហើយប្រើដូឡេងឡៅឲ្យការនាំសំបុត្រចូលមកប្តឹងពីការនោះ សូម្បីដូឡេងនឹងឡៅមានដំរេះប្លាស់ប្តូរយ៉ាងណា ក៏មិនអាចនឹងទទឹងបង្គាប់ឡើយបាន ដែលលោកនឹងឲ្យសម្លាប់អ្នកទាំង ២ ប្លាណាចេញនោះ សូមឲ្យលោកត្រិះរិះមើលតាមការគួរសិនចុះ ។ ចូឆូបានស្តាប់ក៏យល់ថាត្រូវ ព្រមលើកទោសដូឡេងនឹងឡៅឲ្យរួចខ្លួន ។ ស៊ុនហុកដំរាបទៀតថា គ្រានេះលោកក៏បានយើញច្បាស់ពិតប្រាកដ ថាឡើយពីប្រែចិត្តចេញអំពីលោក

បើនឹងសៀមទុកយូរយើញថា សឹកសត្រូវនេះនឹងកំរើកចិត្តប្រទូសរ៉ាយវិញពុំខាន ។

ចូរួយើញត្រូវកំធ្វើសំបុត្រសម្ងាត់តាមិតាក្យស៊ុនហុកថា, ហើយប្រើមនុស្សខំនុំកទុកចិត្តឲ្យនាំទៅឲ្យគីមៅ ។ ដឹងក្នុងសេចក្តីសំបុត្រនោះហើយក៏ឲ្យហៅខ្លួន តាន់តេង៉មកប្រឹក្សា តាន់តេង៉ធ្វើយថា ការប៉ុណ្ណេះកំលុមនឹងគិតធ្វើបាន ព្រោះឥឡូវឡៅពីចេញទៅតាំងបញ្ជុះបញ្ជាលមនុស្សនោខាងក្រៅស្រុកពាល់ថ្ងៃជានិច្ច ពេលព្រឹកនេះសុំឲ្យលោកចាត់ទាហានទៅបង្កប់ទុកសង៉ខាងផ្លូវ បើកាលណាឡៅតីនឹងវិលចូលមកក្នុងស្រុកវិញ កំឲ្យទាហានដែលបង្កប់នោះចេញស្កាត់ចាប់សម្លាប់ចេញ ខ្លួនឱ្យបានឧន៏លើកទាហានទៅនៅលើកំពែង បើគួនអ៊ូ. តៀវហ៊ុយលើកតាមមក ខ្ញុំនឹងឲ្យទាហានបាញ់ធ្លាក់ទល់ទុកមិនឲ្យគួនអ៊ូ តៀវហ៊ុយ ចូលស្រុកបានការទាំង៉ពួង៉កំនឹងបានសម្រេចដោយងាយ ។ គីមៅយល់ឃើញត្រូវតាន់តេង៉កំលាគីមៅទៅដួបនឹងតាន់គុយជាបិតា ហើយពណិនាកយរឿងឲ្យស្តាប់គ្រប់ប្រការ ។ តាន់គុយនិយាយថា ឡៅតីនេះជាមនុស្សមានសតិបញ្ញាណាស់ ចាំងចិត្តថ្លៃមក៏ល្អកេះរាយរាក់ទាក់នឹងពួកម៉ាកហើយជាពួជព្រះពជវង្សព្រះចៅហៀនតេ ដែលបូធ្លុះគិតនឹងធ្វើប្រទូសរ៉ាយឡៅតីនោះ ហើយយើងចូលគំនិតធ្វើអាក្រក់នឹងឡៅតីទៀតមិនគួរទេ ត្រូវតែយើងទៅប្រាប់ឡៅតីឲ្យដឹងខ្លួនវិញ នោះទើបជាការប្រពៃ ។

តាន់តេង៑បានឮបិតាថាដូច្នោះ កំផ្ទាស់ត្រឡប់ចិត្តគិតយើញត្រូវ
ផង តាន់គុយក៏ប្រើតាន់តេង៑ឲ្យលបចេញទៅច្រាប់ឡៅពី លុះទៅដល់
កណ្តាលផ្លូវប្រទះនឹង៑គួនអ៊ូ តៀវហ៊ុយលើកគាហានមកមុន តាន់តេង៑ក៏ថ្លែង
រឿង៑ពីវដែលចូតួមានសំបុត្រមកឲ្យគីមៅសម្លាប់ឡៅពីចេញនោះ ឲ្យគួនអ៊ូ,
តៀវហ៊ុយ ស្តាប់គ្រប់ប្រការ ។ គួនអ៊ូ, តៀវហ៊ុយ ឃានឮដូច្នោះខឹង៑
ណាស់ ។ តៀវហ៊ុយថា ដែលគីមៅគិតសម្លាប់បង៑យើង៑នោះ ត្រូវតែ
យើង៑នឹង៑ធ្វើការកាច់ឫលាយយកស្រុកនេះឲ្យបានជាមុន កុំឲ្យគីមៅវិះគិត
ធ្វើយើង៑ឃានមុនឡើយ ។ គួនអ៊ូថា គីមៅនៅក្នុង៑កំពែង៑ប្រុង៑ប្រៀប
រៀបបំរុង៑សេនាគាហានជាស្រេច យើង៑នឹង៑លើកចូលទៅច្បាំង៑ខាង៑ក្នុង
គង់នឹង៑ឃ្លោះការ ត្រូវតែបង្អង់ឈប់នៅទីនេះសិន ចាំពេលយប់សុំចាត់
ការឲ្យគាហានចូតួដែលនៅនឹង៑យើង៑នោះ ចូលទៅស្រែកហៅគីមៅថា
ចូតួប្រើតៀវលៀវឲ្យមកនិយាយការជាប្រញាប់ ឲ្យអញ្ជើញគីមៅ
ចេញមកជួបនឹង៑ឃានិយាយការជាអាថ៌កំបាំង៑បន្តិច លុះគីមៅចេញមក
ខាង៑ក្រៅក្រុង៑ យើង៑នឹង៑លើកគាហានចូលចាប់សម្លាប់ចេញ ។ តាន់
តេង៑តបថា បើលោកចាប់គីមៅមិនបាន គីមៅមុខជានឹង៑ត្រឡប់ចូលក្នុង
ក្រុង៑វិញ ខ្ញុំនឹង៑ឲ្យគាហានចាញ់ជស្លាត់” ថាហើយតាន់តេង៑ត្រឡប់
មកវិញតាន់គុយ ។

លុះវេលាយប់យាម ២ គួនអ៊ូទើបឲ្យគាហានកាន់ទង់សំគាល់របស់ចូឆួ ចូលទៅដល់ដើងកំពែង ហើយប្រាប់នាយទ្វារថាមហាឧបរាជឲ្យតៀវលៀវមករកគីមៅទីង ប្រាប់សេចក្តីអាថ៌កំបាំងមួយ ។ នាយទ្វារក៏នាំសេចក្តីនោះទៅជំរាបគីមៅ ។ ក៏ឲ្យហៅរកតាន់តេងមកប្រឹក្សាថា ឥឡូវមានគាហានមកប្រាប់ថា ចូឆួប្រើតៀវលៀវមកហៅយើងឲ្យចេញទៅជួបប្រសិនបើយើងមិនចេញទៅជួបវេលានេះ បើចូឆួប្រើមកពិតចូឆួក៏នឹងសង្ស័យថាយើងប្រែចិត្តចេញ, បើយើងនឹងលើកទ័ពចេញទៅទាំងយប់ស្ងាត់ដូច្នេះ មិនដឹងច្បាស់ថាតៀវលៀវនឹងមកមែនឬមិនមែន ជាកលឧបាយសឹកទេក៏មិនដឹង ។

តាន់តេងឆ្លើយថា លោកមានប្រសាសន៍នោះត្រូវហើយ ចាំខ្ញុំបាទឡើងទៅមើលលើសែនបន្ទាយសិន ។ គីមៅក៏នាំតាន់តេងឡើងទៅលើសែន ក្រឡេកមើលទៅឃើញគាហានជាច្រើន តែមិនស្គាល់មុខច្បាស់ ចាំបានតែទង់ជ័យសម្រាប់ទ័ពចូឆួ គីមៅវិស្រែកហៅទៅថា ពេលនេះយប់ជ្រៅណាស់ទៅហើយ មហាឧបរាជប្រើមកដោយហេតុការអ្វីចាំពេលព្រឹកសឹមជួបនិយាយគ្នា ។

គាហានគួនអ៊ូស្រែកតបទៅថា មហាឧបរាជប្រើមកជាការអាថ៌កំបាំងធំបង្អង់ចាំស្អែកមិនបានទេ ត្រែងឡើងពីដឹងខ្លួន ឲ្យលោកបើកទ្វារចេញមកជួប ១ រំពេច ទើបបាននិយាយគ្នាកុំឲ្យឡើងពីដឹងការខាន់ ។

តាមៅបានឮដូច្នោះ ក៏មិនអស់សង្ស័យទេ ឯគាហានដែលនៅក្រៅកំពែង នោះក៏ចេះតែស្រែកឿនឲ្យបើកទ្វារ តាមៅបានឮក៏លើកគាហានបំពាន ផុតគប់ក្តើងបើកទ្វារធ្វេងស្ពានគូចេញទៅហើយស្រែកសួរថា តៀវលៀវ នៅឯណា ? ។ គួនអ៊ូយើញបានការ ក៏បំផាយសេះចូលទៅត្រង់មុខតាមៅ ហើយស្រែកថា អាកំណាច ! ។ តួរឬអាឯងគប់តែគ្នានឹងចូនូបចូសាយ បងអញ ។ តាមៅបានឮដូច្នោះក្រឡេកមើលទៅឃើញគួនអ៊ូ ទឹងណាស់ ញាក់សេះបរចូលច្បាំងនឹងគួនអូបាន ១០ ក្បែង តាមៅអស់កម្លាំងញាក់ សេះថយតែចូលស្រុកវិញ ។

ឯតាន់តេងដែលនៅលើសែនបន្ទាយ ឃើញតាមៅវាត់ចូលមក ក៏បង្គាប់ឲ្យគាហានបិទទ្វារស្រុកជាប់ ហើយយកដុំបាញ់ចម្រុះទប់ពីមុខ, តាមៅចូលស្រុកមិនបាន ក៏បំផាយសេះទៅតាមដើងកំពែងចៀសទៅ ។ គួនអូក៏បរសេះតាមទៅតាន់លើកជាវឡើងកាប់តាមៅធ្លាក់ពីលើសេះស្ទាប់ ។ គួនអ៊ូក៏កាត់យកក្បាលតាមៅត្រឡប់មកស្រុកវិញ ហើយស្រែកប្រកាសប្រាប់គាហានដែលនៅលើសែនថា តាមៅគិតសេចក្តីអាក្រក់នឹងយើងៗ ក៏សម្លាប់កាត់យកក្បាលមកហើយ អ្នកទាំងអស់គ្នាបើព្រមចុះចូលធ្វើការជាមួយនឹងយើងក៏ឲ្យបបួលគ្នាចេញមករកយើងដោយល្អចុះ យើងមិនធ្វើអ្វីទេ ។ គាហានទាំងពួងបានឮដូច្នោះ ក៏បើកទ្វារចេញមកគំនាប់គួនអ៊ូ ។ ឃើញបណ្តាអ្នកស្រុកឈឺដីវចេញមកគំនាប់ ដោយស្រួលក៏មាន

សេចក្តីត្រៃតអរណាស់ហាមច្រាមពាហានទាំងពួង មិនឲ្យធ្វើអន្តរាយអ្វីឡើយ ។

លុះវេលាព្រឹក គួនអ៊ូក៏ឲ្យគ្រឿវហ៊ុយចូលទៅនៅវត្តស្រុកឈើដាវ ហើយគួនអ៊ូក៏នាំយកកញ្ចាលតីម៉ៅត្រឡប់ឲ្យទៅពីមើល ខ្លួលប្រទេនទឹងទៅពីតណ្តាលផ្លូវក៏បង្ហាញកញ្ចាលនោះ ហើយគួនអូតណានាយរឿងដែលតីម៉ៅគិតប្រទូសរ៉ាយឲ្យច្បាស់ព្រោះតាន់តេងបានឲ្យដំណឹងរឿងហេតុនេះ ។ ទៅពីបានស្តាប់ត្រង់ប្រការក៏មានសេចក្តីភ័យថារម្តេចណាស់ថាសេចក្តីដែលប្អូនធ្វើដូច្នេះ ប្រសិនបើដឹងដល់ចូនួ ។ មុខជាទឹងលើកកងទ័ពមកធ្វើអន្តរាយដល់យើងៗ ទឹងគិតប្រការម្តេច? ។ គួនអ៊ូឆ្លើយថា ទោះបីចូនួទឹងលើកកងទ័ពមកធ្វើអន្តរាយដល់យើង ខ្ញុំបានទឹងគ្រឿវហ៊ុយអាចហ៊ានសុំយកអាសាស៊ូតច្បាំងទឹងចូនួត្រាតែអស់ដំរេះច្រាជ្រៀងខ្លួន ។ ទៅពីបានឮដូច្នោះក៏មិនអស់តែក្តី ទើបនាំគួនអ៊ូទឹងពាហានទាំងពួងលើកចូលទៅក្នុងស្រុកឈើដាវ ។ ខណៈនោះតាន់តេងទឹងបណ្តាអ្នកស្រុកក៏នាំគ្នាចេញទៅទទួលទៅពីទាំងអស់ ។ គ្រឿវហ៊ុយដឹងថាទៅពីទៅដល់ហើយក៏ចេញទៅទទួលហើយជំរាបទៅពីថា ត្រង់ត្រកវិយាបុត្រតីម៉ៅនោះខ្ញុំបានសំម្លាប់ចោលទាំងអស់ទៅហើយ ។ ទៅពីឮដូច្នោះក៏តែតែមានបរិតក្តីខ្លួនព្រួយពន់ប្រមាណថា ប្អូនឯងសម្លាប់តីម៉ៅទឹងត្រង់

គ្រួគឺមៅអស់សូន្យដូច្នេះ មុខជាចូធូនឹងលើកទ័ពមកធ្វើអន្តរាយដល់យើងមិនលែងទេ ។

គាន់តេងជំពាបថា ដែលចូធូនឹងលើកកងទ័ពមកនោះខ្មុកជាខ្ញុំបាទនឹងរិះគិតរកឧបាយកល ធ្វើមិនឲ្យចូធូចូលប៉ុយដល់លោកបានឡើយ ។

ឡៅពីក៏សួរគាន់តេងថា អ្នកឯងនឹងគិតធ្វើប្រការម្តេចខ្លះ? ។ គាន់តេង តបថា សព្វថ្ងៃនេះចូធូបានតែអ្នកសៀវឡៅហ្វាយស្រុកគីជីវ ១ ទេ ព្រោះអ្នកសៀវមានទាហានប្រមាណ ១០០ ម៉ឺន មានសេនាឯកនឹងទីប្រឹក្សាក៏ច្រើន ឯស្រុកសេងជីវ, ស្រុកអ៊ីវជីវ, ស្រុកបេងជីវ, ៣ តំបន់នេះជាមណ្ឌលធំ សុទ្ធតែឡើងចំណុះអ្នកសៀវទាំងអស់ បណ្តាស្រុកតូចៗ ដែលឡើងដល់ស្រុកទាំង ៣ នោះ ជាលំដាប់ទៅទៀតក៏ច្រើន, បើលោកឲ្យមានសំបុត្រទៅសុំកងទ័ពអ្នកសៀវលើកមកជួយហើយ ក៏នឹងខ្ជាប់អ្វីដល់ចូធូនោះ ។

(មានត)

រឿងព្រេងប្រទេសឥណ្ឌៀ

# អ្នកស្រីស្រីរ៉ែន-សារីយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាថ្មាំងមកជាភាសាខ្មែរ

(តមក)

ព្រះនាងខំរត់រកសព្វគីកន្លែង - គ្មានឃើញព្រះចន្ទនាលៈសោះ ។ ព្រះនាងព្រួយព្រះទ័យ ហើយទឹងមានសេចក្តីគាន់តឹងពន់ពេកណាស់ ទ្រង់ព្រះតម្រិះថា: "គ្មានជោគវាសនាអ្នកឯណាអាក្រក់ដូចយើងទាំងពីរនេះទេ ជីវិតយើងរស់នៅដោយលំបាកពន់ពេក" ។

នៅពេលនោះ ស្រាប់តែពស់មួយយ៉ាងធំលោតចេញពីក្នុងដំបូកមួយនៅក្បែរនោះមករុបរិតព្រះនាងមួយរំពេច ។ ព្រះនាងទ្រង់ព្រះកន្សែងជាខ្លាំង ហៅព្រះអគ្គីឲ្យមកជួយ ប៉ុន្តែគ្មានអ្នកណាមួយជួយសោះ ព្រះនាងមុខជាសុគតដោយឥតកំពូតែម្នាក់ឯងក្នុងព្រៃ ។

ព្រានម្នាក់ដែលដើរក្នុងព្រៃ ឮស្រែកព្រះនាងថ្ងូរក៏រត់ចូលទៅមើលឃើញព្រះនាងសន្ធប់ចាត់ស្មារតី ព្រានក៏ហួតដាវកាប់ក្បាលពស់កំណាចជាច់ខ្លាត់ខ្លាយចេញ ព្រះនាងក៏ដួលផ្ងួនដី ។ ព្រានរត់ទៅរកទឹកមកស្រែបព្រះកំក្តៅថ្ងាយព្រះនាង ។ ក្សាព្រះអគ្គីមានស្មារតីឡើង, ព្រានក៏ថ្ងាយផ្លែឈើព្រះនាងសោយ ហើយក៏សាកសួរព្រះនាងថា: "នាងជាអ្វី នាងមានក្លែកស្រទន់ល្អដូចជាក្លែកឈ្វីស តើអ្នកណា នាំនាងមកចោល

នៅកណ្តាលព្រៃដូច្នេះ? នាងមានឫកពារថ្លៃថ្លាណាស់ សមតែនៅគេហដ្ឋានដ៏ឧត្តុង្គឧត្តម ហើយនាងនៅជាស្ត្រីកសំពត់អាវបែបតោកយ៉ាកនៅវិញ, តើចៃដន្យដូចម្តេចបានជានាងធ្លាក់វេទនាដល់ម្ល៉េះ?" ។

ព្រះនាងឃើញថាព្រាននោះជួយសង្គ្រោះព្រះនាង ក៏មានបន្ទូលធ្លាប់រឿងរ៉ាវតាមដំណើរ ហើយទ្រង់មានបន្ទូលអំពីសេចក្តីវេទនា ។ ព្រានបើធ្លាប់ព្រះនាងមានព្រះទ័យរាយរាយដោយព្រះសូរសៀងស្រទន់ពីពេះ, ព្រះនាងគ្មានអាវពាក់ទេ លំអព្រះនាងហាក់ដូចជាស្ទើចាំងកន្ទឹព្រៃ ក៏បណ្តាលឲ្យកាមពាធជុតពេលកាលព្រាននោះ ក៏ស្ទុះចូលទៅស្រាវជ្រាវព្រះនាងមួយរំពេច មានបបូរមាត់ញ៉ែបែបដោយកាមតណ្ហា ។ ព្រះនាងយល់ខ្លួវសេចក្តីប្រមាថមើលងាយដូច្នោះហើយ ក៏ខំស្រែកញ៉ែអស់អង្គថា: "នាឡ:! នាឡ:! ម្តេចបានជាមនុមកធ្វើទោសមនុស្សអកុសលនេះទៅ, ទ្រព្រះពជស្វាមីសំឡាញ់ខ្ញុំអើយ!" ។ ព្រះនេត្រព្រះនាងសំឡក់ព្រានក្តៅហាក់ដូចជាចេញភ្លើង ព្រាននោះក៏ចង់លែងព្រះនាងដែរ ប៉ុន្តែស្ទាប់តែដួលស្ទាប់មួយរំពេច ខ្លួនទៅរលហាក់ដូចជាដើមក្រូជាតិដែលពេលដោយភ្លើងវន្ទះ ។

## ភាគទី ២៣

ព្រះនាងទ្រង់ត្រាប់ឡើងក្តុំ ប្តូរវល្លកាត់ព្រៃ កាត់ចំការ ចាំងថ្ងៃចាំងយប់ ។ ព្រះនាងទ្រង់ទ្រយល់រូងក្តុំ ដែលមានម្រឹគកាចសាហាវពួននៅ,

យល់កន្ទែងដ៏ល្អអស្ចារ្យដែលមានសត្វចាបជ្រែងយ៉ាងពីរោះ ។ ព្រះនាងចេះតែបង្កហេតុព្រះចាទនាល:គ្មានឈប់ឈរ ប៉ុន្តែព្រះចាទនាល:ទ្រង់មិនបានធ្វើយតបព្រះនាងសោះ ព្រះនាងយាងតាមក្បែរមាត់ព្រែកដួងកាត់ស្ទឹង ទ្រង់ចុះស្រង់កន្ទក់រាវដាំថ្វា ។ ព្រះនាងមានបន្ទូលសួរគ្រប់មនុស្សដែលព្រះនាងបានជួបថា: "អ្នកបានឃើញព្រះចាទនាល:ផងឬទេ?" ។ ប៉ុន្តែគ្មានអ្នកណាឃើញសោះ ជួនកាលគេមានធម៌មេត្តាដល់ព្រះនាង ជួនកាលគេនាំគ្នាសើចរំគន់ ។ ពេលល្ងាចមួយ ព្រះនាងអស់ព្រះកាយពលពេកទ្រង់ក៏ឈប់គង់នៅក្បែរមាត់ព្រែក ព្រះនាងឮសូរសំឡេងសត្វមួយយំគួរឱ្យខ្លាច ប៉ុន្តែព្រះនាងមិនខ្លាច ទ្រង់ទំបំភ្លេចក្តីព្រួយដោយនឹកដល់សំដីគ្មានព្រៃ នឹងពាក្យសច្ចាធិដ្ឋានរបស់ព្រះចាទនាល: ដែលទ្រង់ភ្លេចនៅពេលនេះ ។ ខ្លាមួយយ៉ាងធំគ្រហឹមនៅក្បែរព្រះនាង ប៉ុន្តែព្រះនាងគ្មានតក់ស្លុត ព្រះនាងមានបន្ទូលទៅរកសត្វខ្លាថា: "ឯងជ្រលែលជាស្តេចម្ចឹគក្នុងព្រៃនេះ! ខ្ញុំឈ្មោះទមយន្តីជាឯកអគ្គមហេសីនៃស្តេចនាល: ខ្ញុំមានសេចក្តីព្រួយជាខ្លាំងណាស់ ចូរអ្នកមកជួយធ្វើឱ្យខ្ញុំកើតសេចក្តីក្សាហានឡើងវិញ នែស្តេចសត្វអើយ! ចូរអ្នកជ្រាបខ្ញុំផង តើអ្នកបានឃើញស្តេចនាល:ទេ? តើស្តេចទ្រង់ជ្រលួនឬសុខសប្បាយព្រះអង្គទេ? តើទ្រង់ព្រួយព្រះទ័យឬទេ? ហ្នឹងហើយព្រោះតែរត់ចោលខ្ញុំ, តើព្រះអង្គស្តេចទៅតាមផ្លូវណា? ម្តេចក៏អ្នកទៅ

ស្ងៀមឈឹង? អ្នកមិនបានឃើញទ្រង់ទេឬ? បើដូច្នេះចូរអ្នកចូលមកហែកខ្ញុំ ទេមយន្តីដែលជាស្រីឥតកត្តាជាចំណីអ្នកចុះ ដើម្បីនឹងឲ្យខ្ញុំផុតអំពីសំចត្តីទុក្ខ" ។

ប៉ុន្តែខ្លាដើរចេញផ្លូវព្រលើយ ព្រះនាងក៏យាងដើរតទៅទៀត មកដល់ដើងក្នុមួយ ព្រះនាងលើកព្រះហស្តពិតទូលថា: "នុគីពិសិដ្ឋដែលជាសសរកន្ទោងនៃផែនដី! ខ្ញុំសូមនុនកាយវន្ទោដោយគោរព ខ្ញុំជាកូនស្តេចជាឯកអគ្គមហេសីស្តេច ខ្ញុំឈ្មោះទេមយន្តី, នុគីពិសិដ្ឋ! សូមអ្នកធ្វើយខ្ញុំមក តើអ្នកបានឃើញស្តេចនាលៈដែរឬទេ? តើទ្រង់យាងទៅឯណាទៅហើយ? ទ្រង់មានបន្ទូលយ៉ាងម្តេចខ្លះ? ម្តេចបានជាក្នុងឯងនៅស្ងៀម? ក្នុមិនបានឃើញព្រះបាទនាលៈទេឬ? នុពុទ្ធោអើយ? កាលណាទៅ ខ្ញុំនឹងបានឮព្រះសូរសៀងព្រះអង្គដែលមានស្នូរស្រទន់ពីពេះ គួរឲ្យស្រឡាញ់ដូចជាស្នូរខ្សែវរំតើយ ដែលសំណូរខ្លាំងដូចជាស្នូរពពក, នុក្នុដ៏អស្ចារ្យអើយ! ម្តេចបានជាអ្នកមិនមកជួយលំហែទុក្ខខ្ញុំផង" ។ ក្នុងខណៈនោះស្រាប់តែព្រះនាងឃើញកំពូលភ្នំមានពន្លឺដ៏រស្មីដូចជាមុជ ហើយមានឫសី ៣ អង្គចុះសំដៅមកកាត់ព្រះនាង គឺវសិស្ឋ (Vaçishtha,) ភ្រិគុ Bharigu) នឹងអត្រី (Atri) ឫសីបញ្ចេញមេត្តាភាពចំពោះព្រះកត្តិនៃព្រះនាង ហើយនិយាយថា: "នុព្រះពាជបុត្តីនៃព្រះបាទកិមៈ អំណាចឫសីអាចធ្វើឲ្យយើងមើលឃើញអនាគតបាន, ព្រះនាងនឹងបានសេចក្តីសុខ

សប្បាយរីញមិនខាន បន្តិចទៀតព្រះនាងនឹងបួបព្រះចុងនាល: ព្រះនាង
នឹងបួបស្តេចនៅពេលដែលទ្រង់រួចអំពីកម្មពៀរ ព្រះនាងនឹងយើញទ្រង់
ពេញដោតវាសនាព្រះអង្គ នឹងសោយរាជសម្បត្តិជាយូរអង្វែង ក្នុងសេចក្តី
ពេញចិត្តនៃពួកបណ្តាកស្តេចផង, ទ្រង់នឹងធ្វើឧណ្ហកម្មដល់មនុស្សកំណាច
ប្រទានរង្វាន់ដល់មនុស្សដែលបានបំពេញកុសលដ៏ប្រសើរ ហើយព្រះ
ឥន្ទនឹងថ្វាយពរសព្វសាធុការដល់ព្រះនាងទមយន្តីនឹងព្រះចុងនាល:" ។
ថាតែប៉ុណ្ណេះឫសីក៏រលាយបាត់ទៅ ពន្ធីក៏ស្អាប់ទៅវិញ ព្រះនាងទមយន្តី
ទឹកស្មានថាព្រះនាងទ្រង់សុបិន ។

## ភាគទី ២៤

ព្រះនាងទ្រង់ចេះតែយាងតទៅទៀត ប្រមាណជាពីរបីថ្ងៃក្រោយមក
ព្រះនាងយាងមកដល់វិថីមួយយ៉ាងធំទូលាយ ដែលទៅតាមក្បែរមាត់
ព្រៃត ។ នៅទីនោះ ព្រះនាងឃើញអ្នកដំណើរមួយពួកដើរដំរង់មក
កាន់ព្រះនាង មានទំនិញយ៉ាងថ្លៃៗ ផ្ទុកលើខ្នងសេះដែលមានពាក់គ្រឿង
យ៉ាងល្អ មានអ្នកបំរើយ៉ាងចំណាប់ ។ ជីកមុខដំរីដែលមានទំនិញយ៉ាងធ្ងន់
ផ្ទុកពីលើខ្នង ។ ព្រះនាងមានសេចក្តីខ្មាសអ្នកដំណើរទាំងនោះណាស់
ព្រោះព្រះនាងមានតែសំពត់រវៃមួយជាសំលៀកបំពាក់លេចមុខលេច
ក្រោយ ព្រះនាងស្ទាំងស្គម ព្រះចុងព្រះនាងជាប់ឈាមដោយបន្ទាស
នឹងឫ សាច់ព្រះនាងរោលដោយកំដៅថ្ងៃ ព្រះនាងចង់រត់ពួន ប៉ុន្តែ

ឈ្មួញម្នាក់ក្រឡេកឃើញព្រះនាង ហើយធ្វើអាការឲ្យព្រះនាងចូលមកជិត បើសិនជាព្រះនាងវត់គេច តើពួកឈ្មួញនឹងយល់ថាព្រះនាងជាមនុស្សអ្វីទៅវិញ? ។

ពួកឈ្មួញចំគយគន់នាងបែបឆ្ងល់ ព្រោះព្រះនាងទោលក្នុណៈល្អមានឫកពាជាក្សត្រ សូម្បីព្រះនាងជល់ទ្បូសេចក្តីវេទនាយ៉ាងនេះ, នាយឈ្មួញក៏សួរព្រះនាងថា: "នាងជាអ្វី? ម្តេចបានជាមកជួបនឹងយើងនៅទីកន្លែងនេះ? តើយើងគួរអាណិតនាងឬគួរខ្ជាប់នាងវិញ? នាងមានភាពជាអ្នកលំបាកគោកយ៉ាក ប៉ុន្តែរូបនោមរោមពណ៌នាងហាក់ដូចជាអាទិទេព, តើនាងជាសមយាចកកំសត់ទេឬ? តើនាងនៅក្នុងទីព្រៃជិតនេះឬ? ចូរនិយាយប្រាប់យើងមក! បើនាងជាអ្នកកំសត់ យើងនឹងជួយយកអាសានាង, បើនាងជាអាទិទេព យើងនឹងសុំនៅក្នុងការទំនុកបំរុងរបស់នាង" ។

ព្រះនាងលុះទ្រង់ព្រះសណ្តាប់ពាក្យនាយឈ្មួញហើយ ក៏មានទឹកចិត្តក្លាហានបន្តិច ហើយមានបន្ទូលតបថា: "ខ្ញុំមិនមែនជាអាទិទេពទេ ខ្ញុំជាស្ត្រីម្នាក់ដែលមានសេចក្តីវេទនាគ្រប់សង្កត់ ទោះបីខ្ញុំនេះជាបុត្រីស្តេចហើយជាឯកអគ្គមហេសីស្តេច, តើអ្នកបានឃើញព្រះចាន់ទាល: ជាប្តីខ្ញុំដែរឬទេ? ខ្ញុំមានសេចក្តីព្រួយទីឯព្រះអង្គបានជាខ្ញុំចំដើរវែកព្រះអង្គ, កាលដែលព្រះអង្គទ្រង់សោយរាជ្យនៅប្រទេសនិសធ: គ្មានអ្នកណាអាចផ្ទឹមនឹងទ្រង់បានឡើយ, បើអ្នកបានឃើញ សូមប្រាប់ខ្ញុំផង!" ។

នាយឈ្មួញឆ្លើយថា: "តុំបានឃើញព្រះអង្គទេ" ហើយក៏សួរ
ទៅពួកអ្នកដំណើរទាំងអស់ថា "មានអ្នកណាបានឃើញទេ" ។
អ្នកទាំងអស់ក៏ឆ្លើយថា "មិនបានស្គាល់ទេព្រះចាខនាល:នោះ" ។
ព្រះនាងទ្រង់ព្រះសណ្តាប់ហើយទ្រង់ដកដង្ហើមធំ ហើយព្រះនាងមាន
បន្ទូលសួរទៅនាយកងវិញថា: "តើក្បួនដំណើរនេះមានបំណងនឹងទៅ
ស្រុកណា?" ។ នាយឈ្មួញឆ្លើយថា: "យើងទៅឯទីក្រុងឆេទីស
(chédis) ដែលមានស្តេចព្រះនាមសុវហុ (Suvahu) សោយរាជ្យ ។
ព្រះនាងក៏ទៅតាមក្បួនដំណើរនោះ ។ អ្នកដំណើរទាំងឡាយក៏ប្រកប
ដោយសេចក្តីសុខគ្រប់ប្រការ ។ ប៉ុន្តែនៃថ្ងៃក្រោយមកគេបានទៅដល់មាត់
បឹង ១ ដែលមានទឹកត្រជាក់ល្អហើយទឹងមានផ្លាកឫកដេរដាស កន្លែង
នោះជាទីគួរឲ្យសប្បាយណាស់ គេក៏នាំគ្នាឈប់សំរាកបរិភោគអាហារ
លុះយប់វេលាណាគេក៏នាំគ្នាដេកអស់ ។ លុះដល់ពាក់កណ្តាលអធ្រាត
ស្រាប់តែមានហ្វូងដំរីព្រៃចុះមកផឹកទឹកបឹងនោះ ។ ដំរីព្រៃកាលបើឃើញ
ដំរីដែលនៅក្នុងក្បួននោះ ក៏កើតសេចក្តីស្អប់ដោយឃើញជាតិខ្លួននៅជា
ខ្ញុំគេដូច្នោះ រាចង់សម្លាប់បំផ្លាញចោល ក៏ស្ទុះ ចូលសង្កត់ញាតិចម្ងាយ
ជាន់ពួកឈ្មួញ។ ស្រែកយំលាន់ឮហឹងហើយក៏ខំស្ទុះរត់ពួន ប៉ុន្តែទៅជា
បែរមុខទៅរកដំរីព្រៃ។ រាចាក់ទន្ថឹកទ្លុកចោកទន្ថឹកប្រមាយ ជាន់ទន្ថឹកដើរ
រាំងអស់ ។ មានមនុស្សទន្ទឹលៈគ្រាះថ្នាក់ដល់ស្លាប់ជាច្រើន កន្លែ
ពេលយប់នោះ ។

ត្រលប់មកវិញ អ្នកដែលបានរួចរស់ជីវិតនាំគ្នាយំទ្រហឹង ដោយបានឃើញការអន្តរាយគួរស្ញែបយ៉ាងដូចនេះ ហើយក៏នាំគ្នាតូចចិត្តនឹងព្រះនាងទមយន្តី ថាបង្កើតមកពីព្រះនាង ព្រោះព្រះនាងជាស្ត្រីកាឡកណ្ណី ដែលអាចនិទេពជាក់ទណ្ឌកម្មដោយមិនដឹងជាធ្វើអ្វីខុសយ៉ាងធំហេតុដូច្នេះហើយបានជាពៀរនោះ ឆ្លងទៅដល់អ្នកឯណាដែលជួយយកអាសាព្រះនាង ។ ព្រះនាងពន្សូរពួកឈ្មួញកំណាចពោលតាក្យដូច្នោះ កំឋយទៅឆ្ងាយមានទឹកព្រះនេត្រជោរជលសស្រាក់ ហើយនឹកខឹងនឹងខ្លួនឯងថា: "ពួកឈ្មួញនិយាយត្រូវមែន ព្រោះអាទិទេពខឹងតែនឹងរូបអញមួយ ពីថ្ងៃនេះទៅ អញលែងស្គាល់សេចក្តីសុខទៀតហើយ, ប្រហែលជាអញបានធ្វើអ្វីអាក្រក់ពីជាតិមុន បានជាអញវេទនាគ្មាន់ស្រាកស្រាន្តយ៉ាងនេះ. ប្តីអញអន្តរាយប្រទេសហើយរត់ចោលអញថែមទៀត ឥឡូវនេះ អញធ្វើឲ្យស្វាប់មនុស្សដែលជួយយកអាសាអញទៀត, តុបុះតោសអ្វីអាក្រក់ម៉ាងនេះ! ម្តេចបានជាដំរីនោះមិនព្រេចអញ? មែនហើយពាក្យចាស់លោកថា "អាយុមិនអស់ មិនស្វាប់" បើដូច្នោះអញមិនទាន់អស់អាយុទេ ពីព្រោះដំរីមិនព្រេចអញ ។ តើអាទិទេពធ្វើទណ្ឌកម្ម ដោយអញរើសយកព្រះបាទនាលៈជាស្វាមីទេឬ? ពុទ្ធោអើយកម្មអ្វីក៏កាចយ៉ាងនេះ" ។

(មានត)

ដំណឹងតាមខ្សែក្នុងកន្លែង

# លោកផេង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

## ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

---

ចួនកាលនាងប្រៀនថា: ស្នេហានៃស្ត្រីទុកដូចជាម្ទេចដើមគ្នោត ក្តីវាលខ្សាច់, ស្នេហានៃបុរសទុកដូចជាខ្សែកំបុតត្បូងដែលមានអំណាច អាចបំបាក់ដើមគ្នោតនោះ ដើម្បីធ្វើម្ទេចឲ្យស្ថិតនៅនឹងតែមួយកន្លែង ។

ឧមាសព្រលឹងបង! អ្នកដែលសម្រាកនៅផ្ទះ អ្នកមិនរលឹកដល់ស្នួនរហាស្ថានដែលបងធ្លាប់នាំអ្នកទៅលេងទេឬ? តើជាស្នួនដែលតាំងនៅត្រង់ចន្លោះ កំពែងយ៉ាងខ្ពស់ សូម្បីចុងឈើក៏ខ្ពស់មិនដល់ តើជាស្នួនដែលគេបង្កប់កងកំពែងសដូចតែវចរណៃកងផ្កាចម្ប៉ា" ។

ឧ មាសស្នេហ៍! អ្នកមិនរលឹកដល់ពេលព្រហាមត្រជាក់ដែលអ្នកបណ្តាយដួងព្រលឹងឲ្យទោរទន់ចុះតាមចំណង់តាមកតរបស់បង ដូចជាដើមគ្នោតតោងចុះតាមអំណាចកម្ងាន់ខ្សល់ ឬទេ? ។

ឧដើមគ្នោតដ៏វែងមាសបងអើយ បងសូមឲ្យដីខ្សាច់ដែលធ្លាជាផ្ទះសង្កត់ពីលើរូបអ្នក មានទម្ងន់យ៉ាងស្រាល ។

ចួនកាលនាងប្រៀនដូច្នេះវិញថា:

សូមឲ្យខ្លួនបងជិតជាប់នៅនឹងដួងវិញ ណាអ្នកជាន់ចុះ ។

តែបងក្មេកអូនដូចជាស្រឡាញ់ផ្កាព្រលិតពីរដែលស្លឹតដោយកំដៅថ្ងៃក្តៅគគ្រឹមដូរ ចំណែកបបូរមាត់អូនទៅក្រហមឆ្អិលដូចផ្លែទន្ទ្រាប់ពុំ ។

បងសុំផ្ទៀងវិតលើប្លន់ហើយ សក់អូនផាត់ផ្កាក់មកគ្របលើថ្ងាសអូនដូចជាត្រចៀកកាំទំពើរហឹបក្តក ហើយនឹកថាក្លុកដែលឡើងស្រួចដូច្នេះ ប្រហែលដូចជាថ្ពាល់អូន ឬទេ? ។

ផ្កាព្រលិតរញ្ជួយហើយ ហេតុអ្វីក៏អូនទៅក្រឡេកមើលបងទៀត?

ត្រចៀកកាំហើរទៅបាត់ហើយ ហេតុអ្វីក៏អូនចាំផាត់សក់ចេញ?

ផ្លែទន្ទ្រាប់រហែកបែកអស់ហើយ ហេតុអ្វីក៏អូននៅញញឹមជាប់បង-ទៀត? ។

ឬនាងច្រៀងដូច្នេះវិញថា:

ត្រាបសទំដេកលើដើមគគីវេលាយប់ ។ មុនដំបូង ឯហើរព័ទ្ធចុះឡើងដុំវិញដើមឈើនេះ បែបញាញើតញាញើមតុំហានចូលដេកឥឡូវនេះ ឯហើរមកដេកពាល់យប់លើចុងមែកដែលខ្ពស់ជាងគេ ។

លលកងោរខ្លួយ ។ រកគ្នា . . .

ចំណែកបង ។ សូមច្រៀងបំពេអូនដោយបិយវាចា ។ បងជឿថាត្រាបសទឹងនាងនារីតែងមានចិត្តដូចគ្នា សម្រាប់នាំខ្លួនទៅរកស្នួនឲ្យរដែលលលកឈប់ងោរ ។

ឬនាងច្រៀងដូច្នេះវិញក៏មាន:

កាលណាអូនចង់សំដែងកាយសញ្ញាឲ្យបងឃើញ អូនលូកដៃចេញមកខាងក្រៅបង្អួចតាមចម្រឹងដែក ។ ឃើញដូច្នោះព្រលឹងបងស្ទុះចាត់មិនដឹងជាទៅណា ។

ផ្កាចម្ប៉ី ថាមានពំណើសហើយ ទឹកភ្នែកនៅលើកំ ថាខុកជាស្កូហើយ, ថ្នាំកៅស៊ូសើរឆាំហើយ, ផ្កាម្ទិះក៏សស្អាតហើយ, ប៉ុន្តែគង់នៅមិនសើរស្មើនឹងព្រមដៃអូនដែលប្រកបដោយគ្រឿងគ្រឿងហមខុំដូចផ្ទៃដម្ពូ ។

បងតែងនិយាយប្រាប់មិត្តភ័ក្តិរបស់បង ដែលចេះតែឆ្ងល់នឹងធំក្ងុនគ្រអូបឈ្មោយថា: ដៃអូនទើបនឹងលូកចេញមកក្រៅបង្អួចអម្បាញ់មិញ ផ្ទៃបំបែកតែង់ហ្នឹងបានជាធំក្ងុនគ្រអូប ព្រោះក្ងុនគ្រឿងអូនស្រឡាយមក ។

ចំណែកនាងឡឺឡាមានប៊ីតិថា: អារម្មណ៍ក្នុងជីវិតាពឥតមានអាក់អួលឡើយ ។ ប៉ុន្តែ នាងតែងរក្សានូវស្រមោលមុខព្រះអង្គម្ចាស់អ៊ីស្ម៉ាអ៊ីលដែលនាងបានជួបមួយភ្លែត ខុកនៅក្តៅ ។ ក្នុងជួនព្រលឹង ហើយរឿងនេះនាំឲ្យនាងសប្បាយជានិច្ច ។ នាងមានសេចក្តីសង្ឃឹមខុកថា គង់ថ្ងៃណាមួយនាងនឹងបានជួបជាមិនខាន, ម្ល៉ោះហើយនាងតែងតែតាំងធ្វើការងារនៅក្បែរម្តាយនឹងស្រី ក្នុងគណៈអ្នកចាចរក៍ ឥតមានវល់អំពីប្រុស្ន អ្វីឡើយ ។ នាងបណ្តាយតាមតែអ្នកដែលស្រឡាញ់ពប់អានគេសរសើរ ហើយត្រង់ខ្លួនបំរុងនឹងប៉ះទៅលើសេចក្តីខុកួយ"ដ៏ធ្ងន់ក៏មិនដឹង ។

ព្រឹកមួយ គឺជាថ្ងៃទី ៤ នៃការសំចតអាស្រ័យនៃអ្នកចាចរក៍ នាងចាដ្យាជាម្តាយហៅកូនតាំងពីរមកប្រាប់ថា:

– បើកូនទាំហួងពពែយកទៅឲ្យស៊ីស្មៅ នាវលាងនាយជ្រោះឯណោះបានឬទេ ? ព្រោះនៅកន្លែងនេះស្មៅក្រហើយសុទ្ធតែខ្ចីៗ គុកសម្រាប់ឲ្យអូដ្ឋស៊ីស្មៅមិនគ្រប់គ្រាន់ផង ។

ឡឺឡានឹងអាឥសឡាតា ដល់ថ្ងៃបួនត្រង់ ក៏នាំគ្នាកៀងពពែចេញទៅ ។ គឺជាថ្ងៃក្តងគិម្ហរដូវដែលអាកាសនឹងមេឃឡើងពណ៌ខៀវថ្លា ។ នាងតាកែវពីរនាក់បងប្អូន នាំគ្នាទៅកន្ត្រកម្លប់ឈើដែលដុះល្បាះៗ ។ នាងទំប្រក់ឡើងឲ្យលាងឲ្យកំភួចមួយ ដុះសុទ្ធតែដើមឈើ ហើយអាចមើលឃើញទន្លេកន្លែងសំណាក់ដែលតាំងនៅខាងត្រើម ទៀបដើងក្តុបានដោយងាយ ។ នាងឡើងតាមច្រកមួយយ៉ាងចង្អៀត ទំប្រវែប្រវែងម្រាំបានដល់ខ្នងខាងលើ ។

នៅទីនោះ ម្លប់ត្រជាក់ស្រែង ក្រោមស្មឹកស្មោតក្រៃប៉ាង ពពែស៊ីស្មៅក្បែរគល់ស្មោត ។ អាឥសឡាតា អស់កម្លាំងពេកក៏អង្គុយចុះហើយសូត្រធម៌ក្បួនដំណុំ ។ តែម្នាក់ឯង ដើម្បីសម្រាលសេចក្តីទុក្ខដែលមាននៅក្នុងចិត្ត ។ ចំណែកឡឺឡាសំឡឹងមើលអច្ឆរិយទស្សនាដែលតើតមានដល់ចក្ខុបសាទនៃនាង ។

ត្រង់កន្លែងដែលនាងជ្រក គេអាចមើលឃើញដីទំនាបទាំងមូលនឹងដីទំនាបច្រកកុំទាំងអស់ ឥតមានសល់ត្រង់ណា ។ ដីពណ៌ពព្លក់ត្រវែស្មីព្រះអាទិត្យចាំងរន្ទះស្ទើរស្រែកំងក្អែក ។ រឿងហេតុអ្វីទាំងប៉ុន្មានដែលមាននៅក្នុងទីវាល សូម្បីបន្តិចបន្តួច ក៏មិនផុតពីក្អែកនាងឡឺឡា ។

នាងក្រមុំមើលឃើញស្រីៗស្លៀកសំពត់ស្តើងៗ នឹងប្រុសៗស្លៀកពាក់សំពត់ស៊ូត្រូវរញាក់រញាល់ រត់ទៅរត់មក ចេញចូលក្នុងជំរំសំពត់ ។ នាងឮសូរសន្ធឹកអ៊ូអ៊ា តាមខ្យល់បក់មក ។ គឺជាជីវភាពដែលប្រព្រឹត្តទៅពាល់ថ្ងៃនៃពួកមនុស្សព្រមទាំងមុខរបរផ្សេងៗ ទាំងសំដីប្រសាទនិយាយគ្នាចំរៀងស្រីៗសម្រែកកូនក្មេង សូរឆ្កែព្រុស នឹងសំឡេងសត្វអូដ្ឋ ។

នាងឡីឡាស្រាប់តែស្រែកដូចគេភ្ញាក់ ។ នាងក្រឡេកទៅឃើញសុទ្ធតែពាហានដ៏រសេះហុយដ៏ខ្លោមដូចពពក បរសំដៅជំរំសំណាក់អាស្រ័យ ។ នាងស្គាល់ជាក់ជាពាហានរសេះសាសន៍តួគិ ព្រោះនាងសំគាល់សំលៀកបំពាក់បាន ។

គ្រឿងសព្វាវុធត្រូវរន្ទះថ្ងៃចាំងសស្វាច ។ នាងនឹកដល់កាលនាងទៅពីក្មេងមានចោរឫទ្ធដូច្នេះម្តង; រឿងដែលប្រកបដោយសេចក្តីទុក្ខព្រួយនឹងដោយសេចក្តីវិនាសនេះ តែនឹកដល់ នាងតែងញាក់ដូចគេគ្រុន ។

ពួកតួគិតែមកហើយ មិនដែលឲ្យសេចក្តីចំរើនទេ មានតែធ្វើឲ្យអន្តរាយគ្រប់យ៉ាង ឬទំដណ្តើមយកសម្បត្តិទ្រព្យ ។

នាងដើរទាំងញ័រចូលទៅជិតអាឥស្សាតា និយាយថ្លាប់ថា: នែអ្នកបង! ពួកពាហានសេះតួគិ ចូលទៅកន្លែងសំណាក់យើងហើយ ។

នាងអាឥស្សាតា ដែលមិនអាចអត់ទ្រាំនឹងការភ័យបាន ក៏ថ្លាប់ប្អូនថា: ឡីឡាមាសបង! រត់យើង! ត្រូវយើងរត់! ។ នាងឡីឡាថាប់

គាញ់ចង់មកនឹងខ្លួនហើយ ទ្រើយថា: ចុះម៉ែយើងយ៉ាងម៉េចទៅហ្ន៎! ។ ចំណែកអាឥស្សាតាញ៉ែរខ្លែកដូចកូនសត្វ ។

ក្នុងខណៈនោះ គេឮស្រែចាញ់កាំភ្លើង ។ ពួកគាហានសេះចរសេះលុកលុយក្នុងទីសំណាក់ ជាន់ស្រែ។ ទឹងក្នែង។ ដួលច្រឡាប់ច្រឡិល ។

នាងនារីមើលឃើញនូវពួកមនុស្សរត់ឈឺចុះឈូឡើង ហើយនាំគ្នាឈរផ្ទុំនៅកណ្តាលទីសំណាក់ ហើយឃើញម្នាក់ទៀតដូចជាមេគេដើរឃ្លាតចេញពីពួកអ្នកអស់នោះចម្ងាយពីរបីម៉ែត្រ ។

ខណៈនោះ នាងឡើងឃើញលោកតាម៉ាត្រុកអែលគាឌី ដើរទៅរកអ្នកនោះ ។ តាមពិត នាងស្តាប់មិនឮសំដីនិយាយទេ ប៉ុន្តែបើតាមអាការនៃលោកតានោះ នាងយល់ថានឹងមានសេចក្តីទុក្ខដល់អ្នកចពចរកែជាថ្មីទៀត ។

លោកតាម៉ាត្រុកអែលគាឌី ដូចជាជជែកតវ៉ាយ៉ាងខ្លាំង តែមេទ័ពតួគិដកយកក្រដាសមួយសន្ធឹកយ៉ាងធំ ពីកាបូបស្បែកព្យួរនៅនឹងកែបសេះ ហើយហុចទៅឲ្យលោកតាម៉ាត្រុក។ ឃើញដូច្នោះ ក៏លើកដៃចាំងពីរទៅលើដោយអាការស្ងួតត្រង់ តែមេទ័ពតួគិមិនយល់ត្រមតាម ។

ក្នុងពេលនោះ មេទ័ពតួគិបង្គាប់ឲ្យគាហានខ្លះលោតចុះពីសេះរត់ចូលទៅឆែកក្នុងជំរំ ហើយប្រហែលមួយស្របក់ ស្រាប់តែឃើញបានកាំភ្លើងព្រមចាំងគ្រាប់រំសេវ ដែលជាអាវុធរបស់អ្នកដើរទេសក៍ធ្វើទុកសម្រាប់ការពារចោរ ។

លុះឃើញដូច្នោះ មេទ័ពតួគិបង្គាប់ឲ្យលើកដំរីចេញពីភូមិ កុំបង្អង់ ។ ត្រង់ហ្នឹងហើយ គឺជាពេលអុកឡុកយ៉ាងខ្លាំងដែលសូរសព្ទលាន់ឮមកដល់ត្រចៀកនាងនារីបងប្អូនទាំងពីរ ។ នាងឡីឡាឃើញម្តាយរបស់នាងមានទាហានតួគ៌បណ្តើរមុខក្រោយ ។ នាងនេះព្រួយពេក ដូចជាជាប់ស្មារតី ដើរទាំងមិនដឹងខ្លួននៅកណ្តាលទាហានពីរនាក់ ។

កងពេលនោះ ឡីឡាដឹងថា ម្តាយរបស់នាងត្រូវការធឹងចង់ដឹងឲ្យច្បាស់ថាត្រូវឲ្យកូនស្រីគាត់ទាំងពីរបួចគ្រោះថ្នាក់ជាជាងលុះក្នុងកណ្តាប់ដៃតួគិ ប៉ុន្តែចំណែករូបនាងយល់ឃើញដូច្នេះវិញ: សេចក្តីទុក្ខដោយជាប់ជាឈ្លើយ ចើបែងចែកគ្នារវាងសត្វកំសត់ប៉ីនាក់ដែលមានសេចក្តីស្នេហាចំពោះគ្នានឹងគ្នា គឺជាសេចក្តីទុក្ខស្រាលបន្តិចជាជាងការបែកនឹងការចាកមុខចេញពីគ្នា ។

គិតដូច្នេះហើយ ឡីឡាមិនអាចញាំងសន្តានប្រកបដោយសេចក្តីតក់ស្លុតឥតឧបមា សេចក្តីទុក្ខយ៉ាងធ្ងន់ ឲ្យគាំងស្មៀមបានក្នុងដួងហឫទ័យព្រោះគិតឃើញថានាងនឹងត្រូវព្រាត់ចាសចាកមាតាជាទីស្រឡាញ់ ។ ប៉ុន្តែ តើនាងក្រមុំអាចទប់ទល់នឹងព្រៃងឹកសនាបានឬទេ? ចំណែកអាឥស្សាគានេះ ក៏ថ្លែងថាហើយថាទៀតទាំងយំផងថា "នែឡីឡា! ត្រូវយើងវត់! បងខ្លាចណាស់! បងមិនចង់ឲ្យគេចាប់យើងបានឡើយ!" ។

នាឥឡូវឃ្លាឈរកៀកនឹងបឋស្រី មើលតាមចំណាំងព្រះអាទិត្យ ពេលព្រលប់ឃើញពួកអ្នកដើរទេសចាំងប៉ុន្មានកំពុងតែរើដំរំ បញ្ជូកស្បៀងអាហារក្នុងហឺប ហើយប្រញាប់ប្រញាល់ធ្វើតាមបង្គាប់នាយកងតួគិដែលប្រាប់ឲ្យលើកទីកន្លែង ។

ត្រង់ដឹងថាសម័យនោះ មិនដូចសម័យឥឡូវនេះឡើយ គឺក្រុងទ្រូប៉ូលីតែន មិនមែនតាំងនៅកងអាណាព្យាបាលនៃសាសន៍អ៊ីតាលីទេ ។

គេដឹងច្បាស់ជាថា គឺសាសន៍អារ៉ាប់ដែលបានរុករានទន្លោនជាច្រើនលើកច្រើនគ្រា កំសម្រែចយកក្រុងនេះបានជាស្រុកអាណានិគមរបស់ខ្លួនក្នុងសតវត្សទី ១១ ប៉ុន្តែសាសន៍នេះមិនអាចទប់ទល់នឹងការរំលោកនៃសាសន៍ទួគីបាន ក៏ត្រឡប់ប្រគល់ស្រុកចំណុះនេះឲ្យទៅពួកកងទ័ពហានៃក្រុងកុងស្តង់ទីណុបវិញ ។

លុះដណ្តើមស្រុកនេះបានមកពីដៃអារ៉ាប់កាលណា សាសន៍ទួគីក៏ចាប់ធ្វើការមានប្រយោជន៍យ៉ាងធំនៅទីក្រុងទ្រូប៉ូលីតែនភ្លាម ឥតបង្អង់ព្រោះក្រុងនេះជាមានច្រកតែមួយ ជាសំណល់សម្រាប់ឲ្យគេធ្វើការរំលាយសាសនា បញ្ចូលទៅជាមួយនឹងពួកជាតិមហាម៉ាត់ប្រទេសអាហ្វ្រិក ។

គេដឹងថា ការរំលាយបញ្ចូលសាសនាវាងក្រុងកុងស្តង់ទីណុបនឹងក្រុងទ្រូប៉ូលីតែន អាចជំនួសសិទ្ធិនយោបាយ ព្រមទាំងបង្កើតស្ថានមេត្រីឲ្យកាន់តែមាំពូកែឡើង ។ (មានត)

# តិណឈាបនកិច្ច

## សពព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

ទុកញ្ញ" មួង-ឃួន ក្រុមការដើមវគ្គលេខ ១
ក្រសួងពុទ្ធសាសនបណ្ឌិត្យភ្នំពេញ
រៀបរៀង

---

ព្រះអមរាភិរក្ខិត អ៊ុយ-ប៉ាង ធ្លើអធិបតីរងក្រុមជំនុំព្រះត្រៃបិដក ក្នុងចំណោមព្រះសង្ឃគិតការាទាំងឡាយនៃពុទ្ធសាសនបណ្ឌិត្យ ជាអ្នកយកចិត្តទុកដាក់ផ្តិតផ្តង់ធ្លើការងារប្រែពិនិត្យព្រះត្រៃបិដក ឥតខ្ចាចខ្លាយហត់ ដល់មកថ្ងៃទី ៤ ខែមីនា ឆ្នាំ ១៩៤៦ ចាប់អាពាធជាទម្ងន់ដោយរោគខ្សែង៉ាឈាមស្ទឹកស្រពន់ញ័រព្រះហស្តខ្លួចមួយចំហៀងខ្លួន ប្រាណនិមន្តទៅព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលាក្នុងភ្នំពេញជាយូរវែង ក៏គ្រាន់តែបានធូរបន្តិច ។ ។

លុះកន្លងមកបាន ៧ ឆ្នាំ រោគនោះបណ្តាលឡើងម្តងទៀត ពួកសិក្ខានុសិស្សទើងក្រុមញាតិ បានរកថ្នាំពេទ្យតែមិនបាត់ ។ រោគកាន់តែរឹតខ្លាំងឡើង ។ រាល់ថ្ងៃ មិនបានធូរថយសោះ ។ លោកក៏ដឹងច្បាស់ថា ខ្លួនលោកមិនជាទេ ក៏សុំលាចេញចាកដំណែងអធិបតីរងក្រុមជំនុំព្រះត្រៃបិដក ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ ។

ដល់មកថ្ងៃទី ២៨ ខែឧសភាឆ្នាំ ១៩៩៤ ពេលនោះលើកតែតែភ្ញាំធ
ឡើងហួសវិស័យពេទ្យព្យាបាល មច្ចុរាជក៏ចូលមកផ្តាច់ជីវិតទ្វិយ ទៃ
ព្រះអមរាភិរក្ខិត អ៊ុយ - ប៉ាង ក្នុងថ្ងៃចន្ទ ១៩ រោច ខែពិសាខ ឆ្នាំមមីឆស័ក
ពេលម៉ោង ៣ ទីង ១៥ នាទី រំលងអាធ្រាត្រ ត្រូវនឹងថ្ងៃទី ៣១ ខែឧសភា
ឆ្នាំ ១៩៩៤ ក្នុងជន្មាយុគំរប់ ៦២ ឆ្នាំ នៅកុដិរបស់លោក ។

សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ ទីង ព្រះពុទ្ធ-
គណៈទាំងឡាយ ព្រមទាំងពួកសិស្សានុសិស្ស ហើយទីង ក្រុមញាតិបាន
ធ្វើពិធីស្រង់ទឹកសពរួច បានលើកសពដំកល់ក្នុងក្តារមឈូស ដែលរចនា
ដោយក្បាច់រំលេចពណ៌ផ្សែង ។ ហើយទាំសពចេញពីកុដិរបស់លោក
ទៅដំកល់លើបញ្ចា ៣ ជាន់ក្នុងសាលាបិណ្ឌ ដើម្បីធ្វើទក្ខិណានុប្បទាន
រៀងរាល់ថ្ងៃ រហូតដល់ថ្ងៃ ៣ កើត ខែដេស្ឋ ឆ្នាំមមីឆស័ក ព. ស.
២៤៨៧ ត្រូវនឹងថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ១៩៩៤ វេលាម៉ោង ១៥ បាន
រៀបពិធីរំកិលសពដំកល់ទៅរថយន្ត ដែលរចនាដោយក្បាច់ក្តីផ្កាផ្សែង ។
ហែសពចេញតាមផ្លូវទៅខាងលិចវត្ត តម្រង់ទៅខាងត្បូងតាមវិថីប៉ូបែរ
រួចបត់ទៅតាមតំរៀបីឡើងសុំស៊ីវត្តិ ព័ទ្ធទៅកាន់ទីសុសានដ្ឋានមុខវត្ត
បទុមវតី ដល់ហើយលើកដង្កៀសពដំកល់ក្នុងប្រាំយ៉ាតព្រះពុទ្ធទ្យ
ដែលតាក់តែងដោយក្បាច់រចនាផ្សែង ។ ។

ក្នុងចំណោមឥស្សរជន ដែលអញ្ជើញទៅកាន់ពិធីបុណ្យគេសង្កេត
ឃើញ ឯ.ឧ.ផូ-ត្រឿង រដ្ឋមន្ត្រីក្រសួងធម្មការ ឯ ឧ.ព័យ-ល្នុត ឯ ឧ.
សម-ញាណ នាយកមន្ទីរ នាយក្រុមនិងពួកពុទ្ធបរិស័ទជាច្រើន ។

ឯចំណែកព្រះសង្ឃមានសម្តេចព្រះសុជម្មាធិបតី អ៊ុង-ស៊ែ សង្ឃ-
នាយកគណធម្មយុត្តិ, ព្រះពោធិវ័ង្ស ហួត-តាត ចាងហ្វាងសាលាបាលី
ជាន់ខ្ពស់ ព្រះអរិយកស្សប អ៊ូច ព្រះពាជាគណនិងឋានានុក្រមហើយនិង
កិត្តិសាមណេរជាច្រើន បានមកជួបជុំជាច្រើនរូបរាក ។

ម៉ោង ១៧ លោកគ្រូមហា ប៉ាង-ខាត់ សមាជិកក្រុមជំនុំព្រះវិន័យ
បិដក តំណាងក្រុមពុទ្ធសាសនបណ្ឌិត្យ បានសូត្រសុន្ទរកថាមួយពណ៌-
នាសរសើរកិត្តិគុណ ព្រមទាំងសេចក្តីសោកស្តាយចំពោះសពព្រះអមក-
កិរក្ខិត អ៊ុយ ប៉ាង ដូចតទៅនេះ

សូមក្រាបទូលសម្តេច ! ព្រះតេជព្រះគុណ !

សូមជំពាប់ឯកឧត្តម ! លោកសប្បុរសទាំងឡាយ !

ព្រះថេរៈដែលខ្ញុំព្រះករុណាអាត្មាភាព ទើងពោលសរសើរកិត្តិគុណ
ព្រមទាំងរៀបរាប់សេចក្តីសោកស្តាយនេះ កាលពីលោកមានជន្មាយុនៅ
ឡើយ លោកធ្លាប់រស់នៅជាមួយមេត្រីភាពជាមួយនឹងយើង, ឥឡូវនេះ
អង្គលោកជានាមធម៌នោះនិមន្តទៅបាត់ហើយ នៅសល់តែរូបធម៌ស្លូក
ស្តើងនឹងថ្កល់លែងមានពុទ្ធដីកាតបតនឹងយើងទៀត ។ មរណកាលអង្គ

លោកនេះ នាំឲ្យយើងខ្ញុំនាំងឡាយសង្វេគតក់ស្លុត ព្រមនាំងលោក
ស្ពាយអង្គុំលោកជាបំផុតមិនដឹងធ្វើដូចម្តេច ព្រោះដាច់ដែលជុតវៃយ
មនុស្សលោកទឹងការពារបាន ទើបយើងខ្ញុំនាំងឡាយបបួលគ្នាមកគោរព
សពអង្គលោកក្នុងពេលបច្ចុប្បន្នេះ មានចិត្តសោរពេញដោយ
វិប្បរិយោគទុក្ខ ។

ព្រះតេជព្រះគុណ ព្រះអមរកិរ្តិ អ៊ុយ - ប៉ាង ជាក្រុមដំទុំព្រះ
ធម៌បិដកមួយរូប លោកចូលធ្វើការកាលពីថ្ងៃទី ២៨ ឆ្នាំ ១៩៣១ លោក
មានគុណសម្បត្តិសមត្ថភាពបរិបូណ៌ ក្នុងកិច្ចការរបស់ក្រុមដំទុំព្រះធម៌
បិដក ដោយការស្លាត់ជំនាញទឹងយកព្រះទ័យទុកជាក់ក្នុងកិច្ចការរបស់
ខ្ញុំនគួរសរសើរ ។ ហេតុនេះ ទើបព្រះករុណាជាម្ចាស់ដីរតែងតំ ព្រះ
មេត្តាប្រោស ព្រះរាជទានគ្រឿងឥស្សរិយយស (មេដែយ៍) មណី
សារកែណ្ឌ នៅថ្ងៃអង្គារ ៩កើត ខែកត្តិក ឆ្នាំម្សាញ់ត្រីស័ក ព.ស.
២៤៨៩ ។ មិនតែប៉ុណ្ណោះទេ លុះដល់មកថ្ងៃទី ១ កុម្ភៈ ១៩៤៤
ព្រះករុណាជាម្ចាស់ដីរតែ តែងតំព្រះមេត្តាប្រោសតែងតាំងជាអធិបតីរង
ក្រុមដំទុំព្រះធម៌បិដកទៀត ដើម្បីឲ្យសមតាមគុណសម្បត្តិសមត្ថភាព
របស់អង្គលោក ។

ដោយភ្ជាប់នៅរួមធ្វើការជាមួយគ្នាអស់កាលយូរ យើងខ្ញុំនាំងអស់
គ្នាបានស្គាល់ព្រះថេរៈអង្គនេះច្បាស់លាស់ណាស់ អង្គលោកជាអធិបតី

រង្គែមដ៏ខ្ពុំជាសង្គីតិកាវ្យមួយអង្គដ៏ប្រសើរ គួរពាប់ថាជាអ្នកច្បាជមួយអង្គ ក្នុងចំណោមអ្នកច្បាជទាំងឡាយក្នុងព្រះពុទ្ធសាសនា មានសណ្ដាប់ធ្នាប់សុភាពរាបសា មានព្រះទ័យខន់ក្ដួនស្រឡាញ់ពាប់អានសហការីទាំងឡាយគ្រប់គ្នាមិនរើសមុខ មានវាចាពីភេះគួរជាទីគោរព មានពុទ្ធដីកាទៅកាន់លោកអង្គណា ឬលោកណាមួយ តែងតែនាំយកមេត្តាចិត្តទៅផ្សំជាមួយផង នាំឲ្យសហការីទាំងឡាយស្រឡាញ់ពេញចិត្តពាប់អានហើយគោរពអង្គលោក ។

ពេលនេះ ព្រះតេជព្រះគុណ ព្រះអមរាភិរក្ខិត អ៊ុយ-ជ៉ាង ដែលយើងខ្ញុំបានពោលសរសើរកិត្តិគុណមកនេះ ផុតកិច្ចនឹងរស់នៅទៀតបានហើយ លោកនិមន្តទៅកាន់បរលោកហើយ នាំយកទាំងសេចក្ដីល្អទៅជាមួយអង្គលោកផង ទុកនៅសល់តែសពអង្គលោកនឹងការងារបស់លោក ជានិមិត្តរូបដែលមិនចេះស្ងាប់ ។ ព្រះតេជព្រះគុណ ព្រះ-អមរាភិរក្ខិត អ៊ុយ-ជ៉ាងនេះ លោកបានយកជីវិតអង្គលោកទៅរួមនៅក្នុងការប្រែសើរនេះ ដែលជាការមិនចេះស្ងាប់ បំណាច់បានជាតើតមកហើយមានជីវិតរស់នៅ ត្រូវធ្វើការឲ្យប្រសើរយ៉ាងនេះ សឹមស្ងាប់ទៅវិញ គឺតើតមកហើយត្រូវយកល្អឲ្យបាន ។ ដូច្នេះហើយ បានជាអ្នកច្បាជទាំងឡាយពោលទុកថា: "ស៊ូស្ងាប់ទៅជា រស់ធម៌កុំបីបាត់" ។

ព្រះតេជព្រះគុណ !

ពេលនេះ យើងមកជួបជុំគ្នាពោលសរសើរកិត្តិគុណ ព្រះតេជព្រះគុណ ពណ៌នារៀបរាប់សេចក្តីសោកស្តាយ ពោលហើយពោលទៀត ស្ទើរតែមិនអស់មិនហើយ ដោយសេចក្តីស្រណោះអាឡោះអាល័យជាទីបំផុត ។ ព្រះតេជព្រះគុណនិមន្តទៅក៏ពិតមែន តែសេចក្តីល្អរបស់ព្រះតេជព្រះគុណបិតនៅកង់ជួងចិត្តយើងខ្ញុំគ្រប់គ្នាមិនក្ងេច ។ យើងខ្ញុំដឹងជាក់ថា - ព្រះតេជព្រះគុណគង់មិនក្ងេចការងារព្រះត្រៃបិដកនេះទេ ។ នៅប្រទេសកាន់ពុទ្ធសាសនា គេតែងបានស្គាល់កិច្ចការយើងប្រាកដណាស់ ; ពេលនេះទៀត, នៅប្រទេសកូមា ព្រះមហាថេរានុត្ថេរៈទាំងអស់ក្នុងសកលលោក មកប្រជុំធ្វើធម្មសង្គាយនានៅក្រុងរ៉ង្គុន ព្រះសង្ឃតិកាចារ្យទាំងអស់អង្គនេះ បានទទួលស្គាល់ព្រះត្រៃបិដកយើង គេយកព្រះត្រៃបិដកយើងជាគោល ជាមេបែបបទ ក្នុងការសង្គាយនាទី ៦ នេះ ។ ដូច្នោះ ! ការងារយើងជាការដ៏ប្រសើរបំផុត បានទុកស្មាព្រះហស្តជាក័ស្តុតាងស្រាប់ ។ រាល់ថ្ងៃ ព្រះតេជព្រះគុណគង់សរសេរ គង់ពិនិត្យ, ងំជញ្ជឹងគិត ទាំងអស់នេះ ធ្លាក់ជាប់នៅក្នុងក្រដាស គឺព្រះត្រៃបិដកយើងនេះ, ព្រះតេជព្រះគុណ មុខជានឹងយកសេចក្តីល្អនេះជាប់ទៅជាមួយព្រះអង្គផង ហើយនិមន្តទៅកើតកង់ទិព្វវិមានឯណោះបុរី ។ យើងខ្ញុំទាំងអស់គ្នា នៅខាងក្រោយចេះតែចំបន្តកិច្ចការដ៏ប្រ-

សើរនេះតទៅទៀត រហូតដល់ទីបំផុត ។ អំណើះតទៅ យើងខ្ញុំទាំងអស់គ្នាមានតែសេចក្តីអាឡោះអាល័យនឹងសេចក្តីសោកស្តាយមិនភ្លេច ។

យើងខ្ញុំទាំងអស់ពោរពេញដោយទុក្ខ សូមប្រមូលបុញ្ញភាគីនៃយើងខ្ញុំគ្រប់គ្នាលើកលើសិរសា ដម្កល់ទុកជាធម្មបណ្ណាការដ៏ខ្ពង់ខ្ពស់ ទុទ្ទិសប្រគេនព្រះតេជព្រះគុណ សូមព្រះតេជព្រះគុណទទួលយកដោយរីករាយ ហើយសូមឲ្យបានសម្រេចជាបត្តានុមោទនាមយ: សូមឲ្យបានប្រកបដោយឥដ្ឋមនុញ្ញផលវិបុលសុខសិរីសួស្តីជយមង្គលតរៀងទៅ ! ។

ទីបំផុត, យើងខ្ញុំទាំងឡាយ សូមខមាទោស ចំពោះព្រះតេជព្រះគុណ សេចក្តីត្អូញត្អែងលើសលោះដោយកាយវាចាចិត្តក្តីណា សូមព្រះតេជព្រះគុណអត័យទោសដោយការញ៉ែកាពឲ្យបាន ។

* * *

បន្ទាប់មក ព្រះអរិយកស្សប អ៊ូច បានថ្លែងសុន្ទរកថាពណ៌នាពីប្រវត្តិរូបនិងគុណសម្បត្តិ នៃសពព្រះអមរាភិវង្សតិ អ៊ុយ-ចាំង ដូចមានសេចក្តីសង្ខេបតទៅ :

ព្រះអមរាភិវង្សតិ (អ៊ុយ-ចាំង) កំណើតនៅភូមិកំពង់ចិនក្នុងឃុំវិញដាំង ខែត្រកែមួនស បិតានាម អ៊ុយ មាតានាម អាត់ សម្លាប់នៅឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៥ ។ កាលនៅពីកុមារបានអាយុ ១៧ ឆ្នាំ បិតានាំកុមារ អ៊ុយ-ចាំង នេះ ឲ្យទៅនៅសិក្សាអក្សរសាស្ត្រ នឹងលោក

គ្រូ សុីម ជាចៅអធិការវត្តចាស់ស្តេតគណៈធម្មយុត្តិ ខែត្រចាក៏ចក្នុង ដែនកូសាំងសុីន ។ លុះកុមារ អ៊ុយ-ចាំង រៀនសូត្រចានចេះដឹងគួរសម ហើយ លោកគ្រូ សុីម ក៏ឲ្យបព្វជ្ជាជាសាមណេរនៅវត្តនោះបានមួយ ព្រះវស្សា ។ មានទុជាសកម្នាក់នាម ទឹម-ទិត នៅក្រុងកំពេញចាំង់បាន បព្វជ្ជាសិក្សាកងសំណាក់សម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្ម-យុត្តិ វត្តបទុមវតី ស្រុកកំណើតនៅខែត្រកែមួនសដែរ បានទៅជួបនឹង សាមណេរ អ៊ុយ-ចាំង បានទូលរៀបរាប់អំពីលទ្ធិព្រះពុទ្ធសាសនា ចាប់សាមណេរ អ៊ុយ-ចាំង។ មានចិត្តជ្រះថ្លាចង់ចេះដឹង ទើបសុំអនុញ្ញាត ពីលោកគ្រូ តាមទុជាសកទិតមកនៅកំពេញ ។ ទុជាសកនេះបានទាំ យកលោកទៅប្រគេនសម្តេចព្រះមង្គលទេព្វាចារ្យព្រះនាម អៀម សង្ឃ-នាយកវត្តបទុមវតី ឲ្យនៅសិក្សាព្រះត្រៃបិដក ។ លុះព្រះជន្ម ២១ ឆ្នាំ សាមណេរ អ៊ុយ-ចាំង ទុបសម្បទាជាភិក្ខុភាវៈនាមប្បញ្ញត្តិធាយាហៅថា ខេមកោ ។ តមកបានឡើងសមណសក្តិជាព្រះចតុប្បាត់អរិយមុនី ។ លុះបួសបាន ៧ ព្រះវស្សា បានសូមលាសម្តេចព្រះមង្គលទេព្វាចារ្យជា ទុបជ្ឈាយ៍ចេញទៅបំពេញវិជ្ជានៅក្រុងចាងកក អាស្រ័យនៅវត្តបវរ-នីវេសន៍ ក្នុងសំណាក់សម្តេចព្រះមហាសមណៈ ទំព្យាយាមបំពេញវិជ្ជា អស់រយៈ ៨ ព្រះវស្សាចេះដឹងសមគួរ ទើបវិលត្រឡប់មកប្រទេសកម្ពុជា នៅអាស្រ័យក្នុងវត្តបទុមវតីភជវាពមវិញ ។ សម្តេចព្រះមង្គល

ខេត្តបាត់ដំបង ព្រះនាម ស៊ុក ជានាមសម័ណសក្តិលោកជាព្រះមហាឧត្តុល; ខាងក្រោយមកបានតាំងសមណសក្តិជា ព្រះអមរកិរត្តិត ជាគណៈ ធ័ចត្តា ។ ព្រះថេរៈអង្គនេះមានគុណសម្បត្តិសមគួរតាមឋានៈបូណ៌ ជាន ចូលធ្វើជាក្រុមជំនុំព្រះត្រៃបិដក ដោយការស្នាត់ជំនាញក្នុងមុខការរបស់ លោក ទើបព្រះករុណា ព្រះបាទសីហនុ ព្រះរាជទានគ្រឿងឥស្សរិយយស (មេដែយ) មណីសារកន្ធា ហើយនឹងតែងតាំងជាអធិបតីរងក្រុមជំនុំព្រះត្រៃបិដក ឱ្យសមតាមឋានៈរបស់លោក ។

*
* *

ម៉ោង ១៨ ថ្ងៃទី ៣ មិថុនា ១៩៥៤ ឯកឧត្តមផ្ទួ-ត្រឿង រដ្ឋមន្ត្រី ក្រសួងធម្មការនឹងឥស្សរជនព្រមទាំងនាហ្នឹងធំ-តូច បានយកខ្លឹមបទន្ធ ទៅសូមខមាទោសចំពោះសពតាមទំនៀមទម្លាប់ រួច ឯ. ឧ. រដ្ឋមន្ត្រី ក្រសួងធម្មការបានបូជាភ្លើងជាកិត្តិយស ។

ពិធីឈាបនកិច្ចសពនេះ បានបញ្ចប់នៅពេលម៉ោង ១៩ ទឹង ២០ នាទី ។

# ភទ្ធមសនិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ២៦ ខែតុលា លេខ ១០

ព.ស. ២៤៩៧ _ គ.ស. ១៩៥៤



# តាន់ដែលសិរីយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — វិរិយារម្ភកថា | ព្រះគ្រូ កែ - អឿន | ៧២៣ |
| — ពុទ្ធបរិស័ទ គឺអ្នកណា (តបប់) | ឃុនបណ្ណានុរ័ក្ស ប៊ូ - ប៊ូ | ៧៣៥ |
| — បញ្ញាសជាតក ភាគទី ២ (តមក) | បណ្ឌិតមហា ឈឹម - ស៊ីម | ៧៥៣ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — រឿងសៅរ៍សោយ (តមក) | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៊ម | ៧៦៧ |
| — រឿងសាមកុក (តមក) | ឧកញ៉ា ន្ល - កន | ៧៧៤ |
| — ឥសិនទីងទមយន្តី (តមក) | អ្នកស្រី ស្រ៊ុន - សារីយ៉ាន់ | ៧៨០ |
| — ដំណឹងតាមខ្សល់ក្នុងកន្ទារៈ (តមក) | លោក ផេង - ជ្រឹ | ៧៨៦ |
| — រឿងបល្ល័ង្កទិព្យ | លោកវ៉ាយ - ប៊ុក | ៧៩១ |
| **កំណត់ទឹងប្រវត្តិការណ៍** | | |
| — ពិធីបុណ្យដួងសាលាចាលីរង វត្តព្រះព្រហ្ម. រតន៍ ខែត្រសៀមរាប | ព្រះគ្រូ កែ - អឿន | ៧៩៤ |



មួយឆ្នាំមាន ៤២ លេខ — ដំឡៃដារ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*

PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Viriyarambhakatha . . . . . | M. Vén. KER - OEURN . . . . | 723 |
| — Les Bouddhistes (suite et fin) . | M. BOU-PO . . . . . | 735 |
| — Pannasajataka vol-II (suite) . | M. CHHIM-SOUM . . . . . | 753 |


PARTIE LITTERAIRE:


| | | |
|---|---|---|
| — Le « SAU-SOY » ou l'influence saturnienne (suite) . . . . . | Vén. PEUNG-PAM . . . . . | 767 |
| — Histoire de Samkok (suite) . . | Oknha NOU-KAN . . . . . | 774 |
| — Nala et Damayanti (suite) . . | Mme SRIN-SARIS-YANN . . . | 780 |
| — Le souffle du désert (suite) . | M. PHENG-CHRIV . . . . . | 786 |
| —Les trente deux récits du TRONE | M. RAY - BUC . . . . . | 790 |


NOTES ET CHRONIQUES:


| | | |
|---|---|---|
| — L'inauguration de l'Ecole Elémentaire de Pali de vat Brah Promrat | Vén. KER - ŒURN . . . . . | 794 |


Prix d'abonnement annuel (comprenant 12 numéros) 200$00

# វិរិយារម្ភកថា

## ព្រះគ្រូបាសាទរង្ស៊ីអ្នគុណ កែ-អឿន (វិរិយប្បញ្ញោ)

### វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប

រៀបរៀង

---

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

វេលានេះ ទើបសំដែងព្រះសទ្ធម្មទេសនាកថាវិរិយារម្ភកថា ដើម្បីប្រជាប់សត្តបញ្ញា ទើបជាគ្រឿងជួយជ្រោមជ្រែងឲ្យកើតឧស្សាហៈកន្លងសម្មាបដិបត្តិ ដល់សាធុជនពុទ្ធបរិស័ទទូទៅតាមពុទ្ធានុសាសនីថា:

កោសជ្ជំ ភយតោ ទិស្វា វិរិយារម្ភញ្ច ខេមតោ
អារទ្ធវិរិយា ហោថ ឯសា ពុទ្ធានុសាសនី

ប្រែថា "អ្នកទាំងឡាយ បើឃើញសេចក្តីខ្ជិលថាជាភ័យហើយ ឃើញសេចក្តីព្យាយាមដ៏មុឺងមាត់ថាជាសេចក្តីក្សេមហើយ ចូរជាអ្នកមានសេចក្តីព្យាយាមដ៏មុឺងមាត់ចុះ, នេះជាពុទ្ធានុសាសនី" ។

អធិប្បាយថា: ធម្មតាបុគ្គលគ្រប់រូបមែងមានការណីយកិច្ចដែលត្រូវធ្វើ ទាំងជានាទីរបស់ខ្លួននិងនាទីរបស់បុគ្គលដទៃ ។ ឯនាទីរបស់ខ្លួននោះ គឺការតាំងខ្លួនឲ្យបានជាអ្នកមានហានៈខ្ពង់ខ្ពស់កន្លងលោកនេះ, ឯនាទីរបស់បុគ្គលដទៃនោះ គឺនាទីដែលខ្លួនត្រូវធ្វើដល់អ្នកដទៃតាមសមគួរដល់ឧកាសដូចជាខ្លួនទៅកន្លងហានៈជាអ្នកតូច ក៏ត្រូវស្តាប់បង្គាប់លោកអ្នកធំ ជួយ

ធ្វើឆ្នុះរបស់លោកឲ្យសម្រេច ចូរព្រឹត្តខ្លួនឲ្យជាទីស្រឡាញ់គាប់ចិត្ត លោកអ្នកធំៗ ក៏ត្រូវមានមេត្តាករុណាដល់អ្នកតូច ជួយអនុគ្រោះអ្នកតូចឲ្យបានសុខផង ធ្វើខ្លួនឲ្យជាទីពឹងពំនាក់របស់អ្នកតូច រហូតដល់ការណីយកិច្ចផ្សេង ។ មានកិច្ចដែលចាត់ទង់ដល់ជាតិ - សាសនា - មហាក្សត្រដោយហាន:ជាពលរដ្ឋរបស់ជាតិនឹងរបស់សាសនាផង ។ ការណីយ-កិច្ចទាំងអស់នេះ បើបុគ្គល:ធ្វើបានសម្រេចដោយរៀបរយ ក៏ជាគុណធ្វើខ្លួន ឲ្យមានតម្លៃថ្លៃថ្នូរ ទាំងបានឈ្មោះថាខ្លួនជាទីពឹងរបស់ខ្លួន ។ ជនបែបនេះមិនគ្រាន់តែជាទីពឹងរបស់ខ្លួនប៉ុណ្ណោះទេ អាចជាទីពឹងអាស្រ័យរបស់ជនខ្លះទៀតបាន ។ ទីពឹងទាំងពីរប្រការនេះ មនុស្សគ្រប់គ្នារមែងត្រូវការជ្រុះថ្នាំដូចគ្នា ប៉ុន្តែមានបុគ្គលខ្លះមិនអាចសម្រេចលទ្ធផលតាមជ្រុះថ្នាំ ។ រឿងនេះមិនមែនព្រោះអ្វី ព្រោះតែសេចក្តីខ្ជិលដែលជាមេកិលេសមួយធំ ទាំមិនឲ្យបានសម្រេចដូចជ្រុះថ្នាំ ។

សេចក្តីខ្ជិលនេះ ជាកិលេសមួយដែលមានទោសជាអនេកប្បការ ហើយជាកំពែងព័ទ្ធកំងមិនឲ្យសេចក្តីចំរើនចូលមកក្នុងសន្តានបាន ធ្វើឲ្យចិត្តរួញរាក្នុងការងារគ្រប់ជំពូក ទោះបីធ្វើការងារណា ក៏ធ្វើសោះតែគេថា មិនធ្វើដោយតាំងចិត្តប៉ងនឹងឲ្យសម្រេច ។ មនុស្សខ្ជិលច្រើនអាងហេតុថា ពេលនេះក្តៅណាស់, រងារណាស់, ត្រជាក់ណាស់, ព្រឹកណាស់, ល្ងាចណាស់, ឃ្លានណាស់, ឆ្អែតណាស់ ដូច្នេះ ហើយមិនធ្វើការងារ ។

ការសិក្សាសូត្រវៀនសិល្បវិជ្ជា បើខ្វិលមិនព្យាយាមសូត្រទន្ទេញ
ទេ សិល្បវិជ្ជាការនោះ ក៏ដល់នូវសេចក្តីភ្លាំងភ្លេចសាបសូន្យអស់ទៅ;
បុគ្គលអ្នកគ្រប់គ្រងផ្ទះសម្បែង បើខ្វិលមិនជួសជុលផ្ទះដែលគ្រាំគ្រាទេ
ផ្ទះនោះក៏នឹងបាក់បែកភ្លាត់ភ្លាយអន្តរាយទៅ, គ្រហស្ថឬបព្វជិត បើខ្វិល
មិនទុស្សាហ៍ដំរះដុសលាងកាយ ឬគ្រឿងប្រើប្រាស់ទេ រាងកាយឬ
គ្រឿងប្រើប្រាស់នោះក៏នឹងមានពណ៌និងក្លិនសៅហ្មងមិនស្អាត, បុគ្គល
អ្នកមានទ្រព្យសម្បត្តិ បើខ្វិលមិនប្រុងប្រយ័ត្នរក្សាឲ្យល្អទេ ទុកដូចជា
បើកទុកាសឲ្យចោរលួចយកទៅបាន ។ សេចក្តីនេះសមដូចព្រះពុទ្ធភាសិតថា:

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ

ប្រែថា: មន្តទាំងឡាយមានការមិនសូត្រឆ្លាយជាមន្ទិល, ផ្ទះទាំង-
ឡាយមានការមិនជួសជុលជាមន្ទិល, សេចក្តីខ្វិលប្រអូសជាមន្ទិលដល់
ពណ៌សម្បុរ, សេចក្តីប្រមាទជាមន្ទិលរបស់អ្នករក្សា ។

បុគ្គលដែលខ្វិលមិនធ្វើការងារ រមែងមិនបានទទួលនូវទ្រព្យដែល
ជាហេតុឲ្យកើតសេចក្តីសុខកាយ សុខចិត្ត ។ មនុស្សខ្វិលរមែងបានជួប
ប្រទះតែផ្លូវវិនាសអន្តរាយគោតទ្រព្យ មិនដែលបានទទួលសេចក្តីសុខ
ដែលកើតអំពីលោកិយទ្រព្យ មិនចាំបាច់និយាយដល់ទៅសេចក្តីសុខ ដែល
ជាលោកុត្តរទ្រព្យនោះឡើយ ។

ម្យ៉ាងទៀត មនុស្សឆ្កួល គ្រៀអំពីភ្លាត់ចាកប្រយោជន៍ ចាក
សេចក្តីសុខនោះហើយ នៅមានការប្រព្រឹត្តិមិច្ចាជីវៈ ប្រកបការងាររក
ស៊ីមិនត្រឹមត្រូវតាមគន្ធងមិមានលួចបន្លំជាដើម ដោយសំគាល់ការងារជា
សម្មាអាជីវៈ ថាជាការបំបាកហួសនិស្ស័យខ្លួន; មនុស្សកំដៀលនោះ
ឈ្មោះថាធ្វើទុក្ខឲ្យមានដល់ខ្លួនឯង ក្នុងបច្ចុប្បន្ន ទំងអនាគត គឺក្នុងបច្ចុប្បន្ន
មានក្តៅក្រហាយព្រោះត្រូវម្ចាស់គេប្រទូសរ៉ាយ ហើយនៅមានគេចាប់
ចងដាក់ទោសទៀត ឬបើគេចាប់មិនបានក៏គង់មានភ័យខ្លាចនឹកអោ ដេក
មិនលក់ បរិភោគមិនឆ្ងាយ, កាលបើលះលោកនេះទៅហើយ ទោសនោះ
ក៏នៅជាប់តាមទៅឲ្យផលទៀត ។ សមដូចព្រះពុទ្ធដីកាដែលព្រះបរមគ្រូ
ទ្រង់ត្រាស់ទុកក្នុងសព្វលហុសសូត្រថា: "ម្នាលភិក្ខុទាំងឡាយ! បុគ្គល
ប្រព្រឹត្តនូវការកាន់យកវត្ថុដែលគេមិនបានឲ្យ រមែងជ្រាបខ្លួនតែលួចដែល
ជាហេតុឲ្យភ្លាត់នរក; ការកាន់យកវត្ថុរបស់ដែលម្ចាស់គេមិនបានឲ្យ មាន
ទោសយ៉ាងស្រាលបំផុត ត្រឹមធ្វើមនុស្សអ្នកប្រព្រឹត្តឲ្យវិនាសចាកភោគ
ទ្រព្យ, កិរិយាកស៊ីដូច្នេះជាអំពើរបស់មនុស្សឆ្កួល, មនុស្សឆ្កួលមិនធ្វើការ
ងារប្រព្រឹត្តតែចោរកម្មនោះ មិនអាចនឹងគ្រប់គ្រងផ្ទះបានទេ ភោគទ្រព្យ
ដែលមិនទាន់កើត ក៏នឹងមិនកើតឡើង ភោគទ្រព្យដែលកើតឡើងហើយ
នឹងវិនាសសាបសូន្យទៅវិញ ទ្រព្យទាំងឡាយចេះតែកន្ធរលង់បុគ្គល
នោះទៅ" ។ បុគ្គលឆ្កួលជាមនុស្សឥតទ្រព្យឥតទ្រាជ្យ, នៅក្នុងលោក
នេះក៏តាំងខ្លួនមិនបាន ជាមនុស្សអស់ពីតិចពាក់ព័ន្ធនាក់អាស្រ័យ ឈម

មុខទៅតឹងនណាក៏តឹងមិនបានដូចចិត្តប៉ង់ ក្លាយទៅជាមនុស្សគ្រែក្រែលំបាក អស់សេចក្តីក្សេមក្សាន្តអំពីខ្លួន ជាមនុស្សលិចចុះក្នុងសេចក្តីទុក្ខមិនមានថ្ងៃណាដែលនឹងបានផុសឆើបមុខឡើងបានឡើយ ដូចគល់ដុំថ្មដែលធ្លាក់ចុះក្នុងស្ទឹងដ៏ជ្រៅ ទោះបីមានដីវាស់នៅក៏គេសេចក្តីចំរើនមិនមាន ព្រោះហេតុនេះហើយទើបលោកចាត់ថា: កិរិយាខ្ជិលច្រអូសនេះជាភ័យមួយយ៉ាងធំក្រៃលែង ។ ប្រទេសណាសម្បូណ៌ដោយប្រជាជនខ្ជិលច្រែន ប្រទេសនោះរមែងកប់ទៅលើភ័យតែម្យ៉ាងប៉ុណ្ណោះ ។ កាលបើប្រជាជនឃើញសេចក្តីខ្ជិលថាជាភ័យហើយ គួរព្យាយាមប្រឹងប្រែងប្រកបការងារបស់ខ្លួន ដោយមិនរួញរាតត្បួញត្អែរ ទោះបីមានទុបស័គ្គគ្រោះថ្នាក់យ៉ាងណាមកកាំង ក៏មិនលះបង់កិច្ចការនោះ ទុស្សាហ៍ខ្ពស់ខ្ជាយតស៊ូតស៊ាតែមានជ័យជំនះឈ្នះទុបស័គ្គ គ្រាតែបានសម្រេចផលដែលខ្លួនប្រាថ្នា ។

សេចក្តីព្យាយាមនោះមានលក្ខណៈ ៣ ប្រការគឺ:

១.— អនិក្ខិត្តធុរតា ការមិនដាក់ធុរៈចោល

២.— អនិព្វិគ្គតា ការមិនខ្សឹយណាយធុញគ្រាន់

៣.— អសង្កុរតា ការធ្វើការងារតាមកាលវេលាមិនបណ្តោះដៃ ។

សេចក្តីព្យាយាមនេះ បើបុគ្គលយកទៅប្រើក្នុងផ្លូវល្អដែលហៅថា សម្មាវាយាម: (ព្យាយាមត្រូវ) នោះរមែងអំណោយផលល្អ, បើនាំយកទៅប្រើក្នុងផ្លូវមិនល្អដែលហៅថា មិច្ឆាវាយាម: (ព្យាយាមខុស) រមែង

អំណោយផលអាត្រក់ ។ តែសេចក្តីចំណង់ក្នុងពុទ្ធសាសនេះ ព្រះបរមគ្រូទ្រង់សំដែងយកព្យាយាមដែលត្រូវ ព្រោះសេចក្តីព្យាយាមត្រូវអាចឲ្យសម្រេចប្រយោជន៍ខ្ពង់ខ្ពស់ទាំងបុគ្គលដទៃទៀត តាំងមិនជាការបៀតបៀនគ្នាទាំងគ្នាផង ។

រឿងនេះ គប្បីឃើញតួយ៉ាងដូចព្រះបរមសាស្តា កាលទ្រង់តាំងសេចក្តីព្យាយាមស្វែងរកពោធិញ្ញាណ ចាប់តាំងពីទ្រង់បំពេញបារមីមកអស់រយៈវេលាជាច្រើនសែនកំប្បទៅគ្មានទាំងបច្ចុប្បជាតិ, មុនពេលដែលព្រះអង្គបានត្រាស់ដឹង តំបន់ស្តេចទៅសិក្សាក្នុងសំណាក់នៃគ្រូដទៃ ទាំងទ្រង់បំពេញព្យាយាមយ៉ាងតឹងរ៉ឹង រហូតដល់បានត្រាស់នូវអនុត្តរសម្មាសម្ពោធិញ្ញាណសមតាមបំណង ។ សេចក្តីសម្រេចនេះ ឲ្យផលយ៉ាងធំក្រៃលែង គឺព្រះអង្គទ្រង់ធ្វើផ្តាច់សេចក្តីទុក្ខបាន ហើយថែមទាំងស្តេចចារិកទៅប្រៀនប្រដៅរំនេយ្យសត្វ ឲ្យបានផ្តាច់ទុក្ខផងទៀត រហូតដល់ទ្រង់ប្រតិស្ឋានព្រះធម៌វិន័យល្អប្រពៃ ទុកជាសាសនា ឲ្យពួកយើងប្រតិបត្តិប្រតិបត្តិតាមដរាបដល់សព្វថ្ងៃនេះ នេះជាផលនៃសេចក្តីព្យាយាមត្រូវ ។ សូម្បីក្នុងកាលជាខាងក្រោយអំពីកាលដែលព្រះអង្គត្រាស់ដឹងមក ព្រះអង្គបានត្រាស់ទៅនឹងភិក្ខុទាំងឡាយថា អប្បដិវានី សទាហំ បទុហាមិ ជាដើម (ប្រែថា) “ម្នាលភិក្ខុទាំងឡាយ! តថាគតមិនជាអ្នកថយក្រោយ, ផ្តើមតាំងសេចក្តីព្យាយាមថា សាច់ទាំង

ឈាមកង៏ពង៏កាយរបស់តថាគតនេះ ចង៏រែងសូតហួតហែង៏ទៅ សល់
នៅតែស្បែកនឹង៏ឆ្អឹង៏ក៏ដោយ, ផលឯណាដែលគប្បីសម្រេចដោយកំលាំង
នៃបុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីខ្នើយហាត់បែក
ញើសហូរញើសរបស់បុរស បើមិនទាន់បានសម្រេចផលនោះទេ
តថាគតនឹង៏មិនបញ្ឈប់សេចក្តីព្យាយាមជាដាច់ខាត" ។

ត្រង់ដែលថា "ឃើញសេចក្តីព្យាយាមដ៏ម៉ឺង៏ម៉ាត់ថាជាសេចក្តីក្សេម"
កង៏ពុទ្ធកាសិតនេះ គឺឃើញថាសេចក្តីព្យាយាមជាហេតុនៃផលគឺសេចក្តី
សម្រេចអំណោយផលល្អទាំង៏កង៏គតិលោកនឹង៏គតិធម៌ ។ កង៏គតិលោក,
មានព្រះពុទ្ធកាសិតដែលត្រាស់ដល់អាឡវកយ័ក្ខកង៏យក្ខសំយុត្តជាគ្រឿង
អាង៏ថា បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ "អ្នកមានធុរៈ
ធ្វើការដោយម៉ាត់ចត់ រមែង៏រកទ្រព្យបាន" ។ កង៏គតិធម៌, ដូចព្រះអង្គ
ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំង៏ឡាយ! អរិយសាវ័កកង៏ព្រះធម៌វិន័យនេះ
ជាអ្នកមានសេចក្តីព្យាយាមតឹង៏រឹង៏ ដើម្បីលះអកុសលធម៌ ដើម្បីសេចក្តី
ដល់ព្រមនៃកុសលធម៌ ជាអ្នកមានកំលាំង៏កំហែង៏ ទោះបីខ្នើយហាត់
ក៏មិនដាក់ធុរៈកង៏កុសលធម៌ ។ លោករមែង៏ពេញចិត្តនឹង៏សេចក្តីព្យាយាម
ច្រានបង្ខសេចក្តីព្យាយាម ផ្តង៏ចិត្តផ្តើមតាំង៏ចិត្តទុក ដើម្បីមិនឲ្យកើតឡើង
នៃអកុសលធម៌ដ៏លាមកដែលកើតឡើង៏ហើយ ដើម្បីញុំង៏កុសលធម៌
ដែលមិនទាន់កើតឲ្យកើតឡើង ដើម្បីតាំង៏នៅ ដើម្បីសេចក្តីមិនសាបសូន្យ

ដើម្បីកើតឡើងដោយវិត្រៃលែង ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីបរិបូណ៌នៃកុសលធម៌ ដែលកើតឡើងហើយដូច្នេះជាដើម" ។

កាលបើបុគ្គលពិចារណាឃើញសេចក្តីខ្លិលថាជាភ័យ ឃើញសេចក្តីព្យាយាមដ៏មុះមុតថាជាដែនកើតនៃសេចក្តីក្សេមក្សាន្ត គឺឃើញសេចក្តីខ្លិលដូចអាសិរិស ឃើញសេចក្តីព្យាយាម ដូចទុសថដែលបំបាត់ពិសដូច្នេះហើយ ក៏គប្បីលះបង់សេចក្តីខ្លិលចោលចេញ ហើយប្រកបសេចក្តីព្យាយាមក្នុងការងារដែលត្រឹមត្រូវឡើង ដូចមានពុទ្ធភាសិតថា:

អនត្ថំ បរិវជ្ជេតិ អត្ថំ គណ្ហាតិ បណ្ឌិតោ

"បណ្ឌិតវៃងលះវៀរនូវរបស់ដែលគ្មានប្រយោជន៍ កាន់យកតែរបស់ដែលមានប្រយោជន៍" ។

ក្នុងគតិលោក. សេចក្តីព្យាយាមជាកំលាំងយ៉ាងមាំក្នុងកិច្ចការគ្រប់ធំៗ បុគ្គលដែលនឹងតាំងខ្លួនបាន រហូតដល់មានកិត្តិយសខ្ពស់ក្តី ប្រទេសជាតិនឹងរុងរឿងឈានទៅមុខក្តី ក៏ព្រោះប្រជាជនជាពលរដ្ឋរបស់ប្រទេសនោះកន្ធាក់ៗ សុទ្ធតែជាអ្នកមានសេចក្តីព្យាយាមខំប្រឹងប្រកបការងារតាមនាទីរបស់ខ្លួនៗ មិនរង្គើរង្គាន់កន្តើកន្តៅក្នុងផ្លូវអបាយមុខ ដែលជាប្រធាននៃសេចក្តីវិនាស គឺមិនធ្វើសុភនិមិត្តភ័យ ដែលជាតំណាងនៃសេចក្តីប្រមាទ ព្រោះជាហេតុឲ្យធ្លាក់សេចក្តីអាក្រក់ឯទៀតៗ, មិនដើរកណ្តាលយប់ព្រលប់ ព្រោះជាហេតុឲ្យខូចការងារនឹងកសេចក្តីរង្គើសសង្ស័យដល់

មនុស្សគាំងឆ្ងាយ. មិនលេងល្បែងក្តាល់មានប្រការផ្សេង។ ព្រោះជាហេតុ
ឲ្យខូចខ្យសម្បត្តិ ទឹងធ្វើនិស្ស័យឲ្យថោកទាបថយចុះ, មិនគប់មនុស្ស
អាក្រក់ជាមិត្តព្រោះជាហេតុនាំឲ្យធ្វើសេចក្តីអាក្រក់ មិនជាប់ចំនុកចុកចិត្ត
ជឿរបស់មនុស្សគាំងឆ្ងាយ ។ អ្នកដែលមានសេចក្តីប្រាថ្នាខ្លួរសេចក្តីចំរើន
ដោយកោតខ្យ គប្បីវៀរចាកហេតុនៃសេចក្តីវិនាសគាំងនេះចេញ ។

បើអ្នកណាសង្ឃឹមពឹងផ្អែកទៅលើអ្នកដទៃទឹងបច្ច័យខាងក្រៅ មាន
សង្ឃឹមជោគជាតាកាសីជាដើម សេចក្តីសង្ឃឹមបែបនេះ ជារបស់មិនគាប់
គួរសោះ ព្រោះជាគ្រោះបង់ច្រើនជាងគ្រោះបាន ។ ព្រោះហេតុនោះ
ទើបគួរកំចាត់ឲ្យអស់ចេញ ហើយបែរមកនិយមត្រែកអរជឿមាំក្នុងកម្មាំង
កាយទឹងសតិបញ្ញារបស់ខ្លួន ទើបទឹងបានសម្រេចផលសមតាមបំណង
មិនខាន ។

ចំណែកគតិធម៌, បុគ្គលដែលចំរើនលូតលាស់ក្នុងធម៌ពាក្យប្រៀន
ប្រដៅរបស់ព្រះពុទ្ធ រហូតដល់រលាស់ខ្លួនចេញចាកទុក្ខបាន ក៏ព្រោះ
អាស្រ័យសេចក្តីព្យាយាម ដូចមានពុទ្ធភាសិតថា: វីរិយេន ទុក្ខមច្ចេតិ
“បុគ្គលដែលទឹងកន្ធងផុតសេចក្តីទុក្ខទៅបាន ក៏ព្រោះសេចក្តីព្យាយាម” ។

សេចក្តីព្យាយាមនោះបែកជា ៤ គឺ:

๑– ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើងក្នុងសន្តាន,

๒– ព្យាយាមលះបាបដែលកើតឡើងហើយ,

๓- ព្យាយាមធ្វើកុសលឲ្យចំរើនឡើងក្នុងសន្តាន,

๔- ព្យាយាមរក្សាកុសលដែលកើតឡើងហើយមិនឲ្យសាបសូន្យ។

ប៉ុន្តែសេចក្តីព្យាយាមទាំង ๔ នេះ បើបំព្រួញឲ្យខ្លីចុះមកមានត្រឹម ๒ គឺព្យាយាមលះបាប ๑, ព្យាយាមចំពេញកុសល ๑ ទាំងពីរយ៉ាងនេះជាកិច្ចគួរធ្វើ ។ ប៉ុន្តែមនុស្សពាលយល់ឃើញថាលំបាកធ្វើ ចំណែកបណ្ឌិតយល់ឃើញថា ងាយធ្វើ ព្រោះចិត្តរបស់បណ្ឌិតតែងត្រេកអរក្នុងការប្រព្រឹត្តិល្អជានិច្ច ដូចព្រះគាសិតថា សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ សេចក្តីល្អមនុស្សល្អធ្វើបានដោយងាយ, សេចក្តីល្អមនុស្សអាក្រក់ធ្វើបានដោយលំបាក" ។

មនុស្សល្អ រមែងខ្វល់ខ្វាយក្នុងការលះសេចក្តីអាក្រក់ ប្រព្រឹត្តសេចក្តីល្អ ។ សេចក្តីអាក្រក់នឹងសេចក្តីល្អទាំងពីរនេះ ជារបស់ដែលបុគ្គលអាចនឹងលះនឹងបំពេញឲ្យមានបាន ។ ព្រះបរមគ្រូសាស្តាចារ្យបានត្រាស់ទុកថា "នែភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរលះអកុសលចេញចុះ, ព្រោះបុគ្គលអាចនឹងលះអកុសលបាន, បើសិនជាបុគ្គលមិនអាចនឹងលះអកុសលបានទេ តថាគតក៏មិនអាចនឹងប្រៀនប្រដៅឲ្យអ្នកទាំងឡាយលះអកុសលបានដែរ; មួយទៀត អកុសលនេះ បើបុគ្គលលះបានហើយ ប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខវិញ តថាគតក៏មិនប្រៀនប្រដៅអ្នកទាំងឡាយឲ្យលះ

អកុសលដែរ; តែអកុសលនេះបុគ្គលអាចនឹងលះបាន កាលបើលះបាន ហើយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍នឹងសេចក្តីសុខ ទើបតថាគតប្រដៅអ្នកទាំងឡាយឲ្យលះអកុសល" ដូច្នេះ នេះជាបហានកិច្ច គឺកិច្ចដែលគួរលះ ។ សូម្បីក្នុងការនៅកិច្ចៗ ដែលគួរចំរើន ក៏អាចធ្វើបានដូចគ្នា ។ កិច្ចទាំងពីរនេះបុគ្គលអ្នកមានព្យាយាម អាចធ្វើឲ្យសម្រេចបានៗ មនុស្សអ្នកមានព្យាយាមទំនើបច្រើនធ្វើការងារ ដែលប្រាសចាកទោសបានច្រើនមកហើយ រមែងបានទទួលប្រយោជន៍អំពីកោតច្រើន៥យ៉ាងគឺ:

๑.- ចិញ្ចឹមខ្លួននឹងមាតាបិតា បុត្រកពរយោបាវព្រាវឲ្យជាសុខ;

๒.- ចិញ្ចឹមមិត្តសំឡាញ់ឲ្យជាសុខ;

๓.- បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ;

๔.- ធ្វើពលី ๕ យ៉ាងគឺ: ក)- សង្គ្រោះញាតិ, ខ)- ទទួលភ្ញៀវ, គ) ធ្វើបុណ្យទទឹសឲ្យដល់អ្នកស្លាប់, ឃ)- ថ្វាយពន្ធដារដល់រាជការដែនដីសូម្បីសង្គ្រោះដល់ប្រទេសជាតិ ឬលះច្រើនបំផុតប្រទេសជាតិដើម្បីសេចក្តីចំរើនស្ថាពរ ចាត់ជារដ្ឋពលីអន្លោមចូលក្នុងខ្លះនេះ; ង)- ធ្វើបុណ្យទទឹសផលផ្សាយដល់ទេវតា ។

๕.- បរិច្ចាគទានដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អ ។

សាធុវោ បពិត្រសប្បុរសទាំងឡាយ ថ្ងៃនឹងយប់ចេះតែកន្លងទៅ មិនមែនយប់នឹងថ្ងៃតែគ្រាន់តែកន្លងទៅប៉ុណ្ណោះទេ កាលវេលាដែលកន្លងទៅកន្លងទៅនេះ តែងស៊ីលេបន្ថយអាយុនឹងសព្វវត្ថុទាំងឡាយ

ឲ្យដកខ្លួនឆ្ងាយចេញផង, កាលបើយ៉ាងនេះ កិច្ចណា ដែលគួរធ្វើ ត្រូវប្រញាប់ប្រញាល់ធ្វើឲ្យហើយទៅ កុំរួញរាថយចាំពេលវេលាឡើយ ចូរប្រារព្ធសេចក្តីព្យាយាមដែលនឹងនាំខ្លួនទៅកាន់សេចក្តីសុខចំរើន; សមដូចព្រះពុទ្ធភាសិតថា អជ្ជេវ កិច្ចមាតប្បំ ដូច្នេះដែរដើម (ប្រែថា, "បុគ្គលគួរធ្វើសេចក្តីព្យាយាមក្នុងថ្ងៃនេះឲ្យហើយ អ្នកណាហ៊ានឹងដឹងថា សេចក្តីស្លាប់នឹងមានមកក្នុងថ្ងៃស្អែក សេចក្តីដៀសវាងឲ្យផុតអំពីមច្ចុមារមិនមានឡើយ" ។ បណ្ឌិតទាំងឡាយហៅបុគ្គលអ្នកមានសេចក្តីព្យាយាមមិនខ្វល់ ទាំងកណ្តាលថ្ងៃនឹងកណ្តាលយប់ ថាជាអ្នកមានភក្តីមួយ ។ សុទ្ធតែចំរើន ។ កាលបើសាធុជនអ្នកមានប្រាជ្ញាញាណ ឃើញទោសនៃសេចក្តីខ្វិលច្រអូស ទន់ឃើញអានិសង្សនៃសេចក្តីព្យាយាម ដោយសភាពជាធម៌ដ៏ក្សេមប្រាសចាកភ័យដូច្នេះហើយ គួរតែបំបរបង់នូវសេចក្តីខ្វិលច្រអូសទ្រមក់ដែលប្រចាំនៅក្នុងសន្តានឲ្យអន្តរធានទៅ ហើយប្រញាប់ប្រញាល់ប្រារព្ធសេចក្តីព្យាយាមក្នុងការងារដែលប្រាសចាកទោស រហូតដល់បានឃើញនូវប្រយោជន៍កន្លងទាំងពីរ ទាំងបានឈ្មោះថា ធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ,សមដោយភាសិតបរិយាយ ដែលបានលើកឡើងតាំងទុកក្នុងខាងដើមថា: កោសជ្ជំ ភយតោ ទិស្វា ฯลฯ ឯសា พุทฺธานุสาสนี ។ អត្ថាភាពសំដែងមកក្នុងរឿងរ៉ាវម្តងថា ចប់ដោយសង្ខេបតាមកាលវេលាតែប៉ុណ្ណេះ ។ ឯវំ ฯ

# ឃុនបណ្ណាគុរ័ក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ

## រៀបរៀង

(ត - ចប់)

---

## សេចក្តីអធិប្បាយអំពីអរិយសច្ច[1]

## ដោយសង្ខេប

១— ទុក្ខអរិយសច្ច ពោលដោយខ្លី សំដៅយក១ចាតទុក្ខ ទាំង ៥ តឺសេចក្តីប្រកាន់មាំថា រូប១ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១ ជារបស់ខ្លួន ។

២— សមុទយអរិយសច្ច សំដៅយកតណ្ហា។ប្រែថា "សេចក្តីប្រាថ្នា" ។ តណ្ហានេះជាដើមហេតុធ្វើឲ្យមនុស្សសត្វកើតហើយស្លាប់។ ហើយកើតទៀត មិនចេះផុត ។ ធ្វើឲ្យមនុស្សជាប្ថុជ្ជនតឹអ្នកគ្រាស់ដោយកិលេស ។ មនុស្សដែលនៅមានតណ្ហាសេចក្តីប្រាថ្នាដរាបណា ក៏មិនដល់ទ្វារតឺលត់ទុក្ខដរាបនោះ ប្រៀបដូចនៅមានភ្លើងតឺហេតុដរាបណា

---

១ មានសេចក្តីពិស្តារក្នុងប្បាប់អរិយសច្ចកថា លេ។ ម. ១២ និងប្បាប់អរិយសច្ចជាពុទ្ធ-ភាសិតរបស់លោកគ្រូ ប៉ាង - ខាត់ ក្នុងកម្ពុជសុរិយាឆ្នាំ ១៩៤៥ និងប្បាប់សៀមឈ្មោះអរិយសច្ចតឺអ្វី លេ។ ម. ៥៧៣ ។

ផលគឺការក្តៅ កំដៅមានដកឫសនោះ ។ តណ្ហាមាន ៣ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

๓_ ឥរោធអរិយសច្ច សំដៅយកការរលត់តណ្ហាអស់ គឺបាន ដល់ព្រះនិព្វាន ។

๔_ មគ្គអរិយសច្ច សំដៅយកមគ្គមានអង្គ ៨ (អដ្ឋង្គិកមគ្គ) ជា ផ្លូវប្រតិបត្តិឲ្យបានដល់ខ្លួនរំលត់ទុក្ខគឺព្រះនិព្វាន ។

## ហេតុផលរបស់អរិយសច្ច

ទុក្ខ ជាផលរបស់សមុទ័យ ។ ជាហេតុរបស់ទុក្ខ ។ និរោធ ជាផលរបស់ មគ្គ ។ ជាហេតុរបស់ និរោធ ។

## កិច្ចដែលត្រូវធ្វើក្នុងអរិយសច្ចមាន ៤ [๑]

๑_ ទុក្ខ ជាបរិញ្ញាតព្វកិច្ច គឺត្រូវកំណត់ដឹង

๒_ សមុទ័យ ជាបហាតព្វកិច្ច គឺត្រូវលះបង់ចេញ

๓_ និរោធ ជាសច្ឆិកាតព្វកិច្ច គឺត្រូវធ្វើឲ្យជាក់ច្បាស់

๔_ មគ្គ ជាភាវេតព្វកិច្ច គឺត្រូវធ្វើឲ្យកើតមានឡើង ។

កិច្ចក្នុងអរិយសច្ចទាំង ៤ នេះ រួមឲ្យខ្លីមក នៅតែត្រឹម ២ យ៉ាងគឺ លះបង់សមុទ័យ ๑ ចំរើនមគ្គ ๑ ។

---

๑ កិច្ច ๔ នេះ គុណនឹងមគ្គ ๔ ទៅជា ๑๖ ហៅថា សោឡសកិច្ច ។

## បរិវិដ្ដក្នុងអរិយសច្ច

បរិវិដ្ដ ប្រែថា "ញាណជាគ្រឿងវិលទៅ" សំដៅយកញាណ
ចាំង ๓ គឺ សច្চញាណ ๑ កិច្চញាណ ๑ កតញាណ ๑ ។

๑ – ច្បាស់ដឹងថា នេះទុក្ខ. នេះហេតុឲ្យកើតទុក្ខ, នេះសេចក្តីរលត់
ទុក្ខ, នេះផ្លូវឲ្យដល់នូវសេចក្តីរលត់ទុក្ខ ហៅថា សច្চញាណ ប្រែថា
ច្បាស់ដឹងរបស់ពិត ។

๒ – ច្បាស់ដឹងថា ទុក្ខនេះគួរកំណត់ដឹង, សមុទ័យនេះគួរលះបង់,
និរោធនេះគួរធ្វើឲ្យច្បាស់, មគ្គនេះគួរធ្វើឲ្យកើតមាន ហៅថា កិច្চញាណ
ប្រែថា ច្បាស់ដឹងកិច្চដែលគួរធ្វើ ។

๓ – ច្បាស់ដឹងថា ទុក្ខនេះអាត្មាំកំណត់ដឹងហើយ, សមុទ័យនេះ
អាត្មាំលះបង់ហើយ, និរោធនេះអាត្មាំធ្វើឲ្យច្បាស់ហើយ, មគ្គនេះអាត្មា
ធ្វើឲ្យកើតមានហើយ ហៅថា កតញាណ ប្រែថា ច្បាស់ដឹងកិច្চដែល
ធ្វើស្រេចហើយ ។

ញាណចាំង ๓ នេះ ប្រព្រឹត្តទៅក្នុងអរិយសច្চចាំង ๔ ត្រូវជាអាការ
๑๒ (๔ × ๓ = ๑๒) ។

## អង្គក្នុងអរិយសច្চ ๑๖

### ទុក្ខមានអង្គ ๔

๑.— បីឡែងគ្គ ប្រែថា បៀតបៀន

๒.— สงฺขตត្ត ប្រែថា ត្រូវបច្ច័យប្រជុំតាក់តែង

๓.— สนฺตាបត្ត " ក្តៅក្រហាយ

๔.— วิបริณามត្ត " ប្រែប្រួល ។

## សមុទ័យមានអត្ថ ๔

๑.— អាយូหนត្ត ប្រែថា ឲ្យកើតកង់ទុក្ខ

๒.— ฐิตានត្ត " ជាហេតុនៃទុក្ខ

๓.— สังโยคត្ត " ប្រកបសត្វទុក្ខក្នុងសង្សារទុក្ខ

๔.— បលิโพธត្ត " ឃុំទាំងសត្វទុក្ខក្នុងគតិសង្សារទុក្ខ ។

## និរោធមានអត្ថ ๔

๑.— นิสฺสรณត្ត ប្រែថា ដួយឲ្យចេញចាកទុបធិ(កិលេស)

๒.— วิเวกត្ត(๑) " ស្ងាត់ចាកកិលេស

๓.— อสงฺขตត្ត " បច្ច័យតាក់តែងមិនបាន

๔.— อมตត្ត " ជាអម្រិតរស(មិនចេះស្លាប់) ។

## មគ្គមានអត្ថ ๔

๑.— นิยฺยานត្ត ប្រែថា ដញ្ជូនសត្វចេញចាកវដ្តសង្សារ

---

๑ ប្បាឋអរិយសច្ចកថា ថាៈ អបលิโพธត្តោ មានអត្ថថា រកកង្វល់រវល់មិនមាន ។

๒.— ហេតុត្ត ប្រែថា ជាហេតុនៃព្រះនិព្វាន

๓.— ទស្សនត្ត[๑] " ឃើញព្រះនិព្វាន

๔.— អធិបតេយ្យត្ត " ជាអធិបតីក្នុងវិមុត្តិញាណទស្សនៈ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់ថាចតុការិយសច្ចជាគោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនាហើយ ត្រូវតែគ្រៃរ៉ៃជ្រើសរើសរកផ្លូវប្រតិបត្តិឲ្យឃើញថាផ្លូវណាជា ៖

## គោលដៃការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុតក្នុងពុទ្ធសាសនា

កាលពីជំនាន់បុរាណ ដែលមិនទាន់មានព្រះពុទ្ធជាម្ចាស់ក្នុងលោក បណ្តាមនុស្សពាល អស់ទាំងអស់ក៏ជាប់ស្គាល់សុខទុក្ខមកហើយ តែងស្អប់ខ្ពើមទុក្ខណាស់ មិនចង់បានទុក្ខសោះ ស្រឡាញ់តែសុខ ចង់បានតែសុខមួយយ៉ាងប៉ុណ្ណោះ ម្ល៉ោះហើយក៏កើតគំនិតរិះគិតរកផ្លូវប្រតិបត្តិដើម្បីចៀសវាងឲ្យផុតពីទុក្ខ ធ្វើឲ្យកើតសុខដល់ខ្លួន ប៉ុន្តែប្រតិបត្តិមិនត្រូវត្រង់ផ្លូវរំលត់ទុក្ខ ក៏គ្រាន់តែបានស្រាកស្រាន្តសូន្យទុក្ខតែបន្តិចបន្តួចកាលខ្លះ លុះអស់អំណាចកម្មាំងធម៌នោះហើយ ក៏ត្រឡប់ជាកើតទុក្ខឡើងវិញជាដដែល ទទួលសោយទុក្ខអស់កាលវែងឆ្ងាយតទៅមុខទៀត មិនចេះផុត ព្រោះតែមិនបានដឹងអរិយសច្ច ๔ ដូចជាអាឡារគោបសទ្ធិ ឧទកតាបសខំចំរើនឈាន

---

๑ ទិទស្សនត្ថោ អធិប្បាយថា សំដែងចេញ ។

ឲ្យបានផលទៅកើតនៅនាស្ថានព្រហ្ម ដោយសំគាល់ខុសថា ស្ថានព្រហ្មជាទីផុតទុក្ខ ជាទីរលត់ទុក្ខអស់ ។ ព្រះពុទ្ធជាម្ចាស់នៃយើង កាលព្រះអង្គកំពុងតែស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខ មុនបានត្រាស់ដឹងជាព្រះពុទ្ធ ទ្រង់ធ្លាប់បានចូលទៅនៅសិក្សាលទ្ធិធម៌ក្នុងសំណាក់តាបសទាំង ២ រូបនោះដែរ ប៉ុន្តែទ្រង់ជ្រាបថាធម៌នេះមិនមែនជាផ្លូវប្រែតបត្តិឲ្យផុតទុក្ខទេ ទើបទ្រង់យាងចេញពីសំណាក់តាបសទាំង ២ រូបនេះ ទៅស្វែងរកផ្លូវប្រែតបត្តិដោយវិធីផ្សេង ។ ទៀត ។

កាលដែលព្រះបរមសាស្ដាបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធថ្មីៗផុតពី ៤៩ ថ្ងៃមក ព្រះអង្គទ្រង់ត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រ (អរិយសច្ច ៤) នឹងអនត្តលក្ខណសូត្រ (ព្រះវិន័យលក្ខណ៍) មុនធម៌ទាំងអស់ ប្រោសកុក្ខបញ្ចវគ្គិយ (៥ រូប) មុនពុទ្ធបរិស័ទទាំងពួងនៅនាវិត្តសិបតនមិគទាយវន ក្បែរក្រុងពារាណសី ។

សេចក្ដីខាងដើមនៃព្រះធម្មចក្កប្បវត្តនសូត្រ ទ្រង់ត្រាស់ប្រាប្តអំពីផ្លូវប្រែតបត្តិ ៣ ប្រការថា ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រែតបត្តិ ១ ឆ្ងាយពេក ហៅ កាមសុខល្លិកានុយោគ ប្រែថា "ការប្រកបខ្លួនឲ្យទទឹកជោកទៅដោយសេចក្ដីសុខក្នុងកាម," ផ្លូវប្រែតបត្តិ ១ ទៀតគឺដ៏រឹងហួសពេក ហៅ អត្តកិលមថានុយោគ ប្រែថា "ការប្រកបខ្លួនទុក្ខក្នុងសេចក្ដីលំបាក" សំដៅយកការប្រែតបត្តិដែលពួកជនខ្លះ ខំព្យាយាមខ្លួនឯងដោយវិធី

ផ្សេង។ មានគាំងក្តៅគំង, ហាលខ្យែជាដើម ដើម្បីឲ្យបានដុតទុក្ខព្រួយ
ទំងឲ្យបានសម្រែចដូចសេចក្តីប្រាថ្នា; ផ្លូវធ្លុះពេកនឹងផ្លូវតឹងពេកទាំង ២
ប្រការនេះ តថាគតបានប្រតិបត្តិរួចមកហើយ ដឹងថាជាផ្លូវឥតផល
ប្រយោជន៍ ជាផ្លូវដ៏អាក្រក់លាមកថោកទាប អ្នកទាំងឡាយមិនត្រូវ
ប្រតិបត្តិតាមផ្លូវទាំង ២ យ៉ាងនេះទេ ។

ម្នាលភិក្ខុទាំងឡាយ នៅមានផ្លូវប្រតិបត្តិ ១ ទៀត ជាផ្លូវប្រតិបត្តិ
យ៉ាងកណ្តាល មិនធ្លុះពេក មិនតឹងពេក ជាផ្លូវប្រតិបត្តិឲ្យដល់នូវទី
រលត់ទុក្ខពិតប្រាកដ ជាផ្លូវដ៏ប្រសើរមានអង្គ ៨ (អដ្ឋង្គិកមគ្គ) ជាផ្លូវ
ដែលតថាគតបានប្រតិបត្តិរួចមកហើយ តថាគតបានត្រាស់ដឹងអរិយសច្ច
៤ (របស់ពិត ៤ យ៉ាង) ដោយសារផ្លូវនេះ អ្នកទាំងឡាយត្រូវប្រតិបត្តិ
ធម៌តាមផ្លូវកណ្តាលនេះចុះ ដែលជាផ្លូវមានឈ្មោះថា មជ្ឈិមាបដិបទា
ប្រែថា "សេចក្តីប្រតិបត្តិជាយ៉ាងកណ្តាល" សំដៅយកការដើរទៅ
តាមគន្លងផ្លូវយ៉ាងកណ្តាល ជាផ្លូវទៅកាន់ទីរលត់ទុក្ខ ។

ផ្លូវកណ្តាលដែលឈ្មោះថា មជ្ឈិមាបដិបទា នេះមានអង្គ ៨
(អដ្ឋង្គិកមគ្គ[1]) គឺ :

๑ - សម្មាទិដ្ឋិ សេចក្តីឃើញត្រូវ

๒ - សម្មាសង្កប្ប សេចក្តីត្រិះរិះត្រូវ

---

๑ មានសេចក្តីពិស្តារក្នុងច្បាប់អរិយសច្ចកថា :បស់ពុទ្ធសាសនបណ្ឌិត្យលេខ ๑ ម. ๑๒ ។

๓_ សម្មាវាចា ការចាត្រូវ

๔_ សម្មាកម្មន្ត ការងារត្រូវ

๕_ សម្មាអាជីវ ចិញ្ចឹមជីវិតត្រូវ

๖_ សម្មាវាយាម ព្យាយាមត្រូវ

๗_ សម្មាសតិ រលឹកត្រូវ

๘_ សម្មាសមាធិ តាំងចិត្តមាំត្រូវ ។

អង្គ៌ទាំង ๘ នេះ លុះតែមានព្រមជាមួយគ្នាគ្រប់ទាំង ๘ រួមចូលគ្នា ជាកំឡាំងតែមួយ ទើបហៅថា មគ្គ ឬអរិយមគ្គ ឬមជ្ឈិមាបដិបទា, បើញែកចេញឲ្យជាច់ពីគ្នាតែអង្គ៌មួយ ។ វិញ មិនហៅថា មគ្គទេ គ្រាន់តែហៅត្រឹមចំណែកអង្គ៌មួយ ។ តាមឈ្មោះអង្គ៌នោះ ។ ប៉ុណ្ណោះ ។

មគ្គមានឈ្មោះ ๔ យ៉ាង តាមកំឡាំងដែលអាចលះកិលេសបាន គឺ

๑_ សោតាបត្តិមគ្គ ជាគូនឹង សោតាបត្តិផល

๒_ សកទាគាមិមគ្គ - សកទាគាមិផល

๓_ អនាគាមិមគ្គ - អនាគាមិផល

๔_ អរហត្តមគ្គ - អរហត្តផល ។

មគ្គ ๔ ផល ๔ នេះ ជាឈ្មោះរបស់ចិត្ត ។ អ្នកមានមគ្គចិត្តនឹងផលចិត្តយ៉ាងនេះ ហៅថា អ្នកបានសម្រេចមគ្គផល ។

ការប្រតិបត្តិធម៌គ្រប់ជាន់ មានមជ្ឈិមាបដិបទាជាបង្គោល ។ មជ្ឈិមាបដិបទាជាទីប្រជុំចុះនៃការប្រតិបត្តិធម៌ទាំងអស់ ក្នុងព្រះពុទ្ធសាសនាទាំងមូល ។ មជ្ឈិមាបដិបទាជាគ្រែសែនៃព្រះនិញ្វាន, ជាផ្លូវដើរនៃចិត្ត, មិនមែនជាផ្លូវសម្រាប់ដើរដោយជើងទេ ។

មជ្ឈិមាបដិបទាជាធម៌សម្រាប់មនុស្សគ្រប់រូប មិនមែនជាធម៌ខ្ពស់ហួសផុតវិស័យរបស់មនុស្សឡើយ, មិនមែនជាធម៌ធ្វើឲ្យមនុស្សខ្វល់ខ្វាយ ឬធ្វើឲ្យខ្ជិលច្រអូស ឲ្យថាលចាញ់សេចក្តីទុក្ខដែលខ្លួនត្រូវអត់ធន់នោះទេ, ជាធម៌សម្រាប់មនុស្សអ្នកស្អប់ខ្ពើមទុក្ខ ហើយចង់បានសុខពិតប្រាកដ, ជាធម៌យ៉ាងកណ្តាល មានថ្នាក់ខ្ពស់ទាបតាមភូមិតរបស់មនុស្សបុថុជ្ជនគ្រប់រូបក្នុងលោកនេះ មិនមែនជាធម៌សម្រាប់តែព្រះអរិយបុគ្គលមួយចំពូកប្រតិបត្តិប៉ុណ្ណោះទេ ដ្បិតថា បើមនុស្សបុថុជ្ជនមិនប្រតិបត្តិតាមមជ្ឈិមាបដិបទានេះហើយ ធ្វើម្តេចនឹងក្លាយខ្លួនទៅជាព្រះអរិយបុគ្គលគឺអ្នកបានសម្រេចមគ្គ ๔ ផល ๔ កើត ហេតុនេះបានជាចាត់មជ្ឈិមាបដិបទាថា ជាគោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុតក្នុងព្រះពុទ្ធសាសនា ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ខ្លួមជ្ឈិមាបដិបទាជាគោលដ៏សំខាន់នៃការប្រតិបត្តិធម៌ហើយ ត្រូវតែពិចារណាដេញដោលរកឲ្យឃើញផលនៃការប្រតិបត្តិធម៌ថា ផលដូចម្តេច ដែលជា ៖

# ផលប្រយោជន៍យ៉ាងខ្ពស់បំផុតនៃការប្រតិបត្តិធម៌ ក្នុងព្រះពុទ្ធសាសនា (๑)

ក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនា បានសំដែងបញ្ជាក់ អំពីផលប្រយោជន៍នៃការប្រតិបត្តិធម៌ ដោយអនេកបរិយាយ ប៉ុន្តែផលទាំងអស់នោះ បើបំប្រួញឲ្យតិចមក នៅមានតែត្រឹម ២ យ៉ាងគឺ ផលជាលោកិយ ๑ ផលជាលោកុត្តរ ๑ ។

## ផលជាលោកិយ

ក្នុងទីនេះ សូមបរិយាយអំពីផលជាលោកិយមុន (๑)៖ អ្នកប្រតិបត្តិធម៌តាមក្រសែនៃមជ្ឈិមបដិបទា ដូចបានរៀបរាប់ខាងដើមហើយនោះ រមែងបានផលប្រយោជន៍យ៉ាងវិសេសក្នុងវេលាកំពុងតែប្រតិបត្តិធម៌ មិនបង្អង់ចាំពេលណាទើបបានផលទេ (អកាលិកោ) ជាធម៌ឲ្យផលពុំមានកាលខាន់ គឺថា មជ្ឈិមបដិបទាធ្វើអ្នកប្រតិបត្តិតាមឲ្យជាមនុស្សមានហេតុផលជាគោលការ, ធ្វើឲ្យជាអ្នកជាប់ស្រែចក្នុងចិត្ត, ធ្វើឲ្យជាអ្នកឈ្នះខ្លួនឯងបាន, ធ្វើឲ្យជាអ្នកបង្គាប់បញ្ជាខ្លួនឯងបាន, ធ្វើឲ្យជាអ្នកមានសេចក្តីជ្រាបច្បាស់ត្រឹមត្រូវ, ធ្វើឲ្យជាអ្នកឆ្ងាយចាត់ត្រង់ផ្លូវ, ធ្វើឲ្យជាអ្នកមានកាយកម្ម, វចីកម្ម នឹងការចិញ្ចឹមជីវិត ប្រាសចាកទុក្ខក្តៅក្រហាយគ្រប់ប្រការ, ធ្វើឲ្យជាអ្នកមានឫទ្ធិ, មានសេចក្តីក្លាហាន មានសេចក្តី

---

๑ ស្រង់ចាកច្បាប់ពុទ្ធសាសនាសៀម លេខ ๑ ម. ๔๓๕ ទំព័រ ๕๑๘ . . . ។

ចេះដឹង ទំនឹងឲ្យមានសេចក្តីទៀងទាត់ក្នុងចិត្ត ល្មមឲ្យជីវិតរបស់ខ្លួនមានរបៀបរៀបរយ គួរដល់ឋានៈរបស់ធម្មិដែលខ្លួនប្រតិបត្តិ ។

កាលមនុស្សបានប្រតិបត្តិធម្មិត្រឹមត្រូវតាមមជ្ឈិមាបដិបទា ដែលមានសម្មាទិដ្ឋិ ជាប្រធាន ជាមេនាំអាទិហើយ ក៏រមែងបានផលអាចឲ្យកើតអង្គមគ្គ ๗ ខាងចុងតៗ គ្នាតាមលំដាប់ក្រមៗ មិនរង់ចាំកាលណាទេ ដូចជាអ្នកមាន ៖

๑ – សេចក្តីយល់ឃើញត្រូវ (សម្មាទិដ្ឋិ) ការចូលចិត្តត្រឹមត្រូវតាមហេតុផល ក៏ជាផ្លូវឲ្យកើត ៖

๒ – សេចក្តីត្រិះរិះត្រូវ (សម្មាសង្កប្ប); សេចក្តីត្រិះរិះត្រូវធ្វើឲ្យកើត ៖

๓ – វិចាត្រូវ (សម្មាវាចា)

๔ – ការងារត្រូវ (សម្មាកម្មន្ត)

๕ – ការបិញ្ចឹមជីវិតត្រូវ (សម្មាអាជីវ)

๖ – ព្យាយាមត្រូវ (សម្មាវាយាម)

๗ – រលឹកត្រូវ (សម្មាសតិ)

๘ – តាំងចិត្តមាំត្រូវ (សម្មាសមាធិ) ។

កាលបើអង្គមគ្គជាហេតុកើតមានយ៉ាងនេះហើយ ការលះកិលេស

នោះ ។ ចានជាផល កើតមានឡើងក្នុងខណៈនៃមគ្គនោះ ។ ដែរ ប៉ុន្តែជាមគ្គនៅទន់ខ្សោយ នៅស្តើងស្តួច មិនទាន់ខ្ជាំងក្លា មិនទាន់ពេញលេញ ហៅថាអរិយមគ្គមិនទាន់ចាន - គ្រាន់តែអាចលះកិលេសចំពួកខ្លះចាន តាមកំឡាំងនៃមគ្គជាលោកិយ ឲ្យចានផលជាលោកិយប៉ុណ្ណោះ ។

បណ្តាផលជាលោកិយទាំងអស់ សំដៅយកត្រង់ការអស់កិលេសចំពួកខ្លះនោះ ថាជាផលប្រសើរបំផុតលើសផលលោកិយនានា មានផលសោយសុខសម្បត្តិក្នុងស្ថានមនុស្សនិងស្ថានសួគ៌ជាដើម ។

## ផលជាលោកុត្តរ

មគ្គជាលោកិយដូចមាននិយាយរួចហើយនោះ ជាគោលនៃការគ្រប់គ្រងជីវិតរបស់អ្នកប្រតិបត្តិឲ្យប្រព្រឹត្តទៅរៀបរយ ឲ្យចានសុខសប្បាយរាល់ៗថ្ងៃ ហៅថា អ្នកចានផលជាលោកិយ ។

ផលជាលោកិយនេះ កាលបើគេអប់រំអង្គមគ្គ ឲ្យចាស់ក្លាដល់កំរិតហើយ អាចក្លាយទៅជា "អរិយផល" ដែលកើតពីអរិយមគ្គចានដូចសេចក្តីអធិប្បាយ ដោយសង្ខេបតទៅនេះ ៖

អ្នកប្រតិបត្តិធម៌តាមលំអាននៃមជ្ឈិមាបដិបទា ជាលោកិយហើយចានព្យាយាមអប់រំអង្គមគ្គទាំង ៨ ឲ្យមានភ្នំាងពេញទីតាមវិធីនៃការប្រតិបត្តិធម៌ ត្រមែត្រង់គ្នាជាកម្លាំងតែ ១ ហើយ ហៅថា "អរិយមគ្គ" ។ នេះ អាចកំចាត់កិលេស ឬ សំយោជន៍យ៉ាងស្អិតបំផុតដែលគ្រាំជាប់ស្អិត

នៅក្នុងចិត្តឲ្យលេស់ទៅតាមចំណែកនៃកម្មាំងអរិយមគ្គដែលខ្លួនអប់រំបាន ។ ផលដែលកើតមានឡើងនូវ អំពីកិលេសបានដាច់នេះ ហៅថា "អរិយផល" ។ អរិយមគ្គដែលចាស់ក្លាដល់កំតែអាចកំចាត់កិលេសក្នុងចិត្តបានត្រឹមណា ក៏មានឈ្មោះហៅតាមជាន់នៃការលះកិលេសរបស់ខ្លួនបានត្រឹមណោះថា សោតាបត្តិមគ្គ, សកទាគាមិមគ្គ អនាគាមិមគ្គ, អរហត្តមគ្គ ។ អរិយផលក៏មានជាគូនឹងអរិយមគ្គគ្រប់ៗមគ្គដែរ គឺសោតាបត្តិផល, សកទាគាមិផល, អនាគាមិផល, អរហត្តផល, ហេតុនោះទើបកើតបានជាមគ្គ ៤ ផល ៤ ហៅគាត់ថ្វីថា "មគ្គផល" ។ អរិយមគ្គជាហេតុ អរិយផលជាផល ។ អរិយមគ្គដែលមានឈ្មោះផ្សេងគ្នាជា ៤ យ៉ាងនោះ ក៏ព្រោះកំចាត់កិលេសបានច្រើនតិចជាងគ្នា(១) ។ តុកាសបើកឲ្យអគ្គមគ្គប្រជុំគ្នាជាអរិយមគ្គបានកាលណា ការកាត់សំយោជន៍ក៏កើតមានឡើងក្នុងកាលណោះមួយរំពេច ។ តុកាសនេះមិនកំណត់កាលទេ (អកាលិកោ) កើតមានឡើងក្នុងខណៈដែលចិត្តមូលជាអារម្មណ៍តែមួយដោយឆាប់ហ័ស ដូចអ្នកខ្លះស្តាប់ទេសន៍បានសម្រេចមគ្គផលនៅពីនោះភ្លាម ក៏មាន (ខិប្បាភិញ្ញា), ដោយសេចក្តីព្យាយាមដ៏ខ្លាំងក្លា ដូចព្រះយោគាវចរខំចំរើនភាវនារឿយៗ ពស់ថ្ងៃទាល់តែបានសម្រេចមគ្គផល ក៏មាន (ទន្ធាភិញ្ញា) ។

---

๑ អរិយមគ្គណា កំចាត់កិលេសអ្វីខ្លះ មានសេចក្តីពិស្តារក្នុងបញ្ចប់អរិយសច្ចកថា លេខ ម. ๑๒ ។

អ្នកប្រតិបត្តិធម៌ហើយបានសម្រេចលោកុត្តរផល ជាផលដ៏ខ្ពស់បំផុតយ៉ាងនេះហើយ ឈ្មោះថាជាអ្នកបានដល់ព្រះនិព្វានជាស្ថានរលត់ទុក្ខទាំងអស់ ឈ្មោះថាជាអ្នកប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្តបំណងនៃព្រះពុទ្ធសាសនាពិតប្រាកដ ព្រោះព្រះពុទ្ធសាសនាទាំងមូល មានបំណងជាទីបំផុតត្រង់មគ្គ ๔ ផល ๔ និព្វាន ๑ រួមជា ๙ ដែលហៅថាព្រះនព្វលោកុត្តរធម៌ ។

## សេចក្តីបញ្ជាប់

មនុស្សជាជាតិអ្វីក៏ដោយ ប្រុសឬស្រី ក្មេងឬចាស់ ដែលជាអ្នកកាន់ពុទ្ធសាសនា បានឈ្មោះហៅថា "ពុទ្ធបរិស័ទ" ហើយត្រូវពិចារណាឲ្យយល់ច្បាស់ដោយគំនិតប្រាជ្ញារបស់ខ្លួនថា ៖

ព្រះពុទ្ធសាសនា ជាសាសនាដ៏ឥតខ្ចាស់ គ្មានសាវ័កណាអាចលុបលាង ឬកែប្រែដូចជាច្បាប់សម្រាប់ប្រទេសមួយៗបានទេ, ជាសាសនាមិនទទួលពាក្យអង្វរករបន់ស្រន់របស់អ្នកណាសោះ, ជាសាសនាមិនទទួលរ៉ាប់រងទុក្ខទោសដួសអ្នកណាសោះឡើយ, ជាសាសនាបង្ហើលហេតុផលយ៉ាងជាប់ខាត ។

ព្រះពុទ្ធសាសនាប្រៀបដូចទូក ពួកពុទ្ធបរិស័ទប្រៀបដូចអ្នកជិះ ។ ទូកលឿនក្តី មិនលឿនក្តី ទៅត្រង់ឬវៀចវេក្តី ក៏ស្រេចតែលើខ្លួនអ្នកជិះ ។ បើទូកបែកធ្លុះធ្លាយ ត្រូវតែអ្នកជិះជួសជុលបំពេញដោយខ្លួនឯង បើមិនបំពេ

ខ្លួនកំលិច ខ្លួនអ្នកជិះកំលង់ទឹកស្ទាប់កណ្តាលទន្លេ គ្មានហៅអ្នកណាឲ្យជួយខ្លួនបានទេ ។

ពួកពុទ្ធបរិស័ទ មិនត្រូវតាំងចិត្តផ្តែកអរេវៅលើព្រះពុទ្ធអង្គដោយទឹកអាងថា "ព្រះពុទ្ធអង្គនឹងមកជួយដឹកដៃយឹតយោងខ្លួនឲ្យរួចពីទុក្ខទោស" ដូច្នេះឡើយ ត្រូវតែតាំងចិត្តដឿកម្មនឹងផលរបស់កម្មជាយ៉ាងជាប់ខាតថា "កម្មល្អឲ្យផលជាសុខ កម្មអាក្រក់ឲ្យផលជាទុក្ខ អ្នកណាបានសុខឬបានទុក្ខ ក៏ព្រោះតែអ្នកនោះបានធ្វើកម្មល្អឬអាក្រក់រួចមកហើយ គ្មានអ្នកណាអាចទទួលសុខទុក្ខជួសអ្នកណាបានទេ ប្រៀបដូចចោរលួចប្លន់គេ។ ចាប់ជាក់គុក គ្មានអ្នកណាទទួលទោសគុកជួសចោរនោះបានទេ សូម្បីតែអាពុកបង្កើតក៏ទទួលទោសជួសកូនមិនបានដែរ ។ សេចក្តីបរិសុទ្ធនឹងមិនបរិសុទ្ធចំពោះតែរូបមនុស្សម្នាក់ៗ គ្មានអ្នកណាបរិសុទ្ធជួសអ្នកណាបាន ប្រៀបដូចអ្នករៀនចំណេះវិជ្ជាផងតាំពួង អ្នកណារៀន អ្នកនោះចេះ ទឹងរៀនជួសគ្នា ឬទឹងចេះជួសគ្នាមិនកើត ។ ការរៀនជាកម្ម គឺហេតុ ការចេះដឹងជាផល ។"

ពួកពុទ្ធបរិស័ទបើដឿកម្មផលដូច្នេះហើយ ទើបបានប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្តបំណងរបស់ព្រះពុទ្ធសាសនា ។ បើមិនដឿកម្មផលទេ ចេះតែធ្វើបុណ្យឲ្យទានរក្សាសីលតាំងខ្លាក់តាំងថ្នល់ ព្រោះចិត្តចង់ឲ្យបានសុខ លុះមិនបានសុខដូចបំណង ដូរត្រូវប្រតិបត្តិខុសគន្លងធម៌ ក៏ទៅជា

ទំបន់ព្រះសំពះទេវតាឲ្យជួយខ្លួន កាលបើមិនឃើញព្រះ ឬ ទេវតាជួយ
ក៏ត្រឡប់ជាទិដ្ឋប់បន្ទោសព្រះ ឬ ទេវតាថាមិនជួយខ្លួនទៅវិញ ។

បណ្ណាយថាសភាវៈតាំងឡាយ (របស់កើតមានឯង) ដូចជាគេ
យកទឹកស្រោចក្តៅៗតែងរលត់អស់ទៅ នេះជាទំនៀមទម្លាប់យ៉ាងទៀង
ទាត់របស់ធម្មតា គ្មានមនុស្សណាជាអ្នកសាងក្តៅឬទឹកដែលជាវត្ថុធម្ម-
ជាតិនោះឡើយ មានតែមនុស្សជាអ្នកដឹងទំនៀមនេះថា "បើគេយកទឹក
ស្រោចក្តៅៗមុខជារលត់អស់មិនខាន" អ្នកដឹងយ៉ាងនេះចាត់ជាមនុស្ស
ដឹងមុនគេ ហើយប្រាប់គ្នាតៗមក ព្រះពុទ្ធអង្គក៏ដូច្នោះដែរ គឺព្រះអង្គ
បានជ្រាបរបស់ពិត (អរិយសច្ច) មុនគេ ព្រះអង្គមិនបានកសាងមគ្គ
តាំង ៨ ឡើងទេ ព្រះអង្គគ្រាន់តែបានស្វែងរកមគ្គឃើញមុនគេ ហើយ
ប្រកាសប្រាប់អ្នកដែលចង់បានសុខ ឲ្យដើរទៅតាមអង្គមគ្គតាំង ៨ នោះ
ប៉ុណ្ណោះ (អក្ខាតារោ តថាគតា) ។

អង្គមគ្គតាំង ៨ ប្រៀបដូចជាផ្លូវថ្នល់ ១ ប្រកបដោយអង្គគុណ ៨
យ៉ាងគឺ មានការបិទប្រកាសប្រាប់ដំណើរ (សម្មាទិដ្ឋិ), មានវៀចវេរ
តែងទៅកាន់ទីតាមប្រាថ្នា (សម្មាសង្កប្បៈ), មានគូស្នាមគ្រោះ (សម្មា-
វាចា), មានម្លប់ឈើ (សម្មាកម្មន្ត), មានកន្លែងសំណាក់អាស្រ័យ
(សម្មាអាជីវៈ), មានទីរកអាហារបាន (សម្មាវាយាម), មានការ

គ្រប់គ្រងអ្នកដំណើរ (សម្មាសតិ), មានសេចក្តីសុខដល់អ្នកដំណើរ (សម្មាសមាធិ), អរិយមគ្គក៏មានអង្គដ៏ខាងដើម ។ ល្មមសមគួរឲ្យបានសម្រេចសេចក្តីប្រាថ្នារបស់អ្នកប្រតិបត្តិដូចជាផ្លូវនោះដែរ ។

អដ្ឋង្គមគ្គដ៏ចំណែក ៨ នឹងដើរជួសគ្នាមិនបានទេ ព្រោះជាចំណែកចិត្ត មិនមែនជាចំណែករាងកាយដូចការលត់ភ្លើងដែលអាចជួយស្មោចជួសគ្នាបានទេ ។ ភ្លើងប្រៀបដូចសេចក្តីទុក្ខក៏មែនហើយ ប៉ុន្តែភ្លើងជាចំណែករាងកាយ ការលត់ជាចំណែកកាយ ទើបអាចជួយលត់ជួសគ្នាបាន ។ ទុក្ខក្នុងដីនេះជាចំណែកចិត្តដែលមនុស្សពាល់រូបដឹងយើញដោយខ្លួនឯង (សន្ទិដ្ឋិកោ) ទើបធ្វើជួសគ្នាមិនបាន ប្រៀបដូចជាអ្នករៀន មិនអាចរៀនសូត្រចំណេះវិជ្ជាជួសគ្នាបានដូច្នោះដែរ ។

ព្រះពុទ្ធអង្គតែងតែជាអ្នកបានប្រាប់ពិតដ៏ប្រសើរ (អរិយសច្ច ๔) មុនគេ ហើយទ្រង់ប្រទានឲ្យស្តាប់តាមថា នេះហៅថាទុក្ខ (ទុក្ខអរិយសច្ច), នេះជាហេតុឲ្យកើតទុក្ខ (ទុក្ខសមុទយអរិយសច្ច), នេះជាសេចក្តីរលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ច), នេះជាផ្លូវដែលនឹងធ្វើអ្នកដំណើរឲ្យដល់នូវសេចក្តីរលត់ទុក្ខ (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច), ជាផ្លូវដែលធ្វើឲ្យមានទឹងសេនាមារតាមមិនទាន់, ជាផ្លូវដែលអ្នកចាំងឡាយត្រូវព្យាយាមដើរទៅដោយខ្លួនឯង ព្រះតថាគតចាំងឡាយគ្រាន់តែជា

អ្នកធ្លាប់ឆ្លងប៉ុណ្ណោះទេ (អក្ខាតារោ តថាគតា) ។ មួយទៀត ព្រះតថាគតទាំងឡាយ មិនដែលទទួលពាក្យអង្វរការបន់ស្រន់របស់អ្នកណាឡើយ (សុទ្ធិអសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ) ។

## ការប្រតិបត្តិធម៌

គឺជាការផ្ទាស់ចិត្តអាក្រក់ឲ្យក្លាយទៅជាចិត្តល្អ,
ជាការធ្វើជីវិតឲ្យបានសុខស្រួល;
ជាការបំបាត់សេចក្តីល្ងង់ខ្លៅ,
ជាការចេញចាកទុក្ខឈានទៅរកសុខ
សឹងមានព្រះនិព្វានជាទីដៅ ។

រឿងពុទ្ធបរិស័ទគឺអ្នកណា សង្វៀបប៉ុណ្ណោះ

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បាត់ឲ្យប្រៃហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតភី ព.ស. ២៤៨៦, គ.ស. ១៩៤៣

តមក

---

## សុភមិត្តជាតក ទី ៩

(តបប់)

(និយាយអំពីដំណើរព្រាត់ប្រាស ព្រោះមានពៀរដោយយកក្តួនសត្វ)

លោកអាចារ្យ ឈឹម-ស៊ុម ក្រុមដំនុំព្រៃប្រៃបិដក

ប្រែពីបាលី

*ចំណែកខាងនាយសំពៅ ចង់រួមសំវាសជាមួយនឹងនាងទេវីនោះណាស់; តែដោយសេចក្តីអធិដ្ឋានរបស់ព្រះនាង នឹងតេជៈសីលនៃព្រះស្វាមី កំនាយសំពៅហាក់ដូចជាក្តៅក្រហាយ មិនអាចប្រកបសុខបានឡើយ, ត្រឡប់ជាធ្វើសក្ការបូជាដូចជាទេវតាទៅវិញ ។ នាងទេវីនោះ តែងតែឲ្យពានមស្សការបូជាចំពោះទេវតាផ្សេងៗជានិច្ច ហើយនាងបួងសួងបន់ស្រន់ចន្ទទេវបុត្ត សុរិយទេវបុត្ត សក្កទេវរាជនឹងទេវធីតាមណិមេខលា ច្បាស់ថា ខ្ញុំសូមឲ្យបានយើញព្រះរាជស្វាមីនៃខ្ញុំកុំខានឡើយ ។*

កាលកន្ទួលទៅ ๗ ថ្ងៃ នាយសំពៅនោះត្រមាំងព្រះនាងទៅជាន
ទៅដល់ក្រុងតក្កសិលា ហើយនាំយកគ្រឿងក័ស្តុភារបណ្ណាការទៅថ្វាយ
ព្រះចៅក្រុងតក្កសិលានោះ ។ កាលបើនាយសំពៅនោះ នៅក្នុងក្រុង
តក្កសិលា អស់វេលាពីរបីខែ ក៏ក្រាបបង្គំលាព្រះពជា សូមត្រឡប់វិញថា

អាបុប្ផាមិ ភូរិ ទេវ គមិស្សាមិ សរាណិជ្ជា
បិរំ នោ ឥធ វាសោវ គមិស្សាមិ សកាលយំ

សូមទានព្រះពជតេជះដម្កល់លើតួង, ខ្ញុលព្រះបង្គំជាខ្ញុំសូម
ក្រាបបង្គំលាទៅកជួញប្រែឯប្រទេសជាទៀត ដ្បិតខ្ញុល ;
ព្រះបង្គំជាខ្ញុំមកនៅក្នុងនីនេះយូរណាស់ហើយ ។

ព្រះពជាទ្រង់ព្រះសណ្តាប់ពាក្យនាយសំពៅនោះហើយ ក៏ទ្រង់
យាត់ថា

បស្សាហិ ភោ មហានាវ ឆប្បតីតេ សុរាទិតេ
ឯការត្តិំ វសិត្វាន បាតោ គច្ឆសិ នាវិក

ម្នាលនាយសំពៅដ៏ចំរើន, ចូរអ្នកនៅចាំមើលមហោស្រព
មួយយប់សិន ស្អែកសឹមអ្នកចេញសំពៅទៅពីព្រឹកចុះ ។

ព្រះពជាទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ធ្វើសក្ការៈកប់អានចំពោះ
នាយសំពៅនោះ ដល់ព្រះអាទិត្យអស្តង្គត នាយសំពៅក៏ក្រាបបង្គំលា
ព្រះពជាទៀតថា សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុលព្រះបង្គំជាខ្ញុំជា

អ្នកជំនួញ ចង់មើលមហោស្រពណាស់ដែរ, ចង់នៅក្នុងទីនេះមួយយប់ទៀត, ប៉ុន្តែជាប់ចំពាក់នឹងការរក្សាសំពៅ ព្រោះព្រួយបារម្ភដល់ទ្រព្យសម្បត្តិក្នុងសំពៅ ខ្លាចក្រែងចោរធ្វើឲ្យអន្តរាយ ។ ព្រះរាជាទើបទ្រង់ត្រាស់នឹងនាយសំពៅនោះថា ណ្ហើយចុះ ចូរអ្នកចាំងឡាយមើលមហោស្រពតាមសប្បាយចុះ, កុំគិតព្រួយបារម្ភឡើយ, ចាំខ្ញុំឲ្យពួកបុរសទៅថែរក្សាសំពៅឲ្យ ។ ព្រះរាជាទ្រង់ត្រាស់ហៅកុមារចាំងពីរមកបង្គាប់ថា ម្នាលឯង, ចូរអ្នកនាំពួកសេវក.ទៅថែរក្សាសំពៅឲ្យពួកអ្នកជំនួញឯស្ងួនផង ។ ឯកុមារចាំងពីរ កំពុងលួលព្រះរាជន្ធានាំពួកសេវក:ទៅថែរក្សាសំពៅ, នាំគ្នាអង្គុយពីរនាក់បងអួនកងទីមួយ ។

គ្រានោះ ព្រះនាងកេសិនីទេវី ទ្រង់យល់សុបិននិមិត្តឃើញថា ព្រះរាជាទន្ធីព្រះនាងទេវី ព្រមចាំងព្រះរាជកុមារចាំងពីរព្រះអង្គ ទ្រង់គង់នៅជាមួយគ្នា ក្នុងសាលាវិនិច្ឆ័យ; មានបុរសពីរនាក់ យកផ្កាឈូកស មកជម្ពល់លើព្រះហស្តព្រះរាជា ព្រះអង្គទ្រង់ទទួលហើយបាចទៅលើព្រះនាងទេវី ព្រះនាងទ្រង់សៀតលើព្រះកាណិចាំងពីរហើយបរិភោគលំអង្គផ្កាឈូកនោះ, ស្រាប់តែផ្កានោះជ្រុះបុះលើព្រះឧកនៃព្រះនាងទេវីទៅវិញ ។ លុះព្រះនាងតើនឡើង ក៏ទ្រង់ព្រះកន្សែង ហូរទឹកព្រះនេត្រល្ហែង ហើយឡើងគង់ទ្រង់រំពឹងគិតថា ព្រឹកស្អែកនេះ អាត្មាអញមុខជាបានជួបនឹងព្រះស្វាមី ព្រមចាំងកូនចាំងគូរបស់អញ មិនខាន

ឡើយ ។ តាំងពីព្រះនាងទ្រង់យល់សុបិនទិព្វឃើញដូច្នេះមក កំពុង
អាចទប់ទឹកព្រះនេត្របានឡើយ ។ លុះដល់វេលាពាក់កណ្តាលរាត្រី
យប់ស្ងាត់ ពួកមនុស្សដេកលក់អស់, ដេយ្យទត្តកុមារក៏លក់ទាំងបង្គុយ
ដោយងងុយ គ្រហស្ថក៏ត់ខ្លាំង, ដេយ្យសេនកុមារជាស្តេចអនុជជា
រឿយ ។ ។ ឯដេយ្យទត្តកុមារកន្ទុបាយកុំឲ្យថ្នមទិទ្ធគ្រហស្ថក៏ភ្ញាក
ទើបមានព្រះបន្ទូលនឹងព្រះរៀមថា បពិត្រអ្នកបង, បើបងឮប់ដឹងរឿង
ត្រៃងអ្វី សូមនិយាយប្រាប់ខ្ញុំផង ។ ដេយ្យសេនកុមារមានព្រះបន្ទូលថា
ប្អូនអើយ, បងពុំឮប់ដឹងរឿងត្រៃងអ្វីដទៃទេ, បងដឹងតែរឿងដែល
យើងត្រាត់ប្រាសគ្នាប៉ុណ្ណោះ ។ - បពិត្រអ្នកបង, រឿងយើងដែល
ត្រាត់ប្រាសគ្នានោះដូចម្តេច? - ម្នាលប្អូន, កាលមាតាបិតារបស់យើង
ចេញពីព្រះនគរបន្តិចមកក៏ត្រាត់ប្រាសគ្នា រហូតមកដល់ឥឡូវនេះ ។ -
មាតាបិតារបស់យើងនៅក្នុងកេរដ្ឋគ្រាមសព្វថ្ងៃនេះទេតើ, ចុះមាតាបិតា
ឯណាដែលត្រាត់ប្រាសគ្នា? - មិនមែនដូច្នោះទេប្អូនអើយ, យើងទាំង
ពីរនាក់មានមាតាបិតាជាមួយគ្នាជាប្រាកដ ។ - អ្នកបង, បើដូច្នោះសូម
ប្រាប់ប្អូនផង ។ - អើប្អូន, ចូរចាំស្តាប់ចុះ, កាលដែលយើង
នៅតូច។ មាតាបិតារបស់យើងត្រាត់ប្រាសចោលយើងទៅ, ឯមាតា
បិតាយើងនោះជាស្តេចសោយរាជ្យ; ព្រះបិតាយើង មានព្រះអនុជ
មួយព្រះអង្គ ព្រះនាមអសុកមិត្តជាឧបរាជ ។ គ្រានោះ អសុកមិត្ត

ទេពកដ តិតនឹងលើកទ័ពទៅដណ្តើមពាជសម្បត្តិពីព្រះបិតាយើង ហើយ
ទ្រង់សូកមាសប្រាក់សំពត់នឹងគ្រឿងអលង្ការដោយដើម ដល់ពួកមហាជន
ឲ្យចុះបួលទ្រង់; ពេលនោះបួនជាមានអាមាត្យម្នាក់ជាអ្នកតតញ្ញូ អាណិត
បិតាយើង លបតេះឡើងទៅក្រាបបង្គំទូលតាមរឿងនោះ; លុះព្រះបិតា
យើង ទ្រង់ព្រះសណ្តាប់ពាក្យអាមាត្យនោះហើយ ក៏ទ្រង់ព្រះចិន្តាថា
'បើសិនជាអាត្មាអញទឹងធ្វើចម្បាំង, សមជាបួនរបស់អញ ត្រមាំង
ពួកពលវេហ៍ ទឹងអន្តរាយខ្ចប់ខ្ចាតច្រើនមិនខាន បើដូច្នោះ គួរតែ
អាត្មាអញ កៀសខ្លួនចេញចាកពាជដ្ឋានទៅទាំងរាត្រីថ្ងៃនេះទើបស្រួល";
លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏ទ្រង់ធ្វើសក្ការៈកប់អាមាត្យនោះ
បញ្ជូនឲ្យត្រឡប់ទៅវិញ ។ គតីនោះមកមាតាបិតាយើង នាំយើង
ទាំងពីរនាក់រត់ចេញពីព្រះនគរមកដល់ស្ទឹងមួយពាក់កណ្តាលផ្លូវ, ក៏ឃប់
សម្រាកនៅត្រើយស្ទឹងនោះ បញ្ជុកបាយបង បំបៅប្អូនឯង ក្រោល
សំពត់សាដកគ្រាប់ឲ្យប្អូនឯងដេក ហើយលបក្រោកឡើងសន្សឹម ។
ទុបតែថើបសិរសោបបោសអង្អែលក្បាលបងហើយទៅ ។ កាលបង
កំពុងយំ ទ្រង់ក៏ដាកមកលួងលោមបង ហើយបណ្តើរគ្នាចុះកូនស្ទឹងបាត់
ទៅ ។ កូនខណៈនោះ មានព្រានសំណាញ់ពីរនាក់ បាននាំយើង
យកមកចិញ្ចឹមធ្វើជាកូន ។

ដើម្បីទត្តកុមារ ទ្រង់ព្រះសណ្តាប់រឿងនោះដូច្នោះហើយ ទ្រង់ព្រះវន្ទាថា ខ្ញុំព្រះជង្គាបង្គំអើយ; ខ្ញុំនឹងជាយ៉ាងហ្នឹងមែនហើយ ។ ដើម្បីសេនកុមារ ទ្រង់ឃាត់ព្រះអនុជថា ប្អូនអើយ អ្នកកុំមាត់កខ្វើយ, បើសិនជាមាតាបិតារបស់យើង មានព្រះជន្មនៅខ្លើយ មុខជាទ្រង់នឹងតាមមកវាកយើងមិនខាន ។ - បពិត្រព្រះបង, ចុះនគរយើងឈ្មោះអ្វី? - ឈ្មោះចម្បាកនគរប្អូន ។ - ចុះបិតាយើងព្រះនាមដូចម្តេច? - ម្នាលប្អូន, បងមិនហ៊ានច្បាប់ព្រះនាមព្រះបិតាយើងទេ ។ ឯដើម្បីទត្តកុមារ ក៏ខំអង្វរករបងថែ ។ ឲ្យតែច្បាប់ព្រះនាមព្រះបិតា, ត្រាតែដើម្បីសេនកុមារអត់ទាំមិនបាន ក៏លើកអញ្ជលីប្រណម្យដោយក្រពុំមានទាំងដប់លើកផ្គងឡើងជាក់លើសិរសា ហើយមានព្រះបន្ទូលច្បាប់ព្រះអនុជថា ប្អូនអើយ, ព្រះបិតាយើងព្រះនាមព្រះបាទក្រុងសុកមិត្ត ។ - បពិត្រព្រះជេដ្ឋា, ចុះព្រះមាតាយើងព្រះនាមដូចម្តេច? - ម្នាលប្អូន ព្រះមាតាយើងព្រះនាម កេសិនីទេវី ។

ចំណែកខាងព្រះនាងកេសិនី កាលបើបានទ្រង់ព្រះសណ្តាប់សព្វគ្រប់ថា ព្រះពាជបុត្រទាំងពីរព្រះអង្គឆ្លើយឆ្លងគ្នាដូច្នោះហើយ ក៏មិនមានក្រោកឡើងប្រវែប្រវាលើកព្រះករតគក់ព្រះទរ ហើយបើកពាំនន្ទសុវត្ថិទៅត្រកងព្រះពាជបុត្រទាំងពីរ ហើយទ្រង់ព្រះកន្សែងចម្រះនេត្រាលនៅទីនោះ ។ កុមារទាំងពីរបើញហេតុដូច្នោះ ក៏ភ័យតក់ស្លុតយ៉ាងខ្លាំង

ខាំបងប្អូនតត់ចេញពីទីនោះទៅ ។ គ្រានោះ ព្រះនាងកេសិនីទេវី ទ្រង់ព្រះកន្សែងសោកវកព្រះពរបុត្រថា

អឺយដេយ្យសេន! អឺយដេយ្យទត្ត! កូនកំសត់មាសម្តាយអើយ, ម្តាយហ្នឹងហើយឈ្មោះកេសិនី, ចូរកូនពីសីអ្នកស្គាល់ចុះ ចូរអ្នកត្រឡប់មកវិញកូនអើយ, ម្តេចក៏អ្នកឃើញម្តាយហើយតត់ចោលម្តាយទៅ ឬមួយអ្នកព្រាត់ប្រាសចាកម្តាយយូរ ហើយខ្វាចម្តាយទេដឹង? តាំងពីម្តាយព្រាត់ប្រាសចាកអ្នកកាលណា ម្តាយវែងរងទុក្ខខ្វោចផ្សាឥតស្រាកស្រួលទេ, កន្លងកាលប៉ុណ្ណោះ ម្តាយឥតបានសុខបន្តិចបន្តួចឡើយ ។

គ្រានោះ កុមារទាំងពីរជាបបា្រស់ជាព្រះមាតាវបស់ខ្លួនហើយ ក៏ត្រឡប់មកក្រាបទ្រង់ព្រះកន្សែងសោកទៀបព្រះបាទទាំងពីរ វបស់មាតា ។ ពួកអ្នកសំភៅ ឮសូរស័ព្ទកោលាហលដូច្នេះហើយ ក៏ជ្រាបដំណឹងនោះដល់នាយសំភៅ ។ នាយសំភៅឮដំណឹងនោះហើយក៏ទំនន្ទត់តៅទៅក្រាបបង្គំទូលព្រះពជាថា សូមព្រះពជតេជះជម្ពូលលើត្បូង, សូមទ្រង់ជ្រាបក្រែមល្អងធូលីព្រះបាទ, ដ្បិតពជបុរសវបស់ព្រះអង្គជាមនុស្សកាចទ្រង់ទ្រីសឃ្នង ប៉ងនឹងប្រព្រឹត្តមេរពុំគ្រាប់ចំពោះកវីយាវបស់ទូលព្រះបង្គំជាខ្ញុំ ជានាំងចាប់បង្ខំឲ្យកើតចលាចលទៅកន្លងនាក់ ។

ព្រះពជាទ្រង់ព្រះសណ្តាប់ពាក្យនាយសំពៅនោះហើយ ក៏ទ្រង់ក្រោធ
ពាក្យយ៉ាងខ្លាំងហើយទ្រង់ត្រាស់បង្គាប់ពេជ្ឈឃាតថា នែប្រសែងឆ
ាំងឡាយ, ចូរអ្នកចាំងឡាយចាប់កុមារចាំងពីរនេះចង នាំយកមក
ឲ្យអញកុំត្រាប្រណី ។ ពេជ្ឈឃាតចាំងនោះ ក៏ទទួលព្រះពជនុង្ការ
ទៅធ្វើបាបកុមារយ៉ាងខ្លាំងចាប់ចងដោយចំណង ៥ ប្រការ នាំទៅក្រាប
បង្គំថ្វាយព្រះពជា ។ ទុម្មុខគួរឲ្យអាសូរ ព្រះពជកុមារមានព្រះកាយ
ប្រឡាក់ដោយឈាម ហូរហាមដូចគេលាបលាក្តលឿងចុំ ។ ព្រះពជា
ទ្រង់ត្រាស់ប្រាប់ពួកពេជ្ឈឃាតថា ចូរអ្នកចាំងឡាយកាត់ក្បាលវា កុំឲ្យ
ទៅ នាំឲ្យអាស្រូវអាប់កេរ្តិ៍ឈ្មោះ ។ ពេជ្ឈឃាតក៏នាំយកព្រះ
ពជកុមារទៅកៃស្មសាន ។ គ្រានោះបុពេហិតម្នាក់ជាអ្នកមានប្រាជ្ញ
ឃើញហេតុនោះហើយ ក៏គិតថា "ទំនៀមស្តេចពីបុពណវៀងមក តែង
ធ្វើនូវអំពើដែលបានពិចារណាហួចហើយ"; កាលគិតដូច្នោះហើយក៏
ហៅកុមារចាំងពីរមកសួរថា នែអ្នកចាំងពីរ, អ្នកមានទោសដូចម្តេច? ។
ដោយស្រេនកុមារ ដំរាបបុពេហិតថា ខ្ញុំបាទឥតមានទោសពៃរអ្វីទេ ។
បុពេហិតក៏ឃាត់ពួកពេជ្ឈឃាតឲ្យបង្អង់ជាំនិន ហើយចូលទៅកាន់ព្រះពជ-
មន្ទីរយ៉ាងរួសរាន់ដោយខ្លួនឯង, ក្រាបបង្គំទូលសួរព្រះពជាថា សូមទ្រង់
ព្រះមេត្តាប្រោស, ព្រះករុណាជាម្ចាស់ដីវិតលើត្បូងទ្រង់ត្រាស់ព្រះពជ-
បញ្ជាឲ្យពួកពេជ្ឈឃាតនាំយកកុមារចាំងពីរទៅធ្វើគត់, តើព្រះករុណាបាន

ទស្សនាការគោសកដូចម្តេច? ។ ព្រះពជាទ្រង់ព្រះសណ្តាប់ពាក្យបុរោហិត
នោះហើយ ទើបទ្រង់ឲ្យបុរោហិតនោះទៅយកកុមារមកវិញ ។ បុរោហិត
ក៏ចុះពីព្រះពជមន្ទីរ រត់ទៅនាំកុមារទាំងពីរមកឡើងលើក្រឡាគំនាល់ ។
ព្រះពជាទ្រង់ត្រាស់សួរកុមារទាំងពីរថា ហេតុអ្វីក៏ឯងធ្វើអំពើអាក្រក់
ក្លាហានយ៉ាងនេះ? ។ ដេយ្យសេនកុមារក្រាបបង្គំទូលថា "សូមទ្រង់ព្រះ
មេត្តាជ្រាស, ទូលព្រះបង្គំជាខ្ញុំព្រះអង្គទាំងពីរនាក់ពុំបានធ្វើអំពើអាក្រក់
យ៉ាងនេះទេ" ហើយក្រាបបង្គំទូលតាមសេចក្តីពិតដោយសព្វគ្រប់ ។
ព្រះពជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់សុតព្រះពជហ្ឫទ័យ ទ្រង់ត្រាស់
សួរថា ចុះនគរអ្នកឈ្មោះអ្វី? ។ ដេយ្យសេនកុមារក្រាបបង្គំទូលថា
សូមទ្រង់ព្រះមេត្តាជ្រាស, នគរទូលព្រះបង្គំជាខ្ញុំឈ្មោះចម្បាកនគរ ។ -
ចុះមាតាអ្នកឈ្មោះអ្វី? - ព្រះមាតាទូលព្រះបង្គំជាខ្ញុំព្រះនាមកេសិនីទេវី ។
- ចុះបិតាអ្នកឈ្មោះអ្វី? ។ - សូមទ្រង់ព្រះមេត្តាជ្រាស, ព្រះនាមព្រះបិតា
ទូលព្រះបង្គំជាខ្ញុំពុំហ៊ានក្រាបបង្គំទូលទេ ។ - ម្តេចក៏អ្នកមិនហ៊ានថ្លាប់? ។
- សូមទ្រង់ព្រះមេត្តាជ្រាស, ទូលព្រះបង្គំជាខ្ញុំខ្លាច ។ - អ្នកកុំខ្លាច
ឡើយ, ថ្លាប់មកចុះ ។ លំដាប់នោះដេយ្យសេនកុមារ លើកកំបាំ
អញ្ជលីប្រណម្យដាក់លើសិរសា ក្រាបបង្គំទូលព្រះនាមព្រះបិតាថា បពិត្រ
ព្រះពជសម្ភារ ព្រះបិតាទូលព្រះបង្គំជាខ្ញុំព្រះនាមព្រះបាទក្រែងសុកមិត្ត ។
ព្រះពជាទ្រង់ព្រះសណ្តាប់ហើយ ហាក់ដូចជានឹងបែកព្រះទ័យ ៧

ភាគ ខ្ញុំតក់ស្លុតរន្ធត់ក្នុងព្រះពុទ្ធជ្ឈ័យ ខ្ញុំស្ទុះគ្រាកចាកព្រះមន្ទីរ
ទៅតែកន្លងបុព្រះពុទ្ធបុត្តទាំងពីរ ខ្ញុំព្រះករុណាសោកសន្ទប់ចាត់ព្រះ
ស្មារតីកន្លងទីនោះឯង ។ គ្រានោះ ពួកពុទ្ធបុរសមានអាមាត្យជាដើមក្តី
ពួកស្រីស្នំទាំងឡាយមានព្រះនាងទេវីជាប្រមុខក្តី ពួកទាហានទាំងឡាយ
មានក្រុមទាហានជាដើមក្តី ក៏សោកសន្ទប់ចាត់ស្មារតីកន្លងទីនោះទាំងអស់ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលព្រះសាស្តាទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា:

ពួកបណ្ដាជន ព្រមទាំងកូនទទឹងប្រពន្ធក្តី ពួកអាមាត្យមានព្រះពុទ្ធជាដើមក្តី ពួកឈ្មួញក្តី ពួកព្រាហ្មណ៍ក្តី ពួកនាងទេវីក្តី ពួកស្រីស្នំស្រីគ្នាក្តី ពួកទាសាទាសីក្តី ពួកសេនាទាហាន មានសេនាជាដើមសេនាវេទនីយសេនាថ្មើរជើងជាដើមក្តី សឹងនាំគ្នាលើកដៃគក់ទ្រូងទ្រហោយំដួលដេកវង្វេងកន្លង ក្នុងព្រះពុទ្ធដ្ឋានរបស់ព្រះបាទក្រុងសុកមិត្ត, ប្រៀបបីដូចដើមកំឆែលចាក់ដោយខ្សល់ព្យុះ ពុំនោះដូចជាដើមឈើតូចដែលរលំដោយខ្សល់ចោកកំទេចដូច្នោះ ។

គ្រានោះ ព្រះពុទ្ធជាម្ចាស់ទ្រង់ព្រះអស្សាសៈធូរស្រួលឡើងហើយ ទ្រង់ត្រាស់ព្រះពុទ្ធបញ្ជាឲ្យស្រាយចំណងព្រះពុទ្ធបុត្រា ព្រះពុទ្ធកុមារ

ตำ ตีរកឹមាន ព្រះសរីរៈ ញ៉ាំ រដូច គេ ទាក់ ដោយ អំណាច មរណៈ ក័យ ។ ទើប ព្រះបរិ ទេវ បញ្ជាក់ ព្រះ ពាជបុត្រ របស់ ព្រះអង្គ ដោយ ពាក្យ នេះ ថា:

ហៃ ដេយ្យ សេន ដេយ្យ ទត្ត, កូន សូន កំសត់ មាស ឪពុក អើយ! បិតា ហ្នឹង ហើយ ឈ្មោះ ព្រះ បាទ ក្រែង សុក មិត្ត, ចូរ អ្នក ស្គាល់ ចុះ ។ ម្នាល កូន, ម្តេច ក៏ អ្នក ទទួល កម្ម កាច អាក្រក់ ម្ល៉េះ? អ្នក នៅ ក្នុង ទី ក្រែង នេះ យូរ យា ណាស់ ហើយ ម្តេច ទ្បើយ ក៏ អ្នក មិន ប្រាប់ បិតា ។

ព្រះ ពាជ កុមារ ទាំង ពីរ ក្រាប បង្គំ ទូល ស្នង ព្រះ រាជ ឫទ្ធា ថា សូម ទ្រង់ ព្រះ មេត្តា ប្រោស, ទូល ព្រះ បង្គំ ជា ខ្ញុំ ពុំ ស្គាល់ ព្រះ អង្គ ព្រោះ ព្រាន សំណាញ់ ចាប់ យក ទូល ព្រះ បង្គំ ជា ខ្ញុំ ទៅ យូរ ណាស់ ហើយ ។

លុះ ព្រះ ពាជ កុមារ ញ៉ាំង ព្រះ ពាជ បិតា ឲ្យ ស្គាល់ ជាក់ ហើយ ទើប ក្រាប ថ្វាយ ទៀប ព្រះ បាទ ា ព្រះ បិតា ទ្រង់ ព្រះ កន្សែង សោក រៀប រាប់ អំពី សេចក្តី ទុក្ខ ព្រួយ ក្នុង ការ ព្រាត់ ប្រាស តាំង ពី ដើម ដំបូង សព្វ គ្រប់ ប្រការ ។ ទើប ព្រះ ពាជ ទ្រង់ ត្រាស់ សួរ ថា ហៃ ឋា, ចុះ មាតា របស់ អ្នក នៅ ឯ ណា? ។ ព្រះ ពាជ កុមារ ក្រាប បង្គំ ទូល ថា សូម ទ្រង់ ព្រះ មេត្តា ប្រោស, ព្រះ មាតា គង់ នៅ ក្នុង សំ ពៅ ។ ព្រះ ពាជ ទ្រង់ សោយ ព្រះ បីតិ សោមនស្ស ស្រស់ ស្រាយ រីក

ភយ, ខើបព្រះពជាព្រមទាំងពជកុមារទាំងពីរ ទ្រង់ចេញចាកព្រះបរម-
ពជវាំង ជាមួយនឹងពួកសេវកាមាត្យ សំដៅទៅមាត់ស្ទឹង ឡើងទៅ
លើសំពៅរបស់ពួកពាណិជ ។ គ្រានោះ ព្រះនាងទេវីតង់នៅកណ្តាល
សំពៅ បានទតឃើញព្រះពជាព្រមទាំងព្រះពជបុត្រ ជ្រាប
ជាក់ជាព្រះពជស្វាមីហើយ ក៏ទ្រង់ព្រះកន្សែងសោកសន្ធប់ចាត់ស្មារតី ។
ព្រះពជាក៏មានព្រះសរីរៈញាប់ញ័រ ទ្រង់ព្រះកន្សែងសោកសន្ធប់ចាត់
ព្រះស្មារតីក្នុងទីនោះដែរ លុះទ្រង់មានព្រះអស្សាសៈធូរស្រួលឡើង
ក៏ទ្រង់លើកព្រះសីរព្រះនាងទេវីជាក់លើព្រះទ្រូងព្រះអង្គ ហើយទ្រង់ព្រះ
កន្សែងសោកទៀត ។ ព្រះពជកុមារទាំងពីរ ក៏លើកព្រះករប្រណម្យ
ឡើងជាក់លើព្រះសិរសោ ទ្រង់ព្រះកន្សែងសោកទៀត ។ លំដាប់នោះ
ព្រះពជាទ្រង់ព្រះកិលាបហើយត្រាស់ថា:

ម្នាលកេសិនីមាសបង, ចូរនាងគ្រោកឡើង ស្វាមីមកដល់
ទីនេះហើយ, កូនទាំងគូរបស់នាងក៏មកដែរ, នាងក្សេម
ឡើងហើយឬ? ។

លំដាប់នោះព្រះនាងទេវី ទ្រង់ក្សេមស្មារតីឡើង ក៏ងើបទៅក្រាប
ទៀបព្រះបាទានៃព្រះពជា ហើយត្រាស់ព្រះពជសារនីយថា:

ឯវ្ហតោ ទានិ មេ សោកោ ឯវ្ហតំ ទានិ មេ ភយំ
ឯវ្ហតោ វិបលោ សោកោ បស្សន្តោ ឦទិសំ បតិ

ឥឡូវនេះសេចក្តីសោករបស់ខ្ញុំម្ចាស់លត់ហើយ, ឥឡូវនេះ
ភ័យរបស់ខ្ញុំម្ចាស់លត់ហើយ, សេចក្តីសោកវិវែងលត់
ហើយ ព្រោះបានដួចនឹងព្រះពុទ្ធសាមី ។

រួចព្រះនាងទេវី ស្តេចទៅក្រសោចនុបព្រះពុទ្ធបុត្រទាំងពីរ
សោកសន្ធប់ប្រាត់ព្រះស្មារតីក្នុងទីនោះទៀត ។ គ្រានោះពួកអាមាត្យទាំង
អស់នឹងពួកស្រីស្នំហនាងទេវីជាប្រធាន ឃើញក្សត្រទាំងនោះដូច្នោះ
ហើយ ក៏សោកសន្ធប់ប្រាត់ស្មារតីជាមួយគ្នាក្នុងទីនោះឯង ។ ក្សត្រ
ទាំងនោះសោយសោកវិលវេញទាំងថ្ងៃសំពៅ ដរាបដល់ទីនគរអស្សគ្គត,
ពួកអាមាត្យក៏រត់ទៅនាំយកព្រះសុពណ្ណសិវិកា រំលេចដោយកែវទាំង ៧
ប្រការមកហែយកព្រះពុទ្ធ នឹងព្រះនាងទេវី ព្រមទាំងព្រះពុទ្ធបុត្រ
ទាំងពីរ ត្រឡប់ទៅកាន់ព្រះពុទ្ធមន្ទីរវិញ ។

គ្រានោះព្រះពុទ្ធទ្រង់ឲ្យរៀបពិធីលេងមហោស្រពអស់ ៧ ថ្ងៃ ទើប
ក្សត្រថ្ងៃទ្រង់អភិសេកព្រះនាងទេវីជាអគ្គមហេសី, ទ្រង់ប្រទានទីឧបភជ
ដល់ដេយ្យសេនកុមារ; ប្រទានដំណែងសេនាបតីដល់ដេយ្យទត្តកុមារ ។
តាំងពីនោះមក ព្រះអង្គទ្រង់ធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើមដរាប
ដល់ទីបំផុតព្រះជន្មាយុ ទ្រង់ព្រះវិង្គតទៅយកព្រះជាតិក្នុងពិភពតុសិត ។

ព្រះសាស្តាទ្រង់នាំធម្មទេសនានេះមកសំដែងប្រាប់ហើយ ទ្រង់
សម្តែងជាតកត្រាស់ព្រះគាថាបច្ឆិមបំផុតនេះថា:

អសុភមិត្តោ ទេវទត្តោ អានន្ទោ ជេយ្យទត្តោ អហុ រាហុលោ ជេយ្យសេនោ ច កេសិនី ទេវី សុទ្ធរា មាតា អាសិ មហាមាយា បិតា សុទ្ធោទនោ អហុ សុភមិត្តោ លោកនាថោ ឯវំ ជាតេបិ ជាតកំ

*អសុភមិត្ត ចេវវិលវឹងមកបានជាទេវទត្ត; ដេយ្យទត្តកុមារ ចេវវិលវឹងមកបានជាអានន្ទ; ដេយ្យសេនកុមារ ចេវវិលវឹងមកបានជាពហុល; នាងកេសិនីទេវី ចេវវិលវឹងមកបានជានាងយសោធរ; ព្រះមាតាចេវវិលវឹងមកបានជាព្រះនាងមហាមាយា; ព្រះបិតាចេវវិលវឹងមកបានជាព្រះបាទសុទ្ធោទន; ព្រះបាទក្រែងសុភមិត្ត គឺសេចក្តីជាបរមលោកនាថសាស្តាចារ្យហ្នឹងឯង; អ្នកទាំងឡាយ ចូរចងចាំជាតកដែលតថាគតសំដែងមកយ៉ាងនេះចុះ ។*

ចប់សុភមិត្តជាតក ទី ៩ តែប៉ុណ្ណោះ

(សិស្សោរដាតក)

# ព្រះមហាឧត្តមរដ្ឋា ធិលញ្ញាណោ ប៊ិង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ
រៀបរៀងតាមតម្រាយសាស្ត្រាស្ទឹកវិត

(តមក)

---

ចោ៉ាលគោកយំលន្ទោច　　លលកភ្ញោចទំដើមកំឆ
ខ្វែងស្រែកស្រែកឮខ្ទាំង　　គួរកក្ងូកំឆស្រែកបន្ទប់ ។
មៀមមុមទំដើមត្រាច　　យំគួរខ្ទោចត្រីស្រែងស្រប់
ទីទុយទំដោយមួប់　　ឈើប្រសព្វមែកត្រែឈ ។
ទុកទ្រូហ៊ូពូយំ　　សូវរណ្តំទំមែកជ្រៃ
ចចាតន្ទូច្រែចៀ　　មានមាន់ព្រៃទំក្តាំឆងារ ។
អស់សត្វផងទាំងឡាយ　　ហើរប្រញាយដោយហួងវ
ចុះទំយំរកគ្នា　　លោតសុះស្ងួចុងចំប៉ី ។
ខ្លះហើរកផលា　　ចឹកកោង្កាជាចំណី
តិចហើយហើរទៅខ្ចី　　ទំចំប៉ីចម្ប៉ាពេញ ។
ត្រសេះហើរត្រសង　　ទំដើមកូងហើយហើរចេញ
ទៅទំដើមរំដេញ　　ខ្លះហើរចេញទំរំដួល ។
តារើសំឡេងខ្ញោក　　សត្វចោ៉ាលគោកសំឡេងស្រួល

ហើរទៅទំដើមស្នួល ជុះលើខួលទីត្រែងដំ ។
ស្តេចស្តាប់សព្ទមាត់សត្វ សូនស្រែងាត់ជិតដើងកុំ
កូនខ្លែងណែនអួលកែំ ស្តេចខះខំបរអាជានេយ្យ ។
រន្ធែងពុំដឹងសោះ នឹងចំពោះទៅទីត្រៃ
លេចវាល់ហើយចូលត្រៃ លំបាក់ត្រៃអង្គអាត្មា ។
ស្តេចត្រាច់ក្នុងព្រឹក្សត្រៃ លំបាកត្រៃឥតឧបមា
ពុំមានគោជនា គ្រាន់តោក្តាំចំអែតផ្លែ ។
ខូរន់ខូរអង្គ កូត្រៃរវាងគង់អាជានេយ្យ
តត្រៃកុរកក្នុងត្រៃ ទើបខម្ចុះដល់វាលស្រែ ។
ស្តេចឈ្មៀងព្រៃនេត្រទៅ យល់ស្រែនោះឯងឯ
ស្តេចគង់ហើយគិតថៃ នេះស្រុកគេមិនទេឡើយ ។
ខ្ញុះគួរអញសំដៅ សញ្ជរទៅស្រុកនោះហើយ
រកបាយគេទៅវើយ ត្រែងគេឲ្យអញតិចវ៉ា ។
ស្តេចគិតដូច្នោះហើយ ពុំលង់ឡើយព្រះរាជា
ស្តេចបរអស្សពាហន៍ ឆ្ពោះទៅនាស្រុកនោះឱ្យ ។

## បទកូនច្ចលីលា

ទឹងថ្ងៃសំដែងស្រដី អ្នកស្រុកប្រុសស្រី តែងធ្វើស្រែស្រូវ ។
ថ្ងៃនោះមានប្រុសមួយកូរ ជាម្ចាស់ស្រែស្រូវ គន់គិតថ្លូនថៃ ។

រៀបចំទំនិងទៅចាំស្រែ  ក្បាលណានោះឯងឯង  យកស្លឹកដោះចាយ ។
ដោះស្រែចយកតែងៀតលាយ  ហើយខ្ចប់ទាំងចាយ  ដាក់ល្អីយកទៅ ។
លុះដល់ពាលស្រែឯក្រៅ  ចួនពេលនោះទៅ  ពុំទាន់ឃ្លានចាយ ។
ទើបទុកល្អីចាយទៅអាយ  ហើយដើរទៅនាយ  មើលស្រែសាលី ។
បង្កើលបក្សាបក្សី  ចួនថៃឃ្នាតខ្លី  ឥតបីបណ្តោយ ។
កាលនោះមានឆ្កែកំព្រាយ  មួយដើរតាមក្រោយ  ដល់ទីនោះខ្លី ។
ឃើញកញ្ចប់ចាយក្នុងល្អី  ទើបពាំរត់ប៉ុស  ពីទីនោះទៅ ។
កាលនោះព្រះបាទសិសៅរ  ស្តេចបរសេះទៅ  តាមផ្លូវភ្លឺស្រែ ។
គ្រានោះរឹងម្ចាស់ស្រែ  មើលស្រូវចួនថៃ  ស្រែចហើយវិលខ្លី ។
ទៅកេកញ្ចប់ក្នុងល្អី  ពុំ ឃើញចំណី  រកអ្វីស៊ីគ្មាន ។
ទំនណាស់ដោយសារវាឃ្លាន  ហើយគន់គិតស្មាន  ថាមានមនុស្សយក ។
កាលនោះពង្សពុទ្ធន្តក  ស្តេចបរសេះមក  ដល់ស្រែនោះណា ។
ម្ចាស់ស្រែនោះបែរនៃគ្រា  ឃល់ព្រះរាជា  ពាក់មកុដពិសី ។
ឃើញជាកញ្ចប់ចាយខ្លី  លោស្តុះទៅប៉ុស  ដល់ពោធិសត្វ ។
ស្រែកដេរបួចតែពីមាត់  ថា "អាខ្ចបក្តាត់  ចិត្តចោរអប្រិយ ។
មឹងមកពីទីណាវ៉ុ  ហ៊ានលួចចាយត្រី  ពីល្អីអញអស់ ។
អញទុកអំមិញស្រស់ ។  លួចយកស៊ីអស់  ត្រីងៀតមួយដុំ ។
បើឃ្លានម្តេចមឹងមិនសុំ  មឹងឯងនេះពុំ  រួចពីអញវាយ ។

ស៊ីហើយមិនធ្វើពាយឆាយ យកកញ្ចប់ចាយ ទូលលេងជាល្បែង" ។
ក្រុណោះពោធិសត្វថ្លែង ប្រាប់ថា "អញឯង មិនជាអ្នកលួច ។
ម្តេចឡើយអ្នកហ៊ានគាន់ក្លួច ថាអញនេះលួច សំណុំចាយឯង ។
ដៃលពាក់លើក្បាលចិញ្ចែង មកុដអញជាក់ស្តែង ម្តេចឯងមាក់ងាយ ។
ថាអញលួចសំណុំចាយ ហើយគិតចង់ឆក់យក អញឯងដូច្នោះ" ។
រីឯម្ចាស់ស្រែស្រូវនោះ យល់ស្តេចធ្វើយដោះ ដូច្នោះវិញណា ។
ម្ល៉ោះហើយរឹងរឹតក្រែងធា ខឹងក្នុងចិត្តា រឹងជាដេរខ្មែត ។
ថា "អាកំសត់ចោលមេ្យត មានរឹងហ៊ានធ្វើត ដដែកប្រែកែក ។
តិចលោអញចាប់មាត់ហែក ម្តេចមិនប្រែកែក អញស្គាល់ចំហុត ។
ម្តេចមិនហ៊ានរឹងថាមកុដ កញ្ចប់សុទ្ធ ។ មកថាមកុដអា ។
មុខឯងមានមកុដពីណា ម្តេចហ៊ានមុសា ពុំខ្មាសគេឯង ។
អានេះចិត្តកាចឥតត្រែង អញវាយអំបែង ក្បាលឯងជាម្តង" ។
ថាច្នោះស្ទុះចាប់បានដង - ដន្ទញមកហោង ចាក់មាត់ក្បត្រា ។
វាយដំធាក់ច្រវាជ្រា ពុំមានមេត្តា ករុណាមហាក្បត្រ ។
ឈាមច្រាលរាល់ច្រមុះក្តាត់ ព្រះពោធិសត្វ កើតមានវេទនា ។
ពុះតង់អស់ទាំងកាយា ជាំជាំមហិមា មានវេទនាណាស់ ។
អង្វរលើកដៃសំពះ "នុះនុ! លោកម្ចាស់ លែងជីវិតខ្ញុំ ។
ព្រះមកុដកែវរ័តន៍ទាំងដុំ នេះរបស់ខ្ញុំ ពិតពុំមុសា ។

ឥឡូវអ្នកឃើញថាជា កញ្ចប់គោជនា ប្រាកដមែនពិត ។
ខ្ញុំសូមសៅតែជីវិត របស់អ្នកពិត អ្នកយកចុះ” ។
អ្នកនោះឮព្រះពាក្យ ថាឲ្យច្នោះណា បន្ទោខឹងប្បាត់ ។
ទើបយកព្រះមកុដកែវតែន លែងពោធិសត្វ ហើយបណ្តោញថា ។
“អាទៅឲ្យឆាប់ៗ” ពីនេះទៅណា កុំមកឡើយនៃ ។
បើមកគ្រោយនោះនឹងក្បុយ ជីវិតប្រល័យ ប្បាត់បង់ពុំជា” ។
កាលនោះសម្តេចក្សត្រា ស្តេចបរអស្សពាហន៍ ពីទីនោះទៅ ។
ទ្រង់មានព្រះកាយហួងសៅ ពាក់ជុំជាំខ្មៅ លំបាកពេកពន់ ។
គ្រាំគ្រាខូកខូរន់ ស្មើរក្បុយព្រះជន្ម ក្នុងព្រៃស្មសាន ។
ឈាមហូរជោកជាំអង្គប្រាណ ទុក្ខពន់ប្រមាណ ទើបសោយសោកថា ។
“នុះតុ! ខ្ញុំនអញនេះណា មកវង់ទុក្ខា ខ្លាំងក្លាស្មើរក្បុយ ។
តាំងនេះព្រោះអញនេៈនៃ មានៈខ្លាំងពៃក ពុំដឿហោក ។
ដែលគេចាយឲ្យអាត្មា ទើបវង់ទុក្ខា វេទនាតាំងម្ល៉ះ” ។
ទ្រង់សោកហើយទ្រង់ដឹកសេះ បណ្តើរគេចវេះ អំពីទីនោះ ។
ដល់ព្រៃស្រងមុខចំពោះ រម្ងាស់ព្រៃនោះ ជាមនុស្សឱឡា ។
កំដិលតុំដែលយាត្រា មើលស្រូវឡើយណា ចោលជាយូរថ្ងៃ ។
ទើបជាបន្ទោះល្អពៃក ឲ្យចោរចង់ផ្តែ លួចប្រគួតស្រូវនោះ ។
ហើយវាវែកយកទៅស្មោះ រឯគ្រោយនោះ ម្ចាស់ស្រូវនោះឯង ។

ចេញទៅពីផ្ទះសម្បែង លីទាំងលំពែង ដើរដល់ស្រែស្រូវ ។
ក្រឡេកមើលស្រែនោះកូវ យ៉ាងយល់ឯស្រូវ រលីងទៅខ្លះ ។
ម្ចាស់ស្រូវនោះកូវខឹងណាស់ ទើបប្រែចិត្តណាប្រុះ ទៅពួនក្នុងស្រូវ ។
គយគន់លបមើលគ្រប់ផ្លូវ ក្រែងចោរនោះកូវ មកលួចទៀតណា ។
ថ្ងៃនោះជាគ្រោះមហិមា ចួនជាក្សត្រា ព្រះបាទសិរីសោវ័ ។
ស្តេចយាងព្រះទីនាំងទៅ តាមផ្លូវដែលទៅ ជិតស្រែនោះនៃ ។
ម្ចាស់ស្រែឯកបែររំពៃ យល់មហាក្សត្រថ្លៃ បរសេះទៅជិត ។
ម្ចាស់ស្រូវមានសញ្ញាគិត ថាជាចោរពិត លោលើកលំពែង ។
ស្រែកដេរគំពាមកំហែង ឥតខ្លាចឥតក្រែង ដល់តិចឡើយនៃ ។
ថា "អាចិត្តចោរចង្រៃ លួចស្រូវសត្វថ្លៃ មិនដែលប្រទះ ។
ឥឡូវនេះទើបតើបតុះ ខ្លួនមឹងឯងច្បាស់ ជាចោរលួចស្រូវ" ។
ទើបស្តេចឆ្លើយថា "ពុំត្រូវ ខ្ញុំឯងនេះកូវ មិនជាចោរលួច ។
ម្តេចឡើយអ្នកហ៊ានកាន់កួច ខ្ញុំនេះឥតលួច កុំដេរឡើយណា" ។
បុរសនោះមើលឃើញថា ព្រះខាន់នៅនា ហត្ថាមហាក្សត្រ ។
ជាក់ជាកណ្តៀវពេក់ក្តាត់ ខ្មោះហើយទើបគាត់ រឹងជាក្រោធក្រែ ។
ថា "នែអាចោរចង្រៃ កណ្តៀវនៅដៃ ម្តេចហ៊ានប្រកែក ។
អញវាយក្បាលមឹងឲ្យបែក ម្តេចមឹងជាជែក ប្រកែកមកផង" ។
ថាហើយក៏ចាប់យកជង លំពែងសំពង ពង្រាយោធិសគ្ង ។

ខែតណាមរហាមច្រែនភ្លាត់ ស្រក់ស្រោចមុខមាត់ ខន់តាំងកៈយា ។
ព្រះអង្គខ្ចែងព្រះចិន្តា តន់តិតរនិច្ចា សារឡើតពេកវៃក្រៃ ។
ថា "តុ! ព្រះខាន់តែវាថ្លៃ កាន់មកសព្វថៃ្ង ឥឡូវនេះកូវ ។
ក៏ច្រែងាកណ្តៀវស្រែវ គឺកម្មអញកូវ ទើបជាច្នោះណា " ។
ស្តេចមានព្រះបន្ទូលថា "អ្នកអើយមេត្តា លែងក៏យខ្ញុំទៅ ។
ថាបើកណ្តៀវពិតនៅ សូមអ្នកយកទៅ ខ្ញុំសូមតែរស់ ។
ផងអ្នកខ្ញុំឲ្យតាំងអស់ ខ្ញុំសូមតែរស់ ជីវិតតទៅ " ។
បុរសឮច្នោះអន់ក្តៅ ពុំសូវមួមៅ បន្ទោចិងបាត់ ។
ទើបយកព្រះខាន់តែវត្តែ លែងពោធិសត្វ ហើយបណ្តេញថា ។
"មឹងទៅឲ្យឆាប់ៗក៏ កុំមកទៀតណា លួចស្រែវអញនៃ ។
បើលួចឯក្រៃគាយនឹងក្រ័យ ដីវិតប្រល័យ សោះសូន្យមរណា " ។
ព្រះបាទសិរីសៅវ៉ាជា ស្តេចខ្ចែងវេទនា សល់សែនឥតបើ ។
ទំអត់សង្កត់ខ្លី ទឹងពាក្យសំដី ដែលគេផ្តាសា ។
ទឹកនេត្រហូរធ្លាក់មកណា ស្រោចស្រង់តក្រ្តា គួរសង្វេគក្រៃ ។
ហើយស្តេចដឹកអាជានេយ្យ រាសរៃ ចេញពីទីនោះ ។
ដល់ស្រែឯមុខចំពោះ មានម្ចាស់នៅនោះ រក្សាស្រែវហោង ។
ម្ចាស់ស្រែវត្រែវឃ្វាលគោផង ដឹកគោទៅចង ឲ្យក្រុស៊ីស្មៅ ។
ចង់ស្រែចពុំបានចាំនៅ ច្រញ៉ាប់រំលៃទៅ បរិភោគ្តា ។

(មានត)

# រឿងសាមកុក

## ខុកញ៉ាវិបុលរាជសេនា ន្ហូ-កន ប្រែរៀបរៀង

(តមក)

ឮរឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

កណ្ឌទី ២០

តាំងពីឡើពីសុំសំបុត្រគេហៀនផ្ញើទៅសុំកងទ័ពអ៊ូនសៀវដាជន្លងឲ្យលើកមកជួយ រហូតដល់ស៊ុនហ៊ីវនិយាយថា នឹងប្រើឧងយ៉ុងឲ្យចេញទៅនិយាយបញ្ចុះបញ្ចូលឡើពៀវ ។

ឡើពីថា គ្រានេះអ៊ូនសុតស្ងាប់ក៏ព្រោះបើងលើកកងទ័ពទៅច្បាំង ដែលនឹងឲ្យមានសំបុត្រទៅសុំកងទ័ពអ៊ូនសៀវនោះ ថ្មីកដជាអ៊ូនសៀវមិនលើកទ័ពមកជួយទេ ព្រោះមិនមានផ្លូវមេត្រីទៅវិញទៅមកនឹងយើង ។

គាន់តេងឆ្លើយថា គេហៀនដែលនៅកងស្រុកលីជីវនេះ ជាជន្លងនឹងអ្នកសៀវ ហើយក៏ត្រូវអធ្យាស្រ័យគ្នានឹងលោកមកពីដើម ខ្ញុំ

ចានយ៉ាប់ឃើញថា ចើលោកទៅតំនាប់តេហៀនរឿយៗ ហើយ ចើលោកទីដ៏សុំសំបុត្រតេហៀនទៅឲ្យអ្នកសៀវ មុខជាអ្នកសៀវនឹងលើកមកជួយលោកតាមសំបុត្រអ្នកសៀវជាប្រាកដ ។ ឡៅពីចានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរទើបនិយាយថា "តេហៀននោះជាគ្រូប្រដៅអក្សរយើងមកពីដើម កាលគ្រាយើងនៅក្នុងស្រុកខុនគួន ក្រោយពីនោះមកតេហៀនចូលទៅធ្វើរាជការជានាហ្មឺន ក្នុងរាជ្យព្រះចៅហៀនតេលុះខន្ធី ១០ នាក់ប្រព្រឹត្តខុសច្បាប់តែអាក្រក់ក្នុងផែនដី តេហៀនក៏លាចេញពីរាជការមកនៅក្នុងស្រុកឈីជីវនេះ" ថាហើយឡៅពីក៏ចាត់ចែងរបស់ទ្រព្យ ហើយនាំខ្លួនតាន់តេងទៅកេតេហៀនឯផ្ទះ ។ ឡៅពីតំនាប់តេហៀនហើយពណ៌នាសេចក្តីឲ្យតេហៀនស្តាប់គ្រប់ប្រការថា ឥឡូវនេះខ្ញុំមានសេចក្តីទុក្ខព្រួយពាន់ពេកណាស់ សំឡឹងមើលទៅឃើញតែលោក, សូមលោកអាណិតខ្ញុំសុំធ្វើថាសំបុត្រឬសលោក ទៅសុំកងទ័ពអ្នកសៀវឲ្យលើកមកជួយដើម្បីបង្ក្រាបនឹងបច្ចុ ។

គ្រានោះតេហៀនចានស្តាប់ឡៅពីនិយាយ ក៏មានចិត្តអាណិតមេត្តាចានសរសេរសំបុត្រតាមពាក្យឡៅពី លុះធ្វើរួចក៏ប្រគល់ឲ្យឡៅពីៗទទួលហើយក៏លាតេហៀនត្រឡប់ទៅផ្ទះវិញ ហើយប្រើស៊ុនទៀនឲ្យកាន់សំបុត្រនោះទៅឲ្យអ្នកសៀវឯស្រុកគីជីវ ។ អ្នកសៀវឃើញសំបុត្រតេហៀនដូច្នោះ ក៏គិតតែក្នុងចិត្តថា "ឡៅពីប្រទូសច៉ាយនឹងអ្នកសុតជា

ប្អូនអញ ។ កំពុងតែតិតនឹងសង្ឃឹកខ្លាំង ឥឡូវបើកញ្ចប់មិនលើកទ័ពទៅជួយទេ កំចាយម្តងតែហៀនដែលបានធ្វើសំបុត្រមកដល់ហើយ" តិតហើយក៏ឲ្យហៅទីប្រឹក្សាមកប្រាប់ថា "គ្រានេះបួនមានកំឡាំងជាច្រើនណាស់ ហើយធ្វើអាក្រក់ទឹងព្រះចៅហៀនតេ យើងនឹងលើកទ័ពទៅកំចាត់បួន តើអ្នកទាំងពួងនឹងយល់ឃើញដូចម្តេច ? ។

តឿនហង៍ទីប្រឹក្សាទ្រើយថា លោកបានលើកកងទ័ពទៅធ្វើសង្គ្រាមគ្រប់ឆ្នាំមិនដាច់ ណាមួយសេនាទាហានកំពុងនឿយហត់ពេកណាស់ ប្រការ១ទៀត ស្បៀងអាហារទៅកងជង្រុកសោតក៏ស្ពិចស្ពីង ទៅមិនទាន់ប្រមូលទុកឲ្យគ្រប់គ្រាន់បរិបូណ៌ ដែលលោកនឹងលើកទៅគ្រានេះខ្ញុំបាទឃើញថា ទាហានទាំងពួងនឹងបានសេចក្តីអត់ឃ្លានខ្លាំងណាស់ សុំឲ្យលោកមានសំបុត្រចូលទៅគាបឲ្យស្តេចព្រះចៅហៀនតេ ឲ្យទន់គ្រាស់ហាមឃាត់បួន កុំឲ្យលើកកងទ័ពទៅធ្វើអន្តរាយដល់អាណាខ្មែរតែទាំង ពួងឲ្យអាណាប្រជានុករស្លុកបានសេចក្តីក្តៅក្រហាយ បើបួនមិនធ្វើតាមព្រះតម្រាស់ យើងនឹងលើកកងទ័ពធំទៅកាយឲ្យគ្រប់មណ្ឌលខ្មែរតែទាំងពួង ហើយកៀរប្រមូលយកមនុស្សនឹងស្រូវអង្ករចំណីអាហារ រៀបគ្រឿងសស្ត្រាវុធបន្ថែមទ្រព្យទ្រង់ទ្រាយឲ្យតែមយ៉ាងច្រើន ហើយធ្វើសំបុត្រចេញប្រកាសដល់នាហ្មឺនមុខមន្ត្រីក្នុងក្រុងថា បួនជាសត្រូវពាជសម្បត្តិ បើនាហ្មឺនទាំងឡាយយល់ឃើញផងយើងក៏បានការ ត្រូវធ្វើដូច្នេះតំរង់៣ឆ្នាំ គង់នឹងសម្រេចការបានដោយងាយ ។

សមដូយបានឮតៀនហង៍និយាយដូច្នោះក៏ឆ្លើយថា អ្នកគិតដូច្នេះ
មិនត្រូវសោះ ព្រោះគាហានរបស់ចៅហ្វាយយើងគ្រានេះ សុទ្ធតែមាន
ថ្លៃដៃច្រើនណាស់ បើនឹងគិតកំចាត់ចូរនោះងាយណាស់ ។បមាដូចជា
លើកដៃផ្តាប់ចុះ ហេតុម្តេចបានជាអ្នកគិតឲ្យយឺតវែងៅដូច្នេះ? ។ ឈើស៊ីវ
បានស្តាប់សមដូយថាដូច្នោះ ក៏ជំរាបៅអ្នកសៀវថា ធម្មតាសង្គ្រាម
មិនមែននឹងមានជ័យជំនះព្រោះគាហានច្រើននឹងតិចនោះទេ វមែងចាញ់
ឈ្នះព្រោះ។បាយកលប្រជាជារិគិតការៅផ្សេង ។ ឯចូរនោះគោះបើ
មានសេនាគាហានតិចជាងយើងក្តីណា តែថាគេមានសតិបញ្ញាជំនាញ
ស្ទាញស្ទាត់ ក្នុងការសង្គ្រាមជ្រៅជ្រួលាយណាស់ ទាំងមីប្រឹក្សាក៏ធ្វើរ
ធ្ងាត ដែលនឹងធ្វើបានដោយងាយ ដូចជាកងស៊ុនចានមិនមែនទេ
សុំឲ្យលោកធ្វើតាមពាក្យតៀនហង៍វិញទើបសម្រេច ។

គួរតៅឆ្លើយជំរាបអ្នកសៀវថា គ្រានេះបានកលការល្មមធ្វើហើយ
ដែលនឹងរង់ចង្អុងចុកតាមពាក្យតៀនហង៍នឹងឈើស៊ីវនោះ មុខជាចូរ
នឹងមានគំនិតច្រើនឡើងៅខាងមុខ គាហានរបស់យើងនឹងមានសេចក្តី
លំបាក ម្យ៉ាងទៀត តេហៀនក៏មានសំបុត្រមកដល់លោកផង បើ
លោកនឹងមិនលើកទ័ពៅគ្រានេះ តេហៀននឹងមានសេចក្តីតូចចិត្ត,
ប្រការ ១ ទ្បៅពីក៏ជាពូជព្រះពជវង្សទាំងមានចិត្តសត្យទៀងត្រង់នឹង
ផែនដី គួរហើយលោកនឹងលើកទ័ពៅជួយទ្បៅពីធ្វើការកំចាត់ចូរ

ចេញ ដើម្បីទ្រព្រះមហាក្សត្រនឹងនាហ្នឹងមុខមន្ត្រីនៅអាណាប្រជា-
ន្តុកស្តុកថានសេចក្តីសុខក្សេមក្សាន្តព្រោះគំនិតរបស់លោក ។

អ្នងសៀវបានស្តាប់ទីប្រឹក្សា ៤ នាក់និយាយមិនចុះរុះគ្នា ក៏នៅស្ងៀម
ទទួលយើញទៅហ៊ីវនឹងស៊ុនខាមចូលមក អ្នងសៀវក៏គិតក្នុងចិត្តថា
"ទៅហ៊ីវនឹងស៊ុនខាមនេះជាមនុស្សមានសតិបញ្ញាជាងអ្នកទាំងពួង យើង
នឹងប្រឹក្សាល្បងមើលគំនិតអ្នកទាំង ២ នេះ តើនឹងគិតយើញដូចម្តេចវិញ"
អ្នងសៀវក៏និយាយប្រាប់ទៅហ៊ីវនឹងស៊ុនខាមតាមដំណើរ ហើយសួរថា
អ្នកនឹងយើញដូចម្តេច? ។

ទៅហ៊ីវនឹងស៊ុនខាមឆ្លើយថា គ្រានេះ ទាហានរបស់លោកក៏មាន
ច្រើនណាស់ ទាំងថ្មីដៃក៏ខ្លាំងពូកែ គួរតែទៅជួយឡៅពីជាពូជព្រះ
ពាជវង្សដែលមានកំលាំងតិច ដើម្បីនឹងកំចាត់ចូឡូដែលជាសត្រូវពាជសម្បត្តិ
ចេញ ដូចជាលោកជួយទំនុកបំរុងដែនដី សេចក្តីគាប់ប្រសើរក៏នឹង
មានដល់លោកទៅខាងមុខ ។ អ្នងសៀវបានស្តាប់ដូច្នោះក៏ឆ្លើយថា
"គំនិតអ្នកទាំង ២ នេះ ត្រូវនឹងចិត្តយើងគិតទុកជាស្រេច" ថាហើយ
ក៏តែងសំបុត្រឲ្យស៊ុនខៀនកាន់ត្រឡប់ទៅឲ្យតេហៀន សេចក្តីថា
"យើងនឹងលើកកងទ័ពទៅកំចាត់ចូឡូ ឲ្យឡៅពីទៅប្រសព្វគ្នានឹងទ័ព
របស់យើងចុះ" ។ ស៊ុនខៀនទទួលយកសំបុត្រនោះ ហើយក៏លាអ្ន
សៀវត្រឡប់ទៅ លុះដល់ស្រុកឈីដីវក៏យកសំបុត្រនោះទៅជូនឡៅពី ។

ឯអ្នកនៅសៀវកំតាំងតែកេណ្ឌពាហាន ឲ្យងាន់លឿន, ប៊ុនធី លើកពាហានចេញទៅជាទ័ពមុខ ឲ្យសុំមជ្ឈិមនឹងអង្គតាជាបាឡាត់ទ័ពបង្កាប់ពាហានតូចធំតាំងពួង ខ្លួនអ្នកនៅសៀវជាមេទ័ពធំលើកពាហានដុះសេះ ១៥ ម៉ឺន, បញ្ជូលគ្នាជាពាហាន ៣០ ម៉ឺនឲ្យទៀនហង, ទៅហ៊ីវ, ស៊ុនខាម, ៣ នាក់នេះជាទីប្រឹក្សា លុះត្រៀមពាហានបាននៅសេចវេលាណា ដល់ឫក្សល្អក៏លើកទ័ពចេញទៅ ។ គួតៅជំពាបអ្នកនៅសៀវថា ដែលលោកនឹងលើកកងទ័ពទៅកំចាត់ចូរធ្នូនោះ ចូរធ្វើការតាន់យកអាណាខែត្រតាំងពួង នឹងបណ្តាក់ស្តុកកុំឲ្យគេចត្រឡប់ចូលទៅខាងចូរធ្នូបាន ។

អ្នកនៅសៀវសួរថា អ្នកនឹងឲ្យធ្វើយ៉ាងម្តេច ? ។ គួតៅជំពាបថា កាលបើលោកនឹងលើកកងទ័ពចេញទៅនោះ សុំឲ្យតែងសំបុត្រទៅបិទទុកគ្រប់ទ្វារស្រុក កុងអាណាខែត្រនីមួយៗ ពោលទោសចូរធ្នូថា ចូរធ្នូធ្វើការអាក្រក់ប្រព្រឹត្តទុច្ចរិតជាក្បត់សត្រូវនឹងផែនដី ។

អ្នកនៅសៀវបានស្តាប់ដូច្នោះ កំមានសេចក្តីត្រេកអរពន់ពេក ទើបនិយាយនឹងតាន់លឹមដែលជាអាល័ក្សពីគ្រាព្រះចៅហាន់តេ ជាព្រះអយ្យកោព្រះចៅហៀនតេ កាលតាំងតុះលើកចូលមកនៅក្នុងស្រុកឡុកអៀងនោះ តាន់លឹមវិះគេចមកនៅនឹងអ្នកនៅសៀវ កំឲ្យតាន់លឹមធ្វើសំបុត្រតាមពាក្យគួតៅថា ។

(មានត)

រឿងព្រេងប្រទេសឥណ្ឌា

# អ្នកស្រីស្រីនិង-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាចាមមកជាភាសាខ្មែរ

(តមក)

---

ពួកឈ្មួញនាំគ្នាធ្វើដំណើរតទៅទៀត ទាំងព្រួយបារម្ភ, ព្រះនាងទមយន្តីទ្រង់យាងតាមក្រោយគេ ដោយមានព្រះទ័យស្រពោនអណ្តែតអណ្តូង ហើយមានដំណើរបែបល្វើយ ។ ក្រោយមកព្រះនាងបានយាងដល់ទៅក្រុងឆេទីស៍ ដែលជាប្រទេសនៃព្រះចាទសុវហុ ។

* * *

ភាគទី ២៥

អ្នកដើរនៅផ្លូវនាំគ្នាមើលព្រះនាង ដែលមានឫកពាជាអ្នកធំ ប៉ុន្តែទៅជាមានសក់ស្រយាក ដើងជាច់ឈាមហូរហាមហើយស្លៀកសំពត់គ្រឹមរហែករហៃ ដើរមិនចំពោះទៅតាមវិថីណាក្នុងក្រុង ។ ពួកកូនក្មេងនាំគ្នាដើរតាមព្រះនាងដោយចង់ដឹង ខ្លះទៀតនាំគ្នារិះគន់ព្រះនាងបួនកាលថែមទាំងយកដុំថ្មចោលព្រះនាង ។

ព្រះនាងយាងដល់មុខព្រះបរមរាជវាំង ។ ឯកអគ្គមហេសីស្តេច, ព្រះរាជបុត្រី និងស្រីស្នំក្រមការ គាល់ស្តេចត្រៀបត្រានៅលើយ៉ព្រះ

ពាជដំណាក់, លុះស្តេចឃើញព្រះនាងទមយន្តីយាងមកដល់ ទ្រង់មានព្រះហឫទ័យអាណិតណាស់ ក៏ច្រើសំម្លាក់ថា: "ចូរឯងនាំស្រីកំសត់នោះមកទីនេះ នាងនោះបែបលំបាកខ្លាំងណាស់ ប៉ុន្តែមើលទៅឫកពាត្រមាំងដំណើរដូចមិនសមជាអ្នកឰ្យត់ឰ្យាយ, ពួកក្មេងនាំគ្នាមើលងាយគ្នាពេក យើងត្រូវតែជួយសង្គ្រោះគ្នា" ។

យូរបន្តិចមក ស្តេចនាងទមយន្តីមកថ្វាយបង្គំព្រះវរពាជជននី ដែលទ្រង់ធូលដោយបានពិនិត្យឃើញព្រះនាងមានរូបឆ្អែក ហើយទ្រង់មានបន្ទូលសួរថា: "តាមដែលខ្ញុំឃើញអ្នកវេទនាខ្លាំងណាស់ អ្នកដើរហាលថ្ងៃ ហាលភ្លៀង ប៉ុន្តែរូបអ្នកនៅតែល្អទៀត សំរែសរបស់អ្នកចាំងចេញពីកន្ទងសំពត់រហែក ហាក់ដូចជាពន្លឺធ្លុះចេញពីដុំពពក អ្នកអាចធ្វើឰ្យពិលក្លែកយើងបាន ដោយមិនបាច់មានគ្រឿងតែងខ្លួនផង មិនតែប៉ុណ្ណោះ អ្នកមានចិត្តក្លាហានថែមទៀត ពួកក្មេងនាំគ្នាដេរអ្នកៗ នៅតែធ្វើព្រងើយកន្តើយទៀត ចូរអ្នកប្រាប់យើងមើល តើអ្នកជាអ្វី?" ។

ព្រះនាងទមយន្តី ថ្វាយបង្គំព្រះវរពាជជននី ហើយទូលតបថា: "ទូលព្រះសារីយ៍សូមទ្រង់ជ្រាប! ខ្ញុំម្ចាស់ជាកូនអកមានពូជល្អដែរ ប៉ុន្តែកម្មអកុសលតាមមកផ្តល់ខ្ញុំម្ចាស់ បានជាខ្ញុំម្ចាស់ធ្លាក់ក្រលំបាកគោកយ៉ាកទទួលទានតែមើមឈើនឹងផ្លែឈើជាអាហារ ជាយូរថ្ងៃកមហើយ, ខ្ញុំម្ចាស់គ្មានគ្នីគ្នាទេ ពេលយប់មកដល់កន្លែងណា ខ្ញុំម្ចាស់ឈប់ទទួលទាន

ដំណេកនៅកន្លែងនោះ, ក៏ប៉ុន្តែប្តីខ្ញុំម្ចាស់ប្រកបដោយគុណធម៌ល្អណាស់ មានចិត្តស្មោះស្ម័គ្រនឹងខ្ញុំម្ចាស់ណាស់ ឃានជាខ្ញុំម្ចាស់ចេះតែដើរតាមរកហាក់ដូចជាស្រមោច អន្ទោលតាមរូប, វាសនាអាក្រក់ធ្វើឲ្យប្តីខ្ញុំម្ចាស់លេងល្បែងខាល់តែចាញ់អស់ទ្រព្យសម្បត្តិគ្មានសេសសល់, មុនដំបូងយើងខំធ្វើពីរនាក់នាំគ្នាដើរកាត់វាលកាត់ព្រៃ ស្រាប់តែថ្ងៃមួយខ្ញុំម្ចាស់គ្រាកឡើងរកប្តីខ្ញុំម្ចាស់មិនឃើញមិនដឹងជាទៅឯណា ឃានជាខ្ញុំម្ចាស់កើតទុក្ខដល់ម្ល៉េះ" ។

ព្រះវរពជជនន៏ ទ្រង់ទតព្រះនាងដោយមានព្រះទ័យរំជួលអាណិត ហើយមានព្រះបន្ទូលថា: "ល្អើយចុះ នាងឯងកំដើរទៅណាទៀតនៅជាមួយនឹងយើងទៅ ក្រែងលោប្តីនាងដើរកាត់តាមក្រុងនេះ, បើនាងចូលចិត្តនៅ យើងនឹងប្រើព្រាហ្មណ៍ឲ្យទៅរកប្តីនាង។ នៅក្នុងប្រាសាទយើងជាទីសុខចុះ, មនុស្សនៅក្នុងដំណាក់យើងទាំងអស់សុទ្ធតែមានចិត្តភប់អាននាង" ។ ព្រះនាងទមយន្តីនៅស្ងៀមដោយរំជួលចិត្ត ដោយឃើញម្ចាស់ក្សត្រីមានព្រះហឫទ័យសប្បុរសពន់ពេក ព្រះនាងរៀបតែនឹងបើកព្រះឧស្ឋក្រាបទូលព្រះវរពជជនន៏ តាមរឿងវ៉ាត្រង់ពិតទៅហើយប៉ុន្តែសេចក្តីអៀនខ្មាសមកឃាត់ព្រះនាងក្លាម ព្រះនាងទ្រង់ព្រះតម្រិះមួយសន្ទុះ ហើយទូលព្រះមហាក្សត្រីថា: "ព្រះវរពជជនន៏! ការដែលទ្រង់ប្រោសប្រណីខ្ញុំម្ចាស់យ៉ាងនេះ ធ្វើឲ្យខ្ញុំម្ចាស់រសាយទុក្ខ ខ្ញុំ

ម្ចាស់សុខចិត្តទៅតាល់បំរើព្រះមហាក្សត្រី បើសិនជាខ្ញុំមេត្តាព្រម
ព្រៀងនឹងពាក្យដែលខ្ញុំម្ចាស់សូមព្រះរាជទានពរ" ។

ព្រះរាជជននីខ្ញុំតបដោយញញឹមថា: "យើងមានសេចក្តីឆ្ងល់
ណាស់ បើសិនជាពាក្យសុំរបស់នាងគ្មានទំនង" ។ ព្រះនាងទូលថា:
"ទី ១ ខ្ញុំម្ចាស់សូមខ្ញុំកុំទុកខ្ញុំម្ចាស់ជាទាសី, ទី ២ ប្រសណាក៏ដោយ
ដែលមានការចង់និយាយនឹងខ្ញុំម្ចាស់ តាល់តែខ្ញុំម្ចាស់ព្រមទើបនិយាយ
បាន ។ បុរសណាចង់បានខ្ញុំម្ចាស់ជាប្រពន្ធក្តី ជាស្រីកំណាន់ក្តី ខ្ញុំ
ម្ចាស់សូមព្រះរាជានុញ្ញាតធ្វើទណ្ឌកម្មដោយដៃខ្ញុំម្ចាស់ ហើយបើសិនជា
ផ្តាសាយ៉ាងនេះហើយ វានៅតែមករំខានខ្ញុំម្ចាស់ទៀត ខ្ញុំម្ចាស់សូម
អំណាចសម្លាប់ចោល ខ្ញុំម្ចាស់នឹងប្រស្រ័យការជាមួយតែនឹងព្រាហ្មណ៍
បណ្ឌិត ហើយខ្ញុំម្ចាស់នឹងគិតរកឧបាយកលនឹងរកប្តីខ្ញុំម្ចាស់ឲ្យឃើញ,
ចំពោះតែព្រាហ្មណ៍ទេ ដែលខ្ញុំម្ចាស់ច្បាប់ឈ្មោះនឹងច្បាប់ស្រុកកំណើត
ពិតនេះហើយដែលជាសេចក្តីសុំរបស់ខ្ញុំម្ចាស់" ។

- "នាងឯងមានគតិបណ្ឌិតមែន យើងព្រមទទួលពាក្យសុំរបស់
នាង" ហើយទ្រង់ក៏មានបន្ទូលហៅព្រះរាជបុត្រី:

- "សុនន្ទា! (Sunanda) នាងនេះមានអាយុស្មើនឹងនាងដែរ ចូរ
នាងរាប់រកគ្នាដូចជាមិត្តសំឡាញ់ទៅ ហើយចូរនៅឲ្យសុខជាមួយគ្នា" ។

ព្រះនាងទទួលនឹងព្រះនាងសុនន្ទា ក៏ទទួលគ្នាដោយមេត្រីភាព ។

ព្រះបាទនាល: គ្រោយពីបានចេញចាលព្រះនាងទមយន្តីមក ស្តេចយាងកាត់ព្រៃ ទ្រង់យាងទៅបន្ទះព្រៃស៊ុំទ្រមមួយដែលកំពុងតែឆេះភ្លើងយ៉ាងខ្លាំង ព្រះអង្គទ្រង់ឮសូរសំឡេងមួយស្រែកចេញពីក្នុងអណ្តាតភ្លើងមកថា: "នុនាល: អ្នងប្រកបដោយគុណធម៌អើយ! មកជួយខ្ញុំផង!" លុះឮដូច្នោះហើយ ព្រះអង្គក៏ទ្រង់យាងចូលទៅក្នុងគុម្ពោតដោយគ្មានញាញើតនឹងភ្លើងសោះ ទ្រង់ទតឃើញនាគរាជមួយញ៉ាំរន្ធត់នៅកណ្តាលភ្លើង ទ្រង់មានព្រះបន្ទូលថា "កុំភ័យ" ហើយទ្រង់ចាប់ពាក្យនាគនោះចេញពីក្នុងភ្លើងមក ។ នាគនោះកំរើកខ្លួនដោយសេចក្តីត្រេកអរណាស់ ហើយក៏បែរមកវាកស្តេច ទូលថា: "សូមអរព្រះគុណព្រះករុណាជាម្ចាស់ដែលក្សាហានយកព្រះអង្គជួយសង្គ្រោះជីវិតទូលព្រះបង្គំ, ទូលព្រះបង្គំបានទៅរំខានឥសីមួយអង្គដែលកំពុងតែចំរើនឈាន ឥសីនោះក្តៅណាស់ ក៏ដាក់បណ្តាសាឲ្យទូលបង្គំនៅនឹងនឹងតែមួយកន្លែង លុះត្រាតែព្រះបាទនាល:បានមកតាស់ដល់ខ្លួនទូលព្រះបង្គំ ទើបទូលព្រះបង្គំលួនចេញពីទីនេះទៅបាន, ភ្លើងរៀបតែនឹងឆាបដល់ខ្លួនទូលព្រះបង្គំទៅហើយ ទ្រង់ព្រះអង្គយាងមកដល់ ហើយឮពាក្យទូលព្រះបង្គំហៅឲ្យជួយ, ទ្រង់បានជួយជីវិតទូលព្រះបង្គំ។ សូមអរព្រះគុណ" ។

– "ការជួយសង្គ្រោះអ្នកមានទុក្ខនេះ ជាការណីយកិច្ចរបស់ខ្ញុំ" ។

- "ដើម្បីទទឹងបង្ហាញសេចក្តីគតញ្ញូរបស់ខ្ញុំលបង្គំ ។ ទទឹងខ្ញុំលអំពីអនាគតរបស់ព្រះអង្គ" រួចខ្ញុំលថា:

- ខ្ញុំត្រូវនៅសោយទុក្ខទៀត ដូច្នេះខ្ញុំត្រូវលាងបាបឲ្យជ្រះ" ។

- "យី ខ្ញុំបានប្រមាថអាទិទេព ដោយធ្វើកម្មអកុសលអ្វី?" ។

- "ចុះព្រះអង្គខ្ញុំចាំទេ នៅវេលាយប់មួយដែលខ្ញុំគ្រសាលស្បែងបរបាញ់សិង្ហជាមួយនឹងពជបុត្រ, នៅពេលនោះ ខ្ញុំស្តុងកងស្បែងពេក ពាល់តែក្ងេបសូត្រនមស្សការព្រះអាទិទេពតាមទំនៀម" ។

- "មែនហើយ . . . មែនហើយ . . . ខ្ញុំនឹកឃើញហើយ ឥឡូវនេះទើបខ្ញុំដឹងនូវផោគ៣សនាអាក្រក់របស់ខ្ញុំ!" រួចព្រះអង្គខ្ញុំថ្លែងតបទុក។

នាគកំណុំលតទៅទៀតថា "ព្រះករុណាស្តេចកុំអស់សង្ឃឹម, ព្រះអង្គតន់តែបានជួបនឹងព្រះនាងទមយន្តីនឹងព្រះពជបុត្រតាំងពីពុំទាន គេនឹងប្រគល់ព្រះពជអាណាចក្រថ្វាយខ្ញុំវិញ ប៉ុន្តែបាបកម្មរបស់ខ្ញុំពុំទាន់អស់ទេ ដូច្នេះ សូមខ្ញុំយាង ២០ ជំហានទៅចំអូរដែលខ្ញុំទតយល់ទៅខាងមុខនោះទៅ" ។

ព្រះបាទមាល:កំធ្វើតាមបង្គាប់ ។

- "បានហើយ ឥឡូវនេះសូមខ្ញុំដឹកដីត្រង់នេះទៅ" ។

ព្រះបាទមាល:កំធ្វើតាមបង្គាប់ទៀត ។ ខ្ញុំកកាយដីបន្តិចទៅខ្ញុំឃើញអាវក្រហមមួយធ្វើអំពីសំពត់គ្រែម ។ (មានត)

ដំណឹងតាមខ្សែក្នុងកន្លែង

# លោកផេង-ជ្រៃ សាស្ត្រាចារ្យនៅសាលាគរុកិច្ចភ្នំពេញ

## ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

---

ពួកជនជាតិអាប៉ក់ក្នុងប្រទេសអាហ្វ្រិក កាលណាបើគេមានការត្រូវជជែកសូម្បីតិចអ្វីតូចមួយ ជាមួយនឹងពួកសេយ្យសាសន៍ តែងតែសុំតាំងឥតញាញើតយកការទំនុកបំរុងមហាម័តមកវិញ ទោះបីពួកសាសនិករបស់លោកនេះមិនជាទីគាប់ចិត្តដល់គណៈរបស់គេក៏ដោយ ។

ក្នុងសម័យដែលកើតមានរឿងនេះឡើង សាសន៍អ៊ីតាលីបានតាំងយោធាទៅឡើងនាប្រាំងស្រុកចំណុះរបស់សាសន៍ទួរគី ដោយមានបំណងនឹងវាយស្រុកវិញយកិត ជាជាប់ស្រេច ។

តិច្ចទីមួយនៃរដ្ឋកិច្ចាលទួរគី គឺត្រូវប្រមូលជនជាតិអ្នកស្រុកអាយតាំងអស់មកចងចាប់ជាមួយគ្នា ដោយពោលយោសនាថានឹងធ្វើចម្បាំងសាសនាទប់នឹងពួកឧិល ។ ដ្បិតការប្រកាន់ចំពោះសាសនា មានសិទ្ធិដ៏ក្រៃវិក្ខាតាំងនៅជាស្ថាពរក្នុងសន្ធាន នៃពួកប្រជាជនប្រកាន់កោតុលហាមង្គល ។

ការប្រកាន់សាសនា តែងបញ្ជាក់ឲ្យឃើញដល់ភ្នែកជនដទៃ សូម្បីតែក្នុងពិធីបុណ្យរបុំចរបុីក៏ដោយ មិនចាំបាច់ដល់ទៅការធ្វើបុណ្យជាអិក:

ធំក ប្រកបដោយក្បួនដង្កែមាំមួន ដូចជាពិធីខួបរបស់លោកម៉ាហ្គូមេត ឡើយ ។ ហេតុដូច្នេះ ពួកបរិស័ទនាំគ្នាដើរហែពាក់ពពួន បែនបត់ តាមថ្នល់ដ៏ចង្អៀត ពីខាងក្រោយ ពួកលោកសង្ឃដែលតាំដែកគោល ដុតយ៉ាងក្រហម ពាំអំបែងតែវ ទឹងឡាដំរីតាំងរស់ ម្យ៉ាងទៀត ត្រូវ ពិនិត្យមើល តើយ៉ាងដូចម្តេចកម្ចាំងចិត្តដ៏ខ្ជាប់ខ្ជួនហើយគោះជាប់នៅក្នុង ដួងហឫទ័យនៃពួកម៉ាហ្គូមេតង់ ក្នុងកំហឹងសុីសាច់របស់គេ ចំពោះស្នាម ឫមានៃអារ្យធម៌ជាតិកេម៉ាំង ។

លុះការផ្សាយថាមានចម្បាំងសាសនាហើយ នាយកងទ័ពខ្លួនគឺ អាចទីពឹងលើជំនួយជាន៉ាល់នៃប្រជាជនអាប៉ាច់បាន ។ ចំណែកខាងពួក ប្រជាជាតិអាប៉ាច់ខ្លះដែលកាន់សាសនាផ្សេង ក៏ផ្តាំកិច្ចាលនៃម៉ាហ្គូមេត មិនមានសេចក្តីញ៉ាំកញ្ជើកឡើយ ។

ប្រជារាស្ត្រក្នុងស្រុកជ្រាប់ចេះបាញ់កាំភ្លើងដោយត្រឹមត្រូវស្រាប់ ។ រាល់តែវេលាពិធីបុណ្យ គេតែងហៅពួកកងកាំភ្លើងនេះមកជាដំនួយ ឃើញការបាញ់កាំភ្លើងស្ទុះគ្នា, នេះបណ្តាលឲ្យដឹងថាគេប្រើការបាន កាលណាមានអាសន្នកើតឡើង ។

ចំណែកខាងពួកអ្នកចរចរកំពែង គេសម្រេចថាត្រូវឲ្យប្រមូល មនុស្ស ប្រមូលគ្រឿងសព្វាវុធនឹងសត្វពាហនៈ ហើយយកមកឃុំទុកក្នុង ឲ្យទៀងណា នៅក្រោមការជំរឿន ទឹងសេចក្តីខ្មុសត្រូវរបស់លោកតាអ៊ុត ។ នេះជាយោបល់របស់លោកម៉ាហ្គូមេតណាប៊ី-បៃ ជាវរសេនីយ៍ត្រីតួន

នៅប្រចាំក្រុងកាសិ-កោសលៈ ។ លោកមានបង្គាប់ឲ្យដឹកនាំរហូតដល់ជាយក្រុងតូចមួយ ឲ្យពួកចុកចក់ព្រមទាំងអាវុធយុទ្ធភ័ណ្ឌ ទឹងប្រដាប់ប្រដាសព្វសារពើ ដែលពួកនេះនាំគ្នាតាំងជំរំនៅ មានចម្ងាយពីរបីគីឡូម៉ែត្រពីមាត់វាលខ្សាច់ ។

លោកអនុរាសនីយ៍ពោម្នាក់ជាមួយនឹងកងទាហានសេះ បានទៅកាន់ផ្ទះឈ្មោះ ស៊ូអាត្ថ ដែលឃើញមានជំរំចុះនៅទីនោះ, ហ្នឹងហើយគឺជារឿងដំណើរចាប់ដែលនាងនារីឡា ឈរលើខ្នងបាតពីទាងលើទីវាលច្រកភ្នំ ក្រឡេកមកបានប្រទះឃើញ ។

ហេតុដូច្នេះ កាលណាលោកតាម៉ាត្រែកអែលគាឌី បានមកតាំងនៅចំពោះមុខហើយ នាយទាហានក៏ថ្លែងប្រាប់សេចក្តីដូចតទៅនេះ ៖

– "ចម្បាំងសាសនាកើតឡើងរវាងឥស្លាម និងពួកខ្ញុំ, ខ្ញុំបានទទួលបទបញ្ជាត្រូវឲ្យមកកេណ្ឌមនុស្ស សត្វពាហនៈព្រមទាំងនាំលោកតាយកទៅរហូតដល់ក្រុងកាសិ-កោសលៈ" ។

លោកតាម៉ាត្រែកយល់ថា រឿងនេះប្រហែលជាមូលហេតុនៃសេចក្តីវិនាសដ៏ពិតប្រាកដដល់កុលសម្ពន្ធរបស់គាត់ ។ គាត់ខំនិយាយការពារនិយាយជំទាស់ហើយនឹងខំល្បួងអធិប្បាយអំពីរឿងផ្សេងៗ ដើម្បីធ្វើឲ្យប្រែសិតគួគ្រាន់ស្តាប់បាន ។ គឺខណៈនោះហើយដែលនាយទាហានបញ្ចេញក្រិត្យមួយច្បាប់ធ្វើពាំងពីរកាសៈ ទូតនឹងគាត់ . នៃព្រះចៅសុលតង់ហុចឲ្យគាត់មើល ។ ក្នុងក្រិត្យនោះមានសញ្ញាព្រះនាមព្រះ

ទៅខ្លួនឯង នឹងឈ្មោះលោកកាអ៊ីត ហើយមានជាក់សេចក្តីខាងចុងថា: បើវែងឆ្ងាយតែត្រូវប្រើអាជ្ញា ។

ក្នុងកាលនោះ លោកតាម៉ាត្រុកត្រូវតែស៊ូអត់ធ្មត់ត្រង់ទទួលជោគវាសនាអាក្រក់ដែលធ្លាក់មកលើ ។ គាត់មានវាចាថា: សូមសេចក្តីស្តុតនៃព្រះអង្គស់សម្រេចចុះ ។ រួចគាត់បែរមុខចំពោះទៅពួកចិត្តស្មគ្រ័របស់គាត់ ដែលមានកាំភ្លើងកាន់ត្រៀមចាំជាស្រេច ហើយបង្គាប់ទាំងមុខស្រងូតថា: ចូរជាក់អាវុធចុះ ការប្រយុទ្ធមិនស្មើកម្លាំងគ្នា ប្រតិបត្តិការមានប្រយោជន៍អ្វីបើឃើញចាញ់ដៃគេមុនរួចទៅហើយ ប៉ុយ៉ាងដូច្នេះមិនត្រូវយកឈាមរបស់មនុស្សដែលទៅក្នុងអាណាព្យាបាល ហើយមានសេចក្តីខុសចិត្តលើខ្លួនដូចជាអាពុក ទៅក្រាលលើផែនដីដូនជីតាឡើយ ។

ពួកចោរ ក៏នាំគ្នាបត់សំពត់ជំទាំងស្រងូតស្រងាត់ ។ គេនាំគ្នាគោរពទូវចិត្តស្មគ្រ័របស់នាយទៅហ្ងាយ ។

កាលណាវត្ថុភ័ស្តុភារសព្វគ្រប់គេប្រុងប្រៀបស្រេចហើយ។ រមិលទៅខែក្នែងទៅតែជិរលើងណឹល គេតាំងឈរតម្រៀបគ្នាជាបៃបក្សនដំណើរយ៉ាងល្អដោយស្ងៀមស្ងាត់ មានលោកតាម៉ាត្រុកទៅជាខាងក្រោយបន្ទាប់មកតីពួកចាហានសេះ គេធ្វើដំណើរសំដៅទីក្រុង ។

នាងក្រមុំ ឡីឡា តាមក្រឡេកមើលពួកអ្នកដំណើរហួតផុតកន្លុយភ្នែកដោយពន្លឺរស្មីនៃព្រះសូរ្យសាយណ្ហ៍ ។ (មានត)

# រឿងបល្ល័ង្កធិត្យ សាមសិបតីរឿង

រឿងព្រេងនិទាន

## លោកសមិន ម្ចាស់ជីវៈ តែង

## លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

---

### អារម្ភកថា

រឿងបល្ល័ង្កធិត្យ សាមសិបតីរឿងនេះ គឺពណ៌នាអំពីព្រះមហាក្សត្រិយ៍វិក្រមធិត្យ ។ ព្រះមហាក្សត្រិយ៍អង្គនេះ មានព្រះកិត្តិនាមល្បីល្បាញក្នុងប្រវត្តិសាស្ត្រឥណ្ឌៀ; ក្នុងវដ្តកាលព្រះអង្គ ជាសម័យដែលវប្បធម៌ឥណ្ឌៀឡើងកាន់វឌ្ឍនធម៌ពេញបរិបូណ៌ ដោយមានបណ្ឌិតជាច្រើនបានចូលទៅសន្និបាតក្នុងព្រះបរមរាជវាំង ។

សម័យព្រះបាទវិក្រមធិត្យនៃប្រទេសឥណ្ឌៀ បើប្រៀបធៀបនឹងប្រទេសក្រិក គឺ សម័យប៉េរិក្លេស, ប្រទេសរ៉ូម៉ាំង សម័យអូគុស្ត, ប្រទេសអ៊ីតាលី សម័យមហាកវីឌ្យេអុងទីដប់, ប្រទេសបារាំង គឺសម័យមហាកវីល្បីទីដប់បួន ។

ប៉ុន្តែពិតមែនតែព្រះបាទវិក្រមធិត្យ ជាមហាក្សត្រមានព្រះកិត្តិនាមល្បីល្បាញ, តែប្រវត្តិសាស្ត្រសាកលមិនបានទទួលស្គាល់ព្រះអង្គសោះឡើយ ព្រោះន័យខាងប្រវត្តិសាស្ត្រពួកជនជាតិឥណ្ឌៀមិនសូវពេញចិត្តនឹងផ្សាយ ឬមិនសូវស្គាល់ទូលំទូលាយ បានជាទៅរចនារឿងព្រេង

មួយឲ្យឈ្មោះថា "បល្ល័ង្កទិព្យ សាមសិបពីររឿង" ដើម្បីនឹងផ្សាយទូ
កិត្តិយសនៃព្រះបាទវិក្រមទិត្យ ។ ឯព្រះពុទ្ធបរិយាធិរាសនៃព្រះអង្គ.
បណ្ឌិតឥណ្ឌូបានយកទៅផ្សាយក្នុងរឿងនេះ ត្រមាំងរឿងរៀបរាល:
ឬ "អាក្សរថ្មែងរឿងមែកច្រាំ" ដែលបានចុះផ្សាយក្នុងទស្សនាវដ្តី
"កម្ពុជសុរិយា" ឆ្នាំ ១៩៥២; បើលោក អ្នកបង់ជ្រាបរឿងនេះ សូម
អញ្ជើញទៅជាវឯពុទ្ធសាសនបណ្ឌិត្យមកអានចុះ ។

តែរឿងបល្ល័ង្កទិព្យសាមសិបពីររឿងនេះ (បើតាមភាសាសំស្ក្រឹត
សិង្ហាសន., ទ្វាត្រឹម្សតិ, Sinhâsana-dvatrimçati) ជារឿងពណ៌នា
ចំពោះព្រះបាទវិក្រមទិត្យតែមួយព្រះអង្គ ។ អ្នកនិពន្ធបាននិពន្ធដើមដំបូង
ជាភាសាសំស្ក្រឹត, តមកបានបណ្ឌិត សុន្ទរ (Sundar) ប្រែមកជា
គ្រាមភាសា (diale cte) ព្រជ-ភាខា (Bbraj-bhâkhâ) ដោយមានព្រះពុទ្ធ-
បញ្ជាពីព្រះមហាក្សត្រិយ៍ សាហ៍-ជិហាន (Shah-Jehân) រួចលោកលល្លូ.
(Lallu) បានប្រែមកជាភាសា ហិណ្ឌូស្ថានី-អ៊ូរឌូ ។ តែសៀវភៅនេះ
គឺលោកឡេអ៊ុងហ្វែរ (Léon Fer) បានបកចេញពីសៀវភៅលោកសមិន
ម្ហ្ស៊ាន់ជម: (Çarmen Mrityanjama) មានឈ្មោះថា: "ពត្រីស-ប៊ុតាលិកា
សិង្ហាសន, (Batris putalika Sinhâsan) ដែលចោះពុម្ពនៅទីក្រុងឡុង
ត ស. ១៨១៥ ។

ខ្ញុំបានអានរឿងនេះឃើញថា មានសារ:ប្រយោជន៍ បានជាខ្ញុំខំ
ព្យាយាមបកប្រែមកជាភាសាខ្មែរសម្រាប់ឲ្យជនជាតិយើងអាន, ពិតណា

ដើម្បីឲ្យកើតសតិជ្រាជ្ញឡើង ។ ឯវត្ថុបំណងរបស់ខ្ញុំនេះ គឺ មាន
ជ្រាជ្ញាដើម្បីនឹងឲ្យជនជាតិខ្មែរ ដែលជាបងប្អូនរួមឈាមជាមួយមាន
ចំណេះវិជ្ជាគ្រប់ៗគ្នាឡើង ព្រោះថា:

"មុននឹងរបាជាតិ ឬ មាតុភូមិ ត្រូវរបាមនុស្សសិន,
កាលរបាមនុស្សបានហើយ, ជាតិឬមាតុភូមិក៏ងាយនឹងរបា
ឲ្យទៅកាន់វិឌ្ឍនធម៌" ។

ព្រោះហេតុដូចនេះ, ខ្ញុំសូមទទួលសេចក្តីសុសលដែលកើតឡើង
ដោយសេចក្តីព្យាយាមនេះ ជូនទៅមាតុភូមិគឺប្រទេសកម្ពុជា, សូមឲ្យ
បានធូរធ្លាសុខក្សេមក្សាន្តរៀងដល់ស្ថានបរមសុខ, ត្រមាំង ឧបាសិកា ជ្រឹ
ជាមាតារបស់ខ្ញុំ សូមឲ្យបានប្រកបដោយអាយុ វណ្ណ: សុខ: ពល:
តរៀងហោង ។

ភ្នំពេញនៅថ្ងៃទី ៣ កញ្ញា ឆ្នាំ ១៩៨៤

ភ័យ - ប៊ុក

# សេចក្តីសង្ខេបក្នុងរឿងបល្ល័ង្កទិព្យ

មហាពជរាគ្រមទិព្យ ជាព្រះមហាក្សត្រិយ៍មួយអង្គមានព្រះពជាឧត្តាពលើសស្តេចទាំងអស់ ដោយព្រះអង្គមានព្រះប្រាជ្ញាមោះមុតអាចយល់ជាក់ច្បាស់នូវវត្ថុដែលមានអត្ថដ៏សុខុមភាព នឹងវត្តមានមនុស្សជាតិ។ ទ្រង់បានទទួលព្រះពជអំណោយពីសក្កទេវរាជនូវបល្ល័ង្កទិព្យមួយ មានរចនារូបទេពនិម្មិតសាមសិបពីរអង្គ ដែលមានតែទ្រង់មួយអាចគង់បាន។ លុះព្រះមហាក្សត្រិយ៍អង្គនេះ សោយព្រះទិវង្គតទៅ បានយាងទៅសោយផលជាទិព្វឯស្ថានសួគ៌។ ព្រះបល្ល័ង្កទិព្យនោះមិនមានព្រះមហាក្សត្រិយ៍អង្គណាមានតេជានុភាពអាចគង់លើបាន។ ព្រះបល្ល័ង្កទិព្យនេះក៏ត្រូវគេយកទៅតម់កន្លែងដដែ។ ដល់ថ្ងៃក្រោយមក, មានព្រះមហាក្សត្រិយ៍ទ្រង់ព្រះនាម កោជៈ បានសោយរាជសម្បត្តិ ទ្រង់បានរកឃើញនូវព្រះបល្ល័ង្កទិព្យនោះ។ បានជាមានពណ៌នារឿងរ៉ាវដូចតទៅនេះ។

(មានត)

# ពិធីបុណ្យឆ្លងសាលាចាស់វត្ត

## វត្តព្រះព្រហ្មវត្ត ខេត្តសៀមរាប

## លោកគ្រូបាសាទរដ្ឋអ្នគុណ កែ-អឿន (រ៉ឺយប្បញ្ញោ)

### រៀបរៀង

---

*តាលពីថ្ងៃ ៨-១០-១១ កើតខែជេស្ឋ ឆ្នាំមមីឆស័ក ព. ស. ២៤៨៧ គឺថ្ងៃទី ៨-១០-១១ ខែមិថុនា គ. ស. ១៩៥៤ នៅវត្តព្រះព្រហ្មវត្ត ខេត្តសៀមរៀប មានធ្វើពិធីបុណ្យដុំវង់ភេចន៍គឺ បុណ្យឆ្លងសាលាបាលីរង និង បុណ្យប្រញុះអដ្ឋិធាតុទ្វិង-ប៊ូគី ។ ពិធីបុណ្យនេះមានការគាក់តែងវិចិត្រវចនាដ៏ឧឡារិកអធិកមហិមា; ក្នុងទីវត្តចាំងមួលគេសំអាតគ្រប់កន្លែងដូចមានវិធានការចាត់ចែងតទៅនេះ ៖*

### ខាងក្នុងសាលាបាលី

*សាលាបាលីនេះមានរៀបចំជារបៀបដ៏ស្អាត, គ្រងំបន្ទប់កណ្តាលមានថូបស្ថានមួយធ្វើពីថ្មើមថ្មសម្រាប់បញ្ចុះអដ្ឋិធាតុ បណ្តោយជាង ១ ម៉ែត្រ ទទឹង ១ ម៉ែត្រ កំពស់ជាង ១ ម៉ែត្រ ។ នៅជញ្ជាំងសាលាខាងលើងថូបស្ថាននោះ ជាមួលព្រះពុទ្ធរូបកញ្ចក់ធំ ១ ព្រះអង្គ ខាងមុខរៀបតុជាថ្នាក់ៗ ជាក់គ្រឿងសក្ការបូជា; ខាងលើថូបស្ថាននោះក៏រៀបគ្រឿងសក្ការបូជាដែរ, នៅជញ្ជាំងដុំវិញជាក់អំពូលភ្លើងតូចៗ មានពណ៌គ្រប់បែប ។*

# យ៉ាសាលាបាលី

នៅយ៉ាសាលានេះ គ្រែធំកណ្តាលមានបុស្បក ១ កំពស់ ៣ ម៉ែត្រ ទំហំដុំវិញជាង ១ ម៉ែត្រ ៤ ជ្រុង ។ ក្នុងបុស្បកនោះគេជប្តូរគ្រែធម្មាសនៈសម្រាប់ធម្មកថិកសំដែងធម៌, សសរបុស្បកទាំង ៤ មានអំពូលភ្លើងតូចៗ, ខាងក្រៅដុំវិញសសរ ព័ន្ធព័ទ្ធសំពត់ប៉ាក់គ្រឹប, ខាងមុខបុស្បករៀបតុងាំឲ្យធំជាថ្នាក់ៗ ជាក់គ្រឿងសក្ការបូជា, នៅកណ្តាលយ៉ា មានចងសំពត់ប៉ាក់គ្រឹបសំយុងចុះមកទាំង ៤ ជ្រុង មានសណ្ឋានដូចជាមេរុ; ខាងលើបណ្តាយទៅ ចងធ្វើជាតិចធ្វើសាសនាខ្សែវែងប្រាក់ខ្លាត់ខ្លែង; នៅជម្បូលសាលាខាងមុខ ជាក់អំពូលភ្លើងធំ - តូច គ្រប់ពណ៌ចម្រុះគ្នាជាង ១ ០០០ អំពូល ។

## ខាងមុខសាលាបាលី

ខាងមុខសាលាមានធ្វើកេងពីរ ប្រក់សំពត់រៃសំយុងចុះមកដុំវិញដោយសំពត់ជាតិ ទឹងក្រមងស្វាយដែលក្រម, នៅសសរនីមួយៗ សុទ្ធតែស្រោបដោយស្វាយទាំង មានអំពូលភ្លើងធំៗ, ខាងក្នុងកេងរៀបតុគៅអីជាច្រើន, នៅជម្បូលកេងទាំងពីរនោះ ចងធ្វើជាតិចធ្វើសាសនាមានជង្គង់ធំៗ ។ កេងទាំងពីរនេះសម្រាប់ទទួលឥស្សរជនដែលអញ្ជើញទៅអនុមោទនាបុណ្យ ។ ខាងមុខបន្ទាប់អំពីកេងទាំងពីរនោះមក មានធ្វើកេងធំមួយទៀតប្រក់ស្វាយ សំយាបដុំវិញមានរៃសំពត់ សណ្ឋានជាចង់

ជាតិ, ខាងកើតពេងនេះមានចង្កេះជាតិ-សាសនាវែងៗ នឹងអំពូលក្តើងធំៗជាច្រើន, ពេងនេះសម្រាប់ទទួលពុទ្ធបរិស័ទជាគ្រហស្ថ ។

## សៅសាលាធម្មសភា

សាលាធម្មសភា ក៏មានការរៀបចំដោយគ្រឿងសក្ការបូជាជាច្រើនណាស់ដែរ, សាលានេះសម្រាប់ប្រគេនកេសជ្ជៈនឹងអង្គាសកគ្គហារដល់ព្រះសង្ឃ ។

## កម្មពិធី

ប្រៀទី ១.— គឺថ្ងៃទី ៩ ខែមិថុនា ព.ស. ២៤៩៧ គ.ស. ១៩៥៤ ម៉ោង ១០ រសៀល ជង្គែអដ្ឋធាតុចាកគេហស្ថាន (ផ្សារសៀមរាប) ទៅដម្កល់ទុកលើថូបស្ថានកងសាលាចាលីថ្មី និមន្តព្រះសង្ឃសត្តប្បការណាកិធម្ម (បង្សុកូល); ម៉ោង ២០ ជួបជុំពុទ្ធបរិស័ទនមស្សការព្រះរតនត្រ័យ និមន្តព្រះសង្ឃចំរើនព្រះពុទ្ធមន្ត រួចនិមន្តព្រះអាចារ្យកែវ-អ៊ីវសំដែងធម៌, លុះទេសនាចប់ហើយ មានបញ្ចាំងរូបភាពយន្ត នឹងលេងល្ខោនខ្មែរ ។

ប្រៀទី ២.— គឺថ្ងៃទី ១០ ខែ-ឆ្នាំជវដែល ម៉ោង ៨ ព្រឹក បញ្ចុះអដ្ឋធាតុក្រោមថូបស្ថានកងសាលាចាលីនោះ, និមន្តព្រះសង្ឃសត្តប្បការណាកិធម្ម; ម៉ោង ១១ ថ្វាយចង្ហាន់ដល់ព្រះសង្ឃ; ម៉ោង ២០ ចំរើនព្រះពុទ្ធមន្ត រួចនិមន្តព្រះតេជព្រះគុណព្រះធម្មាចារ្យសួរ-ហាយ វត្តឧណ្ណាលោម ក្រុងកំពង់ស្ពឺ សំដែងធម៌, លុះទេសនាចប់ហើយ បញ្ចាំងរូបភាពយន្តនឹងលេងល្ខោន ។

ថ្ងៃទី ៣.— តាំងថ្ងៃទី ១១ ខែធ្នូ ជាដែល មោង ១០ ព្រឹក ជួបជុំព្រះសង្ឃនិងគ្រហស្ថនៅសាលាចាលី, ឧ.-ប៊ូសាយ សូត្រសុន្ទរកថាដូចមានសេចក្តីតទៅនេះ ៖

ព្រះថេរានុត្ថេរៈ គ្រប់អង្គ! អស់លោក-អ្នកសប្បុរសអ្នកចាំឆ្លាយ! ខ្ញុំព្រះករុណា, យើងខ្ញុំចាំឆ្លាយ គឺលោកមាតាមប្រម, ឧ.-ប៊ូសាយ នាងកាត់ប៊ូ ជាភរិយា, អ៊ុយតាំង-កួយ នាងឧ.-ព្រួនជាភរិយា, ឧ.-ប៊ូគុណ, តាន់គិម-វ៉ុន នាងឧ.-លួមជាភរិយា, ឧ.-ប៊ូកា, នាងឧ.-ឆុយហួយ សូមពណ៌នាអំពីបុព្វហេតុនៃការកសាងសាលាចាលីនេះ ដូចតទៅនេះ ៖

ដើមដំបូងខ្ញុំព្រះករុណា យើងខ្ញុំចាំងអស់គ្នា មានបសាទសទ្ធាជ្រះថ្លាប្រកបដោយភត្តាភតវេទិតាធម៌ចំពោះលោកឧ.-ប៊ូគី ជាបិតា ដែលមរណភាពទៅជាយូរឆ្នាំហើយ, យើងខ្ញុំបានគិតគ្នាទំនងធ្វើបូជនីយស្ថានដំកល់អដ្ឋិធាតុរបស់លោក តាមប្រពៃណីអំពីបុរាណ ទុកជាទីសក្ការបូជាដល់គុណឧបការៈរបស់លោក, តែលោកមាតាមប្រម បានពន្យល់ថា: "ការកសាងវត្តនោះ មានប្រយោជន៍ដែរហើយ តែមិនបានជាប្រយោជន៍ខ្លួនទៅ, ជួនថ្មីត្រូវកសាងសាលាចាលីវិញ ៖ ព្រោះសាលាចាលីជាសិរសីនៃព្រះពុទ្ធសាសនា ឬជាបេះដូងជាទីរងឥតអាយុព្រះពុទ្ធសាសនា អាចបណ្តុះធម្មវិជ្ជានៃសិក្ខាកាមកុលបុត្តីកនៃព្រះពុទ្ធសាសនា អប់រំព្រះសង្ឃ

ដែលនៅក្នុងមុខវិជ្ជាភាព ឲ្យឡើងទៅកាន់បណ្ឌិតភាព រចនាឲ្យមានចំណេះវិជ្ជា ឲ្យមានពន្ធឹកូស្វាង ដើម្បីឲ្យការសាងនឹងអក្សរជាតិខ្មែរវិវត្តន៍ទៅកាន់វឌ្ឍនធម៌, ឬអាចនឹងបណ្តុះវិជ្ជានានាទៀតក៏ចេះតែបាន ។ ម្យ៉ាងទៀត អ្នកដែលកសាងសាលាសម្រាប់សិក្សាទុកដូចជាដើមវិញ្ញា, ព្រះសង្ឃដែលបានចូលសិក្សាទុកដូចជាបុប្ផាគឺផ្កាដែលមានក្លិនក្រអូប, ឧបាសក - ឧបាសិកា ដែលជួយឧបត្ថម្ភការសិក្សាទុកដូចជាឃ្មុំឬកន្ធឹដែលជញ្ជក់នូវលំអងបុប្ផាទាំងនោះ មកធ្វើជាសំបុក គឺចំណេះវិជ្ជាគ្រប់គ្នា" ។ កាលមាតាយើងខ្ញុំពន្យល់យ៉ាងនេះ យើងខ្ញុំក៏ព្រមតាមយោបល់លោក ។

និមិត្តតែវត្តបំណងនេះកើតឡើងហើយ ក៏បានចាប់ផ្តើមកសាងសាលាបារីនេះ ពីឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ គ.ស. ១៩៥៣ ។ សាលាបារីនេះចែកជា ៣ ភាគ គឺភាគ ២ សម្រាប់ព្រះសង្ឃរៀនសូត្រ, ភាគមួយត្រង់កណ្តាលសាងជាថូបស្ថាន សម្រាប់បញ្ចុះអដ្ឋិធាតុលោកឧបាសិកាជាបិតា ឧបាសិកាវិយោល័យ សម្រាប់ចាត់ការព្រះពុទ្ធសាសនា ។ ឥឡូវនេះសាលាបារីនេះ បានសាងរួចស្រេចដូចបំណងហើយ ។ ពេលនេះយើងខ្ញុំបានធ្វើបុណ្យទូន ព្រមទាំងធ្វើបុណ្យទក្ខិណានុប្បទានបញ្ចុះអដ្ឋិធាតុក្នុងសាលានេះ, ក្នុងពេលបន្ទាប់ពីនេះទៅ យើងខ្ញុំនឹងវេរសាលាបារីនេះជូនព្រះសង្ឃទុកជាពុទ្ធសាសនសម្បត្តិតទៅ ។ សូមលោក-អ្នកទាំងឡាយ ជួយអនុមោទនា វេរជាមួយនឹងយើងខ្ញុំ ។

ដោយអានុភាពនៃកុសលកម្មដ៏ប្រសើរក្នុងពេលនេះ យើងខ្ញុំជាកូនចៅនឹងបុត្រធីតាទាំងអស់គ្នា សូមទទួលផលដូចដល់ដួងវិញ្ញាណនៃលោកតួន-ប៊ូតី ជាស្វាមីនឹងជាបិតា សូមឲ្យលោកបែកគ្រាមកទទួលអនុមោទនាយកចំណែកនៃបុញ្ញកម្ម ដែលយើងខ្ញុំបានធ្វើហើយ បញ្ជូនទៅឲ្យក្នុងពេលនេះ ដោយសុវត្ថិភាព! ។

ខ្ញុំបាទ- យើងខ្ញុំ សូមថ្វាយសេចក្តីសោមនស្សដ៏ខ្ពង់ខ្ពស់ ចំពោះអស់លោក - អ្នកសប្បុរសទាំងឡាយ ដែលអញ្ជើញមកទទួលភ្ញៀវកិត្តិយសក្នុងបុញ្ញពិធីដ៏ឧត្តមនេះ មានឯកឧត្តមអតីតរាជទូតប្រទេសថៃ នាមឈុំ នឹងលោកស្រីដែលបានត្រៀតអញ្ជើញមក ជាអធិបតីនៃបុណ្យនេះជាប្រធាន សូមឲ្យបានចំណែកបុណ្យស្មើៗគ្នា! នឹងសូមឲ្យសម្រេចឥដ្ឋផលគ្រប់ប្រការ តាមសេចក្តីប្រាថ្នារបស់លោក-អ្នក! មួយទៀតសូមឲ្យបានសម្រេចសម្បត្តិ ៣ ប្រការ គឺ សម្បត្តិក្នុងបច្ចុប្បន្ន ១ សម្បត្តិក្នុងបរលោក ១ សម្បត្តិដ៏ពិសិដ្ឋបំផុតគឺព្រះនិព្វាន ១ កុំបីឃ្លៀងឃ្លាតឡើយ! ។

លុះចប់សុន្ទរកថាហើយ ឧបាសកឡែម-រឿន ជាដំណាងអាចារ្យវត្ត បានផ្តើមវេរសាលាបាលីវង់ដល់ព្រះសង្ឃ ដោយបាលីថា:

--មយំ ភន្តេ តិមំ ឧបាលិសិក្ខាការំ --សង្ឃស្ស និយ្យាទេម; សាធុ ភន្តេ សង្ឃោ តិមំ ឧបាលិសិក្ខាការំ

បដិគ្គណ្ហាតុ មាតាបិតាទីនំ គុណាវុឌ្ឍានញ្ចេវ[1] អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ; តតិយម្បិ ។

"បតិត្តព្រះសង្ឃដ៏ចំរើន យើងខ្ញុំតាំងឡាយសូមវេរចាយ នូវសាលាចាលីវង់នេះ ដល់ព្រះសង្ឃ; បតិត្តព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកសាលាចាលីវង់នេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់លោក-អ្នកដ៏មានគុណតាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំតាំងឡាយផង អស់កាលជាអង្វែងតៅហោង ។ អស់ភវៈពីរជង់ផង; អស់ភវៈបីជង់ផង" ។

ចប់វេរហើយ ព្រះសង្ឃទទួល "សាធុ" គ្រប់អង្គ រួចសូត្រអនុមោទនា; ពុទ្ធបរិស័ទសូត្រផ្សាយបត្តិទានគាថា, ទន-ប៉ុ"សាយយក ទឹកស្នោទកដ្ឋចជាក់លើព្រហស្តព្រះវេរ ៣ រូបគឺព្រះមេគណ-អនុគណ-ចៅអធិការ, បន្ទាប់មក ព្រះគ្រូអនុគណ កែ-អឿន ថ្លែងចាប់កថា ទទួលអំណរសាមីទាន, រួចពុទ្ធបរិស័ទជាក់ចាត្រធ្វើបុណ្យ, មោង ១៩, ៣០ ទេសនាសង្គាយនា ។ ចប់ហើយ បញ្ចាំងរូបភាពយន្តនឹងលេងល្ខោនជាសម្រែចកិច្ចបុណ្យតែប៉ុណ្ណោះ ។


ចប់

---

១ របៀបចាលី បើប្រើ ច-សព្ទ ពីរឡើងទៅ, ច-សព្ទខាងដើម ត្រូវប្រែកច ឯរ-សព្ទ ។

# ព្រះពុទ្ធសាសនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ២៦ ខែវិច្ឆិកា លេខ ១១

ព.ស. ២៤៩៧ — គ.ស. ១៩៥៤



# ពន្លឺសង្ឃឹម

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — សាមគ្គីកថា | ព្រះមហា ឈឹម - មី | ៨០៣ |
| — បញ្ញាសជាតក ភាគទី ២ (តទៅ) | បណ្ឌិតមហា ឈឹម - ស៊ុម | ៨១២ |
| — រឿងសុនក្ខត្តលិច្ឆវិបុត្ត | ឃុនបណ្ណានុរ័ក្ស ប៊ូ - ប៊ូ | ៨២១ |
| ផ្នែកអក្សរសាស្ត្រ | | |
| — រឿងសាមកុក (តទៅ) | ឧកញ៉ា នូ - កន | ៨៣០ |
| — ថាលៈនំងទមយន្តី (តទៅ) | អ្នកស្រី ស្រ៊ីន - សារីយ៉ាន់ | ៨៣៦ |
| — ដំណឹងតាមឡស់ក្នុងកន្ត្រោះ (តទៅ) | លោក ដេង - ដ្រីវ | ៨៤៧ |
| — រឿងបល្ល័ង្កទិព្យ (តទៅ) | លោកវ៉ាយ - ប៊ុក | ៨៤៩ |
| — សាមគ្គីភាពនៃក្រុមដំនុំទំនៀមទម្លាប់ខ្មែរការ ស្តាបនាត្រឹ ស្តា | លោកស្រី - អ៊ូ | ៨៥៣ |
| កំណាត់នឹងប្រវត្តិសាស្ត្រ | | |
| — ដំ ណឹងរឿងមន្តទៅកាន់ប្រទេសភូមា | ព្រះទេពសត្ថា កឹម - ឆួរ | ៨៦៦ |



មួយឆ្នាំមាន ៤២ សៀវភៅ — ដំឡៃដាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## *TABLE DES MATIÈRES*


| | | Page |
|---|---|---|
| **PARTIE RELIGIEUSE:** | | |
| — Samaggikatha . . . . . | *Brah Maha* CHHIM-MY . . . . | 803 |
| — Pannasajataka- vol. 2 (suite) . | M. CHHIM-SOUM . . . . . | 812 |
| — Sunakkhattalicchaviputta . . . | M. BOU-PO . . . . . | 821 |
| **PARTIE LITTERAIRE:** | | |
| — Histoire de Samkok (suite) . . | *Oknha* NOU-KAN . . . . . | 830 |
| — Nala et Damayanti (suite) . . | *Mme* SRIN-SARIS-YANN . . . | 836 |
| — Le souffle du désert (suite) . . | M. PHENG-CHRIV . . . . . | 840 |
| — Les trente deux récits du TRONE (suite) . . . . . | M. RAY - BUC . . . . . | 846 |
| — Activité de la Commission des Moeurs et Coutumes : (La construction des maisons ) . . . . . | M. SREY-OU . . . . . | 853 |
| **NOTES ET CHRONIQUES:** | | |
| — Le voyage en Birmanie . . . . . | *Brah Debasatha* KEM-TO. | 866 |


Prix d'abonnement annuel (comprenant 12 numéros) 200$00

# សាមគ្គីកថា

## មហា ឈឹម-មី សិស្សសាលាបាលីជាន់ខ្ពស់

*វត្តសាកវ័នតេជោ*

*សង្កាត់លេខ ៣ កំពេញ*

រៀបរៀង

---

ឥមោ តស្សូ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្សការ ចំពោះព្រះភគវន្តមុនីអរហំសម្មាសម្ពុទ្ធព្រះអង្គនោះ (ព្រមទាំងព្រះធម៌ នឹង ព្រះអរិយសង្ឃដោយសេចក្តីគោរព) ។*

*វេលានេះ អាត្មាភាពសូមសំដែងអំពីដើមកំណើតនៃសន្តិសុខក្នុងលោក ជាសង្ខេប តាមកាលវេលា ដូចមានសេចក្តីតទៅនេះ ៖*

សុខា សង្ឃស្ស សាមគ្គី សេចក្តីព្រមព្រៀងគ្នារវាងពួកក្រុម ជាហេតុនាំឲ្យកើតសន្តិសុខក្នុងលោក ។

ព្រះពុទ្ធភាសិតនេះ មានសេចក្តីដែលគួរលើកមកអធិប្បាយ ៣ បទ គឺ សាមគ្គី ១ បទ, សង្ឃ ១ បទ នឹង សុខ: ១ បទ ។

សាមគ្គី ប្រែថា “សេចក្តីព្រមព្រៀងគ្នា, ជំណើរស្រុះស្រួលមូលមិត្តនឹងគ្នា, រួបរួមគ្នា, ចងចាប់គ្នា ពួតដៃគ្នា, វៀរគំនិតចួលគ្នា, មានចិត្តស្មើគ្នា, មានអធ្យាស្រ័យគ្នាវាគ្នា, ទុកចិត្តគ្នា, មិនបែកចិត្តពីគ្នា, មានចិត្តស្មោះស្ម័គ្រគេកគ្នា, មានការណីយកិច្ចគ្នាវាគ្នា, ប្តុះចិត្ត

សិប់ដូចគ្នា, ចុះសំរុងគ្នា, មានមេត្រីចិត្តរលាយចូលគ្នាដូចជាទឹកនឹងទឹក, ឥតខាស់ខែងវែងគំនិតគ្នា, មិនប្រកួតប្រកាន់គ្នា, មិនចង់តំទុំគ្នា" ។

សង្ឃ ប្រែថា "ពួក, ក្រុម, ប្រជុំ, ហ្វូង, បន, គណៈ, កាយ, សង្គម ឬ បរិស័ទ" ។ តែបើតាមព្រះវិន័យវិញ លោកសំដៅយកតិចតួចតាំងពី ៤ រូបឡើងទៅ ហៅថា សង្ឃ ។

សុខៈ ប្រែថា "សេចក្តីសប្បាយរីករាយ, ធម្មជាតទេសោះតែជារបស់គួរប្រាថ្នា-គួរស្រឡាញ់, ដំណើរស្រួល, ស្រណុក, មិនវឹកវរ, មិនជ្រួលច្របល់, មិនត្រូវលំបាកកាយ, មិនរកាំចិត្ត, មិនក្តៅក្រហាយ, មិនស្អាយក្រោយ ជាដើម គឺសេចក្តីសម្បាន្តយ៉ាងស្រួល ។ តែក្នុងទីនេះ សំដៅយក សន្តិសុខ គឺសេចក្តីសុខសូប ឬ សន្តិភាព ដែលជាទីប្រាថ្នារបស់លោកទាំងមូល ។

កាលបើរួបរួមសេចក្តីប្រែនៃព្រះពុទ្ធភាសិតទាំង ៣ បទនេះ ចងឲ្យទៅជាប្រយោគមួយទៅ សឹងឃើញច្បាស់ថា សន្តិសុខដែលជាទីស្រឡាញ់ពេញចិត្តរបស់លោកទាំងមូល ទឹងតើតឡើងយ៉ាងងាយ មិនចាំបាច់និច្ឆ័យរកឆ្ងាយឆ្ងែកអំពី ៣ មគ្គីនេះឡើយ ។

សាមគ្គីនេះ ចែកចេញជា ៣ យ៉ាងគឺ :

កាយសាមគ្គី សេចក្តីស្រុះស្រួលព្រមព្រៀងគ្នាដោយកាយ ១

វចីសាមគ្គី សេចក្តីស្រុះស្រួលមូលមាត់គ្នាដោយពាក្យសំដី ១

បិត្តសាមគ្គី ឬ មនោសាមគ្គី សេចក្តីព្រមព្រៀងស្រុះស្រួលមូលគំនិតគ្នាខាងផ្លូវចិត្ត ១ ។

ការស្រុះស្រួលរួមរ៉ែក្បែរបក់រកគ្នាទៅវិញទៅមកវាងពួកគណៈ ឬសង្គម រហូតដល់លោកជាទីបំផុត មិនប្រែធាបែកបាក់គ្នាជាពួកបក្សគណៈនិកាយ រមែងជាបច្ច័យឲ្យបានទទួលនូវសន្តិសុខ, ទំនងសេចក្តីចំរើនវុឌ្ឍីឥតអាក់ ឥតមានឧបស័គ្គអ្វីមួយមកពាក់ព័ន្ធបានឡើយ ។

សាមគ្គីនេះឯង ទុកជាកម្លាំងមួយយ៉ាងសំខាន់ ដែលអាចជួយសាសនា, ប្រទេស, ជាតិ ទំនងលោកទាំងមូលឲ្យបានរំរើនជាប់មាំបិតថែរ មិនឲ្យត្រឡប់រៀវរេយ ឬវិនាសទៅបាន. បើសាសនិកជន ឬប្រទេសជាតិណាមានសាមគ្គីធម៌ចុះចំរើនដុះដាល ឬក៏តាំងនៅជាប់មាំល្អហើយ សាសនិកជន ឬប្រទេសជាតិនោះ រមែងបានទទួលសេចក្តីសុខដ៏ថ្កុំថ្កើនវុឌ្ឍីរឿងយ៉ាងអស្ចារ្យ ឥតមានអំណាចអ្វីចូលទៅលុកលុយឲ្យសាបសូន្យរលាយរលត់បានឡើយ. ប្រៀបដូចជាសរសៃអម្បោះតូចធ្លាវ បើប្រសិនជាគេយកច្រើនសរសៃទៅវេញត្រចាញ់ ឬត្រកួញចូលជាមួយគ្នា គេអាចយកសរសៃអម្បោះនោះទៅចងសត្វតាំងធ្ងាយមានដំរីជាដើម ដែលជាសត្វមានកម្លាំងច្រើនឲ្យជាប់បាន, សត្វតាំងនោះ មិនអាចនឹងទាញរើឲ្យជាប់ខ្សែអម្បោះនោះបានឡើយ ។ សូម្បីរូបកាយយើងទៀតសោត ដែលនឹងតាំងនៅ ឬនឹងចំរើនឡើងបាន

កំដោយសារអាស្រ័យសាមគ្គីរបស់ធាតុទាំង ៤, អាការៈ ៣២ នឹងសរីរវយវៈ ដំសេសក៏ដូច្នោះដែរ, បើរបស់ទាំងនេះមិនរួបរួម ឬមិននៅជួបជុំគ្នា ពុកផុយ ឬក៏បែកបែកកម្ចាំងគ្នាហើយ រូបកាយយើងក៏មិនអាចប្រព្រឹត្តទៅ ឬចំរើនឡើងបានឡើយ ។ នៅក្នុងពៃព្រមានសត្វចតុប្បាទ ១ ពួកមាឌតូចៗ ហៅថា សុនខពៃព្រ មាឌតូចជាងសុនខស្រុកទៅទៀត តែវាមានសាមគ្គីស្រុះស្រួលគ្នាជាទំបំផុត វាអាចទៅចោមរោមទាំសត្វទាំងឡាយ មានខ្លា នឹងសីហៈជាដើម ដែលជាសត្វមានមាឌធំសម្បើមហើយកាចសាហាវយ៉ាងក្រៃលែង យកទៅធ្វើជាអាហារបស់វាបាន; សត្វខ្លានឹងសីហៈជាដើមតែងមានភ័យដ៏ពន្ធឹកអំពីពួកសុនខពៃព្រជានិច្ច ។ ស្រមោច, សង្ឃ្វារ, កណ្តៀរ, . ឃ្មុំនឹងម្រាមជាដើម វាអាស្រ័យជាមិសាមគ្គីស្រុះស្រួលរួមរ័ក្សាពប់រកគ្នា ឬបានជាវាអាចញាំងកិច្ចគ្រប់យ៉ាងឲ្យសម្រេចតាមបំណងបាន, ទាំងនេះក៏ព្រោះអាស្រ័យសាមគ្គីជាហេតុ ។

សុនខពៃព្រជាដើម ជាសត្វតិរច្ឆានទាំងមាឌក៏តូចហើយថែមទាំងកាចសាហាវពន់ពេកណាស់ ឥតដែលមានសាសនាណាប្រៀនប្រដៅឥតដែលមានសៀវភៅក្បួនច្បាប់សម្រាប់មើល ទាំងគ្មានអ្នកថ្លៃឈ្នួលសម្រាប់ខ្ចីនាប្រៀនប្រដៅឲ្យចេះស្រឡាញ់រាប់អានគ្នា ឲ្យមានសាមគ្គីស្រុះស្រួលគ្នាសោះទេ តែវាចេះបណ្តុះសាមគ្គីស្រុះស្រួលរវាងគ្នាវាបាន ។ ចុះយើងទាំងអស់គ្នាជាមនុស្សជាតិត្រឡាំង មានសាសនាល្អវិសេស

សម្រាប់កាន់កាប, មានក្បួនតម្រាសម្រាប់មើល, មានអ្នកជ្រាបជ្រយ៉ាំង
ឆ្នើម ។ សម្រាប់ខ្ចាន់ប្រៀនប្រដៅ, ថែមទាំងមានជាតិអ្នកដឹងខុសត្រូវ-
ទៀសល្អអាក្រក់ក៏ស្រាប់ កំគួរតែបណ្តុះសាមគ្គីឲ្យកើតឡើង កុំឲ្យអន់
ថយខ្សោយជាង៩សត្វតិរច្ឆានមានកណ្តៀរដើម ។ កុំប្រើសំដីលូកលើ
សើរក្រែម ព្រោះជាហេតុទាំឲ្យក្លាយទៅជាទោសវិញទេ ។ ឯការទំ
ប្រឹងប្រែងជួយជ្រោមជ្រែង៩ព្រះពុទ្ធសាសនា ឧ៩ប្រទេសជាតិឲ្យបាន
ចំរើនឡើង៩នោះ បើជ្រាសចាកចំនង ឬជ្រាសចាកៗបាយរួបរួមបណ្តុះ
សាមគ្គីហើយ ក៏មិនជាយឧ៩បានសម្រេចប្រយោជន៍តាមបំណង៩បាន
ឡើយ, វត្ថុបំណង៩នោះឧ៩ទៅជាអសារឥតការ ។

ក្នុង៩សម័យឥឡូវនេះ ដំឡៃនៃសីលធម៌ឧ៩វឌ្ឍនធម៌ ចេះតែរលត់
ខ្សត់ខ្សោយរលាយអស់ទៅ នាំឲ្យអស់សេចក្តីសង្ឃឹមក្នុង៩ផ្លូវសន្តិសុខ
ព្រមទាំង៩វឌ្ឍនធម៌, បើទុកឲ្យជាទំប្រឹង៩ប្រែង៩ស្វែង៩រកដោយសតិ-
បញ្ញា ដ៏ល្អិតសុខុមយ៉ាង៩ណាក៏កម្រិទឧ៩ធ្វើឲ្យកើតឲ្យចំរើនឡើង៩បាន ។
គួរណាស់តែសាធុជនទំប្រឹង៩ធ្វើតាមឲ្យកើតមានឡើង ។

បើតាមច្បាប់ព្រះពុទ្ធសាសនាថា សន្តិសុខក្នុង៩លោកនេះ ឧ៩កើត
ឡើង៩បានក៏ដោយសារកម្លាំង៩នៃសាមគ្គីធម៌ ឧ៩មេត្រីចិត្តដ៏បរិសុទ្ធ ។
ឯការប្រែធាជាក់ចែកខ្ចប់ខាតអន្តរាយ ឬវិនាសទៅនៃសាមគ្គីឧ៩
មេត្រីចិត្តនេះ កើតឡើង៩ដោយសារហេតុច្រើនប្រការ គឺដោយសារ

ឧបក្លិសធម៌, ដោយសារអគតិ ទឹងដោយសារទិដ្ឋិជាដើម ។ ឯការ
ច្រែងឆោដោយសារឧបក្លិសធម៌នោះ ចានដល់ឧបក្លិស ១៦ គឺ:

១_ អភិជ្ឈាវិសមលោភ: សេចក្តីរំលោភចង់ចានហួស
ខំនង ឬ បំពានយកវបស់គេមកធ្វើជាវបស់ខ្លួន

២_ ទោស: ច្រែងសពយ, ផ្តន្ទា, បៀតបៀន ឬ ដុះជាន់គេ

៣_ កោធ: គ្រោធខឹង ឬកំឆ្នើងខ្ពុកបុកម្ខេញាគេ

៤_ ឧបនាហ: ចងពៀរ, ចងគំនុំ, វេចខ្ចប់នូវកំហឹងខ្ពុក

៥_ មក្ខ: លុបគុណ, វេរគ្នើគុណ, ឬមំក្ងេចគុណគេ

៦_ បលាស: ពាយឬកស្មើ, លើកខ្លួនជ្ជឹមនឹងលោក·អ្នក
ដែលមានបុណ្យសំក្តិ ឬចង់ច្រណាំងពាសនា

៧_ ឥស្សា ឬសា ច្រណែនឈ្នានីសគេ

៨_ មច្ឆរិយ: សេចក្តីកំណាញ់ស្ងួតស្ងាញ, លាក់លៀមទ្រព្យ
សម្បត្តិរបស់ខ្លួន ឬមិនព្រមចែករំលែកលាភ, យស - សុខ - សរសើរ
ទឹងច្រយោជន៍ព្រមពាំងអានុភាពទឹងសមត្ថភាពដល់អ្នកដទៃ

៩_ មាយា មានពុតត្បុតអាក្រក់ ឬបំពុំងខ្លួនទម្ងាក់ទោសរបស់ខ្លួនទៅលើអ្នកដទៃ

១០_ សាឋេយ្យ: អួតអាងអែបអប ឬសរសើរលើក
គុណដែលមិនមានកងខ្លួនថាមាន

๑๑_ បិម្ភ: កោងកាច, ព្រហើន-រឹងត្អឹង ឬចចេស-មុខរឹង

๑๒_ សារម្ភ: ប្រណាំងប្រជែង, ចង់ឈ្នះ ឬដណ្តើមយកឲ្យតែតែម្នាក់ឯង

๑๓_ មាឆ: អួតថាវិសេសជាងគេ លើកកំពស់ ឬប្រកាន់ខ្លួនឆ្មើងកន្ទ្រើង, ក្រអឺតក្រអោង

๑๔_ អតិមាឆ: ចង់ឲ្យខ្ពស់ហួសវិស័យ គឺមើលងាយគេ

๑๕_ មទ: ស្រវឹងឈ្កក់ឬកាន់តំនិតក្នុងលាភ, យសសុខសរសើរ

๑๖_ បមាទ: ធ្វេសប្រហែស, លង់ខ្លួន, ចោះចិត្តទៅក្នុងកាមគុណ, ភ្លេចស្មារតី ឬច្រាសចាកសតិសម្បជញ្ញៈ ។

ការប្រែធាដោយអគតិគឺការលំអៀងនោះ ចាន់ដល់អគតិ ๔ យ៉ាង គឺ

๑_ ឆន្ទាគតិ សេចក្តីលំអៀង ព្រោះយល់មុខ, ព្រោះស្រឡាញ់, ព្រោះគាប់ចិត្តថាល្អ ថាប្រសើរ ។

๒_ ទោសាគតិ សេចក្តីលំអៀង ព្រោះស្អប់, ព្រោះខឹងមិនពេញចិត្ត ។

๓_ មោហាគតិ សេចក្តីលំអៀង ព្រោះល្ងង់ខ្លៅតុំយល់ការខុសត្រូវ-ជ្រុលពក់ ។

๔_ ភយាគតិ សេចក្តីលំអៀង ព្រោះខ្លាចបុណ្យ, ខ្លាចអំណាច, ខ្លាចធនធាន ឬ ខ្លាចចិត្តគេ ។

ចំណែកការប្រែធាសាមគ្គីដោយទិដ្ឋិ គឺការឈ្វេងយល់ខុសបាន ដល់ទិដ្ឋិជាសត្រូវធំ ២ យ៉ាង គឺ:

១— ខុប្បែទិដ្ឋិ លទ្ធិមិនជឿកាន់សួគ៌ - នរក; មិនជឿបាប, បុណ្យ - គុណ - ទោស - អាក្រក់ - ល្អជាដើម គិតតែឲ្យបានថ្លុះថ្លើងរុងរឿងឬសប្បាយក្នុងបច្ចុប្បន្ន ។

២— អត្ថិទិដ្ឋិ លទ្ធិគិតតែប្រយោជន៍ផ្ទាល់ខ្លួន ពួកបក្ខខ្លួន ឬត្រកូលខ្លួន ។

ធម៌ដ៏លាមកប៉ុណ្ណេះជាដើម សុទ្ធតែជាឈ្នួនបំបែកសាមគ្គី, ជាមូលហេតុបំផ្លាញសាមគ្គី ឲ្យវិនាសអន្តរាយរលត់រលាយសាបសូន្យវិនាសទៅ ។ ហេតុនេះ ពុទ្ធមាមកជនទាំងឡាយគួរតែចៀសវាងឲ្យស្រឡះ កុំបណ្តោយឲ្យអកុសលធម៌ទាំងនោះកើតមានក្នុងសន្តានឡើយ ទើបអាចបណ្តុះសាមគ្គីរវាងសាសនិកជន ឬមនុស្សជាតិផងគ្នាឲ្យកើតឡើងបាន ។ បន្ទាប់ពីនេះនឹងសូមសំដែងអំពីធម៌ជាគ្រឿងបណ្តុះសាមគ្គីដូចតទៅនេះ។

សាមគ្គីដែលនឹងកើតឡើងបាន ឬសូម្បីប្រែធាបែកបាក់ទៅហើយនឹងផ្សារភ្ជាប់ទៅវិញបាន ដោយអាស្រ័យធម៌ច្រើនប្រការគឺ ដោយសារសង្គហវត្ថុ ទើបសាធារណីយធម៌ជាដើម ។ ឯសាធារណីយធម៌មិនបានយកមកសំដែងទេ ព្រោះពេលវេលាដែលត្រូវសំដែងនៅខ្លីពេក សូមយកតែសង្គហវត្ថុមកសំដែងតែម្តង, ឯសង្គហវត្ថុនោះមាន ៤ យ៉ាង គឺ:

១_ ទាន: ការឲ្យទេយ្យវត្ថុ ឬចែករំលែកអានុភាពនឹងសមត្ថ-ភាពដល់គ្នានឹងគ្នាតាមកាលគួរ ។

២_ បេយ្យវាចា ការពោលវាចាគួរឲ្យគេចង់ឮចង់ស្តាប់ ឬ ទស្សាហ៍ពាក់ព័ន្ធពោលពាក្យពីពោះ ចំពោះជនខ្លួនៅមិនទើសមុខ, ទស្សាហ៍រំឭកជាស់តឿនប្រាប់ប្រយោជន៍ដល់គ្នានឹងគ្នា ឬពោលពីប្បាប់ទន្ទាប់នឹងសេចក្តីចុះសត្រុងឲ្យគេបានចេះដឹងដោយសារខ្លួន ។

៣_ អត្ថចរិយា ការប្រព្រឹត្តិអំពើជាប្រយោជន៍ដល់គ្នានឹងគ្នា ឬធ្វើប្រយោជន៍ឲ្យកើតឡើងដល់ខ្លួនព្រមទាំងអ្នកដទៃ ។

៤_ សមានត្តតា ការប្រព្រឹត្តិខ្លួនឲ្យស្មើ គឺមិនវ៉ែនឆ្ពីង, មិនប្រកាន់ខ្លួនដោយជាតិ, ត្រកូល, យសស័ក្តិ នឹងទ្រព្យសម្បត្តិ ។

អាគ្នាភាពសំដែងមកអំពីធម៌ជាហេតុឲ្យសាមគ្គីសាបសូន្យវិនាស់ទៅ នឹងធម៌ជាគ្រឿងធ្វើសាមគ្គីឲ្យចំរើនឡើងនេះ សមគួរដល់វេលានឹងបញ្ចប់ហើយ ។ ដោយអំណាចកុសលដែលកើតអំពីធម្មទេសនានេះ សូមឲ្យពុទ្ធបរិសទ្យទាំងឡាយកើតមានសាមគ្គីធម៌ឡើង តាំងពីពេលនេះទៅ កុំបីខកខានឡើយ ។

ឯវំ សម្មតា ធម្មទេសនា ការសំដែងធម៌ សន្មតថាចប់ដោយសេចក្តីសង្ខេបតែប៉ុណ្ណេះ តាមសមគួរដល់កាលវេលា ។

ភាគទី ២

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីដាន់ខ្ពស់ ចាត់ឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតគឺ ព.ស. ២៤៨៦, គ.ស. ១៩៤៣

(តមក)

---

## សិរីធរជាតក ទី ១០

(និយាយអំពីការប្រពេនបង្ហាន់ បានផលក្នុងបច្ចុប្បន្ន)

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមដំនុំព្រៃត្រៃបិឯក

ប្រែពីបាលី

បស្សថ សទ្ធាយ ទានគ្គិ តំទំ សត្ថា ជេតវនេ
វិហរន្តោ ឯកំ បុរិសំ អារព្ភ កថេសិ ។

*សត្ថា រតនត្តយសម្តេចព្រះសេដ្ឋបរមសាស្តាចារ្យ កាលទ្រង់សម្រាន្តព្រះឥរិយាបថ នៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនូវបុរសម្នាក់ ទ្រង់សំដែងនូវព្រះសទ្ធម្មទេសនា មានបទព្រះបាលីថា បស្សថ សទ្ធាយ ទានំ ដូច្នេះជាដើម ។*

*បានឮមកថា នៅនគរសាវត្ថី មានបុរសកំសត់ម្នាក់ចិញ្ចឹមជីវិតជាមួយភរិយា តែងនាំគ្នាពាំង ២ នាក់កាប់ឧស ស្រូបតុរស្មៅ នាំទៅលក់យក*

កម្រៃចិញ្ចឹមជីវិតសព្វៗថ្ងៃ តាមសណ្តាប់ជាអ្នកទិគាល់ក្រ ។ ដោយហេតុតែបុរសនោះជាអ្នកមានសទ្ធាល្អ កំរមែងចែងភាគរបស់អ្វីៗដែលខ្លួនកេចានមកនោះជាបីចំណែក គឺ ១ ចំណែកសម្រាប់ឲ្យទាន, ១ ចំណែកសម្រាប់បរិភោគ, ១ ចំណែកទៀតសម្រាប់សំចៃទុក ។ បុរសនោះជាអ្នកមានគំនិតគិតដល់អតីត អនាគត បច្ចុប្បន្ន ដោយគ្រប់គ្រាន់ពាំងអស់; មិនតែប៉ុណ្ណោះថែមទាំងពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ថាជារបស់ពុំទៀងជួរច្នេះទៀត, ទើបឆ្លៀតនំយាយសសោះអន្ធឯណោះកាលយោឲ្យយល់តតិធម្មតារបស់សង្ខារថា "ម្នាលភានអើយ, សង្ខារទាំងឡាយមិនទៀងទេ; កាលណាយើងស្លាប់ទៅ ទ្រព្យសម្បត្តិមិនទៅតាមយើងឡើយ; ហេតុដូច្នេះ គួរតែយើងឲ្យទាន ដែលជាបុណ្យតែងប្រព្រឹត្តទៅតាមយើងដូចស្រមោលអន្ទោលតាមក្បាណ; ម្នាលភានអើយ, ណ្ហើយយើងឲ្យទ្រព្យ ១ ចំណែក ដែលយើងសំចៃទុកនោះ ទៅជាទានទៀតចុះ" ។ គ្រានោះ កវិយាកំទួលអនុមោទនាជាមួយនឹងស្វាមី ឥតមានសេចក្តីតូញតែរឡើយ ។ ដល់ខាងក្រោយមក បុរសនោះចិញ្ចឹមជីវិតដោយទ្រព្យតែ ១ ចំណែក ឲ្យទានអស់ ២ ចំណែក ឥតមានសំចៃទុកទៀតទេ ។ តាំងពីថ្ងៃនោះមក ជនទាំង ២ នាក់ភាប់ៗសច្ចៃតស្មោះទៅលក់ ចាន់ថ្ងៃច្រើនជាងប្រក្រតី ដោយតែចានជាអ្នកស្តុកស្តម្ភ ។

ថ្ងៃមួយ ជនទាំងពីរនាក់នោះ មានសេចក្តីនឹករលឹកដល់សម្តេចព្រះដ៏មានព្រះភាគជាម្ចាស់, ទើបនាំគ្នាទៅឯវត្តព្រះជេតពនក្រាបបង្គំទូល

សម្តេចព្រះដ៏មានបុណ្យថា "បពិត្រព្រះអគ្គដ៏ចំរើន, របស់អ្វីៗដែលខ្ញុំ ព្រះអង្គរកបានមក ឥតបានលែលកសំចៃទុកសោះ, ខ្ញុំព្រះអង្គតែងបរិច្ចាគ ឲ្យទៅជាទានចាំងអស់ឥតមានសល់, ឥឡូវនេះ ទានោះឲ្យផល ឲ្យខ្ញុំ ព្រះអង្គបានចំរើនឲ្យសម្បត្តិឡើងជាអ្នកស្តុកស្តម្ភគ្រាន់បើ" ។ សម្តេច ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា "អ្នកចាំងឲ្យទានហើយ បានឡើងជាអ្នកស្តុកស្តម្ភយ៉ាងនេះ ក៏ដូចជាបណ្ឌិតចាំងឲ្យពីបុរាណដែរ" ទ្រង់ត្រាស់តែប៉ុណ្ណេះ ក៏ទ្រង់គង់ស្ងៀម ពុំមានព្រះពុទ្ធដីកាថា ដូចម្តេចទៀតឡើយ, ទាល់តែជនចាំងនោះក្រាបបង្គំអាកាធនា ទើប សម្តេចព្រះកតវេទ្ធ៌នាំអតីតនិទានមកសំដែងច្រើនថា ៖

អតីតេ ភិក្ខវេ ពារាណសិយំ ព្រហ្មទត្តោ នាម រាជា រជ្ជំ ការេសិ ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានព្រះរាជា មួយព្រះអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិនៅនគរ-ពារាណសី; សម័យនោះ ព្រះបរមពោធិសត្វបានយកកំណើតកើតជា សេដ្ឋីឈ្មោះសិរីវឌ្ឍ នៅនគរពារាណសី ជាអ្នកបរិបូណ៌ដោយសទ្ធាវក្ក សីល ៥ ជានិច្ច ។ គ្រានោះ មានព្រះបច្ចេកពុទ្ធ ១ ព្រះអង្គ ទ្រង់ចូល និរោធសមាបត្តិអស់ ៧ ថ្ងៃ, កាលបើចេញចាកនិរោធសមាបត្តិហើយ ក៏ ទ្រង់គិតក្នុងព្រះចិត្តថា "ថ្ងៃនេះ គួរអាត្មាអញទៅផ្ទះសិរីវឌ្ឍសេដ្ឋី នគរពារាណសីចុះ"; លុះគិតដូច្នោះ ក៏ទំពាឈើស្តន់ពុះព្រះឧស្សុំចីវរ

កាន់យកជាត្រដាំដែលសម្រេចដោយរិទ្ធិមកតាមអាកាស ចុះមកឋិតនៅ
ទៀបទ្វារផ្ទះនោះក្នុងបាតរាសវេលា គ្រាដែលគេបរិភោគបាយព្រឹក ។

សិរីធរសេដ្ឋីនោះ បានឃើញព្រះបច្ចេកពុទ្ធហើយ មានចិត្តត្រេក
អរសាទរក្រៃពេក ដោយគិតថា "យីអើ! អញបានឃើញព្រះបច្ចេកពុទ្ធ
ផ្ទាល់ទឹងក្មែកឯងតែម្តងហ្ន៎! ព្រះបច្ចេកពុទ្ធអង្គនេះ ដែលខំសូរពន្ធូរមកពី
ចម្ងាយខាំងម្ល៉េះ ប្រាកដជាមកដោយសេចក្តីអនុគ្រោះដល់អញហ្នឹងឯង";
កាលបើគិតឃើញដូច្នេះហើយ ក៏លើកកោជនៈបាយដែលជនខាំងឡាយ
រៀបចាត់ចែងរួចស្រេច មកប្រគូលលើក្បាល ចេញពីផ្ទះរលេះរលាំងទៅ
ដល់ទីដិតព្រះបច្ចេកពុទ្ធ ជាក់កាជនៈមាសក្នុងបាត្រព្រះបច្ចេកពុទ្ធ ហើយ
តាំងសេចក្តីប្រាថ្នាថា "បពិត្រព្រះអង្គដ៏ចំរើន, ដោយតេជៈនៃទានរបស់
ខ្ញុំព្រះករុណានេះ សូមឲ្យពួកមនុស្សត្រៃមាងពួកទេវតាធ្វើមហាសក្ការ
បូជាដល់ខ្ញុំព្រះករុណាកុំឲ្យខានសោះ; មិនតែប៉ុណ្ណោះ ដល់អនាគតទៅ
ឯភ្លោក ខ្ញុំសូមឲ្យបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ស្មើចស្រង់សត្វអំពី
វដ្តសង្សារ ជាក់ដល់ត្រើយនាយគឺអមតមហានិព្វាន" ។

ព្រះបច្ចេកពុទ្ធ មានព្រះពុទ្ធដីកាថា "សេចក្តីប្រាថ្នារបស់អ្នក
ចូរសម្រេចដូចោះចុះ" ហើយទ្រង់អនុមោទនាជាគាថាថា៖

ឥច្ចិតំ បដ្ឋិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ
សព្ពេ បូរេន្តុ សង្កប្បា បន្ធោ បណ្ណរសោ យថា

សេចក្តីថ្កុំថ្កើងដែលអ្នកតាំងខ្លួនហើយ ចូរឲ្យសម្រេចយ៉ាងឆាប់ៗចុះ; តម្រែតែវាំងនឲ្យយូរតាំងពួង ចូរពេញចរិបូណ៌ដល់អ្នក ដូចជាព្រះចន្ទក្នុងថ្ងៃ១៥កើត ។

កាលលោកធ្វើអនុមោទនាដូច្នេះហើយ ក៏ឃាត់ចង្ហាន់នោះនិមន្តត្រឡប់ទៅឆាន់ឯកុំគន្ធមាទន៍វិញ ។

ចំណែកខាងសិរីធរសេដ្ឋី បរមពោធិសត្វ ងាកមុខបែរចូលមកផ្ទះរបស់ខ្លួន រំពឹងនឹករលឹកដល់ទាននោះ ហើយអធិដ្ឋានថា បើអានិសង្សទាននេះមាន, សូមឲ្យមានលាភក្នុងបច្ចុប្បន្ននេះជាក្រោកដ ។ ដោយតេជៈនៃទាន ក៏ផ្ទះបុរាណរបស់សេដ្ឋីនោះបាត់ទៅ ហើយប្រាសាទមាសពេញពាសដោយកែវ៧ប្រការកើតឡើងភ្លាមក្នុងខណៈនោះឯង ។ សេដ្ឋីនោះបានឃើញប្រាសាទរបស់ខ្លួនភ្លាយទៅជាមាសដូច្នោះ ក៏មានសេចក្តីរីករាយសប្បាយចិត្តគិតថា "អ៎! សន្ទិដ្ឋិកផលកើតដល់អញ ដោយតេជៈទាននេះហើយតើ!" ទើបចូលទៅក្នុងប្រាសាទមាស ឡើងអង្គុយលើបល្ល័ង្កមាស ។ ចំណែកខាងអ្នកធ្វើកត្តិ នាំភាជន៍កត្តមកដម្កល់ទុកនៅទីចំពោះមុខពោធិសត្វ ក៏ពិភ្លេចស្រាប់តែកើតឡើងពេញ។ ភាជន៍មាស ក្នុងខណៈនោះឯង ។ ពោធិសត្វក៏នឹកក្នុងចិត្តថា "អ៎ហ្ន៎! អាត្មាអញអើយ ស្រាប់តែបានបរិភោគនូវភោជនដូចជាទេវតា ដោយសារតេជៈបុណ្យ តេជៈទាន" ។ កាលដែលសិរីធរសេដ្ឋីពោធិសត្វ បរិភោគ

ផ្នែតស្តាប់ស្តល់, ក៏ឲ្យកោដនដែលសល់ដល់បុរសទាំងឡាយទាំងរយទាំង
ពាន់នាក់ឲ្យបរិភោគជាទាន់ក្រោយ; បុរសទាំងនោះ ក៏បរិភោគពុំអស់ ។
កូនទិព្វកោដននោះ ផ្សព្វផ្សាយទៅពាសពេញទីក្រុងទាំងមូល; អ្នកនគរ
ទាំងអស់ ក៏ផ្តើលជ្រួលជ្រើមឡើងដោយចង់ដឹងថា កូននោះ ជាកូន
វត្តអ្វី ។ មហាជនទាំងប្រុសទាំងស្រី ដែលបានមកប្រជុំនៅទីនោះទាំង
ប៉ុន្មាន អត់ត្រាំពុំបាន ទានស្ងៀចពុំកើត ខ្វះអើតមើលពីចម្ងាយ កើត
សេចក្តីរីករាយក្រៃពេក ដោយបានឃើញប្រាសាទមាសនឹងរបស់ចំឡែក
កើតឡើងថ្មែក ។ អស្ចារ្យដូច្នោះ; ម្ល៉ោះហើយ ក៏ផ្គងអញ្ជលីថ្វាយបង្គំ
ព្រះបរមពោធិសត្វ ស្រែកឡើងថា "បពិត្រមហាសេដ្ឋី, យើងខ្ញុំសូម
អនុមោទនាចំពោះទានរបស់លោក" ហើយក៏លើកទង់ជាយទង់ជ្រុងទាំង
ម៉ឺនសែន ស្រែកឲ្យពរសំពួសាធុការទ្រហឹងអឺងកង ។ កាលដែលជនទាំង
នោះ កំពុងប្រជុំគ្នាត្រៀបត្រាដូច្នោះ ព្រះបរមពោធិសត្វក៏សំដែងធម៌
ទេសនា ដើម្បីចំរើនសទ្ធាដល់ពួកបណ្តាជនថា ៖

បស្សថ សទ្ធាយ ទានំ អន្នស្សេវ ពលំ
សព្ពាភិបត្ថិតំ ទេតិ ពលវា ឧ សម្បរាយេ

អ្នកទាំងឡាយ ចូរមើលនូវការបរិច្ចាគទាន ដែលខ្ញុំធ្វើហើយ
ដោយសទ្ធា; កម្លាំងជាយហ្នឹងឯង រមែងឲ្យសម្រេចនូវសេចក្តីប្រាថ្នា
គ្រប់យ៉ាង ទាំងក្នុងលោកនេះ និងក្នុងលោកខាងមុខ ។

អន្នទាតំ ធិលាវិហំ អាយុ វិណ្ណំ សុខំ ពលំ
យសំ កិត្តិ បដិភាណំ ឋិធេរ៑ បសម្បាយេ

*ការឲ្យជាយ ជាទានដ៏ប្រសើរបំផុត តឹឲ្យមានអាយុវែង ឲ្យ
មានពណ៌សម្បុរល្អ ឲ្យមានសេចក្តីសុខ ឲ្យមានកម្លាំងកាយ
កម្លាំងប្រាជ្ញា ឲ្យមានយសបរិវារ ឲ្យមានសេចក្តីសរសើរ
ឲ្យមានប្រាជ្ញា ក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។*

តិទំ សុរិណ្ណបាសាទំ កូដាគារំ រោបិតំ
ទានតេជេនេរ៑ប្បន្នំ តិដ្ឋំ កន្តំ ទាតុស្ស មេ

*ប្រាសាទមាសនេះ ដ៏រុងរឿងដោយផ្ទះកំពូល ជាទីប្រាថ្នា
ជាទីត្រេកអរ កើតឡើងដល់ខ្ញុំជាអ្នកឲ្យ ដោយតេជៈនៃទាន
ហ្នឹងឯង ។*

តស្មា ទទេយ្យ បណ្ឌិតោ សម្បស្សំ អត្តមត្តនោ
មា មច្ចេរំ ឧប្បាទេតុ អនត្តញ្ញំ មច្ចរិយន្តិ ។

*ព្រោះហេតុនោះ បុរសបុគ្គលអ្នកមានប្រាជ្ញា គប្បីឲ្យទាន, កុំបណ្តោយឲ្យ
សេចក្តីកំណាញ់កើតឡើងបានឡើយ, ដ្បិតសេចក្តីកំណាញ់
ជាទោសឥតមានប្រយោជន៍ទេ ។*

កាលចប់ធម៌ទេសនា បណ្តាជនដែលមានសេចក្តីជ្រះថ្លា បានប្រគល់ខ្លួនជាទាសីទាសាបូជាធម៌ជាច្រើនគ្នា ។ គ្រានោះ ទិព្វបុប្ផ កំពេយចុះចាកទ្រកាមាវចរទេវលោក ធ្លាក់មកបូជា, ទាំងនាគពជ ក៏នាំយកតែវ ៧ ច្រកាមកបូជាធម៌, ទាំងសម្តេចសក្កទេវរាជ ក៏មានសេចក្តីត្រេកអរបានទាំយកព្រះពុទ្ធិព្វមកបូជា ព្រះសទ្ធម្ម, មហាព្រហ្ម ធ្វើធត្តបូជាធម៌ទេសនា, ព្រះចាតុព្រហ្មទត្តបរមារាជា ក៏ធ្វើអត់តែពុំបានបានចូលទៅដល់ត្រព្រះមហាសត្ត ហើយធ្វើបូជាធម៌ទេសនាព្រះមហាសត្តដោយដំរីមួយរយ សេះមួយរយ រថមួយរយ នារីមួយរយ ។ ព្រោះហេតុនោះ បានជាកាលគ្រាដែលសម្តេចព្រះបរមសាស្តាចារ្យជាម្ចាស់បានត្រាស់ឡើងហើយ ទ្រង់សំដែងព្រះធម៌វិសេសទេសនាថា

> ទានជាកិច្ចដ៏ឧត្តុង្គឧត្តមក្នុងលោក, ទានដែលបុគ្គលឲ្យហើយរមែងមានអានិសង្ស គឺឲ្យកើតសេចក្តីសរសើរ ចំរើនផ្សព្វផ្សាយទៅ ដោយប្រការដូច្នេះឯង ។

ចាប់ដើមពីថ្ងៃនោះមក ព្រះបរមពោធិសត្វតែងចំណាយម៉ាសមួយពាន់ដង្គីឲ្យទានពាល់ៗថ្ងៃ ។ មនុស្សទាំងឡាយ មកទទួលទានតែងពោលសរសើរព្រះបរមពោធិសត្វជាអនេកប្រការ ទើបត្រឡប់ចេញទៅវិញ ។ ព្រះបរមពោធិសត្វសោយសម្បត្តិបិតទៅជាសុខ តែងធ្វើបុណ្យទាំងឡាយមានការបរិច្ចាគទានជាដើម ដរាបដល់អស់អាយុ បាន

ទៅកើតកន្លងពីមានមាសកំពស់ ២៩ យោជន៍ រីចតែដោយកែវ ៧ ប្រការ មានស្រែទេពអប្សរ ១ សែន ចាមរោមជាបរិវារ សោយទិព្វកោជន ក្នុងភាជនទិព្វ ជាទីរីករាយសប្បាយតាមប្រាថ្នា អស់កាលជាអង្វែង ។

អគ្គសម្ពោធព្រះសពេជ្ឈបរមសាស្តា ទ្រង់នាំព្រះធម្មទេសនាមកសំដែង ចប់សព្វគ្រប់ហើយ ទ្រង់ប្រកាសអរិយសច្ច ដល់ចប់ស្រេច ក៏ជនទាំងពីរនាក់ បានសម្រេចដល់សោតាបត្តិផល, ទើបអគ្គសម្ពោធព្រះទសពលទ្រង់ប្រដុំជាតកថា ព្រះឥន្ទ្រកាលនោះ លុះចេរវិលវិញមកបានមកកើតជាអនុរុទ្ធ, មហាព្រហ្ម បានមកកើតជាអានន្ទ, ព្រះបាទព្រហ្មទត្តបានមកកើតជាសារីបុត្ត, នាគរាជ បានមកកើតជាមោគ្គល្លាន, ក្រុមបរិសទ្យទាំងឡាយ បានមកកើតជាពុទ្ធបរិសទ្យទាំងអស់, ព្រះបច្ចេកពុទ្ធបរិនិព្វានទៅ, ឯសិរីធរសេដ្ឋី គឺអគ្គតថាគត ជាសម្មាសម្ពុទ្ធហ្នឹងឯង; អ្នកទាំងឡាយ ចូរចាំទុកនូវជាតកនេះយ៉ាងនេះចុះ ។

ចប់ សិរីធរជាតក ទី ១០ តែប៉ុណ្ណោះ

---

# ហេតុអ្វីបានជាពួកមនុស្សប្រុប្លិជ្ជនមានអធ្យាស្រ័យ ខិនទៅរកលោកាមិស[1] ខ្លាំងម្ល៉េះ?

*សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នៃព្រៃមហាវន ជិតក្រុងវេសាលី ។ គ្រានោះ មានកិក្ខុជាច្រើនរូបប្រកាសអរហត្តផលក្នុងសំណាក់ព្រះដ៏មានព្រះភាគថា "ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ខ្ញុំព្រះអង្គទាំងឡាយបាននៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះគ្មានទៀតទេ" ។*

*សុនក្ខត្តលិច្ឆវិបុត្តបានឮពាក្យកិក្ខុទាំងនោះ ប្រកាសព្រះអរហត្តផលដូច្នោះហើយ ក៏នឹកសង្ស័យ ទើបចូលទៅគាល់ព្រះសាស្តាក្រាបថ្វាយបង្គំរួចហើយទូលសួរថា "បពិត្រព្រះអង្គដ៏ចំរើន! កិក្ខុទាំងនោះបានប្រកាសព្រះអរហត្តផលដោយប្រពៃមែនពិតឬ ឬមានកិក្ខុពួកខ្លះក្នុងទីនុ៎ះបានប្រកាសព្រះអរហត្តផលដោយការស្មានដែរ?" ។*

---

១ លោកាមិស (លោក + អាមិស) នុយរបស់សត្វលោក គឺបញ្ចកាមគុណ (រូប, សំឡេង, ក្លិន, រស, សម្ផស្ស) ។ វិបស្សនាក្រម ភាគ ២ ។

ព្រះដ៏មានព្រះភាគត្រាស់ថា "ម្នាលសុនក្ខត្ត! កិកូពួកខ្លះប្រកាសអរហត្តផលដោយប្រពៃមែនក៏មាន ដោយការស្មានក៏មាន។ ម្នាលសុនក្ខត្ត! កាមគុណមាន ๕ ប្រការគឺ រូប ๑ សំឡេង ๑ ក្លិន ๑ រស ๑ ផោដ្ឋព្វៈ ๑ ដែលគួរដឹងច្បាស់ដោយភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ប្រកបដោយកាម គួរជាទីរីករាយ។

ម្នាលសុនក្ខត្ត! មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យនុនៅរកលោកាមិសរមែងមាន។ ពាក្យសំដីរបស់បុរសបុគ្គលដែលមានអធ្យាស្រ័យនុនៅរកលោកាមិស តែតាំងចាប់ទំាយាយឡើងតែងប្រៀបធៀបនៅរកកាមគុណផង បុរសបុគ្គលនោះតែងត្រិះរិះរឿយ។ ពិចារណារឿយ។ ឮវិហេតុដែលប្រព្រឹត្តទៅតាមកាមគុណនោះផង តែងគប់រកបុរសបែបនោះផង តែងគោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយប្រកបដោយអានេញ្ជសមាបត្តិ បុរសបុគ្គលនោះមិនចង់ស្តាប់ផង មិនផ្តង់ត្រចៀកផង មិនតាំងចិត្តចង់ដឹងផង មិនគប់រកបុរសបែបនោះផង មិនគោរពតាមបុរសបែបនោះផង ប្រៀបដូចជាបុរសចេញអំពីស្រុក ឬនិគមរបស់ខ្លួនដែលជាទីធ្លាប់នៅយូរហើយ។ បុរសនោះកាលបើឃើញអ្នកណាមួយទើបនឹងចេញពីស្រុកឬនិគមនោះមក ក៏សាកសួរអំពីស្រុកនិគមនោះ ដែលថា

ដែនមានសេចក្តីក្សេមក្សាន្តផង ជាដែនមានភិក្ខាហារដ៏សម្បូណ៌ផង ជាដែនគ្មានអាសាធផង បំភោះបុរសនោះ។ និយាយថ្កាប់សព្វគ្រប់ហើយ; ចុះអ្នកស្តេចនោះគប្បីស្តាប់ភាក្យសំដីរបស់គេ ផ្ចង់ត្រចៀក តាំងចិត្តចង់ដឹង គប់រកបុរសនោះផង គោរពតាមបុរសនោះផង ដែរឬទេ? ។ សុនក្ខត្តលិច្ឆវីបុត្តក្រាបបង្គំទូលថា ព្រះកុរណាព្រះអង្គ ។ - ម្នាលសុនក្ខត្តលិច្ឆវីបុត្ត! បុរសបុគ្គលដែលមានអធ្យាស្រ័យនុនទៅរកលោកាមិស ក៏ដូចជាបុរសអ្នកស្តេចគេអំពីស្រុកឋិនគមដែលខ្ជិនធ្លាប់នៅពីមុននោះដែរ ។

ម្នាលសុនក្ខត្ត! មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យនុនទៅរកអានេញ្ជសមាបត្តិរមែងមាន ។ ពាក្យសំដីរបស់បុរសបុគ្គល ដែលមានអធ្យាស្រ័យនុនទៅរកអានេញ្ជសមាបត្តិ តែគាំងចាប់និយាយឡើង តែងប្រៀតទៅរកអានេញ្ជសមាបត្តិនោះ បុរសបុគ្គលនោះរមែងត្រិះរិះរឿយៗ ពិចារណារឿយៗ នូវហេតុដែលប្រព្រឹត្តទៅតាមអានេញ្ជសមាបត្តិនោះផង តែងគប់រកបុរសបែបនោះផង តែងគោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយប្រកបដោយលោកាមិស បុរសបុគ្គលនោះមិនចង់ស្តាប់ផង មិនគោរពតាមបុរសបែបនោះផង ។ ម្នាលសុនក្ខត្ត! ស្មឹកឈើខ្ចីមានពណ៌លឿងផ្ទុះចេញចាកទង់ហើយ មិនគួរនៅខៀវខ្ចីទៀតបានឡើយ យ៉ាងណាមិញ បុរសបុគ្គលដែលមានអធ្យាស្រ័យនុនទៅរកអានេញ្ជសមាបត្តិរមែងផ្ទុះចាកការប្រកបក្នុងលោកាមិស ក៏យ៉ាងនោះដែរ ។

ម្នាលសុនក្ខត្ត ! មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យនៅរកអាកិញ្ចញ្ញាយតនសមាបត្តិ រមែងមាន ។ ពាក្យសំដីរបស់បុរសបុគ្គល ដែលមានអធ្យាស្រ័យនៅរកអាកិញ្ចញ្ញាយតនសមាបត្តិ តែតាំងចាប់និយាយឡើង តែងប្រៀបនៅរកអាកិញ្ចញ្ញាយតនសមាបត្តិនោះ តែងគោរពតាមបុរសបែបនោះ ចំណែកខាងពាក្យសំដី ដែលគេនិយាយប្រកបដោយអានេញ្ជសមាបត្តិ បុរសបុគ្គលនោះមិនចង់ស្តាប់ផង មិនគោរពតាមបុរសបែបនោះផង ។ ប្រៀបដូចដុំថ្មគ្រាស់បែកចេញជាពីរគាគមិនជាប់គ្នាវិញបាន យ៉ាងណាមិញ បុរសបុគ្គលដែលមានអធ្យាស្រ័យនៅរកអាកិញ្ចញ្ញាយតនសមាបត្តិ ក៏យ៉ាងនោះឯង ។

ម្នាលសុនក្ខត្ត ! មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យនៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងមាន ។ ពាក្យសំដីរបស់បុរសបុគ្គលដែលមានអធ្យាស្រ័យនៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ តែតាំងចាប់និយាយឡើង តែងប្រៀបនៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិនោះផង គោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយប្រកបដោយអាកិញ្ចញ្ញាយតនសមាបត្តិ ក៏បុរសបុគ្គលនោះមិនចង់ស្តាប់ផង មិនគោរពតាមបុរសបែបនេះផង ។ ប្រៀបដូចបុរសបរិភោគចុយជាពីតាប់ចិត្តនៃអ្នក

ឆ្ពន់ហើយលែង ចុះថ្នាំងាយនោះទៀត ព្រោះថាងាយនោះគេសន្មតថាជារបស់បដិកូល ។ ម្នាលសុនក្ខត្តៈ! បុរសបុគ្គលដែលមានអធ្យាស្រ័យទន្ទេរទៅរកនៅវិសញ្ញានាសញ្ញាយតនសមាបត្តិ រមែងខ្ជាក់ចោលនូវការប្រកបក្នុងអាកិញ្ចញ្ញាយតនសមាបត្តិនោះ យ៉ាងនេះឯង ។

ម្នាលសុនក្ខត្តៈ! មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានអធ្យាស្រ័យទន្ទេរទៅរកព្រះនិព្វានដោយប្រពៃ រមែងមាន ។ ពាក្យសំដីរបស់បុរសបុគ្គលដែលមានអធ្យាស្រ័យទន្ទេរទៅរកព្រះនិព្វានដោយប្រពៃ តែតាំងចាប់និយាយឡើង តែងប្រៀតទៅរកតែព្រះនិព្វាននោះផង គោរពតាមបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយប្រកបដោយវិសញ្ញានាសញ្ញាយតនសមាបត្តិ ក៏បុរសបុគ្គលនោះមិនចង់ស្តាប់ផង មិនគោរពតាមបុរសបែបនោះផង ។ ប្រៀបដូចដើមត្នោតកំបុតចុង ដុះលូតលាស់ឡើងវិញមិនបាន យ៉ាងណាមិញ បុរសបុគ្គលដែលមានអធ្យាស្រ័យទន្ទេរទៅរកព្រះនិព្វានដោយប្រពៃ រមែងផ្តាច់ផ្តិលនូវការប្រកបក្នុងវិសញ្ញានាសញ្ញាយតនសមាបត្តិ ឲ្យអស់រលីងដូចជាដើមត្នោត ដែលគេកែបែលគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម្មលែងមានកំណើតតទៅមុខទៀតហើយ ក៏យ៉ាងនោះឯង ។

ម្នាលសុនក្ខត្តៈ! ហេតុដែលនាំឲ្យកើតខ្លះ ក្នុងសាសនានេះ មានសេចក្តីតែះរិះថា សតគឺតណ្ហា ឧច្ឆេទជាពិសគឺអវិជ្ជា ដែលព្រះសមណៈ

ត្រាស់ហើយថា តែងកំរើកដោយធម្មតានឹងព្យាបាទ សរគឺតណ្ហានោះជា
របស់ដែលអាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជា ជារបស់
ដែលអាត្មាអញបាននាំចេញហើយដែរ អាត្មាអញមានអធ្យាស្រ័យនឹង
ទៅរកព្រះនិព្វានដោយប្រពៃហើយ សេចក្តីត្រិះរិះយ៉ាងនេះជាដើមជា
សេចក្តីត្រិះរិះមានប្រយោជន៍ ដូច្នេះរមែងមាន ។ កិក្ខុនោះប្រកប
រឿយៗ នូវអារម្មណ៍មិនជាទីសប្បាយរបស់បុគ្គល ដែលមានអធ្យាស្រ័យ
នឹងទៅរកព្រះនិព្វានដោយប្រពៃ ។ កិក្ខុនោះប្រកបរឿយៗ នូវរូបមិនជា
ទីសប្បាយដោយចក្ខុ ប្រកបរឿយៗ នូវសំឡេងមិនជាទីសប្បាយដោយ
សោតៈ ។បេ។ ប្រកបរឿយៗ នូវធម៌មិនជាទីសប្បាយដោយចិត្ត ។
កាលកិក្ខុនោះប្រកបរឿយៗ នូវការឃើញរូបមិនជាទីសប្បាយដោយចក្ខុ
។បេ។ ពគៈក៏គ្រប់សង្កត់ចិត្ត ។ កិក្ខុនោះ លុះត្រូវពគៈគ្របសង្កត់
ចិត្តហើយ ក៏ដល់នូវមរណៈគឺសឹកឬដល់នូវសេចក្តីទុក្ខស្ទើរតែមរណៈ ។
ប្រៀបដូចជាបុរសដែលត្រូវសរ ត្រាំដោយថ្នាំពិសលាបជោកជាំហើយ
មិត្រអាមាត្យញាតិសាលោហិតរបស់បុរសនោះ ក៏ឲ្យពេទ្យវះអ្នកស្ទាត់
ដំនាញរក្សា ។ ពេទ្យវះនោះក៏វះមុខដំបៅរបស់បុរសនោះដោយសស្ត្រា
លុះវះរួចហើយក៏វេកសរដោយគ្រឿងសម្រាប់ពាវេក (ដង្កៀប) រួចដក
សរដែលមានពិសជាទោសសេសសល់នៅឲ្យអស់ចេញ ក៏ដឹងថាពិស
ជាទោសគ្មានសេសសល់នៅទេ ទើបពេទ្យវះប្រាប់បុរសនោះថា "សរ
របស់អ្នកយើងបានដកចេញហើយ ពិសជាទោសយើងបាននាំចេញ

ហើយ ឥតមានសេសសល់ឡើយ ល្មមគ្មានអន្តរាយដល់អ្នកហើយ អ្នកគួរបរិភោគតែភោជនដែលជាទីសប្បាយ អ្នកកុំបរិភោគភោជនមិនជាទីសប្បាយឲ្យដំចៅរីករឹតឡើយ អ្នកគួរលាងនឹងលាបមុខដំចៅតាមកាលដ៏សមគួរ លុះអ្នកលាងនឹងលាបរួចហើយ កុំរុំមុខដំចៅដែលមានខ្យុះនឹងឈាមឡើយ អ្នកកុំដើរហាលខ្យល់នឹងកំដៅថ្ងៃ កាលបើអ្នកដើរហាលខ្យល់នឹងកំដៅថ្ងៃ កុំឲ្យលំអងធូលីរុំមុខដំចៅបានឡើយ ។ បុរសនោះគិតថា សរីរបស់អាត្មាអញពេទ្យបានដកចេញហើយ ពិសជាទោសពេទ្យបានទំាចេញហើយគ្មានសេសសល់ទេ ល្មមគ្មានអន្តរាយដល់អញហើយ ។ បុរសនោះបរិភោគភោជនមិនជាទីសប្បាយ ដំចៅក៏រីកឡើង ពាំងមិនលាងមិនលាបមុខដំចៅតាមកាលគួរ ខ្យុះនឹងឈាមក៏រុំមុខដំចៅ បុរសនោះចេះតែដើរហាលខ្យល់នឹងកំដៅថ្ងៃ សត្រូវគឺធូលីក៏រុំមុខដំចៅ មិនរក្សាដំចៅផង មិនផ្សះដំចៅផង មុខដំចៅចេះតែដោរឡើង ។ បុរសនោះក៏ដល់នូវមរណៈ ឬដល់នូវទុក្ខស្ទើរតែមរណៈដោយដំចៅដែលដោរឡើងនោះ សេចក្តីនេះមានឧបមាយ៉ាងណា ឯតិក្ខុអ្នកត្រេកអរចំពោះកងតាមគុណក៏មានឧបមេយ្យយ៉ាងនោះដែរ ។

ម្នាលសុន្ទរិកភារទ្វាជ មួយទៀត ហេតុដែលនាំឲ្យតិក្ខុខ្វះកងសាសនានេះមានសេចក្តីត្រិះរិះថា សរគឺតណ្ហា ទោសជាពិសគឺអវិជ្ជា ដែលព្រះសមណៈត្រាស់ហើយថា តែងកំរើកឡើងដោយឆន្ទរាគនឹងព្យាបាទ សរគឺតណ្ហានោះអាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជាអាត្មាអញបាន

នាំចេញហើយ អាត្មាញមានអធ្យាស្រ័យនុនៅរកព្រះនិព្វានដោយប្រពៃហើយ ដូច្នេះវមែងមាន ។ កាលដែលគេកំពុងមានអធ្យាស្រ័យនុនៅរកព្រះនិព្វានដោយប្រពៃ កិក្ខុនោះមិនប្រកបរឿយៗនូវអារម្មណ៍មិនជាទីសប្បាយរបស់បុគ្គល អ្នកមានអធ្យាស្រ័យនុនៅរកព្រះនិព្វានដោយប្រពៃឡើយ មិនប្រកបរឿយៗនូវការឃើញរូបមិនជាទីសប្បាយដោយចក្ខុ ។ បេ ។ មិនប្រកបរឿយៗនូវធម៌មិនជាទីសប្បាយដោយចិត្ត ។ កាលកិក្ខុនោះមិនប្រកបរឿយៗ នូវអារម្មណ៍មិនជាទីសប្បាយដូច្នោះហើយ ពគៈក៏មិនគ្របសង្កត់ចិត្តបាន ។ កាលកិក្ខុនោះមិនត្រូវពគៈគ្របសង្កត់ចិត្តហើយ ក៏មិនដល់នូវមរណៈ (មិនសឹក) ឬថាមិនដល់នូវទុក្ខស្ទើរតែមរណៈ ។ ប្រៀបដូចបុរសត្រូវសរត្រាំដោយថ្នាំពិសលាបឲ្យជោកជាំហើយ ឲ្យពេទ្យវះមុខដំចៅក៏ខំថែទាំរក្សាដំចៅឲ្យសះជាតាមបណ្តាំពេទ្យគ្រប់ប្រការឥតធ្វេសប្រហែសឡើយ បុរសនោះក៏មិនស្លាប់ឬមិនកើតទុក្ខដិតស្លាប់ សេចក្តីនេះមានឧបមាយ៉ាងណា កិក្ខុអតមិនត្រេកអរក្នុងកាមគុណក៏មានឧបមេយ្យដូច្នោះដែរ ។

ម្នាលសុនក្ខត្ត! កិក្ខុនោះឯង ជាអ្នកសង្រួមក្នុងឥស្សាយតនៈទាំង ៦ ដ៏ឯប្បាស់ថាកិលេសជាឫសគល់នៃសេចក្តីទុក្ខ លុះដឹងដូច្នេះហើយក៏ជាអ្នកគ្មានកិលេស ជាអ្នករួចស្រឡះហ៊ាយ ព្រោះការអស់ទៅនៃកិលេសទាំងបង្អោនទាយឬទាំងផ្តេកផ្តួលចិត្តទៅកាន់កិលេស ហេតុដូច្នេះមិនដែលមានឡើយ ។ ម្នាលសុនក្ខត្ត! ដូចដុំលស់រិទ្ធិមានពណ៌មានក្លិនមាន

រសល្អ តែផ្តិលនោះច្រឡាក់ថ្នាំពិស ។ កាលបើមានបុរសអ្នក
ចង់តែរស់ មិនចង់ស្លាប់ចង់តែសុខ ខ្លើមទុក្ខ មកដល់ ។ បុរសនោះ
គួរដឹកទឹកនឹងផ្តិលសំរិទ្ធិនោះដែលខ្លួនដឹងថា អាត្មាអញដឹកទឹកនេះទៅ
ហើយ នឹងដល់នូវមរណៈឬដល់នូវសេចក្តីទុក្ខស្ទើរតែមរណៈដែរឬទេ? ។
- បពិត្រព្រះអង្គដ៏ចំរើនគេមិនដឹកទឹកនឹងផ្តិលសំរិទ្ធិនោះទេ ។

- មួយទៀតដូចជាអាសិរពិសមានពិសដ៏ពន្លឹក ។ កាលបើបុរសអ្នក
ចង់តែរស់មិនចង់ស្លាប់ ចង់តែសុខ ខ្លើមទុក្ខ មកដល់ ។ បុរសនោះ
គួរហុចដៃទាំងអស់ ឬហុចតែមេដៃឲ្យអាសិរពិសមានពិសដ៏ពន្លឹកនោះ
ដែលខ្លួនដឹងថា អាសិរពិសនេះចឹកអាត្មាអញហើយ នឹងដល់នូវមរណៈ
ឬដល់នូវសេចក្តីទុក្ខស្ទើរតែមរណៈ ដែរឬ? ។ - បពិត្រព្រះអង្គដ៏ចំរើន!
គេមិនហុចដៃឲ្យអាសិរពិសនោះចឹកទេ ។

ម្នាលសុនក្ខត្ត! តិក្ខុនោះឯងជាអ្នកសង្ឃឹមក្នុងផស្សាយតនៈទាំង ៦
ដឹងថាកិលេសជាឫសគល់នៃសេចក្តីទុក្ខ លុះដឹងដូច្នេះហើយ ក៏ជាអ្នក
គ្មានកិលេស រួចស្រឡះហើយ ព្រោះតែការអស់ទៅនៃកិលេស នឹង
បង្អោនកាយឬផ្គេកផ្លូវចិត្តទៅរកកិលេស ហេតុដូច្នេះ មិនដែលមាន
ខ្សោយ កំយ៉ាងនោះឯង ។

លុះព្រះដ៏មានព្រះភាគសំដែងព្រះសូត្រនេះចប់ហើយ សុនក្ខត្តលិច្ឆវីបុត្ត
មានចិត្តត្រេកអរពេញចំពោះភាសិតរបស់ព្រះដ៏មានព្រះភាគ ។ ចប់

# ឧកញ៉ាវិបុលរាជសេនា ង្វូ-កង ប្រែរៀបរៀង

( តមក )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
គឺឯបេះឧបាយកលបំណាន
ទាំងមានសង្គ្រានស្នេហារាជាតិ ។

តាន់លឹមទើបតែងសេចក្តីសំបុត្រនោះ ១៨ច្បាប់ សេចក្តីដូចគ្នាថា: "ព្រះមហាក្សត្រៃសោយរាជសម្បត្តិមកពីដើម ស្រុកទេសរមែងកើត "អន្តរាយផ្សេង ។ ព្រោះមានអ្នកភ្ញាំងពួកែប្រព្រឹត្តសេចក្តីទុច្ចរិតអាក្រក់ "ប្រទូសរ៉ាយទឹងផែនដី នាហ៊ុនមុខមន្ត្រីទាំងឡាយក៏នៅក្នុងអំណាច "អ្នកនោះ, ប្រការ ១ ព្រះមហាក្សត្រៃស្តាប់ពាក្យស្រីយកជាគ្រឹមុខ "ស្រុកក៏វិនាសអន្តរាយ, ប្រការ ១ ព្រះមហាក្សត្រៃស្តាប់ពាក្យ "មនុស្សអន្ធពាលទាំងឡាយ រាជសម្បត្តិរមែងវិនាសជាបរិយាបន្ន "ផ្សេង ។ ។ ១ដែលថា អ្នកភ្ញាំងពួកែប្រព្រឹត្តទុច្ចរិតអាក្រក់ នាហ៊ុន

"មុខមន្ត្រីតាំងឡាយនៅក្រៅមណ្ឌបទ្វារនោះ គឺគ្រាត្រេះថាដ៏នស៊ុ-
"អង្គតេ សោយរាជសម្បត្តិតាំងពីព្រះជន្មាយុ ៧ ព្រះវស្សា តៀវកោ
"ជានាហ្មឺនធំ ត្រេះថាដ៏នស៊ុអង្គតេទុកព្រះទ័យនឹងតៀវកោ ។ គិត
"ទុច្ចរិតអាក្រក់ក្សត់ជណ្តើមយករាជសម្បត្តិ គាន់ក្រមុំចូលគាល់ជាដរាប,
"នាហ្មឺនមុខមន្ត្រីតាំងឡាយ នៅក្រៅមណ្ឌបត្រៀវកោជាច្រើន, ថ្ងៃ
"១ តៀវកោចង់ដឹងថា បណ្តានាហ្មឺនខាងក្នុងតាំងនឹងតៀងត្រង់ច្រើន ឬ
"ជាមនុស្សប្រចុបប្រចែងច្រើនដាង ទើបឲ្យយកប្រឹស ២ ទៅបញ្ជរ
"កណ្តាលទីប្រជុំ ហើយតៀវកោនិយាយនឹងនាហ្មឺនតាំងឡាយថា យើង
"បាននេះ ២ នេះមក នរណាស្គាល់ច្បាស់ប្លែក ? នាហ្មឺនដែលទុច្ចរិត
"ប្រចុបប្រចែងនោះក៏បបួលគ្នាថា លោកបាននេះ ២ នេះមកពីណា
"ត្រូវលក្ខណៈល្អណាស់ ? ដែលថានេះតាមពាក្យតៀវកោនោះប្រមាណ
"៧ ភាគ នាហ្មឺនដែលតៀងត្រង់ប្រហែល ៣ ភាគធ្វើយថា ប្រឹសទេ
"មិនមែននេះ, តៀវកោបានពុតជូរច្រោះក៏គិតថា នាហ្មឺនតាំងសឹងតែនៅ
"ក្រៅមណ្ឌបអញ ៧-៨ ភាគអស់ហើយ តាំងពីនោះមកតៀវកោក៏
"កំរើកចិត្តគិតធ្វើការអាក្រក់តាមមណ្ឌបចិត្តគិតថា រាជសម្បត្តិនេះនៅ
"ក្នុងកណ្តាប់ដៃយើងហើយ, បណ្តានាហ្មឺនដែលមិនបានចូលគាំទ្រដល់
"នោះ តៀវកោក៏ក្រែងយកទោសខុសសម្លាប់បេញ្ញខ្លះ ដកហូតងារ
"បេញ្ញពីដំណែងរាជការខ្លះ ។

"ខណៈនោះ ព្រះចៅជិនស៊ីអង តេនឆិនាហ្នឹនសព្វមុខទ្រូនៅ
"អស់អាណាប្រជានុកស្ត្រ សឹងតែក្តៅក្រហាយខ្លួនាំងផែនដី, នាហ្នឹន
"មុខមន្ត្រីឯណាដែលសុចរិតពិតត្រង់នឹងព្រះមហាក្សត្រ ក៏តតែមគ្នា
"ចាប់ខ្លួនតៀវកោនឹងគណៈញាតិសម្ងាប់ចេញអស់; រីសេចក្តីអាក្រក់
"របស់តៀវកោក៏មានថ្កុតដរហូតមកដល់សព្វថ្ងៃនេះ ។

"ខដែលព្រះមហាក្សត្រដឿស្តាប់ពាក្យស្ត្រីនោះ គឺកាលគ្រាព្រះ
"ចៅហាន់កោចោចបានសោយរាជសម្បត្តិ មានព្រះទ័យស្រឡាញ់នាង
"លីហៅជាព្រះមហេសីណាស់ បើនាងលីហៅនឹងពិតឲ្លូលពីរឿងអ្វី
"ព្រះចៅហាន់កោចោចេះតែដឿស្តាប់គ្រប់ប្រការ ហើយព្រះចៅហាន់
"កោចោតាំងលីឆ័ននឹងលីឡុក ដែលជាបួននាងលីហៅឲ្យធ្វើនាហ្នឹន
"ជំរ៉ូងស្តាំ ឯលីឆ័ននឹងលីឡុកនោះគោះនឹងចូលទៅខាងកងកំបាន ប៉ើ
"នឹងធ្វើការអ្វីក៏មិនបានកោតក្រែងព្រះទេស្តា ប្រើអំណាចតំរាមកំហែង
"រំបៃកទ្រព្យរបស់អស់ បណ្តាភស្តុខ្លះ, សម្ងាប់ម្ចាស់របស់ចេញខ្លះ,
"នាហ្នឹនក៏ទៅកងអំណាចលីឆ័ននឹងលីឡុកតាំងអស់, បើមានមនុស្សមក
"ប្តឹងសាទុក្ខពោលទោសលីឆ័ននឹងលីឡុកថា កំហែងកំចោកពេកភស្តុ
"ដោយប្រការម្តេច ។ នាងលីហៅក៏ទូលទាស់ព្រះចៅហាន់កោចោ ។
"ក៏ដឿស្តាប់ ម្ល៉ោះហើយអាណាប្រជានុកស្ត្រតាំងឡាយ ក៏បាន
"សេចក្តីក្តៅក្រហាយខ្លួទៅតាំងផែនដី, លុះអំណើះតមកព្រះចៅហាន់-

" គោះចាន្រ្តែដ៏សុវណ្ណគត លីធ័នទឹងលីឡុកកំរើកចិត្តគិតតាំងខ្ជួនឡើង
" ៖សោយរាជសម្បត្តិ ចំណែកដីប៉ុន្តែទឹង៖ឡុះដៀងជានាហ្មឺនធំ នៅកន្លែង
" ក្រុងដែលជាមនុស្សខៀងត្រង់ទឹងផែនដី រិះគិតបបួលគ្នាចាប់ខ្ជួន
" លីធ័ន លីឡុក ទឹងវង្សាគណ៖ញាតិបងប្អូនសម្លាប់ចេញអស់ហើយ
" កំអញ្ជើញអាន់ប៉ុន្តែ ជាព្រះរាជបុត្រឡើងសោយរាជសម្បត្តិ ជាម្ចាស់
" ផែនដី ស្រុកទេសក៏ជាសុខក្សេមក្សាន្តតមក ។

" ១ដែលជាព្រះមហាក្សត្រដឿស្តាប់ពាក្យមនុស្សអន្ធពាលនោះ គឺ
" ព្រះចៅហាន់តេបានសោយរាជសម្បត្តិ ហើយដឿស្តាប់ពាក្យ១ន្ធីតាំង
" ពួង គ្រានោះចោរថេងជាបិតាបួនធ្លូធ្លើជានាហ្មឺន រួមគំនិតគ្នាទឹងពួក១ន្ធីធ្លើ
" ការខុច្ចិតប្រព្រឹត្តអាក្រក់ទឹងផែនដី ប្រទេសក៏កើតចលាចលប្រែប្រួល
" ច្បាប់ទម្លាប់ត្រឡប់យកខុសជាត្រូវ ជាប់ជាលំដាប់តមកដល់សម័យ
" នេះ, លុះព្រះចៅហ៊ុនតេបានសោយរាជក៏បានសេចក្តីក្តៅក្រហាយ
" ក្នុងព្រះរាជហ្ឫទ័យមកជាច្រើនគ្រា។ នេះបួនមានសេនាឳហានជាច្រើន
" ហើយមានចិត្តកំរើកទឹងធ្វើការអ្វី។ ក៏ប្រែទៅតាមអំណាចអំពើចិត្ត ឥត
" គោតក្រែងព្រះចេស្តាព្រះមហាក្សត្រ ប៉ង់ទឹងដណ្តើមយករាជសម្បត្តិ
" ដើម្បីខ្លួន សូន្យអស់ទំនៀមទម្លាប់ច្បាប់ដែលល្អក្នុងព្រះនគរជាវរើក
" ពន្ធឹកណាស់, ព្រះចៅហ៊ុនតេសព្វថ្ងៃនេះក៏មានព្រះរាជហ្ឫទ័យរំដួល
" ក្តៅនៅជានិច្ចតិចបានសុខ ។

"យើងឈ្មោះអ្នកនៅវៀវចៅហ្វាយស្រុកគីជីវ ជាពូជនាហ្មឹនតមកពី
"ដើម មានចិត្តថ្លើមខ្លៀតតែងនឹងផែនដី គិតឃើញថា ចូរធ្វើជាមនុស្ស
"អប្រិយខុចូរតែអាក្រក់ខ្លាំង ប្រែងនឹងធ្វើសេចក្តីប្រទូសរ៉ាយដល់ព្រះមហា
"ក្សត្រ យើងក៏រៀបចាត់លើកកងទ័ពទៅនឹងកំចាត់ចូឆួ ដែលជាខ្មាំង
"សត្រូវនឹងផែនដីនោះឲ្យសាបសូន្យ ដើម្បីជាទីតបស្នងគុណព្រះតេជៈ
"ព្រះគុណព្រះចៅហៀនតេជាអម្ចាស់, បើចៅហ្វាយខ្លែតាំង ១៨
"មណ្ឌលយល់ឃើញ សំបុត្រយើង ដែលនាំមកដល់បិទទុកនៅទ្វារស្រុក
"នេះកាលណា ក៏ត្រូវឲ្យមានចិត្តគិតកត្ញូដល់ព្រះចៅហៀនតេ នឹង
"ព្រះមហាក្សត្រអំពីបុព្វណាផង កុំឲ្យចៅហ្វាយតាំងឡាយនឹងបណ្តា
"កស្តេនានាប្រែចិត្តទុច្ចរិតទៅចូលគំនិតខាងចូឆួជាជាប់ខាត" ។

លុះតាន់លឹមតែងសំបុត្រដូច្នេះរួចហើយ អ្នកនៅវៀវក៏ប្រគាហាន
ស្រួតរួតយកសំបុត្រនោះទៅបិទនៅទ្វារស្រុកតាំង ១៨ មណ្ឌល; លុះ
ដល់ថ្ងៃឯកឫក្សល្អអ្នកនៅវៀវក៏នាំតាន់លឹម នឹងសេនាពាហនលើកជាក្បួន
ទ័ពទៅដល់ដំបន់ស្រុកលឹមយ៉ុងចុងដែនស្រុកហ៊ូគោ ហើយឲ្យបញ្ឈប់
កងទ័ពតាំងបន្ទាយនៅទីនោះ ។

ឯណៈនោះពាហនចូឆួ លុះឃើញសំបុត្រដែលអ្នកនៅវៀវឲ្យចំរើនាំ
ទៅបិទតាមទ្វារស្រុកដូច្នោះ ក៏ចំឡងតាមរឿងសេចក្តីហើយនាំយកទៅ
ឲ្យចោហាន់នៅក្នុងក្រុងហ៊ូគោ ។ ចោហាន់យកសំបុត្រនោះទៅបង្ហាញ

ចូរឆ្ង ។ ពេលនោះចូរឆ្ងកំពុងមានជម្ងឺឈឺដេកនៅខាងក្នុង លុះបានទទួលសំបុត្រនោះមើលដឹងសេចក្តីហើយ ក៏បង្កើតទោសៈពេញក្នុងហឫទ័យតែម្តង ទើបគាត់ហូរចេញមកគ្រប់សរសៃលោមា ទើបគ្រាកឡើងសួរចាហង់ថា សំបុត្រនេះនរណាអាចដឹងថាឈ្មោះណាតែង? ។ ចាហង់ដាក់បថា ខ្ញុំបាទបានដឹងដំណឹងថា សំបុត្រនេះគឺតាន់លឹមជាអ្នកតែង ។

ចូរឆ្ងបានស្តាប់ដូច្នោះក៏និយាយថា អ្ជូនសៀគិតធ្វើការធំដូច្នេះព្រោះមានអ្នកមានសតិបញ្ញា តែថាសេនាភាហានដែលមានថ្វីដៃខ្លាំងពូកែនោះគ្មាន បើប្រសិនជាមានព្រមគ្នាតាំង ២ ៣ ង៉ ឃើញថាអ្ជូនសៀនឹងធ្វើការនោះសម្រេចបាន គួរស្តាយតាន់លឹមដែលជាមនុស្សមានសតិបញ្ញាហើយទៅនៅនឹងអ្ជូនសៀជាការឥតប្រយោជន៍សោះ ។ ដល់នោះចូរឆ្ងក៏ឲ្យហៅទីប្រឹក្សាតាំងពួងមកពីគ្រាថា គ្រានេះអ្ជូនសៀវលើកទ័ពមកយើងនឹងគិតចេញតតាំងច្បាំងឬប្រការម្តេច? ។

ទុងយ៉ុងទ្វើយថា អ្ជូនសៀវលើកកងទ័ពមកពេលនេះធំពន្លឹកណាស់ ឃើញថាកំឡាំងយើងនឹងតស៊ូមិនបានទេ សុំឲ្យលោកព្រមនុស្សទៅនិយាយបញ្ចុះបញ្ចូលជាផ្លូវចរចាស្ងួនមេត្រីនឹងអ្ជូនសៀដោយល្អ មុខជាអ្ជូនសៀនឹងលើកទ័ពត្រឡប់ទៅវិញ ។

(មានត)

ជាលៈនិង ទមយន្តី

រឿងព្រេងប្រទេសឥណ្ឌៀ

# អ្នកស្រីស្រ៊ុន-សារីយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

## ប្រែពីភាសាចាំងមកជាភាសាខ្មែរ

(តមក)

---

នាគបង្គាប់ទៀតថា: "សូមព្រះករុណាទ្រង់ព្រះពស្ត្រនេះទៅ ហើយទ្រង់ទៅធ្លុះមើលរូបព្រះមង្គកុដទឹកអូរនោះ" ។

ព្រះចាទនាល:ទ្រង់ឧនព្រះកត្តៀទៅក្នុងអូរស្រាប់តែទ្រង់ថយវិញ ។

នាគៈសើចក្អាកក្អាយ "ព្រះអង្គទ្រង់ខ្លាចតែរូបខ្លួនឯង អាវនោះមានអានុភាពនឹងផ្ទាស់ព្រះកំឡុងទ្រង់, ដរាបណាតែព្រះអង្គទ្រង់អាវនេះដរាបនោះព្រះអង្គមានរូបអាក្រក់តែលែង, គ្មានអ្នកណាមួយអាចស្គាល់ទ្រង់ចាន់ឡើយ សូមព្រះអង្គយកព្រះនាមជាវាហុក: (Vahuka សូមស្តេចយាងទៅឯនគរអយុធ្យា (Ayodhya) ហើយចូលទៅថ្វាយខ្លួនជាបំរើព្រះចាន់តុបនិ: (Rituparna) ព្រះអង្គនឹងទៅជាអ្នកឃ្លាសេះ ទោះការនោះថាកខាបលំចាកយ៉ាងណាក៏ដោយ សូមទ្រង់ចេះតែគាំទៅ កុំភ្លេញភ្លែត ព្រះអង្គនឹងលែងតូចព្រះហឫទ័យនៅវេលាដែលទ្រង់ចានដួបព្រះនាងទមយន្តីនៅពេលនោះ ចូរព្រះអង្គដោះអាវក្រហមនេះគ្រវាត់ចោលទៅ ព្រះអង្គនឹងមានរូបឆោមលោមពណ៌ល្អឡើងវិញដើម្បីនឹង

បង្ហាញព្រះអង្គ នៅចំពោះព្រះភ័ក្ត្រព្រះនាងទមយន្តី ដែលជាធ្នើមព្រះទ័យព្រះអង្គ" ។ ថាតែប៉ុណ្ណោះ នាគក៏រលាយបាត់ដូចជាផ្សែងចុះអ័ព្ទ ។ ព្រះបាទនាលៈទ្រង់ពាក់អាវក្រហមហើយយាងសំដៅទៅឯក្រុងអយុជ្ឈា ។

## ភាគទី ២៧

ព្រះបាទនាលៈបានយាងមកដល់ក្រុងអយុជ្ឈា លុះដល់ថ្ងៃទីពីរទ្រង់ក៏សុំចូលធ្វើជាអ្នកឃ្វាលសេះហ្វូងបានដោយងាយ ។ វស្ន័យ (Varshneya) ជានាយដំរួតសេះស្តេច មុនដំបូងប្រើទ្រង់ឲ្យធ្វើការយ៉ាងលំបាក ប៉ុន្តែទ្រង់ចេះតែបំពេញកិច្ចដោយស្រួល ។ វស្ន័យក៏កាន់តែពាប់អានទ្រង់បន្តិចម្តងៗ ។

ព្រះបាទនាលៈទ្រង់ចេះតែថ្នរនឹងលួចទ្រង់ព្រះកន្សែងជារឿយៗ ហើយតែងមានបន្ទូលវអ្ញតែមួយអង្គឯងថា: "នាងនៅឯណា? នាងធ្វើអ្វី? សូមកុំឲ្យតែនាងស្ងាប់ដោយទុក្ករ! តើអាវរហែកនោះ អាចគ្រប់កុំឲ្យនាងរងាបានឬទេ? តើនាងនឹកឃើញដល់មនុស្សអកុសលដែរទេ? តើនាងដឹងថាខ្ញុំនៅឯណា?" ។ រំលាយបន្តួច វស្ន័យ ក្តុសួរវហុក: និយាយគួញត្អែរដោយពាក្យក្រលួច ជាអ្នកពិបាកចិត្តជាងយប់មុនៗទៀត ថា: "នាងនៅឯណាទៅហ្ន៎? តើនាងកំពុងតែធ្វើអ្វី? តើនាងនឹកដល់បុរសអកុសលទេ? ។ វស្ន័យ ក៏សួរទៅវហុក:ថា: "វហុក: ហេតុ

ម្តេចបានជាឯងដេកថ្ងូរដូច្នេះ? ឬមែលជាឯងមានការព្រួយឬ? ខ្ញុំបាន
ឮឯងនៅពេលដែលឯងកំពុងតែយំ កំពុងតែដកដង្ហើមធំជារៀងដង
ណាស់មកហើយ, កុំលាក់ទង្វើខ្ញុំៗជាសំឡាញ់ឯងទេ តើឯងនឹកស្រណោះ
ស្រីដែលឯងស្រឡាញ់ណាមួយឬ ឬជាឯងថ្ងូរដល់ម្ល៉េះ?" ។

វហុកៈនិយាយមួយៗ ធ្វើយមកវិញៈ "ខ្ញុំបានឮដល់សំឡាញ់
ខ្ញុំបានម្នាក់ ដែលប្រកបដោយចិត្តជាបណ្ឌិត ឆ្លងដោយសេចក្តីសុខ
គ្រប់ប្រការ ប៉ុន្តែថ្ងៃមួយវាបានធ្វើឲ្យអាទិទេពអាក់អន់ស្រពន់ចិត្ត តាំងពី
ថ្ងៃនោះមក វាធ្វើមារយាទដូចជាមនុស្សឆ្កួត ប្រពន្ធវាជាស្រីប្រកប
ដោយលក្ខណៈ ល្អលើសស្រីកង៉ាលោក បុរសអកុសលនោះមិនប្រព្រឹត្ត
តាមពាក្យសន្យាជាមួយគ្នា ហើយឥឡូវនេះមិនដឹងជានាងនោះនៅឯណា
ធ្វើការអ្វី បើប្តីចិត្តអាក្រក់លះបង់ចោលដូច្នេះ? មិនដឹងជានាងនៅវង្វេង
វល់កង្វៃស្ទើរស្ងាប់ ស្ទើរវង្វេងឬយ៉ាងណា? ចំណែកបុរសដែលចេះតែ
ដើរទៅទៀតនោះ ក៏ស្គាល់តែសេចក្តីស្កប្រកាយនឹងសេចក្តីទុក្ខគ្មាន
ល្អ. ទុក្ខធ្ងន់នេះហើយដែលធ្វើឲ្យបុរសនោះ ខានស្គាល់ពេលសំភក
ព្រោះវាចេះតែគិតមមៃទៅស្រីដែលវាបានដើរចោល, ប៉ុន្តែក្រោយមក
បុរសតំណាចរកបានឱកាស្រួយមួយ វានៅតែមិនសប្បាយចិត្តទៀត
ដោយសារវាបានធ្វើប្រពន្ធ ដែលជាទីស្រឡាញ់របស់វាឲ្យធ្លាក់ទៅក្នុង
សេចក្តីទុក្ខ នៅពេលដែលកម្មអកុសលធ្លាក់មកលើខ្លួនវា, នាងនោះ

ចង់ទៅតាមវាទៀត ប៉ុន្តែទៅកណ្តាលព្រៃវាជាប់ចិត្តដើរចោលឲ្យនាងទៅតែឯងក្នុងព្រៃ, នុអាមនុស្សឲ្យត់ដោយគុណធម៌! តើបានអ្នកណាជួយយកអាសារនាង, វេស្ស័យ តើអ្នកស្គាល់អ្នកណាអាក្រែក់លើសមនុស្សដែលខ្ញុំបាននិយាយមកនេះទេ?" ។

វេស្ស័យស្តាប់រួចហើយ និយាយក៏មានសេចក្តីឆ្ងល់ ហើយនឹកក្នុងចិត្តថា: "ក្រែងខ្លួនវាទេដឹង ដែលបានប្រព្រឹត្តអាក្រក់ចំឡែកនេះ ប៉ុន្តែវាធ្វើជាថាសំឡាញ់វាទៅវិញ" ។

## ភាគទី ២៨

ព្រះបាទកិមៈ ទ្រង់ក៏បានជាបន្ទូលសេចក្តីអន្ទះអន្ទែងនៃព្រះបាទនាលៈនឹងព្រះនាងទមយន្តីដែរ ទ្រង់មានព្រះទ័យចង់ឃើញព្រះភ័ក្ត្រព្រះរាជបុត្រីភ្លាំងណាស់ ទ្រង់ក៏ត្រាស់បង្គាប់ឲ្យពួកព្រាហ្មណ៍ដើរតាមវេ: "ចូរឯងទៅរកកូនស្រីយើងនឹងព្រះបាទនាលៈឲ្យឃើញ ហើយទូលនាលៈឲ្យបានស្តាប់ថាយើងនឹងឲ្យគោមួយពាន់ ឲ្យចំការធំទូលាយនឹងឲ្យទីក្រុងធំក្នុងចំណោមក្រុងដែលយើងសោយរាជ្យសព្វថ្ងៃនេះ; អ្នកណានាំព្រះនាងទមយន្តី នឹងព្រះបាទនាលៈមកឲ្យយើងបាន យើងនឹងឲ្យរង្វាន់ជាទីគាប់ចិត្ត" ។

ពួកព្រាហ្មណ៍នាំគ្នាដើរវេតាមទីក្រុង ក្នុងស្រុកស្រែចំការ ប៉ុន្តែមិនមានមនុស្សអ្នកណាមួយបានប្រទះព្រះបាទនាលៈ ឬព្រះនាងទមយន្តីទេ ។

(មានត)

# លោក ផេង-ជ្រៃ សរស្តេចារឿងសៅសាគរប្តីជ្វាភ្នំពេញ

ប្រែពីភាសាចាវ៉ាំងមកជាភាសាខ្មែរ

(តមក)

---

## ចំពូក ៤

## ដំណើរទៅកាន់សេបក្តីស្លាប់

នាងឡឺឡាបែរមកវាកបងស្រីដែលចេះតែថ្លូជានិច្ច ហើយនិយាយច្រាបថា "អាឥស្សាតា! កុលសម្ពន្ធយើង កងទ័ពតួរគីនាំទៅអស់ហើយ"។

នាងខ្វាក់ពោលតបមកវិញថា "អា! ត្រូវយើងវត់ ឡឺឡា! ត្រូវយើងវត់ទៅកងវាលខ្លាច"។

នាងឡឺឡានិយាយថា: "ឧបងស្រីសំឡាញ់កំសត់! យើងវត់ទៅកងវាលខ្លាច! ប៉ុន្តែបងត្រូវនឹកដល់គ្រោះថ្នាក់ដែលយើងនឹងត្រូវជួបប្រទះសិន, ក្រែងកំឡាំងកាយយើងទាំដើរមិនបានឆ្ងាយទេដឹង"។

នាងអាឥស្សាតាពោលតបថា: "ម្នាលឡឺឡាមាសបង! អូនឯងស្គាល់ទីកន្លែងកងវាលខ្លាចគ្រាន់បើជាងលោកតាម៉ាត្រកផង, អូនស្គាល់កន្លែងដែលមានភូមិនៅជិត, កាលណាយើងបានដល់ភូមិនោះហើយមិនយូរប៉ុន្មានយើងនឹងប្រទះពួកឈ្មួញហើយ ពួកនេះមុខជានឹងព្រមទទួលយើងដោយសេចក្តីមេត្តាមិនខាន"។

តាមការណ៍ពិត នាងឡឺ ឡាស្គាល់ពាលឡាច់ឡាស់ ជ្រោកដដូចជាពួកចរចរក់ដែរ ។ នាងស្គាល់កន្លែងណាមានមនុស្សនៅ កន្លែងណាឥតមានមនុស្សនៅ ។ ដូចជាត្រង់កន្លែងឈ្មោះ អាប៊ូ-អ័ដជីឡាក្នងបណ្តាគុម្ពោតឈើ ទឹងពាលស្រែដែលលាតសន្ធឹងតាមមាត់ច្រាំងទន្លេ ប្រហែលជ្រុំពីរឬជ្រុំបីគីឡូម៉ែត្រ ហើយមានជរម្រៅទៅក្នុងប្រហែលជ្រុំឬជ្រុំមួយគីឡូម៉ែត្រ នាងយល់ឡាស់ក្នងចិត្តថាទៀងទឹងបានជួបប្រជាជនមួយពួកចិត្តល្អ ហើយទឹងបានទីពឹងជាជ្រោកដ ។

នៅត្រង់ដំរំព្រឹក្សឈ្មោះ "អ័សាវ៉ា" ក៏មានទំនងប្រហែលគ្នាដែរ ព្រោះនៅទីនោះ មានដីជាតិជាងភូមិឯទៀតៗ ក្នងពាលឡាច់ ហើយប្រកបដោយដើមគ្នោតដុះច្រងច្រាង ដើមផលព្រឹក្សទឹងចំការស្រែតែមួយចាំងមានបណ្តាជនប្រហែលបីមុឺននាក់ ។

នៅដំរំព្រឹក្សឈ្មោះទុមមិនដូច្នោះទេ គេត្រូវរង់ចាំដំណើរទៅមកនៃពួកឈ្មួញសិន ព្រោះកន្លែងនេះតូចពេក ដូចគ្នាទឹងកន្លែងខ្លះដែលនៅមាត់ពាលឈ្មោះ ក៉ាម៉ែល ទឹង ឡេបជា ដែរ គឺជាដំរំព្រឹក្ស ក្រៀមក្រៃស់គ្មានមនុស្សអាស្រ័យនៅ ហើយពួកកាប៉ាល់ស្រុកកាហ្គ៉ាណា តែងមកប្តូរយកផ្លែឈើ ក្នងមួយឆ្នាំម្តងជាវៀងពាល់ឆ្នាំ ។

វេលានោះ នាងឡឺ ឡាដឹងច្បាស់ថានាងទឹងត្រូវជួបប្រទះនូវសេចក្តីលំបាកជាជ្រោកដ សូម្បីធ្វើដំណើរគ្រាន់តែត្រឹមដំរំព្រឹក្សនៅយ៉ាងជិតក៏

ដោយ ។ ការធ្វើដំណើរកាត់ភលខ្លាច់ សូម្បីតែពីរ ប៊ីត៍ឡូម៉ែត្រ ជា
កិច្ចហួសកំឡាំងរបស់ក្មេងអាយុម្ភៃឆ្នាំ បើកាលណាគេមិនទៅដោយខ្នង
សត្វអូដ្ឋទេ ។

នាងឡឺឡាតប់ប៉ម៉ាល់ក្នុងចិត្តពេក ដោយនឹកដល់សេចក្តីលំបាកខាំង
នោះ ហើយការប្រែផ្លូនៃទុក្ខវេទនានៅក្បែរ។ ចេះតែកើតមានក្នុងចិត្ត
មិនចេះអស់មិនចេះហើយ ។ នាងនឹកថា ភលខ្លាច់ជាកន្លែងគ្មាននណា
ស្គាល់ផងជារហ័សភាពផង ។ ដីខ្លាច់ធំចាំបហាច លាតសន្ធឹងទៅឆ្ងាយ
ជាច់តន្ទុយក្អែក គួរឲ្យតក់ស្លុតស្រប់ស្រែងរៃពេក ។ ទោះបីនាងនៅក្នុង
វ័យជាយុវភាព តែឡឺឡាហាក់ដូចជាយល់ច្បាស់ឯង។ ថា នាងនឹងប្រទះ
សេចក្តីទុក្ខមិនខាន ។

នាងស្ញើការណ៍នឹងបងថា: "បើប្រសិនយើងទៅតាន់ត្រែង កាស៊ី-
ភាពប៊ូលី ដូចជាស្រួលជាង? យើងប្រហែលនឹងបានជួបសេចក្តីទុក
បុំរុងរបស់ជនអ្នកដែលធ្លាប់ទិញទំនិញលោកតាម៉ាត្រែតមិនខាន" ។

ប៉ុន្តែនាងអាត់ស្ញាតា ប្រកបដោយសន្តានតឹងរ៉ឹងនៃបុគ្គលភូមិល-
ភាពនឹងគីលានភាព ព្រោះសេចក្តីទុក្ខវេទនានៃបុគ្គលពួកនេះតែងធ្វើ
មនុស្សដឹតខាងខ្លួនឲ្យទៅជាមានសន្តានចេះអត់ធន ឲ្យទៅជាមានចំលាប់
មិនចង់ដំនាស់ដល់ចិត្តស្ម័គ្រេចរបស់គេ នាងធ្វើយតបតាំងយំខ្សឹកខ្សួលថា:
"យើងត្រូវតែ ឡឺឡា! យើងត្រូវតែ! បងសូមអង្វរ ចូរអូនស្តាប់បង" ។

ខណៈនោះ នាងឡឺឡាឃើញកងស្បាតគាហានសេះ ចំដាយសេះក្នុងរលែកកុំ ហើយបីដូចជាបរសំដៅមករកនាង ។ ប្រែហែលពួកនេះនឹងដួលប្រែនាងកុមារីតា ឬ ដួលម្តេច ? ។

ក្នុងពេលនោះ ការអង្វរញាយ ។ សេចក្តីខ្លាចរបស់អាឥស្បាតាដែលទៅជាដម្លឹងធ្ងន់ សេចក្តីភ័យខ្លែងខ្លាក់ទៅក្នុងកណ្តាប់ដៃនៃកងគាហាន ក៏រណ៌ទាំងអស់នេះហើយ ដែលសម្រែចឲ្យឡឺឡាលុះតាមបំណងរបស់អាឥស្បាតា ។

នាងនិយាយថា: មក បង! ។

នារីទាំងពីរនាំគ្នារំលៀទៅឲ្យហួសពីកដី ។ ចំណែកពពែទាំងឡាយគិតតែស៊ីស្មៅព្រៃដើយ ។ នាងឡឺឡាក្រឡេកមើលហ្វូងសត្វទាំងនោះដោយចិត្តអាណិត ។ មេពពែមួយកំពុងបំបៅកូន យុំម៉ែ។ ។

វេលានោះ ឡឺឡាចាប់ដឹកដៃអាឥស្បាតា នាងក្រមុំទាំងពីរនាំគ្នាចុះទៅដម្រាលខ្នងភ្នំមាង រួចក៏ស្ថិតនៅកងទីចំពោះមុខវាលខ្ចាប់ធំល្ហល្លៅ ។ ចំហាយខ្សល់ត្តៅកាយៗបក់ចូលដល់កងចំពង់ករបស់នាង ។

នាងឡឺឡាទ្រង់ញញើតញញើម មិនបានដាច់ស្រែចមួយស្រែបក់ប៉ុន្តែពេលវេលាកាន់តែលឿនទៅមុខ ។ ព្រះអាទិត្យលិចចុះជាត់ឯដើងមេឃ ។

ខណៈនោះ ឈប់គិតគូរអ្វីទៀត នារីទាំងពីរក៏ដាច់ចិត្តដើរឆ្ងាកាត់វាលផកខ្ចាប់ ។ អាឥស្បាតាមានទ័កមុខស្រស់បន្តិច ព្រោះនាងនឹកស្មានថានឹងបានរួចខ្លួនហើយ ។ ខុ! ប្រសិនជានាងដឹងថា...! ។

មុនដំបូង នាវបង់ប្អូនដើរទៅ បៃបស្រួលគួរសម ។ ប៉ុន្តែដើង
នាងដែលពាក់ទ្រនាប់ដើងសំបែត ៖ចេះតែផុងទៅក្នុងដីខ្សាច់ ហើយ
ក្រសត្តូច ។ ហូរចូលក្នុងជាតស្បែកដើងកកិតសាច់ធ្វើឲ្យនាងរំខានពេក ។
នាងដោះស្បែកដើងចោលដើរតែដើងទទេ ។ ផ្កខ្សាច់ច្រៃណាស់
បន្តគ្នាវកូត ហើយត្រូវឡើងចុះ ។ ពីមួយទៅមួយ ។ អាឥស្សាតាដែល
មានដំណើរមិនសូវប៉ិន ជាន់ប្អូនជាអ្នកដឹកដៃ ដើរមិនជាន់ប៉ុន្មាន ក៏
ភ្ញាក់ដំហានអិលដួលទៅលើដីខ្សាច់ ។ លុះគ្រាកឡើងវិញកាលណា
នាងថ្ងូរហិះ ព្រោះក្អែកគោរលាត់នឹងដីខ្សាច់ ។

នាងឡឺឡាយល់មួយរំពេច អំពីមូលហេតុដែលធ្វើឲ្យដំណើរ
នេះទៅជានោយពិបាក ឬ ជាទៅពុំជាន ។

ដំរឹត្រីក្សយ៉ាងដិតជាងគេបំផុត នៅចម្ងាយប្រហែលដប់ជុំ ឬ ម្ភៃ
គីឡូម៉ែត្រ ។ ក្នុងមួយយប់ នាងប្រហែលទៅមិនដល់ទេ ។ ឡឺឡា
អស់កំឡាំងជាត់សេចក្តីក្លាហាននឹងដើរទៅទៀត ។

នាងមានរាថានឹងបងស្រីថា: "អាឥស្សាតាមាសប្អូន យើងត្រូវ
ឈប់សិន ! ត្រូវយើងដេកជ្រកនឹងផ្កខ្សាច់នេះចុះ" ។

ប៉ុន្តែ នាងខ្លាក់ធ្លើយដំនាស់ថា: "ទៅ ! ទៅទៀត ! កុំឈប់ !
ត្រូវទៅឲ្យដល់ដំរឹត្រីក្សមុនថ្ងៃបួលរន្ធ បងខ្លាចណាស់ ឡឺឡា !" ។

នាងចំដើរទៅទៀត តែមួយដំហានថ្ងូរម្តង ។ ខណៈនោះនាង
ឡឺឡាឥញ៉ាដៃបងស្រីម្ខាងមកឲ្យកៀកនឹងកន្ទួន ហើយនាំគ្នាដើរបៃបនេះ

ត្នង់កាត់ព្រៃចំអស់មួយសន្ទុះធំ ទើបឡឺឡាដឹងជាបងស្រីទន់ដង្គង់ ។ នាងភ្ញាក់ដួលពោបលើព្រៃចំ ។ ប្អូនស្រីនុនមើលបងឃើញក្អែកគោហើមឡើងឃ្លិប ឃើញទឹកក្អែកហូរចេញរហាមពីកលចក្ខុ ។

អាឥសិតានិយាយប្រាប់ប្អូនដោយសំដីត្រួយថា: "បងទៅទៀតអស់រួចហើយ! បងទៅអស់ជានហើយ! ។

នាងឡឺឡាចាប់ទុបបងដោយចិត្តករុណា ហើយនាងដឹងថាបងស្រីក្តៅខ្លួនខ្លាំង ។ គឺចិសាចកងពលព្រៃចំបៀតបៀននាង ។

អាឥសិតាប្រាប់ប្អូនថា: "ចូរប្អូនស្រែកទៅ! ស្រែកហៅគេមកជួយ, ដំណើរមកទីនេះចំណាត្រឹលសោះ. បើធ្វើជាឈ្មីយពួកតួរគីស្រួលជាងាយ មិនគួរមកស្ងាប់នៅកណ្តាលព្រៃចំអសារឥតការណ៍ ។

នាងឡឺឡាងាកមើលជុំវិញខ្លួន ហើយដឹងថានាងស្ថិតនៅកងជង្រុកមួយមានផ្ទុកព្រាចំព័ទ្ធជុំវិញ ។ បើដូច្នេះ ខ្លួននាងដូចជានៅជាប់ឆ្ងាយពីមនុស្សផងទាំងពួង ។ តើនឹងមានអ្នកដំណើរវង្វេងផ្លូវឯណាដូចនាងនឹងអាចមកជួយសង្គ្រោះ? ម្ល៉ោះហើយនាងនឹកអំពាវនាវតែកងចិត្តសូមឲ្យព្រះអាឡស់ជួយ ។

អាឥសិតាប្រាប់ថា: "ឡឺឡា! អូនឯងនៅដើរបាន! ចូរអូនរត់តាមពួកទំព ហើយសុំឲ្យអ្នកណាម្នាក់មកជួយបងផង ។

(មានត)

# រឿងបល័ង្កជិត្យ សាមសិបពីររឿង

រឿងព្រេងឥណ្ឌៀ

លោកសមិន ម្ចុត្ស៊ែនដឹម: តែង
លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

## បុព្វប្រយោគ

នៅប្រទេសឥណ្ឌៀភាគខាងត្បូង មានទីក្រុងមួយឈ្មោះធារ ។ នៅជិតទីក្រុងនោះ មានទន្លាន់មួយដាំស្រែវាលី ឈ្មោះ សម្ពន្ធករៈ ជារបស់នៃអ្នកក្សៃត្រកវ ឈ្មោះយជ្ញទត្ត ។ អ្នកក្សៃត្រកវនេះ ឋានដ៏កចង្អួរដុំវិញចម្ការ ហើយបានដាំព្រឹក្សជាតិផ្សេងៗ ជាច្រើន គឺដើមសាលៈ, តាលៈ, តមាលៈ, បិយាលៈ, ហិន្តលៈ, វកុលៈ, អម្រៈ, អម្រាតកៈ, ចំបកៈ, អសោកៈ, កិម្សុកៈ, វកៈ, គុវ៉ាកៈ, នារិកេលៈ, នាយកេសារៈ, មាធវី, មាលតី, យុថី, ជាតី, សេវតី, តទលី, កេរៈ, កុន្ទៈ, មលិកាៈ, ទេវទារុ . . . . ល . . . . ; អ្នកក្សៃត្រកវនោះ ក៏ចាត់ចែងធ្វើជាទន្លាន រួចហើយក៏តាំងសង់គេហដ្ឋានមួយនៅទីនោះ ។

នៅជិតទន្លាននោះ មានវនប្បទេសមួយធំសម្បើមអស្ចារ្យ ដែលមានសត្វ ដំរី, ខ្លា, ក្រចៃ, រមាស, ស្វា, ជ្រូកព្រៃ, ទន្សាយ, ខ្លាឃ្មុំ, ប្រើស ទំនងសត្វឯទៀតជាច្រើន ចេញចូលទៅមកបរិភោគនូវដំណាំតាំង

នោះ ។ ដោយហេតុនេះ ទាំងឲ្យយដ្ឋគត្ត មានសេចក្តីគោរពនូវ
ជាខ្លាំង ហើយក៏ស្ថាបនានូវសុទ្ធិយដ្ឋាន (Observatoire) មួយនៅ
កណ្តាលទន្យាន ហើយក៏ឡើងទៅនៅលើទីនោះ ដើម្បីទទឹងយាមល្បាត
ការពារកុំឲ្យសត្វទាំងនោះមកបំផ្លាញដំណាំបាន ។

កាលណាបើបុរសនោះស្ថិតនៅលើសុទ្ធិយដ្ឋានដរាបណា, បុរស
នោះតែងបង្គាប់, ចាត់ការ, ពោលពាក្យសំដីដូចជាព្រះអគ្គិភជ ដែល
ធំលើសព្រះមហាក្សត្រិយ៍ទាំងពួង គ្រាស់បង្គាប់ ចាត់ព្រះពលញ្ញត្តិ,
មានព្រះពលធុង្គារនូវព្រះបន្ទូលសូរសិរិសាទ ។ ដល់យដ្ឋគត្ត ចុះ
ពីសុទ្ធិយដ្ឋាន ក៏ត្រឡប់ជាបុគ្គលមានសតាពជាសាមញ្ញទៅវិញ ។
ពួកជនអ្នកនៅជិតខាង នៃអ្នកកសិកនេះបានឃើញការការៈថ្មែកដូចនេះ
មានសេចក្តីឆ្ងើងធ្ងល់ពន់ពេក ហើយក៏និយាយជជែកគ្នាពីការថ្មែក
អស្ចារ្យនេះ ។ សំដីទាំងនោះពោលតៗ គ្នាទៅ ក៏បានជ្រាបទៅដល់
ព្រះស្រោតនៃព្រះបាទកោជៈ ព្រះមហាក្សត្រិយ៍នៃព្រះនគរធាក ។
ព្រះពជា, ដោយមានព្រះទ័យចង់តន្ទូអាកប្បកិរិយាចំឡែកនោះ ក៏ទ្រង់
យាងចេញពីព្រះពជនិវេសនដ្ឋានទៅកាន់ទីនោះ មានព្រះពជបរិពារហែ
ហមទៅផង គឺ ព្រះពជទ័ប្រីក្សា, ពួកសេនាគាហាន, កងទ័ពនឹង
មេបញ្ជាការកងទ័ព ។ លុះយាងទៅដល់ទីនោះ ព្រះអង្គទ្រង់ឃ្លាតទត
យល់នូវអាកប្បកិរិយាដោយព្រះនេត្រដូច្នេះ ក៏ទ្រង់គ្រាស់បង្គាប់ឲ្យព្រះ

ពាដទ្រីកូវម្នាក់ ដែលព្រះអង្គមានព្រះទ័យទុកចិត្តឲ្យឡើងទៅលើទស្សនីយដ្ឋាននោះ ។ ព្រះពាដទ្រីកូវកាលឈរនៅលើទីនោះ ក៏បង្អាប់រៀបចាត់ការសម្រែចកិច្ចផ្សេង ។ ដូចជាព្រះអគ្គិពាដដែលមានព្រះពាដហានន្តរសំគ្គិឲ្យសំដាងមហាពាដគំងួន ។ លុះព្រះកុណាឲ្យនំតសព្វគ្រប់, ទ្រង់មានព្រះតម្រិះថា "គុណសម្បត្តិបែបនេះ មិនមានហេតុគាត់ទង្គានឹងទស្សនីយដ្ឋាន ឧទ្ធឹងអ្នកកសិករឬ ព្រះរាជទ្រីកូវសោះឡើយ, ប្រហែលនៅទីនេះមានវត្ថុអ្វីមួយប្លែកអស្ចារ្យ ឲ្យជានាំចិត្តអ្នកកសិកនេះឲ្យតាំងខ្លួនជាស្តេច" ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះយោបល់យ៉ាងនេះហើយ ក៏ទ្រង់គ្រាស់បង្គាប់ឲ្យដឹកគាស់ដីចម្ការ ដើម្បីឧទ្ធឹងរកទូវត្ថុនោះ ។ ពួកបរិវារបានទទួលព្រះពាដឧង្ការហើយ ក៏នាំគ្នាដឹកគាស់កកាយដីនោះ, ស្រាប់តែផុសព្រះពាដបល្ល័ង្កមួយមានរចនាដោយកែវភ្លឺផ្លេកដ៏រិចិត្រ, សម្រស់អស្ចារ្យ, មានស្មើចែងចាំងបង្ហាញនូវរូបទេពនិម្មិតសាមសិបពីរ មានកំពូលដាំតូងផ្សេង ។, រចនាដោយផ្កាថ្ម, មុក្តា, ទទឹម, ពេជ្រ, កែវ, ច្ញើមថ្ម, មរកត ។ ព្រះបល្ល័ង្កទិព្យនោះចោលរស្មីភ្លឺស្វាងរុងរឿងអស្ចារ្យ ពាល់តែព្រះមហាក្សត្រិយ៍ទឹងបរិវារស្រែកាំងមិនអាចទតមើលបាន ។

ព្រះមហាក្សត្រិយ៍ទ្រង់មានព្រះពាដឫទ័យសោមនស្សពន់ពេក ដោយទ្រង់បានទតយល់នូវព្រះបល្ល័ង្កទិព្យនោះ ក៏ទ្រង់មានព្រះពាដចំណងចង់

ឲ្យអាមាត្យសែងព្រះបល្ល័ង្កទិព្យយកទៅដំកល់ទុក នៅក្នុងព្រះមហាប្រាសាទ ហើយទ្រង់ត្រាស់បង្គាប់ទៅអាមាត្យសេនាតំង នាះឲ្យធ្វើតាមព្រះពាជនុង្ការ ។ អាមាត្យតំងអស់ព្រមតំងព្រះពាជបរិវារ ក៏នាំគ្នាទំលើកព្រះបល្ល័ង្កទិព្យនោះឥតការក្រែកពីទីកន្ទែងសោះ ។

ក្នុងទុកាសនោះ, ស្រាប់តែមានសំឡេងមួយស្រែកពីលើអាកាសមកថា: "ទុមហាពាជ, ត្រូវព្រះអង្គធ្វើព្រះពាជពិធីអំណោយទូវសំពត់, គ្រឿងអលង្ការផ្សេង។ ទីន៏ត្រង់ទៀត ហើយបូជាចំពោះព្រះបល្ល័ង្កទិព្យនោះ ដោយជង្វាយព្រមតំងពលិកម្ម; ព្រះបល្ល័ង្កទិព្យនោះគេនឹងលើកចេញបានដោយងាយ" ។ ព្រះមហាក្សត្រិយ៍ទ្រង់បានសព្វនូវសំឡេងនោះ ក៏ទ្រង់ចាត់ឲ្យធ្វើតាមដូចពាក្យពោលខាងលើ កំបានលើកព្រះបល្ល័ង្កទិព្យចេញរួចពីទីនោះទៅ ។ ព្រះមហាក្សត្រិយ៍ទ្រង់បានចាត់ឲ្យសែងព្រះបល្ល័ង្កទិព្យនោះយកទៅដំកល់ទុកនៅព្រះនគរធាង, ត្រង់សាលប្រជុំគណៈវេដ្ឋមន្ត្រី ដែលមានសសរលោបលនដោយមាស, ប្រាក់, ផ្លាំង ទីន៏តែវ ។ ហើយព្រះអង្គមានព្រះពាជបំណងចង់គង់លើព្រះបល្ល័ង្កទិព្យនោះ; ព្រះអង្គទ្រង់មានព្រះពាជនុង្ការឲ្យហៅពួកបណ្ឌិតមកកំណត់ថ្ងៃនក្ខត្តឫក្ស ហើយឲ្យពួកអាមាត្យរៀបចំព្រះពាជដង្វាយសម្រាប់ពាជាភិសេក ។ ពួកអាមាត្យទទួលព្រះពាជនុង្ការហើយ ក៏ចាត់នាំទីកដោះគោ កំញាន, បុប្ផាផ្សេង។, រមៀត, លាមកគោញី, ព្រះភូស់, ធ័ត្រវត,

កន្ទុយសត្វផ្សេងៗ, កន្ទុយគោញី, កន្ទុយក្ងោក, ព្រួញ, អាវុធយុទ្ធោបករ, កញ្ចក់នឹងត្បូងឯទៀត របស់ពួកស្ត្រីដែលមានស្វាមី បុត្រាបុត្រីកាន់, ព្រមទាំងកណ្ឌផ្សេងៗ ដែលអាចរចនាព្រះពាជពិធីនោះឲ្យទៅជាមានសភាពទុឡ្ភវិភអស្ចារ្យ ។ ក្រៅពីវត្ថុទាំងនោះមានស្បែកខ្លាមួយមានពណ៌ឆ្មូត មានត្បូរផែនទំពិកពណ៌ភោកមានទ្វីបចុំពីរ ។ គឺជារបស់សរុបមូលហេតុទាំងប៉ុន្មានដែលបានបញ្ជាត្តិក្នុងសាស្ត្រ ចំពោះព្រះពាជពិធីរាជាភិសេក ។ ដល់រៀបចំរួចស្រេច ពួកអាមាត្យក៏ក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ឲ្យទ្រង់ជ្រាបសព្វគ្រប់ ។ លុះដល់ពួក គ្រូ, បុរោហិត, ព្រាហ្មណ៍, បណ្ឌិត, ព្រះពាជទេប្រឹក្សា, នាយក្រុមផ្សេងៗ, ពួកឥសាន, ទុត្តមបញ្ជាការកងទ័ព ចូលទៅកន្លែងព្រះពាជពោធិពិធីនោះព្រះបាទកោដៈ ទ្រង់យាងទៅដឹកព្រះបល្ល័ង្កទិព្យ ដើម្បីនឹងគង់ រួចចាត់ការអភិសេកកន្លងពេលនោះ ។

កន្លងវេលានោះរូបទេពនិម្មិតទីមួយ ដែលរចនាភ្ជាប់នឹងព្រះបល្ល័ង្កទិព្យ ពោលថា: "ទុព្រះមហាក្សត្រិយ៍, សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ទូលបង្គំដូចតទៅនេះ: ព្រះមហាក្សត្រិយ៍អង្គណាដែលមានព្រះគុណសម្បត្តិគឺមានព្រះពាជទ្រព្យច្រើនជាអនេកប្បការៈ មានព្រះទ័យសប្បុរសដ៏លើសលុប មានព្រះទ័យមេត្តាជាយ៉ាងក្រៃលែង មានតេជានុភាពដ៏វីរបុរស មានព្រះទ័យសោកំណប់ផុត មានព្រះពាជវិរិយភាពកាន់សីលធម៌មានពលភាពនឹងព្រះពាជកិត្តិយស, ព្រះមហាក្សត្រិយ៍អង្គនោះគប្បីអាចគង់លើ

ព្រះបល្ល័ង្កទិព្យនេះបាន; ព្រះមហាកស្សត្រៃយ៍ ដែលគ្មានព្រះពាជចរិយា ដូចខាងលើនេះ មិនអាចគង់លើព្រះបល្ល័ង្កទិព្យនេះបានឡើយ ។

ព្រះមហាកស្សត្រៃយ៍ទ្រង់សរនាទូវាចានៃរូបទេពនិម្មិតទីមួយនោះហើយ ក៏ទ្រង់មានព្រះបន្ទូលតបទៅវិញថា: "នែរូបអើយ, ឲ្យតែបុគ្គលណាមួយមកសូម យើងៗ ទើបំពេញការណ៍យកចិត្តរបស់យើងៗ ទើបធ្វើអំណោយទូវាមាសមួយ ល័ក្ខ (lac) កន្ទុះ ចំពោះបុគ្គលនោះក្នុង ។ ចំណែករឿងនេះ គ្មានមហាពាជអគ្គ្ណាមួយក្នុងពិភពលោក អាចមានព្រះទ័យសទ្ធាសប្បុរសជាងយើងទៀតឡើយ" ។

រូបទេពនិម្មិតនោះបានស្តាប់ព្រះពាជឧង្ការ ក៏មានភ័ក្ត្រពីរកញ្ជឹម ហើយទូលព្រះអគ្គថា: "នែព្រះមហាកស្សត្រៃយ៍ មនុស្សដែលគេទុកជាមហាបុរស មិនដែលអួតអំពីគុណសម្បត្តិរបស់ខ្លួនឡើយ ។ ព្រះអង្គទ្រង់សរសើរនូវព្រះគុណសម្បត្តិព្រះអង្គឯង ។ ដោយហេតុនេះហើយ បើតាមទូលបង្គំយល់, ព្រះអង្គមិនជាប្រុសើរណាស់ណាទេ ។ មនុស្សប្រុសើរ គឺមនុស្សដែលមានអ្នកដទៃសរសើរពីគុណសម្បត្តិដួសខ្លួន ។ បើអ្នកណាសរសើរនូវគុណសម្បត្តិខ្លួន ដោយខ្លួនឯង, ការសរសើរនោះគ្មានបានផលប្រយោជន៍អ្វីឡើយ ។ តែងមានអ្នកតាំងពួងពោលថា ធ្វើបែបនេះ ជាអកតញ្ញិយកិច្ច ដូចជាស្ត្រីដែលចចាប់សុតនខ្លួនដោយខ្លួនឯង មិនអាចធ្វើចិត្តខ្លួនឲ្យស្រើបត្រេកត្រអាលបាន ។ ហើយអ្នកដទៃពោលថាជាកិច្ចប្រកបដោយហិនតាត" ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្តាប់នូវសំដីរូបទេពនិម្មិតនោះ ទ្រង់មានព្រះទ័យអៀនខ្មាសពន់ពេក ហើយមានព្រះបន្ទូលតបថា: "នែរូបអើយ ព្រះចលុង្គិព្យនេះ តើជារបស់អ្នកណា? តើសម្រាប់ប្រើការយ៉ាងណា? សូមអ្នកពណ៌នារឿងក៏រមែកឲ្យយើងស្តាប់ក្នុងពេលឥឡូវនេះ" ។

រូបទេពនិម្មិតនោះក៏ថ្លែងថា: "ទ្រង់ព្រះអភិរាជ, សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវរឿងក៏រនៃព្រះចលុង្គិព្យ ដូចតទៅនេះ:

"នៅក្នុងនគរអវន្តី មានព្រះមហាក្សត្រិយ៍មួយអង្គទ្រង់ព្រះនាមព្រះបាទតរតីហរិ ។ ស្តេចនេះកាលទទួលរាជាភិសេកហើយ, ព្រះបាទវិក្រមទិត្យជាព្រះអនុជរបស់ព្រះអង្គ មានព្រះហ្ឫទ័យឫស្យាគរហានិន្ទាព្រះអង្គហើយ ទ្រង់បានចេញពីប្រទេស ស្តេចទៅគង់នៅឯប្រទេសក្រៅ ។ ព្រះបាទតរតីហរិគាំងពីបានរាជាភិសេក ទ្រង់បានទបត្តម្ភសត្វលោក. បើដូចជាព្រះរាជបុត្ររបស់ព្រះអង្គ តែទ្រង់ធ្វើព្រះរាជ-ទណ្ឌកម្មចំពោះពួកពាលសាមន្យដោយឥតត្រាប្រណី; នេះជាសភាវដែលព្រះបាទតរតីហរិទ្រង់បានគប្បីគង់ប្រទេសរបស់ព្រះអង្គ ។ ព្រះអគ្គមហេសីរបស់ព្រះអង្គ ព្រះនាមព្រះនាងគន្ធសេនា ។ ព្រះនាងមានព្រះរូបឆោមលោមពណ៌តែចន្ទ ទ្រង់ព្រះគុណសម្បត្តិដ៏ថ្លៃថ្លា បានបញ្ចេញព្រះកិត្យានុភាពធ្វើឲ្យព្រះរាជសូម៉ៃស្នេហាដ៏លើសលុប ។

---

## ការស្នាមជាគ្រែស្នាន

## លោក ស្រី-អ៊ូ

*នៅសង្កាត់លេខ ៦ ក្នុងភេញ តែង*

(ជាប់លេខ ១)

*គ្រែហា, លំនៅរបស់មនុស្ស ដែលសង់ដោយឈើ, ឫស្សី, ឥដ្ឋ នឹងស៊ីម៉ង់ត៍ជាដើម ហៅថា "ផ្ទះ" ។ ផ្ទះរបស់ខ្មែរយើងមានសណ្ឋានខុសគ្នាយប្លែក ៗ គ្នា អ្នកខ្លះធ្វើតូច អ្នកខ្លះធ្វើធំ អ្នកខ្លះធ្វើវែង អ្នកខ្លះធ្វើខ្លី ហើយមានឈ្មោះច្រើនយ៉ាង តែឈ្មោះដែលល្បីមកណាត់ចាំបាន គឺផ្ទះពេងដោល, ផ្ទះកឹង, ផ្ទះខ្មែរ, ផ្ទះបុត, ផ្ទះកន្ទាំង នឹងផ្ទះហាតល ។*

## គោលនៃការតែងរឿងផ្ទះទាំងនេះមាន ៣ យ៉ាង គឺ

*១ – ខ្នាតគ្រាយផ្ទះ;*

*២ – រដូវកាលដែលគេធ្វើផ្ទះ;*

*៣ – ល្អែងផ្ទះ;*

*៤ – ការរចនាផ្ទះប្លែក ៗ គ្នា;*

*៥ – របៀបធ្វើផ្ទះធំនឹងផ្ទះបាយ;*

*៦ – ពិធីលើកផ្ទះ;*

## ៧— ពិធីឡើងផ្ទះ ។

មានសេចក្តីអធិប្បាយដូចតទៅនេះ ៖

### ១— ទ្រង់ទ្រាយផ្ទះ

ក) ផ្ទះរោងជើលៈ គេធ្វើរាងវែងសួង មានដៃស្មាចាប់តល់ផ្ងួនចែងចាំងពីខាង មានហោជាងតូចតាបទ្រនាប់ត្រង់ប្រជុំហប់ មានចាំងហប់មុខហប់ក្រោយ ហៅថា "ផ្ទះរោងជើល" ។ ផ្ទះរោងជើលនេះអ្នកខ្លះធ្វើតែហប់មុខគ្មានហប់ក្រោយទេ ហៅថា "ផ្ទះកំបុតហប់ក្រោយ" ។ ចំពោះជាគេធ្វើកំបុតហប់ក្រោយដូច្នេះ ព្រោះខ្លះគ្រឿងឧបសម្ភារៈចំពោះជនអ្នកមិនសូវមានកោតទ្យ ។ ប៉ុន្តែមានអ្នកជនបខ្លះ ហៅផ្ទះរោងជើលដែលកំបុតហប់ក្រោយនេះថា "ផ្ទះរោងឧឡឹង" ទៅវិញក៏មាន ។

ផ្ទះរោងជើល អ្នកខ្លះធ្វើសសរទ្រូង ៣ មាន ៤ ល្វែង, បើគេធ្វើសសរទ្រូង ៤ មាន ៥ ល្វែង ហើយមានតែមួយថ្នាក់ គេដឹកជាំសសរទៅក្នុងដី មិនសូវមានដំកល់ថ្មទេ ។ ផ្ទះ ៤ ល្វែងក្តី ៥ ល្វែងក្តី គេចាំងជញ្ជាំងទ្រូងត្រង់សសរទ្រូងខាងលិច ។ ល្វែងកណ្តាលហៅថា "ល្វែងចាន់" ជាល្វែងសម្រាប់ដេក, ល្វែងខាងមុខសម្រាប់ទទួលភ្ញៀវ, ល្វែងខាងលិច (ល្វែងក្នុង) មួយចំហៀងខាងត្បូង ក្បែរជញ្ជាំងខាងលិចចាំងធ្វើជាជង្រុកស្រូវ; មួយចំហៀងខាងកើតនៃជង្រុកស្រូវសម្រាប់

កូនក្រមុំនៅ ដាក់ហឺបសំពត់អាវផ្សេង។; ល្អែងក្នុងចំហៀងខាងដើង សម្រាប់ដាក់ ដីងក្រានបាយ ទឹងដាក់ចានឆ្នាំងតាងក្រឡផ្សេង។ (នេះនិយាយចំពោះផ្ទះ គ្មានផ្ទះបាយ ទឹងគ្មានជង្រុកស្រូវ) ។

(ត្រង់នេះ ប្បាប់ដើម មានគំនូររូបផ្ទះពោងដោល នឹងប្រាប់ខ្នាតផង)

ខ) ផ្ទះកឹង: គេធ្វើមានជម្បូលពីរថ្នាក់ ខាងក្រោមធ្វើជាពីរថ្នាក់ដែរ គេចាំងជញ្ជាំងថ្នាក់លើ, ថ្នាក់ក្រោមគេធ្វើបង្អាន់ដៃព័ទ្ធជុំវិញ ។ តែផ្ទះកឹងនេះ ពួកទុបាសុកមិនសូវធ្វើទៅទេ ច្រើនតែធ្វើក្នុងវត្តសម្រាប់សង្ឃភាជ ហៅថា "កុដិកឹង" ។

(ត្រង់នេះ ប្បាប់ដើម មានគំនូររូបផ្ទះកឹង នឹងប្រាប់ខ្នាតផង)

គ) ផ្ទះខ្មែរ: គេធ្វើមានសសរ ៤ ជួរ កំពស់ស្មើគ្នា មានធ្នឹមទទឹងចាប់ក្បាច់នឹងក្បាលសសរជួរក្នុង ហើយបណ្តុះដើងគកធ្វើជាជម្បូល មានជម្បូលស្រួចច្រាកចោតចុះមក មានហោជាងធំខាងក្រោម ស្រួចឡើងទៅខាងលើមានតែហប់មុខ គ្មានហប់ក្រោយទេ ឬកណ្តាលហៅថា "ផ្ទះខ្មែរ" មានពីរថ្នាក់ គឺថ្នាក់ខាងមុខជាថ្នាក់ក្រោមសម្រាប់ទទួលភ្ញៀវ ថ្នាក់ខាងក្រោយសម្រាប់នៅ, គេច្រើនតែធ្វើតូច ហើយខ្ពី ទទឹង ៤ ម៉ែត្រ បណ្តោយ ៦ ម៉ែត្រ ។ ផ្ទះខ្មែរនេះ ច្រើនតែលោកសង្ឃធ្វើកុដិនៅតាមវត្តអារាម ហៅថា "កុដិខ្មែរ" ។

(ត្រង់នេះ ប្បាប់ដើម មានគំនូររូបផ្ទះខ្មែរ នឹងប្រាប់ខ្នាតផង)

ឃ) ផ្ទះប៉ុត្ត : គេធ្វើមិនមានដៃស្មាចាប់គល់ផ្ងោងហប់ទឹងគល់ផ្ងោងចែងទេ គឺគល់ផ្ងោងហប់ទឹងគល់ផ្ងោងចែងមកចាប់ត្រង់ពុងមេដំបូលប្រជុំក្បែរក្បាលសសរទ្រូងជាទីបំផុត ។ គេមិនសូវធ្វើវែងសួងដូចផ្ទះកោងដោលទេ បើគេធ្វើទទឹង ៦ ម៉ែត្រ បណ្តោយ ៩ ម៉ែត្រ ស្មាបជញ្ជាំង ៣ ម៉ែត្រ ៧តឹក, ខាងក្រោមពីត្រឹមដីលល់ទឹងរត ៣ ម៉ែត្រ ។ អ្នកខ្លះធ្វើសសរឈើជំគល់ថ្មជាទក្រោម, អ្នកខ្លះរៀបឥដ្ឋដល់រត, អ្នកខ្លះចាក់ស៊ីម៉ងត៍ដល់ទឹងរត, អ្នកខ្លះធ្វើសសរទ្រូង ២ មាន ៣ ល្វែង, អ្នកខ្លះធ្វើសសរទ្រូង ៣ មាន ៤ ល្វែង, បើគេធ្វើសសរទ្រូង ៤ មាន ៥ ល្វែង ។

(ត្រង់នេះ ច្បាប់ដើម មានគំនូររូបផ្ទះប៉ុត្ត តែងប្រាប់ខ្លាតផង)

ង) ផ្ទះកាំង : គេធ្វើគ្មានហប់មុខ ហប់ក្រោយទេ អ្នកខ្លះធ្វើកងវែងមានសសរកន្ទោង ឬ សសរទ្រូង ៣ បណ្តោយចំនួន ១០ ម៉ែត្រ ទទឹង ៦ ម៉ែត្រក៏មាន អ្នកខ្លះធ្វើកង ២ ។ មានសសរទ្រូងតែ ២ បណ្តោយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រក៏មាន ៖

កាលកងរដ្ឋកាលព្រះករុណាពាជានុគោដ្ឋ នៅស្រុកវៃស្រែចំការ មានតែចិនទឹងយួនធ្វើផ្ទះកន្តាំងជាផ្ទះផ្សារ ឬផ្ទះតៀមនៅផ្ងាល់ទឹងដីសម្រាប់លក់ដូរទំនិញផ្សេង ។ ដល់មករដ្ឋកាលព្រះករុណាខត្តិយកោដ្ឋទឹងរដ្ឋកាលបច្ចុប្បន្ននេះ ប្រជាជនវៃ្ញនិយមធ្វើផ្ទះកន្តាំងច្រើនណាស់ អ្នកខ្លះធ្វើនៅផ្ងាល់ទឹងដី អ្នកខ្លះធ្វើតុស៊ុងឡើងជាមួយជាន់ពីរជាន់ក៏មាន ។ ផ្ទះកន្តាំង

នេះ គេធ្វើក្បាយទៅជាបៃបផ្សេងៗទៀតបាន គឺគេធ្វើដម្បូលលើ ត្រង់ខាងមុខនឹងខាងក្រោយ ទម្រាក់ជាហប់បន្តិច ល្មមល្អមើល ហៅថា "ផ្ទះកន្ត្រាំងក្បាយ" បើគេបុតជ្រុងត្រង់មេដំបូលខាងមុខ ខាងក្រោយ ឲ្យខុបចុះបន្តិច ឲ្យមានសណ្ឋានដូចមាត់សត្វ ហៅថា "ផ្ទះកន្ត្រាំងចាំកណុក" (ពាក្យនេះប្រហែលជាមកពីភាសាសៀម) ។

ផ្ទះកន្ត្រាំងដែលពួកខ្មែរធ្វើទៅសព្វថ្ងៃនេះ អ្នកខ្លះគេធ្វើទទឹង ៦ ម៉ែត្រ បណ្តោយ ១០ ម៉ែត្រ ស្មាបជញ្ជាំង ៤ ម៉ែត្រ ខាងក្រោម ៣ ម៉ែត្រខ្លះ ពីរម៉ែត្រខ្លះ (តាមអ្នកស្រឡាញ់) ។

(ត្រង់នេះ ច្បាប់ដើម មានគំនូររូបផ្ទះកន្ត្រាំង នឹងច្រាប់ខ្នាតផង)

ប) ផ្ទះហោតិល: គេមិនដែលធ្វើអំពីឫស្សីនឹងឈើទេ គេធ្វើអំពីស៊ីម៉ង់ត៍ នឹងដែក ត្រួស ខ្សាច់ ឥដ្ឋ កំបោរ ធ្វើជាមួយជាន់ក៏មាន ពីរជាន់ក៏មាន បីជាន់ក៏មាន អ្នកខ្លះធ្វើពង ៤ ជ្រុង អ្នកខ្លះធ្វើពងប្លន ជ្រុងម្ខៃវែង តាមសេចក្តីស្រឡាញ់ គេរៀបឥដ្ឋធ្វើជាជញ្ជាំងព័ទ្ធជុំវិញ គេមិនធ្វើជ្រោងជ្រាន បង្គន់ ដៃវណែង ហើយប្រក់ក្បឿងទេ គឺគេវែងសំរៀសដែក ហើយចាក់ត្រួសខ្សាច់ស៊ីម៉ង់ត៍ ពេបស្មើពីលើតែម្តង ហៅថា "ផ្ទះហោតិល" ។ ផ្ទះហោតិលនេះ អ្នកស្រែចម្ការកន្លងកម្ពុជរដ្ឋយើង គេមិនសូវធ្វើទៅទេ, នៅក្រុងភ្នំពេញ គេមានធ្វើច្រើន មានដំណាក់ព្រះអង្គម្ចាស់ចន្ទលេខា ជាដើម ធ្វើដំណាក់ហោតិលមុនគេ ។

(ត្រង់នេះ ច្បាប់ដើម មានគំនូររូបផ្ទះហោតិល នឹងច្រាប់ខ្នាតផង)

## ២ — រដ្ឋកាលដែលគេធ្វើផ្ទះ

តាំងពីសម័យនគរវត្ត ហូតមកដល់រដ្ឋកាលព្រះករុណាសុវណ្ណគោដ្ឋ ប្រជាជនខ្មែរយើងច្រើននិយមរាប់អានធ្វើផ្ទះពេងដោល ផ្ទះកឹង នឹងផ្ទះខ្មែរហើយធ្វើបណ្ដោយថ្ងៃ បែរមុខចំទៅទិសខាងកើត ជាការសំដែងសេចក្ដីគោរពចំពោះព្រះអាទិត្យ ។ ព្រោះទំនៀមខ្មែរសម័យបុរាណថ្វីថាព្រះអាទិត្យជានាមនៃទេវតាពួកមួយ ជាបុត្រនៃនាងអទិតិ ។ បណ្ដាបុត្រទាំងនោះ មានបុត្រមួយឈ្មោះអាទិត្យ ឬឈ្មោះ សូរ្យាទិត្យ ជាទេវបុត្រ អ្នកបំភ្លឺលោក ហៅថាព្រះអាទិត្យ ។ សូម្បីតែគេរៀបមង្គលការកូនប្រុសស្រីក្ដីណា មុននឹងដង្ហែកូនប្រុសទៅដឹងទៅផ្ទឹម គេឲ្យកូនប្រុសនោះអង្គុយបន្ទេរដើងបែរមុខទៅទិសខាងកើត សំពះព្រះអាទិត្យដែលទើបនឹងរះជាមុនដែរ ហៅថា "សំពះពេលា ឬសំពះព្រះអាទិត្យ", នេះជាសេចក្ដីគោរពព្រះអាទិត្យ ។ គេធ្វើផ្ទះបែរមុខទៅទិសខាងកើតក៏ជាកិច្ចគោរពព្រះអាទិត្យ ។ (ទំនៀមនឹងដំនឿនេះ ខ្ញុំបានស្ដាប់អំពីសំណាក់តាសុខ នៅឃុំក្រែលគោ ស្រុក·ខ្វែតស្វាយរៀង គាត់និយាយថ្កាប់តាំងពីខ្ញុំមានអាយុ ១៧ ឆ្នាំ ) ។

ប្រជាជនខ្មែរសម័យបុរាណ និយមរាប់អានធ្វើផ្ទះពេងដោលនេះជាច្រើន សឹងមាននៅជាប់មកដល់សព្វថ្ងៃនេះខ្លះ ដូចយ៉ាងនៅភូមិឃ្លាំងស្បែក នឹងភូមិច្រាំងចំរែះជាដើម ។ ដល់មករដ្ឋកាលព្រះករុណា

ពជាខ្ទុះកោដ្ឋ ព្រះករុណាទ្រង់ត្រាស់ថាកោដ្ឋ ទីឯផ្ទះកាលបច្ចុប្បន្ននេះ គេច្រើនមិយមធ្វើផ្ទះបិទ ទីឯផ្ទះកន្តាំឯច្រើនពាន់ពេក អ្នកខ្លះធ្វើបណ្តាយវែង អ្នកខ្លះធ្វើទទឹងវែង ។

## ៣— ល្វែងផ្ទះ

ផ្ទះនីមួយ ។ រៀវលែងតែផ្ទះកន្តាំឯចេញ បើគេធ្វើសសរក្រែងពីរ មាន ៣ ល្វែង, បើគេធ្វើសសរក្រែង ៣ មាន ៤ ល្វែង, បើគេធ្វើសសរក្រែង ៤ មាន ៥ ល្វែង, ល្វែងកណ្តាលហៅថា "ល្វែងចាន" សម្រាប់ដេកនៅ, ល្វែងហាប់ក្រោយសម្រាប់កូនក្រមុំនៅ ទីឯធ្វើជាជង្រុកស្រូវផង សម្រាប់ជាក់ចានឆ្នាំឯតាងក្រឡទីឯដើងក្រានបាយផង, ល្វែងហាប់មុខសម្រាប់ទទួលភ្ញៀវ (នេះចំពោះផ្ទះគ្មានផ្ទះបាយ ទីឯជង្រុកស្រូវ) ។ ផ្ទះកឯទីឯផ្ទះខ្មែរ គេធ្វើមានពីរថ្នាក់: ថ្នាក់លើសម្រាប់នៅទីឯជាក់ទ្រព្យរបស់ផ្សេងៗ ថ្នាក់ក្រោមសម្រាប់អង្គុយលេងកំសាន្ត ទីឯទទួលភ្ញៀវ ។ ផ្ទះកន្តាំឯ បើគេធ្វើសសរកន្ទោងពីរ មានតែ ១ ល្វែង, បើធ្វើសសរកន្ទោង ៣ មាន ២ ល្វែង, បើធ្វើសសរកន្ទោង ៤ មាន ៣ ល្វែង ។ ផ្ទះកន្តាំឯនេះ គេធ្វើក្បាយចេញទៅទៀត ច្រើនបែបច្រើនយ៉ាឯណាស់ មិនអាចនឹងកំណត់បាន ។

## ៤— ការរបងផ្ទះប្លែកៗគ្នា

អ្នកស្រុកខ្លះ គេធ្វើផ្ទះរបងផ្សេងៗទៅតាមស្រឡាញ់ គឺធ្វើតួផ្ទះ

តែមួយតែធ្វើដម្បូលលើជាពីរឬបីខ្នង, ចាំង់ជញ្ជាំងតែពីរខ្នង ខុកមួយខ្នង ធ្វើជាហោណាំង, អ្នកខ្លះធ្វើផ្ទះធំមួយខ្នង ធ្វើហោណាំងមួយខ្នងទៀត បណ្តោយតម្រៀបគ្នា, អ្នកខ្លះធ្វើហោណាំងទទឹងពីខាងមុខផ្ទះធំ, អ្នកខ្លះធ្វើផ្ទះធំតសំយោបទម្ងាក់តាក បណ្តោយផ្ទះធំក៏មាន, អ្នកខ្លះទម្ងាក់តាកហប់មុខឬហប់ក្រោយក៏មាន ។

## ៥— ទំនៀមធ្វើផ្ទះធំទឹងផ្ទះបាយ

ក្នុងភូមិភាគស្វាយរៀង ខែត្រស្វាយរៀង គេធ្វើផ្ទះធំសម្រាប់នៅចំកណ្តាល ផ្ទះបាយខាងលិច, ជង្រុកស្រូវខាងជើង, ពេនគោខាងត្បូង, ក្រោលក្របីខាងកើត (តែគេច្រើនធ្វើក្រោលក្របីខាងក្រៅភូមិ), អណ្តូងទឹកនៅទិសឦសាន ទឹងទិសអគ្នេយ៍ នៅខាងក្រៅភូមិ, បង្គន់ខាងលិចផ្ទះធំ ។

## ៦— ពិធីលើកផ្ទះ

មុនដម្បូង គេលើកជីធ្វើជាភូមិ បុកបង្ហាប់ឲ្យរាបស្មើល្អ ប្រុងប្រៀបគ្រឿងទូសម្ភារៈបានគ្រប់គ្រាន់ ទើបគេរើសមើលថ្ងៃ-ខែណាដែលល្អល្មមលើកបាន ។ ខ្មែរបុរាណច្រើនឲ្យមលើកផ្ទះក្នុងខែបុស្ស ផល្គុន ពិសាខ; ឯខែអាសាធ ភទ្របទ ទឹងខែកត្តិក ភ្ញៀងជោកជាំពេកគេមិនសូវលើកផ្ទះទេ ។ ថ្ងៃដែលត្រូវលើកផ្ទះបាននោះគឺថ្ងៃពុធ, ព្រហស្បតិ៍ សុក្រ, សៅរ៍ ។ ខ្មែរសម័យពីដើមមិនលើកផ្ទះថ្ងៃអាទិត្យទឹងថ្ងៃចន្ទទេ

ព្រោះមានភាសាទំនឹមទំនៀមថា ‘ អាទិត្យចន្ទ្រវៀរការឈើផង ” ប្រសិន
បើចេះតែទូចលើក ត្រូវប្រយ័ត្នឲ្យមែនទែនក្រែងរលំមានគ្រោះថ្នាក់ ។
អ្នកលើកផ្ទះថ្ងៃអាទិត្យចន្ទ្រ ច្រើនរលំមានគ្រោះថ្នាក់ ឃានជាគេមិន
ដែលលើក ។ ថ្ងៃអង្គារលើកផ្ទះបានសុខដែរ តែធ្វើមិនហើយ ។ អ្នក
លើកផ្ទះថ្ងៃអង្គារ ធ្វើមិនដែលហើយទេ មុខជាចុំដ៏កន្ទេលខ្វះមិនខាន;
ហេតុនាំដ៏នេះហើយ ឃានជាគេវៀរថ្ងៃ ៣ នេះចេញ, ក្រៅពីថ្ងៃ ៣ នេះ
លើកឃានសុខសប្បាយទាំងអស់ ។

កាលដែលនឹងលើកផ្ទះ, មុនដម្បូង គេដោតស្វាធម៌ ១ គូ អុជធូប
ទៀន និយាយបួងសួងនឹងកុម្ភទេវតាដែលហៅថាព្រះភូមិ សុំភូមិ
ហើយទើបគេកាស់វៃដ៏បែងក្រឡាសសរឲ្យត្រង់ជួរ តាមទំនឹមបណ្តោយ
ហើយចោះស្នឹងជាគ្រឿងសំគាល់ ហៅថា ‘ ខ្វែងភូមិ ” ។ ដល់ដឹក
រណ្តៅសសរគេប្រយ័ត្នមិនឲ្យសម្រាមធ្លាក់ក្នុងរណ្តៅនោះទេ ដោយខ្លាច
មានកៀវឡើងផ្ទះច្រើន ។

ពិធីលើកផ្ទះ គេយកសំពត់ជាតិចដួតក្បាលសសរទ្រូង កណ្តាល
ហើយយកអំពៅឡើមមួយដើម ដកដោយឫសខ្វះផង មិនកាត់ចុងចេញ
ទេ គឺទុកដាំដ៏ឫសដាំចុង មកចងភ្ជាប់បណ្តោយសសរទ្រូងនោះ
ឲ្យខ្ពស់ហួសក្បាលសសរបន្តិច រួចគេរៀបពិធីសែន មានក្បាលជ្រូក
ស្វា ១ មាន់ស្វាមួយគូ ទឹកតែពីរពែង ខ្វះមានស្រាមួយដប នឹង

ផ្ទៃឈើ ៤ ជ្រុង ១ រៀល សំពត់សមួយអាវ ទឹកអប់ ១ ផ្តិល យកហឺប
គ្រឿងប្រដាប់ធ្វើផ្ទះរបស់មេជាងមកជាក់ជាមួយផង ។ រួចអាចារ្យសូត្រ
រលាស់ទឹកជាក់ក្បាលសសរទ្រូងនោះ មេជាងគេនិយាយបួងសួងដល់
ព្រះពិស្ណុការ ហើយអាចារ្យវាយឃ្មោះ ៣ អន្លង់ ពួកជាងផ្ទះក៏នាំគ្នា
លើកសសរទ្រូងតឹបឡើង ។ គេយកសំពត់ជាតីកន្ទុំមែ"តែគួរជាយ័ន្ត
ក្អែកក្រួចចោះក្លាប់ជាកណ្តាលមេដម្បូល ដើម្បីការពារកូដ (នេះជា
ទំនៀមរបស់អ្នកស្រុកស្វាយរៀង កន្លងសម័យបុរាណ, ដែលគេធ្វើយ"ាង
នេះ ដើម្បីនៅឲ្យជាន់សេចក្តីសុខនឹងចំរើនកោគទ្រព្យ) ។

## ៣.— ពិធីឡើងផ្ទះ

កាលគេធ្វើផ្ទះរួចហើយ គេមើលថ្ងៃខែដែលល្អ តាមទម្លាប់ចំណាំ
របស់គេ ដើម្បីនៅឲ្យបានសុខសប្បាយ ។

នៅជនបទខ្លះ ដូចយ"ាងនៅស្រុកស្វាយរៀង កាលដែលនឹងឡើង
ផ្ទះ គេអញ្ជើញបងប្អូនញាតិមិត្តជិតឆ្ងាយមកចួបជុំ ដល់ពេលព្រលប់
(ម៉ោង ៧) និមន្តព្រះសង្ឃ ៤ អង្គចំរើនបរិត្ត មានសូត្រធម៌ជិវិតានផង
ទានមិនបាន ជាទម្លាប់របស់គេ ។ កាលនៅនិមន្តព្រះសង្ឃ ត្រូវ
ពិត្រលោកថា "សូមនិមន្តនៅសូត្រមន្តឡើងផ្ទះ" ។ បើបានពិត្រ
លោកដូច្នេះ ទើបលោកអាចចាត់លោកដែលចេះចាំធម៌ជិវិតានឲ្យមក
សូត្រមន្ត ។ ពេលដែលសូត្រមន្ត អ្នកម្ចាស់ផ្ទះតាំងប្តីប្រពន្ធមកអង្គុយ

ទន្ទឹមគ្នាស្តាប់ធម៌ដោយគោរព ហើយលោកសូត្រធម៌ត្រជុះរលាស់ទឹកមន្តឱ្យ ។ លុះព្រះសង្ឃចំរើនព្រះបរិត្តចប់ហើយ អាចារ្យអ្នកចាត់ការមង្គលឡើងផ្ទះនោះ ឱ្យតវដល់អ្នកម្ចាស់ផ្ទះ រួចប្រាប់អំពីល្វែងផ្ទះថា "ល្វែងមុខហៅ ល្វែងសិរី, ល្វែងកណ្តាល ហៅល្វែងចាន់, ល្វែងក្រោយ ហៅល្វែងល័ក្ខណ៍" ហើយយកអន្ទងទឹកមកជាប់សសរកន្ទោងមុខ ៣ អន្ទង រួចនិយាយថា "នែសសរកន្ទោង! អ្នកឯងកាលពីដើមជា គគីក្រកោះ ផ្ចិក សុក្រំ ឥឡូវគេលើកអ្នកឯងឱ្យធ្វើជាកន្ទោង ត្រូវព្រះកន្ទោងឯងថែរក្សាទ្វារអ្នកនេះនាងនេះ ដែលជាម្ចាស់ផ្ទះ ព្រមទាំងបុត្តធិតាឱ្យបានសេចក្តីសុខ - ចំរើន កាត់កបកើតកាលវាលគុម្ពត្រជាក់ត្រជំតាំងពីថ្ងៃនេះតរៀងទៅ" ។ អ្នកខ្លះ បញ្ចប់កិច្ចឡើងផ្ទះត្រឹមសូត្រមន្តប៉ុណ្ណេះ; អ្នកខ្លះដល់ព្រឹកឡើងនិមន្តព្រះសង្ឃមកវេរគ្គធាន់ម្តងទៀតទើបបញ្ចប់ ។

នៅដំបន់ខ្លះ ដូចយ៉ាងឃុំផ្ទះកណ្តាល ស្រុកព្រៃតបោង ខេត្តកំពង់ចាម គេលើកផ្ទះពីព្រឹក ពេលល្ងាចឡើងនៅ មិនឱ្យកន្ទងពត្រីទេ គឺគេប្រុងប្រៀបរៀបគ្រឿងទុំសម្ភារៈឱ្យបានគ្រប់គ្រាន់ជាស្រេច ហើយស្តីញាតិមិត្តជិតខាងបានចំនួន ៥០ ឬ ៦០ នាក់ មកជួបជុំទើបគេឡើងផ្ទះ, ដល់ពេលល្ងាច (ម៉ោង ៦ កន្លះ) បានឡើងនៅ (ទំនៀមនេះនៅមានដល់សព្វថ្ងៃ) ។

ន័យមួយទៀត ខ្ញុំបានដឹងបានឮតាអាចារ្យគល់(១) នៅឃុំស្វាយជ្រំ ស្រុកខែត្រស្វាយរៀង និយាយប្រាប់អំពីពិធីឡើងផ្ទះថ្មី ដើម្បីនៅឲ្យបានសុខសប្បាយថា:

ទំនៀមឡើងផ្ទះថ្មី គេតែងឲ្យយកវត្ថុផ្សេងៗ ដែលគេនិយមប្រាប់អានថាជារបស់មង្គលទៅដាក់ក្នុងផ្ទះគ្រប់ទិសទាំង ៩ គឺ: [redacted]

| | | |
|---|---|---|
| ១ - | ទិសបូព៌ | ត្រូវដាក់ដើងគ្រានបាយ ; |
| ២ - | ទិសអគ្នេយ៍ | ត្រូវដាក់តាំងយូឬធ័ត្រ ; |
| ៣ - | ទិសទក្សិណ | ត្រូវដាក់អង្ករ ទឹងឆ្នាំងបាយ ; |
| ៤ - | ទិសនិរតី | ត្រូវដាក់ព្រះសង្ឃឲ្យគង់សូត្រមន្ត ; |
| ៥ - | ទិសបស្ចឹម | ត្រូវដាក់ព្រាល - ផ្លែ ; |
| ៦ - | ទិសពាយ័ព្យ | ត្រូវដាក់ភ្លុកទឹងគ្រឿងដែក ; |
| ៧ - | ទិសឧត្តរ | ត្រូវដាក់ស្បូវ ទឹងកញ្ចើ ; |
| ៨ - | ទិសឦសាន | ត្រូវឲ្យស្ត្រីមានគភ៌អង្គុយ ទឹងគ្នា ហើយទឹងគ្រឿងទន់ដែង, ស្ពាន ; |
| ៩ - | ត្រង់កណ្តាល | ត្រូវដាក់កន្ទេលពួកខ្ចី ទឹងគ្រឿងសស្ត្រាវុធ គឺជាវឹកាំភ្លើង ។ |

ការបើបានធ្វើដូចរៀបរាប់មកនេះ ទឹងកើតសិរីសួស្តីដល់ម្ចាស់ផ្ទះ។


---

១. តាមរឿងគាត់អនិច្ចកម្មទៅហើយ ។

របស់ដែលត្រូវឲ្យដាក់តាមទិសទាំងនេះ មិនមែនកំណត់ឲ្យទុកយូរ រហូតតទៅនោះទេ គឺគ្រាន់តែឲ្យដាក់មួយគ្រាក្នុងពេលដែលរៀបពិធីឡើងផ្ទះប៉ុណ្ណោះឯង, រួចកិច្ចពេលណា ទោះបីនឹងរើរុះយកទៅទុកដាក់ក្នុងទីដ៏គួរក៏បាន ឥតមានទាស់អ្វីឡើយ ។

ចប់

---



មិត្ត ៤ ពួក

ប័ក្សពួកជាមិត្រអ្នកដើរផ្លូវឆ្ងាយ,
រូបម្ភាយជាមិត្រក្នុងផ្ទះអាត្មា,
ជនជាសំទ្បៃញ៉ូលៅសហាយ
ជាមិត្រក្នុងការកើតទ្បើងរឿយៗ ។
ប៉ុណ្យគឺកុសលធ្វើដោយខ្លួនឯង
ខ្លួនបានតាក់តែងរូបស្រេចមកហើយ
ប៉ុណ្យនោះជាមិត្រជាប់ជិតបង្កើយ
នេះហើយជាមិត្រក្នុងលោកខាងមុខ ។

ព្រះអាចារ្យ ដួយ-ម៉ែ

# សេចក្តីរៀបរៀង

របស់ព្រះធេពសត្តា កឹម - ង្គ្រី វត្តខ្ពង់ណាលោម

អំពី

ដំណើរទៅកាន់ប្រទេសភូមា

និង

សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ និងគណៈប្រតិភូខ្មែរ ដើម្បីធ្វើឆន្ទសង្គាយនា តាមសេចក្តីនិមន្តន៍របស់រដ្ឋាភិបាល និងពុទ្ធសាសនសភា ព្រមទាំងគណៈសង្ឃនៃប្រទេសភូមា ដូចមានសេចក្តីរាយការណ៍ជាលំដាប់ដោយសង្ខេបតទៅនេះ :

## ដំណើរចេញពីប្រទេសកម្ពុជា

ថ្ងៃអង្គារទី ១១ ខែសីហា ១៩៥៨ ម៉ោង ៧ ៣០ សម្តេចមួយអង្គៀ ដោយប្រតិភូខ្មែរទាំងអស់ បានចេញពីវត្តខ្ពង់ណាលោម ដោយរថយន្តឆ្ពោះទៅកាន់ស្ថានីយអាកាសយានពោធិចិនតុង ។ ពួកព្រះសង្ឃដារ៉ែចិនអគ្គមានសម្តេចព្រះធម្មលិខិតខ្ពស់ប្រកបវត្តលង្កាជាដើម និងពួកអស់លោកគ្រហស្ថដារ៉ែចិនមានឯកឧត្តម ង្វូ - ត្រឿង រដ្ឋមន្ត្រីក្រសួងធម្មការ, ឯកឧត្តម ង៉ុក - ធុច ប្រធានពុទ្ធិកសមាគមកម្ពុជវត្ត, លោក ព័យ - ប៊ុក ប្រធានសមាគមមិត្តសាសាថាលីជាដើម ចានដួនដំណើរសម្តេចដោយ

រថយន្ត ឆ្ពោះទៅកាន់ស្ថានីយអាកាសយានពោធិចិនតង ។ ម៉ោង-
១០,៣០ សម្តេចនឹងប្រតិភូចាំងអស់ឡើងអាកាសយាន អ៊ែរវៀតណាម
(Air Viet nam) ឆ្ពោះទៅកាន់ប្រទេសថៃ ។

## ដំណើរដល់ប្រទេសថៃ

ម៉ោង ១៤ ខ្វះ ១៩ នៃថ្ងៃទី ១១ ឧសភានោះ អាកាសយានបានដួន
ដំណើរសម្តេចនឹងគណៈប្រតិភូខ្មែរទៅដល់ដនមឿង ជាស្ថានីយអាកាស-
យានប្រទេសថៃ ។ ខណៈនោះ ឃើញពួកទេសាសកខ្មែរខ្លះ ថៃខ្លះ
មានឯកឧត្តម ឌី គិមស្ហួ អគ្គរាជទូតខ្មែរ នឹងទូតកូមាប្រចាំប្រទេសថៃជា
ដើម ព្រមទាំងព្រះសង្ឃជាតិខ្មែរជាច្រើន មកត្រៀមរង់ចាំទទួលសម្តេច
នៅស្ថានីយអាកាសយានដនមឿង ។ សម្តេចនិមន្តចេញពីស្ថានីយ
ដនមឿង ដោយរថយន្តឆ្ពោះទៅកាន់ក្រុងទេពមហានគរ (ចាងកក),
ពួកបរិស័ទចាំងនោះក៏ដួនដំណើរសម្តេច, ហើយនិមន្តសម្តេចទៅគង់
សម្រាកនៅវត្តតិស្សាន្តារាម ហៅវត្តចាងហ្វាងឱតក្រុងទេព អស់រយៈ
កាល ៤ ថ្ងៃ រង់ចាំអាកាសយានដែលត្រៀមទៅទទួលកូមា ។ ក្នុង
កំឡុង ៤ ថ្ងៃនោះ សម្តេចបានទទួលបដិសណ្ឋារៈចំពោះព្រះសង្ឃខ្មែ-
ថៃ នឹងឧបាសកឧបាសិកាខ្មែរ ថៃ ដែលចូលមកថ្វាយបង្គំគាលសម្តេច
ជាហូរហែពុំសូវមានពលទំនេរទេ ។

ថ្ងៃទី ១៥ ឧសភា ម៉ោង ៦,៣០ សម្តេចព្រមទាំងប្រតិភូខ្មែរបពូជិត
៥ រូប គ្រហស្ថ ៨ នាក់ បានចេញពីក្រុងទេព ដោយរថយន្តឆ្ពោះទៅកាន់

ស្ថានីយអាកាសយានដនមឿង, មានឯកទុតមុខ - តំមស្ងួអគ្គភាជនូតខ្មែរ
ទឹងទូតកូមាប្រចាំប្រទេសថៃជាដើម ព្រមទាំងព្រះសង្ឃជាច្រើនអង្គ ចាន
ជូនដំណើរទៅដល់ស្ថានីយអាកាសយាន ។ ម៉ោង ១០,៣០ ឡើង
អាកាសយាន ថៃ អែរ វ៉េ (Thai airevays ឆ្ពោះទៅកាន់ប្រទេសកូមា ។

## ដំណើរដល់ប្រទេសកូមា

ម៉ោង ១៥,៣០ (ម៉ោងព្រះទេសខ្មែរ) នៃថ្ងៃទី ១៥ ខែសកា ដដែល
នោះ អាកាសយានចានជូនដំណើរសម្តេច ទឹងគណៈប្រតិភូខ្មែរ ទៅ
ដល់ស្ថានីយអាកាសយាន មង្គលៈដូន ប្រទេសកូមា ចមា្ងយពីក្រុងរ៉ង្គូន
(Rangoon) ជាង ៨ គីឡូម៉ែត្រ, ឃើញពួកឥស្សរជនមកពីការ ព្រម
ទាំងព្រះសង្ឃទឹង ចុះសក ចុះសិកាជាតិកូមាជាច្រើន នៅរង់ចាំទទួល
ពួកប្រតិភូខ្មែរមានសម្តេចជាដើម ហើយក៏ចាត់ចែងចង្ហាន់ប្រគេនធាន់
កន្លងស្ថានីយនោះ ។

## មហាចាសាណាកុហា

## ទីសម្រាប់ប្រជុំធ្វើឆដ្ឋសង្គាយនា

នៅថ្ងៃទី ១៥ ខែសកា ដដែលនោះ សម្តេចទឹងគណៈប្រតិភូខ្មែរ លុះ
ចានទទួលភត្តនៅស្ថានីយអាកាសយានរួចហើយ ក៏ឡើងរថយន្តពិសេស
ដោយមានពុទ្ធបរិស័ទជូនដង, ឆ្ពោះទៅកាន់តំបន់យគុ។ នេះឯងជាកន្លែង
ដែលត្រូវធ្វើឆដ្ឋសង្គាយនា ចមា្ងយពីក្រុងរ៉ង្គូនជាង ៥ គីឡូម៉ែត្រ ។

ទីនេះបានជាគេហៅថាយេតុ ព្រោះដីខ្លួលត្រង់កណ្តាល មានដីខំនាបទឹក ជក់មានសណ្ឋានដូចជាស្លឹងព័ទ្ធជុំវិញ, គេសាងមន្ទីរសម្រាប់ប្រជុំធ្វើឆដ្ឋសង្គាយនាចំត្រង់កណ្តាលផ្ទៃដីដែលមានភាពខំនួលបន្តិចនេះ គេឲ្យឈ្មោះមន្ទីរនេះថា: មហាបាសាណគុហា ។ នេះបើមើលពីខាងក្រៅមានសណ្ឋានធំទៃវែងខ្ពស់ទ្រទុងទៅលើដូចជាកំសុទ្ធសាធ ព្រោះគេយកដុំថ្មកំមកវៀបជាឈ្វងធកបន្តិច។ ពីលើដំបូល: ខាងក្នុងត្រង់ផ្ទៃកណ្តាលធំទូលាយល្វឹងល្វើយ មានសសរធំ។ ៦ ដើម មានថ្នាក់អមជុំវិញ ៨ ថ្នាក់ សម្រាប់ព្រះសង្ឃ ២៥០ អង្គគង់ប្រជុំបានយ៉ាងទូលាយ; ត្រង់ផ្ទៃខាងកណ្តាលសម្រាប់ពួកគ្រហស្ថតាំងប្រុសតាំងស្រី អង្គុយបានពាក់ពាន់នាក់; ទៅជុំវិញផ្ទៃកណ្តាលមានថ្នាក់ថ្មជាន់ ក្នុងជាន់នីមួយៗមានបន្ទប់សម្រាប់ធ្វើការជាច្រើនកន្លែងហើយអាចដើរទៅមកជុំវិញបាន ។ ទៅទិសខាងលិចចម្ងាយពីមហាបាសាណគុហាប្រហែល ១០០ ម៉ែត្រ គេសង់មហាកុដិ ៤ ខ្នង សម្រាប់ព្រះសង្ឃប្រហែល ៣០០០ អង្គ ដែលនិមន្តមកធ្វើសង្គាយនាគង់ទៅតាំងយប់តាំងថ្ងៃ ។ ក្នុងមហាកុដិមួយខ្នងៗ បណ្តោយ ១១០ ម. ទទឹង ១៨ ម. មានថ្នាក់ ៣ ជាន់ៗ ដូចគ្នាតាំងអស់, ទៅក្នុងជាន់នីមួយៗ មានបង្អន់, បន្ទប់ងូតទឹកនឹងកន្លែងសម្រាប់លុបមុខ ។ នៅចន្លោះកណ្តាលនៃមហាកុដិតាំង ៤ ខ្នង មានកត្តគ្គសាលាមួយខ្នងទៀត បណ្តោយ ៥០ ម. ទទឹង ៣០ ម. មានថ្នាក់ ៣ ជាន់ សម្រាប់ព្រះសង្ឃ

ប្រហែល ៣០០០ អង្គុតធំខាន់ ។ នៅទិសខាងត្បូងចម្ងាយពីមហា
ចេតិយសាណគុហា ប្រហែល ២០០ម. មានចេតិយធំមួយហៅថា កម្ពាអេ
សំឡេងកូមាថា កៈចាអេ (Kabâye) ឬហៅ "លោកសន្តិចេតិយ"
ដែលឯកទគ្គម អ៊ូ - នុ. នាយការដ្ឋមន្ត្រីបច្ចុប្បន្ន សាងឡើងតំកល់ព្រះបរម-
សារីរិកធាតុ នៃព្រះអង្គជាតុនៃព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន
ដោយឯកទគ្គមនេះបានអញ្ជើញទៅទទួចសុំចែកពីប្រទេសឥណ្ឌាមក ។
ក្នុងចេតិយនេះ ឃើញប្រជាជនកូមាចាំងស្រីប្រសាស់ក្មេង ចូលទៅ
នមស្ការបូជាបច្ច័យនឹងផ្កា សូត្រធម្មសូត្រច្រើនពាល់ថ្ងៃ ។ នៅខាងត្បូង
នឹងខាងកើតនៃចេតិយនេះ មានសាលាមហាវិទ្យាល័យពុទ្ធសាសនាមួយ
ខ្នង, មានមន្ទីរឃោសនាការមួយខ្នង, ពេធ៌ពុទ្ធមួយខ្នង, មន្ទីរសម្រាប់
ចាត់ការផ្សេង ។ មួយខ្នង ។ មន្ទីរចាំងនេះ សុទ្ធតែធ្វើពីឥដ្ឋនឹងបេតុង
អារម៉ែចាំងអស់ ។ នៅខាងលិចនឹងខាងជើងនៃចាសាណគុហា មាន
ពេធ៌ប្រក់សង្កសីក្រាលក្តារ ទទឹង ១៥ម. បណ្តោយ ៥០ម ចំនួន ៥០ ខ្នង
សម្រាប់ពួកទគ្គចាសកទគ្គចាសិកាជាតិកូមា ដែលមកពីទីដ៏តឆ្ងាយនៅស្នាក់
អាស្រ័យក្នុងទគ្គាសបុណ្យសន្និបាត ។ នៅទិសខាងជើងចម្ងាយពី
មហាចាសាណគុហាប្រហែល ១៥ម. មានពេធ៌ពុទ្ធមួយខ្នងទទឹង ១៥ម.
បណ្តោយ ៣០ម. ព័រជាន់ សម្រាប់ចុះពុទ្ធព្រះវិត្រៃបិដកនឹងសៀវភៅ
សិក្សាក្នុងព្រះពុទ្ធសាសនាតវៀងទៅ ។ នៅខាងក្នុងនឹងខាងក្រៅនៃ
មហាចាសាណគុហាក្តី នៅមហាកុដិចាំង ៤ ខ្នងក្តីនៅភគ្គគ្គសាលាក្តី

ទំងំមន្ទីរផ្សេង ។ ឯទៀតក្រៅពីនេះក្តី សុទ្ធតែមានពន្ធឹក្លឹះព្រាងព្រាត ដោយក្តៅងអគ្គិសនីពាំងអស់ ដោយមាស៊ីនដែលបន្តមកពីក្រុងវ៉ាស៊ីនដូចពីក្រុងមួយតួច ។ គួរឱ្យអស្ចារ្យណាស់ មន្ទីរពាំងរស់មានមហាចាសាណគុហាជាដើម រដ្ឋាភិបាលចាត់ពួកវិស្វករឱ្យចាប់សង់ឡើងអស់រយៈកាលត្រឹមតែ ១៤ ខែទន្ទឹង ១០ ថ្ងៃប៉ុណ្ណោះហើយស្រេចពាំងអស់ ។

កន្លែងដែលសម្តេចនិមន្តទៅដល់ទីមហាចាសាណគុហា ជាកន្លែងដែលធ្វើសន្ទាយនានោះ មានពួកពុទ្ធបរិស័ទ្ធជាតិកូមាជាច្រើនត្រៀមរង់ចាំទទួលធ្វើគារវកិច្ចចំពោះសម្តេច ហើយនិមន្តឱ្យទៅគង់ក្នុងមហាកុដិមួយខ្នងត្រង់ថ្នាក់កណ្តាល ។ មហាកុដិនេះគេសន្មតឈ្មោះថាប៉ូពីរ៉ាទេហ្វីប ។ កន្លែងជាលំដាប់តមក សម្តេចបានទទួលបដិសណ្ឋារៈចំពោះពុទ្ធបរិស័ទ្ធពាំងព្រះសង្ឃពាំងគ្រហស្ថជាតិកូមា នឹងជាតិដទៃជាច្រើន ដែលចូលមកថ្វាយបង្គំគាល់គ្រប់វេលាស្មើរឥតស្រាក ។ ចំណែកខាងឥស្សរជនជាន់ខ្ពស់មានឯកឧត្តម អ៊ូ - នុ. នាយករដ្ឋមន្ត្រី នឹងឯកឧត្តម អ៊ូ វិន រដ្ឋមន្ត្រីក្រសួងធម្មការជាដើម ក៏បានចូលមកធ្វើបដិសណ្ឋារៈថ្វាយបង្គំគាល់សម្តេចក្នុងទីនោះដែរ ។

ថ្ងៃទី ១៦ ខែសីហា ១៩៥៤ វេលាព្រឹក ព្រះសង្ឃពាំងអស់ប្រជុំសន្ទនាឯណ្ឌសីមាក្នុងមហាចាសាណគុហា ។

## វេលាបើកសម័យប្រជុំ ដៅថ្ងៃទី ១

ថ្ងៃទី ១៧ ខែសីហា ១៩៥៤, ម៉ោង ១២,២០ ចាប់បើកសម័យប្រជុំ ។

ពុទ្ធចរិស័ទដែលប្រជុំក្នុងមហាចុសាណគុហានោះ មានពួកព្រះសង្ឃជាតិកូមាដោយច្រើន នឹងព្រះសង្ឃជាប្រតិកូតំណាងប្រទេសនានា រួមទាំងអស់ចំនួន ២៥០០ អង្គ, ពួកឥស្សរជនជាតិកូមានឹងបរទេស មានលោកបណ្ឌិត (Doctor) អ៊ូកអ៊ូប្រធានាធិបតី, ឯ.ឧ. អ៊ូនុ នាយករដ្ឋមន្ត្រី, ឯ.ឧ. អ៊ូវិន រដ្ឋមន្ត្រីក្រសួងធម្មការជាដើម, ក្រុមសមាគមទាំងឡាយ មានលោក អ៊ូឆ្វិន ប្រធាននៃពុទ្ធសាសនសកាជាដើម មួយអន្ទឹងដោយប្រជាជនជាតិកូមាកាប់ពាន់នាក់ ។ វេលាដែលដួបជុំគ្នារួចហើយ សូរសំឡេងស្គរឆ្នឹងគងចួងក៏លាន់ឮរំពងទ្រហឹងអស់រយៈវេលា ៥ នាទី ទើបលោកកន្ទនាគវំសៈ (ជាតិកូមា) ប្រកាសបើកពេលប្រជុំជាភាសាចាលីនឹងកូមា :

១ – លោកកន្ទវណ្ណៈ ដែលជាសង្ឃមហាថេរ សូត្រសន្ទុតដល់សង្ឃ តំណាងនាមនៃលោកអគ្គមហាវជិរញាណ កន្ទវេតៈ ដែលជាសង្ឃនាយកមហាថេរនៃការផ្តើមសង្គាយនា ។

២ – ព្រះសង្ឃនាយកមហាថេរ និមន្តឡើងគង់លើថេរាសនៈ ។

៣ – លោកកន្ទបណ្ឌិតៈ សូត្រនូវវេលូគាថា ។

៤ – លោក អ៊ូសេង៉ដរ អានន្ទូបូជនីយមង្គលថោមនគាថា, ឯ.ឧ. អ៊ូ វិន រដ្ឋមន្ត្រីក្រសួងធម្មការ អានប្រកាសមួយដែលសរសើរអំពីព្រះពុទ្ធសាសនា ។

๕ - លោកបណ្ឌិតអ៊ូ កអ៊ូ ប្រធានាធិបតីសហភាពកូមា អានប្រកាសមួយប្រកបដោយសេចក្តីគោរព ទទួលការប់រងនាពីជាសង្ឃរាយនាយកលើនាមនៃពុទ្ធសាសនិកថេរវាទពីពាងឆ្ងាយ ។

๖ - លោក អ៊ូ ធ្លិន ប្រធាននៃពុទ្ធសាសនសភាជាតំណាងនាមនៃរដ្ឋាភិបាលសហភាពកូមា អានប្រកាសមួយដោយគារវភាពទទួលការប់រងខុសត្រូវពេញបន្ទុកក្នុងផ្នែកនៃពុទ្ធសាសនា ដើម្បីទំនុកបំរុងបព្វជិតដោយបច្ច័យនឹងវត្ថុដទៃ តាមគួរដល់តំណើរការណ៍ ។

๗ - ថ្លែងការណ៍អំពី .....

(๑) សម្តេចសង្ឃរាជ ប្រទេសថៃ ព្រះវិមលធម្ម (អាសភៈ) វត្តមហាធាតុ ថ្លែងការណ៍តំណាង ។

(๒) លង្កាទេត្តរីតរសភា, បណ្ឌិតធម្មរំសៈ ថ្លែងការណ៍តំណាង ។

(๓) អមរបុរនិកាយ នឹងកល្យាណីវំសនិកាយ បណ្ឌិតធម្មកុសលត្ថេរ ថ្លែងការណ៍តំណាង ។

(๔) ពមញ្ញនិកាយ, បណ្ឌិតសរណង្ការត្ថេរ ថ្លែងការណ៍តំណាង ។

(๕) លោកប្រធានាធិបតី ប្រទេសឥណ្ឌា, លោក ក. ក. អគ្គរាជទូតកិត្តិយស ថ្លែងការណ៍តំណាង ។

(๖) ព្រះចៅប្រទេសនេប៉ាល, នាងកញ្ញា វិមលា ថ្លែងការណ៍តំណាង ។

(๗) ព្រះចៅប្រទេសថៃ, លោកខាប កុញ្ជរ ថ្លែងការណ៍តំណាង ។

(៨) សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកប្រទេសកម្ពុជា ថ្វែងការណ៍តំណាងប្រទេសកម្ពុជា ។

(៩) លោកអគ្គមហាបណ្ឌិត កទ្ទគន្ធាសភៈ ថ្វែងសេចក្តីតប ។

(១០) ព្រះសង្ឃនាយកត្តេរ ថ្វែងអង្គការរបស់លោក ។

លោកកទ្ទគន្ធាគារវៈ ប្រកាសវេលាសម្រាកនៅម៉ោង ១៤,៣០ ឲ្យសញ្ញាដោយគង ១០ អន្លុង, ដល់ម៉ោង ១៥,៣០ ទើបប្រកាសបើកវេលាប្រជុំឡើងវិញ ឲ្យសញ្ញាដោយគង ១០ អន្លុង ។

៨- ព្រះសង្ឃនាយកត្តេរ ប្រកាសឲ្យមតិដល់សង្ឃក្នុងនាមនៃលោកអគ្គមហាបណ្ឌិតកទ្ទគន្ធសោកនៈជាអ្នកសួរ នឹងលោកឧបដកធរៈ ធម្មកណ្ឌាគារិកៈ កទ្ទគន្ធិវិចិត្តសារៈ (ឬវិចិត្តសាកគិរវៈ) ជាអ្នកឆ្លើយដោយសេចក្តីគោរពក្នុងការផ្ទៀងផ្ទាត់នូវវិនិយឧបដក បឋមចាតុដកសិក្ខាបទ ។

៩- លោកអ្នកសួរ នឹងលោកអ្នកឆ្លើយ ឡើងកាន់អាសនៈពិសេសរៀងខ្លួន ។

១០- លោកអ្នកសួរ អាចធនាជំនួសសង្ឃ ដើម្បីសុំឲ្យលោកឆ្លើយនូវបញ្ហាក្នុងការផ្ទៀងផ្ទាត់នូវចុលឧបឋមចាតុដកសិក្ខាបទ ។

១១- លោកអ្នកឆ្លើយ សុំអំណាចអំពីសង្ឃដើម្បីឆ្លើយនូវបញ្ហា ។

នៅទីបំផុតនៃការសួរនឹងការឆ្លើយ ព្រះសង្ឃ ២៥០ អង្គ ទទួលថា សាធុ បីដង ហើយសូត្រនូវវេញ្ចកណ្ឌចាតុដក ផ្តើមអំពី តេន សមយេន រហូតដល់ចប់បឋមចាតុដកសិក្ខាបទជាទីបំផុត ។ លុះ

ដល់ពេលទំនឹងបញ្ចប់ លោកភន្តនាគរំសៈ ប្រកាសបិទសម័យប្រជុំ ឲ្យ
សញ្ញាដោយគង ១០ អន្លង ។

## វេលាបើកសម័យប្រជុំនៅថ្ងៃទី ២

ថ្ងៃទី ១៨ ឧសភា ១៩៥៤, លោកភន្តនាគរំសៈ ប្រកាសបើក
វេលាប្រជុំ ជាភាសាបាលីនឹងកូមា នៅម៉ោង ១២,៥០ ។

១ – ឯកឧត្តមអ៊ូ នុ នាយករដ្ឋមន្ត្រីថ្លែងគោលការណ៍ដែលមានៈសេចក្តី
អធិប្បាយអំពីការចំរើននៃព្រះពុទ្ធសាសនា នឹងការធ្វើឲ្យព្រះពុទ្ធសាសនា
តាំងនៅអស់កាលជ័យរៃ ។

២ – លោក សិរីសុធម្មៈ អ៊ូ សេងម៉ោង បាធ៍ហ្វាងត្រួសួងយុត្តិធម៌
នៃសហភាពកូមា លោកជាអនុប្រធាននៃពុទ្ធសាសនសភាកូមាផង
ថ្លែងគោលការត្រួតត្រាទូវកិច្ចការទាំងឡាយនៃពុទ្ធសាសនសភា ដើម្បី
ជាវឌ្ឍនធម៌ដល់ព្រះពុទ្ធសាសនា ។

៣ – លំដាប់តពីនេះ គណៈប្រតំកូតំណាងប្រទេសនានា មាន
ព្រះថេរៈធម្មវរៈ ប្រទេសកម្ពុជាជាដើម ឋានពោលសេចក្តីថ្លែងការណ៍ ។

៤ – មហាថេរមួយរូប ថ្លែងសេចក្តីតបជាភាសាបាលីនឹងកូមា ។

(លោកភន្តនាគរំសៈ ប្រកាសវេលាសម្រាកនៅម៉ោង ១៤,-
៣០ ដល់ម៉ោង ១៥,៣០ ប្រកាសបើកវេលាប្រជុំឡើងវិញ ដោយ
ឲ្យសញ្ញាគង ១០ អន្លង)

៥– ព្រះសង្ឃនាយក: តាំងញត្តិប្រកាសនាមនៃលោកអ្នកសួរនឹងលោកអ្នកឆ្លើយ ដោយការផ្លៀងផ្ទាត់នូវចំណុចលើចាពជិកសិក្ខាបទទី ២ នឹងទី ៣ ។

៦– លោកអ្នកសួរនឹងលោកអ្នកឆ្លើយ ឡើងកាន់ធម្មាសន:ពិសេសប្រកាសញ្ជាំងសង្ឃឲ្យដឹងហើយ ទើបសួរ-ឆ្លើយក្នុងចាពជិកសិក្ខាបទទី ២ នឹងទី ៣ ។

៧– លំដាប់តមក ព្រះសង្ឃទាំងឡាយ ២៥០ អង្គ ស្វាធ្យាយចាលើចាពជិកសិក្ខាបទទី ២ នឹងទី ៣ ក្នុងវេលាចប់នៃការសួរ-ឆ្លើយ ។

៨– ពួកពុទ្ធបរិស័ទជាតិភូមា នឹងអ្នកតំណាងប្រទេស ក៏ទទួលថា សាធុ ៣ ដង ព្រម ។ គ្នា ។

(លោកកន្តនាគវំស: ប្រកាសចំទេសម័យប្រជុំថ្ងៃទី ២ ឲ្យសញ្ញាដោយគង ១០ អន្លុង),

វេលាបើកសម័យប្រជុំនៅថ្ងៃទី ៣

ថ្ងៃទី ១៨ មេសា ១៩៥៤, លោកកន្តនាគវំស:ប្រកាសបើកវេលាប្រជុំ ជាភាសាចាលីនឹងភូមា នៅម៉ោង ១២ ។

១– ឯកទត្តម អ៊ូ វិន រដ្ឋមន្ត្រីក្រសួងធម្មការ ថ្លែងសុន្ទរកថាដោយសេចក្តីគោរព ចំពោះសេចក្តីបរិសុទ្ធិនឹងសេចក្តីចំរើននៃព្រះពុទ្ធសាសនា ។

២– គណ:ប្រតិភូតំណាងប្រទេសនានា ឡើងថ្លែងការតាមលំដាប់គឺ អ្នកតំណាងប្រទេសលាវ, លង្កា, មហាពោធិសមាគមប្រទេស

ឥណ្ឌៀ, ពុទ្ធិកសមាគម ប្រទេសបេង្គ័ល, ពុទ្ធិកសមាគម ប្រទេសជប៉ុន, ប្រទេសមាឡាយូ, បេកាំង, ពុទ្ធិកសមាគម ប្រទេសថៃ, ប្រទេសឥណ្ឌូណេស៊ីជាដើម ។

៣_ លោកអគ្គមហាបណ្ឌិត កទ្ទឥន្ទាសកៈ ប្រទេសកូមាថ្ងៃនេះ សេចក្តីឆ្លើយតបចំពោះអ្នកតំណាង ប្រទេសទាំងអស់ ។

លោកកទ្ទនាគវំសៈ ប្រកាសសម្រាក ប្រជុំជាការសាចាលីនិងកូមានៅវេលាម៉ោង ១៤,៣០ ឲ្យសញ្ញាដោយគង ១០ ដង ។ ដល់ម៉ោង ១៥,៣០ ប្រកាសបើកវេលាប្រជុំឡើងវិញ ឲ្យសញ្ញាដោយគង ១០ ដង ។

៤_ ព្រះសង្ឃនាយក តាំងញត្តិប្រកាសនាមនៃលោកអគ្គមហាបណ្ឌិត កទ្ទសោកនៈជាអ្នកសួរ និងលោកកទ្ទវិចិត្តសារៈ ធម្មកថាគារិកៈ ជាអ្នកឆ្លើយ ដោយការផ្ទៀងផ្ទាត់នូវចាលីបាឋដកសិក្ខាបទទី ៤ ។

៥_ លោកអ្នកសួរនិងលោកអ្នកឆ្លើយ ឡើងកាន់ធម្មាសនៈពិសេស ។

៦_ លោកអ្នកសួរសូមទុកាសចំពោះព្រះសង្ឃ ហើយសួរនូវបញ្ហាចំពោះលោកអ្នកឆ្លើយ, លោកអ្នកឆ្លើយប្រកាសញ៉ាំងសង្ឃឲ្យដឹង ហើយឆ្លើយកងបាឋដកសិក្ខាបទទី ៤ ។

នៅទីបំផុតនៃការសួរនិងការឆ្លើយ ព្រះសង្ឃ ២៥០ អង្គ តំបញ្ចេញវាចាថា សាធុ ត្រមគ្នា ហើយចាប់សូត្រចាលីបាឋដកសិក្ខាបទទី ៤ ត្រមតាំងនិទានដរាបដល់ចប់ ។ ចំណែកខាងពុទ្ធបរិស័ទជាតិកូមានិងអ្នកតំណាងប្រទេសនានាក៏បានទទួលអនុមោទនាថា សាធុ ត្រមគ្នា ។

៧- លោកកន្តិសុខ: លេខាធិការនៃធម្មសង្គាយនា ថ្លែងការណ៍ចំពោះព្រះសង្ឃ ២៥០០ អង្គ សូមជ្រើសរើសយក ៥០០ អង្គ ទុកដើម្បីទំនងធ្វើសង្គីតិការកៈរវាង ២ ឆ្នាំតទៅអនាគត ។

៨- លោក អ៊ូ ធ័ន ថុន លេខាធិការនៃពុទ្ធសាសនស៍ភាកូមា ថ្លែងសេចក្តីទទួលអំណរចំពោះសេចក្តីថ្លែងការណ៍ផ្សេងៗ ក្នុងពេលបើកសម័យប្រជុំដោយសេចក្តីពេញចិត្ត ។

៩- លោកកន្តុកជ: សូត្រដងយមង្គលគាថា ហើយថ្លែងសេចក្តីរំលឹកនូវសម័យដែលបើកប្រជុំ ។

## សេចក្តីសង្ខេបកិច្ចការប្រជុំ

នៅទីការនោះ យើងបានសង្កេតឃើញពួកព្រះសង្ឃចាំង ២៥០០ អង្គ ក្នុងពិធីប្រជុំធ្វើសង្គាយនានោះ ដែលខ្លះមកពីលង្កាទ្វីប, ខ្លះមកពីឥណ្ឌា, ខ្លះមកពីនេប៉ាលជាដើម ទំនងព្រះសង្ឃប្រទេសកូមា សុទ្ធសឹងមានចំពរ, ស្បង់ទំនងសង្ឃាដីដូចៗគ្នា គឺដូចចាំងថ្មេរ, ចាំងខ្មៅ, ចាំងកន្ទៃងំ-តូច ចាំងទឹកអម្ចត់ដែលជ្រលក់កំមានពណ៌ត្រហមត្រមៅស្រស់ដូចគ្នាទៀត សមរម្យជាពណ៌សមណកេទ; ចំណែកព្រះសង្ឃប្រតិភូខ្មែរ មានសម្លៀកជាប្រមុខ ក៏សុទ្ធតែមានពណ៌ចំពរត្រូវទំនងព្រះសង្ឃចាំងនោះដែរ ដោយយើងបានជ្រលក់គ្រាក់ខ្លះឲ្យបានពណ៌ល្មមគួរដល់ការប្រើប្រាស់តាំងពីអាយុទៅ ។ តែងំនេះយើងយល់ឃើញថាព្រះសង្ឃចាំងនោះសុទ្ធតែនៅប្រទេសផ្សេងគ្នា ហើយឆ្ងាយពីគ្នាណាស់

ផង តែអាចប្រើប្រាស់ត្រៃចីវរត្រួមទាំងពណ៌ត្រៃចីវរត្រូវគ្នាសុទ្ធសាធ ឃ៉ាងនេះ មកពីលោកចេះព្រះត្រៃបិដកហើយធ្វើតាមច្បាប់កុងគម្ពីរតែមួយដូចគ្នា, ព្រះសង្ឃដែលមកប្រជុំទាំងប៉ុន្មាននោះ សុទ្ធតែចេះបាលីអាចនិយាយប្រស័យគ្នាទៅវិញទៅមក ជាភាសាបាលីដោយរួសរាវបាន ។

## ដំបន្ទន្ទកិច្ចរបស់ឥស្សរជនជាតិភូមា

ថ្ងៃទី ២០ ខែសីហា ១៩៥៤, វេលាព្រឹកម៉ោង ១០, ព្រះសង្ឃចំនួន ២៥០០ អង្គ នឹងគ្រហស្ថជាអ្នកបរិច្ចាគទាំងអស់បានទទួល-អញ្ជើញទៅទទួលភត្តនៅគេហដ្ឋាននៃលោកបណ្ឌិត អ៊ូតអ៊ូ ប្រធានាធិបតីប្រទេសភូមាក្រុងរ៉ង្គូន ។

ថ្ងៃទី ២១ ខែសីហា ១៩៥៤, វេលាព្រឹកម៉ោង ១០, ព្រះសង្ឃប្រទេសកម្ពុជា, ព្រះសង្ឃប្រទេសថៃ នឹងព្រះសង្ឃប្រទេសលាវ មានសម្តេចព្រះមហាសុមេធាធិបតីជាប្រមុខ មួយអន្ទោដោយពួកគ្រហស្ថទាំង ៣ប្រទេសំ បានទទួល-អញ្ជើញទៅទទួលភត្តនៅគេហដ្ឋាននៃឯក ឧត្តម-អ៊ូ-នុ នាយករដ្ឋមន្ត្រីប្រទេសភូមាក្រុងរ៉ង្គូន ។ ក្នុងវេលាដែលទទួលភត្តនៅគេហដ្ឋាននៃលោកនាយករដ្ឋមន្ត្រីនោះ សម្តេចគង់រថយន្តពិសេសដោយឡែក (រថយន្តសម្រាប់ ឯ. ឧ. អ៊ូ-នុ) មានពួកនគរបាលជាតិដ៏ខ្លោចក្រយានយន្តនាំមុខនឹងអមក្នុងស្តាំ ដកឋដល់គេហដ្ឋាននៃ ឯ. ឧ. នាយករដ្ឋមន្ត្រី ទាំងទៅទាំងមក មានដំណើរដូចគ្នា ។

ថ្ងៃទី ២២ ឧសភា ១៩៥៤, ម៉ោង ៩,១៥ លោកវរសេនីយ៍ឯក ស្នងការ ក្រសួងធម្មការនិមន្តព្រះសង្ឃប្រចេសកម្ពុជា, ប្រចេសថៃ និងប្រចេសលាវ មានសម្តេចព្រះមហាសុមេធាធិបតីជាប្រមុខ នៅចំពោះព្រះបរិត្តនៅមន្ទីរ ធម្មសភាជាតិសង្គីតរចនីយ (ហៅស្ទេតាគុង) ម៉ោង ១០,១៥ ទើប និមន្តទៅទទួលកត្តព្រមទាំងជវិការនៅគេហដ្ឋាននៃ ឯ. ឧ. អ៊ូ វិន រដ្ឋមន្ត្រី ក្រសួងធម្មការ ។ រំលងដែលសម្តេចនិមន្តទៅមកអំពីគេហដ្ឋាននៃលោក រដ្ឋមន្ត្រីនេះ មានភ្នាក់ងារនគរបាលជិះទោចក្រយានយន្តនាំមុខនិងអម ឆ្ពោះស្តាំផង, បន្ទាប់ពីរថយន្តសម្តេចមក រថយន្តព្រះសង្ឃប្រចេសខ្មែរ ថៃ លាវ ជាច្រើនគ្រាពីខាងក្រោយ ។

## សេចក្តីសង្ក្តេតក្នុងការធ្វើជាអាចារ្យនៃពុលាឡ

ពួកឥស្សរជនប្រចេសកម្ពុជា ដែលនិមន្តព្រះសង្ឃទៅទទួលកត្ត ចំពោះព្រះបរិត្តរៀងខ្លួននោះ យើងបានសង្កេតមើលមិនឃើញមានអ្នកណា មួយធ្វើជាអាចារ្យដំទួសអស់លោកឥស្សរជននោះ ។ ឡើយ, ឃើញតែ លោកជាម្ចាស់ផ្ទះម្ចាស់បុណ្យនោះឯងធ្វើជាអាចារ្យផ្ទាល់ខ្លួន, បើទទួល កត្តនៅផ្ទះលោកប្រធានាធិបតី ។ ផ្តើមនាំគេឯទៀតសូត្រធម៌សុំសីល ដោយខ្លួនលោក ចំណែកខាងផ្ទះលោកនាយករដ្ឋមន្ត្រីនិងលោករដ្ឋមន្ត្រី ធម្មការជាដើមក៏ដូចគ្នាដែរ ។ ត្រង់ណែះ យើញថាឥស្សរជនប្រចេស កម្ពុជា ខុសពីឥស្សរជនក្នុងប្រចេសយើង ។ (មានត)

# ភ្នំពេញសម័យ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ




ឆ្នាំទី ២៦ ខែធ្នូ លេខ ១២

ព.ស. ២៤៩៨ — គ.ស. ១៩៥៤




ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| — សន្តានទៅមនុស្សជាន់ ..... | ព្រះធម្មបាលវង្ស ម៉ឺង - សែស ... | ៨៨៣ |
| — បញ្ញាសជាតក ភាគទី ៩ (តមក) ... | បណ្ឌិតមហា ឈឹម -ស៊ីម ..... | ៨៨៦ |
| **ផ្នែកអក្សរសាស្ត្រ** | | |
| — រឿងសៅរសោយ (តមក) ..... | ព្រះមហាឧត្តមវិជ្ជា ប៊ឹង—ប៉ម ... | ៨០៨ |
| — រឿងសាមកុក (តមក) ..... | ឧកញ៉ា ង្ហ- កន ..... | ៨១៣ |
| — នាលៈនិងទមយន្តី (តចប់) ..... | អ្នកស្រី ស្រឹង-សារីយ៉ាន់ ... | ៨១៨ |
| — ដំណឹងតាមឡរ៉ល់ក្នុងភន្តារៈ (តមក)... | លោក ផេង - ជ្រឹរ ..... | ៨២៩ |
| — រឿងបល្ល័ង្កទិព្យ (តមក) ..... | លោកវ៉ាយ - ប៊ុក ..... | ៨៣៤ |
| **កំណត់ទឹកប្រវត្តិការណ៍** | | |
| — ដំណើរទៅកាន់ប្រទេសភូមា (ត- ចប់) .. | ព្រះទេពសត្ថា កឹម- ភួរ ..... | ៨៣៩ |
| — បញ្ជីរាយនាមបៅអធិការដែលទើបតាំងថ្មី . | (តមក) ក្រសួងធម្មការ ..... | ៨៥៩ |



មួយឆ្នាំមាន ១២ លេខរៀៗ — ដំឡៃដារ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

PARTIE RELIGIEUSE: Page

— Satthadevamenussanam . . . . vén. MENG-SES . . . . . 883

— Pannasajataka- vol 3 (suite) . M CHHIM-SOUM . . . . . 896

PARTIE LITTERAIRE:

— Le «SAU SOY» ou l'influence saturnienne (suite) . . . . . vén. PEUNC-PAM . . . . . 908

— Histoire de samkok (suite) . . oknha NOU-KAN . . . . . 913

— Nala et Damayanti (suite et fin) Mme SRIN-SARIS-YANN . . . 918

— Le souffle du désert (suite) . . M. PHENG-CHRIV . . . . . 929

— Les trente deux récits du TRONE (suite) . . . . . M. RAY - BUC . . . . . 934

NOTES ET CHRONIQUES:

— Le voyage en Birmanie(suite et fin) Brah Debasatha KEM-TO. 939

— La nomination des nouvaux chau-Adhikar (suite) . . . . . Ministère des Cultes . . . 959

Prix d'abonnement annuel (comprenant 12 numéros) 200$00

# សូមជូនដំណឹង

## អំពីទស្សនាវដ្តីកម្ពុជសុរិយា ផ្សាយចេញ

## អំពីពុទ្ធសាសនបណ្ឌិត្យ

---

ទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៤ ដែលអស់លោក-អ្នក ចានចុះឈ្មោះជាវមកនោះ នឹងចប់ត្រឹមខែលេខ ១២ នេះហើយ ។ យើងសូមថ្លែងអំណរគុណយ៉ាងក្រៃលែង ចំពោះអស់លោក-អ្នកដែល ចានចុះឈ្មោះជាវទាំងនោះ ហើយមានសង្ឃឹមថា អស់លោក អ្នកនឹង ចុះឈ្មោះជាវទស្សនាវដ្តីកម្ពុជសុរិយាក្នុងឆ្នាំ ១៩៥៥ តទៅទៀត ដែល យើងកំពុងរៀបរៀងនឹងប្រមូលផ្សុំរឿងរ៉ាវនឹងចោះពុម្ព ។ កិច្ចដែល អស់លោក-អ្នកចុះឈ្មោះជាវច្រើនឡើង ។ នេះ ឈ្មោះថាជាការជួយ ឧបត្ថម្ភអក្សរសាស្ត្រខ្មែរឲ្យលូតលាស់ចំរើនឡើង ទាំងឈ្មោះថាជាការ ជួយឲ្យកម្លាំងនឹងលើកតំកើងខ្លួនពួកអ្នកនិពន្ធខ្មែរយើង ។

តាមការណ៍ពិត ទស្សនាវដ្តីកម្ពុជសុរិយានេះ ជាទស្សនាវដ្តីផ្លូវការ ផ្សាយចេញនូវរឿងរ៉ាវផ្នែកសាសនានឹងអក្សរសាស្ត្រ ទុកដូចជាប្រទីប សម្រាប់បំភ្លឺប្រជាជនរួមជាតិឲ្យមានបញ្ញាចក្ខុ មើលឃើញច្បាស់នូវ សេចក្តីវិនាសនឹងសេចក្តីចំរើនក្នុងផ្លូវលោកនឹងផ្លូវធម៌ ព្រមទាំងពង្រីក អក្សរសាស្ត្រជាតិឲ្យរីកធំទូលាយតាមសម័យ ។

ឯរឿងព័ត៌មានក្នុងផ្នែកសាសនានឹងអក្សរសាស្ត្រ ដែលយើងនឹងចោះពុម្ព ផ្សាយក្នុង ទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៥ ដូចមានកាយមាតិកាតទៅនេះ ៖

## ផ្នែកសាសនា

១ - ជំណឹងផ្សេង ៗ ខាងព្រះពុទ្ធសាសនា ។

២ - ធម្មទេសនា ដែលមានអត្ថរសច្រើក ៗ ។

៣ - សីលធម៌របស់ព្រះពុទ្ធសាសនា ។

៤ - ការជ្រើសរើសប្រែព្រះសូត្រខ្លះ ដែលមានសេចក្តីគួរដឹងនឹងជាផ្លូវប្រតិបត្តិ ។

## ផ្នែកអក្សរសាស្ត្រ

១ - គោលចារឹកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងការសិ្ងាយឃ្វាងចាស់ ៗ ឬទំនើប ។

២ - ឯកសារ (រឿងព័ត៌មានសំខាន់ ៗ ដូចសិលាចារឹកជាដើម) ។

៣ - រឿងសាមកុក នៅតែចោះពុម្ពតទៅទៀត គ្រាតែចប់ ។

៤ - សុភាសិតផ្សេង ៗ របស់ជាតិយើងនឹងនានាជាតិ ។

៥ - រឿងព្រេងខ្មែរ ឬរឿងព្រេងរបស់នានាជាតិ ។

៦ - រឿងទំនៀមទម្លាប់ខ្មែរ របស់គណៈកម្មការទំនៀមទម្លាប់ខ្មែរ ។ ល ។

ហេតុនេះ អស់លោក-អ្នកដែលមានចំណងនឹងជាវទស្សនាវដ្តី
កម្ពុជសុរិយាប្រចាំឆ្នាំ ១៨៩៩ សូមផ្ញើឈ្មោះពីឥឡូវនេះទៅ អគ្គលេខា-
ធិការនៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ (Monsieur le Secrétaire
Général de l'Institut Bouddhique Phnom-Pénh) ដោយមានចុះនាមទឹន
ទីលំនៅ ត្រមាំងដំឡៃជាវប្រចាំឆ្នាំចំនួន ២១០ រៀលផង ។

ពុទ្ធសាសនបណ្ឌិត្យ

---

ជាតិខ្មែរអាស្រ័យយើង

បើស្រឡាញ់កូន ត្រូវស្រឡាញ់ជាតិ,
បើស្រឡាញ់ជាតិ ត្រូវស្រឡាញ់អក្សរសាស្ត្រ,
តែកុំស្រឡាញ់ត្រឹមមាត់ ត្រូវឧបត្ថម្ភជាតិនឹងអក្សរ-
សាស្ត្រ ដូចឧបត្ថម្ភកូន ទើបជាតិនឹងអក្សរសាស្ត្រ
រស់នៅជៀងមានជំនៃ ស្មើមុខនឹងអរិយប្រទេស
ក្នុងលោក ។

ឃ. អ.

# សត្ថា ទេវមនុស្សានំ

## ព្រះឧបាលិវង្ស ម៉ឹង-សែស វត្តមហាមន្ត្រី

រៀបរៀង

---

### ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ (ត្រមាំង ព្រះធម្មិនឹងអរិយសង្ឃ ដោយសេចក្តីគោរព) ។*

*ឧកាសនេះ អាត្មាភាពសូមសំដែងអំពីព្រះពុទ្ធគុណត្រង់បទថា* សត្ថា ទេវមនុស្សានំ *ដែលពុទ្ធបរិស័ទតាំងឡាយ ភ្ជាប់សូត្រតៗគ្នាថ្វាយបង្គំសព្វទិវាតិ ។ ពាក្យថា* សត្ថា ទេវមនុស្សានំ *នោះ ប្រែថា " ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជាគ្រូនៃទេវតានឹងមនុស្សតាំងឡាយ " តែព្រះអង្គប្រៀនប្រដៅណែនាំពន្យល់ទេវតានឹងមនុស្សឲ្យចេះដឹងស្គាល់ប្បាស់ត្រង់ប្រយោជន៍ ៣ យ៉ាង គឺ ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ដែលកើតមានឡើងក្នុងបច្ចុប្បន្ននេះ ១ សម្បរាយិកត្ថៈ ប្រយោជន៍ដែលកើតមានឡើងក្នុងបរលោក ១ បរមត្ថៈ ប្រយោជន៍ដ៏សំខាន់ជាងគេបំផុតគឺព្រះនិព្វាន ១ ។*

### ប្រយោជន៍ក្នុងបច្ចុប្បន្ន

*ឯប្រយោជន៍ដែលកើតមានឡើងក្នុងបច្ចុប្បន្ននេះ នោះសម្រេចមក*

អំពីសេចក្តីព្យាយាមចំពោះនូវសេចក្តីសិក្សារៀនចំណេះវិជ្ជា តាំងអំពីអក្សរសាស្ត្រ
លេខនព្វន្ត រហូតដល់ទៅវិជ្ជាគួរចំផ្សេងៗ មានវិជ្ជារបស់ជាងមាស
ជាងថ្កាក់ ជាងស្មិទ្ធិ ជាងឥដ្ឋ កំបោរ ជាងឈើជាដើមក៏មាន,
សម្រេចមកអំពីកម្លាំងកាយ កម្លាំងចិត្ត ចំណែកខ្លះប្រឹងប្រែងធ្វើការងារ
ឥតមានអាងុញ្ញាគាន់ទឹងត្រជាក់ក្តៅ ខ្យល់យ ហត់អត់ឃ្លានលំបាកក៏មាន,
តាំងអំពីក្រៃហួតដល់គាន់ខ្លើន, សមដូចបទភាសិតក្នុងមង្គលសូត្រ ១ កន្លែងថា អនាកុលា ច កម្មន្តា ប្រែថា " ការងារមិនល្អក់ មិនផ្គេសផ្គាស មិនឆ្ងល់ " គឺ ការងារដែលត្រឹមត្រូវមិត្តចត់ស្អាតបាត; ការងារបែបនេះជាមង្គលដ៏ឧត្តម ។

ពាក្យថា " ការងារមិនល្អក់ មិនផ្គេសផ្គាស មិនឆ្ងល់ " នោះ
សំដៅយកកសិកម្ម គោរក្ខកម្ម ទីឆ្ងាវណិជ្ជកម្មជាដើម ។

កសិកម្ម គឺការងារភ្ជួរកាស់ដីចំការប្លង្រៃ ព្រមទាំងសាបព្រោះ
ដកស្មៅ ច្រូតបូតក្តិចក្តាប់ ចោកបែនអុំកេយ រែកពុនដឹកជញ្ជូនផល
ស្រូវយកទៅជាក់ដោក ដាក់ដង្ក្រែក ។

គោរក្ខកម្ម គឺការងាររក្សាថែទាំគោក្របី ដោយមេត្តាករុណាពិតៗ
ចំប្រឹងប្រែងការពារចោរឆ្នួយកុំឲ្យលួចប្លន់យកបាន ការពារសត្វជាសត្រូវ
ផ្សេងៗ មានមូសសុចរជោមជាដើម ប្រឹងប្រែងបំប៉ននិស្ស៊ៀឲ្យជាត់ធំមាន
កំឡាំងច្រើន ដើម្បីតឹងផ្ចែកយកកំឡាំងសត្វទាំងនោះ ជំនួសកំឡាំង

ខ្លួនផង ដើម្បីយកគោរសចាំង ៥ សម្រាប់ចិញ្ចឹមជីវិតខ្លួនផង លក់ដូរ
យកថ្លៃជាស្បៀងលៀនជីវិតទៅមុខផង ។

ឯគោរសចាំង ៥ នោះគឺ: ឱរំ ទឹកដោះស្រស់ ១ ទធិ ទឹកដោះជូរ
បន្ទាប់អំពីទឹកដោះស្រស់នោះ ១ ឃ្រឹតំ ទឹកដោះថ្លា ១ តក្កំ ទឹកដោះរាវ
គេលាយដោយទឹកសុទ្ធ ៣ ភាគ ទឹកដោះមួយភាគ តែមានរសជូរ ១
ផរិធីតំ ទឹកដោះខាប់ ១ ។

វណិជ្ជកម្ម គឺការដោរដូរញ្ញែតាមផ្លូវគោក ផ្លូវទឹក ក្នុងទីផ្លុះសំ-
បែងកន្លែងកន្លះជាដើមផង ទិញថោកលក់ថ្លៃដោយមិនបំបាត់ប្រាំពួន
ជាកំរៃចិញ្ចឹមជីវិត បង្កបង្កើនធនធានតាំងអំពីតិចតួច រហូតដល់ច្រើន
កប់មិនអស់, ដូចជាចូឡកន្តេវាសិកបុរស ក្នុងក្រុងពារាណសីក្នុងអតីត-
កាល កាលពីដើមនៅជាអ្នកបំរើរបស់ចូឡកសេដ្ឋី ជាអ្នកតំសត់ទីចំលែក
បានសត្វកណ្តុរងាប់ត្រឹមតែមួយប៉ុណ្ណោះ យកទៅលក់ឲ្យគេ អ្នកចិញ្ចឹម
ឆ្មាម្នាក់ គេទិញយកទៅឲ្យឆ្មាស៊ី បានដំឡៃជាប្រាក់ចំនួន ១ កាកណិក
យកប្រាក់ ១ កាកណិកនោះទៅទិញ របស់របរលក់ដូរតេះតោះយក
ចំណេញបន្តិចម្តងៗ យូរៗទៅ កាន់តែបានចំណេញច្រើនឡើងឥត
អាក់ រហូតដល់ទៅមានប្រាក់ចំនួនពីរសែន (២០០.០០០) កហា-
បណៈ បុរសកំសត់នោះប្រែកបដោយសេចក្តីកតញ្ញូដ៏គុណ១បការចូឡក-

សេដ្ឋី ដែលបានសន្សើរទំនុកបំរុងខ្លួនពីដើម កំយកថ្លាក់ ១ សែន (១០០.០០០) កហាបណៈទៅដូនចូឡកសេដ្ឋី។ គំគិតថាបុរសនេះមិនមែនជាអ្នកឋយថោកទេឡើយ ជាអ្នកប្រកបដោយបញ្ញាស្មារតី ទំនងសេចក្តីព្យាយាមឱ្យឃ្លាត ទុហាតសង្ឃឹតរកស៊ីធ្វើការដូញប្រែ ផ្សេងៗ សន្សំទ្រព្យសម្បត្តិបានច្រើនដល់ប៉ុណ្ណោះ បុរសនេះមិនសមនឹងនៅជាអ្នកបំរើអញទៀតឡើយ ហើយកំឱ្យកូនស្រីរបស់ខ្លួន ធ្វើជាភរិយារបស់បុរសនោះ។ លុះចូឡកសេដ្ឋីធ្វើមរណកាលទៅ បុរសនោះក៏បានឡើងជាសេដ្ឋីតំណាងចូឡកសេដ្ឋីនោះឡើង បានថ្កុំថ្កើងរុងរឿងក្នុងបច្ចុប្បន្ជាតបដល់អស់ជីវិត។

ម្យ៉ាងទៀត មនុស្សដែលឯលច្រអូស ដំអក់ទំនង់ពុតត្បុតច្រើនមិនប្រឹងប្រែងធ្វើការរកស៊ី រមែងជួបប្រទះនឹងទុក្ខលំបាក ដោយក្រខ្សត់អត់ឃ្លាន, សមដោយបាលីពុទ្ធភាសិត ១ កន្ទែងថា:

អតិសីតំ អតិឧណ្ហំ អតិសាយមិទំ អហុ
ឥតិ វិស្សដ្ឋកម្មន្តេ អត្ថា អច្ចេន្តិ មាណវេ

ប្រែថា "មនុស្សណា និយាយពាក្យគួរញ៉ែរបណ្តោះបណ្តែថា "ត្រជាក់ពេកណាស់ ក្តៅពេកណាស់ ល្ងាចពេកណាស់ ធ្វើការមិនបានទេ" ហើយមិនធ្វើការងារ, ប្រយោជន៍ទាំងឡាយគឺទ្រព្យសម្បត្តិ រមែង

លោតផ្លោងលែងមនុស្សនោះដែលលះបង់ការងារចាលចេញ មិនបិតនៅជិតមនុស្សនោះឡើយ" ។

មនុស្សដែលមានខន្ធីអំណត់អត់ធ្មត់ធ្វើការងារ រមែងបានសេចក្តីសុខ - ចំរើនជាងគ្រោយ, សមដោយបាលីថា:

យោ ច សីតញ្ច ឧណ្ហញ្ច តិណា ភិយ្យោ ន មញ្ញតិ
ករំ បុរិសកិច្ចានិ សោ សុខា ន វិហាយតិ

ប្រែថា "មនុស្សណាមិនសំគាល់នូវត្រជាក់ទឹងក្តៅដោយក្រែលែងជាងស្មៅ គឺជាមិនអើពើ មិនរាងធុញទ្រាន់នឹងត្រជាក់ក្តៅ សំគាល់ត្រជាក់ក្តៅនោះ ប្រហែលគ្នានឹងស្មៅដែលៈតជាន់ដោយដើង, ទំរឹងប្រែងធ្វើកិច្ចការងារបស់បុរស, មនុស្សនោះមិនសាបសូន្យចាកសេចក្តីសុខដែលកើតអំពីទ្រព្យសម្បត្តិ ព្រោះការចាយវាយទ្រព្យសម្បត្តិបរិភោគឡើយ" ។

ន័យមួយទៀត ប្រយោជន៍ក្នុងបច្ចុប្បន្ននេះ បើប្រមូលរួបរួមមក មាន ៤ ប្រការគឺ:

๑.- ឧដ្ឋានសម្បទា ការក្រោកឡើងប្រញាប់ប្រញាល់រកនូវខ្នះខ្នែងស្វែងរកប្រយោជន៍ គឺទ្រព្យសម្បត្តិដោយពេញកម្លាំង ត្រាតែបានសម្រេចប្រយោជន៍ម្ល៉ាង ៗ ដូចបានសំដែងហើយខាងដើម ។

២.— អារក្ខសម្បទា មានទ្រព្យសម្បត្តិមកហើយប្រុងប្រយ័ត្នរក្សាការពារថែទាំទ្រព្យសម្បត្តិនោះឲ្យគង់នៅមិនឲ្យរលាត់រំលាយ មិនឲ្យអន្តរាយខូចខាតទៅដោយសត្វកណ្តៀរ កណ្តុរ ភ្លើងនេះ ចោរលួចជាដើម ។

៣.— កល្យាណមិត្តតា ការសេពគប់កាប់ច្រៃសត្វ នឹងអ្នកច្រក្ដដ្ឋសប្បុរសដែលមានសទ្ធាន ល្អធ្វើជាមិត្តសិក្ខាស្មោល ដេកអង្គុយឈរដើរជាមួយគ្នា ដើម្បីបើកកែកពន្លឹកបញ្ញាឲ្យចេះដឹងស្គាល់ការខុសត្រូវ សត្វអន្ទើតែងបានល្អរៀនដូចជាពួជហង្ស ដែលទំនម់នៅលើកំពូលភ្នំមាស ដែលមានពន្លឺស្មើល្អ ពួជហង្សក៏ល្អដោយសារភ្នំមាសនោះដែរ ។

៤.— សមជីវិតា ការចិញ្ចឹមជីវិតស្មើល្មមដោយទ្រព្យដែលខ្លួនរកបាន គឺរកមានកិច្ចចាយវាយចិញ្ចឹមជីវិតតាមកិច្ច រកបានច្រើនចាយវាយចិញ្ចឹមជីវិតតាមច្រើន មិនប្រើច្រាស់ឲ្យហួសហេតុហួសប្រមាណ មិនឲ្យដំពាក់ចំណុលគេ ។

## ប្រយោជន៍ក្នុងបរលោក

ឯប្រយោជន៍ដែលកើតមានឡើងក្នុងបរលោកនោះ មានច្រើនប្រការណាស់ តែដើម្បីមូលរួបរួមឲ្យខ្លីទៅ មានត្រឹម ៤ ប្រការគឺ:

១.— សទ្ធា ការជឿជាក់ចំពោះកម្មនឹងវិបាកថា មានពិតមែន

អំពើល្អអាក្រក់ដែលធ្វើដោយកាយវាចាចិត្ត ហៅថា កុសលកម្ម អកុសលកម្ម, ផលដែលកើតចេញមកអំពីកម្មទាំងពីរនោះហៅថា វិបាកៗ ជាអព្យាកតធម៌ មានប្រកែកច្រើន មានបដិសន្ធិចិត្ត ភវង្គចិត្ត ឆឹងចុតិចិត្ត ជាដើម ព្រមទាំងសុខទុក្ខ ដែលហៅថា វិបាកសុខ វិបាកទុក្ខ ។

មួយទៀត ការដឿថាសត្វមានកម្មជាវបស់ខ្លួន សត្វធ្វើនូវកម្មណាៗ ល្អឬអាក្រក់ តែងបានទទួលយកផលវបស់កម្មនោះៗ ។

ការដឿជាក់ចំពោះពោធិញ្ញាណរបស់ព្រះតថាគត សេចក្តីថា មានបុរសអស្ចារ្យខ្លះៗ បានបំពេញពុទ្ធការកធម៌ ឬបារមីធម៌ទាំង ១០ មានទានជាដើម បានពេញគ្រប់គ្រាន់ហើយ បានត្រាស់ដឹងធម៌ទាំងឡាយជាព្រះពុទ្ធប្រកបដោយគុណច្រើនប្រការ មានអស់កិលេសជាដើម ។ ការដឿដូច្នេះនាំឲ្យកើតកុសលទាំងពួង កើតផលល្អក្នុងលោកខាងមុខ បានជាហៅថា ប្រយោជន៍ក្នុងបរលោក ។

ម្យ៉ាងទៀត សទ្ធានេះជាគូគ្នានឹងបញ្ញា តែងជួយគាំពារយឹតយោងបញ្ញា ឲ្យស្ទុះឡើងទៅរកបុណ្យកុសលមិនឲ្យគ្រាន់តែដឹងទេ ឥតមានធ្វើកុសលអ្វីសោះនោះឡើយ ។ សទ្ធានេះជាទ្រព្យប្រសើរវិសេសរបស់បុរសក្នុងលោកនេះ ហៅថាអរិយទ្រព្យផង ជាមិត្តសំឡាញ់របស់អ្នកដែលសាងបុណ្យកុសលទាំងពួងផង ។

២_ សីលៈ: ការសង្រួមប្រឹងប្រយ័ត្នកាយវាចាឲ្យរៀបរយល្អ ឲ្យមានរបៀបបទសណ្តាប់ធ្នាប់ត្រឹមត្រូវ, មានលក្ខណៈប្រមូលខុនខ្លួកាយកម្ម វចីកម្ម មនោកម្ម ឲ្យមូលល្អ មិនឲ្យពត់ពយភ្នត់ភ្នយផ្តេសផ្តាស, មានលក្ខណៈស្ងួយខ្នុវកុសលធម៌ទាំងពួង ដូចជាផែនដីតែងស្ងួយខ្នុវផ្ទះសំបែងព្រឹក្សាលតាវល្លិស្មៅជាដើម, មានប្រកែខច្រែន មានសីល ៥ សីល ៨ ជាដើម, សីលនេះបើបរិសុទ្ធផូរផង់ពេញទីហើយ រមែងមានក្លិនក្រៃបក្រែអបក្រអូបឈ្ងុយឈ្ងប់ ផ្សាយទៅកន្លងមនុស្សលោកនឹងទេវលោកជាហេតុនាំឲ្យបានខ្លួសុគតិភព, បានជាឈ្មោះថាប្រយោជន៍កន្លងបរលោក ។

ម្យ៉ាងទៀតសីលនេះជាហេតុនាំឲ្យកើតសមាធិផង ជាទ្រព្យប្រសើរវិសេស ហៅថាអរិយទ្រព្យផង ជាជ្រាមផង ។

៣_ បាគិ: ការលះកាត់កំចាត់សេចក្តីលោភ សេចក្តីកំណាញ់ជាមន្ទិលចោលចេញ ហើយលើកយកទេយ្យវត្ថុ ឲ្យទានដល់អ្នកគ្រឹក្រលំបាកជាដើម, រមែងកើតផលល្អកន្លងលោកខាងមុខ ទើបបានឈ្មោះថាប្រយោជន៍កន្លងបរលោក ។ ចាគៈនេះជាទ្រព្យប្រសើរវិសេសហៅថាអរិយទ្រព្យផង ។

៤_ បញ្ញា សេចក្តីដឹងខ្លួទៅ ស្គាល់ច្បាស់ការខុសត្រូវបុណ្យបាបគុណទោសជាដើម ជាពន្លឺភ្លឺស្វាងរុងរឿងកន្លងលោកជាគ្រឿងត្រៃលក់

បំភ្លឺរបស់អ្នកដែលមានបញ្ញា, ជាគួរគ្មានទីសង្ស័យ តែងជួយគាំពារ ទំនុកបំរុងសង្គ្រាមឲ្យដើរទៅតាមផ្លូវត្រង់ មិនឲ្យដឿខុសផ្តេសផ្តាសច្រឡេសច្រឡាសឥតប្រយោជន៍, តែងជួយដុសខាត់សីល ឲ្យបរិសុទ្ធផូរផង់ឡើង ឬជួយអប់រំសីល ឲ្យក្រអូបឈ្ងុយឈ្ងប់ឡើង, តែងជួយចាគៈ ការបរិច្ចាគទាន ឲ្យមានផលច្រើនឡើង ជាកុសលមូល គឺជាហេតុនាំឲ្យកើតកុសលទាំងពួងដែលជាពៃរហេតុ ទើបបានឈ្មោះថាប្រយោជន៍ក្នុងបរលោក ។ ជាទ្រព្យប្រសើរវិសេស ហៅថា បញ្ញាភារមីផង ។

បញ្ញានេះបានចំរើនមោះមុតស្រួចស្រាលឡើង ដោយហេតុបានសេពគប់នឹងអ្នកប្រាជ្ញសប្បុរស ដែលមានបញ្ញាជ្រាលជ្រៅមានចំណេះវិជ្ជាច្រើន ព្រមទាំងបានសិក្សារៀនសូត្រចំណេះវិជ្ជាមកពាល់ជាតិពាល់កពក, ប្រៀបដូចគាំចិត ដែលបានស្រួចស្រាលមុតថ្លាឡើង ក៏អាស្រ័យឫទ្ធិនឹងទំកព្រមទាំងកម្លាំងព្យាយាមរបស់បុរសដែលច្រឹងច្រែងដុសខាត់សំលៀងសង្ខ័តចាប់មុខញាយ។ ។

## ប្រយោជន៍ដ៏សំខាន់គឺព្រះនិព្វាន

ឯប្រយោជន៍ដ៏សំខាន់ជាងគេបំផុតគឺព្រះនិព្វាននោះ និព្វាន: ជាពាក្យចាលី ប្រែកាត់បទជាពីរបទ និ បទ ១ ព្វាន: បទ ១, និ ប្រែថាគ្មាន, ព្វាន: ជាតួតណ្ហា ប្រែថា "ដោតក្រង - ដេរ - ចាក់ស្រែះរួបរឹត"; តបទទាំងពីរចូលគ្នាជា និព្វាន: ប្រែថា "គ្មានតណ្ហា

ព្រះនិព្វានសម្រេចមកអំពី អដ្ឋង្គិកមគ្គ គឺផ្លូវមានអង្គ ៨ គឺ សម្មាទិដ្ឋិ សេចក្តីយល់ត្រូវ ១ សម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវ ១ សម្មាវាចា និយាយត្រូវ ១ សម្មាកម្មន្តៈ ការងារត្រូវ ១ សម្មាសតិ សេចក្តីរឭកត្រូវ ១ សម្មាសមាធិ ការដំកល់ចិត្តត្រូវ ១ ត្រូវជា ៨ ។ មគ្គទាំង ៨ នេះ ហៅថា ជិព្ឈនគាមិនីបដិបទា សេចក្តីប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានៗនេះហៅថា បរមត្ថៈ ប្រយោជន៍ដ៏សំខាន់ជាងគេបំផុត ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះ ប្រៀនប្រដៅទេវតានឹងមនុស្សឲ្យស្គាល់ប្រយោជន៍ទាំង ៣ ដូចមានសំដែងមកហើយដោយសង្ខេបនេះ ទើបបានទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ។

អាត្មាភាពសំដែងធម៌មកនេះ ក៏សូមបញ្ចប់ធម៌ទេសនា តឹមតែប៉ុណ្ណេះ សូមថ្វាយព្រះពជកុសលចំពោះព្រះករុណា ជាអម្ចាស់ដីវិតព្រះហឫទ័យក្លាហានក្នុងកិច្ចការ ជាធម្មិកមហារាជ ព្រមទាំងព្រះពជវង្សានុវង្ស សូមជួនកុសលជូនដល់អស់លោកអ្នករាជការគ្រប់ដំណែងក្នុងក្រសួងវប្បធម៌ និងពួកអស់លោក - អ្នកសប្បុរសដែលបានស្តាប់ធម៌នេះ សូមឲ្យបានសម្រេចតាមបំណងប្រាថ្នាផង ដូចគ្រាថាកុំបីឃ្លាតឡើយ ឯវំ សង្ខេបេន សម្មត្តា ធម្មទេសនាកថាបញ្ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# បញ្ញាសជាតក

## ភាគទី ៣

ចម្លែកតមហា ឈឹម - សុំម សាស្ត្រាចារ្យ

នៅសាលាបាលីដាន់ខ្ពស់ បាត់ឲ្យប្រៃហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅភោទបព្វជិតពី ព. ស. ២៤៨៦, គ. ស. ១៩៤៣

---

ខុលកបណ្ឌិតទី ១១

លោកអាចារ្យ ឈឹម - ណាក ក្រុមដំនុំព្រះត្រៃបិដក

ប្រែពីបាលី

កម្មយោនិ កម្មពន្ធូតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ
អត្តនោ ទានបារមឹ អារព្ភ កថេសិ ។

*សត្ថា កាលអង្គសម្តេចព្រះសាស្តាចារ្យជាម្ចាស់ ទ្រង់ប្រថាប់
នៅវត្តជេតពន នាក្រុងសាវត្ថី ទ្រង់ប្រារព្ធនូវទានបារមីរបស់ព្រះអង្គ
ទ្រង់សំដែងធម៌ទេសនាមានបទថា កម្មយោនិ កម្មពន្ធុ ដូច្នេះជាដើម ។*

*មានសេចក្តីដំណាលថា ក្នុងសម័យដែលកន្លងទៅហើយ កាលព្រះ
ដ៏មានព្រះភាគជាលោកនាយកទ្រង់ព្រះនាមកស្សប បរិនិព្វានទៅបាន
៧ ថ្ងៃ មានព្រះរាជា ១ ព្រះអង្គ ទ្រង់ព្រះនាមចិន សោយរាជសម្បត្តិ
ក្នុងចិនរដ្ឋ ។ នៅក្នុងនគរនោះ មានព្រាហ្មណ៍ម្នាក់ជាបុរោហិតរបស់*

ព្រៃអង្គ ។ ក្នុងសម័យនោះមានកុក ៣៣ រូប មានឥន្ទ្រិយស្រគត់ស្រគំរម្យ ទំយ៉ាងកៃលែង បាននិមន្តចូលមកតាមវិថីនៃនគរ ។ ព្រាហ្មណ៍បុរោហិត បានឃើញកុកទាំងនោះហើយគិតថា យ៉ាអើហ្ន៎ ! សមណៈទាំងនេះ ចូលមកក្នុងនគរ បើព្រះរាជា ជាម្ចាស់អញបានឃើញ ប្រាកដជាទ្រង់មានព្រះរាជហប្ញទ័យដុះថ្នា ចំពោះពួកស្រមណ៍ទាំងនេះមិនខាន· កាលបើដុះថ្នាយ៉ាងនេះហើយ, លាភសក្ការៈរបស់អញនឹងសាបសូន្យជាប្រាកដ; បើដូច្នោះមានតែអញបំបែកលទ្ធិរបស់ព្រះរាជានឹងញុះញង់ព្រះអង្គឲ្យសម្លាប់ពួកស្រមណ៍ទាំងនេះចោលទើបគួរ ។ គ្រានោះ ព្រាហ្មណ៍បុរោហិត ក៏ប្រញាប់ប្រញាល់ដម្រង់ទៅកាន់សំណាក់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ចាប់ព្រះហស្តព្រះរាជានាំទៅខាងលើប្រាសាទ ក្រាបបង្គំទូលថា បពិត្រមហារាជ, ពួកចោរទាំងនោះ ក្លែងកេងជាកុក មានប្រាថ្នានឹងផ្ងន់អ្នកនគរទាំងអស់ ។ ព្រះរាជាទ្រង់ទតព្រះនេត្រឃើញពួកកុកទាំងនុ៎ះ ហើយទ្រង់ត្រាស់ថា បពិត្រលោកអាចារ្យ, ជនទាំងនេះឈ្មោះថាកុក ជាសាវ័កព្រះមហាសមណៈទេតើ ។ ព្រាហ្មណ៍បានឮព្រះរាជាមានព្រះរាជតម្រាស់ដូច្នោះហើយ ក៏ក្រាបបង្គំទូលម្តងទៀតថា បពិត្រព្រះសម្មតិទេព, នេះប្រាកដជាពួកចោរក្លែងកេងជាកុក មានបំណងនឹងចូលមកផ្ងន់អ្នកនគរទាំងអស់មែន ព្រះអង្គ ! ។ ព្រះរាជាទ្រង់ព្រះសវនាការស្តាប់ពាក្យព្រាហ្មណ៍នោះ ក៏ទ្រង់ជឿពាក្យព្រាហ្មណ៍ជាប្រាជ្ញមិត្ត ហើយ

គ្រាស់ថា អើលោកអាចារ្យ, បើដូច្នោះតើយើងនឹងធ្វើដូចម្តេច? ។ ព្រាហ្មណ៍បុរោហិតក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, សូមព្រះអង្គកុំបង្អែបង្អង់ឡើយ, សូមឲ្យពួកជបុរសចាប់ពួកគិរគាំងនោះចង ហើយឲ្យវាយយ៉ាងខ្លាំង នាំយកទៅដាក់លើឈើអណ្តាត ។ ព្រះពាលទ្ធរាជព្រះសវនាការពាក្យព្រាហ្មណ៍បុរោហិតនោះហើយ ទ្រង់មានព្រះពាលទ្ធរាជថា "ស្រួលហើយលោកអាចារ្យ" រួចទ្រង់គ្រាស់ហៅពួកពេជ្ឈឃាតឲ្យចូលមកយ៉ាងរួសរាន់ ទ្រង់គ្រាស់ព្រះពាលទ្ធរាជបញ្ជាថា នែឪ! ពួកពេជ្ឈឃាត, ចូរឯងពាល់គ្នាទៅចាប់ពួកចោរកំណែងគេទាំងកិរ ចងវាយសំពងកុំត្រាប្រណីឡើយ, ហើយនាំទៅឯព្រៃស្មសាន ដាក់លើចុងឈើអណ្តាតទៅ ។ លំដាប់នោះ ពួកពេជ្ឈឃាតដែលជាមនុស្សគ្មានសេចក្តីអាណិតអាសូរ ជាមនុស្សគ្មានដឹងគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ឮបានស្តាប់ព្រះពាលទ្ធរាជហើយក៏ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ប្រពៃហើយ ។ ពួកពេជ្ឈឃាតទាំងនោះ ក៏នាំគ្នាទៅកាន់សំណាក់ព្រះនាគទីបកត្តេ ហើយទាញយកជាតមកបំបែកចោល, ពួកពេជ្ឈឃាតខ្លះចាប់យកបីវមកហែកចោល, ពួកពេជ្ឈឃាតខ្លះវាយសំពងព្រះសិរលោកទាំងនោះ, ពួកពេជ្ឈឃាតខ្លះវាយទះមាត់ ។ គ្រានោះ កិរទាំងឡាយបានសេចក្តីទុក្ខលំបាកយ៉ាងសំបើម; មានឈាមហូរចេញពីត្រចៀក ច្រមុះ មាត់ គ្រប់ៗរូប ។ កិរទាំងនោះ ក៏ស្រែកគ្រហោយំបម្រះនៀល រងទុក្ខវេទនាជាយ៉ាង

ត្រៃលែង ។ លំដាប់នោះ ព្រះសង្ឃត្មេរលង្ឃរលោមគិតុំទាំងនោះហើយ លោកសំដែងប្រាប់ឲ្យដឹងខ្លួនដោយជម្ងឺកថាថា "ម្នាលលោកដ៏មានអាយុទាំងឡាយ, លោកកុំគិតអ្វីឡើយ, លោកកុំសោយសោកអ្វីឡើយ, នេះហើយជាហេតុរបស់កម្មចាស់នៃយើងពីរនាក់គ្នា; លោកទាំងអស់មិនដឹងទេឬ? រឿងនេះព្រះពុទ្ធដ៏មានបុញ្ញាភិសម្ភារៈធំបានត្រាស់សំដែងរួចហើយតើ;" ហើយលោកភោលតុំគ្នាថាប្រាប់គិតុំទាំងឡាយថា:

កម្មយោនី កម្មពន្ធូ កម្មស្សកា ភវាភវេ
យាវ កម្មា ន មុញ្ចន្តិ តាវ កម្មេន សំសគា
កម្មស្សកា កម្មទាយាទា កម្មប្បដិសរណា តេ
យំ យំ កម្មំ អភិសុ ឧ តំ តន្តេសំ ផលំ ទុទ្ទេ

សត្វទាំងឡាយ មានកម្មជាកំណើត មានកម្មជាផៅពន្ធ្ម មានកម្មជារបស់ខ្លួន; សត្វទាំងឡាយមិនភាន់ច្រឡំចាកកម្មដកបណា ក៏តែងជាប់ជំពាក់ដោយកម្មដកបនោះ ក្នុងកតត្ថកតធំ, សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាគ្រឿងប្រគល់ឲ្យនូវផល មានកម្មជាទីពំនាក់អាស្រ័យ; សត្វទាំងឡាយបានធ្វើហើយនូវកម្មឯណា កម្មនោះរមែងប្រគល់ឲ្យនូវផលដល់សត្វទាំងឡាយនោះ ។

គ្រានោះ ពួកអ្នកនគរទាំងអស់ក៏ផ្តើលធោខ្លោខ្លើង ។ កាលណោះ ព្រះពោធិសត្វនៃយើង ទ្រង់ព្រះនាមពុលកបណ្ឌិត កើតក្នុងត្រកូលសេដ្ឋី បានជ្រាបព័ត៌មាននោះហើយ ក៏មកប្រញាប់ប្រញាល់ ចូលទៅរកព្រះនាគទីបកត្តេរ, លុះចូលទៅដល់សំណាក់លោកក៏ក្រាបថ្វាយបង្គំព្រះថេរៈ ហើយសួរថា បពិត្រលោកម្ចាស់, លោកម្ចាស់រាល់អង្គ មានទោសកំហុសដូចម្តេច? ។ លំដាប់នោះ ព្រះថេរៈមានថេរវាចាថា ក្នុងអត្តភាពនេះ ទោសរបស់អាត្មាភាពទាំងអស់ មិនច្រកដល់ឡើយ, បើក្នុងកាលអតីតភព អាត្មាភាពទាំងអស់ មិនអាចនឹងដឹងទោសដែលកើតឡើងបានឡើយ ។ លំដាប់នោះ ព្រះពោធិសត្វដោះគ្រឿងអម្ពរឲ្យដល់ពួកពេជ្ឈឃាត ហើយប្រាប់ថា អ្នកទាំងឡាយ ចូរបង្អង់បន្តិចសិនដោយសេចក្តីសង្គ្រោះដល់ខ្ញុំ ។ ក្រុណោះ ព្រះពោធិសត្វទៅកាន់ព្រះភដំណាក់ ថ្វាយបង្គំព្រះរាជាក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេវរាជដ៏ទ្រង់នូវព្រះភដ-សម្ភារ, សូមទ្រង់ព្រះមេត្តាប្រោសសង្គ្រោះទូលព្រះបង្គំជាខ្ញុំ។ ឱងសូមថ្វាយមាសឬប្រាក់តាមសព្វព្រះរាជហ្ឫទ័យ ដើម្បីទិញយកកិកូទាំង ៣ ៣ រូប ដែលព្រះករុណាជាម្ចាស់ជីវិតឲ្យពួកពេជ្ឈឃាតយកទៅសម្លាប់ ។ ព្រះរាជាទ្រង់ព្រះសវនាការពាក្យព្រះពោធិសត្វហើយ ទ្រង់មានព្រះរាជ-ឫទ្ធារថា ម្នៃពុលកបណ្ឌិត, ពិតប្រាកដដូចជាអ្នកនិយាយមែនឬអ្ហ្ន? ។ ព្រះពោធិសត្វក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស! ពិតប្រាកដ

ដូចបានគ្រាបបង្គំទូលមែន ។ ព្រះពាជាទ្រង់ត្រាស់ថា អើពុលកបណ្ឌិត! បើដូច្នោះ ចូរឯងឲ្យមាសចំនួនទម្ងន់ប៉ុនគ្នានឹងទម្ងន់សរីរៈកុមារឯងនុ៎ះមកយើងចុះ ។ ពុលកបណ្ឌិត បានស្តាប់ព្រះពាជឱង្ការនោះហើយ ក៏មានហ្ឫទ័យពេញដោយបីតិសោមនស្ស គ្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព, ប្រពៃណាស់ព្រះអង្គ! ហើយគ្រាកចេញចាកអាសនៈទៅផ្ទះប្រញាប់ប្រញាល់ គ្រាបថ្វាយបង្គំមាតាហើយជម្រាបតាមសេចក្តីពិតថា បពិត្រមាតា, ខ្ញុំបានសូមមាស, សូមមាតាឲ្យបានមាសដល់កូនកុំខាន ។ មាតាបានស្តាប់ពាក្យព្រះពោធិសត្វហើយសួរថា ម្នាលកូនជាទីស្រឡាញ់ពេញចិត្តម្ចាស់! អ្នកយកមាសធ្វើអ្វី? ។ ពោធិសត្វជម្រាបថា បពិត្រមាតា, ខ្ញុំបានយកទៅលោះកុមារាភាវរូប ដែលស្តេចឲ្យចាប់យកទៅសម្លាប់ ។ មាតាអង្អែលពោះកូនហើយលាន់មាត់ថា "តុហ្ន! អញបានកូននេះមកបែកបង់ដោយដៃលល្អណាស់តើ!" ហើយនិយាយថា ម្នែកូនជាទីស្រឡាញ់ពេញចិត្តមាតា, ចូរអ្នកយកមាសតាមគាប់ចិត្តចុះ ។ ព្រះពោធិសត្វបានស្តាប់ពាក្យមាតាហើយ ក៏មានហ្ឫទ័យពេញដោយបីតិ គ្រាកចាកអាសនៈស្ទុះសំពត់មានជម្ងៃកាត់មិនបាន ចូលទៅកាន់ឃ្លាំងមាសដូចជាមណ្ឌលនៃព្រះចន្ទ្រកង់ថ្ងៃពេញបូណ៌មី មានរស្មីភ្លឺត្រចះអណ្តែតត្រសែតទៅកង់កណ្តាលនភាល័យដូច្នោះ ហើយជញ្ជូនយកមាសទៅគរជាគំនរក្នុងព្រះរាជដាន ទើបចូលទៅគ្រាបបង្គំទូលព្រះពាជាថា បពិត្រ

ព្រះសម្មុតិទេព, កាលនេះជាកាលគួរហើយ សូមព្រះអង្គទទួលយកមាសដែលខ្ញុំព្រះបង្គំជាខ្ញុំយកមកគរថ្វាយក្នុងទីនេះ តាមសព្វព្រះពាជហ្ឫទ័យ ។ ព្រះពាជាទ្រង់ព្រះសវនាការពាក្យពោធិសត្វហើយ ទ្រង់មានព្រះពាជឫទ្ធារថា អើបើដូច្នោះ ចូរអ្នកឯងឲ្យមកចុះ ។ លំដាប់នោះ ពុលកបណ្ឌិតចូលទៅកាន់សំណាក់ព្រះនាគទីកែត្បែរ ហើយក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន និយាយថា បពិត្រលោកម្ចាស់ដ៏ចំរើន, សូមលោកម្ចាស់ជួយសង្គ្រោះដល់ខ្ញុំព្រះករុណា, សូមឡើងគង់លើជញ្ជីង, ខ្ញុំព្រះករុណានឹងដាក់មាសទម្ងន់ប៉ុនសរីរៈលោកម្ចាស់ ហើយនឹងឲ្យជាថ្លៃនៃលោកម្ចាស់ ព្រះពោធិសត្វមានក្តីថ្នាក់ថ្នមទឹងដោះកិត្តិគាថ ៣ ៣ រូបតាមទំនងនេះ ហើយពោលប្រកាសដល់ទេវតាទាំងឡាយថា

សុណន្តុ ភោន្តោ មេ វិបតំ ទេវិសង្ឃា សមាគតា
ភិក្ខុំ ហិ បមោចេយ្យុំ ពោធិយាយេវ ការណា

បពិត្រទេវតាទាំងឡាយដ៏ចំរើន, សូមពួកទេវតាទាំងអស់ក្នុងសោឡសដ្ឋាន អញ្ជើញមកជួបជុំជាសាក្សីពេជ្ឈាណដើម្បីនឹងស្តាប់ពាក្យខ្ញុំ, ពីព្រោះខ្ញុំបានដោះកិត្តិគាថឡាយឲ្យរួចចាកមរណភ័យដោយសេចក្តីថ្នាក់ថ្នមពោធិញ្ញាណតែម្យ៉ាង ។

លំដាប់នោះពោធិសត្វ ចាននាំឲ្យពួកទៅតាឲ្យដឹងដូច្នោះហើយ
ក៏ដោះលែងតិក្ខុទាំង ៣ ៗ រូប, ប៉ុន្តែនៅសល់តិក្ខុ ៣ រូបក៏អស់មាសទៅ ។
ព្រះរាជាឃើញដូច្នោះហើយ ទ្រង់មានព្រះរាជឫទ្ធានុភាពថា នែឧុលកបណ្ឌិត,
អ្នកមានមាសទៀតដែរឬ? ។ ពោធិសត្វក្រាបបង្គំទូលថា បពិត្រព្រះ
សម្មតិទេព, ទូលព្រះបង្គំជាខ្ញុំអស់មាសហើយ ។ — អើឧុលកបណ្ឌិត, បើ
ដូច្នោះអ្នកឯងនិតនិតដូចម្តេច? ។ ពោធិសត្វបានស្តាប់ពាក្យនោះហើយក្រាប
បង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះអង្គបង្អង់បន្តិចសិន"
ហើយក្រាបថ្វាយបង្គំព្រះរាជាក្រោកចាកអាសនៈទៅកាន់ផ្ទះអាត្មា ប្រាប់
ភរិយាថា ម្នាលប្អូនស្រី, បងសូមលាឯងហើយ ដ្បិតបងបានយកមាស
ទៅថ្វាយស្តេច ដើម្បីដោះលែងពួកតិក្ខុ ៣ ៗ រូប ដែលស្តេចចាប់ពីរុន្ទ,
ឥឡូវមាសអស់ទៅ នៅសល់តិក្ខុ ៣ រូប, បងនឹងលក់ខ្លួនបងឲ្យតែបាន
ទ្រព្យយកមកបំពេញទានចុះមើ ។ ភរិយាបានឮពាក្យស្វាមីប្រាប់ ក៏
ឆ្លើយទៅវិញថា បពិត្រអ្នកម្ចាស់ជាអយ្យបុត្រ, សូមអ្នកកុំលក់ខ្លួនអ្នក
ឡើយ, សូមលក់ខ្ញុំព្រមទាំងកូនឲ្យទៅជាទាសីអ្នកដទៃវិញចុះ, អ្នក
ត្រូវការយកថ្លៃប៉ុន្មាន តាមសេចក្តីគាប់ចិត្តចុះ ។ ព្រះពោធិសត្វបានឮ
ភរិយាថាដូច្នោះ ក៏កើតចិត្តសោមនស្សពេញហ្ឫទ័យ ស្រដីថា ម្នាលប្អូន
ស្រី, ស្រួលណាស់ហើយ ។ ចាប់ដៃភរិយាដើរទៅកន្លែងមានទ្រព្យ ដល់
ហើយនិយាយថា អ្នកយកកូនប្រពន្ធខ្ញុំនេះចុះ ហើយសូមអ្នកឲ្យមាស
មកខ្ញុំ ។ នឹងយកទៅលោះតិក្ខុពីរូបដោយថ្លៃអ្នកទាំងពីរនេះ ។ លំដាប់

នោះមានសាមណេរតូច ១ រូបទៅសល់ មាសក៏អស់ទៅ ។ សាមណេរ
នោះ មានសេចក្តីតិតក័យអំពីសេចក្តីស្លាប់ យំសោកស្តាយខ្លួនឯងព្រះ
សរ មានមុខជោកជាំដោយទឹកភ្នែក ស្រែកឡើងហោយំ ហើយនិយាយ
ទៅកាត់ពួកពេជ្ឈឃាតថា ម្នាលអ្នកពេជ្ឈឃាត, ចូរអ្នកជោតអាត្មាដោយ
ដៃកស្រួចនេះឲ្យស្លាប់ឆាប់ៗទៅចុះ ។ លំដាប់នោះ ពួកពេជ្ឈឃាត
ទាំងអស់ បានស្តាប់ពាក្យសាមណេរដែលឥតទីពឹងជ្រួចនោះ ក៏បែរជាជោះ
ស្លេងបណ្តោះអាសន្នសិន ។ សាមណេរបានឱកាសដូច្នោះហើយ ក្រោក
ដើរតម្រង់ទៅកាន់សំណាក់ព្រះនាគទីបកត្តេរ ក្រាបថ្វាយបង្គំដោយ
បញ្ចង្គប្រតិស្ឋានទូលថា បពិត្រលោកម្ចាស់ដ៏ចំរើន, ខ្ញុំព្រះករុណា សូម
ថ្វាយបង្គំលាលោកម្ចាស់ហើយ, សូមលោកម្ចាស់មេត្តាសង្គ្រោះខ្ញុំព្រះ
ករុណា ? តាំងពីខ្ញុំព្រះករុណាបួសមក ក្រែងជួនជាមានសេចក្តីភ្ញាំងភ្ញាត់
បន្តិចបន្តួច ជាកាយកម្មក្តី វចីកម្មក្តី មនោកម្មក្តី សូមលោកម្ចាស់មេត្តា
អត់ទោសគឺសេចក្តីភ្ញាំងភ្ញាត់ទាំងអស់នោះដល់ខ្ញុំព្រះករុណា; នេះជាទី
បំផុតនៃអកិរិយនាការ របស់ខ្ញុំព្រះករុណាហើយ; បពិត្រលោកម្ចាស់ដ៏
ចំរើន, បើមាតាបិតាខ្ញុំព្រះករុណាសួរក, សូមលោកម្ចាស់ប្រាប់ដំណឹង
តាមរឿងរ៉ាវហ្នឹងផងចុះ, សូមលោកម្ចាស់ឲ្យវត្តពន្ធបង្អែះ បីវារ សាជកនេះ
ស្លាប់មាតាបិតាខ្ញុំព្រះករុណាឲ្យទានផង, មាតាបិតាខ្ញុំព្រះករុណានឹងស្គាល់
នូវវត្តទាំងនេះបាន; ម្យ៉ាងទៀត គាត់នឹងបន្ទោបង់នូវសេចក្តីសោកស្តាយខ្ញុំ

ព្រះកុណាថាន, សាមណេរថាន៖ពាលតាក្យដូច្នេះហើយ ក៏ស្ទើរនឹងបែកបេះដូងជាពីរភាគ ហើយអង្គុយទ្រហោយំក្នុងទីចំពោះព្រះភក្ត្រព្រះថេរៈ។ ព្រះនាគទីបកត្តេរ ឃានស្តាប់ពាក្យសាមណេរចប់ហើយ មានព្រះទ័យញាប់ញ័រខ្លួនស្ទើរតែនឹងដាច់ស្មារតី ទើបលោកនិយាយថា ម្នាលសាមណេរ អ្នកកុំគិតឡើយ, កុំសោយសោកឡើយ, អាត្មាមិនលះបង់ជីវិតអ្នកឯងឡើយ ។ លោកលួងលោមសាមណេរហើយ សំដែងធម៌ទេសនាថា

សព្វេ អនិច្ចធម្មា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារទាំងអស់របស់សត្វទាំងឡាយ មានការមិនទៀងជាធម្មតា, មានការកើតឡើងនឹងរលត់ទៅវិញជាធម្មតា, កើតឡើងហើយ រមែងរលត់ទៅវិញ. ការរម្ងាប់នូវសង្ខារទាំងនោះ ជាគ្រឿងនាំមកនូវសេចក្តីសុខ ។

ព្រះថេរៈប្រៀនប្រដៅសាមណេរនោះដោយធម្មកថាយ៉ាងនេះឯង។ ខុលកបណ្ឌិតឃានស្តាប់ធម៌ទេស្នាវបស់ព្រ ថេរៈនោះហើយ ក៏និយាយនឹងខ្លួនឯងថា នែមុលកបណ្ឌិត, អ្នកឯងស្រឡាញ់ជីវិតជាង ឬមួយស្រឡាញ់ព្រះពុទ្ធព្រះធម៌ព្រះសង្ឃជាង? លុះនិយាយដូច្នេះហើយ ក៏ពោលបង្អាប់បន្ទុះខ្លួនឯង ហើយចូលទៅកាន់ព្រះពន្លាគ្រាបបង្គំទូលថា: សូមទ្រង់

ព្រះមេត្តាច្រើនណាស, ខ្ញុំសូមព្រះបន្ទូលជាខ្ញុំនឹងលះបង់ជីវិតជំនួសសាមណេរ ។ ព្រះពុទ្ធទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលពុទ្ធក, ពិតមែនឬអ្វី? ។ - សូមទ្រង់ព្រះមេត្តាច្រើនណាស ពិតមែន ។ - អើបើពិតយ៉ាងហ្នឹងមែន, ចូរអ្នកឯងប្ដូរជីវិតចុះ ។ ពោធិសត្វ មានហឫទ័យប្រកបដោយបីតិសោមនស្ស ហើយក្រោកចាកអាសនៈទៅកាន់សំណាក់សាមណេរ ដោះលែងសាមណេរអំពីចំណងហើយពោលប្រកាសទៅដោយសច្ចវាចានេះថា:

បពិត្រទេវតាកងឆកាមាវចរសួគ៌ទាំងឡាយ, សូមលោកអញ្ជើញមកដូចជុំចាំស្ដាប់ពាក្យខ្ញុំ! ដ្បិតខ្ញុំបានលះបង់ជីវិតរបស់ខ្លួន ព្រោះហេតុបង់បានពោធិញ្ញាណតែម្យ៉ាង; ពួកទេវតាដែលឋិតនៅនាអាកាសក្ដី ឋិតនៅលើផែនដីក្ដី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្ដី អាត្មាទេវតាទាំងឡាយក្ដី សូមអនុមោទនាបុណ្យខ្ញុំ; ដោយការបរិច្ចាគជីវិតនេះ ខ្ញុំសូមឲ្យបានត្រាស់ដឹងព្រះពុទ្ធ ចំឡងមនុស្សនឹងទេវតា ទៅកាន់ត្រើយនៃជាតិភពកាលជាអនាគត, ម្យ៉ាងទៀតទៅ បើខ្ញុំនៅអន្ទោលក្នុងវដ្ដសង្សារ, សូមកុំឲ្យឃើញផែនពាលទាំងឡាយសោះ, សូមឃើញតែពួកសប្បុរសដរាបដល់ព្រះនិព្វានជាហានខ្ពង់ខ្ពស់បំផុត ។

ព្រះពោធិសត្វ កំដោះសាមណេរលែងអំពីចំណង ហើយប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចំរើន, សូមលោកម្ចាស់ខំរក្សាសីល ចំរើនមេត្តាភាវនា ផ្សាយសេចក្តីមេត្តាចំពោះសត្វទាំងឡាយ ហើយសូមគង់នៅជាសុខចុះ", ហើយក្រាបថ្វាយបង្គំសាមណេរដោយបញ្ចង្គប្រតិស្ឋានពោលយ៉ាងនេះថា "ប្រសិនជាខ្ញុំព្រះករុណាមានទោសគឺសេចក្តីធ្វេស-ប្រហែសឯណាមួយ ដោយកាយកម្មក្តី វចីកម្មក្តី មនោកម្មក្តី សូមលោកម្ចាស់អត់ទ្រាំទោសនោះ ៗ ដល់ខ្ញុំព្រះករុណា", ហើយក្រោកចាកអាសនៈ ទៅកាន់ពួកពេជ្ឈឃាត ប្រាប់ពួកពេជ្ឈឃាតថា "ម្នាលពេជ្ឈឃាត ដ៏ចំរើន, ចូរអ្នកចងខ្ញុំហើយពាយខ្ញុំតាមគាប់ចិត្តចុះ ។

លំដាប់នោះពួកពេជ្ឈឃាត ចាប់ខ្លួនកបណ្ឌិតចងដោយចំណង ជុំប្រការ រឹតត្បួយ៉ាងមាំ រាយដំសំពត់យ៉ាងក្រាស់ នាំយកទៅកាន់ព្រៃស្មសានភ្លាម ។ កន្លងថ្ងៃនោះ ពួកអ្នកនគរទាំងអស់ កំភួតកំភឹតភ្ញាក់ផ្អើលនោះឡើង ។ លំដាប់នោះមាតាព្រះពោធិសត្វ ជ្រាបព័ត៌មាននោះហើយ ក៏លើកដៃទាំងពីរគក់ទ្រូងគក់ស្មា រំសាយសក់ស្រែកទ្រហោយំ ឱ្យកន្ធាលអួលឧ។ ចុះចាកគេហដ្ឋាន រត់ទៅតាមក្រុងឯព្រៃស្មសាន, លុះទៅដល់ឃើញក្រុងដែលពួកពេជ្ឈឃាតចងរឹតត្បួងជាប់ដោយចំណង ៥ ប្រការ ដែលគ្មានទោសកំហុសបុព្វិចរួចសោះ ហាក់ដូចជាមានក្តីទុក្ខ ទីធ្លាបែកសង្កេតជាជុំពីរដង្កត ស្រែកយំអង្វរកូនថា: (មានត)

រឿងសៅរ៍សោយ

(សិសោរជាតក)

# ព្រះមហោឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមគម្ពីរសាស្ត្រាស្វាមីរាត

(តពីលេខ ១០)

---

ស៊ីស្រែចទើបវិលយាត្រា　ទៅមើលគោណា　ពុំឃើញវាសោះ ។

តាមពិតវាឯគោនោះ　ពុំស៊ីស្មៅសោះ　ពីព្រោះឃើញញី ។

ស៊ុះបោលពុំបានរកស៊ី　ដាច់ខ្សែខ្លួនខ្លី　តាមញីទៅបាត់ ។

ម្ចាស់គោដើរតាមច្រវាត់　តាមគោដែលបាត់　ពុំឃើញរឹងក្តៅ ។

ចួនជាបែរក្អែកសំដៅ　មើលចំពោះទៅ　ខាងមុខនោះនៃ ។

ឃើញព្រះសៅរ៍ជើស្ងួដ័យ　ដឹកអាជានេយ្យ　បណ្តើរយាត្រា ។

ម្ចាស់គោសំគាល់សញ្ញា　ថាគោអាគ្នា　ឥតមានសង្ស័យ ។

រួចរត់ប្រញាប់តែ ។　ដល់ហើយថាហៃ　អាចោរចិត្តកាច ។

ហានលួចគោអញឥតខ្លាច　យើ! អាកំណាច　ចិត្តកាចអប្រិយ ។

កាលនោះក្បត្រៃថ្លៃពិសី　ស្តេចស្តាប់សំដី　គេដេរឥតក្រែង ។

ស្តេចបើកព្រះឧស្ឋថ្លាថ្លែង　ប្រាប់ថាខ្ញុំឯង　មិនជាចោរទ្មើយ ។

សេះខ្ញុំបរមកយូរហើយ　ឥឡូវរម្តេចឡើយ　មកថាគោខ្លួន ។

អ្នកនេះមិនដឹងសមសួន　ទ្រព្យគេទ្រព្យខ្លួន　ឲ្យច្បាស់ជាក់លាក់ ។

ម្ចាស់គោខឹងណាស់លោធាក់ ហើយចាប់កន្ត្រាក់ ៗយរោធិសត្វ ។
ៗយដំធាក់ច្រែះចាត់ ពង្រាយរោធិសត្វ ហើយៗដេរថា ។
អាកាចកំណាចឫស្យា ម្តេចឡើយកំអា ហ៊ានក្លាដដែក ។
គោអញ ។ ឃើញទឹងក្អែក ម្តេចមឹងប្រកែក ៗសវែកដូច្នេះ ។
អញមិនស្គាល់ឬអាផែះ គោហើយទឹងសេះ កាលណាដូចគ្នា ។
ពេលនោះពន្ធកពុទ្ធា ឃើញសេះអាត្មា ក្លាយជាគោហើយ ។
ក្សត្រៃថ្លៃអាល័យឥតស្ទើយ ថាតុ ! អ្នកអើយ ! ចូរអ្នកយកទៅ ។
ខ្ញុំសូមតែបានរស់នៅ គោអ្នកយកទៅ ខ្ញុំឥតបើថា ។
ម្ចាស់គោឮព្រះរាជា ថាឲ្យគោណា បន្ទោខឹងជាត់ ។
ហើយយកព្រះទីនាំងក្នែ ឯអគ្គមហាក្សត្រ កើតទុក្ខខ្លាំងក្លា ។
ព្រោះទ្រង់មានចិត្តស្នេហា ស្រឡាញ់លើអ- ជានេយ្យនោះណាស់ ។
កាលសេះនោះព្រាត់ស្រឡះ ទើបធ្វើឲ្យព្រះ - អគ្គស្តាយពេកក្រៃ ។
នេះឯងជាកម្មចង្រៃ នៃព្រះដៀស្តដ័យ តាមទាន់ឲ្យផល ។
ហេតុនោះទើបព្រះទសពល ទេសនាពន្យល់ ដល់សត្វគ្រប់ឋាន ៖

"ថាសព្វសត្វកើតក្នុងគ្រប់គ្នីគ្នា សុទ្ធសឹងជាមានកម្មប៉ះពាល់ច្រើនណា
ហើយទទួលកម្មនោះឥតលោះខាន គឺត្រូវបានផលជាទុក្ខ - សុខ ។
កម្មជាចាប់អកុសលតែងផ្តល់ឲ្យ សព្វសត្វសោយទោសពៀរវៃពុំខ្លះ
ឯកម្មល្អតែងឲ្យសត្វសោយសុខ ទោសគ្រប់មុខភ្លាត់ភ្លាយធ្លាយពុំដឹង ។

ពិតមែនហើយសត្វលង់ក្នុងកំពប៉ី ពុំឃើញជាក់អរិយសច្ចពិត
ត្រូវតណ្ហាអវិជ្ជាវប្បរិត ទើបងងឹតបិទខ្ទាក់លក្ខណញ្ញាណ ។
កាលអន្ទោលយោលលង់ក្នុងវិត្រវដ្ត ត្រាច់ឆ្គាត់ឥតវៀងឆ្ងៃតែបាន
សោយសុខទុក្ខនុក្ខទុក្ខតេលោះខាន តាមមូលដ្ឋាននៃកម្មជាធម្មតា ។
បើកុសលឱ្យផលជល់ហើយកូវ ពេលនោះត្រូវសត្វផងរងសុខា
អកុសលឱ្យផលជល់កាលណា ពេលនោះដាវិបត្តិសត្វសោយទុក្ខ ។

អធិប្បាយថាសត្វពិតឆ្ងៃឆាត់ ដែលឆ្គាត់វិលវល់គ្មានឃល់មុខ
តែងបានផលជាសុខ ឬជាទុក្ខ តាមចំនុកនៃកម្មប្រចាំក្បាណ ។
បើបុណ្យដែលខ្លួនស្អាងសាងសន្សំ ។បត្តម្ភពុំបាត់សត្វក៏បាន
ដូចលាភ,យស,សរសើរ,សុខសម្បត្តិ ហើយនឹងបានតេជះតបះកែ ។
ទាំងជាទីស្រឡាញ់ពេញចិត្តា នៃមនុស្សាសត្វសព្វគ្រប់យប់ថ្ងៃ
ទាំងខ្ពាយក្សយង់តង់ពិស្ដុយ ឱ្យពរជ័យស្រីសុខសព្វវេលា ។
ទៅទីណាទោះក្រែកក៏តគ្ងុះ គេសំពះបែហួរគេបូជា
ក្នុងទីនោះឈ្មោះឡើងថ្កើងមហិមា ដូចចន្ទ្រាបូណ៌មីរស្មីស្វាង ។
ជួនដុនដាបថ្កាបកម្មតាមមកទាន់ ក៏ប្រែភ័ន្តត្រឡប់សព្វបែបយ៉ាង
ទាំងតេជះយស,លាភ,ភ័ព្វសំណាង គ្មានសំអាងរុងរឿងថ្កើងទៅទៀត ។
គ្មានមនុស្សទេព្ភាណាស្រឡាញ់ គេតែងខ្ពាញ់រអើមខ្ពើមបង្កៀត
គ្រប់កន្លែងតែងមានគេបៀនបៀត សូម្បីញាតិគង់ធ្វើតបៀតបៀន
ក្បាណ ។

អ្នកនោះប្រែប្រែជាអនាថា ទៅទីណាគេស្អប់មិនពាប់អាន
តែងរងទុក្ខមុខជ្រប់គ្រប់ពីហាន ពុំដែលបានថ្ពាន់ថ្កើងឡើងឥស្សី ។
ដូចអំពិលអំពែកស្មើគ្នាប ភ្លឺតែបន្តិច តែក្អែងរឹតត្រឹម
គាលអាចិត្យឫទ្ធិរះបាស់ឡើងខ្ញុំ ក៏ឃាត់បង់រង្ស៊ីស្មើថ្លា" ។

ស្តេចទ្រង់សង្វេគអនិច្ចា អកុសលអាត្មា តាមកាន់ទៅអាយ ។
ខុ:ខ្ញុ! អនិច្ចារូបកាយ ទុក្ខតតរសោយ កម្មកាយអ្វីអើយ ។
ឲ្យព្រាត់ពីវដ្តមកហើយ ទុក្ខតតស្លេះល្ហើយ ថែមហើយថែមទៀត ។
កម្មអ្វីក៏ចេះតែបៀត ត្រួតហើយត្រួតទៀត តតមានសោកស្ទាយ ។
មកុដជាកញ្ចប់ជ័យហើយ មិនតែម្ល៉ោះឡើយ ព្រះកាន់តែសំបូរ ។
ភ្លាយជាកណ្តៀវច្រួតស្រូវ តឡូវនេះភ្លូវ ស្ទេះតែអត់ពៅ ។
ប្រែខ្វែបែរជាសត្វគោ អស់ទៅព្យរសេដ្ឋោ ព្រាត់ចេញអស់ហើយ ។
ខុ:ខ្ញុ! អនិច្ចារូបអើយ តតមានអ្វីឡើយ កំដរខ្លួនសោះ ។
នៅតែព្រះពស្ត្រ១ស្មោះ ស្ងៀកដណ្តប់នោះ កំដរអង្គអញ ។
អនិច្ចាអាត្មាគួរខ្លាញ់ ស្បែកសាច់ឈាមអញ ពុះពងអស់ហើយ ។
ព្រះចៅសិរីសៅវ៍តាណាត្រើយ ព្រាត់គ្រឿងអស់ហើយ នៅតែភូសា ។
ទ្រង់សោកវិយោគខ្លាំងក្លា ព្រះមហាក្សត្រា ស្រឡាញ់សេះវិគ្រៃ ។
ទើបនាំឲ្យព្រះហ្ឫទ័យ ពេលកាលស្ទើរក្ស័យ ប្រល័យជន្ម ។
ពុំដឹងនឹងធ្វើយ៉ាងណា ទើបតាំងចិត្តា យាត្រាចាំងសៅ ។

លុះដល់ថ្ងៃក្រោយទៀត បរមចមចៅ ខន់អស់កាយា ។
ស្រែកឃ្វានព្រែនគ្មានកោជនា ក្រៀមក្រំកក្តួា ល្ងិតៗល្ហៀៗ ។
ទើបចូលទៅជ្រកដើមដៃជ ដុះនៅជាយដៃព្រៃ សម្រាកកាយា ។
លុះបានស្រាកស្រាន្តហើយណា ស្តេចតំយាត្រា ឆ្ងងកាត់ព្រៃជ្រៅ ។

## បឋកាកកតិ

ចមកពនរបតី ស្តេចត្រាច់ទៅខ្ចី ស្មារតីហ្វឹនហ្វង់ អត់ទាំងព្រះស្ងោយ ខន់ខ្សោយកេយអង្គ អំណើះយូរលង់ ព័របីថ្ងៃហើយ ។ សេចក្តីស្រែកឃ្វាន រំងាលុកុរកពន ឥតឯស្សាស្សីយ តុំដែលបានសោយ ព្រះស្ងោយតិចឡើយ ល្ងិតៗ ល្ហៀយៗ ខន់ស្បើយកាយា ។ ស្តេចខំដំរង់ ស្មារតីផ្តិតផ្តង់ ឲ្យតង់ជន្មាខំយាងតិចៗ តាមដោយមាគ៌ា យូរតិចទៅណា បានឃើញវត្តលោក ។ ស្តេចគន់គិតថា ៖ “តុអង្គអាត្មា អត់ជាយបរិភោគ បើច្នេះអញទៅរកសូមជាយលោក ក្រែងលោកអធ្យាគ ឲ្យខានកោក្តា” ។ គិតច្នោះពុំទៅ ស្តេចយាងរៀងទៅ ឃើញខេន ១ ណា នៅជិតវិហារ តែឯងឯកា ស្តេចមានចិត្តា ស្នេហាពេកណាស់ ។ ទើបមានវាចា ទីឆ៍សាមណេរថា ៖ “តុលោកអម្ចាស់ ខ្ញុំមកពីឆ្ងាយ អត់ជាយយូរណាស់ ព្រះគុណអម្ចាស់ ជ្រោសយកបុណ្យាណា ។ ខ្ញុំឃ្វានពេកណាស់ សូមព្រះគុណម្ចាស់ ឲ្យខ្ទះទៅក” ហើយសូមអាស្រ័យ ពីរបីទឹក លុះស្រួលវេទនា ទីឆ៍លាបេញ្ញាទៅ” ។

(មានត)

## កណ្ដាលី ២០

# ឧកញ៉ាវិបុលរាជសេនា ង្ហួ-ឃន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
ទំងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ស៊ុនហុកបានឮដូច្នោះក៏ឆ្ងើយតបនឹងខុងយ៉ឺងថា . អ៊ួនសៀវនឹងមានប្រាជ្ញចេះគិត ប្តូនឹងមានថ្វីដៃច្បាំងពាំងដល់ខ្លាំងពូកែក៏ទេ។ គ្រាន់តែមានគាហានច្រើនប៉ុណ្ណោះ ដែលនឹងឲ្យទៅនិយាយសម្រួលជាផ្លូវមេត្រីវិញនោះមិនគួរសោះ ។ ខុងយ៉ឺងឆ្ងើយថា អ៊ួនសៀវគ្មានសតិបញ្ញា គ្មានថ្វីដៃខ្លាំងពូកែក៏មែនហើយ តែមានស្រុកចំណុះជាច្រើនតំបន់ ទាំងស្បៀងអាហារក៏បរិបូណ៌ត្រឹម, មួយទៀតបានសឹមផ្ចួយ, ទៅហ៊ីវ, គួតៅ, ហាងគី ទាំង ៤ នាក់នេះ សុទ្ធតែមានសតិបញ្ញាជាទីប្រឹក្សាបស់អ៊ួនសៀវ ឯគាហានឯកដែលមានថ្វីដៃនោះ គឺតៀនហង, ឈីស៊ីវ, ងាន់លៀង,

ប៊ុនធីវ, គោឡាំ, តៀវខាប់, អ៊ីខេង មនុស្សចាំងនេះ សុទ្ធតែមានដំរេះ ច្បាជ្ញានឹងថ្វីដៃខ្លាំងពូកែខៀងគ្រង់នឹងអ្នកសៀវ ព្រមទាំងកូនខាហាន កំមានយ៉ាងច្រើន ហេតុម្តេចអ្នកទៅប្រមាថមើលងាយអ្នកសៀវដូច្នេះ ។

ស៊ុនហុកបានស្តាប់ដូច្នោះក៏អស់សំណើចហើយតបថា សេនាឯកអ្នកសៀវដែលមានច្បាជ្ញានឹងថ្វីដៃខ្លាំងពូកែនោះ នឹងកាប់ទុកជាចំណានមិនបានទេ ដ្បិតតៀនហាងនោះជាមនុស្សអាក្រក់កាចសាហាវ, ខៅហ៊ីវនោះមានបញ្ញាក៏មែន តែជាមនុស្សល្មោភ ធ្វើការអ្វីច្រើនតែខូចការនោះ, ស្មឹមផ្ចួយជាមនុស្សអួតចេះ ទោះបីនរណានិយាយត្រូវក៏ប្រកាន់ថាខុស, ហាងគីនោះជាមនុស្សជាងសំដី រៀហារយកជាការមិនបាន, ចាំង ៤ នាក់ដែលជាទីប្រឹក្សាអ្នកសៀវនោះ សុទ្ធតែជាមនុស្សមានទំដឹងដល់ណែម គ្នាយកត្រូវទៅដោយខ្លួន ។ ឯសេនាឯកដែលមានថ្វីដៃចាំង ៧ នាក់នោះ មិនស្គាល់ប្បាស់ទីបង់ទីបានទេ បើបានធ្វើសឹកធំគ្រានេះឃើញថានឹងចាប់ខ្លួនបានជាច្រើនជាក់ ឯកូនខាហានដែលមានច្រើនប៉ុន្មាន គ្រាន់តែបណ្តោយចាញ់បណ្តោយឈ្នះប៉ុណ្ណោះ ។ ខុងយ៉ុងបានស្តាប់ដូច្នោះក៏នៅស្ងៀម ។

ចូរូបានឃើញខុងយ៉ុងនៅស្ងៀមដូច្នោះ ក៏អស់សំណើចហើយថា "ស៊ុនហុកនេះឆ្កួតប្រមាណការអ្វីមិនចេះខុសសោះ គួរជ្រើតំនិតដែលគិតការម្តងនេះត្រូវដូចតំនិតរបស់យើង" ថាហើយក៏ចាត់ទ្រាតាយទឹងអង្គតុងឲ្យលើកខាហាន ៥ ម៉ឺន យកទង់ជ័យសម្គាល់ចូរូទៅផង ទឹងឲ្យ

លើកទៅវាយយកស្រុកឈើដីវ ។ ធៀយុកធ្វើយថា ដែលលោកនឹងប្រើ
ខ្លាតាយនឹងអង្គតុងលើកកងទ័ពចេញទៅនោះ ខ្ញុំបានយល់ឃើញថា
អ្នកទាំង ២ តស៊ូក្បូដៃខ្លាតីមិនបានទេ ។ ចូធួតបថា "អ្នកនិយាយនេះ
ត្រូវហើយ ដែលយើងប្រើខ្លាតាយនឹងអង្គតុងទៅគ្រានេះ បីដូចជា
ឲ្យទៅលេងកងទ័ពខ្លាតីទុកប៉ុណ្ណោះទេ គឺមិនឲ្យកងទ័ពខ្លាតីចូលដល់
គ្នានឹងកងទ័ពអ្ងួនសៀវ" ថាហើយចូធួក៏បង្គាប់ខ្លាតាយនឹងអង្គតុងថា
ដែលអ្នកនឹងលើកកងទ័ពទៅនោះ កុំអាលចូលទៅតច្បាំងកាប់យកស្រុក
ឈើដីវឡើយ ឲ្យតាំងទ័ពរក្សាទីការពារប៉ុណ្ណោះ បើកងទ័ពយើង
ច្បាំងនឹងអ្ងួនសៀវខាងនេះ មានជ័យជំនះវិលាណា គង់នឹងលើកទៅ
សន្ធប់ខ្ទប់គ្នាវាយយកស្រុកឈើដីវតែម្តង ។ ខ្លាតាយនឹងអង្គតុងក៏តំនាប់
លាចូធួ ទទួលនាំយកទាហាន ៥ ម៉ឺនលើកចេញទៅតាមបង្គាប់ចូធួ ។
កំចាត់ចែងទាហានលើកចេញទៅប្រមាណ ២០ ម៉ឺនទៅដល់តំបន់គួតវ ក៏
ឲ្យបញ្ឈប់កងទ័ពតាំងបន្ទាយនៅទីនោះ ចម្ងាយផ្លូវទៅដល់បន្ទាយអ្ងួន-
សៀវប្រហែល ៨០០ សិន (៣២ គីឡូម៉ែត្រ) ។

អ្ងួនសៀវដឹងថា កងទ័ពចូធួលើកមកតាំងនៅដូច្នោះ ក៏ប្រឹក្សា
នឹងសេនាទាហានទាំងពួងថា យើងនឹងលើកចេញតច្បាំងនឹងកងទ័ពចូធួ
ឬប្រែការម្តេច? ។ ការប្រឹក្សាគ្នានេះមិនបានជាប់ស្រេច ព្រោះហេតុ
ទៅហ៊ុវមានៈសេចក្តីតូចចិត្តថា ស៊ុមផ្ងួយបានជាបាឡាត់ទ័ពបង្គាប់បញ្ជាលើ

សេនាទាហានចាំងពួន ឈឺស៊ីវកំតូចចិត្តនឹងអ្នកសៀវថា ខ្លួនទឹងប្រឹក្សាការពារជាតអ្វីក៏អ្នកសៀវមិនយល់ឃើញផង, អ្នកសៀវទើបមិនបានចេញច្បាំងនឹងចូឆូ, ទ័ពអ្នកសៀវនៅត្រៀមខុកតាំងពីខែកត្តិកលុះដល់ខែកត្តិក ។

ចូឆូឃើញថាអ្នកសៀវមិនបានលើកទ័ពចេញច្បាំង ក៏ត្រែងថាអ្នកសៀវនឹងធ្វើកលតែងទ័ពលើកទៅខ្ពប់រាយយកក្រុងហ៊ូគោ ទើបប្រើចុងចា"ជាសេនាលីចោ"ឲ្យលើកទាហានទៅចាំស្កាត់ផ្លូវ ត្រង់ប្រទល់ដែនស្រុកឈីជីវ កុំឲ្យទាហានអ្នកសៀវនឹងទាហានឡៅពីដើរទៅមកវាកគ្នាបាន ប្រើអ៊ុកមនឹងលីតៀន លើកទាហានជាកងមុខទៅចាំស្កាត់ផ្លូវខ្នេហង៉ហោ ព្រំដែនស្រុកហ៊ូគោ កុំឲ្យទាហានអ្នកសៀវនឹងទាហានឡៅពីដើរទៅមកវាកគ្នាបាន ប្រើចោយិនលើកកងទ័ពធំទៅតាំងនៅតំបន់គួតរ ខ្លួនចូឆូក៏លើកត្រឡប់ចូលទៅក្នុងក្រុងហ៊ូគោវិញ ហើយធ្វើសំបុត្រចាត់បំរើសេះឲ្យកាន់ទៅដល់ឡៅតាយនឹងអង់តុង ឲ្យបង្ខំលើកទ័ពចូលវាយទំលាយយកស្រុកឈីជីវឲ្យបាន ។

ឯឡៅពីដែលនៅក្នុងក្រុងឈីជីវលុះដឹងថា កងទ័ពលើកទៅចោះនៅជិតក្រុងបម្ងាយពីព្រំដែនប្រវែងប្រហែល ៨០០ សិន (៣២ គីឡូម៉ែត្រ) ក៏នៅមិនទាន់ច្បាស់ជាទាហានចូឆូនោះ នៅណាជាមេទ័ព ។ ឡៅពីក៏មិនបានចេញច្បាំង គ្រាន់តែត្រៀមសេនាទាហានឲ្យឡើងរក្សាសែន

បន្ទាយពាយយាមល្បាតខាត់ក្រែវែលជាយ៉ាងម៉ាំមួន ហើយចាំស្តាប់ដំណឹងអ្នកសៀវ ដែលលើកមកច្បាំងនឹងចូរនោះ នឹងឈ្នះឬចាញ់ប្រការម្តេចក៏មិនបានជាក់ច្បាស់សោះ ។

បំរើសេះនាំសំបុត្រចូរនោះទៅប្រគល់ ឲ្យឡៅតាយនឹងអង្គតុងក្នុងបន្ទាយ ។ ឡៅតាយនឹងអង្គតុងដឹងសេចក្តីហើយ ទើបប្រឹក្សាគ្នាថា នរណានឹងលើកចេញទៅ រាយយកស្រែកឈើដីវាជាមុន ។ ឡៅតាយនិយាយនឹងអង្គតុងថា មហាឧបាជ្ឈៃយើងដាមេទ័ពមក ត្រូវអ្នកលើកទ័ពទៅរាយយកស្រែកឈើដីវមុនយើងចុះ ។ អង្គតុងតបថា មហាឧបាជ្ឈៃឲ្យយើងលើកទ័ពមកនោះ នឹងបានបង្គាប់ចំពោះឲ្យអ្នកធ្វើមេទ័ពតែឯងក៏ទេ គឺបង្គាប់ឲ្យខ្ញុំនឹងអ្នកលើកទាហាន ៥ ម៉ឺនមកជាមួយគ្នា បើអ្នកនឹងតាំងខ្លួនជាមេទ័ពតែឯងនោះខ្ញុំមិនព្រមផងទេ ។ ឡៅតាយតបថា អ្នកនឹងខ្ញុំប្រឹក្សាគ្នាមិនចុះរុះសោះ បើដូច្នេះត្រូវសរសេរអក្សរ ២ តួ មួយថាមុនមួយថាក្រោយ ហើយឲ្យលូកចាប់ដោយផ្សង បើនរណាបានតួអក្សរមុនឲ្យលើកទ័ពទៅច្បាំងមុន បើនរណាបានតួអក្សរក្រោយឲ្យលើកទៅច្បាំងជាក្រោយ ។ អង្គតុងយល់ឃើញត្រូវ ក៏សរសេរអក្សរជា ២ តួ តាមសំដីហើយផ្សងចាប់ អង្គតុងចាប់បានអក្សរមុន ឡៅតាយចាប់បានអក្សរក្រោយ ទើបបែងទាហានពាក់កណ្តាលឲ្យអង្គតុងលើកទៅរាយយកស្រែកឈើដីវ ។

(មានត)

រឿងព្រេងប្រទេសឥណ្ឌៀ

# អ្នកស្រីស្រិន-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបាលីមកជាភាសាខ្មែរ

(ត—ចប់)

---

ព្រាហ្មណ៍ឈ្មោះ សុទេវៈ (Sudeva) ដើរវេរហូតដល់ក្រុងចេទី (Chédis) ។ ព្រះករុណានឹងឯកអគ្គមហេសីទ្រង់ទទួលដោយពាក់ព័ន្ធ ។ នៅពេលដែលព្រាហ្មណ៍ថ្លែងនូវសេចក្តីអរគុណ ចំពោះព្រះភ័ក្ត្រនៃព្រះបាទាក្រុងនោះ ព្រាហ្មណ៍ស្រាប់តែឈប់នៅស្ងៀម... ។

ព្រះករុណាមានបន្ទូលសួរថា: "ចុះមានការអ្វីបានជាឈប់ដូច្នេះ ព្រាហ្មណ៍បណ្ឌិត?" ។

ព្រាហ្មណ៍ទូលតបថា: "សូមទ្រង់ព្រះមេត្តាប្រោស! សូមព្រះករុណាព្រះពាជានុញ្ញាត ឲ្យទូលព្រះបង្គំនិយាយនឹងនាងដែលជាសំឡាញ់នៃព្រះពាជបុត្រីព្រះអង្គបានបន្តិច" ។ ព្រាហ្មណ៍ទូលហើយក៏សំឡឹងទៅព្រះនាងទមយន្តី ។ ព្រះករុណាទ្រង់ត្រើយថា: "បើសិនជានាងនោះសុខចិត្ត អ្នកឯងអាចនិយាយនឹងនាងបាន" ។

ព្រះនាងត្រើយថា: "ខ្ញុំម្ចាស់សុខចិត្តឲ្យព្រាហ្មណ៍នេះនិយាយនឹងខ្ញុំម្ចាស់បាន" ថាហើយព្រះនាងក៏ធ្វើសញ្ញាឲ្យព្រាហ្មណ៍ដើរមកតាម

ព្រះនាងដែលថយចេញឆ្ងាយពីព្រះករុណា ទឹងព្រះវរកជជនន៏ ។ ព្រាហ្មណ៍សុទេវៈ កំផ្តើមនិយាយថា: "ខ្ញុំលព្រះបង្គំជាខ្ញុំមកពីប្រទេសដែលព្រះនាងជ្រាបស្រាប់ហើយ ពីព្រោះព្រះនាងមានរូបកន៏ដូចជាម្ចាស់ក្សត្រីដែលខ្ញុំលព្រះបង្គំដើរកណាស់ គឺជាព្រះរាជបុត្រីនៃព្រះចាទភិមៈ" ។ ព្រះនាងមានបន្ទូលសួរដោយរួសរាន់ថា: "យី! ចុះកូនខ្ញុំយ៉ាងណាទៅ?" ។ ព្រាហ្មណ៍ទូលតបដោយញញឹមថា: "ព្រះរាជបុត្រតាំងពីព្រះអង្គសុខសប្បាយគ្រប់ព្រះអង្គទេ អាទិទេពមានព្រះទ័យសន្តោសជួយថែរក្សាព្រះរាជបុត្រព្រះនាង ដូចជាព្រះបិតាព្រះនាងដែរ" ។ ព្រះនាងទមយន្តីទ្រង់រំដួលព្រះទ័យខ្លាំងពេក ដោយបានឃើញព្រាហ្មណ៍សុទេវៈ នាំដំណឹងពីព្រះរាជបុត្រមកទូលទ្រង់ឲ្យជ្រាបព្រះនាងនឹកដល់ព្រះវរបិតានឹងព្រះចាទនាលៈ ហើយក៏ទ្រង់ព្រះកន្សែងសោក ។ ព្រះអង្គម្ចាស់ក្សត្រីសុនន្ទា (Sunanda) លុះឃើញព្រះនាងសោកក៏ទ្រង់រត់ទៅទូលព្រះមាតាថា: "ព្រះមាតា! សូមទ្រង់ទតនាងដែលជាសំឡាញ់ខ្ញុំម្ចាស់ មិនដឹងជាព្រាហ្មណ៍នោះនាំដំណឹងអ្វីមកថ្កាប់នាងទេ ស្រាប់តែនាងយំសស្រាក់" ។ ព្រះរាជជនន៏មានបន្ទូលថា: "ចូរកូនទៅហៅព្រាហ្មណ៍នឹងនាងមកនេះ" ។ ព្រាហ្មណ៍សុទេវៈ ទឹងព្រះនាងទមយន្តី ចូលទៅដិតព្រះមហាក្សត្រី ។ ទ្រង់សួរថា: "អ្នកចាំងពីរនាក់ហាក់ដូចជាស្គាល់គ្នា ហើយខ្ញុំបានយល់ថានាងនេះជាកូនអ្នកត្រកូលខ្ពស់,

តើឥឡូវនេះ នាងគួបប្រាប់យើងថា ឪពុកនាងឈ្មោះអ្វី? ប្តីនាងឈ្មោះអ្វីបានឬទេ? យើងនឹងរាប់អាននាង ហើយនឹងជួយទុបត្ថម្ភនាងផង" ។

ព្រះនាងទមយន្តីនៅតែទ្រង់ព្រះតម្រែងអួលអាក់ ។ ព្រាហ្មណ៍ក៏ឆ្លើយដួសថា: "ព្រះមហាក្សត្រីដ៏ប្រសើរ! ទ្រង់មិនលែងជាបន្ទូវព្រះហៅក្រុងវិទភ៌:ទេ ដែលមានព្រះនាមថាព្រះបាទភីម: ព្រះនាងនេះទ្រង់ព្រះនាមទមយន្តី ជាព្រះរាជបុត្រីនៃព្រះបាទភីម:នោះ មួយទៀតព្រះមហាក្សត្រីគង់ទ្រង់បានជាបន្ទូវព្រះមហាក្សត្រនៃពួក និសធ: ដែលទ្រង់ព្រះនាមព្រះបាទនាល:ដែរទេ? ព្រះនាងដែលនៅចំព្រះភ័ក្ត្រនេះជាព្រះអគ្គមហេសីនៃព្រះបាទនាល:នោះ, នាល:ជាស្តេចអកក្ខ ទ្រង់បានបោះបង់ចោលព្រះរាជអាណាច័ក្រវបស់ព្រះអង្គ ហើយព្រះនាងទមយន្តីទ្រង់ព្រមព្រៀងចេញចាកព្រះរាជធានី ទៅតាមព្រះអង្គនៅពេលដែលទ្រង់ភ្នាត់ចេញពីប្រទេស . . . " ។ ព្រះរាជជននីទ្រង់មានបន្ទូលកាត់ព្រាហ្មណ៍ថា: "យីព្រាហ្មណ៍! នាងនេះជាព្រះរាជបុត្រីព្រះបាទភីម:ឬ? ដូច្នេះតើបានជាយើងគួបចិត្តស្រឡាញ់គាំងពីដំបូង" ហើយទ្រង់បែរព្រះភ័ក្ត្រមកកាត់ព្រះនាងថា: "ឯងជាកូនរបស់បងស្រីយើង ម្ចាយឯងនឹងយើងជាព្រះរាជបុត្រីព្រះបាទសុទម័ន (Sudamam) ដែលជាស្តេចពួកទេសណ៌: (Daçarnas) ។

ព្រះនាងឆ្លើយតបព្រះសារនីយ៍ថា: "ខ្ញុំម្ចាស់ក៏ដឹងដែរ ប៉ុន្តែខ្ញុំម្ចាស់លាក់ឈ្មោះព្រោះខ្ញុំម្ចាស់ខ្មាស, ដោយសារតែខ្ញុំម្ចាស់អៀនខ្មាសនេះ:

ហើយ ចានជាខ្ញុំម្ចាស់ចេះតែលើកការសន្ទនាជាមួយនឹងព្រាហ្មណ៍នៅ
ទីត្រង់នេះ ស្អែកជាខានស្អែក ខ្ញុំម្ចាស់មិនហ៊ានពណ៌នាអំពីសេចក្តីវែងនា
របស់ខ្ញុំម្ចាស់ទេ ខ្ញុំម្ចាស់មិនហ៊ានប្រាប់ព្រាហ្មណ៍ថាអ្នកណាមួយជាប្តីខ្ញុំ
ម្ចាស់ទេ ខ្ញុំម្ចាស់ខ្លាចត្រែងមិនជឹតលេចឮការសំងាត់របស់ខ្ញុំម្ចាស់" ។
ព្រះមហាក្សត្រីនឹងព្រះរាជបុត្រីសុនន្ទា ទ្រង់មានព្រះទ័យសោមនស្ស
ពន់ពេកកង់ពេលនោះ ។

*
* *

ភាគទី ២៩

ព្រះនាងទមយន្តីយាងទៅគង់នៅជួបជុំជាមួយព្រះវរាជបិតា នឹង
បុត្រាបុត្រី ។ ព្រះនាងសព្វព្រះហឫទ័យនឹងព្រះរាជបុត្រណាស់ ។
ប៉ុន្តែកាលណា ព្រះនាងគង់នៅស្ងាត់តែមួយព្រះអង្គឯង ទ្រង់ព្រះកន្សែង
សោកដោយនឹកដល់ព្រះចុន្ទនាលៈជាទីស្រឡាញ់របស់ព្រះនាង ។

ថ្ងៃមួយ ព្រះនាងត្រាស់ហៅព្រាហ្មណ៍សុទេវៈ ហើយមានព្រះ
បន្ទូលថា "សុទេវៈ! ខ្ញុំស្គាល់គតិបណ្ឌិត នឹងសេចក្តីវៃឆ្លាតរបស់អ្នក
ព្រោះអ្នកបានទៅរកខ្ញុំឃើញនៅកណ្តាលក្រុងឆេទី ចូរអ្នកអាណិតខ្ញុំ
ដកបណាព្រះចុន្ទនាលៈមិនគង់នៅទីនេះជាមួយនឹងខ្ញុំទេ ដកបនោះខ្ញុំគ្មាន
សប្បាយបន្តិចឡើយ បើដូច្នេះ ចូរអ្នកធ្វើដំណើរទៅរកព្រះអង្គនៅ
គ្រប់ដំបន់" ។

ព្រាហ្មណ៍ទូលតបថា: "ព្រះមហាក្សត្រ! ខ្ញុំលព្រះបង្គំនឹងធ្វើតាមព្រះពាជសារាជ្ញា ខ្ញុំលព្រះបង្គំនឹងទៅកាន់ទីក្រុងគ្រប់ព្រះពាជអាណាចក្រទាំងអស់ ហើយបើព្រះអង្គគង់ជីវិតនៅឡើយ ខ្ញុំលព្រះបង្គំនឹងនាំស្តេចត្រឡប់មកនគរវិទេហៈវិញ" ។

ព្រាហ្មណ៍ដើរសួរសព្វទីកន្លែង តាំងតែពីស្តេចសោយរាជ្យមានកត្តិនាមល្បីល្បាញ រហូតដល់ពួកស្ងួយាចក ប៉ុន្តែគ្មានឃើញព្រះបាទនាលៈសោះ ។ ក្រោយបង្អស់ព្រាហ្មណ៍សុទេវៈបានចូលដល់ក្រុងអយុជ្ឈា ចូលទៅគាល់ព្រះបាទរីតុបទិ: ។ ព្រាហ្មណ៍ពុំបានជ្រាបនូវកលល្បិចរបស់ព្រះបាទនាលៈទេ ព្រាហ្មណ៍នោះរៀបនឹងដើរចេញមកហើយ ស្រាប់តែវរស្ន័យ ដែលជានាយគង្វាលសេះស្រែកហៅឲ្យឈប់ ហើយច្រាប់ទៅព្រាហ្មណ៍ថា: "ព្រាហ្មណ៍! ក្នុងចំណោមគង្វាលសេះដែលធ្វើការក្រោមបង្គាប់ខ្ញុំ មានបុរសកំសត់ម្នាក់ចេះតែគ្អូញគ្អែរថ្លូគ្មានឈប់ឈរ វាច្រាប់គេថាវាឈ្មោះវហុក: តែបើវានឹកដល់ប្រពន្ធរបស់ពួកម៉ាកវាឡើងវាយំ វាថាស្រីនោះសំឡាញ់វាបានរត់ចោលនៅកណ្តាលព្រៃ ថាសំឡាញ់វាបានធ្វើឲ្យរលាយអស់ទ្រព្យសម្បត្តិ ខ្ញុំខ្លាចក្រែងរឿងនេះជារឿងរបស់វា ប៉ុន្តែវាត្រឡប់ថាគេទៅវិញ ព្រោះរឿងដែលវានិយាយនោះ ដូចរឿងព្រះបាទនាលៈដោយពិតណាស់" ។

ព្រាហ្មណ៍សុទេវៈក៏ដើរតាមវរស្ន័យទៅក្នុងកន្លែងចិញ្ចឹមសេះ ហើយលប

ម៉ើលវាហុក:ទៅទីនោះ ទៅពេលនោះវាហុក:កំពុងតែយំថ្ងូរដូចកាលសត្វមួយដងៈ "ដឹងជានាងទៅឯណា! មិនដឹងជាដោតក់សនាអក្រែក់នាំនាងទៅឯណា! ដឹងជានាងស្លាប់ដោយអត់អាហារ ឬដោយគ្មានទឹក! ឬមួយជាស្លាប់ដោយសត្វសាហាវហែកស៊ីជាចំណី! ឱលោកអើយ នាងទៅឯណាទៅ?" ។ ព្រាហ្មណ៍នោះប្រែងស្តាប់ហើយក៏និយាយទឹងវាស្ម័យថា: "កាលពីដើម ខ្ញុំធ្លាប់ឮបានស្តាប់សំឡេងព្រះបាទនាលៈ ហើយខ្ញុំនៅចំណាំសំណូរសំឡេងនោះ" ។

វាស្ម័យឆ្លើយឡើងថា: "មែនហើយព្រាហ្មណ៍! ទៅពេលដែលខ្ញុំឮសំដីវាហុក: ខ្ញុំស្មានតែព្រះបាទនាលៈដែរ" ។

– "ព្រះបាទនាលៈ មានរូបឆោមល្អលើសមនុស្សក្នុងលោក តើអ្នកណាទឹងអាចផ្ទាស់កេរព្រះអគ្គកើត ម៉ើវាហុក:អាក្រក់ផុតនិស្ស័យយ៉ាងនេះ" ។

វាស្ម័យឆ្លើយថា: "វាហុក:ដំនាញខាងបរសេះណាស់ បើដូច្នេះយើងគិតយកវិជ្ជានេះដាក់ឲ្យឃើញសាកសិន្ធ ព្រោះខាងល្បឿនសេះគ្មានអ្នកណាស្មើនឹងព្រះបាទនាលៈទេ" ។

ព្រាហ្មណ៍ឆ្លើយថា: "បើដូច្នោះចាំពីរបីថ្ងៃទៀត យើងនឹងយកវិជ្ជារបស់វាហុក:មកសាកមើល" ថាហើយក៏ចេញពីក្រុងអយុធ្យាទៅប៉ុន្មានពីរបីថ្ងៃក្រោយមកពាហ្មណ៍ត្រឡប់មកវិញ ចូលទៅថ្វាយបង្គំព្រះ

ជាទេវីតុបនិ:ទៀត ហើយទូលព្រះអង្គថា: "ព្រះបាទូលព្រះគុណជាម្ចាស់ជីវិតលើត្បូង! ព្រះនាងទមយន្តី ទ្រង់លែងសង្ឃឹមនឹងបានឃើញព្រះបាទនាល:វិញហើយ ព្រះបាទកិម: នឹងព្រះនាងបានព្រមព្រៀងគ្នានឹងរើសរកព្រះស្វាមីជាថ្មីមួយទៀត ហើយប្រមូលស្តេចគ្រប់នគរឲ្យយាងចូលមកប្រជុំសន្និបាតអាភរកាមគ្គល បើដូច្នេះ សូមស្តេចយាងទៅកុំខាន" ។

ព្រះបាទវីតុបនិ:មានព្រះបន្ទូលថា: "យើងនឹងទៅមិប្រជុំមិនខាន, អ្នកណាដែលមិនសប្បាយចិត្ត បើបានរួមរាសនាជាមួយនឹងព្រះនាងទមយន្តី នឹងបានសប្បាយចិត្ត" ។

ព្រាហ្មណ៍សុទេវ:ទូលតទៅទៀតថា: "ប៉ុន្តែសូមទ្រង់យាងប្រញាប់ព្រោះគេត្រូវបើកប្រជុំនៅពេលវៃស្អែកនេះ" ។

- នៅពេលវៃស្អែក! តើកូនមួយថ្ងៃឲ្យខ្ញុំទៅដល់ប្រទេសព្រះបាទកិម: ម្តេចបាន បើឆ្ងាយម្ល៉េះ? ខ្ញុំគ្មានសេះឲ្យលឿនល្អហើយគ្មានទាំងបំរើយ៉ាងបំណាប់អាចនឹងនាំខ្ញុំឲ្យដល់ទៅប្រទេសវិទេភ: ក្នុងមួយថ្ងៃបានទេ" ។

ព្រាហ្មណ៍ទូលថា "សូមស្តេចមានព្រះទ័យរហ័ចំរើទ្រង់ទាំងអស់គ្នាមក មិនលែងមានអ្នកណាម្នាក់អាចនាំទ្រង់ទៅឯក្រុងវិទេភ:បានទេ" ។

ព្រះបាទវីតុបន: ត្រាស់បង្គាប់ឲ្យហៅអ្នកគង្វាលសេះមកទាំងអស់ហើយទ្រង់មានព្រះបន្ទូលថា "ព្រះនាងទមយន្តីត្រូវការរើសប្តីមួយទៀត

មហាសន្ធិបាតអាវហរិវាហមន្តលត្រូវបើកប្រដុំនៅពេលស្អែកនេះ, តើក្នុងចំណោមអ្នកពាល់គ្នា មានអ្នកណាមួយអាចនាំខ្ញុំទៅគ្រងរៃគិះ ឲ្យទាន់ពេលស្អែកនេះបានឬទេ?"

វហុកៈញ៉ែមនោសញ្ចេតនា ឈានមួយជំហានទៅមុខ ហើយបង្គំទូលថា: "ទូលព្រះបង្គំជាខ្ញុំ" ។ ស្តេចទ្រង់ទតដោយឆ្ងល់ ។ វហុកៈធ្វើយបញ្ជាក់ម្តងទៀតថា: "ព្រះករុណាថ្លៃវិសេស! ទូលព្រះបង្គំនឹងជានាជូនទ្រង់ឲ្យបានសំរេចដូចព្រះពាជបំណង សូមទ្រង់កុំព្រួយឲ្យតែគេរៀបចំមព្រះពាជរថឲ្យទូលព្រះបង្គំចុះ ស្អែកនេះយើងនឹងបានដល់ព្រះពាជអាណាចក្រនៃព្រះបាទកិម:" ។

ព្រាហ្មណ៍សុទៈនិយាយទៅកាន់វាស្ទ័យថា "ខ្ញុំស្មានថាខ្ញុំមុខជានឹងរកព្រះបាទនាលៈឃើញ" ។

* * *

## ភាគទី ៣០

ពឹកនោះ ព្រះនាងទមយន្តីតើនទ្បើងដោយមានព្រះហឫទ័យរីករាយណាស់ ។ ពន្ធីថ្លាក្នៃព្រះអាទិត្យចាំងចូលមកក្នុងបន្ទប់ព្រះនាង ។ នៅក្នុងទន្សាននេះឮសូរសំឡេងបក្សាយំយ៉ាងពីរោះ ។ ព្រះនាងបានទ្រង់ព្រះសណ្តាប់ន្ធូរសំរែកដំរីរោទ៍នឹងសំរែកសេះ បន្ទូសំណួរឮពីឆ្ងាយសំដែងសេចក្តីរីករាយ ។ ព្រះនាងទមយន្តីទ្រង់យាងទ្បើងទៅលើយ៉ាននៃមហាប្រាសាទ ដែលមានព័ទ្ធយោធ្រីករាមបក់ត្រជាក់ល្អ ហើយនឹងមាន

ផ្ការីកស្គុះស្គាយ ។ នៅលើវាលស្មៅពណ៌បៃតង មានក្លុកកំលេងកំសាន្ត ។ ឯក្លុននៃព្រះបរមកដវាំងនាំគ្នាហែលត្រសង់ក្នុងស្រះស្រី ។

ពេលត្រីកប្រកបដោយអាកាសល្អធ្វើឲ្យព្រះនាងភ្ញាក់ព្រះហប្ញទ័យ ព្រះនាងទតឃើញរនេះមួយក្ដីចំឡែកបរខាងផ្លូវមួយឆ្ងាយដាច់ស្រយាល ។ រនេះនោះបរលឿនណាស់ ហើយកាន់តែមកជិតឡើងៗ សារថីពាក់អាវពណ៌ក្រហម ។ បន្ទាប់រនេះចូលដល់ក្នុងក្រុងហើយមកឈប់នៅពីមុខទ្វារព្រះបរមកដវាំង បុរសពាក់អាវក្រហមចុះពីរនេះ រត់ចូលមកក្នុងមហាប្រាសាទ រត់កាត់តាមថែវ ព្រមទាំងស្រែកថា. "ទមយន្តី! ទមយន្តី!" ដល់ហើយក៏ដោះអាវក្រហមគ្រវត់ចោល ព្រះនាងស្គាល់ច្បាស់ជាព្រះបាទនាលៈ ក៏ស្រែកទទួលទៅវិញថា: "នាលៈ! នាលៈ! ម្ចាស់សំឡាញ់!" ។

ស្ដេចទាំងពីរព្រះអង្គទ្រង់ទបក្រសោបគ្នាទៅវិញទៅមក ជាយូរដោយសេចក្ដីរីករាយ ។

* * *

## ភាគទី ៣១

ព្រះបាទរតុបនៈ ទ្រង់ឆ្ងល់ទឹងឃើញវិហុក លោតចូលតាមទ្វារព្រះបរមកដកំដូចជាមនុស្សឆ្កួត ។ ពួកឆ្មាំទ្វារនាំស្ដេចយាងទៅដួបទឹងព្រះបាទកមៈ ទ្រង់គ្មានឃើញគេរៀបចំប្រដាប់សន្ធឹបាតសោះ គ្មានឃើញស្ដេចណាឬព្រះអង្គម្ចាស់ណាមួយសោះ គេទទួលទ្រង់តែមួយអង្គឯងដោយ

កិត្តិយស ។ ព្រះបាទកិមៈទ្រង់សាកសួរអំពីសេចក្តីសុខទុក្ខផ្សេងៗ ហើយ
មានបន្ទូលថា ទ្រង់សព្វព្រះរាជហឫទ័យនឹងបានឃើញព្រះភ័ក្ត្រព្រះអង្គ
ហើយទ្រង់ត្រាស់សួរទៅទៀតថា: "តើស្តេចយាងមកមានការអ្វីជាប្រញាប់ឬ
បានជាទ្រង់ស្តេចមកដោយមិនបានឲ្យដំណឹងយើងជាមុន? តើមានសត្រូវចង់
បៀតបៀនស្តេចឬ? ទ្រង់ត្រូវការនឹងជំនួយយើងទេ? បើទ្រង់ត្រូវការ
សូមទ្រង់មានបន្ទូលមកចុះ" ។

ព្រះបាទតុបនិ: មិនដឹងធ្វើយ៉ាងណា ក៏គង់នៅស្ងៀមបែបអៀន
ក្នុងព្រះទ័យ ។ ព្រះបាទកិមៈក៏ត្រាស់សួរដោយសំដីស្រទន់ទៀតថា:
"ព្រះអង្គមានការអ្វី មានបន្ទូលមកចុះ" ។ ព្រះបាទតុបនិៈក៏ទូលតបថា:
"ព្រះករុណាដ៏ប្រសើរ! ទូលព្រះបង្គំមានចំណងចង់មកថ្វែងសេចក្តី
មេត្រីភាព នឹងសេចក្តីគោរពចំពោះព្រះភ័ក្ត្រព្រះអង្គតែប៉ុណ្ណោះទេ" ។
នៅពេលនោះ ព្រះនាងមយន្តីនឹងព្រះបាទនាលៈ កាន់ព្រះហស្តគ្នាត្រម
ាំងមានព្រះរាជបុត្រានឹងព្រះរាជបុត្រី យាងតាមគ្រែយព្រះអង្គដោយ
មានព្រះភ័ក្ត្រសប្បាយរីករាយផង ចូលមកកន្លែងព្រះរាជបាហុនដ្ឋាន (មន្ទីរ
ទទួលភ្ញៀវនៃស្តេច) ។ ព្រះបាទតុបនិ: ទ្រង់មានប្រជ្ញាវ័យទ្រង់ដឹងក្លាម
ថា អ្នកដែលបាននាំទ្រង់មក គឺព្រះបាទនាលៈទើបទូលស្តេចថា: "ទូល
ព្រះបង្គំចង់នាំវីរបុរសឲ្យមកជួបនឹងព្រះនាងដែលតែងទ្រង់ទុក្ខខ្វាំង" ។

*
* *

ពេលនេះជាពេលបុណ្យយ៉ាងតគ្រឹកគគ្រែងនៅក្នុងក្រុងពួកវិទេគៈ ។ ព្រះចុទនាលៈ ទ្រង់យាងត្រឡប់មកក្រុងពួកនិសភៈដោយពេញកំត្តិយស ។ ទ្រង់យកឡុកឡាក់ ហើយទ្រង់ហៅទ្រង់ប៉ុស្ការៈ មកគ្រសាលជាមួយនឹងទ្រង់ទៀត ។ ម្ចងនេះអាទិទេពដួយឧបត្ថម្ភទ្រង់ទៅវិញ ទ្រង់ឈ្នះបានព្រះពជអាណាចក្រវិញ ប៉ុន្តែដោយទ្រង់យល់ថា ប៉ុស្ការៈហាក់ដូចជាវេទនាពេក ទ្រង់ក៏ចែកព្រះពជអាណាចក្រមួយចំហៀងឲ្យសោយរាជ្យ ។ ព្រះចុទនាលៈ ទឹងព្រះនាងទមយន្តី ទ្រង់សោយរាជសម្បត្តិប្រកបដោយសេចក្តីសុខ សេចក្តីចំរើនរហូតដល់អវសាន ។

ចប់

ត្រូវឃើញឆ្ងាយកុំឃើញជិត

អ្នកធ្វើប្រយោជន៍ដល់ជាតិ គឺអ្នកមើលឃើញឆ្ងាយ, អ្នកនោះឯងជាទុតជាវីរបុរស។ តែងមិនឃើញជិត យ៉ាងអ្នកដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួនទេ;

ធ្វើម្តេចហ្ន៎! ឲ្យខ្មែរគ្រប់ថាន:មើលឃើញឆ្ងាយគ្រប់គ្នាទៀង!

ឃ. អ.

ដំណើរតាមខ្សែក្នុងភាពងងឹត

# លោក ផើង-ជ្រើរ សាស្ត្រាចារ្យនៅសាលាគរុកិច្ចភ្នំពេញ

## ប្រែពីភាសាចាវ៉ាមកជាភាសាខ្មែរ

(តមក)

---

នាងឡឺឡាឧបមាដោយមេត្តា ហើយពោលថា: "ម៉ាសសម្លាញ់ប្អូនអើយ!" ។

អាឥស្សាតាក័យខ្ចាចស្ងាប់ ។ ដើមឡើយ គឺនាងទេតើដែលបង្គាប់ឲ្យរត់ចេញពីកងភាហានតួរគី ឥឡូវត្រឡប់ឲ្យទៅសួរខ្ញុំពីដំណឹងកងភាហាននេះវិញ ។ សូរពែងមាត់ផ្តែផ្តៃពាំងឡាយឮមកដល់នាងតាមខ្សែពេលល្ងាច ។ អាឥស្សាតាខ្ចាចញ័រអស់ពាំងខ្លួន ។ នាងថ្ងូរហើយអង្វរប្អូនថា:

– ទៅ! ឡឺឡា! ទៅ! កុំទុកឲ្យបងស្លាប់! ។

ខណៈនោះ នាងឡឺឡាសំឡឹងមើលបងកំសត់ ហើយមានចិត្តអាណិតរកទីបំផុតគ្មាន ។ នាងនិយាយច្រាបបងស្រីថា:

– សូមបងចាំប្អូនត្រង់ហ្នឹងចុះ ប្អូនសន្យាទឹងមកជួយសង្គ្រោះអ្នកបងជាមិនខាន ។

រួចនាងដើរកាត់ព្រលឹងព្រៃ ប្រកបដោយសេចក្តីភ្ញាហានហួសប្រមាណខ្លួនជាស្រីក្រមុំ ។ នាងចំប្រព័ន្ធឡើងផ្នែងព្រៃ លុះបានដល់

ខាងលើកាលណា នាងលាន់មាត់តែខ្លួនឯង ។ ខៅឯណោះឆ្លុយបន្តិច ប្រហែលមួយគីឡូម៉ែត្រ នាងឃើញគណៈលោកតាម៉ាត្រក មានភាហានតួរតែដើរពីខាងក្រោយ គ្រាច់ៗសន្សឹមៗ សំដៅទីក្រុង ។

នាងកុមារិកាពាំងពីរនាក់ ទឹកស្មានថាខ្លួនអាចគ្រាច់តាត់រាល់ឡាប់បាន ។ ក្មេងកំសត់ នាំគ្នាដើរវិលវង់ពីផ្ទះមួយទៅផ្ទះមួយ គ្មានបានឆ្លុយប៉ុន្មានពីកន្ទែងដែលចេញសោះ ។

នាងឡីឡាទឹកថាក្រែកដជាព្រះអាឡស់ជួយនាង ។

ចំណែកពួកឈ្លើយដើរខៅមុខតិចៗ បើរត់ នាងអាចខៅទាន់គ្នាម ។ នាងឡីឡាមិនចាប់គិតច្រើន ព្រោះប្រែកបដោយមេត្តាក្រៃថ្នាំងដួយសង្រ្គោះជីវិតរបស់បងស្រី ។ នាងឡីឡាក្មេចទឹកដល់ការអស់កំឡាំងគ្រោះថ្នាក់ដើងសង្កៀរ នាងស្ទុះរត់លើដីឡាប់ពណិក្រហមព្រឿន ។ ដោយរស្មីព្រះអាទិត្យជិតយប់ សំដៅពួកឈ្លើយដើម្បីរំដោះខ្មុចបងស្រី ។

* * *

នាងឡីឡាមកគ្រាបចុះក្បែរដើងសេះរបស់នាយភាហានវង្ងាក ។ គឺជាភាហានម្នាក់ដែលរដ្ឋាភិបាលតួរតីបញ្ជូនមកកាន់ស្រុកចំណុះ ដោយបញ្ជាប់លែងឲ្យធ្វើការនៅឯស្រុកកំណើត ។ គាត់នេះ ស្រុកដើមកំណើតនៅកស្ថិន៍ គេតែងហៅគាត់ថាព្រិន្ទូបាលពោម៉ារីយោ ។ គាត់បានឡើងដល់ឋានន្តរស័ក្តិគួចមួយនេះ មិនមែនបានដោយរដ្ឋាភេ

តិចាន់ដោយសារធ្វើការយូរ ។ គាត់ខុសជាតិអាក៉ាប់ជាមនុស្សអាយ៉ងតេ ហើយមានសិទ្ធិចង់សម្លាប់ ឬខុសដំរែតអ្នកណាក៏ចាន់តាមចិត្ត ។

កាលពីក្មេង គាត់តែងគោចរតែក្នុងតៀមទឹកស្រែធំនាក្រុងកុងស្តង់-ទីណុប រហូតដល់ជាប់សុក ហើយបើទឹងរៀបចំកិច្ចការអ្វីគាត់ច្រើនប្រើតែអារុងជាប្រមាណ នាំធ្វើឲ្យគេកល់គ្នាំងាន់ដោយសារ ។ ថ្វីបើគាត់ជាអ្នកកាន់សាសនាម៉ាហ្គូមេត ប៉ុន្តែគាត់នេះគ្មានគោរពបទបញ្ញត្តិណាមួយរបស់ព្រះអង្គសោះ គាត់ប្រពឹត្តផឹកតែទឹកស្រវឹង ពាល់តែក្អែកឡើងក្រហមដូចក្អែកអាអូត មុខក្រហមដូចមុខមាន់គក ហើយច្រើនខឹងតូងរគាង ។ នាយពាហានទាំងឡាយស្អប់គាត់ណាស់ ប៉ុន្តែអធ្យាស្រ័យអត់អោនឲ្យដោយសារដឹងថាគាត់ប៉ិនប្រាក្នុងមុខក្រសួង ។ ម្យ៉ាងទៀតពួកវរសេនីយ៍ទាំងនោះគំជាមនុស្សមិនល្អប៉ុន្មាន ។ ក្នុងជាន់មុន រជ្ជកិច្ចាល កុងស្តង់ទីណុបខុកក្រុងទ្រីប៉ូលីតែនជាកន្លែងសម្រាប់ទំរេសដែលគេតែងបញ្ជូនគ្នាក់ងារពជការ ឬក្រុមពាហានមក ។ ហេតុដូច្នេះហើយបានជាកងវរសេនីយ៍ធំនេះ មានច្រើនសុទ្ធតែក្រុមពាហានទឹងនាយពាហានមានជាតិទឹងកិរិយាមារយាទមិនបរិសុទ្ធល្អទេ ។

ចំណែកក្រុមពាហានមិនសូវចូលចិត្តទឹងលោកត្រិនូបូលេពា ម៉ារីយោនេះសោះ ព្រោះលោកនេះមានចំណេះពីសំណាក់នាយពាហានអាឡឺម៉ង់ត៍ ហើយតែងតែយកវប្បធម៌ប្រពៃណីអាឡឺម៉ង់ត៍មកប្រពឹត្ត ។ តាមវិន័យខាងលើនេះ គេឃើញលោកម៉ារីយោប្រពឹត្តអំពើយង់ឃ្នងជាច្រើន ។

មានមួយថ្ងៃ គាត់កាត់ស្លឹកត្រចៀកបស់ខាហានម្នាក់ដែលនៅ
ក្រោមបង្គាប់គាត់ ។ ម្ដងទៀត គាត់ប្រយុទ្ធដែលគាត់ដិះចាស់តែស្ងាប់ ។
កាលដែលសេះនោះកំពុងជក់បង្ហាមាន់ គេឃើញចំបើងដែលជាក់ឲ្យ
សេះនោះដេកប្រឡាក់សុទ្ធតែឈាម ព្រោះលោកម៉ារីយោតែងដិះសេះ
ណាដែលលោកដឹងថាជាសេះកៀប ដោយពាក់ស្បែកដើងបាតបន្ទាមុត
ដូចគាំបិតគោ ។

លោកព្រន្ធបាលម៉ារីយោងក់ប៉ូកាក់ប៉ូប្លែកនៅលើខ្នងសេះ ព្រោះស្រវឹង
ស្រាអាប្ញែនក្នុងកំប៉ុងដែលព្យួរទងខ្សែក្រវាត់ នៅជាបន្ទោះជាវទងកាំភ្លើង
វែងល្អ ។ លុះសេះទប់ដីក់ ទើបលោកម៉ារីយោបើកភ្នែក ហើយ
ឃើញនាងឡាឡាលុតជង្គង់នៅពីមុខសេះដោយអាការអនវ៉ែន ។ គាត់
ញញឹមហើយសួរថា:

- មកពីណា នាងក្រមុំ? ។

ពួកខាហានខ្លះទើងអ្នកដិះអូដ្ឋ ដែលដើរពីក្រោយកំឈប់តាម, ក្នុង
បណ្ដាអាប៉ាច់ទាំងឡាយ នាងឡាឡាស្គាល់លោកតាម៉ាត្រុត ។ កាលចេញ
ពីជ្រលងភ្នំមកគាត់ដើរមុនគេ ប៉ុន្តែគាត់ចាស់ដើរមិនលឿន ក៏ត្រឡប់ជា
នៅក្រោយវិញ ។ លុះបានឃើញមុខលោកតាជានាយគណៈចាចរក៍
នាងក្រមុំត្រឡប់មានកំឡាំង ហើយមានសេចក្ដីសង្ឃឹមបន្ដិចបន្ដួចក្នុងចិត្ត ។
នាងងើបឡើង ហើយមានឪពាក់:

— ខ្ញុំសូមអង្វរលោក សូមលោកមេត្តាជួយស្រង់អាយុចង្រៃខ្លាក់ខ្ញុំផង គាត់ទៅតែម្នាក់ឯងក្នុងព្រលឹងប្រាប់ឯណោះ ។

លោកមាំរៃយោគ្រេកឡេកយើញនារីនេះ តម្រេកក៏កើតមានឡើងហើយបញ្ចេញអាការឲ្យយើញតាមភ្នែក ។ សំឡឹងពីខាងក្រៅសំពត់ដែលគ្រវែញសដាមដិតជាប់នឹងកាយនៃនាង គាត់ទឹកស្នានដល់ទៅយុវាសណ្ឋានអាក្រាត ដល់ស្ពន់យ៉ាងក្បាំដូចផ្លែទន្ទាប់ មានចុងពណ៌សូកូឡាផ្អាប់នឹងទ្រូង ដល់ទៅសាច់ពោះសរលីងដូចបណ្តូលចេក ហើយគាត់គិតថា បងស្រីក៏មិនចាញ់ប្អូនប៉ុន្មាន ។ រួចមានស្រមៃនេះញាំងភាគគ្នីឲ្យឆេះឡើង មានបំណងនឹងបង្ខិតអង្គហ្មត្ថវិយធម៌ ចំពោះលើរូបនាងកុមារីកាន់តែពីរ គាត់នេះចង់ជានស្រីកំណាន់យូរណាស់ហើយចង់ធ្វើឲ្យដូចជានាយហានតាំងពួង គឺមានស្រីកំណាន់ចំពោះខ្លួនទៅបំរើជានិច្ចដូចជាទាសី ។

លោកព្រឹទ្ធបាលជញ្ជឹងមួយស្របក់ តែភ្នែកសំឡឹងព្រះអាទិត្យដែលលិចចុះឯដើងមេឃ ហើយចោលមួយទៅលើក្បាលក្បូនដំណើរដែលមានលោកវរសេនីយ៍ទោ សេលីម ជាអ្នកបញ្ជាការ ។ នាយហានេះត្រូវជាកូយរបស់ព្រះបាម៉ុយនិវ ប៉ាបា ជាមន្ត្រីមិនវឡេះវឡោះភ្នែមុខក្រែសួង ហើយមិនសូវអត់ទោសចំពោះលោកព្រឹទ្ធបាលនេះផង ។

(មានត)

# រឿងបស់ព្រះទេព្យ សាមសិបតំរាវរឿង

រឿងព្រេងតំណៀ

## លោកសមិន ម្ចាស់វត្តជិម: តែង

## លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

កន្លងពេលនោះ, នៅក្នុងព្រៃនគរអវន្តី មានព្រាហ្មណ៍ម្នាក់តែងគោរពបូជានាងទេវីជាទេវតារក្សាប្រទេស ។ នាងទេវីមានព្រះទ័យត្រេកអរនូវការវន្ទានៃព្រាហ្មណ៍នោះ បានមកបង្ហាញរូបឲ្យព្រាហ្មណ៍នោះឃើញ ហើយពោលសរសើរព្រាហ្មណ៍ជាអនេកបរិយាយ ហើយសួរថា: "ឱ ព្រាហ្មណ៍អើយ, អ្នកឯងប្រាថ្នាចង់បានអ្វីក្នុងលោកនេះ" ។ ព្រាហ្មណ៍នោះកាលបានពណ៌នាអំពីគុណសម្បត្តិនៃនាងទេវី ក៏តបទៅវិញថា: "ឱ ទេវី, បើនាងមានចិត្តអាណិតខ្ញុំដោយស្មោះត្រង់ ខ្ញុំសូមឲ្យនាងធ្វើឲ្យខ្ញុំផុតពីសេចក្តីងាស់ដកនឹងមរណៈ" ។ នាងទេវីបានស្តាប់នូវពាក្យព្រាហ្មណ៍នោះហើយ ក៏មានអំណរជាយ៉ាងក្រៃលែង ហើយប្រគល់ផ្លែឈើមួយទៅព្រាហ្មណ៍នោះរួចប្រាប់ថា: "បើកាលណាអ្នកឯងបរិភោគផ្លែឈើនេះ អ្នកឯងនឹងផុតពីសេចក្តីងាស់ដកនឹងមរណៈ" ។ រួចនាងទេវីក៏ចាត់ខ្លួនក្នុងពេលនោះ; ព្រាហ្មណ៍ក៏ត្រឡប់ទៅគេហដ្ឋានខ្លួនវិញ ។ ដល់ថ្ងៃស្អែក, ព្រាហ្មណ៍នោះបានបំពេញការណាយកិច្ចចំពោះនាងទេវី ដោយ

លុបព្រះកត្តុ, ឬជាទ្វារដង្វាយផ្សេងៗ ។ ហើយប្រគល់ប្រគៀបនឹងយកផ្លែឈើនោះមកបរិភោគ ខ្លួលមានចិត្តមួយគិតថា: "ខ្ញុំអញជាអ្នកសូមយាចកជាទុព្ភិក្ខបុគ្គល, តើមានប្រយោជន៍អ្វី នឹងឲ្យជីវិតអញមានថេរវេលាតទៅទៀត? ព្រះបាទពារ្តីហរិ ជាព្រះមហាក្សត្រិយ៍ទ្រង់ទសពិធរាជធម៌, ការដែលធ្វើឲ្យព្រះអង្គមានទីយាយុ នាំឲ្យបានប្រយោជន៍ដ៏ឧត្តមចំពោះបុគ្គលទាំងពួងជាច្រើន" ។ កាលព្រាហ្មណ៍នោះតិចារណាយ៉ាងនេះហើយ, ក៏ធ្វើដំណើរទៅកាន់ព្រះរាជនិវេសន៍ដ្ឋានគ្រាបបង្គំថ្វាយទ្វារផ្លែឈើនោះទៅព្រះមហាក្សត្រិយ៍ ហើយក៏ទូលទ្រង់ឲ្យជ្រាបទ្វារឿងសព្វគ្រប់ ។ ព្រះមហាក្សត្រិយ៍ទ្រង់ទទួលផ្លែឈើនោះហើយ ក៏បានប្រគល់ទ្វារគ្រឿងឥស្សរិយយសជាច្រើនឲ្យដល់ព្រាហ្មណ៍; ឯព្រាហ្មណ៍នោះក៏វិលទៅគេហដ្ឋានខ្លួនវិញ ។ មហាជនបានចូលទៅកុងក្រឡាព្រះបន្ទំនៃពួកស្រីស្នំ ក៏បានព្រះរាជទានទ្វារផ្លែឈើនោះទៅព្រះនាងហនី ហើយទ្រង់បានថ្លែងរឿងរ៉ាវឲ្យព្រះនាងស្តាប់សព្វគ្រប់ប្រការ ។ ព្រះនាងហនីមានចិត្តប្រតិព័ទ្ធស្នេហាចំពោះព្រះរាជទេវីប្រឹក្សាទីមួយ ក៏យកផ្លែឈើនោះទៅប្រគល់ឲ្យព្រះរាជទេវីប្រឹក្សានេះ ។ ព្រះរាជទេវីប្រឹក្សានោះ មានសេចក្តីស្នេហាចំពោះស្រីស្នំម្នាក់ទៀត ក៏បានយករឿងរ៉ាវទៅពណ៌នាថ្លែងប្រាប់នាងហើយក៏ឲ្យទ្វារផ្លែឈើនោះ ។ ឯស្ត្រីស្នំនេះបានទទួលផ្លែឈើនោះហើយក៏សម្រេចក្នុងចិត្តថា: "បើអញយកផ្លែឈើនេះទៅថ្វាយព្រះបាទ

ពរត្រីហរិ មុខជាអញបានសម្បត្តិទេព្យទ្រែន" ។ កាលគិតយ៉ាងនេះ
ហើយ នាងក៏នាំយកផ្លែឈើនោះទៅថ្វាយព្រះមហាក្សត្រិយ៍។ ទ្រង់
ទទួលនូវផ្លែឈើនោះ ដោយមានព្រះពាដរិចិតិច្ឆាថា: "ផ្លែឈើនេះ
អញបានឲ្យទៅព្រះនាងហនី, តើសេចក្តីស្រឡាញ់ព្រះនាងហនី ចំពោះ
នាងតារកានេះយ៉ាងណាទៅ?" ព្រះមហាក្សត្រិយ៍ទ្រង់ក៏បានត្រាស់
បង្គាប់ឲ្យស៊ើបសួរឿងនេះ ហើយក៏ទ្រង់ជ្រាបនូវឿងរ៉ាវទាំងអស់ ។
ព្រះអង្គក៏មានព្រះទ័យខឿយណាយនឹងលោកាមិស ហើយទ្រង់ជ្រាប
ច្បាស់នូវសភាពណាមក ដែលកើតពីទេព្យសម្បត្តិក្រៅពីនេះ គឺស្តី,
តារក . . . . ល . . . . ។ ព្រះអង្គទ្រង់ព្រះតម្រិះដូចនេះថា "ស្តីនេះ
អញស្រឡាញ់លើសជីវិតអញទៅទៀត, ឥឡូវនេះអញឃើញដោយជាក់
លាក់ថាវាឥតមានស្នេហាមកលើខ្លួនអញសោះឡើយ, ប្រែទៅជាមានចិត្ត
ប្រតិព័ទ្ធនឹងទីប្រឹក្សាអញវិញ; ទីប្រឹក្សានេះគ្មានចិត្តស្នេហានឹងនាងហនីទេ
ប្រែទៅស្រឡាញ់ស្រីស្នំទៅវិញ; ចំណែកឯស្រីស្នំគ្មានប្រតិព័ទ្ធនឹងទី
ប្រឹក្សានេះ ប្រែទៅជាស្រឡាញ់ទេព្យសម្បត្តិទៅវិញ ។ ព្រោះហេតុ
នេះ ការស្នេហាចំពោះស្តី, តារក ឬវត្ថុឯទៀតក្នុងលោកនេះ គឺជា
ការបំភាន់គំនិតអញសោះ" ។ ព្រះមហាក្សត្រិយ៍ដល់ទ្រង់វិតក្កៈយ៉ាង
នេះហើយ ក៏ទ្រង់លះបង់រាជសម្បត្តិយាងទៅគង់នៅក្នុងវិព្រៃជារុក្ខមូល
នៅទីនោះ ទ្រង់សោយនូវផ្លែឈើដែលព្រះបន្លឺតមក, ហើយក៏ផ្គង

ចិត្តទៅក្នុងសមាធិយ៉ាងតេញាលេញ ។ មហាភវតណ្ហាមិនមានព្រះភវនុរសេ, ព្រះភវអាណាចក្រក៏គ្មានស្តេចសោយភវ្យ ហើយប្រជាពលស្តេមានសេចក្តីភ័យជាខ្លាំង ដោយមានចោរពាលសាមន្យប្រព្រឹត្តលួចប្លន់កាន់តែមានចំនួនច្រើនជារៀងរាល់ថ្ងៃ ។

មានវេតាល:(១) នាមថាអគ្គី បានតាំងគេហដ្ឋាននៅក្នុងប្រទេសនោះ ។ ចំណែកខាងពួកទីប្រឹក្សា ដោយសេចក្តីភ័យជាខ្លាំង បានចាត់ផ្សេរភវ-សម្បត្តិមកឲ្យយុំនៃមួយនាក់ឈ្មោះសត្រិយ ដែលមានលក្ខណៈជាស្តេច ។ តែថ្ងៃដែលគេយកយុំនៃនោះមកអភិសេក វេតាលៈអគ្គីមកពិឃាដយុំនៃនោះ រួចត្រឡប់វិលទៅគេហដ្ឋានវិញ ។ តាំងពីនោះមក, បើពួកទីប្រឹក្សាបានលើកឥស្សរជនណាមួយឲ្យសោយភវសម្បត្តិ វេតាលៈអគ្គីនោះមកពិឃាដភ្លាម ។ ព្រោះហេតុនេះ គេលែងហ៊ានលើកឥស្សរជនណាមួយឲ្យសោយភវសម្បត្តិក្នុងប្រទេសនោះ ។ ការប្រព្រឹត្តិអំពើពាលទុច្ចរិតនៃពួកចោរឫកអសប្បុរស កាន់តែមានអានុភាពខ្លាំងពាល់ទិវាកត្រី ពាល់តែប្រទេសចុះក្នុងស្ថានការណ៍ដ៏លំបាក ។ ព្រះភវទីប្រឹក្សាបានខំពិចារណារកមធ្យោបាយ ដើម្បីនឹងការពារស្តេចកុំឲ្យវេតាលៈនោះមកពិឃាដបាន តែព្រះភវទីប្រឹក្សានេះ មិនអាចរកឧបាយកលណាឃើញឡើយ ។

---

១ វេតាលៈ បិសាចមួយរូប ដែលនៅទីប៉ាក់ជា មានវិជ្ជានុភាព អាចឲ្យទុក្ខទោសសព្វយ៉ាងដល់អ្នកដែលខ្លួនស្អប់ ឬបំណងនឹងព្យាបាទ ។

មានមួយថ្ងៃ ពួកវរជ្ជមន្ត្រីបានធ្វើសន្និបាត, ក្នុងពេលប្រជុំ កំពុងតែវិនិច្ឆ័យរឿងនេះ ស្រាប់តែព្រះបាទវិក្រមទិត្យ ទ្រង់ក្រោធព្រះអង្គចូលមកក្នុងព្រះពលមន្ទីរ ហើយមានព្រះឱង្ការសួរទៅកាន់វរជ្ជមន្ត្រីទាំងឡាយថា: "ហេតុដូចម្តេច ក៏បានជាព្រះរាជអាណាចក្រនេះ គ្មានព្រះមហាក្សត្រិយ៍?" ។ ពួកវរជ្ជមន្ត្រីទូលថា: "ព្រះមហាក្សត្រិយ៍ទ្រង់យាងទៅគង់ក្នុងព្រៃ; កាលណាបើយើងខ្ញុំរើសក្សត្រិយ៍អង្គណាមួយ ឲ្យសោយរាជ្យវៃតាលៈអគ្គី ក៏មកបំផ្លាញដីវិតនូវព្រះមហាក្សត្រិយ៍អង្គនោះភ្លាម" ។ ព្រះបាទវិក្រមទិត្យ ទ្រង់ព្រះសណ្តាប់នូវពាក្យនេះហើយ, ទ្រង់មានព្រះរាជឱង្ការថា: "ឲ្យពួកអ្នកអតិសេកខ្ញុំជាស្តេចក្នុងពេលឥឡូវនេះចុះ" ។ ពួកវរជ្ជមន្ត្រីបានឃើញព្រះបាទវិក្រមទិត្យមានព្រះរាជចរិយាដ៏ថ្លៃថ្លា គួរឲ្យសោយរាជ្យជាស្តេចបាន ក៏បានអភិសេកព្រះអង្គជាស្តេច ហើយប្រកាសថា: "តាំងពីថ្ងៃនេះ ព្រះអង្គជាព្រះមហាក្សត្រិយ៍នៅប្រទេសអវន្តី យើងទាំងអស់គ្នាសូមប្រព្រឹត្តតាមព្រះរាជឱង្ការព្រះអង្គគ្រប់ប្រការក្នុងកិច្ចការទាំងពួង" ។ កាលព្រះបាទវិក្រមទិត្យ ទ្រង់បានសោយរាជ្យជាស្តេចនៅប្រទេសអវន្តី ទ្រង់បានរៀបចំចាត់ការក្នុងព្រះរាជអាណាចក្រ ពាល់ទំាងត្រឹម, ប្រទេសក៏បានទទួលនៅសេចក្តីសុខ ។

(មានត)

# សេចក្តីរៀបរៀង

## របស់ព្រះទេពសត្ថា បង្ហូមង្គលោ កិម-គ្ឃ្ឍរ

វត្តខ្ណាលោម

អំពី

## ដំណើរទៅកាន់ប្រទេសកូមា

(ត-ចប់)

---

## ពិធីប្រគេនសមណស័ក្តិជាអគ្គមហាបណ្ឌិត

## បំពោះសម្តេចព្រះមហាសុមេធាធិបតី ជ. ណាត

កន្លងថ្ងៃទី ២២ ឧសភា ១៩៥៤ នោះ នៅវេលាម៉ោង ១៤, រដ្ឋាភិបាលប្រទេសកូមា បានចាត់ការរៀបពិធីមួយដ៏ខ្ពង់ខ្ពស់ ដើម្បីប្រគេនសមណស័ក្តិដល់សម្តេចទំង់ព្រះថេរៈឯទៀត ៧ អង្គ នៅគេហដ្ឋានរបស់លោកប្រធានាធិបតី, ជាពិធីយ៉ាងថ្មីកអស្ចារ្យដែលប្រទេសយើងមិនធ្លាប់បានធ្វើទាំងមិនធ្លាប់បានឃើញផង គឺគេរៀបអាសនៈមួយដ៏ខ្ពស់រចនាដោយក្បាច់ក្បូរនឹងផ្កា មានកូសំបើកចុងពីខាងលើ មានពួកស្ត្រីក្មេងចាស់ប្រហែល ២០០ នាក់ សុទ្ធតែស្លៀកពាក់ជាឯកសណ្ឋានអង្គុយតម្រៀបគ្នាពីខាងមុខឈៀងម្ខាងនៃអាសនៈព្រះមហាថេរ ដែលត្រូវទទួលសមណស័ក្តិ, ពួកវេជ្ជមន្ត្រីនិងមន្ត្រីជាលំដាប់ត្រមាំងឥស្សរជន

តំណាងប្រទេសទាំងអស់ ដែលបានអញ្ជើញមកក្នុងពិធីនោះប្រហែល ៣០០ នាក់ ក៏អង្គុយពីខាងមុខឈៀងម្ខាងនៃអាសនៈទាំងនោះដែរ, ពួកព្រះសង្ឃកូមានទីតំណាងប្រទេសជាច្រើន ដែលនិមន្តមកក្នុងពិធីនោះ គង់លើអាសនៈពីខាងក្រោយ ។ ម៉ោង ១៥, វេលាជល់ហើយ មានបុរសម្នាក់ឈរស្រែកឲ្យសញ្ញាភ្លាម, ភ្លេងតូរ្យតន្ត្រីកំលាន់ឮរំពងឡើង ។ ខណៈនោះឯង គេហែសម្តេចនឹងព្រះមហាថេរឯទៀតចេញមកពីក្នុងកន្លែងមួយ, ឯកទុតមរដ្ឋមន្ត្រីក្រសួងធម្មការកាន់កូនផ្កាដោយដៃទាំងពីរដើរនាំមុខសម្តេច, បន្ទាប់ពីសម្តេចមក ព្រះមហាថេរឯទៀត ។ សម្តេចនឹងព្រះមហាថេរ ៧អង្គ និមន្តឡើងគង់លើអាសនៈខ្ពស់ដែលគេតាក់តែងបំរុងទុក, ភ្លេងតូរ្យតន្ត្រីក៏សូរសាត់សូរក្តាម, មានការ ៨ នាក់សូត្រចសរភ័ញជាភាសាកូមាព្រមៗគ្នា អស់វេលា ៥ នាទី, បន្ទាប់មកលោករដ្ឋមន្ត្រីម្នាក់ឡើងសូត្របវត្តិរបស់សម្តេចជាភាសាកូមា. លោករដ្ឋមន្ត្រីម្នាក់ទៀតឡើងសូត្រជាភាសាអង់គ្លេស, ហើយទើបថ្វាយប្រវត្តិនៃព្រះថេរៈដទៃៗទៀតតាមលំដាប់លំដោយ, បន្ទាប់មក លោកប្រធានាធិបតីឡើងថ្វាយគុណសម្បត្តិរបស់សម្តេច រួចហើយក៏លើកសញ្ញាប័ត្រនឹងត្រាដែលមានក្លាក់នឹងហឹបតូចដ៏វិចិត្រ ប្រគេនសម្តេចជាមុនបង្អស់ រួចប្រគេនមហាថេរឯទៀតគ្រប់ៗអង្គ ។ ពិធីដែលពណ៌នាមកនេះឯង គឺរដ្ឋភិបាលមានលោកប្រធានាធិបតីកូមាជាប្រមុខជាន់ប្រគេនសមណសក្តិ ចំពោះសម្តេចព្រះមហាសុមេធាធិបតីសង្ឃ-

នាយកប្រទេសកម្ពុជា ឲ្យឡើងជា អគ្គមហាបណ្ឌិត ប្រទេសភូមា ។ សេចក្តីពិត តាមដែលលោកសង្ឃនៅប្រទេសភូមានិយាយប្រាប់ខ្ញុំថា សមណស័ក្តិទីអគ្គមហាបណ្ឌិតនេះ សូម្បីព្រះថេរៈខាងឡាយដែលនៅប្រទេសភូមា ក៏មិនដែលបានដោយងាយៗទេ លុះតែបរិបូណ៌ដោយគុណសម្បត្តិ - ចរិយាសម្បត្តិនឹងចំណេះវិជ្ជាគ្រប់យ៉ាង ព្រមទាំងមានវស្សាច្រើនផង ទើបគួរទទួលឋានៈនេះបាន ។ នៅប្រទេសភូមា ព្រះមហាថេរ ដែលបានឡើងសមណស័ក្តិជាអគ្គមហាបណ្ឌិតនេះ មានមិនច្រើនអង្គទេ, មានច្រើនតែសមណស័ក្តិទីធម្មាចារ្យ ដែលបានដោយការប្រឡង, ប្រហែលដូចជាសញ្ញាប័ត្រសាលាចាលីនៅប្រទេសខ្មែរយើងដែរ ។

## ជំណើរទស្សនាការបូជនីយស្ថានតៅប្រទេសភូមា

ថ្ងៃទី ២៣ ឧសភា ១៩៥៤, រដ្ឋាភិបាលប្រទេសភូមា បានចាត់ការជូនគណៈប្រតិភូតំណាងប្រទេសផ្សេង ។ ទាំងព្រះសង្ឃទាំងគ្រហស្ថ ចំនួន ១៩៦ រូប ដោយអាកាសយាន ៧ : គ្រឿងសុទ្ធតែកង្វារ ២, ទៅកាន់ក្រុងមន្តលេ ដើម្បីពិនិត្យមើលព្រមទាំងនមស្ការបូជនីយដ្ឋានដ៏សំខាន់ៗ ។ រយៈផ្លូវអាកាសយានពីក្រុង រ៉ង្គូនទៅមន្តលេ ប្រហែល ៤៣៤ ម៉ែល (ជាង ៦០០ គីឡូម៉ែត្រ) ។ ម៉ោង ៨, យន្តហោះចេញពីស្ថានីយអាកាសយានមន្តលេ: ជូន, ម៉ោង ១០,៣០ ដល់ស្ថានីយអាកាសយានក្រុង

មន្ត្រលេ ។ ពួកបរិស័ទជាតិកូមាជាច្រើនចាំងអ្នកភាជការចាំងប្រជារស្ត្រ
មកវង់ចាំទទួលគណៈប្រតិកូចាំងអស់, និមន្តរញ្ជើញដោយរថយន្តឲ្យទៅ
ស្នាក់កងមហាវិទ្យាល័យមួយដែលទើបនឹងសង់ហើយថ្មី ។ ក្នុងក្រុងមន្ត្រលេ
ហើយទទួលកត្តាថ្ងៃត្រង់នៅទីនោះ ។ ម៉ោង ១៣ គណៈប្រតិកូចាំង
អស់ ដែលមានលោកថៅហ្វាយក្រុងនិងក្នាក់ងារនគរបាលជិះរថយន្តនឹង
ខោចក្រយានយន្តនាំមុខ, បានទៅនមស្ការចេតិយមួយហៅ មហាម៉ាក់-
ម៊ុនី (ប្ញមហាមុនី) នៅចំកណ្តាលក្រុងមន្ត្រលេ ចេតិយនេះធំខ្ពស់មានផ្លូវ
សណ្ឋានជាជណ្តើរ មានដំបូលស្រួច ។ ជាប់គ្នាពីថ្ងល់ចូលទៅប្រហែល-
៣០ម. ទើបដល់តួចេតិយធំដែលមានព្រះពុទ្ធរូបមួយព្រះអង្គធំគ្រងគង់
វែនព្រះក្នែន ។ នៅអមសងខាងផ្លូវចូលទៅកាន់ចេតិយធំ មាន
ប្រជាជនកូមាចាំងស្រីប្រុសលក់របស់ប្លែកប្លាស់គ្រប់មុខ ទីផ្សារផ្សេង។
សម្រាប់ឲ្យអ្នកចូលទៅទិញយកទៅបូជា ។ លំដាប់ពីនេះ គណៈប្រតិកូ
ចាំងអស់បានទៅនមស្ការចេតិយធំមួយទៀតហៅថា បេតិយមីងដ្ងិង
តាំងនៅខាងទិសអគ្នេយ៍នៃក្រុងមន្ត្រលេ ដែលព្រះពាជាមួយព្រះអង្គគ្រង
ព្រះនាម ព្រះបាទមីងដ្ងិង បានសាងឡើង ។ នៅជុំវិញចេតិយនេះមាន
ចេតិយតូច ។ បីតនៅជាជួរ ។ ក្នុងចេតិយតូច ១និមួយ ។ មានផ្ទាំងថ្មកែវ
មួយផ្ទាំង ។ ទទឹង ១ម. កំពស់ ១ម.៩០ គ្រាស់ជាង ១០សង់ទីម៉ែត្រ ចំនួន

៧២៤ ឆ្នាំឆ ឆ្លាក់ជាលីតែរៃតែបិដកមួយចប់ជាអក្សរកូមា, មានកំពែងធ្វើ ដោយឥដ្ឋព័ទ្ធជុំវិញពីខាងក្រៅនៃចេតិយតាំងអស់នោះ ។ តមកទៀត បានទៅសក្រាកនៅសាលាធំមួយ មានថ្នាក់ពីរជាន់ជារបស់តាបសឈ្មោះ អ៊ូ-ខន្តី កសាង ។ ពួកបរិស័ទកូមាបានលឿងកេសដ្ឋ:ដល់គណ:ប្រតិកូ តាំងអស់ក្នុងសាលានោះ រួចហើយក៏នាំគ្នាឡើងទៅមើលទៅនមស្ការ ចេតិយធំលើកំពូលភ្នំមន្តលេ ។ ភ្នំនេះមើលពីខាងក្រោមទៅឃើញខ្ពស់ សន្ធឹម, គេធ្វើចេតិយធំដាល់ព្រះពុទ្ធរូបមួយព្រះអង្គធំទ្រង់ឈរក្នុងចេតិយ ចំកណ្តាល, មានជណ្តើរវៀចជាថ្នាក់ៗសម្រាប់ឡើង មានត្រប់ទិស តាំង ៤, ជណ្តើរនីមួយៗ តាំងពីជាន់ក្រោមទៅដល់ជាន់លើប្រហែល ២៩០ ម ដំបូលប្រកស័ង្កសីដូចគ្នាតាំងអស់ ។ ម៉ោង ១៧, ៣០ ទើប ត្រឡប់មកឯកន្លែងស្នាក់នៅមហាវិទ្យាល័យក្រុងមន្តលេវិញ ។

ថ្ងៃទី ២៤ ឧសភា ១៩៥៤ ម៉ោង ៧ ព្រឹកគណ:ប្រតិកូតាំងអស់ ចេញពីក្រុងមន្តលេ ដែលមានលោកចៅហ្វាយក្រុងមន្តលេនឹងក្រុម ភ្នាក់ងារពាណិជ្ជកាមួយចំនួនជូនដំណើរផង, បានទៅ មើលព្រមទាំងនមស្ការបូជនីយដ្ឋានក្នុងតំបន់ម៉ែងគុន ដោយចក្កនាវធំមួយ ឈ្មោះថ្មាំងោក ( Padauk ) ទទឹង ៨ម បណ្តោយ ៣០ម. តាមទន្លេឥរ៉ាវ៉ាឌី ។ ម៉ោង ៨,៣០ ដល់ម៉ែងគុន មានពួកភ្នាក់ងារពាណិជ្ជកានិងអ្នកស្រុកមកទៅរង់ ចាំទទួលទៅទីនោះ គណ:ប្រតិកូតាំងអស់ក៏ចុះអំពីចក្កនាវដើរទៅមើល

ព្រមទាំងនមស្ការចេតិយនៅក្នុងតំបន់ម៉ែងគុននោះជាច្រើនកន្លែង, ចេតិយ
ខ្លះកំពស់ ៥០ម. ក៏មាន, ៦០ម. ក៏មាន, ចេតិយតូចៗ ក៏មាន' ឃើញដែរ
ជាសរាប់ពាន់ចេតិយ ។ ដល់ម៉ោង ១០ ទទួលភត្តថ្ងៃត្រង់នៅវត្តមួយក្នុង
តំបន់ម៉ែងគុន ដែលអ្នកស្រុកចាត់ចែងប្រគេន ។ លុះទទួលភត្តរួច
ហើយ គណៈប្រតិភូទាំងអស់ ក៏ចុះដំណើរក្តៅដដែលតាមទន្លេឥរាវតី
ទៅតំបន់មួយទៀតហៅសាកែង ឬសាហ្គែង (Sagaing) ។ ម៉ោង ១៣,
ចក្ខុនាវដល់ចំណតសាកែង, ឃើញមានវេយ្យាវច្ចធំតូចតំរៀបជាជួរតាម
ច្រាំង ទាំងពួកភ្នាក់ងារពាណិជ្ជការក៏រង់ចាំទទួលទៅទីនោះដែរ, គណៈប្រតិភូ
ទាំងអស់ក៏ចុះពីនាវាហើយឡើងជិះវេយ្យាវច្ចនោះទៅកាន់ រាជមណ្ឌិបូទ្ធ
បេតិយ ជាចេតិយមួយយ៉ាងធំ មានកំពែងព័ទ្ធជុំវិញពីខាងក្រៅ, ខាង
ក្នុងចេតិយនោះ មានព្រះពុទ្ធរូបមួយព្រះអង្គធំគង់ពែនព្រះវិក្ខន, នាំគ្នា
នមស្ការចេតិយនោះ ហើយក៏សម្រាកក្នុងយ៉ាចេតិយទទួលកេសជ្ជៈអស់
វេលា ៣០ នាទី, រួចហើយក៏ឡើងវេយ្យាវច្ចទៅនមស្ការចេតិយមួយទៀត
ឈ្មោះ ប៉ាប៉ាក់ជី ។ ចេតិយនេះក៏ធំណាស់ដែរ មានព្រះពុទ្ធរូបមួយ
ព្រះអង្គធំទ្រង់គង់ពែនព្រះវិក្ខនខាងក្នុង ។ តពីនេះ គណៈប្រតិភូទាំងអស់
ឡើងវេយ្យាវច្ចត្រង់ទន្លេឥរាវតីដោយសាឡាង ត្រឡប់ចូលមកកាន់ក្រុងមន្ត-
លេវិញ ។ ប៉ុន្តែលុះមកដល់តំបន់មួយឈ្មោះ អ្នមរប៊ូរ: ជាទីក្រុង

ចាស់នៅដិតក្រែងមន្តលេ, ពួកភ្នាក់ងារពេជគារទើងប្រជាជនច្រើនរៀបតុ-
កៅអី ព្រមទាំងកេសដ្ឋះផ្សេងៗរង់ចាំទទួលក្នុងទីនេះ ។ គណៈប្រតិភូ
ទាំងអស់បានទទួលកេសដ្ឋះរួចហើយ គេក៏នាំចូលទៅមើលពេជចក្រ
តូចញាស់ពត់ដោយគ្រឿងមាសុីន ឃើញមានពេងតម្បាញតីឈើជាច្រើន
កន្ទេល ទឹងពេងចោះតុម្ពសាច់សំពត់ជាដ្ឋាតិផ្សេងៗ, រួចហើយក៏ឡើង
រថយន្តមកកន្ទេលសំណាក់នៅមហាវិទ្យាល័យដដែលវិញ ។

ថ្ងៃទី ២៩ ឧសភា ១៩៥៤, ម៉ោង ៧ គណៈប្រតិភូទាំងឡាយ
ចេញដំណើរពីក្រែងមន្តលេទៅខេត្តប៉ាកាន (ប្ដូច្ប៉ាហ្គាន (Pagan) ហៅ
តាមឈ្មោះក្រែងចាស់ពីដើម ដែលខ្មែរយើងធ្លាប់ស្គាល់មកថាភូគាម ឬ
អរិន្ទមៈពីក្នុងគាលៈព្រឹងនាយ) ដោយចក្កនាវធំឈ្មោះប៉ាដោកដដែល
តាមទន្លេឥរាវតី មានទាំងលោកចៅហ្វាយក្រែងមន្តលេទឹងក្រុមភ្នាក់ងារ
ពេជគារជូនដំណើរទៅផង, ម៉ោង ១៨ ដល់តំបន់សាលាស្រុកមួយឈ្មោះ
ញ៉ាងអ៊ូ ក្នុងខេត្តប៉ាកាន, ចក្កនាវក៏ត្រូវចតឈប់នៅទីនេះ ឃើញ
ក្រុមភ្នាក់ងារពេជគារ ទឹង ប្រជាជនជាច្រើនមកៈត្រៀមរង់ចាំទទួលនៅទីនេះ
ដែរ ។ ក្នុងពេលនោះគេរៀបកន្ទេលប្រគេនសម្តេចសង្ឃក្នុងនាវនោះ ឯព្រះ
សង្ឃខ្លះទៀត គេនិមន្តឲ្យទៅសង្ឃនៅវត្តមួយឈ្មោះវិសុទ្ធារាម ចម្ងាយពី
ចំណតនាវឈប់ ប្រហែល ៣ គីឡូម៉ែត្រ ។

ថ្ងៃទី ២៦ ខែសីហា, ម៉ោង ៧, ៣០ គេយកវេយន្តតូចពិសេសមួយ
មកប្រើគេនសម្តេចគង់ ទឹងវេយន្តធំៗ ជាច្រើនសម្រាប់គណៈប្រតិភូ
ឯទៀត ឲ្យទៅមុន-អញ្ជើញទៅមើលព្រមទាំងនមស្ការចេតិយ ស្វេស័គុង,
ចេតិយសាញ្ជ, ចេតិយអនន្ត (ដែលបំប្រួញមកពីពាក្យថាអនន្តប្បញ្ញោ)
ទឹងចេតិយកុន្តោបល្លង, ចេតិយទាំងអស់នេះសុទ្ធតែជាចេតិយធំៗ, ក្នុង
ចេតិយនីមួយៗ មានយ៉ាដំបូលលយចេញ មានប្រវែងប្រហែល ១០០ម.
ជាផ្លូវសម្រាប់ឲ្យមនុស្សដើរចូលទៅបាន ។ ខាងក្នុងចេតិយនីមួយៗ មាន
ព្រះពុទ្ធរូបធំៗ ច្រើនឈរក៏មាន, គង់តែនព្រះក្នុងក៏មាន ។ លុះដើរ
មើល - នមស្ការចេតិយធំៗ ក្នុងតំបន់នេះរួចហើយក៏ត្រឡប់ទៅទទួលភត្ត
ថ្ងៃត្រង់នៅវត្តវិសុទ្ធាកម, ចំណែកខាងសម្តេចគេនិមន្តទៅទទួលភត្ត
ក្នុងនាវាដែលវិញ ។ ក្នុងថ្ងៃដដែល ម៉ោង ១៤ គណៈប្រតិភូទាំង
អស់ ដែលមានក្រុមការងារពាក់ព័ន្ធដំណើរផង, បានទៅនមស្ការ
ចេតិយធំៗ ក្នុងព្រះរាជវាំងចាស់ ដែលបិតនៅក្នុងតំបន់ប៉ាកានដែរ ។
ក្នុងទីនោះឃើញចេតិយធំតូចច្រើនដេរជាស រាប់រយរាប់ពាន់, ចេញ
ពីទីនោះបានចូលទៅមើលរោងហត្ថកម្មរបស់ជាងភ្លុច ។ ក្នុងរោងនោះ
ឃើញពួកកម្មករអង្គុយដង្កៀតគ្នាជាដួរ, មុនដំបូង ខ្ញុំយកបន្ទោះប្លុស្ស
ដែលបិតសម្រាំងហើយគ្រាញតម្លើងជាប្រអប់មួល ប្តូបួនជ្រុងធំតូច
មានគ្រប់ មានថតសម្រាប់ដាក់ស្វាយ៉ាក៏មាន, ជាចានធំតូចក៏មាន,
ជាចានស្លាក់មានដែសម្រាប់យួរក៏មាន ។ ល ។ ខ្ញុំទទួលយកទៅ

ទុកដោយម៉ែក្សណ៍, ខ្ញុះទទួលយកទៅត្រឡឹងខាត់, ខ្ញុះទទួលយក
ទៅធ្វាក់ជារូបក្បាច់ផ្កាក្តីផ្សេងៗ, ខ្ញុះទទួលយកទៅជាត់ថ្នាំពណ៌ផ្សេងៗ,
ខ្ញុះទទួលយកទៅខាត់សម្រេច ។ បេះដែលធ្វើរួចហើយ គេយកទៅ
ជាក់តាំងតម្រៀបគ្នាសម្រាប់លក់ ។ លុះដល់វេលាល្ងាច គណៈ
ប្រតិភូទាំងអស់ក៏ត្រឡប់មកស្នាក់ទៅកន្លែងដើមវិញ ។ ក្នុងពេលនោះ
ប្រហែលម៉ោង ១៩ ក្រុមគ្រូអាចារ្យការនីនីប្រជាជនព្រមទាំងព្រះសង្ឃ
ភូមាជាច្រើន ចាន់និមន្តសម្តេចនីនីប្រតិភូប្រទេសឯទៀតសុំឲ្យថ្លែងការណ៍
ខ្លីៗ នៅក្នុងសុគោនប្បវេតិយ ។

## ជំណើរទស្សនាការទេសភាពនៃប្រទេសភូមា

ថ្ងៃទី ១៧ ឧសភា ១៩៥៨, ម៉ោង ៨ គណៈប្រតិភូទាំងអស់ ក៏ចាន
ចេញដំណើរពីស្រុកញ៉ាងអ៊ូ ដោយមគ្គុទ្ទាក់ជដែលតាមទន្លេឥរាវតី ឆ្ពោះ
ទៅកាន់ស្ថានីយអាកាសយាន ត្រង់កន្លែងដែលគេដឹកអណ្តូងយកប្រេង
សាំងប្រេងកាតដែលបិតនៅក្នុងតំបន់ឈ្មោះឡានីញ ។ ខណៈនោះគណៈ
ប្រតិភូខ្លះ ចាន់ឡើងយន្តហោះមួយឆ្ពោះចេញមុនគេ ។
ម៉ោង ១៤, ៣០ ដល់ស្ថានីយអាកាសយានមង្គលដូន សម្តេចនិមន្តចុះពី
អាកាសយាន ហើយគង់រថយន្តឆ្ពោះមកកាន់មហាកុដជិតមហាចាសាណ-
គុហា (មន្ទីរសង្គាយនា) វិញ ដែលគេរៀបចំមុងទុកប្រគេនពីថ្ងៃមុន ។
ក្នុងថ្ងៃដដែលម៉ោង ១៦, ៣០ យើងត្រៀបសម្តេច ចាន់ចូលទៅក្នុង

រ៉ឺគ្លីនដោយរថយន្តរបស់ពុទ្ធសាសនសិកា, គេនាំយើងទៅមើលភេន
ឧស្សាហកម្មជាច្រើនកន្លែងទៀតគឺ ភេនចក្រធ្វើប្រដាប់ប្រើប្រាស់ដូច
ចានស្រាក់, ឆ្នាំងយួរ ។ល។ ធ្វើដោយដែកអាលុយម៉ូម, ភេនជាង
ធ្នាក់ព្រះពុទ្ធរូបឬតែវនឹងថ្មើម្ច, ភេនជាងសិតឬស្មូនធ្វើព្រះពុទ្ធរូប,
ធ្វើឆ្លុតត្បូតរបនាជាក្បាច់ក្បឿផ្សេងៗ យ៉ាងល្អសម្រាប់ជាគំពូលចេតិយ, ធ្វើ
តង់រាំងបួងធំតូច ទឹងរបស់ប្រើប្រាស់ផ្សេងទៀតជាច្រើនប្រភេទ, ភេន
ជាងដេរកាត់ស្បែកដើង ។ល។ ក្នុងទីផ្សារ៉ឺគ្លីនទាំងមូល យើញច្រើន
តែប្រជាជនជាតិកូមាតាំងរបស់លក់ដេរដាសនៅតាមស្លែងផ្លូវ, ក្រៅ
ពីជាតិកូមា មានជាតិឥណ្ឌានឹងជាតិអង់គ្លេសលាយមួយ។ ឯជាតិចិន
យើញមានបន្តិចបន្តួចស្ទើរតែរាប់ថាមានពុំបាន, ចេញឆុតពីទីផ្សារបន្តិច
មក យើញរូបអនុស្សាវរីយមួយខ្នាតត្រដែតធ្វើដោយស៊ីម៉ងត៍ សសរ
មូលកំពស់ ៦ម. មានរូបភាពលោកសង្ឃមួយអង្គឃ្លុំចីវរឈរពីខាងលើ,
បានសាកសួរលោកដែលនៅប្រទេសកូមា លោកប្រាប់ថា រូបឧទ្ទុះគឺរូប
ព្រះថេរៈឈ្មោះ អ៊ូ វិបាវៈ ។ លោកនេះ ជាអ្នកប្រាជ្ញាក់ដុតខ្លាំ
ខាងអក្សរសាស្ត្រនឹងការសាសអង់គ្លេស តាមទាំងបេះព្រៃតែបិដកផង
លោកជាទីស្រឡាញ់រាប់អាននៃប្រជាជនកូមាស្ទើរតែទាំងអស់ ។ កាល
ពី គ.ស. ១៩៤២ កងទ័ពជប៉ុនចូលមកកាន់ប្រទេសកូមា, លោក
អ៊ូ វិចារៈ បាននាំប្រជាជនធ្វើបដិវត្តន៍តាមការយកឯកពីអង់គ្លេស

ប៉ុន្តែលោកនេះត្រូវអង់គ្លេសចាប់ជាក់គុកតាំងទៅបួសហើយលោកមិនត្រូវមានឱ្យលាន់អ្វីសោះដកឋដល់ក្រុយដីវិត ។ មួយទៀតលោកដដែលថាន ប្រាប់ថា មានឧបាសកអ្នកភជការម្នាក់ឈ្មោះ អ៊ាងសាំង ជាអ្នកស្នេហាជាតិប្រមែគំនិតគូដៃធ្វើបដិវត្តន៍ជាមួយទីឆ៍ះលោកអ៊ូវិចារៈ ។ លោកអោងសាំងនេះ ក៏ត្រូវអង់គ្លេសកេចាប់ដែរ ប៉ុន្តែបានគេចគៀសខ្លួនទៅទៅឯប្រទេសជប៉ុនដល់មក គ. ស. ១៩៤៥ កងទ័ពជប៉ុនមានជ័យជំនះលើកងទ័ពអង់គ្លេសក្នុងប្រទេសកូមា ហើយក៏ទៅនាំយកលោកអោងសាំង ពីប្រទេសជប៉ុនមកតាំងឲ្យធ្វើជានាយករដ្ឋមន្ត្រីខ្លួនឯកពាក្យប្រទេសកូមា, លោកអោងសាំងកាន់តែនាយករដ្ឋមន្ត្រីមិនបានយូរប៉ុន្មានក៏ត្រូវមនុស្សក្បត់ជាតិលប់ប្រហារលោកក្រុយដីវិតបង់ទៅ ។ កងសម័យដែលប្រទេសកូមាបានឯកពាក្យបរិបូណ៌ហើយគេថតពត្រឹកបូប លោកអោងសាំង ជាក់គ្រប់ក្រសួងពាណិជ្ជការទឹងស្ថានីយយន្តហោះ ដើម្បីខ្លួនក្លាអនុស្សាវរីយ ។

ថ្ងៃ ២៨ ឧសភា ១៩៥៤, ម៉ោង ១០ សម្តេចបាននិមន្តទៅខ្លួលកត្តនៅគេហដ្ឋាននៃលោកអ៊ូ· តាន់សេង លេខាធិការក្រសួងធម្មការមួយអន្ទើដោយព្រះសង្ឃប្រតិក្ខេបទៀត ។ មានក្រុមភ្នាក់ងារនគរបាលជំនះទោចក្រយានយន្តអមទាំមុខរថយន្តសម្តេច ជួនដំណើរតាំងទៅតាំងមក, កងថ្ងៃដដែល ម៉ោង ១៨, សម្តេចនិមន្តដោយរថយន្តរបស់ពុទ្ធសាសន-

សកា ទៅនមស្ការចេតិយធំ។ ក្នុងក្រែងរឆ្នុំន គឺចេតិយស្វេតាគុង, សូឡ, តោតាថោង ។ មុនដំបូង សម្តេចនិមន្តទៅតនមស្ការចេតិយស្វេតាគុង ឬហៅសិង្គត្តរចេតិយ ប៉ុន្តែពាក្យថា សិង្គុត្តរចេតិយនេះ ប្រជាជនភូមាទាំងអស់មិនសូវដែលហៅទេ ខ្លះក៏មិនស្គាល់ផង ឮហៅថាស្វេតាគុង។ច្រើនជាង ។ ចេតិយស្វេតាគុងនេះ ធំសម្បើមអស្ចារ្យណាស់ ទំហំខាងក្រោម ៥០០ម. គេរៀបក្លែមថ្មធ្វើជាជណ្តើរសម្រាប់ឡើង, ខាងលើជណ្តើរគេធ្វើជាដំបូលជាប់បន្តគ្នា មានកំពូលស្រួច។ ជង្រែគ្មានចន្លោះ ដោយក្បាច់ក្បូរផ្សែង។ តាំងពីខាងក្រោមឡើងទៅលើនឹងលានចេតិយខាងលើ ។ ជណ្តើរបែបនេះ មានគ្រប់ទិសទាំង ៤; ក្នុងជណ្តើរនីមួយៗ ប្រវែង ១៥០ ម. នៅអមសងខាងជណ្តើរឡើងទៅនីមួយៗ មានប្រជាជនភូមាទាំងស្រីប្រុសតាំងរបស់ជ្រើបាស់គ្រប់មុខសម្រាប់លក់ នឹងផ្កាផ្សែង។សម្រាប់លក់ឲ្យអ្នកបូលទៅទិញយកទៅបូជាព្រះពុទ្ធរូប, នៅវាលលានចេតិយខាងលើទំហំ ២០០ ម. គួចេតិយធំនៅចំកណ្តាល មានចេតិយតូច។ជាច្រើនតំកល់ព្រះពុទ្ធរូបថ្មកែវនៅព័ទ្ធជុំវិញចេតិយធំ, នៅជុំវិញចេតិយតូច។នេះ គេក្រាលសុទ្ធតែថ្មេមថ្មទំហំ ២០ ម. ជាទីតាសវាលសម្រាប់ដើរបាន, នៅជុំវិញទីវាលនេះ មានសាលាតូចធំជាច្រើនតំកល់ព្រះពុទ្ធរូបថ្មកែវខ្ចីឈរក៏មាន, ខ្ចីពែនព្រះភ្នែនក៏មាន, ខ្ចីដុំក៏មាន ។ នៅចេតិយស្វេតាគុងនេះមិនកំណត់ថាពេលណាជាពេល

ណាទេ តាំងពីថ្ងៃតាំងយប់ ឃើញប្រជាជនកូមាស្រីប្រុសក្មេងចាស់ ខ្ចីដំ
ណោកសង្ឃខ្លះបុះខ្លះទៀងបន្តគ្នា កាន់ផ្កាយកទៅបូជាព្រះបដិមាកន្លែងប
កន្ទែង, ត្រង់កន្ទែងបូជានីមួយៗ ឃើញសុទ្ធតែផ្កាឈើនឹងត្រួយពីង
ស្រស់ៗដោតសំពោងនៅទឹងផើងជាដួរ ។, នៅតាមកន្ទែងនីមួយៗ ឮស្ងួរ
តែសូត្រធម្មិទ្ធហឹងអឺងអាប់ ។ លំដាប់ពីនេះ សម្តេចនិមន្តទៅនមស្ការ
ចេតិយសូទ្បៃ ទឹងចេតិយពោតាថោងទៀត,ចេតិយតាំងពីរនេះកំពស់ណាស់
ដែរបន្ទាប់បន្សំទឹងចេតិយ ស្ទើតាគុង ឃើញតែប្រជាជនចុះទ្បើងយកផ្កា
ទៅបូជាថ្វាយបង្គំសូត្រធម្មិជាធម្មតាដូចគ្នា ។ រួចកិច្ចនមស្ការគេតចេតិយ
តាំងអស់នេះហើយសម្តេចក៏និមន្តត្រឡប់មកគង់នៅកន្ទែងដើមវិញ ។ ក្នុង
ពេលទុកាសពីការចូលប្រជុំធ្វើសង្គាយនាមុនៗ យើងបានដំរះថយន្តពុទ្ធិក-
សមាគមជាមួយនឹងលោកកូមាចូលទៅក្នុងទីក្រែងរ៉ែន ស្ទើតែសព្វកន្ទែង,
បានសង្កេតមើលប្រជាជនកូមាលក់របស់ផ្សេង ។ នៅតាមផ្លូវ ខាងក្រៅ
ក្រែងក្តី ខាងក្នុងក្រែងក្តី ដូចជានៅទីកោជនីយដ្ឋានជាដើម មិនឃើញ
មានលក់សុកនឹងអ្នកផឹកសុកទេ, ទើបសួរលោកកូមា លោកប្រាប់ថា
នៅប្រទេសកូមាតាំងមូលគ្មានផ្ទះធ្វើសុកទេ កាលពីដើមមានដែរ ប៉ុន្តែ
រដ្ឋាភិបាលសព្វថ្ងៃបានតាំងច្បាប់បញ្ជត្តហាមដោយដាច់ខាត មិនឲ្យ
ប្រជាជនណាមួយធ្វើសុកផឹកឬលក់ក្នុងប្រទេសកូមាឡើយ សូម្បីទៅទិញ
ពីញាំយកពីប្រទេសក្រៅមកលក់ក្នុងប្រទេសកូមាក៏ពុំបានដែរ ។ មួយ

ទៀតលោកនិយាយថា គោនឹងក្របីសត្វទាំងពីរពួកនេះកំរដ្ឋកិច្ចលំបាន តាំងច្បាប់បញ្ញត្តដល់ប្រជាជន មិនឲ្យសម្លាប់យកសាច់ធ្វើជាអាហារឡើយ សូម្បីគោក្របីនោះចាស់ជរាប្រឹការមិនកើតក៏ដោយ ព្រោះគេយល់ឃើញថា សត្វទាំងនេះជាពាហនៈដ៏សំខាន់សម្រាប់ច្រើបាស់កំសត់កម្រៃរបស់មនុស្សបានជាក្នុងប្រទេសកូមា គេបង្កើតសមាគមជាច្រើនកន្លែងសម្រាប់ទទួលចិញ្ចឹមគោក្របីចាស់ ។ ដែលផុតការប្រើហើយ ប្តូអ្នកណាមួយមានគោក្របីចាស់ជរាប្រឹការមិនកើតហើយពិបាកចិញ្ចឹម អាចនាំយកគោក្របីចាស់នោះទៅប្រគល់ឲ្យប្តូលក់ឲ្យក្រុមសមាគមនោះក៏បាន, ឯក្រុមសមាគមចិញ្ចឹមគោក្របីចាស់ នោះ គេទទួលចិញ្ចឹមដរាបដល់គោក្របីនោះអស់ជីវិតស្លាប់ឯង ។ ប្រយោជន៍ដែលបានសមាគមនោះតែស្បែកប៉ុណ្ណោះ ឯសាច់ត្រូវតែកប់ចោលជាដរាប ។ ត្រង់នេះគួរឲ្យសរសើរវដ្ឋកិច្ចប្រទេសកូមា ដែលចេះចាត់ការបំបាត់មុខសុភនិច្ឆាបញ្ញត្តិមិនឲ្យសម្លាប់គោក្របីយកសាច់ធ្វើជាអាហារ, ការនេះសមជាប្រទេសអ្នកកាន់ព្រះពុទ្ធសាសនាមែន ។ ប្រទេសកម្ពុជាគួរតែយកតម្រាប់ប្រទេសកូមាព្រោះជាប្រទេសកាន់ពុទ្ធសាសនាដូចគ្នា ! ។

## បព្វជិតនៅប្រទេសភូមា

នៅប្រទេសកូមា បែកខាងពុទ្ធសាសនាមានវត្តប្រហែល ២ ម៉ឺនវត្ត មានលោកសង្ឃទាំងភិក្ខុទាំងសាមណេរប្រហែល ៥ ម៉ឺនរូប(១) ។

---

១ វត្តខ្លះមួយៗ មានព្រះសង្ឃតែមិនស្មើរប្រើនអ្វីបងាប្រទេសខ្មែរទេ ។

កិក្ខុសាមណេរនៅប្រទេសកូមា ប្រើពណ៌ចីវរត្រូវគ្នាទាំងអស់ គឺចីវរ ប្រើតែចីវរបញ្ចវិណ្ណ (ចីវរមានវិណ្ណ ប្លែកដាំងក្នុងវិណ្ណនីមួយៗ មាន ក្បែងពីរ) ឯសង្ឃាដិ មានវិណ្ណ ៥ មានក្បែង ១០ ដូច គ្នានឹងចីវរដែរ, ចំណែកឧត្តរាសង្គដិប្រើពីរដាន់ដូចគ្នា, ពណ៌ចីវរ ទាំងអស់នោះជ្រលក់ទឹកអម្ចត់ឡើងពណ៌ក្រហមជាំ ស្រស់ល្អ មិនមែនដូច ពណ៌ជ្រលក់លំក្តេ សូម្បីសំពត់ងូតសម្រាប់ស្រង់ទឹកក៏សុទ្ធតែជ្រលក់ ទឹកអម្ចត់ដែរ ។

នៅតាមវត្តនីមួយៗក្នុងប្រទេសកូមា មានសាលាបង្រៀនបាលី ស្ទើរតែគ្រប់វត្ត ទោះបីវត្តណាមិនទាន់មានសាលាបង្រៀន ក៏គង់ធ្វើកិក្ខុសា-មណេរដែលបួសហើយចេញទៅរកវត្តណាមួយដែលមាននៅជិត ខាងតុំខាន តុំស្ងប់ទៅទំនេរ, ដោយហេតុនេះ បានជាប្រទេសកូមាសម្បូរ បព្វជិតជាពហុស្សុតអ្នកចេះបាលីណាស់ ។ ក្នុងសាលារៀនមួយៗ ដែលមាននៅតាមវត្តទាំងប៉ុន្មាន ក៏មានការប្រឡងតាមលំដាប់ថ្នាក់ លំដាប់ឆ្នាំ. បានសញ្ញាបត្រដូចជាកិក្ខុសាមណេរៀនបាលីនៅប្រទេស កម្ពុជាយើងដែរ ។ មានសាលាជាន់ខ្ពស់មួយទៀតហៅថា សាលាធម្មទូត ឬមហាវិទ្យាល័យ ដែលពុជការទើបនឹងបង្កើតឡើង, សាលានេះក្នុងមួយ ឆ្នាំៗ ពុជការត្រូវជ្រើសរើសយកកិក្ខុសាមណេរដែលសិក្សាសាលាបាលី

នៅតាមវត្តនីមួយ ។ មានសញ្ញាចំត្រង់ជាគ្រឿងសំគាល់ហើយ ទើបឲ្យ ចូលរៀនក្នុងសាលាធម្មទូតមានកំណត់ឆ្នាំតទៅទៀត ។

## ពួកសីលវតីនៅប្រទេសភូមា

ពួកស្ត្រីអ្នករក្សាសីល (ដែលទុកដូចជាអ្នកបួស) នៅប្រទេសភូមា មាន ៣ ប្រភេទគឺ មួយប្រភេទរក្សាសីល ៥ មានសម្លៀកបំពាក់ពែបពណ៌ ខ្មៅ១, មួយប្រភេទរក្សាសីល ៨ មានសម្លៀកបំពាក់ពែបពណ៌ផ្កាឈូក, មួយប្រភេទទៀតរក្សាសីល ១០ ដែលហៅថា អតិរេកសីលសម្រាប់ គ្រហស្ថ, សុទ្ធតែប្រើសម្លៀកបំពាក់ពណ៌ផ្កាឈូកដែរ, ខ្ញុំបានសួរគេ។ ថ្លាប់ថា ដែលក់ដោយគ្រាប់ដូម្បីឲ្យមានពណ៌អម្ចត់ប៉ុន្តែផ្សេងពីពែពណ៌ ក្រៃចីវរព្រះសង្ឃ ។ ស្ត្រីទាំងបីប្រភេទនេះ គេហៅថា សីលវតី ប្រែថា "ស្ត្រីអ្នកមានសីល" ឬហៅថា អគារិកា ប្រែថា "ស្ត្រីអ្នកគ្មាន ផ្ទះសម្បែង" ។ ពួកសីលវតីនេះមានច្រើនណាស់ក្នុងប្រទេសភូមា, ឃើញមាននៅតែជោយវត្ត។, វត្តខ្លះមានសីលវតីនៅ ៣០ នាក់, ៥០ នាក់, ១០០ នាក់ក៏មាន ច្រើនជាងនេះក៏មាន តាមវត្តធំតូច ។ វត្ត ណាដែលមានពួកសីលវតីនៅហើយ វត្តនោះឥតមានកិកុសាមណេរនៅ ច្បូកច្បាស់ទេ, ពួកសីលវតីដែលមាននៅក្នុងវត្តនីមួយ។ ខ្លះរៀន កម្មដ្ឋាន, ខ្លះរៀនបាលី ព្រោះហេតុនោះបានជាមានពួកសីលវតីជាច្រើន ចេះនិយាយបាលី, ចេះព្រះអភិធម្ម, ធ្វើជាធម្មកថិកា អ្នកសំដែងធម៌, បង្រៀនធម៌អាចិដល់គ្នាខ្លួនឯង ។

# ដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ

ថ្ងៃទី ២៩ ឧសភា ១៩៥៤ សម្តេចនឹងប្រតិភូខ្មែរត្រៀមធ្វើដំណើរត្រឡប់មកប្រទេសកម្ពុជាវិញ ។ ម៉ោង ១៧.៣០ ចេញពីមហាកុដិ (កន្លែងសំណាក់ធ្វើសន្និសីទ) ដោយមានក្រុមនគរបាលជំនាញគ្រប់យានយន្តនឹងក្នាក់ងារពាក់ព័ន្ធជាច្រើន មានលោកវរសេនាធិការគ្រួសួងធម្មការជាដើមជូនដំណើរដោយដល់ស្ថានីយអាកាសយានមង្គលៈដូន ។ ម៉ោង ២០ សម្តេចនឹងប្រតិភូចាំងអស់ឡើងអាកាសយាន (Thai airivays) ត្រលប់មកប្រទេសថៃ ។ ម៉ោង ២២,៣០ ដល់ស្ថានីយអាកាសយានដនមឿងក្រុងបាងកក, ចេញពីដនមឿងដោយរថយន្តត្រលប់ទៅវត្តចាងហ្វាងទិតក្រុងបាងកក, ឈប់សម្រាកនៅវត្តនោះអស់រាង ៩ ថ្ងៃ ។

ក្នុងរាង ប៉ុន្មានថ្ងៃ ដែលឈប់សម្រាកក្នុងក្រុងបាងកកនោះ ពួកព្នុទ្ធបរិស័ទចាំងបព្វជិតចាំងគ្រហស្ថជាតិខ្មែរខ្លះ ថៃខ្លះ បានចូលទៅថ្វាយបង្គំគាល់សម្តេចពុំសូវមានពេលស្រាក ។ ចៅឃុនព្រះទេពវេទី (ពាជាគណៈ) វត្តសាមផ្សា (សាមព្រះយា) ក្រុងបាងកក បាននិមន្តសម្តេចទៅថ្ងៃឆការណ៍អប់រំព្រះសង្ឃថៃចំនួន ៧៩៦ អង្គ ដែលនៅក្នុងក្រុងខ្លះមកពីខេត្តក្រៅខ្លះ ប្រជុំគ្នាក្នុងសាលាវត្តសាមផ្សា ។ សម្តេចបានទទួលនិមន្តទៅថ្ងៃឆការណ៍អប់រំជាភាសាថៃចំពោះព្រះសង្ឃចាំងនោះអស់រាៈពីរលើក ។

នៅទីបំផុតបង់សេចក្តីថ្លែងការណ៍អប់រំរបស់សម្តេចហើយ ទើបលោកយុនព្រះទេពវេទី ឡើងថ្លែងសេចក្តីប្រកាសប្រាប់ព្រះសង្ឃថៃថាំងអស់ថា សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយប្រទេសកម្ពុជា អង្គនេះជាអ្នកប្រាជ្ញមានកិត្តិស័ព្ទខ្ចរខ្ចាយក្នុងលោក, ដែលសម្តេចថ្លែងការណ៍អម្បាញ់មិញនេះដោយយោបល់ត្រូវល្អណាស់ គួរយើងដឿស្តាប់ហើយគោរពប្រតិបត្តិតាមកុំគប្បីក្រេចក្រោយ តទៅអនាគត ។ ថ្ងៃបន្ទាប់មក, លេខាធិការទី ១ នៃស្ថានទូតកូមានៅប្រចាំប្រទេសថៃក្រុងបាងកក បានទិមន្តសម្តេចនឹងព្រះសង្ឃខ្មែរ - លាវទៅទទួលភត្តនៅគេហដ្ឋានរបស់លោក ដើម្បីនឹងបានឧកាសប្រាស្រ័យសំដែងសេចក្តីគោរពតាមសមគួរដល់ការប្រាស្រ័យ ។

ថ្ងៃទី ៤ មិថុនា ១៩៥៤ សម្តេចនឹងគណៈប្រតិភូខ្មែរត្រូវធ្វើដំណើរចេញពីក្រុងបាងកកមកប្រទេសកម្ពុជាវិញ ។ គ្រានោះ ឯ. ឧ អគ្គរាជទូតខ្មែរ, ទូតកូមាដែលប្រចាំនៅប្រទេសថៃ, ព្រះសង្ឃជាតិខ្មែរ នឹងជាតិថៃ នឹងឧបាសកឧបាសិកាជាតិខ្មែរ-ថៃជាច្រើនបានជូនដំណើរដោយរថយន្ត មកកាន់ស្ថានីយអាកាសយានដ្ឋានមៀង ។ ម៉ោង ៨, ៣០ ឡើងអាកាសយាន ចេញឆ្ពោះមកក្រុងភ្នំពេញប្រទេសកម្ពុជា ។ ម៉ោង ១១, ៣០ យន្តហោះដល់ស្ថានីយអាកាសយានពោធិចិនតុង ។ កន្លងវេលាយន្តហោះបន្ទាប់ចុះដល់ផ្ទៃផែនដីឈប់នៅនឹងថ្កល់, ឃើញ

ពួកឥស្សរជនជាន់ធំព្រះសង្ឃភាំងគ្រហស្ថជាន្រ្តើនតាន់តាប់ មានសម្តេច
ព្រះធម្មលិខិតទុត្តមប្រិក្សា, ព្រះតេជព្រះគុណព្រះពោធិវង្សាចារ្យហ្វាង
សាលាចុលីជាន់ខ្ពស់, ឯកទុត្តមរដ្ឋមន្ត្រីក្រសួងធម្មការនិងរោងសាការ,
ឯកទុត្តមប្រធានពុទ្ធិកសមាគមកម្ពុជវង្ស, លោកប្រធានសមាគមមិត្ត
សាលាចុលី, ព្រះសង្ឃថេរានុត្ថេរៈ តំណាងសាមណេរនិងគហបតីជាន្រ្តើន
ជាន្រ្តើន មួយអន្ទើរដោយក្រុមសមាជិកនៃពុទ្ធិកសមាគមនិងសមាគមមិត្ត
សាលាចុលីព្រមទាំងនារីរាំមួយក្រុមផង ត្រៀមរង់ចាំទទួលដំណើរ
សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ដែលទើបត្រឡប់មកដល់
ពីប្រទេសកូមា, ដោយមានរបៀបរៀបរយជាដួរជាសង្កាត់គួរឲ្យរមិលមើល
គឺមាននារីរាំ ៤ នាក់ឈរកាន់ដើងគានប្រាក់ក្រវៀមាសពេញ
ដោយផ្កាគ្រប់ពណ៌ចាំបាច់ផ្កានាំមុខ ។ សម្តេចព្រះធម្មលិខិត, ព្រះ
តេជព្រះគុណព្រះពោធិវង្ស, ឯកទុត្តមរដ្ឋមន្ត្រី, ប្រធានសមាគមទាំងពីរ
ព្រមទាំងព្រះសង្ឃនិងអស់លោកធំៗ ជាន់ដំបូង បានឈរជង្គង់ក្រាបពីដណ្តើរ
អាកាសយានមក ។ ខណៈនោះ សម្តេចបានទទួលចុះចាកអាកាសយាន
ដោយព្រះហស្តបីគ្រឿងព្រះពុទ្ធរូបជាវិការៈនៃឈើម៉ៃសាក់ទឹបមាសមួយព្រះ
អង្គផង (ដែលបានមកពីប្រទេសកូមា) ។ លោកប្រធានសមាគមមិត្ត
សាលាចុលី បានទទួលព្រះពុទ្ធរូបអំពីព្រហស្តសម្តេច, ផ្ទាក់ផ្ទាក់ដើរ
ជាសលើផ្លូវដែលមានព្រះសង្ឃនិងគ្រហស្តឈរអម, សម្តេចនិមន្តដោយ

ដំណើរធម្មតា ។ មុននឹងឡើងរថយន្ត សម្តេចបានមានថេរដីកាទៅកាន់ពុទ្ធបរិស័ទដោយសេចក្តីខ្លីថា ខ្ញុំកុណា - អាត្មា មានសេចក្តីត្រេកអរជាអនេក ចំពោះសម្តេច, ឯកឧត្តម, អស់លោក-អ្នក ព្រះថេរានុត្ថេរៈ កិត្តិសាមណេរ ដែលបានមិទ្ធ - អញ្ជើញមកកាន់ការទទួលដំណើរនេះ, ខ្ញុំកុណា - អាត្មាសូមប្រគេន សូមជូនពរចំពោះសម្តេច, ឯកឧត្តម, អស់លោក-អ្នកនឹងព្រះថេរានុត្ថេរៈគ្រប់អង្គ សូមឲ្យបានបិតនៅក្នុងសុខ-ភាពនឹងវឌ្ឍនភាពតរៀងទៅ ។

លុះចប់សេចក្តីថ្លែងអំណរដោយសង្ខេបនេះ សម្តេចនិមន្តឡើងគង់រថយន្ត ទាំងពុទ្ធបរិស័ទគ្រប់រូបក៏ឡើងរថយន្តជូនដំណើរសម្តេចដរាបដល់វត្តទុណ្ណាលោម ។ នៅខាងមុខវិហារវត្តទុណ្ណាលោម, មានពុទ្ធបរិស័ទទាំងព្រះសង្ឃទាំងគ្រហស្ថជារាប់រយ ឈរតម្រៀបគ្នាជាពីរជួរតាំងពីក្បែងទ្វារកំពែងវត្តដរាបដល់ចាំពាំងកងកំពែងវិហារ ។ សម្តេចចុះពីរថយន្តនិមន្តតាមដំណើរធម្មតាចូលតង់កងចាំពាំងដែលគេតាក់តែងយ៉ាងស្អាតបំរុងទុក ។ ពុទ្ធបរិស័ទទាំងអស់ក៏នាំគ្នាចូលមកធ្វើគារវកិច្ចចំពោះសម្តេច។ ក៏មានថេរដីកាអំពីដំណើរទៅប្រទេសភូមាជាសេចក្តីខ្លី ។ តាមគួរដល់វេលាហើយ ពុទ្ធបរិស័ទទាំងអស់ក៏គ្រាចថ្វាយបង្គំលាចេញទៅកាន់លំនៅវិញរៀង។ ខ្លួន ។

---

# បញ្ជីភ្ជាប់ជាមួយនឹងសារដែលតាំងថ្មី

របស់គ្រូសូរិយធម្មការ

(តពីសៀវភៅលេខ ៥ ឆ្នាំ ១៩៥៣)

---

សញ្ញាប័ត្រលេខ ៩១១ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-ជាំង នាមនាយ ព្រហ្មជោត កើតឆ្នាំកុរ អាយុ ៧៤ វស្សា ៣៦ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១២ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ខៀវ-រ័យ នាមនាយ សុវណ្ណសរ កើតឆ្នាំខាល អាយុ ២៨ វស្សា ៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៣ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សៅរ៍-ឆេង នាមនាយ សុវណ្ណត្ថេរ កើតឆ្នាំមមី អាយុ ៣២ វស្សា ១៣ ជាចៅអធិការ វត្តអង្គភ្លាវ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៤ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ ណុប-មុត នាមនាយ ចន្ទត្ថេរ កើតឆ្នាំច អាយុ ២៨ វស្សា ៩ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៥ ចុះកាលបរិច្ឆេទដដែល តាំងលោកគ្រូ សុខ-គាំ នាមនាយ ចន្ទត្ថេរ កើតឆ្នាំរោង អាយុ ២៦ វស្សា ៣ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៦ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-សាយ នាមឆាយា សុវណ្ណកេសរ កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២៣ ជាចៅអធិការវត្តអង្គតាពៅ ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៧ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សោម-កណ្តៀង នាមឆាយា ជោតរង្សី កើតឆ្នាំមមី អាយុ ៣២ វស្សា ១១ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៨ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ កង-ម៉ុល នាមឆាយា សុវណ្ណរង្សី កើតឆ្នាំម្សាញ់ អាយុ ២១ វស្សា ២ ជាគ្រូសូត្រឆ្វេង វត្ត ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩១៩ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុក ជា នាមឆាយា សុវណ្ណបញ្ញា កើតឆ្នាំមមែ អាយុ ៤៣ វស្សា ២៣ ជាចៅអធិការ វត្តបទុមសុរិយា ឃុំ-ស្រុក-ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២០ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ សុិន-ង៉ិន នាមឆាយា សុជម្ចសរ កើតឆ្នាំកេ អាយុ ៤២ វស្សា ២០ ជាគ្រូសូត្រស្តាំ វត្ត-ឃុំ ស្រុក ខេត្តដដែល ។

សញ្ញាប័ត្រលេខ ៩២១ ចុះគាលបរិច្ឆេទដដែល តាំងលោកគ្រូ ខេត-ជា នាមឆាយា ឥន្ទ្រជោត កើតឆ្នាំរោង អាយុ ៣៤ វស្សា ១៤ ជាគ្រូសូត្រឆ្វេង វត្ត-ឃុំ-ស្រុក-ខេត្តដដែល ។ (មានត)